រដ្ឋបាលសុរិយោដីអាចចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ វិញ្ញាបនប័ត្របញ្ជាក់ហ៊ីប៉ូតែក សលាកប័ត្រពត៌មាននិងលិខិតបញ្ជាក់សុរិយោដី អំពីប្រភេទ ស្ថានភាពគតិយុត្តិ លក្ខណៈរូបនិងបន្ទុកនៃក្បាលដី ដោយផ្អែកលើឯកសារនិងសៀវភៅគោលបញ្ជីដី ។

មាត្រា ២៤២.-

វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុត្រូវចេញឱ្យចំពោះតែកម្មសិទ្ធិករឬអ្នកមានសិទ្ធិស្របច្បាប់លើអចលនវត្ថុនោះតែប៉ុណ្ណោះ ។

មាត្រា ២៤៣.-

សលាកប័ត្រពត៌មានសុរិយោដីអាចត្រូវបានផ្តល់ឱ្យជនដែលបានស្នើសុំ ។ ភ្នាក់ងារដែលបានផ្តល់ពត៌មាននេះត្រូវទទួលខុសត្រូវចំពោះការផ្តល់ពត៌មានមិនត្រឹមត្រូវដល់អ្នកស្នើសុំ ។ ពត៌មានដែលផ្តល់ឱ្យមិននាំឱ្យជាប់ការទទួលខុសត្រូវដល់រដ្ឋបាលសុរិយោដីទេ ។

មាត្រា ២៤៤.-

លិខិតបញ្ជាក់សុរិយោដីគឺជាមូលដ្ឋាននៃការអះអាងជាផ្លូវការមួយនៃលិខិតគតិយុត្តិ ។

កម្មសិទ្ធិអចលនវត្ថុកើតឡើងដោយលិខិតលក់ អោយ ផ្សរឬដំរះមរតក ដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមានទីតិសម្បទាដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ ។ លិខិតទាំងនោះត្រូវតែតំកល់ទុកនៅរដ្ឋបាលសុរិយោដី ។

មាត្រា ២៤៥.-

លិខិតលក់ អោយ ផ្សរឬដំរះមរតកធ្វើឡើងជាឯកជនមិនអាចចុះបញ្ជីបានឡើយ ។ តតិយជនមិនអាចជំទាស់បាន លុះត្រាតែលិខិតនោះធ្វើឡើងតាមបែបបទដែលបានកំណត់ក្នុងមាត្រា ២៤៤ នៃច្បាប់នេះ ។

មាត្រា ២៤៦.-

ប្រសិនបើលិខិតលក់អោយផ្សរឬដំរះមរតក បានធ្វើឡើងតាមរូបមន្តយថាភូតដោយបុគ្គលដែលមានទីតិសម្បទា ប៉ុន្តែមិនបានចុះបញ្ជីនៅសុរិយោដីទេ លិខិតនោះនៅតែតតិយជនអាចជំទាស់បាន ហើយកម្មសិទ្ធិករនិងសិទ្ធិវន្តត្រូវទទួលខុសត្រូវដោយខ្លួនឯងក្នុងការខកខានចុះបញ្ជីនេះ ។

មាតិកាទី ៧
អំពីទោសប្បញ្ញត្តិ
ជំពូកទី ១៩
អំពីការប៉ះពាល់កម្មសិទ្ធិ

មាត្រា ២៤៧.-

រាល់ការប៉ះពាល់កម្មសិទ្ធិនិងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុអាចជាបទល្មើសព្រហ្មទណ្ឌអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ ហើយការខូចខាតទាំងឡាយដែលបណ្តាលមកពីអំពើនេះត្រូវដោះស្រាយដោយសំណងរដ្ឋប្បវេណី ។

មាត្រា ២៤៨.-

ត្រូវចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិនិងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុ ជាបទល្មើសព្រហ្មទ័ណ្ឌក្នុងន័យនៃច្បាប់នេះមាន :

-រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រំលោភកាន់កាប់អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់បំណ្ណចេញដោយរដ្ឋបាលសុរិយោដី

-រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រាភាំងអ្នកកាន់កាប់ដោយសន្តិភាពឬភោគីនៃទ្រព្យមួយនៅក្នុងតំបន់មិនទាន់មានបង់សុរិយោដី ដែលរបបកម្មសិទ្ធិមិនទាន់បានពង្រឹងជាស្ថាពរតាមបញ្ញត្តិនៃច្បាប់នេះ

-រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ឬមិនប្រក្រតីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនស្របតាមមាត្រា ១៧ មាត្រា ១៨ និងមាត្រា ១៩ នៃច្បាប់នេះ

-រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម ។

មាត្រា ២៤៩.-

ការប៉ះពាល់កម្មសិទ្ធិក្នុងន័យនៃមាត្រាខាងលើអាចជាទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬជាទង្វើរបស់សាមញ្ញជនដែលធ្វើដោយម្នាក់ឯង ឬដោយផ្សំគំនិតជាមួយភ្នាក់ងាររបស់អាជ្ញាធរ ។

មាត្រា ២៥០.-

មន្ត្រីឬអាជ្ញាធរមានសមត្ថកិច្ចដែលបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើអចលនវត្ថុត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសព្រហ្មទណ្ឌនិងសំណងរដ្ឋប្បវេណី ។

ផ្នែកទី ១ : អំពីការប៉ះពាល់កម្មសិទ្ធិសាធារណៈ ឬឯកជនដោយសាមញ្ញជន

អនុផ្នែកទី ១ : អំពីការប៉ះពាល់កម្មសិទ្ធិឯកជន

មាត្រា ២៥១.-

ជនណាដែលបានក្លែងបន្លំក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

មាត្រា ២៥២.-

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្មឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន) រៀល ដល់ ៣.០០០.០០០ (បីលាន) រៀល ឬ/និងដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦(ប្រាំមួយ) ខែ ។

មាត្រា ២៥៣.-

ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់ បានធ្វើប័ណ្ណឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល ឬ/និងដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២(ពីរ) ឆ្នាំ ដោយពុំទាន់គិតបញ្ចូលទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស ។

បន្ថែមលើទោសខាងលើ អ្នកប្រព្រឹត្តអំពើហិង្សាត្រូវទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះ ដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន ។

បើអំពើហិង្សាខាងលើត្រូវបានបញ្ជាពីជនដទៃទៀតក្រៅពីអ្នកបង្ក ហើយជនទោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានេះក៏ត្រូវទទួលការផ្តន្ទាទោសដូចអ្នកប្រព្រឹត្តអំពើហិង្សា..... ផ្ទាល់ដែរ ។

មាត្រា ២៥៤.-

គ្មានករណីណាមួយដែលអនុញ្ញាតឱ្យប្រើប្រាស់កម្លាំងឯកជន ដើម្បីធានាចំពោះការគោរពប័ណ្ណកម្មសិទ្ធិ ឬចំពោះការប្រតិបត្តិសេចក្តីសំរេចរបស់តុលាការក្នុងការបណ្តេញចេញ ឬក្នុងការបង្ក្រាប់ឱ្យចាកចេញបានឡើយ ។ ជនណាដែលប្រើកម្លាំងឯកជនក្នុងហេតុផលនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន) រៀល ដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២ (ពីរ) ឆ្នាំ ។

មាត្រា ២៥៥.-

ជនណាដែលបានលួចលាក់ឬលួចបញ្ជូនអចលនវត្ថុដែលមិនមែនជារបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣ (បី) ឆ្នាំ ដោយមិនគិតដល់ល្សនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន ។

មាត្រា ២៥៦.-

កម្មសិទ្ធិករណាដែលបានធ្វើការដាំដុះលើដីរបស់ខ្លួន ឬប្រគល់ដី ឬជួលដីឱ្យតតិ-យជនដាំដុះដោយចេតនាទ្រង់មុខដំណាំដែលច្បាប់ឬបទបញ្ជាហាមឃាត់ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល ដល់ ៤៥.០០០.០០០ (សែសិបប្រាំលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ជាធរមាន ។

មាត្រា ២៥៧.-

សហកម្មសិទ្ធិករអវិភាគដែលធ្វើឱ្យប៉ះពាល់ដល់ចំណែករួមជួចមានចែងក្នុងមាត្រា ១៨០ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀលដល់ ៩.០០០.០០០ (ប្រាំបួនលាន) រៀល ។ ក្នុងករណីមិនអាចចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ។

មាត្រា ២៥៨.-

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួមនៃសហកម្មសិទ្ធិខ្លួន ឬមិនគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈដូចមានចែងក្នុងមាត្រា ១៨៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន) រៀល ដល់ ៣.០០០.០០០ (បីលាន) រៀល ។

អនុផ្នែកទី ២ : អំពីការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ

មាត្រា ២៥៩.-

ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០(ហាសិបលាន) រៀល ឬ/និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

ចារីត្រូវមានកាតព្វកិច្ចចាកចេញពីទ្រព្យសម្បត្តិសាធារណៈនោះជាបន្ទាន់ ។ ចារីគ្មានសិទ្ធិទារកំរៃអំពីពលកម្មឬការរៀបចំដែលបានធ្វើលើទ្រព្យនោះឡើយ ។

ក្នុងករណីដែលអ្នកកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ មុនច្បាប់នេះចូលជាធរមាន ហើយមានឯកសារសំអាងនិងបញ្ជាក់ជាក់លាក់ថា ខ្លួនបានទិញពីជនណាម្នាក់អាចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តតាមវិធានច្បាប់ចំពោះបុគ្គលដែលបានលក់ទ្រព្យសម្បត្តិសាធារណៈនេះដោយខុសច្បាប់ និងដើម្បីជាប្រយោជន៍របស់ខ្លួនដែលបានរងគ្រោះដោយសារទង្វើនេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះនេះពុំមានសិទ្ធិកាន់កាប់បន្តលើទ្រព្យសម្បត្តិសាធារណៈបានឡើយ ។

មាត្រា ២៦០.-

ជនណាដែលបានលើកចេញ ឬរំកិលចេញ ឬបំផ្លាញចោលនូវបង្គោលស៊ីម៉ង់ត៍ដៅចំណុចឋានលេខានិងទីតាំងផ្ទាកសញ្ញាសុរិយោដី ត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច ។ ក្នុងករណីមិនរារាំងចាល់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន) រៀល ដល់ ៣.០០០.០០០ (បីលាន) ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែ ដោយមិនគិតដល់លុសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន ។

ផ្នែកទី ២ : អំពីការប៉ះពាល់កម្មសិទ្ធិសាធារណៈឬឯកជនដោយអាជ្ញាធររដ្ឋបាល

មាត្រា ២៦១.-

មន្ត្រីឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ជាក្តី ឬគ្មានបញ្ជាក្តី ដើម្បីដកហូតអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន) រៀល ដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

ចាត់ទុកជាការរំលោភមាន ការក្លែងបន្លំ ការកសាងប័ណ្ណដោយបំពាន ការកៀបសង្កត់ឬវិធានការសម្ភារៈ ដើម្បីបណ្តេញចេញធ្វើឡើងចំពោះអ្នកកាន់កាប់អចលនវត្ថុ ។

បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សា ចាវីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២ (ពីរ) ឆ្នាំ ថែមទៀត ។

អ្នកបញ្ជាដោយរំលោភត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តផ្ទាល់ដែរ ។

មាត្រា ២៦២.-

អាជ្ញាធរមានសមត្ថកិច្ចឬកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានរំលោភយកទ្រព្យជាអចលនវត្ថុក្នុងមណ្ឌលដែលខ្លួនមានភារកិច្ចការពារសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខមកធ្វើជារបស់ខ្លួន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៣.-

អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិករ របស់ភោគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៤.-

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

រាប់ចូលជាការរំលោភ ការផ្តល់ទិន្នន័យជាផ្លូវការខុស ការចេញប័ណ្ណកម្មសិទ្ធិខុស ការបិទបាំងហ៊ីប៉ូតែកឬបន្ទុកផ្សេងៗ ការចោះគោលព្រំដីខុសដោយចេតនានិងរាល់ការធ្វេសប្រហែសក្នុងការធ្វើលេខាចារិកលើឯកសារសុរិយោដី ។

មាត្រា ២៦៥.-

រាល់ការប៉ះពាល់ធ្វើឡើងដោយប្រឆាំងនឹងសិទ្ធិលើដីរបស់សហគមន៍ជនជាតិដើមភាគតិចដោយអាជ្ញាធរដែលទទួលខុសត្រូវគ្រប់គ្រងតំបន់ដែលអចលនវត្ថុនោះតាំងនៅត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់ ៩.០០០.០០០ (ប្រាំបួនលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៦.-

ការប៉ះពាល់អចលនវត្ថុរបស់វត្ត ដោយបុគ្គលដែលទទួលបន្ទុកគ្រប់គ្រងត្រូវបង្ខំឱ្យសងទ្រព្យនោះវិញ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំ-សែន) រៀល ដល់ ៩.០០០.០០០ (ប្រាំបួនលាន) រៀល ។

មាតិកាទី ៨

អវសានប្បញ្ញត្តិ

មាត្រា ២៦៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៦៨.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្ហិនូវតាមរាជ

សូមឱ្យព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ហត្ថលេខា

អ៊ឹម ឈុនលឹម

លេខ: ១៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា

សង្ខារនុក្រម

LEXIQUE

ក . ខ . គ

កម្មសិទ្ធិ (Propriété) : សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ ។ សិទ្ធិនេះរួមបញ្ចូលទាំង សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យ ។

កម្មសិទ្ធិករ(Propriétaire) : ម្ចាស់កម្មសិទ្ធិលើទ្រព្យ និងមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យដែលជារបស់ខ្លួន ។

កតិការភេទ (Rescision) : កិរិយាបដិសេធកិច្ចសន្យាណាមួយ ដោយមកពីកិច្ចសន្យានោះ មានវិការៈដល់ឬសគល់នៃការព្រមព្រៀងគ្នា ។ ក្នុងទីនោះកតិការភេទ បានន័យថាបដិសេធកិច្ចសន្យាលក់ចោល ដោយមកពីលក់អចលនវត្ថុមានវិការៈអាថិកំបាំង ។

កាតព្វកិច្ច (Obligation) : ចំណងនៃសិទ្ធិ ដែលបង្ខំជនម្នាក់ឱ្យផ្ទេរកម្មសិទ្ធិ ឬសិទ្ធិណាមួយ ឱ្យបំពេញ នូវកិច្ចការណាមួយ ឬឱ្យឈប់បំពេញនូវកិច្ចការណាមួយ ដល់ជនម្នាក់ទៀត ។

ការជំរៈមរតក(Règlement des successions) : កិរិយាធ្វើបញ្ជីទ្រព្យសម្បត្តិរបស់ខ្មោច អោយដឹងថានៅសល់ប៉ុន្មាន បាត់ប៉ុន្មាន ដើម្បីនឹងចែកគ្នា រវាងទាយាទ និងទាយាទ ។

ការ្យ (Ouvrage) : ផលអ្វីទាំងពួង ដែលកើតមកពីស្នាដៃជាង ឬពីស្នាដៃសិល្បករ ។
<u>ឧទា</u> : តុ ទូ ជាការ្យរបស់ជាង ឯប្រលោមលោកជាការ្យរបស់អ្នកនិពន្ធ ។

កើយ (Balcon) : វានហាលតូចគ្មានសរសរទ្រពីក្រោមទេ តែមានបង្គាន់ដៃព័ទ្ធជុំវិញ ។

កូនបំណុល (Débiteur) : ជនជំពាក់ប្រាក់ ឬជំពាក់កាតព្វកិច្ចគេ ។

កំពែង (Clôture) : ស្តាមភ្លោះ របង ភ្លឺ ។

ច . ឆ . ដ

ចរន្តការ (Mise à jour) : ការកត់ត្រាទុកជាប្រចាំ ក្នុងឯកសារស៊ីវិយោដី នូវរាល់ការប្រែប្រួល ឬ ការផ្លាស់ប្តូរ ដោយយោងតាមឯកសារគតិយុត្ត ។

ចារី (Auteur) : អ្នកប្រព្រឹត្ត. អ្នកដែលធ្វើ ។

ច្បាប់ (Loi) : លិខិតបទដ្ឋានគតិយុត្តដែលអនុម័តដោយអង្គការនីតិបញ្ញត្តិ(សភា) និងចូលជាធរ-មានតាមរយៈព្រះរាជក្រមប្រកាសឱ្យប្រើ ។

ឆន្ទានុសិទ្ធិ (Pouvoir discrétionnaire) : អំណាចដែលប្រគល់ ដល់អាជ្ញាធរ អោយពិសេសកមធ្យោបាយណាមួយ តាមចិត្តខ្លួន មកដោះស្រាយបញ្ហាណាមួយ ។

ជនជាតិដើមភាគតិច (Indigène) : ជនជាតិខ្មែរដើម ។

ជ. ត . ថ . ឆ . ឆ . ទ

តតិយជន (Tiers, tierce) : ជនទីបី ឬភាគីទីបីក្នុងរឿង ។ អ្នកដទៃ ឬអ្នកក្រៅ ។ ឧទា : អ្នកលក់ និងអ្នកទិញ ជាភាគីទី ១ និងទី ២ ។ អ្នកផ្សេងទៀត ក្រៅពីអ្នកលក់ និងអ្នកទិញ ហៅថា តតិយជន ។

តីរហាន (Quai) : ការដែលបានកសាងនៅក្នុងកំពង់ផែ ឬលើច្រាំងទន្លេសំរាប់នាវាចូលចត សំរាប់អ្នកដំណើរឡើង-ចុះនាវា និងសំរាប់ដុកទំនិញ និងដាក់ទំនិញចុះ ។

តែងតាំង (Nommer) : អោយមុខការ អោយគុណភាព ផ្តល់ឋានន្តរទី ។ ឧទា : ឈ្មោះ " ក " បាន តែងតាំង ឈ្មោះ " ខ " ជាទាយាទរបស់ខ្លួន ។

ថ្លស់សិទ្ធិ (Déchéance du droit) : ការប្រាស់ចាកសិទ្ធិ-ការបាត់បង់សិទ្ធិដោយហេតុទណ្ឌកម្ម ឬដោយហេតុមិនបានបំពេញលក្ខខណ្ឌដែលច្បាប់ ឬកិច្ចសន្យាតម្រូវឱ្យបំពេញក្នុងរយៈពេល មានកំណត់ ។

ទាយាទ (Héritier) : អ្នកដែលច្បាប់តម្រូវអោយទទួលមរតកពីជនណាម្នាក់ ។
ឧទា : កូនជាទាយាទរបស់ឪពុក ម្តាយ ចៅជាទាយាទរបស់ជីដូន ជីតា ដែលឥតមានបច្ឆាញ្ញាតិជាតំណវង្ស ។

ធនលាភ (Rente) : ជលដែលផ្តល់មកអោយរាល់ឆ្នាំ ដូចជាការប្រាក់ ឈ្នួលដី ឈ្នួលផ្ទះជាដើម ។

ធម្មានុរូប (Légitime) : ដែលមានគុណភាពជាអ្វីមួយតាមច្បាប់ ។ ឧទា : ចៅហ្វាយស្រុកជាអាជ្ញាធរធម្មានុរូប ។ កូនដែលកើតពីឪពុកម្តាយមានខាន់ស្លា ហៅថាកូនធម្មានុរូប ឬកូនមានខាន់ស្លា ។

និទាយាទភាព(Déshérence) : ភាពឥតអ្នកត្រូវទទួលមរតក ។

និទ្ទេស (Mention) : សេចក្តីដែលចុះដោយសង្ខេប នៅលើរឹមទំព័រ ឬនៅខាងចុងទំព័រនៃលិខិតណាមួយ ។

និរាករណ៍ (Abrogation) : លប់ចោលលែងអោយប្រើច្បាប់នោះតទៅទៀត ។

នីត្យានុកូល (Légal) : ការកើតមកពីច្បាប់ ដែលច្បាប់តាក់តែងមក ។

នីតិបុគ្គល (Personne morale) : ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរ តែដាច់ទៃពី សមាជិកនៃខ្លួន ។
ឧទា : ពុទ្ធិកសមាគម ជានីតិបុគ្គល, ក្រុមហ៊ុនធ្វើស្តុរ ក៏ជា នីតិបុគ្គលដែរ ។

នីតិបុគ្គលនៃនីតិសាធារណៈ(Personne morale du droit public) : ក្រុមរាជការសាធារណៈ។ ឧទា : រដ្ឋ ខេត្ត ឃុំ ឬគ្រឹះស្ថានសាធារណៈ ដូចជា សកលវិទ្យាល័យជាដើម ។

នីតិបុគ្គលនៃនីតិឯកជន(Personne morale du droit privé) : សមាគម ក្រុមហ៊ុន ក្រុមមូលនិធិ ។

នីតិវិធី (Procédure) : វិធីដែលតុលាការប្រើប្រាស់ ដើម្បីចាត់ចែងរឿងក្តីតាំពីដើមរហូតដល់ចប់ ។

នីតិសម្បទា (Habilité) : សមត្ថភាពដែលច្បាប់បើកអោយជនម្នាក់ៗ មានយ៉ាងគ្រប់គ្រាន់ ដើម្បីធ្វើការអ្វីមួយ ។

៥ . ៥ . ៣ . ត . ៥

បទបញ្ជា (Règlement) : លិខិតបទដ្ឋានដែលចេញដោយអង្គការ ឬអាជ្ញាធរមានសមត្ថកិច្ច ។

បទប្បញ្ញត្តិ (Disposition) : សេចក្តីបញ្ជាតិរបស់ច្បាប់ ឬរបស់មាត្រាណាមួយនៃច្បាប់ ខសំខាន់របស់លិខិតក្នុងតុលាការ ។

បដិគាហក(Donataire) : អ្នកទទួលអំណោយ

បដិប្បញ្ញត្តិ (Dérogation) : ការតាំងបញ្ជាតិផ្ទុយ ឬ មិនស្រប ។

ប័ណ្ណ (Titre) : លិខិតដែលមានរូបមន្តយថាភូត (ដែលមានរូបភាព និងទម្រង់ ត្រឹមត្រូវតាមច្បាប់) សំរាប់បញ្ជាក់ពីសិទ្ធិណាមួយ ។

ប្លង់សុរិយោដី ឬផែនទីសុរិយោដី ឬប្លង់ក្បាលដី (Plan cadastral) : ប្លង់រួមនៃដីក្នុងតំបន់ណាមួយ ដែលមន្ត្រីជំនាញសុរិយោដីបានវាស់វែង គូរ បំពេញយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់ តាមបទដ្ឋានបច្ចេកទេស ហើយដាក់លេខក្បាលដី ឬដីឡូតិ៍យ៉ាងច្បាស់លាស់ ។

បន្ទុក, ភារៈ ឬ ធុរៈ (Charges) : មុខការ, មុខងារ, អណ្តាត្តិ, ប្រតិកម្មដែលជនណាម្នាក់ធ្វើ ឬបំពេញ ។

បាលិត (Pupille) : កូនកំព្រាជាអនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលនៃជនម្នាក់ ។

បុព្វសិទ្ធិ(Prérogative) : សិទ្ធិជាពិសេសដែលឱ្យដាច់ទៅលើមុខងារ ឬទៅលើក្រុមនីមួយៗ លើសពីអ្នក ដទៃ ។

បុរិមា(Préférence) : សិទ្ធិដែលបើកអោយជនណាម្នាក់ បានអ្វីមួយ មុនជនឯទៀត ។

បេតិកភណ្ឌ (Patrimoine) : ទ្រព្យដែលជនម្នាក់ៗមាន និងបំណុលដែលជនម្នាក់ៗជំពាក់គេ ។ ទាំងទ្រព្យ ទាំងបំណុលរបស់ជនម្នាក់ ៗ ហៅថា "បេតិកភណ្ឌ" ។

ប្រធានសក្តិ (Force majeure) : ព្រឹត្តិការណ៍ដែលកើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន ។

ប្រទានកម្ម (Donation) : ការអោយ-អំណោយ ។

ប្រាតិភោគភណ្ឌិក (Sûreté réelle) : ការយកទ្រព្យទៅធានាបំណុល ។ ឧទា : ការបញ្ចាំស្រែជា ប្រាតិភោគភណ្ឌិក អចលនវត្ថុ ។ ការបញ្ចាំខ្សែមាស ជាប្រាតិភោគភណ្ឌិកចលនវត្ថុ ។ (ក្រមរដ្ឋប្បវេណីចាស់ប្រើ ប្រាតិភោគប្រត្យក្ស)

ផលទុន (Revenu) : ផល ឬចំណេញ ដែលកើតមកពីប្រាក់ទុន ឬពីមូលនិធិ ដែលគេយកទៅប្រកបមុខរបរណាមួយ ។

ផលធម្មជាតិ (Fruit naturel) : ផលិតផល ដែលកើតអំពីដីធ្លី ឬកូនសត្វស្រុក ដែលកើតពីមេបាវា ។

ផលស៊ីវិល (Fruit civil) : ប្រាក់ ដែលបានមកពីវត្ថុ ឬពីប្រាក់ ដូចជា ការប្រាក់ ឬឈ្នួលផ្ទះជាដើម ។

ផលុបភោគ (Usufruit) : សិទ្ធិបរិភោគ និងប្រើប្រាស់ផល និងផលទុនដែលកើតមកពីទ្រព្យជាកម្មសិទ្ធិ របស់អ្នកដទៃ ។

ផលុបភោគី (Usufruitier) : អ្នកបាននូវផលុបភោគ អ្នកស៊ីផល ។

ព្យសនកម្ម (Préjudice) : ការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់រូបកាយក្តី ដល់សម្ភារៈក្តី ដល់ទឹក ចិត្តក្តី ដែលបណ្តាលមកពីអំពើរបស់អ្នកដទៃ ។

ព្រឹត្តិការណ៍ (Evènement) : អ្វីៗ ដែលកើតមានឡើង ឬដែលប្រព្រឹត្តទៅ ។

ភតិសន្យាបតី (Bailleur) : ម្ចាស់អចលនវត្ថុ ដែលដាក់អចលនវត្ថុ ជូលអោយអ្នកដទៃ ។

ភាគី(Partie) : គូក្តី គូសញ្ញា ជនម្ខាងៗ នៃកិច្ចសន្យា ។

ភោគៈ(Possession) : សិទ្ធិ ដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្តោះអាសន្ន មិនទាន់ស៊ប់ ជារបស់ខ្លួនមែនទែនទេ ។ "ភោគៈ" ជាពាក្យផ្ទុយនឹងកម្មសិទ្ធិ ដែលជាសិទ្ធិពេញបរិបូរណ៍របស់ជនម្នាក់ៗ លើទ្រព្យណាមួយ ឧទា: ដីមានប្លង់សុរិយោដី ជាដី កម្មសិទ្ធិ ឯដីមិនទាន់មានប្លង់សុរិយោដី គឺជា ដីភោគៈ ។

ភោគី (Possesseur) : អ្នកទទួលបានភោគៈ ។

មធ្យោបាយ (Moyen) : អ្វីដែលជាគ្រឿងសំរាប់យកទៅដោះស្រាយកិច្ចការ ឬបញ្ហាណាមួយ ។

មាតិកា (Titre) : មេសេចក្តី ដើមសេចក្តី ចំណែកធំៗ នៃច្បាប់ ។ អត្ថបទច្បាប់ ចែកចេញជាតន្តី តន្តីចែកជាមាតិកា មាតិកាចែកជាជំពូក ជំពូកនីមួយៗ ចែកចេញជាផ្នែក ។

យថាហេតុ (Eventualité) : ហេតុដែលពឹងផ្អែកទៅលើព្រឹត្តិការណ៍ណាមួយ គឺថា បើព្រឹត្តិការណ៍នោះ កើតឡើងយ៉ាងណា ហេតុនោះក៏ត្រូវធ្វើយ៉ាងនោះដែរ ។

យ៉ (Saillie) : ចំណែកផ្ទះ ដែលចេញពីជញ្ជាំងទៅខាងមុខ ។

រូបមន្ត (Formule) : ការងារ ដែលត្រូវបំពេញអោយមានរូបតាមច្បាប់កំណត់

រូបវន្តបុគ្គល (Personne physique) : បុគ្គលដែលមានរូបមែន។ គឺមនុស្សមែន។ ផ្ទុយនឹងនីតិបុគ្គល ដែលជាមនុស្ស ដោយសន្មតតាមរបៀបច្បាប់ ។

លេខាចារឹក (Inscription) : ការកត់ត្រា រឿងហេតុអ្វីមួយចូលក្នុងស្បៀវភៅ ឬបញ្ជី តាមរូបមន្ត ដែលបានកំណត់ ដើម្បីគ្រប់គ្រងអចលនវត្ថុ អោយបានត្រឹមត្រូវតាមច្បាប់ ។

លក្ខខណ្ឌ (Condition) : គុណភាពដែលត្រូវមាន ឬ ខដែលត្រូវបំពេញអោយគ្រប់ចំនួន ដើម្បីអោយបានសម្រេចបំណងណាមួយ ។

លក្ខណៈ (Caractère) : កិនភាគ ឬកពារ កិរិយា បែបទ ។

លទ្ធកម្ម (Acquisition) : ការបានឡើងជាកោតី ឬជាកម្មសិទ្ធិករនៃវត្ថុណាមួយ ដោយការងាររបស់ ខ្លួនក្តី ដោយទិញក្តី ដោយដូរក្តី ដោយសន្តតិកម្មក្តី ។

លិខិតយថាភូត(Acte authentique) : លិខិតធ្វើតាមរូបមន្តនៃច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម ។

វិធាន (Règle) : មូលសាស្ត្រ ច្បាប់ បន្ទាត់ ។

វិធានការ (Mesure) : មធ្យោបាយ សេចក្តីប្រយ័ត្ន របៀបចាត់ចែងឡើង ដើម្បីបង្ការ ឬទប់ទល់នឹងអ្វីមួយ ។

វិការៈអាថិកំបាំង(Vice caché) : គុណវិបត្តិ ឬការខូចខាតនៃវត្ថុអ្វីមួយ ដែលបានលក់ ហើយដែលគេពិនិត្យមើលលើកដំបូងទៅ គ្មានឃើញថាវត្ថុនោះខូចខាតទេ ប៉ុន្តែពេលយកវត្ថុនោះទៅប្រើប្រាស់ពុំកើតឡើយ ។

ស . ហ

សន្តតិកម្ម (Succession) : ការផ្ទេរតាមច្បាប់ នូវទ្រព្យរបស់អ្នកស្លាប់ អោយទៅអ្នករស់ ។ មតិក ឬ ទ្រព្យរបស់ខ្ទោច ដែលត្រូវបានទៅទាយ៉ាទ (អ្នកបន្តមតិក) ។

ស្បៀវភៅគោលបញ្ជីដី (Registre foncier) : បញ្ជីគោល សំរាប់កត់ត្រានូវខ្លឹមសារ នៃទិន្នន័យ ដែលបង្កើតជាស្ថានភាពនៃសិទ្ធិទាក់ទងទៅនឹងទ្រព្យណាមួយ ។ ទាក់ទងនឹង ស្ថានភាពនេះ ជាទូទៅត្រូវបានកាន់កាប់ និងធ្វើចរន្តការតាមលំដាប់ពេលវេលា ។

សំរង់សុរិយោដី (Relevé cadastral) : សេចក្តីដកស្រង់ នូវទិន្នន័យពាក់ព័ន្ធនឹងបច្ចេកទេស និង គតិយុត្ត ក្នុងវិស័យសុរិយោដី ពីស្ថានភាពជាក់ស្តែងលើដី យកមកកសាងជាឯកសារ សុរិយោដី ដើម្បីធានាសិទ្ធិស្របច្បាប់របស់កម្មសិទ្ធិករ ។

ទ្រព្យសម្បត្តិសាធារណៈ (Domaine public): ទ្រព្យ ដែលត្រូវរក្សាអោយគង់រូប តាមធម្មជាតិរបស់វា ដើម្បីទុកអោយអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅ ដូចជា : ស្ពាន ផ្លូវ ....។ល។ ទ្រព្យទាំងអស់នេះ ស្ថិតនៅជាប្រយោជន៍សាធារណៈ មិនអាចលក់ ដូរ និង គ្មានកំណត់អាជ្ញាយុកាល ទេ ។

ទ្រព្យសម្បត្តិឯកជន (Domaine privé) : ទ្រព្យរបស់សង្គម ដែលមិនសំរាប់ឱ្យជនក្នុងសង្គមនោះប្រើប្រាស់ជាសាធារណៈទូទៅទេ ជាសម្បត្តិដែលសង្គម អាចលក់ ដូរ ជួល ធ្វើអំណោយបាន ។

សម្បទាន (Concession) : អចលនវត្ថុ(ដីធ្លី)ដែលរដ្ឋផ្តល់អោយរូបវន្តបុគ្គល ឬនីតិបុគ្គល សំរាប់សង់លំនៅឋាន ឬ/និងបង្កបង្កើនផល ដោះស្រាយជីវភាពរស់នៅ ក្នុងទំហំដីតូច ពិសេសសំរាប់ប្រជាពលរដ្ឋក្រីក្រ (សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម) ឬសំរាប់ធ្វើការដាំដុះធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម ក្នុងទំហំដីធំទូលាយ ពិសេសសំរាប់អ្នកវិនិយោគទុន (សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច) តាមរយៈកិច្ចសន្យាផ្តល់សម្បទានដោយត្រូវបង់ប្រាក់ជូនរដ្ឋ ។

សម្បទានិក (Concessionnaire) : អ្នកទទួលបានសម្បទាន ។

សមាមាត្រ (Proportion) : ការ ឬរបស់អ្វីមួយដែលសម ដែលល្មមនឹងការ ឬនឹងរបស់មួយទៀត ។ ឧទា: ទណ្ឌកម្ម ដែលតុលាការបានផ្តន្ទានេះ មានសមាមាត្រនឹងអំពើ ដែលជននោះបានប្រព្រឹត្តហើយ គឺថាសមរម្យនឹងអំពើនោះហើយ ។

សមូហភាព (Collectivité) : ជនទាំងឡាយដែលមករួមគ្នាជាក្រុម ឬជាសម្ព័ន្ធមួយ ។ មនុស្សទាំងអស់ ក្នុងឃុំ ឬក្នុងស្រុក ឬក្នុងក្រុងណាមួយ ហៅថាសមូហភាព ។

សហកម្មសិទ្ធិ (Co-propriété) : កម្មសិទ្ធិតែមួយជារបស់ជនច្រើននាក់ ។ ឧទា : ជនច្រើននាក់រួបរួមគ្នាទិញ រថយន្តមួយ ។ រថយន្តនោះ ជាសហកម្មសិទ្ធិរបស់ជនទាំងឡាយ ដែលទិញនោះ ។

សហកម្មសិទ្ធិករ (Co-propriétaire) : អ្នកដែលមានសហកម្មសិទ្ធិ ។

សហគមន៍ (Communauté) : អ្វីៗ ដែលជនទាំងឡាយយកមករួមគ្នា ។ ទ្រព្យសហគមន៍ គឺទ្រព្យ ដែលប្តីប្រពន្ធរកបានជាមួយគ្នា ។

ចារី (Auteur) : អ្នកប្រព្រឹត្ត អ្នកដែដល់ ។

សហទាយាទ (Co-heritier) : អ្នក ដែលត្រូវចូលរួមក្នុងការចែកមរតកណាមួយ ។

សហព័ទ្ធ (Conjoint) : ប្តី ឬប្រពន្ធ ឬ ទាំងប្តី ទាំងប្រពន្ធ ។

ស្ថាពរ(Définitif) : មាំមួន, ជាប់រហូត ។ ឧទា :សាលក្រមជាស្ថាពរ គឺសាលក្រម ដែលកាត់សេចក្តីជាស្រេចដាច់ខាត មិនត្រូវរុះរើទៀតទេ គឺថា តូក្តីមិនអាចប្តឹងឧទ្ធរណ៍ ប្តឹងសារទុក្ខ បានឡើយ ។

សិទ្ធិវន្ត (Ayant-droit) : អ្នកមានសិទ្ធិលើវត្ថុណាមួយ ។

សេវភាព (servitude) : បន្ទុកដែលដុំកលើអចលនវត្ថុមួយ(ដីបំរើ ឬដីក្រោម) ដើម្បីជាប្រយោជន៍ដល់អចលនវត្ថុមួយទៀត (ដីប្រើ ឬដីលើ) ដែលជារបស់កម្មសិទ្ធិករផ្សេងទៀត ។
ឧទា : ស្រែក្រោម មានសេវភាពខាងទទួលទឹកពីស្រែលើ ។ ស្រែក្រោម ហៅថា ស្រែបំរើ ហើយស្រែលើ ហៅថាស្រែប្រើ ។

ហិតូបត្ថម្ភកៈ (Curateur) : ជន ដែលច្បាប់ចាត់អោយឃុំគ្រងទ្រព្យរបស់អនីតិជន ឬទ្រព្យរបស់ជន ល្ងីល្ងើ ជាដើម ។

ឣ

អចួយទាន (Legs) : សំបុត្របណ្តាំ ដែលផ្តាំអោយចែកទ្រព្យមរតកណាមួយ អោយទៅជនណាម្នាក់ ឬច្រើននាក់ ។

អឌ្ឍសិទ្ធិ (Mitoyen) : ដែលមានសិទ្ធិពាក់កណ្តាលម្នាក់ ដែលជារបស់ជនពីរនាក់ និងជាព្រំនៃកម្ម-សិទ្ធិនៃជនទាំងពីរនាក់នោះផង ។ ឧទា : ជញ្ជាំងអឌ្ឍសិទ្ធិ គឺជញ្ជាំងរបស់ជនពីរ នាក់ ដែលមានផ្ទះជាប់គ្នា ។

អឌ្ឍសិទ្ធិភាព (Mitoyenneté) : ភាពដែលជាអឌ្ឍសិទ្ធិ ។

អត្តសញ្ញាណ (Identité) : សញ្ញាទាំងអស់នៃជនម្នាក់ៗ ដែលជាគ្រឿងសំគាល់កុំអោយកាន់ច្រឡំ នឹងជនម្នាក់ទៀត ។

អត្តាធិនភាព (Emancipation) : ការបើកអោយក្លែង ដែលនៅក្នុងអនីតិភាពនៅឡើយ គ្រប់គ្រងខ្លួន និងទ្រព្យ សម្បត្តិខ្លួន ដោយខ្លួនឯង ។

អត្ថគាហកៈ (Bénéficiaire) : អ្នក ដែលបានចំណេញ ឬបានកំរៃពីវត្ថុណាមួយ ពីគុណប្រយោជន៍អ្វីមួយ ឬពី ឯកសិទ្ធិណាមួយ ។

អនុបយោគ (Désaffectation) : ការលែងប្រើតាមការចាត់ ការលុបនូវតម្យស្ថាន នៃ អគារសាធារណៈ ។ នៅទីនេះ ច្បាប់អនុបយោគ ជាច្បាប់ដែលរំសាយពីប្រភេទទ្រព្យសម្បត្តិមួយ ទៅប្រភេទទ្រព្យសម្បត្តិមួយទៀតដូចជារំសាយពីទ្រព្យសម្បត្តិសាធារណៈ មកជាសម្បត្តិឯកជនរបស់រដ្ឋ ជាដើម ។

អាណាព្យាបាល (Tuteur) : បុគ្គលដែលមានភារកិច្ចតំណាងឱ្យអនីតិជន ។

អវយវភេទ(Démembrement) : ការបាក់បែកអវយវៈ។ ក្នុងច្បាប់ អវយវភេទបានន័យថា ការផ្ទេរ សិទ្ធិខ្លះរបស់ខ្លួនលើកម្មសិទ្ធិណាមួយអោយទៅអ្នកដទៃ ។

អវិភាគកម្ម (Indivision) : ភាពដែលចែកគ្នាមិនបាន ។ ឧទាៈ ផ្ទះមួយ ជាមរតករបស់កូនប្រាំនាក់ ពុះផ្ទះនោះចែកគ្នា ផ្ទះនោះនឹងអន្តរាយជាមិនខាន ។ ដូច្នេះ ផ្ទះនោះជាមរតកអវិភាគ។

អសារ-កម្មសិទ្ធិ (Nue-propriété) : កម្មសិទ្ធិ ដែលឥតអោយផលដល់ម្ចាស់កម្មសិទ្ធិទេ ដោយហេតុ ថាម្ចាស់កម្មសិទ្ធិនោះអោយសិទ្ធិខ្លួនទៅអ្នកដទៃស៊ីផលនៃកម្មសិទ្ធិនោះទាំងអស់ ។

អាជ្ញាធរ (Autorité) : អ្នកទ្រទ្រង់អំណាច អ្នករាជការដែលកាន់អំណាច ។

អាជ្ញាយុកាល (Prescription) : មធ្យោបាយម្យ៉ាងសំរាប់ដោះខ្លួន អោយរួចផុតពីភាតព្វកិច្ចណាមួយ កាលណាបើម្ចាស់កាតព្វកិច្ចនោះបណ្តែតបណ្តោយអោយជំពាក់យូរពេកមិនទារ ។

ឧបាគមន៍(Accession) : អំពើដែលឈានទៅដល់, ការឈានទៅទទួលបាន (ក្រមរដ្ឋប្បវេណីចាស់ប្រើសិទ្ធិដំណុះ) ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់

ភូមិបាល ២០០១

ដែលបានលុបចោលមាត្រាមួយចំនួន ដោយច្បាប់អនុវត្តក្រមរដ្ឋប្បវេណី

ឆ្នាំ ២០១១

ច្បាប់
ភូមិបាល

(៣០ សីហា ២០០១)

វិសោធនកម្មដោយ
ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

(៣១ ឧសភា ២០១១)

ព្រះរាជក្រមនស/រកម/ ០៨០១ / ១៤/
ថ្ងៃទី៣០ ខែ សីហា ២០០១
(អនុម័តដោយរដ្ឋសភាថ្ងៃទី ២០ ខែ កក្កដា ២០០១)

ច្បាប់ភូមិបាល

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ចាត់ទុកជាអចលនវត្ថុ តាមន័យនៃច្បាប់នេះមានអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ពវាសនានិងអចលនវត្ថុតាមការកំណត់របស់ច្បាប់ ។

អចលនវត្ថុពីកំណើតមានដីធម្មជាតិដូចជា ដីព្រៃឈើ ដីភាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាច ដាំដុះ ដីលិចទឹកដោយទឹកនៅនឹងឬទឹកហូរនិងសំណង់ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្សហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន ។

អចលនវត្ថុពីភ័ព្វវាសនាមានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យមានការខូចខាត ឬមិនដូរសភាពដើមដូចជា ដើមឈើ ឧបករណ៍ តែងលំអជាដើម ។

អចលនវត្ថុតាមការកំណត់របស់ច្បាប់មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ ។

មាត្រា ៣.-

ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។

ការគ្រប់គ្រងផ្ទៃករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

បទបញ្ជា និងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

មាតិកាទី ១
អំពីកម្មសិទ្ធិឯកជន និង កម្មសិទ្ធិសាធារណៈ
ជំពូកទី ១
អំពីគោលការណ៍នៃកម្មសិទ្ធិ

មាត្រា ៤.-

សិទ្ធិនៃកម្មសិទ្ធិដែលចែងក្នុងមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ អនុវត្តទៅលើអចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ ។

មាត្រា ៥.-

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយ ច្បាប់ និងបទបញ្ជាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

មាត្រា ៦.-

មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឱ្យបានកម្មសិទ្ធិ ។

រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុ
ដែលជារបស់រដ្ឋក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

~~រាល់ការផ្ទេរឬផ្លាស់ប្តូរសិទ្ធិនៃកម្មសិទ្ធិត្រូវធ្វើឡើងតាមវិធាននៃនីតិរួមនៃការលក់ ការបន្តមរតក ការដូរ ឬប្រទានកម្ម ឬ តាមសេចក្តីសំរេច របស់តុលាការ ។~~

មាត្រា ៧.-

របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់ ។

មាត្រា ៨.-

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រ- កម្ពុជា ។

អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជាគឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជានិងគ្រប់អង្គការកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល ។

ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឱ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា
នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥១ នៃច្បាប់នេះ ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឱ្យឡើយ ។

មាត្រា ៩.-

ក្រុមហ៊ុនដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី ៥១ ភាគរយឡើងទៅ កាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជាអាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន ។ មានតែចំនួនភាគរយនៃប្រាក់ហ៊ុនដែលមានចែងក្នុងលក្ខន្តិក:ក្រុមហ៊ុនប៉ុណ្ណោះទេដែលទទួលយកជាការបាន ។ រាល់ការព្រមព្រៀងដែលចុះហត្ថលេខាជាលក្ខណៈឯកជនរវាងអ្នកចូលហ៊ុនទាំងឡាយដែលមានន័យពីនេះត្រូវទុកជាមោឃៈ និង គ្មានអានុភាព ។

ប្រសិនបើចំនួនភាគរយដែលមានចែងក្នុងលក្ខន្តិក:បានប្រែប្រួលបណ្តាលឱ្យក្រុមហ៊ុនលែងមានសញ្ជាតិជាខ្មែរ ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការផ្លាស់ប្តូរលក្ខន្តិក:ឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែង ហើយត្រូវផ្តល់ពតិមានទៅស្ថាប័នមានសមត្ថកិច្ចអំពីការប្រែប្រួលនេះដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន ។

មាត្រា ១០.-

~~កម្មសិទ្ធិរបស់បុគ្គលតែម្នាក់ទោះជារូបវន្តបុគ្គលក្តីឬនីតិបុគ្គលក្តីគឺជាកម្មសិទ្ធិឯកត្តជន ។~~កម្មសិទ្ធិរបស់បុគ្គលមួយក្រុមដែលមានបុព្វសិទ្ធិរៀងៗខ្លួន តាមរយៈច្បាប់ដែលមានបញ្ញត្តិអំពីកម្មសិទ្ធិនេះ គឺជាកម្មសិទ្ធិសមូហភាព ។

~~កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ដែលអនុវត្តសិទ្ធិរបស់ខ្លួនដោយសាមគ្គីភ្ជាប់ទៅលើទ្រព្យទាំងមូលគឺកម្មសិទ្ធិអវិភាគ ។~~

កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ដែលអនុវត្តនូវសិទ្ធិឯកជនផ្តាច់មុខលើភាគខ្លះនៃទ្រព្យហើយភាគដទៃទៀតហៅថាភាគរួមត្រូវដាក់នៅក្រោមបញ្ជានីត្យានុកូល ឬតាមការព្រមព្រៀងគឺសហកម្មសិទ្ធិ ។

ប្រភេទនៃកម្មសិទ្ធិនីមួយៗ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិដោយឡែករបស់កម្មសិទ្ធិទាំងនោះ ។

មាត្រា ១១.-

របបគតិយុត្តនៃកម្មសិទ្ធិអចលនវត្ថុប្រែប្រួលទៅតាមតម្រូវការរបស់សង្គមខ្មែរដូចជា ដីកសិកម្ម ព្រៃឈើ ផ្លូវទឹក ត្រពាំង បឹងបួរ ឬធារទឹក ត្រើយសមុទ្រឬច្រាំងទន្លេ អចលនវត្ថុក្នុងទីក្រុង និងដីសំរាប់សាងសង់តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម ។

ច្បាប់ពិសេសត្រូវបំពេញបទប្បញ្ញត្តិទាំងឡាយនៃអត្ថបទច្បាប់នេះ ឬតាំងបដិប្បញ្ញត្តិដើម្បីរក្សានូវការចាំបាច់ខាងសង្គមសេដ្ឋកិច្ច ការរៀបចំដែនដី និងនគរូបនីយកម្ម ។

បទបញ្ជាទាំងឡាយនឹងបញ្ជាក់លំអិតនូវរបបផ្សេងៗនៃកម្មសិទ្ធិ ដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់ ។

ជំពូកទី ២
អំពីកម្មសិទ្ធិសាធារណៈ

មាត្រា ១២.-

រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងក្នុងមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣និងទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ឬមិនមែនជាទ្រព្យដែលកំពុងកាន់កាប់ជារបស់ឯកជនស្របតាមបទប្បញ្ញត្តិនៃជំពូកទី ៤ នៃច្បាប់នេះ ។

មាត្រា ១៣.-

ក្រៅពីរដ្ឋ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈនិងនីតិបុគ្គលនៃនីតិសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល អាចជាកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងជំពូកនេះ ។

មាត្រា ១៤.-

ទ្រព្យមួយចំនួនរបស់រដ្ឋ
ឬរបស់សមូហភាពដែនដីសាធារណៈដែលត្រូវបានដាក់នៅក្រោមរបបគតិយុត្តពិសេសគឺជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈ។ ទ្រព្យមួយចំនួនទៀត ត្រូវគ្រប់គ្រងដូចកម្មសិទ្ធិឯកជននិងអាចជាកម្មវត្ថុនៃកិច្ចការជំនួញ
គឺជាទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ ។

មាត្រា ១៥.-

រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ :

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេ ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាននិងត្រើយសមុទ្រ
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅដូចជាតឹរបាន កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើតឬក្រោយពីបានរៀបចំដូចជាផ្លូវថ្នល់ ផ្លូវលំផ្លូវរទេះ ផ្លូវដើរ សួនច្បារ និង ឧទ្យានសាធារណៈនិងដីចំណី
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសំរាប់សេវាសាធារណៈដូចជាសាលារៀន ឬ អគារសិក្សាសាធារណៈ អគាររដ្ឋបាលមន្ទីរពេទ្យ សាធារណៈទាំងឡាយ
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបំរុងធម្មជាតិការពារដោយច្បាប់
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌និងប្រវត្តិសាស្ត្រ
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រ កំពុងគ្រងរាជ្យ ។

មាត្រា ១៦.-

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយហើយ កម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាជ្ញាយុកាលបានទេ ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចឋិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃជំពូកទី ៤ នៃច្បាប់នេះបានទេ ។

ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្ន មិនឡើងហើយអាចដកហូតវិញបាន លើមិនបានបំពេញកាតព្វកិច្ច បង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី ៣ នៃច្បាប់នេះ ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធិភណ្ឌិកជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនោះបានឡើយ ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈអាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ ។

មាត្រា ១៧.-

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់ ។

ទ្រព្យទាំងនោះអាចផ្តល់ឱ្យតាមរយៈភតិសន្យា និងជាកម្មវត្ថុនៃកិច្ចសន្យា ដែលបានធ្វើឡើង ត្រឹមត្រូវតាមច្បាប់ ។ លក្ខខណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជន របស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈនឹងកំណត់ដោយអនុក្រឹត្យ ។ គ្មានការលក់ណាមួយអាចត្រូវ បានសម្រេចដោយគ្មានអនុក្រឹត្យនេះឡើយ ។ ដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុ នៃសម្បទានក្នុងលក្ខខណ្ឌដែលមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

គ្មានការចាប់យកដីតាមទំនើងចិត្តណាមួយ អាចកើតឡើងទៅលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈបានឡើយចាប់ពីច្បាប់នេះចូលជាធរមាន ទោះបីស្របនឹង ជំពូកទី ៤ នៃច្បាប់នេះក៏ដោយ ។

ប៉ុន្តែដីទំនេរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចត្រូវបានបែងចែកទៅឱ្យបុគ្គលដែលត្រូវការដីក្នុងគោលដៅសង្គមកិច្ច តាមលក្ខខណ្ឌដែលកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៨.-

ត្រូវទុកជាមោឃៈនិងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយនូវ :

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និង ការបំប្លែងនេះកើតមាននៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក
- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់នេះចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម
- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី ៥
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន

មាត្រា ១៩.-

បុគ្គលទាំងឡាយដែលមានប័ណ្ណឬមានស្ថានភាពជាក់ស្តែងឋិតនៅក្រោមឥទ្ធិពលនៃមាត្រា ១៨ នៃច្បាប់នេះមិនអាចទាមទារសំណងទូទាត់ឬសោហ៊ុយសំរាប់ការថែទាំឬការរៀបចំដែលបាន ធ្វើនៅលើអចលនវត្ថុដែលបានកាន់កាប់ដោយខុសច្បាប់បានឡើយ ។

លទ្ធកម្មណាមួយដោយខុសច្បាប់ និងដោយចេតនា ឬដោយបោកប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈត្រូវផ្តន្ទាទោសដូចមានចែងក្នុង មាត្រា ២៥៩ នៃច្បាប់នេះ ។

ចំពោះការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ ដែលបណ្តាលឱ្យខូចខាតឬធ្វើឱ្យឃឹតយ៉ាវដល់ការងារដែលជាប្រយោជន៍ទូទៅ ពិសេសចំពោះការកាន់កាប់ដីចំណីផ្លូវកិរិតទោសនឹងត្រូវកំណត់ជាថ្មី ។

ក្នុងគ្រប់ករណី បើជនល្មើសមិនបញ្ឈប់ការកាន់កាប់របស់ខ្លួនក្នុងរយៈពេលដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចទេ អាជ្ញាធរអាចដំណើរការបណ្តេញជនល្មើសចេញ ។

ជំពូកទី ៣
អំពីកម្មសិទ្ធិរបស់សមូហភាព
ផ្នែកទី ១ : អំពីអចលនវត្ថុរបស់វត្ត

មាត្រា ២០.-

អចលនវត្ថុជាដីនិងជាសំណង់ដែលមាននៅក្នុងនិងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាជាបេតិកភ័ណ្ឌប្រើប្រាស់ជានិច្ចកាលសំរាប់ព្រះពុទ្ធសាសនា និងដាក់ឱ្យពុទ្ធសាសនិកប្រើប្រាស់ក្រោមការថែទាំរបស់គណៈកម្មការវត្ត ។

មាត្រា ២១.-

អចលនវត្ថុរបស់វត្តមិនអាចលក់ដូរឬធ្វើអំណោយហើយគ្មានកំណត់អាជ្ញាយុកាលឡើយ ។

អចលនវត្ថុរបស់វត្តអាចជួល ឬប្រវាស់បាន តែផលទុនដែលបានមកពីការជួលឬប្រវាស់នេះត្រូវទុកសំរាប់តែកិច្ចការក្នុងសាសនាប៉ុណ្ណោះ ។

កិច្ចការពារទ្រព្យទាំងនេះត្រូវធានាដោយតំណាងគណៈកម្មការវត្ត ។ នីតិវិធីនៃការជ្រើសរើសគណៈកម្មការនិងតំណាងដើម្បីការពារផលប្រយោជន៍វត្ត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា ។

មាត្រា ២២.-

ទីកន្លែងសក្ការបូជានិងទ្រព្យសម្បត្តិនៃជំនឿសាសនាដទៃទៀតមិនស្ថិតនៅក្រោមរបបដែល មានបញ្ញត្តិក្នុងមាត្រា ២០ និងមាត្រា ២១ នៃច្បាប់នេះឡើយ ។ ទ្រព្យទាំងនោះត្រូវគ្រប់គ្រង ដោយសមាគមនៃសាសនិកដែលបង្កើតឡើងទៅតាមបញ្ញត្តិនៃច្បាប់ ។

ផ្នែកទី ២ : អំពីអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច

មាត្រា ២៣.-

សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋ កិច្ចប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព ។

ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែង មកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ២៤.-

ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលគុណប្រយោន៍ពី ការធានាសិទ្ធិនិងការការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ អំពីវប្បធម៌និងសង្គមរបស់សហគមន៍ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀតនិងដោយព្រមទទួលនូវសាមគ្គីភាពនិងភាពចំណុះដែលនាំឱ្យមានការចូលក្នុងសហគមន៍ ។

មាត្រា ២៥.-

ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាននិងប្រកបរបរកសិកម្មប្រពៃណី ។

ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀតដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល ។

ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាងនិងដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី៦ នៃច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ។

មាត្រា ២៦.-

កម្មសិទ្ធិនៃអចលនវត្ថុដែលបានចែងក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព ។កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ ។
ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គលឬក្រុមណាមួយបានឡើយ ។

ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និង លក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសំរេចរបស់សហគមន៍ អនុលោមតាមទំនៀមទំលាប់របស់ពួកគេ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនឹងអចលនវត្ថុដូចជាច្បាប់ការពារបរិស្ថានជាដើម ។

បញ្ញត្តិនៃមាត្រានេះមិនមែនជាឧបស័គ្គដល់សកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការ នៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ ។

មាត្រា ២៧.-

ដើម្បីសម្រួលការវិវត្តន៍វប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសមាជិកសហគមន៍ជនជាតិដើមភាគតិច និងដើម្បីអនុញ្ញាតឱ្យពួកគេបានចេញដោយសេរីពីសហគមន៍ឬរួចផុតពីការបង្ខិតបង្ខំសិទ្ធិនៃកម្មសិទ្ធិឯកត្តជន អាចនឹងត្រូវផ្ទេរជាពិសេសឱ្យពួកគេបានលើចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍ ប៉ុន្តែចំណែកនៃដីដែលជាកម្មវត្ថុនៃការយកធ្វើជាកម្មសិទ្ធិឯកជននោះ មិនអាចជាដីដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទេ ។

មាត្រា ២៨.-

គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិ ដើមភាគតិចបានឡើយ ។

មាតិកាទី ២
អំពីលទ្ធកម្មនៃកម្មសិទ្ធិ
ជំពូកទី ៤
អំពីការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុ
តាមលទ្ធកម្មពិសេសនៃភោគៈ

មាត្រា ២៩.-

ក្នុងក្របខ័ណ្ឌនៃការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុនៅកម្ពុជាក្រោយសម័យមានវិបត្តិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដោយមិនចំណុះទៅនឹងវិធានទូទៅនៃអាជ្ញាយុកាលស្តីពីកម្មសិទ្ធិលើអចលនវត្ថុ ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ ១៩៨៩ អាចបង្កើតជាពិសេសនូវសិទ្ធិភណ្ឌិកលើអចលនវត្ថុ នឹងនាំទៅដល់លទ្ធកម្មនៃកម្មសិទ្ធិដោយអ្នកកាន់កាប់ទ្រព្យក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ ។

ការចូលកាន់កាប់ភោគៈត្រូវបញ្ចប់នៅពេលដែលច្បាប់នេះចូលជាធរមាន ។

មាត្រា ៣០.-

បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និង មិនមានការជំទាស់ ចាប់ពី ៥(ប្រាំ) ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។

ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥(ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភោគីដើមឬពីសិទ្ធិវិន្តស្របច្បាប់ឬអ្នកទទួលផ្ទេរកម្មសិទ្ធិឬពីសន្តតិជនរបស់ខ្លួន ។

មាត្រា ៣១.-

បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប្រសិនបើបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយក្នុងការក្លាយទៅជាកម្មសិទ្ធិករ អាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យបន្តែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់ ៥ (ប្រាំ) ឆ្នាំ និងបានប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ការអនុញ្ញាតឱ្យបន្តរយៈពេល មិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ប្រសិនបើភោគៈបានមកដោយសន្តិវិធីនិងមិនមានការជំទាស់ ។

អាជ្ញាធរមានសមត្ថកិច្ចដែលបដិសេធដោយរំលោភនូវការអនុញ្ញាតឱ្យបន្តរយៈពេលត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះមុខច្បាប់ ។

ការទទួលស្គាល់ដោយរំលោភដោយអាជ្ញាធរមានសមត្ថកិច្ច នូវភោគៈដែលមិនបំពេញលក្ខខណ្ឌនៃច្បាប់ ត្រូវចាត់ទុកជាមោឃៈ និងគ្មានអានុភាព ។ អាជ្ញាធរដែលបានទទួលស្គាល់ ដោយរំលោភនេះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ខ្លួនចំពោះមុខច្បាប់ ។

មាត្រា ៣២.-

អចលនវត្ថុទាំងឡាយដែលមិនអាចក្លាយទៅជាកម្មសិទ្ធិនៃអ្នកកាន់កាប់ស្របតាមច្បាប់នេះ ក្នុងករណីភោគីបំពេញមិនបាននូវលក្ខខណ្ឌនៃច្បាប់ ដោយហេតុមកពីលក្ខណៈសម្បត្តិរបស់ខ្លួនជាភោគីកេងបន្លំ ឬដោយឥរិយាបថរបស់ខ្លួនជាភោគីដែលលួចលាក់នឹង

ច្បាប់ ឬដែលមិនចេញមុខឬជាភោគីដោយប្រើហឹង្សា ។ អចលនវត្ថុនោះត្រូវទុកជាសម្បត្តិរដ្ឋ ហើយមិនអាចឱ្យជនណាចូលកាន់កាប់ជាភោគីថ្មីសំរាប់លទ្ធកម្មនៃកម្មសិទ្ធិក្នុងលក្ខខណ្ឌនៃជំពូកនេះបានឡើយ ។

មាត្រា ៣៣.-

ក្នុងករណីមានការដកហូតអចលនវត្ថុដោយហឹង្សាឬដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយប្រសិនបើគ្មានបណ្តឹងទាមទារពីភោគីស្របច្បាប់នៃអចលនវត្ថុដែលត្រូវបានដកហូត ។បណ្តឹងទាមទារនេះមានរយៈពេល ៣ (បី) ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត ។

មាត្រា ៣៤.-

អ្នកកាន់កាប់ថ្មីលើអចលនវត្ថុ របស់នីតិបុគ្គលសាធារណៈឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណ ក្រោយច្បាប់នេះចូលជាធរមានត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់នេះ ។

មាត្រា ៣៥.-

មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះដែលអាចឱ្យអ្នកកាន់កាប់អចលនវត្ថុគ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ ។

សាមញ្ញជន ឬអាជ្ញាធរដែលមិនតាងនាមរដ្ឋឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាពមានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ ។ ការដេញអាចធ្វើបានតែតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ ។

តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឱ្យចាកចេញដើម្បីជាប្រយោជន៍ដល់បុគ្គលដែលបង្ហាញប័ណ្ណត្រឹមត្រូវនិងពេញលេញរបស់សុរិយោដីបានឡើយ ។

មាត្រា ៣៦.-

បើវិធានការបណ្តេញចេញ បង្គាប់ដោយតុលាការអាចបណ្តាលឱ្យមានភាពវឹកវរឬមានផលវិបាកធ្ងន់ធ្ងរដល់សង្គម អាជ្ញាធរមានសមត្ថកិច្ច អាចសុំព្យួរការអនុវត្តន៍ជាបណ្តោះអាសន្នបាន ។

មាត្រា ៣៧.-

លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុដោយភោគៈអាចសម្រេចបាន ចំពោះតែគុណប្រយោជន៍ដល់បុគ្គលដែលបានកាន់កាប់អចលនវត្ថុស្របតាមលក្ខខណ្ឌនៃច្បាប់នេះ ។ លទ្ធកម្មនេះមិនអាចជាគុណប្រយោជន៍ដល់ភោគីកេងបន្លំឡើយ ។

មាត្រា ៣៨.-

ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ ដោយពិតប្រាកដ គ្មានហឹង្សា ដឹងឮជាសាធារណៈគ្មានអាក់ខាននិងដោយសុចរិត ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយពិតប្រាកដគឺថា ភោគីទោះកាន់កាប់ដោយខ្លួនឯងក្តី ឱ្យអ្នកដទៃធ្វើឱ្យក្តីត្រូវកាន់កាប់ឱ្យឃើញថា ការនោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលដៅខ្លួនជាភោគីយ៉ាងផ្តាច់មុខ កុំឱ្យឃើញថាការដែលធ្វើនោះគឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៅវិញ ។ប្រសិនបើ ភោគីពិតប្រាកដមិនចេញមុខ នៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈដើម្បីធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ ។ ភោគៈនោះត្រូវចាត់ទុកជាមោឃៈ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានហិង្សាគឺថា ភោគៈដែលបានមកដោយហិង្សា មិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ ។ក៏ប៉ុន្តែ បើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកដណ្តើមនោះ ហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានដោយសន្តិភាពតាំងពីដើមមកនោះទេ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយដឹងឮជាសាធារណៈគឺថា ភោគីត្រូវកាន់កាប់ដោយឥតលាក់បិទបាំងអ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះនឹងបានដឹងឮឃើញមិនខាន ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានអាក់ខានគឺថាភោគីត្រូវធ្វើនូវកិច្ចការផងទាំងពួង តាមធម្មតាជាប្រក្រតីក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ ។ ការអាក់ខានក្នុងរយៈពេលខ្លីឬបោះបង់ទុកឱ្យនៅទំនេរដើម្បីឱ្យមានជីជាតិឡើងវិញមិនមែនជាឧបសគ្គ ដល់លទ្ធកម្មកម្មសិទ្ធិនោះទេ ។

ភោគីត្រូវកាន់កាប់អចលនវត្ថុដោយសុចរិតគឺថា ភោគីមិនដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជនលើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ ។

មាត្រា ៣៩.-

ក្នុងការរង់ចាំដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់នេះបង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ ។ភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ ផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួញ ។

មាត្រា ៤០.-

ក្នុងការរង់ចាំការរៀបចំឡើងវិញនូវបណ្តុំសុរិយោដីនិងស្បៀវភៅគោលបញ្ជីដី អាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចំពោះភោគៈដែលមានកន្លងមក មុនច្បាប់នេះចូលជាធរមាន ។

ប័ណ្ណសំគាល់សិទ្ធិនេះជាវត្ថុតាងនៃសិទ្ធិកាន់កាប់ ប៉ុន្តែមិនមែនជាប័ណ្ណកម្មសិទ្ធិទេ ហើយក៏មិនមែនជាលិខិតដែលតវ៉ាមិនបាននោះដែរ ។

ប័ណ្ណសំគាល់សិទ្ធិនេះ អាចនឹងបង្កើតបានជាប័ណ្ណស្តាពរនៃកម្មសិទ្ធិដែលមានលក្ខណៈ មិនអាចតវ៉ាបាន លុះត្រាតែគ្មានការជំទាស់នៅពេលបង្កើតស្បៀវភៅគោលបញ្ជីដី ។

ក្នុងករណីមានការជំទាស់ទាមទារ ការកំណត់ថានរណាជាភោគីស្របច្បាប់នៃអចលនវត្ថុនោះ ត្រូវផ្អែកលើការស៊ើបអង្កេតបន្ថែមនូវរាល់ភស្តុតាងដែលពាក់ព័ន្ធទាំងអស់ ។ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុគឺជាភស្តុតាងមួយប៉ុន្តែមិនអាចកំណត់តែឯកឯងបានទេ ។

មាត្រា ៤១.-

ត្រូវហាមឃាត់ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលមិនអាចយកធ្វើជារបស់ឯកជនបាន ឬដែលមិនបានកាន់កាប់តាមលក្ខខណ្ឌស្របច្បាប់ ។

មាត្រា ៤២.-

បុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែសអ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់នេះ ។

មាត្រា ៤៣.-

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះក្នុងករណីណាក៏ដោយ ។

ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅតែមិនទៀងទាត់ និង ខុសច្បាប់ដដែលប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតតាមបែបផែនដែលបានកំណត់ដោយច្បាប់ទេនោះ ។

បុគ្គលកាន់កាប់ខុសច្បាប់ត្រូវបង្ខំឱ្យចាកចេញជាបន្ទាន់ ហើយត្រូវទទួលទណ្ឌកម្មដែលបាន កំណត់ក្នុងមាត្រា ២៥៩ នៃច្បាប់នេះ ។

បុគ្គលកាន់កាប់ខុសច្បាប់គ្មានសិទ្ធិទាមទារសំណងសំរាប់ចំណាយលើការងារ និងការកែលំអដែលខ្លួនបានធ្វើនៅលើអចលនវត្ថុនោះឡើយ ។

មាត្រា ៤៤.-

ប័ណ្ណឬឯកសារសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឬ របស់នីតិបុគ្គលសាធារណៈដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យដល់បុគ្គលឯកជន ត្រូវទុកជាមោឃៈនិងគ្មានតម្លៃគតិយុត្ត ។

ភ្នាក់ងារដែលចេញប័ណ្ណ ឬឯកសារសំគាល់សិទ្ធិកាន់កាប់នេះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទាំងខាងស៊ីវិលនិងព្រហ្មទណ្ឌ ។

អាជ្ញាធរដែលព្រងើយកន្តើយចំពោះការរំលោភខុសច្បាប់តាមរបៀបនេះ ដែលខ្លួនបានដឹងចាត់ទុកជាអ្នករួមគំនិតហើយត្រូវទទួលទោសដូចគ្នានឹងចារីដែរ ។

មាត្រា ៤៥.-

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះអាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

មាត្រា ៤៦.-

ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុដោយអាជ្ញាធរមានសមត្ថកិច្ច ឱ្យបុគ្គលក្រៅពីភោគីពិតប្រាកដដែលបានកាន់កាប់អចលនវត្ថុគឺជាបទល្មើសដែលត្រូវទទួលទោសតាមបញ្ញត្តិ នៃមាត្រា ២៦១ នៃច្បាប់នេះ ។

មាត្រា ៤៧.-

វិវាទរវាងភោគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេតនិងដោះស្រាយតាមនីតិវិធីដែលបានកំណត់ ។ លទ្ធផលនៃការស៊ើបអង្កេត ត្រូវដាក់ជូនគណៈកម្មការសុរិយោដីដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។ គណៈកម្មការនេះត្រូវធ្វើសេចក្តីសំរេចលើបដិវាទកម្មនោះ ។ ក្នុងករណីមិនសុខចិត្តគូវិវាទ អាចប្តឹងទៅតុលាការបាន ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៥
អំពីសម្បទានដី

មាត្រា ៤៨.-

សម្បទានដីជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្តចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចរដ្ឋានុសិទ្ធិឱ្យ រូបវន្តបុគ្គលឬនីតិបុគ្គលឬក្រុមមនុស្សដើម្បីកាន់កាប់ដីនិងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់នេះ ។

មាត្រា ៤៩.-

សម្បទានដីត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គមឬទៅនឹងប្រយោជន៍សេដ្ឋកិច្ច។ សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅឋាន ឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីធានាការចិញ្ចឹមជីវិត ។

សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍កាប់ឆ្ការ ទាញយកផលដោយធ្វើអាជីវកម្ម កសិឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥០.-

សម្បទានអាចមានរូបភាពផ្សេងទៀតដូចជាការអនុញ្ញាតឱ្យប្រើប្រាស់ រៀបចំឬធ្វើអាជីវកម្មដីដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះជាភ្ជាប់ ឬមិនភ្ជាប់ទៅនឹងការបំពេញសេវាសាធារណៈក៏ដោយមានជាអាទិ៍ សម្បទានរ៉ែ សម្បទានកំពង់ផែ សម្បទានព្រលានយន្តហោះ សម្បទានរៀបចំ តំបន់ឧស្សាហកម្ម សម្បទានទេសាទ ។សម្បទានទាំងនេះមិនឋិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះទេ ។

មាត្រា ៥១.-

សម្បទានដីមិនអាចប្រគល់ឱ្យដោយឥតគិតថ្លៃទេ លើកលែងតែសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គមដែលប្រគល់ឱ្យគ្រួសារក្រីក្រសំរាប់តាំងទីលំនៅ ឬ/និងដាំដំណាំចិញ្ចឹមជីវិត ។

មាត្រា ៥២.-

សម្បទានដីអាចបង្កើតបានតែសិទ្ធិក្នុងរយៈពេលមួយជាកំណត់តាមកិច្ចសន្យាដែលបានបង្កើត សម្បទាននោះស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

សម្បទានដីមិនអាចឈានដល់ការបង្កើតនូវសិទ្ធិជាកម្មសិទ្ធិលើដីដែលបានផ្តល់ជាសម្បទាន ជាប្រយោជន៍ដល់សាមីជននោះទេ លើកលែងតែចំពោះសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍ សង្គម ។

មាត្រា ៥៣.-

សម្បទានដីមិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានទេ ។ សម្បទានដី ត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ដែលបានចេញមុនការកាន់កាប់ដីដោយអាជ្ញាធរមានសមត្ថកិច្ចគឺរដ្ឋ ឬសមូហភាពដែនដីសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលជាកម្មសិទ្ធិករនៃដីដែលត្រូវបានផ្តល់ជាសម្បទាន ។ សម្បទានត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

មាត្រា ៥៤.-

សម្បទានដីត្រូវមានលក្ខខណ្ឌ ។ សម្បទានត្រូវតែអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះដែលជាសណ្តាប់ធ្នាប់សាធារណៈ ។

លិខិតសម្បទានអាចមានខដោយឡែកផ្សេងទៀតដែលមានតម្លៃជាកិច្ចសន្យា ។

មាត្រា ៥៥.-

សម្បទានដីត្រូវបានដកហូតវិញដោយសេចក្តីសំរេចខាងរដ្ឋបាល ក្នុងករណីលក្ខខណ្ឌច្បាប់មិន ត្រូវបានគោរព ។ ករណីនេះ សម្បទានិកមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីដែលច្បាប់បានកំណត់ ។

សម្បទានដីអាចត្រូវបានទុកជាមោឃៈដោយតុលាការ កាលបើសម្បទានិកមិនគោរពខុដោយ ឡែកដែលមានចែងក្នុងកិច្ចសន្យា ។

មាត្រា ៥៦.-

សិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងអំឡុងពេលនៃសម្បទាន គឺជាសិទ្ធិដែលទទួលស្គាល់ដូចជាកម្មសិទ្ធិករលើកលែងតែការផ្ទេរសិទ្ធិ ។ សម្បទានិកមានសិទ្ធិជា ពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ។

សម្បទានិកអាចការពារដីដែលបានផ្តល់ជាសម្បទានឱ្យខ្លួនចំពោះការទន្ទ្រាន ឬការប៉ះពាល់ ទោះជាតាមរូបភាពណាក៏ដោយ ។

សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួនធ្វើការរៀបចំដាំដុះស្របតាមគោលបំណងនៃសម្បទាន ។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទានធ្វើឱ្យប៉ះពាល់ដល់រចនាសម្ព័ន្ធធម្មជាតិ និងធ្វើអាជីវកម្មដែលមានលក្ខណៈជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ ។

មាត្រា ៥៧.-

ការផ្ទេរដីសម្បទានមិនអាចធ្វើឡើងតាមរយៈការផ្ទេរសិទ្ធិបានឡើយ ។ ការផ្ទេរដីសម្បទាន អាចកើតឡើងតែតាមរយៈការបង្កើតកិច្ចសន្យាថ្មីនៃសម្បទានដោយអាជ្ញាធរមានសមត្ថកិច្ច ជាគុណប្រយោជន៍ដល់អ្នកទទួលសិទ្ធិសម្បទានថ្មី ។

ក្នុងករណីដែលសម្បទានិកទទួលមរណភាព ទាយាទទាំងឡាយរបស់ខ្មោចប្រសិនជាមានបំណងអាចនឹងបន្តប្រើប្រាស់សិទ្ធិទាំងនោះ ក្នុងរយៈពេលសម្បទានដែលនៅសល់ ។

មាត្រា ៥៨.-

សម្បទានដីអាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជន របស់រដ្ឋ ។ សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ដីចំណីផ្លូវនិងដីចាំបាច់សំរាប់ថែទាំក៏ដូចជាផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបំរុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ ។

មាត្រា ៥៩.-

សម្បទានដីអាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០ (មួយម៉ឺនហិកតា) ហិកតា ។

សម្បទានដីដែលសំរេចហើយ ហើយមានទំហំលើសពីទំហំកំណត់ខាងលើ ជាកម្មវត្ថុនៃការកាត់បន្ថយ ។ ប៉ុន្តែប្រសិនបើការកាត់បន្ថយនេះមានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍អាជីវកម្មដែល កំពុងមានដំណើរការ សម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេស ។ នីតិវិធីនៃការកាត់បន្ថយនិងការលើកលែងជាពិសេសត្រូវកំណត់ដោយអនុក្រឹត្យ ។

ត្រូវបានហាមឃាត់ការចេញលិខិតសម្បទានដីច្រើនកន្លែងឱ្យបុគ្គលតែម្នាក់ ឬឱ្យនីតិបុគ្គលច្រើន តែគ្រប់គ្រងដោយរូបវន្តបុគ្គលឬនីតិបុគ្គលដដែលៗ ដែលមានទំហំសរុបធំជាងទំហំ ដែលបានកំណត់នៅវាក្យខ័ណ្ឌខាងលើ ។

មាត្រា ៦០.-

នីតិវិធីនៃការផ្តល់សម្បទានដីសំរាប់ការសង់លំនៅឋាននិងសម្បទានដីកសិកម្មសំរាប់ការចិញ្ចឹមជីវិតឬអាជីវកម្មកសិឧស្សាហកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៦១.-

រយៈពេលនៃសម្បទានដីត្រូវកំណត់ ៥៩ (កៅសិបប្រាំបួន) ឆ្នាំ យ៉ាងច្រើន ។

មាត្រា ៦២.-

រាល់សម្បទានដីសំរាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល១២ (ដប់ពីរ) ខែ បន្ទាប់ពីការផ្តល់សម្បទានបើមិនដូច្នោះទេនឹងត្រូវទុកជាមោឃៈ ។

ការខកខានធ្វើអាជីវកម្មរយៈពេលលើសពី ១២ (ដប់ពីរ) ខែ នាំឱ្យមានមោឃភាពសម្បទាន ប្រសិនបើការខកខាននោះពុំមានមូលហេតុត្រឹមត្រូវ ។

រាល់សម្បទានដីដែលបានផ្តល់ឱ្យមុនច្បាប់នេះចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្ម ចាប់ពី ១២ (ដប់ពីរ) ខែ ឡើងទៅគិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ត្រូវទុកជាមោឃៈ ប្រសិនបើការខកខានមិនបានធ្វើអាជីវកម្មនោះពុំមានមូលហេតុត្រឹមត្រូវ ។

រាល់ការមិនបានបំពេញកិច្ចតាមស្បៀវភៅបន្ទុកដោយសម្បទានិក នាំឱ្យមានការដកហូតសម្បទាន ។ ក្នុងករណីនៃការដកហូតសម្បទានទោះជាមានមូលហេតុអ្វីក៏ដោយសម្បទានិក គ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ ។

ជំពូកទី ៦

~~អំពីអប្បរិយលក្ខណៈនៃកម្មសិទ្ធិ~~

អំពីលក្ខណៈនៃកម្មសិទ្ធិ

~~**មាត្រា ៦៣.-**~~

~~ការផ្ទេរកម្មសិទ្ធិអចលនវត្ថុរវាងបុគ្គលឯកជនតាមរយៈការលក់ ការដូរ ការធ្វើអំណោយឬតាមរយៈសន្តតិកម្មត្រូវអនុវត្តតាមបញ្ញត្តិ នៃច្បាប់ ។~~

~~ផ្នែកទី ១ : អំពីលក្ខណៈដោយការលក់អចលនវត្ថុ~~

~~**មាត្រា ៦៤.-**~~

~~ការលក់អចលនវត្ថុគឺជាកិច្ចសន្យាដែលអនុញ្ញាតឱ្យផ្ទេរសិទ្ធិជាកម្មសិទ្ធិនៃអចលនវត្ថុពីអ្នកលក់ទៅឱ្យអ្នកទិញ ដោយអ្នកទិញត្រូវបង់ប្រាក់ថ្លៃអចលនវត្ថុនោះទៅឱ្យអ្នកលក់ ។~~

~~**មាត្រា ៦៥.-**~~

~~ការផ្ទេរកម្មសិទ្ធិមិនអាចជំទាស់តែតែយជនបាន លុះត្រាតែកិច្ចសន្យាលក់អចលនវត្ថុត្រូវ បានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើដោយអាជ្ញាធរមានសមត្ថកិច្ចហើយ ត្រូវបានចុះបញ្ជីនៅអង្គភាពសុំរិយាជ ។~~

~~កិច្ចសន្យាលក់តែងតែងាង មិនអាចចាត់ទុកជាការផ្ទេរកម្មសិទ្ធិទ្រព្យនោះពេញលក្ខណៈច្បាប់ បានឡើយ ។~~

~~**មាត្រា ៦៦.-**~~

~~បុគ្គលដែលមានសញ្ជាតិខ្មែរ និងមានលទ្ធភាពចុះកិច្ចសន្យាអាចលក់ ឬទិញទ្រព្យជាអចលនវត្ថុបាន ។~~

~~បុគ្គលដែលមិនអាចលក់បានគឺ :~~

~~- បុគ្គលដែលមិនមែនជាកម្មសិទ្ធិការនៃទ្រព្យដែលត្រូវលក់~~

~~- កម្មសិទ្ធិការនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធិការអវិភាគ ផ្សេងទៀត~~

~~- បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការឹបអូស ។~~

~~បុគ្គលដែលមិនអាចទិញបានគឺ :~~

~~- អាណែក្យាបាលមិនអាចទិញទ្រព្យរបស់បាលិតខ្លួន~~

~~- ឫទ្ធបត្តម្ភក: មិនអាចទិញទ្រព្យដែលខ្លួនត្រួតត្រាង~~

~~- ចៅក្រម ឬភ្នាក់ងាររដ្ឋបាលមិនអាចទិញទ្រព្យដែលឃុត្តាធិការរបស់ខ្លួន ឬដែលខ្លួនមានបេសកកម្មលក់~~

~~- បុគ្គលដែលមានទ្រព្យត្រូវឹបអូសមិនអាចទិញទ្រព្យនោះវិញបានទេ ។~~

~~មាត្រា ៦៧.~~

~~ការលក់រវាងសេចក្តីទុច្ចរិតជាមោឃៈ ។~~

~~មាត្រា ៦៨.~~

~~អ្នកលក់ត្រូវធានាជាមួយអ្នកទិញ ក្នុងកិច្ចសន្យា ចំពោះអចលនវត្ថុដែលលក់នូវភាពវិវាទ: អាថិកំបាំងសំខាន់ ។ បើពុំនោះទេនាំឱ្យមានកាពិកាភេទនៃការលក់ ។~~

មាត្រា ៦៩.~

~~ការផ្ទេរកម្មសិទ្ធិត្រូវចាត់ទុកជាបានសម្រេច ចាប់ពីពេលដែលបានចុះបញ្ជីកិច្ចសន្យានោះនៅអង្គភាពចុះរបាជី ។ ថ្លៃលក់ត្រូវតែចុះក្នុងកិច្ចសន្យាលក់ បើមិនដូច្នោះទេកិច្ចសន្យាលក់នោះ ត្រូវទុកជាមោឃៈ ។~~

កិច្ចសន្យាលក់អចលនវត្ថុនឹងអាចចុះបញ្ជីបាន លុះត្រាតែភាគីទាំងអស់បានបង្ហាញភស្តុតាង ថារាល់ពន្ធដារលើទ្រព្យនោះ ត្រូវបានបង់រួច ។

ផ្នែកទី ២ : អំពីលទ្ធកម្មដោយការជួរអចលនវត្ថុ

~~មាត្រា ៧០.~~

~~ការជួរអចលនវត្ថុ គឺជាកិច្ចសន្យាដែលភាគីទាំងសងខាងព្រមព្រៀងឱ្យអចលនវត្ថុត្លាទៅវិញទៅមក ។~~

~~ការជួរអចលនវត្ថុអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុបាន ។~~

~~ការជួរនេះត្រូវមានលក្ខខណ្ឌដូចគ្នានឹងការលក់ដែរ ។~~

ផ្នែកទី ៣ : អំពីលទ្ធកម្មដោយសន្តតិកម្ម

~~មាត្រា ៧១.~~

~~អាចផ្ទេរតាមរយៈសន្តតិកម្មពេលណ្តាំ សន្តតិកម្មមានបណ្តាំឬអត់ឱយទាន្ទរ: ~~

~~- ទ្រព្យជាអចលនវត្ថុដែលប័ណ្ណកម្មសិទ្ធិត្រូវបានរៀបចំជាភ្លាមៗប្រសិនតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ~~

~~- រោគៈទាំងឡាយប្រសិនតាមច្បាប់ដោយយោងទៅលើប័ណ្ណឬឯកសារពាក់ព័ន្ធ ឬភស្តុតាងផ្សេងៗទៀត~~

~~- រាល់អវយវៈរោទនៃកម្មសិទ្ធិនិងរាល់សិទ្ធិភណ្ឌិកអចលនវត្ថុ ។~~

មាត្រា ៧២.-

ក្នុងករណីសន្តតិកម្ម ការគិតរយៈពេលចាំបាច់នៃការកាន់កាប់អចលនវត្ថុសំរាប់លទ្ធកម្មកម្មសិទ្ធិពេញលេញ ដូចដែលបានបញ្ញត្តិក្នុងមាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់ នេះត្រូវរាប់ចាប់ពីពេលដែលខ្មោចបានចូលកាន់កាប់ទ្រព្យនោះ ។

មាត្រា ៧៣.-

ទ្រព្យជាអចលនវត្ថុដែលគ្រាន់តែកាន់កាប់ដោយជាក់ស្តែង ហើយមិនទាន់បានចុះបញ្ជីឬ បញ្ជាក់ដោយលិខិតរដ្ឋបាល ប៉ុន្តែត្រូវបានកាន់កាប់ស្របតាមលក្ខខណ្ឌនៃច្បាប់ ក៏អាចជាកម្មវត្ថុនៃការផ្ទេរតាមសន្តតិកម្មបានដែរ ។

មាត្រា ៧៤.-

ក្នុងករណីទ្រព្យកាន់កាប់គ្មានប័ណ្ណត្រូវបានផ្ទេរតាមរយៈសន្តតិកម្ម ទាយាទដែលជាអ្នកកាន់ កាប់ថ្មីអាចបន្តចាត់ចែងទ្រព្យនោះ និងទទួលបាននូវកិច្ចការពារ ដោយហេតុថាស្ថានភាពរបស់ខ្លួន ឆ្លើយតបទៅនឹងលក្ខខណ្ឌនៃច្បាប់ ។

ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចឬជនណាក៏ដោយមិនអាចយកលេសពីស្ថានភាពនៃការកាន់កាប់ជាក់ស្តែងរបស់ ខ្មោច ឬយកលេសពីការខ្វះនូវការជំរះមរតកត្រឹមត្រូវ ដើម្បីធ្វើឱ្យប៉ះពាល់សិទ្ធិនៃទាយាទនិងជាពិសេសដើម្បីបដិសេធការទទួលស្គាល់ ឬមិនបញ្ជាក់ការកាន់កាប់របស់គេបានឡើយ ។

~~**មាត្រា ៧៥.-**~~

~~កាលបើអចលនវត្ថុជាមរតកប្រើប្រាស់សំរាប់ជាលំនៅឋាននៃគ្រួសាររបស់ខ្មោច ឬ ជីប្រើប្រាស់សំរាប់ការផ្គត់ផ្គង់ជីវភាពដោយផ្ទាល់ទាយាទ មិនអាចស្នើសុំបែងចែកឬសម្រេចលក់ទ្រព្យនោះទេ លើកលែងមានការយល់ព្រមដោយច្បាស់ពីសហទាយាទទាំងអស់ ។ ក្នុងករណី មានការជំទាស់អំពីការបែងចែកមរតក សហទាយាទមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំឱ្យដោះស្រាយចំនាស់នេះ ។~~

~~ការលក់ចំណែកសិទ្ធិរបស់សហទាយាទណាម្នាក់ត្រូវទុកជាមោឃៈ ប្រសិនបើគ្មានការយល់ព្រមច្បាស់ពីសហទាយាទទាំងអស់ ។ ម៉្យាងទៀតចំពោះសហទាយាទដែលបានលក់ចំណែកសិទ្ធិរបស់ខ្លួននេះត្រូវរាប់បង់សិទ្ធិនៃសន្តតិកម្មលើទ្រព្យដែលបានលក់ ។ សហទាយាទណា ម្នាក់ដែលបានបំពេនការហាមលក់មរតកនេះ ត្រូវទទួលខុសត្រូវតែម្នាក់ឯងលើអំពើរបស់ខ្លួនចំពោះអ្នកទិញ ។~~

~~**មាត្រា ៧៦.-**~~

~~ទាយាទទាំងឡាយដែលមិនអាចបន្តនិរន្តរភាពនៃការកាន់កាប់ទ្រព្យជាមរតកបាន ដោយជាក់ស្តែងឬដោយគតិយុត្ត ឬមិនចង់ទទួលបន្ទុកដោយខ្លួនឯង អាចធ្វើការផ្ទេរ ដោយប្រគល់សិទ្ធិឱ្យតតិយជនបាន ។~~

មាត្រា ៧៧.-

បើអ្នកទទួលសម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ចមិនមែនជាក្រុមហ៊ុន ហើយមានប័ណ្ណអចលនវត្ថុកាន់កាប់ដោយរូបវន្តបុគ្គលម្នាក់ដែលទទួលមរណភាពសម្បទាននោះ មិនអាចជាកម្មវត្ថុនៃការបែងចែកដោយគ្មានការយល់ព្រមពីអាជ្ញាធររដ្ឋបាល ដែលបានផ្តល់សម្បទានបានឡើយ ។

មាត្រា ៧៨.-

ដីដែលធ្លាក់ទៅជាទ្រព្យរដ្ឋ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៣០០ (មតិកដែលធ្លាក់ទៅជាទ្រព្យរដ្ឋ នៃក្រមរដ្ឋប្បវេណីត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

~~ទ្រព្យទាំងឡាយដែលកម្មសិទ្ធិករស្លាប់ដោយគ្មានបន្សល់ទុកនូវទាយាទ ឬអច្ចយសោកីត្រូវត្រឡប់មកជារបស់រដ្ឋហើយត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋ ។~~

~~មាត្រា ៧៩.~~

~~ការចាត់ចែងមរតកត្រូវស្ថិតនៅក្រោមវិធានទាំងឡាយនៃទំនៀមទម្លាប់ប្រពៃណីក្នុងរឿងនេះក្នុងពេលរង់ចាំការប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីថ្មី ។~~

ផ្នែកទី ៤ :អំពីលទ្ធកម្មដោយប្រធានកម្ម

~~មាត្រា ៨០.~~

~~ប្រធានកម្មគឺជាកិច្ចសន្យាដែលជនម្នាក់ហៅថាអ្នកអោយ ឬទាយកផ្ទេរនូវកម្មសិទ្ធិនៃទ្រព្យរបស់ខ្លួនឱ្យទៅជនម្នាក់ទៀតហៅថា អ្នកទទួលឬបដិគ្គាហកដែលត្រូវទទួលយកទ្រព្យនោះ ។~~

~~មាត្រា ៨១.~~

~~ប្រធានកម្មអចលនវត្ថុមិនអាចត្រូវបានជំទាស់ពីតតិយជនបាន លុះត្រាតែប្រធានកម្មនោះ ត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយ៉ាងតូច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពបុរិសយោធិ ។~~

~~មាត្រា ៨២.~~

~~អចលនវត្ថុអាចជាកម្មវត្ថុនៃប្រធានកម្មរវាងអ្នកនៅរស់ឬប្រធានកម្មដោយហេតុមរណៈឬអច្ចយទាន ។ ប្រសិនបើជាប្រធានកម្មទៅវិញទៅមក ប្រតិបត្តិការនេះបង្កើតបានជាការប្លូរ ។~~

មាត្រា ៨៣.-

រដ្ឋអាចធ្វើអំណោយជាអចលនវត្ថុចំពោះតែរូបវន្តបុគ្គលដោយហេតុផលសង្គមកិច្ច ដើម្បីឱ្យស្នាក់នៅឬដាំដុំណាំចិញ្ចឹមជីវិត ។ តម្លៃអចលនវត្ថុដែលផ្តល់ឱ្យត្រូវបានកំណត់សមស្របទៅនឹងគោលដៅណាមួយដែលចង់បាននិងមិនអនុញ្ញាតឱ្យកេងយកកំរៃ ឬធ្វើមានបានមិនស្របទៅនឹងកិរិតជីវភាពសង្គមនៃអ្នកទទួល ។

ប្រទានកម្មដែលរដ្ឋបានធ្វើពីមុនមកហើយមិនអាចសើរើបានឡើយ ។

~~មាត្រា ៨៤.~~

~~ប្រធានកម្មទ្រព្យជាអចលនវត្ថុមិនអាចដកហូតមកវិញបានឡើយ នៅពេលដែលមានការត្រមទទួលហើយនោះ ។ ប្រធានកម្មនេះអាចធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិបានភ្លាម ។ ប៉ុន្តែទាយកអាចរក្សាទុកសំរាប់ខ្លួននូវសិទ្ធិផលពុបភោគនៃទ្រព្យ សិទ្ធិប្រើប្រាស់និងអាស្រ័យនៅនៃអចលនវត្ថុដែលត្រូវចែងក្នុងកិច្ចសន្យានិងត្រូវចុះបញ្ជីនៅអង្គភាពបុរិសយោធិ ។~~

មាតិកាទី ៣

~~អំពីរបបកម្មសិទ្ធិដែនដន~~

អំពីវិធានដី និងសេវភាព

ជំពូកទី ៧

អំពីវិធានដី

~~អំពីសិទ្ធិនិងការតម្រូវកិច្ចនៃកម្មសិទ្ធិករ~~

~~ផ្នែកទី ១ : អំពីការអនុវត្តយ៉ាងដូចនៃកម្មសិទ្ធិ~~

~~មាត្រា ៨៥.~~

~~កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុមានសិទ្ធិប្រើប្រាស់ អាស្រ័យផលនិងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និងទូលំទូលាយកុំឱ្យតែយកទ្រព្យនោះទៅប្រើប្រាស់ក្នុងបទណាមួយដែលច្បាប់បានហាមឃាត់ ។~~

~~មាត្រា ៨៦.~~

~~កម្មសិទ្ធិករនៃទ្រព្យ មិនអាចប្រើប្រាស់ទ្រព្យនោះក្នុងគោលដៅព្យាបាទ ប្ញទំខានដល់តតិយជននិងជាតិសេវដល់អ្នកជិតខាងរបស់ខ្លួនបានឡើយ ។~~

~~ការប្រើប្រាស់ទ្រព្យជាធម្មតាដែលមានចរិតធម្មានុរូបមិនអាចចាត់ទុកជាការរំខាន ដែលបណ្តាលឱ្យរាំងស្ទះដល់ការប្រើប្រាស់ទ្រព្យនោះបានឡើយ ។~~

~~មាត្រា ៨៧.~~

~~កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដី រាល់ការជាំជុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួនលើកំសែងដីតែមានច្បាប់ហាមឃាត់ ។ការរៀបចំឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ស្របតាមបញ្ញត្តិនៃផ្នែកទី ៣ នៃជំពូកនេះ ។~~

~~មាត្រា ៨៨.~~

~~កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចរៀបចំឬកែប្រែបានដោយលើនូវប្រភេទ និង រចនាសម្ព័ន្ធដើមនៃទ្រព្យរបស់ខ្លួន ស្របតាមការប្រើប្រាស់ដែលខ្លួនចង់ធ្វើតាមការកំណត់នៃច្បាប់ ។~~

~~មាត្រា ៨៩.~~

~~ចាត់ទុកជាការកែប្រែប្រភេទឬរចនាសម្ព័ន្ធដើមនៃទ្រព្យជាអចលនវត្ថុក្នុងន័យនៃច្បាប់នេះមានជាអាទិ៍ ការគាស់រានដី ការកាប់ព្រៃឈើ ការជាំជុះលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីករុករក ការជីកយកដីចេញ ការជីកអណ្តូងរ៉ែឬកន្លែងយកថ្ម ការរៀបចំឬការធ្វើឱ្យស្ងួតដែនវារីជាតិ ការរៀបចំជីកលែកម្មទៅជាទីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្មនិងការបង្កើតទីតាំងសោរឯកជន ។~~

~~មាត្រា ៩០.~~

~~កម្មសិទ្ធិករនៃផ្ទៃជីពឹងជាកម្មសិទ្ធិករនៃផ្ទៃក្រោមដី និងរាល់អ្វីៗដែលអាចទាញយកផលបាន កុំឱ្យតែផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៧៨ និងមាត្រា ៨៥ នៃច្បាប់នេះ។ ព្រំប្រទល់នៃផ្ទៃខាង ក្រោមដីត្រូវបានកំណត់តាមបន្ទាត់ឈរនៃផ្ទៃរាបខាងលើ។~~

~~ប៉ុន្តែកម្មសិទ្ធិករមិនអាចទាមទារយកជាកម្មសិទ្ធិនូវរបស់ដែលមាការ ចម្លាក់ក្រឡោតឬបុរាណវត្ថុគ្រប់ប្រភេទដែលបានរកឃើញ។ ល្មៅដែទាំងនេះ ជាចំណែកនៃបេតិកភណ្ឌជាតិ ហើយត្រូវតែប្រគល់ឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។~~

~~មាត្រា ៩១.~~

~~កម្មសិទ្ធិករនៃផ្ទៃជីពឹងជាកម្មសិទ្ធិករនៃលំហអាកាស~~

~~និងវត្ថុធាតុអចិន្ត្រៃយ៍ដែលស្ថិតចំពីលើដីជាកម្មសិទ្ធិរបស់ខ្លួនលើកលែងតែបណ្តាញខ្សែអគ្គិសនីនិងទូរគមនាគមនិងដែលត្រូវអនុវត្តតាមច្បាប់ដោយឡែក។ ជាពិសេស~~

~~កម្មសិទ្ធិករអាចកាប់មែកឈើរុក្ខជាតិខាងដែលលយចូលមកលើកម្មសិទ្ធិរបស់ខ្លួនឬបេះយកផលផ្លែឈើនោះបាន។~~

~~ប៉ុន្តែកម្មសិទ្ធិករមិនអាចហាមឃាត់ការហោះហើរដោយអាកាសយានគ្រប់ប្រភេទបានឡើយ។~~

~~មាត្រា ៩២.~~

~~កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចបង្កើតបានជាប្រាតិភោគនៃកិច្ចសន្យា ប្រែបតាមបញ្ញត្តិដែលបានកំណត់ក្នុងមាតិកាទី ៥ នៃច្បាប់នេះ។~~

~~មាត្រា ៩៣.~~

~~កម្មសិទ្ធិករនៃទ្រព្យអាចចាត់ចែងផលិតផលនិងការកើនឡើងតាមធម្មជាតិឬតាមបែបប្បនិម្មិតដែលផ្សំគ្នា~~
~~ឬដែលជាប់ជាមួយនឹងទ្រព្យនោះតាមវិធានដែលបានកំណត់ក្នុងផ្នែកទី២ និងទី៣ នៃជំពូកនេះ។~~

~~ផ្នែករងទី ២ : អំពីទ្រង់ទ្រាយនិងផលិតផលនិងផលទុនដែលកម្មសិទ្ធិ~~

~~មាត្រា ៩៤.~~

~~កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុមានសិទ្ធិទទួលផលគ្រប់បែបយ៉ាងពីទ្រព្យនោះមានផលធម្មជាតិនិងផលសុីវិលតាមសិទ្ធិដូចខាងមុន។~~

~~ផលធម្មជាតិគឺផលដែលកើតពីដីដោយឯកឯង ឬដោយអំពើរបស់មនុស្ស។~~

~~ផលសុីវិលគឺផលទុន ផនលភាគនិងការប្រាក់។~~

~~មាត្រា ៩៥.~~

~~ផលដែលកើតចេញពីដំណាំលើទ្រព្យជាដីជារបស់កម្មសិទ្ធិករនៃទ្រព្យនោះ~~
~~លុះត្រាតែកម្មសិទ្ធិករនោះបានលះបង់ពីផ្លែនៃការប្តូរអាស់ ពលកម្ម និងពូជដែលបានផ្តែជាយថាហេតុដោយពតិយជន។~~

~~ផ្នែករងទី ៣ : អំពីការកើនឡើងកម្មសិទ្ធិ~~

~~អនុផ្នែករងទី ១ : អំពីការកើនដោយអំពើរបស់មនុស្ស~~

~~មាត្រា ៩៦.~~

~~ចំណែក ជំណាំនិងការ្យទាំងឡាយដែលបានធ្វើនៅលើដីឬនៅក្រោមដី~~
~~ត្រូវបានចាត់ទុកថាបានធ្វើដោយកម្មសិទ្ធិការដោយសោហ៊ុយផ្ទាល់ខ្លួនហើយដាវបង់កម្មសិទ្ធិការនោះលើកលែង តែមានភស្តុតាងផ្ទុយពីនេះ ។~~

~~មាត្រា ៩៧.-~~

~~កម្មសិទ្ធិការនៃដីដែលបានធ្វើការខាងលើ ដាំដុះ ឬរៀបចំដោយប្រើសម្ភារៈដែលមិនមែនជារបស់ខ្លួនត្រូវចេញថ្លៃសម្ភារៈទាំងនោះឱ្យម្ចាស់គេវិញ។ កម្មសិទ្ធិការនោះអាចត្រូវផ្តន្ទាទោស ឱ្យសងជម្ងឺចិត្តផងដែរ ប្រសិនជាមាន ប៉ុន្តែម្ចាស់សម្ភារៈគ្មានសិទ្ធិដកយកសម្ភារៈនោះចេញឡើយ ។~~

~~មាត្រា ៩៨.-~~

~~កាលបើដំណាំ សំណង់និងការរៀបចំទាំងឡាយត្រូវបានធ្វើឡើងដោយបំពានពីតំរិយជននិងដោយសម្ភារៈរបស់ខ្លួន កម្មសិទ្ធិការនៃដីមានសិទ្ធិរក្សាទុករបស់ទាំងនោះឬបង្ខំឱ្យតំរិយជននោះដកយកចេញបាន ។~~

~~ប្រសិនជាកម្មសិទ្ធិការនៃដីចុំឱ្យដកយកចេញនូវដំណាំ និងសំណង់ដែលបានធ្វើដោយបំពានចោទប៉ុយនៃការដកចេញជាបន្ទុករបស់តំរិយជនហើយក្នុងសំណងណាមួយសំរាប់អ្នកនោះទេ ។ តំរិយជននោះក៏អាចត្រូវផ្តន្ទាទោសឱ្យសងជម្ងឺចិត្តផងដែរ ប្រសិនបើមានក្យសេនកម្មជាយថាហេតុ ដល់កម្មសិទ្ធិការនៃដី ។ ប្រសិនបើកម្មសិទ្ធិការចង់រក្សាទុកដំណាំនិងការ្យទាំងនោះ កម្មសិទ្ធិការនោះត្រូវសង់ថ្លៃសម្ភារៈនិង ថ្លៃការងារដោយមិនគិតដល់តំលៃលើសេ តិចឬច្រើន ដែលជីវភាពនឹងកើនតំលៃនោះទេ ។~~

~~ចំពោះដំណាំ សំណង់ឬការ្យទាំងឡាយណាដែលបានធ្វើដោយតំរិយជនដោយសុចរិតដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ កម្មសិទ្ធិការមិនអាចសុំដកយកចេញនូវការ្យ ដំណាំឬការរៀបចំទាំងនោះបានឡើយ ។ កម្មសិទ្ធិការមានជំរើសពីរ ឬមួយសងថ្លៃសម្ភារៈនិងថ្លៃតេវកម្មឬមួយសងជាទឹកប្រាក់ស្មើនឹងតំលៃលើសដែលដីបានកើនតំលៃក៏បាន ។~~

~~អនុផ្នែកទី ២ : អំពីការកើនដោយធម្មជាតិ~~

~~មាត្រា ៩៩.-~~

~~ដីដុះដែលកើនឡើងជាបន្តបន្ទាប់ បន្តិចម្តងៗលើដីជាប់មាត់ទន្លេឬថ្នើរ ព្រែកហៅថាល្បាប់ ។~~

~~ល្បាប់ត្រូវបានជាប្រយោជន៍ដល់កម្មសិទ្ធិការដែលមានដីជាប់មាត់ទឹកដែលនាវា ឬ ក្បូនចេញចូលបាន បណ្តែតបានឬមិនបាន។ ក្នុងការណីនាវាឬក្បូនចេញចូលបាន បណ្តែតបាន កម្មសិទ្ធិការត្រូវទុកផ្លូវសំរាប់ទាញតួរនាវាស្របទៅតាមបទបញ្ជាទាំងឡាយ ។~~

~~មាត្រា ១០០.-~~

~~ចំពោះដីដែលកើនឡើងដោយសារចរន្តទឹកហូរនាំល្បាប់បន្តិចម្តងៗមើលមិនដឹង~~
~~ពីច្រាំងម្ខាងទៅការនៅច្រាំងម្ខាងទៀតជាប់ជាមួយនឹងដីអ្នកផ្សេង~~
~~កម្មសិទ្ធិការនៃដីដែលជាប់នឹងដីជុះនោះទទួលបានគុណប្រយោជន៍នៃល្បាប់នេះ~~
~~ដោយមិនអាចឱ្យអ្នកមានដីនៅច្រាំងម្ខាងដែលបាត់ដីមកពន្ធារ យកដីដែលបាត់នោះបានឡើយ ។~~

~~មាត្រា ១០១.-~~

~~ប្រសិនជាទន្លេឬថ្នើរ ព្រែក ដែលនាវាចេញចូលបានឬមិនបាននាំយកចេញដោយកន្លាំង~~
~~ទឹកជំនន់ភ្លាមៗនូវចំណែកដីដ៏ធំនិងអាចស្គាល់បានពីច្រាំងម្ខាងទៅភ្ជាប់នឹងដីខាងក្រោមខ្សែទឹក ឬ នឹងច្រាំងម្ខាងទៀត~~

កម្មសិទ្ធិការនៃដីដែលជាប់ចេញអាចពាំយកជាកម្មសិទ្ធិរបស់ខ្លួនវិញបាន តែត្រូវជាប់ពាក្យប្តឹងទាក់ងរយៈពេលយ៉ាងយូរ ១ (មួយ) ឆ្នាំ គិតពីថ្ងៃកើតឡើងនូវព្រឹត្តិការណ៍នោះ បើហួសរយៈពេលនេះ បណ្តឹងទាមទារ មិនត្រូវបានទទួលយកមកដោះស្រាយឡើយ លើកលែងតែកម្មសិទ្ធិការនៃដីដែលមានដីជាប់ទៅភ្ជាប់នោះមិនទាន់បានកាន់កាប់នៅឡើយ ។

មាត្រា ១០២.-

កោះធំ កោះតូចនិងដីដុំទាំងឡាយដែលនឹងកកើតថ្មីក្នុងដែនទន្លេ ឬស្ទឹង ត្រូវកោះដែលនាំឬ ក្បួនចេញចូលបាន បណ្តែតបាន ជារបស់រដ្ឋ ។

មាត្រា ១០៣.-

កោះធំ កោះតូចនិងដីដុំទាំងឡាយដែលនឹងកកើតថ្មីក្នុងស្ទឹង ត្រូវកោះដែលនាំ ឬ ក្បួនចេញចូលមិនបាន បណ្តែតមិនបាន ត្រូវបានមកកម្មសិទ្ធិការនៃដីជាប់ច្រាំងដែលមាន កោះ ឬដីដុំនោះ ។ប្រសិនបើការដុះនោះមិនបានដុះជ្រុលទៅច្រាំងម្ខាងទៅនោះ ត្រូវបានទៅកម្មសិទ្ធិការដែលមានដីជាប់ច្រាំងទាំងសងខាងគិតពីបន្ទាត់ពុះពាក់កណ្តាលស្ទឹង ។

មាត្រា ១០៤.-

ប្រសិនបើស្ទឹង
ត្រកោះឬទន្លេបង្កើតជាផ្លូវទឹកថ្មីមួយកាត់យកដីកម្មសិទ្ធិអ្នកនៅជាប់មាត់ទឹកណាម្នាក់ហើយបង្កើតបានជាកោះមួយ កម្មសិទ្ធិការនោះរក្សាបានសិទ្ធិជាកម្មសិទ្ធិនៃដីរបស់ខ្លួនដែលជាច់នោះដដែល ទោះបីជាកោះនោះដុះក្នុងទន្លេឬស្ទឹង ត្រកោះដែលនាំឬក្បួនចេញចូលបានបណ្តែតបានក៏ដោយ ។

មាត្រា ១០៥.-

ប្រសិនជាទន្លេឬស្ទឹង ត្រកោះណាមួយដែលនាំឬក្បួនចេញចូលបាន បណ្តែតបាន
បង្កើតជាផ្លូវទឹកថ្មីមួយដោយបោះបង់ចោលផ្លូវទឹកចាស់កម្មសិទ្ធិការដែលមានដីជាប់ច្រាំងនោះ អាចធ្វើលទ្ធកម្មកម្មសិទ្ធិក្នុងដែនទន្លេ ឬ ស្ទឹង ត្រកោះចាស់ដែលពោកនោះបាន ហើយម្នាក់ៗត្រូវបានតាមសិទ្ធិរបស់ខ្លួនរហូតដល់ខ្សែបន្ទាត់ដែលពុះពាក់កណ្តាលទន្លេ ឬស្ទឹង ត្រកោះនោះ។ ថ្លៃជំនៃផ្លូវទឹកចាស់នោះត្រូវបានកំណត់ដោយអ្នកជំនាញដែលតែងតាំង ដោយពុទោការខេត្ត-ក្រុងទីនោះ តាមពាក្យស្នើសុំពីអាជ្ញាធរខេត្ត-ក្រុងឬពីភាគីដែលមានប្រយោជន៍ក្នុងរឿងនេះ ។

បើកម្មសិទ្ធិការនៅមាត់ទឹកនោះមិនចង់បានដីនោះតាមថ្លៃដែលអ្នកជំនាញកំណត់ទេ អាជ្ញាធរត្រូវលក់ឡាយឡុងផ្លូវទឹកចាស់នោះឱ្យតោធារណជន ។ ថ្លៃដែលបានមកពីការលក់ដីនោះ
ត្រូវយកទៅចែកឱ្យកម្មសិទ្ធិការដែលមានដីជាប់ទៅនោះតាមសមាមាត្រនៃដីដែលខូចខាតរៀងៗខ្លួន ។

~~ផ្នែករងទី ៤ : អំពីការជួលអចលនទ្រព្យ~~

~~មាត្រា ១០៦.-~~

~~កម្មសិទ្ធិការនៃទ្រព្យជាអចលនវត្ថុអាចជួលទ្រព្យរបស់ខ្លួនឱ្យអ្នកដទៃបាន ។ ការជួលជាកិច្ចសន្យាដែលកម្មសិទ្ធិការនៃទ្រព្យមួយប្រគល់ទ្រព្យនោះឱ្យជនណាម្នាក់ប្រើប្រាស់ក្នុងរយៈពេលមួយ~~

ដោយយកជាប្រាក់ឈ្នួលមកវិញយ៉ាងឯកឡែកទាត់តោមលេមាមាត្រនៃរយៈពេលប្រើប្រាស់ ។

កិច្ចសេន្យានៃការជួលអចលនវត្ថុហៅថាភតិសេន្យា ។

កិច្ចសេន្យាជួលអចលនវត្ថុមានពីរយ៉ាងគឺ ការជួលរយៈពេលមិនកំណត់ និង ការជួលរយៈពេលកំណត់ ។

ការជួលរយៈពេលកំណត់មានការជួល រយៈពេលខ្លីអាចបន្តជាថ្មីបាន និងការជួលរយៈពេលវែង ១៥ (ដប់ប្រាំ) ឆ្នាំ ឬលើសេ ។

~~មាត្រា ១០៧.~~

កិច្ចសេន្យាជួលរយៈពេលមិនកំណត់ឬរយៈពេលខ្លី

ហើយអាចបន្តជួលជាថ្មីបានបង្កើតបានជាមំនាក់មំនងផ្ទាល់ខ្លួនរវាងភតិសេន្យាបតី និងអ្នកជួល ។

ការជួលបន្តឱ្យតតិយជនអាចធ្វើទៅបាន លុះត្រាតែមានការព្រមព្រៀងដោយជាក់លាក់ឬការអនុញ្ញាតពីកម្មសិទ្ធិករ ។

~~មាត្រា ១០៨.~~

កិច្ចសេន្យាជួលរយៈពេលវែងបង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ ។ សិទ្ធិនេះអាចត្រូវបានប្រគល់ឱ្យដោយមានថ្លៃ ឬផ្ទេរបន្តតាមរយៈសេន្តពិកម្ម ។

ទ្រព្យដែលបានជួលរយៈពេលវែងអាចជាកម្មវត្ថុនៃការរៀបចំនិងការបំប្លែង ប៉ុន្តែឱ្យតែការងារនោះមានអានុភាពបំផ្លាញ ឬបំប្លែងជាហេវន្តនូវលេភាពជើមនៃវត្ថុនោះ លើកលែងការណីមានចែងដោយឡែកក្នុងភតិសេន្យា ។

នៅពេលផុតកំណត់នៃការជួល ភតិសេន្យាបតី

ឬទាយាទទាំងឡាយរបស់ជននេះទទួលបានមកវិញនូវកម្មសិទ្ធិពេញលេញនៃបំណង់ដោយគ្មានការសងតេាប៉ុន្តែការរៀបចំឬការកែសំអុទាំងឡាយដែលបានធ្វើដោយអ្នកជួល ។

ភតិសេន្យាបតីឬទាយាទមិនអាចបង្ខំអ្នកជួលឱ្យប្រគល់អចលនវត្ថុតាមស្ថានភាពដើមបានឡើយ

បើលែងជាអ្នកជួលពេរពេបទប្បញ្ញត្តិនៃវាក្យខណ្ឌ ២ នៃមាត្រានេះ ។

~~មាត្រា ១០៩.~~

ភតិសេន្យាត្រូវធ្វើឡើងតាមអន្តៈនៃបណ្តោរភាពីនិងតាមបញ្ញត្តិនៃច្បាប់ ឬបទបញ្ជាទូទៅជាធរមាន ។

ភតិសេន្យាត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ ភតិសេន្យាធ្វើឡើងដោយផ្ទាល់ មាត់ត្រូវទុកជាបណ្តោះអាសន្ន

ហើយអាចត្រូវបានបញ្ឈប់នៅគ្រប់ពេលដោយជូនដំណើរជាមុន ក្នុងរយៈពេលថ្ងៃនឹងរយៈពេលបង់ប្រាក់ឈ្នួល ។

~~មាត្រា ១១០.~~

មុនការចូលអាស្រ័យផលលើអចលនវត្ថុ អ្នកជួលត្រូវតែដឹងអំពីស្ថានភាពនៃអចលនវត្ថុ និង

សម្ភារៈនៅនឹងកន្លែងដែលបានរៀបចំតាមការព្រមព្រៀងជាមួយនឹងភតិសេន្យាបតី ។

ការមិនបានពិនិត្យស្ថានភាពអចលនវត្ថុនិងសម្ភារៈនៅនឹងកន្លែងនៅពេលចូលអាស្រ័យផល

ត្រូវចាត់ទុកថាព្រឹមត្រូវតាមសក្ខខណ្ឌដូចមានចែងក្នុងភតិសេន្យា ។

ទ្រព្យដែលជួលមិនត្រូវមានវិការៈអាថិកំបាំងដែលធ្វើឱ្យការប្រើប្រាស់មិនអាចប្រព្រឹត្តទៅបានតាមធម្មតាឡើយ ។

~~មាត្រា ១១១.~~

~~អ្នកជួលត្រូវធានាការថែទាំទ្រព្យជាធម្មតា និង ត្រូវសងមកវិញក្នុងស្ថានភាពមួយស្របតាមស្ថានភាពនៃអចលនវត្ថុនិងសម្ភារៈនៅនឹងកន្លែង នៅពេលផុតកំណត់នៃកិច្ចសន្យាជួលដោយគិតទាំងតម្លៃនៃការខូចខាតដែលកើតពីការប្រើប្រាស់មិនធម្មតាលើកលែងការណើមានថែងដោយទ្វេភាគីឯកភាពសន្យា ។~~

~~មាត្រា ១១២.~~

~~ភាគីសន្យាបតីមិនត្រូវធ្វើសកម្មភាពប្តូរគ្រោយបទអ្វីដែលអាចធ្វើឱ្យបង្អាក់ប្តូរខានដល់ការអាស្រ័យផលរបស់អ្នកជួលផ្តុយពីភាគីសន្យាឡើយ ។~~

~~មាត្រា ១១៣.~~

~~បែបបទនៃកិច្ចសន្យាជួលអចលនវត្ថុដើម្បីប្រើប្រាស់សំរាប់ស្នាក់នៅ សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្មនិងសំរាប់កសិកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។~~

ផ្នែកទី ៥ : អំពីវិធានដី

មាត្រា ១១៤.-

សិទ្ធិនិងកាតព្វកិច្ចនៃកម្មសិទ្ធិករត្រូវបានកំរិតដោយវិធានដីទាំងឡាយសំដៅធានា ការពារផលប្រយោជន៍ទូទៅដែលកំណត់ដោយច្បាប់ ។

មាត្រា ១១៥.-

បែបបទសំណង់និងលក្ខខណ្ឌទាំងឡាយនៃការរៀបចំដែនដី និងនគរូបនីយកម្មចំពោះកម្មសិទ្ធិករនឹងកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១១៦.-

ការប្រើប្រាស់កម្មសិទ្ធិដែលមិនស្របតាមវិធានដី តែជាប់កិច្ចសន្យាមុនការប្រកាសឱ្យប្រើច្បាប់នេះមិនអាចប៉ះពាល់បានឡើយ ។ ប៉ុន្តែការប្រើប្រាស់នោះមិនអាចពង្រីកថែមនៅក្រោយពេលប្រកាសឱ្យប្រើវិធានដីដែលបានកំរិត ឬហាមឃាត់បានឡើយ ។

ក្នុងករណីបន្ទាន់ ឬតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈ ច្បាប់អាចបញ្ញត្តិថែមទៀតនូវការអនុវត្តបន្ទាន់នៃវិធានដីកំរិតពីការប្រើប្រាស់កម្មសិទ្ធិដែលមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ ។

ជំពូកទី ៨

អំពីសេវភាព

~~អំពីអចយចភេគនៃកម្មសិទ្ធិ~~

~~មាត្រា ១១៧.-~~

~~កម្មសិទ្ធិមានអវយវភោគ កាលណាការអាស្រ័យផលបានទៅបុគ្គលក្រៅពីកម្មសិទ្ធិករនៃទ្រព្យ ។ សិទ្ធិដែលនៅសល់សំរាប់កម្មសិទ្ធិករឈ្មោះថាអសោរកម្មសិទ្ធិ ។~~

~~មាត្រា ១១៨.-~~

~~រូបភាពនៃអវយវភោគនៃកម្មសិទ្ធិមាន : ផលបុបភោគ សិទ្ធិប្រើប្រាស់និងអាស្រ័យនៅនិងសេវភាព ។~~

~~ជំពូករងទី ១ : អំពីដំណើរការ~~

~~មាត្រា ១១៩.~~

~~ផលប្រយោជន៍ពីការអាស្រ័យផលនៃអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ~~
~~សំរាប់រយៈពេលមួយកំណត់មិនអោយលើសពីមួយអាយុជីវិតនៃអ្នកបានសិទ្ធិអាស្រ័យផលនោះឡើយ ។~~

~~មាត្រា ១២០.~~

~~ផលប្រយោជន៍បង្កើតឡើងដោយច្បាប់ឬដោយការព្រមព្រៀង ។ ផលប្រយោជន៍អាចបង្កើតឡើងដោយឥណទំណង់កាលក៏បាន ឬមានកំណត់កាលក៏បាន ឬរហូតដល់បំពេញបានសេចក្តីចង្អុរំលេចក្នុងឯកសារដែលបានកំណត់ក៏បាន ។~~

~~ប្រសិនបើលក្ខខណ្ឌនៃរយៈពេលមិនបានបញ្ជាក់~~
~~ផលប្រយោជន៍ត្រូវបានចាត់ទុកថាបង្កើតឡើងសំរាប់រយៈពេលមួយអាយុជីវិតនៃអ្នកទទួលសិទ្ធិផលប្រយោជន៍ ។~~

~~កិច្ចសន្យាផលប្រយោជន៍នឹងយកជាការបាន លុះត្រាតែបានធ្វើលិខិតតាមទំរង់បទមន្តឃាត់ឃាត ។~~
~~កិច្ចសន្យានេះមិនអាចដំទាស់តតែពីយុជនបាន លុះត្រាតែបានចុះបញ្ជីសុំរយោជ្ជិរួចហើយ ។~~

~~មាត្រា ១២១.~~

~~ផលប្រយោជន៍មានសិទ្ធិអាស្រ័យផលគ្រប់ប្រភេទ ជាផលធម្មជាតិ ជាផលស៊ើរិលដែលកើតចេញពីអចលនវត្ថុដែលខ្លួនមានសិទ្ធិ ។~~

~~មាត្រា ១២២.~~

~~ផលធម្មជាតិដែលជាប់នឹងដី នៅពេលចាប់ផ្តើមផលប្រយោជន៍ត្រូវបានទៅផលប្រយោជន៍ ។ ផលធម្មជាតិដែលមានស្ថានភាពដូចគ្នា នៅពេលចប់ផលប្រយោជន៍ត្រូវបានទៅអោរកម្មសិទ្ធិករដោយគ្មានការទូទាត់ទៅវិញទៅមកចំរាប់ការងារភ្ជួររាស់ប្តូរផ្លែឈើ ឬការងារអ្វីៗឡើយ ។ប៉ុន្តែបើមានអ្នកជួលឬអ្នកប្រវាស់រួចហើយ នៅពេលចាប់ផ្តើមឬនៅពេលចប់ផលប្រយោជន៍អ្នកជួលឬអ្នកប្រវាស់នេះមិនត្រូវបាត់បង់ចំណែកដែលត្រូវបានមកខ្លួននោះទេ ។~~

~~មាត្រា ១២៣.~~

~~ផលស៊ើរិលបានទៅផលប្រយោជន៍ពីតាមសេមាមាត្រទៅនឹងរយៈពេលនៃផលប្រយោជន៍ ។~~

~~មាត្រា ១២៤.~~

~~ផលប្រយោជន៍អាចអាស្រ័យផលដោយខ្លួនឯងផ្ទាល់នូវផលប្រយោជន៍ ឬជួល ឬប្រវាស់ ឬក៏ផ្ទេរសិទ្ធិរបស់ខ្លួនដោយយកថ្លៃ ឬដោយឥតយកថ្លៃឲ្យទៅអ្នកដទៃបាន ។~~

~~ក្នុងការណីជួលឬប្រវាស់ កិច្ចសន្យាមិនត្រូវកំណត់ឲ្យហួសពី ៣ (បី) ឆ្នាំឡើយ ។ ប្រសិនបើចង់ជួលឬប្រវាស់បន្ត កិច្ចសន្យាថ្មីត្រូវបញ្ចប់មុន ១ (មួយ) ឆ្នាំ នៃថ្ងៃចប់កិច្ចសន្យាផលប្រយោជន៍ ។~~

~~មាត្រា ១២៥.~~

~~ផលប្រយោជន៍អាស្រ័យផលពីការកើនដោយថាហេតុ ដោយស្លាប់ទៅលើដីដែលខ្លួនមានសិទ្ធិផលប្រយោជន៍ ។~~

~~មាត្រា ១២៦.~~

~~ផលប្រយោជន៍ប្រើប្រាស់នូវសេរីភាពនានានិងសិទ្ធិទាំងឡាយដែលកម្មសិទ្ធិការអាចអាស្រ័យផលបាន លើកលែងតែសិទ្ធិចាត់ចែង ។~~

~~មាត្រា ១២៧.~~

~~ផ្តល់បុព្វហេតុប្រើប្រាស់សិទ្ធិតាមរបៀបដូចគ្នានឹងកម្មសិទ្ធិការ~~
~~លើផលិតផលនៃកន្លែងយកថ្មដែលមានច្រាប់នៅលើដីដែលជាក់ជាផលបុព្វហេតុ ។~~

~~មាត្រា ១២៨.~~

~~ផលបុព្វហេតុត្រូវបានទទួលដោយផ្តែផ្តួលដែលត្រូវបង់ឱ្យកម្មសិទ្ធិការនៃដីពីសេម្ចទានិការណ្តែរ~~
~~ក្តុងបរិវេណជុំក្រោមសិទ្ធិផលបុព្វហេតុរបស់ខ្លួន ។~~

~~មាត្រា ១២៩.~~

~~អហេតុកម្មសិទ្ធិការមិនអាចធ្វើអ្វីឱ្យរំខានដល់សិទ្ធិរបស់ផលបុព្វហេតុ ទោះតាមរូបភាពណាក៏ដោយ ។~~

~~ចំណែកឯផលបុព្វហេតុវិញ នៅពេលអនុវត្តសិទ្ធិអាស្រ័យផលមិនអាចទាមទារលើណែនាំការកែលំអដែលខ្លួនអះអាងថាបានធ្វើនៅលើអចលនវត្ថុជាប់ផលបុព្វហេតុបានឡើយ~~
~~ទោះជាអចលនវត្ថុនោះបានកើនតម្លៃដោយសារការរៀបចំរបស់ខ្លួនក៏ដោយ ។~~
~~ផលបុព្វហេតុប្លុកទាយាទរបស់ជននេះអាចដកយកចេញបានឡើយ ផ្តាំឯកំនូរ~~
~~និងគ្រឿងតុបតែងផ្សេងៗដែលខ្លួនបានដាក់តាំងនៅក្នុងអគារ ប៉ុន្តែត្រូវរៀបចំកន្លែងនោះឱ្យមានស្ថានភាពដូចដើមឡើងវិញ ។~~

~~មាត្រា ១៣០.~~

~~ផលបុព្វហេតុត្រូវទទួលបន្ទុកតែលើការជួសជុលថែទាំប៉ុណ្ណោះ ។~~
~~ការជួសជុលធំៗជាបន្ទុករបស់អហេតុកម្មសិទ្ធិការលើកលែងតែការខូចខាតណាដែលបណ្តាលមកពីការខ្វះស្មោរតីថែទាំរបស់ផលបុព្វហេតុ~~
~~ចាប់តាំងទទួលបានផលបុព្វហេតុមក ។ ក្តុងការណីនេះផលបុព្វហេតុត្រូវធ្វើដោយខ្លួនឯង ។~~

~~ការជួសជុលធំៗគឺ ការជួសជុលជញ្ជាំងទ្រ ព្តែងទ្វារ ការរៀបឡើងវិញនូវធ្នើមជិបូលទាំងស្រុង~~
~~ការរៀបចំឡើងវិញនូវទំនប់ទឹកជញ្ជាំងទប់ដីឬទឹកនិងរបងទាំងមូល ។~~

~~ការជួសជុលក្រៅពីនេះជាការជួសជុលថែទាំ ។~~

~~មាត្រា ១៣១.~~

~~ទាំងអហេតុកម្មសិទ្ធិការ ទាំងផលបុព្វហេតុ ត្រូវកាតព្វកិច្ចសង់ឡើងវិញនូវអ្វីដែលបានទ្រុឌទ្រោម ឬអ្វីដែលបានបំផ្លាញ~~
~~ដោយការណីប្រធានសក្តិឡើយ ។~~

~~ប៉ុន្តែបើអចលនវត្ថុដែលបានដាក់ធានារ៉ាប់រងត្រូវវិនាសបណ្តាលមកពីមហន្តរាយដោយថាហេតុ~~
~~អហេតុកម្មសិទ្ធិការឬផលបុព្វហេតុអាចសុំយកថ្លៃធានារ៉ាប់រងទៅជួសជុល ឬសាងសង់ឡើងវិញបាន ។~~

~~មាត្រា ១៣២.~~

~~ផលបុព្វហេតុត្រូវទទួលក្តុងពេលដែលខ្លួនអាស្រ័យផលនូវបន្ទុកប្រចាំឆ្នាំនៃអចលនវត្ថុ ដូចជា ពន្ធ និងអាករលោប៊ុយ ធានារ៉ាប់រង~~
~~ដែលត្រូវបង់ ។~~

~~ផលបុព្វហេតុត្រូវបន្តអនុវត្តកិច្ចសន្យាធានារ៉ាប់រងធ្វើសាជាថ្មីឱ្យទាន់ពេលវេលា និង ចុះកិច្ចសន្យាធានារ៉ាប់រង ដែល មានប្រយោជន៍ ដល់អចលនវត្ថុ ជាផលបុព្វហេតុរបស់ខ្លួន ទោះជាកិច្ចសន្យាធានារ៉ាប់រងនោះកំពុងដំណើរការ នៅពេលដែលផលបុព្វហេតុ~~
~~បានចាប់ផ្តើមហើយក្តីឬជាកិច្ចសន្យាធានារ៉ាប់រងដែលត្រូវឱ្យធ្វើនាពេលក្រោយដោយអហេតុកម្មសិទ្ធិការក្តី ។~~

~~មាត្រា ១៣៣.~~

~~ក្នុងពេលដំណើរការផ្តល់បុព្វភោគ បើមានតតិយជនណាមកប្រៀតប្រៀនសិទ្ធិនៃអតោរកម្មសិទ្ធិការ ផ្តល់បុព្វភោគីត្រូវជូនដំណឹងទៅអតោរកម្មសិទ្ធិការបើមិនដូច្នោះទេ ផ្តល់បុព្វភោគីនោះត្រូវទទួលខុសត្រូវលើការខូចខាតដែលបណ្តាលមកពីរឿងនោះ ចំពោះអតោរកម្មសិទ្ធិការដូចការណើដែលខ្លួនបានធ្វើឱ្យខូចខាតដោយផ្ទាល់ ។~~

~~មាត្រា ១៣៤.~~

~~ផ្តល់បុព្វភោគផុតវេលាត់ :~~

- ~~ដោយមរណភាពនៃផ្តល់បុព្វភោគី~~
- ~~ដោយការផុតកំណត់វេយ:តាមប្រការសេចក្រែចបានន្លូវលែក្នុខណ្ឌដែលបានកំណត់ ។~~
- ~~ដោយកិច្ចព្រមលះបង់សិទ្ធិរបស់ផ្តល់បុព្វភោគី~~
- ~~ដោយអចលនវត្ថុដែលជាប់ផ្តល់បុព្វភោគ ត្រូវអន្តរាយទាំងស្រុង~~
- ~~ដោយសេចក្តីបំរែចរបស់តុលាការស្របតាមបទប្បញ្ញត្តិនៃមាត្រា ១៣៥ នៃច្បាប់នេះ ។~~

~~មាត្រា ១៣៥.~~

~~ការបាត់បង់សិទ្ធិរបស់ផ្តល់បុព្វភោគី អាចនឹងត្រូវបានប្រកាសដោយតុលាការតាមបណ្តឹងរបស់អតោរកម្មសិទ្ធិការដោយហេតុថាផ្តល់បុព្វភោគីបាននំតោរលើការអាប្រ័យផល ពិសេសប្រសិនបើផ្តល់បុព្វភោគីនោះធ្វើឱ្យមានវិការភាពលើអចលនវត្ថុឬទុកឱ្យអចលនវត្ថុខូចខាតដោយមិនថែទាំ ។~~

~~ក្នុងការណើនេះ ម្ចាស់បំណុលនៃផ្តល់បុព្វភោគីមានសិទ្ធិប្តឹងទៅតុលាការដើម្បីបុំបន្តសិទ្ធិរបស់ផ្តល់បុព្វភោគីដោយធានាការជួសជុលនូវវិការភាពដែលមាននិងការធានាសំរាប់អនាគត ។~~

~~ដោយយោលទៅតាមកាល:ទេសៈ និងហេតុផលផ្សេងៗតុលាការអាចប្រកាសការរលត់ជាបន្ថែនៃផ្តល់បុព្វភោគឬក្រោនតែបង្គាប់ឱ្យប្រគល់អចលនវត្ថុឱ្យអតោរកម្មសិទ្ធិការដោយបង់ប្រាក់ប្រចាំឆ្នាំឱ្យផ្តល់បុព្វភោគី ឬសិទ្ធិវន្តរបស់ជនរនេះនូវទឹកប្រាក់មួយចំនួនជាកំណត់រហូតដល់បញ្ចប់ផ្តល់បុព្វភោគ ។~~

~~មាត្រា ១៣៦.~~

~~ការលក់អចលនវត្ថុដែលកំពុងជាប់ផ្តល់បុព្វភោគដោយអតោរកម្មសិទ្ធិការ
មិនធ្វើឱ្យមានការផ្លាស់ប្តូរណាមួយចំពោះផ្តល់បុព្វភោគីដែលកំពុងបន្តប្រើប្រាស់សិទ្ធិរបស់ខ្លួននោះទេ
លើកលែងតែមានការលះបង់ដោយជាក់លាក់ពីផ្តល់បុព្វភោគី ។~~

~~មាត្រា ១៣៧.~~

~~ប្រសិនបើផ្តល់បុព្វភោគមានតែលើអគារ ហើយអគារនោះត្រូវអន្តរាយដោយថាហេតុ សិទ្ធិរបស់ផ្តល់បុព្វភោគីត្រូវរលត់ ហើយផ្តល់បុព្វភោគីមិនអាចទាមទារសិទ្ធិផ្តល់បុព្វភោគលើដីឬលើសម្ភារ:សំណង់នោះទេ ។~~

~~ប៉ុន្តែបើផ្តល់បុព្វភោគមានលើដីនិងលើអគារ ហើយបើអគារនោះត្រូវអន្តរាយផ្តល់បុព្វភោគនៅមានលើដីដដែល ។~~

~~ជំពូកទី ២ : អំពីសិទ្ធិប្រើប្រាស់និងអាប្រ័យផល~~

~~មាត្រា ១៣៨.~~

~~បិទ្ធិប្រើប្រាស់គឺជាសិទ្ធិទទួលយកពីដីនូវបរិមាណផលចាំបាច់សំរាប់សេចក្តីត្រូវការរបស់អត្តភាពហាក់និងគ្រួសាររបស់ខ្លួន ។~~

~~បិទ្ធិអាស្រ័យនៅគឺជាសិទ្ធិកាន់កាប់ផ្ទះនូវចំណែកចាំបាច់សំរាប់រស់នៅរបស់អត្តភាពហាក់និងគ្រួសាររបស់ខ្លួន ។~~

~~ទោះបីថ្ងៃក្រោយមក អត្តភាពហាក់នោះមានប្តី ប្រពន្ធក្តីឬមានកូនក្តី ក៏សិទ្ធិទាំងពីរនេះនៅតែមានដល់អត្តភាពហាក់ដដែល ។~~

~~មាត្រា ១៣៩.~~

~~បិទ្ធិប្រើប្រាស់និងអាស្រ័យនៅ កើតឡើងនិងបាត់បង់ទៅវិញ្ញេ តាមបែបនៃផលបុបផ្លោគដែរ ។~~

~~បិទ្ធិនៃអ្នកប្រើប្រាស់និងអ្នកអាស្រ័យនៅកំណត់ដោយខចែងក្នុងកិច្ចសន្យាតាមរូបមន្តលិខិតយ៉ាងណាក្តី ឬដោយបញ្ញត្តិនៃច្បាប់ដែលចែងអំពីសិទ្ធិនេះ ។~~

~~មាត្រា ១៤០.~~

~~អត្តភាពហាក់នៃសិទ្ធិប្រើប្រាស់ឬសិទ្ធិអាស្រ័យនៅ មិនអាចផ្ទេរឬជួលសិទ្ធិរបស់ខ្លួនទៅអ្នកផ្សេងទៀតបានឡើយ ។~~

~~បិទ្ធិប្រើប្រាស់និងអាស្រ័យនៅជាសិទ្ធិផ្តាស់ខ្លួនរបស់បុគ្គល ។ សិទ្ធិនេះបញ្ចប់នៅពេលមរណភាពនៃអត្តភាពហាក់ ឬដោយអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យា ។~~

~~មាត្រា ១៤១.~~

~~ប្រសិនបើអត្តភាពហាក់នៃសិទ្ធិប្រើប្រាស់ប្រមូលយកផលទាំងអស់នៃដីឬប្រសិនបើអត្តភាពហាក់នៃសិទ្ធិអាស្រ័យនៅកាន់កាប់ពេលជាង១ទាំងមូល អ្នកនោះត្រូវទទួលបន្ទុកចំណាយសោហ៊ុយក្នុងការដាំដុះ ឬការជួសជុលថែទាំនិងបង់ពន្ធអាករ និងសោហ៊ុយធានារ៉ាប់រងដូចផលបុបផ្លោគដែរ ។~~

~~ប្រសិនបើអត្តភាពហាក់យកតែចំណែកណាមួយនៃផល ឬកាន់កាប់តែមួយចំណែកនៃពេលជាង១ អ្នកនោះត្រូវចូលរួមចំណាយទៅតាមសមាមាត្រដែល ខ្លួនអាស្រ័យផលនោះ ។~~

ផ្នែកទី ៣ : អំពីសេវភាព

~~មាត្រា ១៤២.~~

~~សេវភាពដីគឺជាបន្ទុកដែលផ្តាក់ទៅលើដីមួយ ហៅដីបំរើឬដីក្រោមសំរាប់ការប្រើប្រាស់ និងប្រយោជន៍នៃដីមួយទៀតហៅដីប្រើឬដីលើដែលជារបស់កម្មសិទ្ធិការផ្សេងទៀត ។~~

~~មាត្រា ១៤៣.~~

~~សេវភាពកើតពីធម្មជាតិ កើតពីច្បាប់ ឬកើតពីការព្រមព្រៀងអាស្រ័យដោយស្ថានភាពនៃទីកន្លែង ដោយការកំណត់របស់ច្បាប់ ឬដោយការព្រមព្រៀងរវាងកម្មសិទ្ធិការ ។~~

អនុផ្នែកទី ១ : អំពីសេវភាពកើតពីធម្មជាតិ

~~មាត្រា ១៤៤.~~

~~ដីក្រោមត្រូវទទួលទឹកដែលហូរពោតធម្មជាតិពីដីលើ ។~~

~~កម្មសិទ្ធិការនៃដីក្រោមមិនអាចលើកទំនប់ ឬ រាំងឬការពារទៃផ្សេងទៀតទប់ការហូរនេះបានឡើយ ។~~

~~កម្មសិទ្ធិការនៃដីលើមិនអាចធ្វើអ្វីដែលធ្វើឲ្យកាន់តែធ្ងន់ដល់សេវភាពនៃដីក្រោមបានឡើយ ។~~

~~**មាត្រា ១៤៥.-**~~

~~កម្មសិទ្ធិករនៃដីលើមានសិទ្ធិប្រើប្រាស់និងចាត់ចែងទឹកភ្លៀងដែលធ្លាក់មកលើដីរបស់ខ្លួន ព្រមទាំងទឹកដែលមានប្រភពផុសឡើងនៅទីនោះលើកលែងតែក្នុងករណីដែលមានចែងក្នុងវាក្យខណ្ឌចុងក្រោយនៃមាត្រា ១៤៤ ។~~

~~**មាត្រា ១៤៦.-**~~

~~កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់ផ្លូវទឹកហូរត្រូវទុកឱ្យទឹកហូរទៅលើដីជិតខាង ហើយកម្មសិទ្ធិករនៃដីជិតខាងក៏ត្រូវមានកាតព្វកិច្ចដូចគ្នាចំពោះដីនៅឆ្ងាយទៅតាមតម្រូវការនៃកសិកម្ម ។~~

អនុផ្នែកទី ២ : អំពីសេវភាពកើតពីច្បាប់

~~**មាត្រា ១៤៧.-**~~

~~បទដ្ឋានកើតពីច្បាប់មានគោលដៅប្រើប្រាស់ជាប្រយោជន៍សាធារណៈឬជាប្រយោជន៍ឯកជន ។~~

~~បទដ្ឋានកើតពីច្បាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈត្រូវកំណត់ដោយច្បាប់ឬដោយបទបញ្ជាពិសេសដែលបង្កើតឡើងលើកម្មសិទ្ធិករ ។~~

~~បទដ្ឋានកើតពីច្បាប់ប្រើប្រាស់ជាប្រយោជន៍ឯកជនកំណត់ព្រំដែន ដែលកម្មសិទ្ធិការអាចធ្វើសកម្មភាពមួយចំនួនក្នុងដីរបស់ខ្លួនលើកលែងតែធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិករដីជិតខាង ។~~

មាត្រា ១៤៨.-

ការកំណត់ព្រំដី និង កម្មសិទ្ធិដែលស្ថិតនៅតាមបណ្តោយផ្លូវសាធារណៈត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្តីត្រូវការជាក់ស្តែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្តីត្រូវការនៃការធ្វើចរាចរ ។

មុននឹងធ្វើរបងឬកសាងអគារប្រភេទណាក៏ដោយដែលស្ថិតនៅជាប់នឹងផ្លូវសាធារណៈ កម្មសិទ្ធិករចាំបាច់ត្រូវតែត្រួតពិនិត្យមើលនូវភាពសមស្របនៃអគារនោះជាមួយនឹងប្លង់តម្រង់ជួរប្រសិនបើមាន ។
រាល់លិខិតអនុញ្ញាតសាងសង់ត្រូវតែយកចិត្តទុកដាក់ដល់ខ្សែតម្រង់ជួរដែលមានរួចហើយ ។

អាជ្ញាធរមានសមត្ថកិច្ចអាចសំរេចធ្វើការផ្លាស់ប្តូរទំហំផ្លូវបាន តាមតម្រូវការចាំបាច់សំរាប់ផលប្រយោជន៍សាធារណៈ ។ នៅពេលដែលអាជ្ញាធរធ្វើការសំរេចពង្រីកទំហំផ្លូវ សំណង់ទាំងឡាយដែលស្ថិតនៅលើបន្ទាត់តម្រង់ជួរត្រូវបន្តយទៅក្រោយ ។ បើជារបងធម្មតាឬជាសំណង់ស្រាល អាជ្ញាធរតម្រូវឱ្យធ្វើការរំកិលចេញ ។ ប្រសិនបើជាអចលនវត្ថុដែលមិនអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ កែសំរួលរុះរើបានអចលនវត្ថុនោះត្រូវបិតក្នុងសភាពដដែលសិន រហូតដល់ពេលអាជ្ញាធរមានសមត្ថកិច្ចសំរេចអំពីការពង្រីកដែលបានគ្រោងទុក ។ ការដកហូតកម្មសិទ្ធិមួយចំណែកឬទាំងស្រុងអាចប្រព្រឹត្តទៅបានដោយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ ។ ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ ព្រមទាំងរបងនិងសំណង់ទាំងឡាយដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ ម្ចាស់កម្មសិទ្ធិមានសិទ្ធិទាមទារឱ្យសងការខូចខាតរបស់ខ្លួន ។

~~**មាត្រា ១៤៩.-**~~

~~កម្មសិទ្ធិការដែលចង់ផ្ទេរនៅលើដីរបស់ខ្លួនត្រូវកិច្ចការដែលមានលក្ខណៈទំនាងដល់ដីជិតខាងដូចជាការខួងអណ្តូង ការជីកស្រះដីការជីករុករកការពារទុកវត្ថុប្រកបដោយគ្រោះថ្នាក់ដែលនាំឱ្យរំខានប្លន់ឆ្លៀសសុខភាពត្រូវអនុលោមតាមបញ្ញត្តិនៃបទបញ្ជាពិសេសស្តីពីការកំណត់ចម្ងាយដែលត្រូវប្រតិបត្តិ ឬស្តីពីការប្រដែលផ្ទៃសំរាប់ទប់ជ្រៃ ។~~

~~មាត្រា ១៥០.~~

~~កម្មសិទ្ធិការមិនអាចនឹងធ្វើប្រហោងទ្វារឬបង្អួច ក៏ឃើញប្លយ៉ត្រង់ចំគ្នាទៅវិញទៅមកចម្ងាយតិចជាងពីរម៉ែត្រពីដីអ្នកជិតខាងបានទេ ។~~

~~មាត្រា ១៥១.~~

~~កម្មសិទ្ធិការមិនអាចដាំដើមឈើធំ តូច មានកំពស់លើសពី ២ (ពីរ) ម៉ែត្រ នៅប្របព្រំដីជាប់គ្នាដែលមានចម្ងាយតិចជាងពីរម៉ែត្រពីព្រំដីបានទេ បើមិនដូច្នោះទេនឹងត្រូវបង្ខំឱ្យឃាត់ចេញ ក្រសួងបើមានបណ្តឹងពីកម្មសិទ្ធិការដែលមានប្រយោជន៍ក្នុងរឿងនេះ ។~~

~~មាត្រា ១៥២.~~

~~កម្មសិទ្ធិការដែលដីរបស់ខ្លួនត្រូវបានបិទជិតនិងគ្មានច្រកចេញចូលទៅផ្លូវសាធារណៈឬមានច្រកមិនគ្រប់គ្រាន់សំរាប់អាជីវកម្មកសិកម្ម ឧស្សាហកម្មនៃកម្មសិទ្ធិរបស់ខ្លួន មានសិទ្ធិស្នើសុំបើកផ្លូវឆ្លងតាមដីអ្នកជិតខាងខ្លួន ដោយត្រូវចេញសំណងតាមសមមាត្រចំពោះការខូចខាតដែលបណ្តាលមកពីកិច្ចការនោះ ។~~

~~មាត្រា ១៥៣.~~

~~ជាពាក្យការណ៍ ផ្លូវដូចមានចែងក្នុងមាត្រា ១៥២ ត្រូវយកកន្លែងណាដែលមានចម្ងាយជិតជាងគេពីដីចិទជិតទៅផ្លូវសាធារណៈ ប៉ុន្តែត្រូវគំណត់កន្លែងណាដែលមានការខូចខាតតិចបំផុតសំរាប់កម្មសិទ្ធិការនៃដីដែលត្រូវទទួលរង ។~~

~~មាត្រា ១៥៤.~~

~~ប្រសិនបើដីចិទជិតកើតឡើងពីការបែងចែកដីតាមរយៈការលក់ ការដូរ ការចែកឬពីកិច្ចសន្យាផ្សេងទៀត ការបើកផ្លូវឆ្លងអាត់អោចប៉ុន្តែនៅលើដីដែលនៅសល់ពីការបែងចែក ។~~

~~ប៉ុន្តែបើដីដែលនៅសល់ពុំអាចបង្កើតបានជាផ្លូវត្រប់គ្រាន់ បញ្ញត្តិនៃមាត្រា ១៥២ និង មាត្រា ១៥៣ នៅតែអនុវត្តបានដដែល ។~~

~~មាត្រា ១៥៥.~~

~~កម្មសិទ្ធិការដែលចង់ប្រើទឹកដែលខ្លួនមានសិទ្ធិដើម្បីប្រើប្រាស់និងត្រូវចរត្រូវផ្ទេរបស់ខ្លួន អោចទទួលបានផ្លូវនាំទឹកឆ្លងអាត់ដីដែលស្ថិតនៅចន្លោះកណ្តាលបាន តែត្រូវចំណាយសោហ៊ុយសងការខូចខាតឱ្យម្ចាស់ដីនោះ ។~~

~~មាត្រា ១៥៦.~~

~~កម្មសិទ្ធិការអាចបញ្ចេញទឹកត្រូវចរត្រូវចេញហើយចេញពីដីខ្លួនឆ្លងអាត់ដីក្រោមបាន តែត្រូវចំណាយសោហ៊ុយសងការខូចខាត ។~~

~~មាត្រា ១៥៧.~~

~~កម្មសិទ្ធិការនៃដីលិចទឹកទាំងស្រុងឬមួយចំណែក អាចបង្ហូរទឹកមិនល្អចេញបានតែត្រូវធ្វើឱ្យបានត្រឹមត្រូវតាមវិធីអនាម័យ ។~~

~~មាត្រា ១៥៨.~~

~~កម្មសិទ្ធិការនៃដីជាប់មាត់ទឹកដែលចង់ប្រើប្រាស់ទឹកដើម្បីស្រោចស្រពដីរបស់ខ្លួន អាចមានសិទ្ធិធ្វើសែលុះការប្តឹងទៅលើដីដែលស្ថិតនៅមាត់ទឹកខ្នងទៀតដើម្បីរៀបចំយកទឹកតែត្រូវទទួលបន្ទុកចេញសោហ៊ុយនៃការខូចខាត ។~~

~~មាត្រា ១៥៩.~~

~~កម្មសិទ្ធិការនៃដីដែលត្រូវឱ្យធ្វើការអ្វីលើដីខ្លួននោះ អាចនឹងបុំប្រើទំនប់ឬរបាំងទឹកនោះបាន ដោយត្រូវចេញសោហ៊ុយធ្វើ និងសោហ៊ុយថែទាំតាក់តែងសេ ។ កម្មសិទ្ធិការនេះមិនត្រូវទំនារសោហ៊ុយថ្លៃដីឡើយ បើបានទទួលហើយត្រូវតែបង្វិលសងវិញ។~~

~~អនុផ្នែកទី ៣ : អំពីសេវភាពកើតពីការព្រមព្រៀង~~

~~មាត្រា ១៦០.~~

~~ត្រូវបានអនុញ្ញាតឱ្យកម្មសិទ្ធិការបង្កើតនៅលើដីរបស់ខ្លួនដូរវាស់សេវភាពជាគុណប្រយោជន៍ដល់កម្មសិទ្ធិការនៃដីផ្សេងទៀតឱ្យតែសេវភាពនោះមិនផ្ទុយពីសេណ្តាប់ធ្នាប់សោធារណៈ ។~~
~~ការប្រើប្រាស់និងរំលោភសេវភាពនៃសេវភាពនេះត្រូវកំណត់ដោយកិច្ចព្រមព្រៀងដែលបានបង្កើតសេវភាពនោះ ។~~

~~មាត្រា ១៦១.~~

~~សេវភាពកើតពីការព្រមព្រៀងអាចបង្កើតឡើងបានតែពេលមានចិញ្ចើមរបាំងទឹកប៉ុណ្ណោះ ។សេវភាពនេះមិនអាចពាយែជនជំទាស់បានទេ ក្រោយពីការចុះសេខាធិការក្តាបញ្ជីសុំរយោជ ។~~

~~ទំនាក់ទំនងសេវភាពរវាងដីបំរើនិងដីប្រើនឹងត្រូវចប់នៅពេលដែលដីណាមួយក្នុងចំណោមដីទាំងពីរត្រូវបានផ្ទេរឱ្យពាយែជនណាម្នាក់បើការរក្សាទុកសេវភាពនោះមិនបានចែងច្បាស់ក្នុងលិខិតផ្ទេរកម្មសិទ្ធិទេ ។~~

~~មាត្រា ១៦២.~~

~~កម្មសិទ្ធិការដែលបានបង្កើតសេវភាពលើដីរបស់ខ្លួនត្រូវបានចាត់ទុកថាយល់ព្រមវាស់អ្វីដែលចាំបាច់សំរាប់សេវភាពនោះ ។ សេវភាពនៃការយកទឹកបង្កើតឡើងនៅកន្លែងប្រភពទឹក អនុញ្ញាតឱ្យអ្នកយកទឹកមានសិទ្ធិឆ្លងកាត់ដីដែលមានប្រភពទឹកនោះបាន ។~~

~~មាត្រា ១៦៣.~~

~~កម្មសិទ្ធិការនៃដីប្រើមានសិទ្ធិធ្វើវាស់ការចាំបាច់ផ្សេងៗ លើដីបំរើដើម្បីប្រើនិងរក្សាទុកសេវភាពបាន ។~~

~~មាត្រា ១៦៤.~~

~~ការចាំបាច់សំរាប់ប្រើនិងរក្សាទុកសេវភាពគឺជាសោហ៊ុយនៃកម្មសិទ្ធិការដីប្រើ លើកលែងតែមានការព្រមព្រៀងក្តាផ្សេងពីនេះ ។~~

~~មាត្រា ១៦៥.~~

~~កម្មសិទ្ធិការនៃដីបំរើមិនអាចធ្វើអ្វីដែលមានបំណងបន្ថយការប្រើប្រាស់សេវភាព ឬធ្វើឱ្យសេវភាពមិនអាចប្រើបានឡើយ ។ កម្មសិទ្ធិការ នៃដីបំរើមិនអាចប្តូរស្ថានភាពនៃការប្រើប្រាស់សេវភាពដែលបានកំណត់ពីដំបូងមកបានទេ ។~~
~~ប៉ុន្តែបើទុកសេវភាពក្នុងស្ថានភាពដើមនាំឱ្យកម្មសិទ្ធិការនៃដីបំរើចំណាយប្រាក់លើការជួសជុលថែទាំច្រើន~~

~~កម្មសិទ្ធិការនៃដីបំរើអាចសុំដាក់សេវាភាពជំនួសនៅទីផ្សេងទៀតបានដែលប្រសួលប្រើដូចគ្នា~~
~~ហើយកម្មសិទ្ធិការនៃដីប្រើមិនអាចបដិសេធបានឡើយ ។~~

~~មាត្រា ១៦៦.~~

~~ចំណែកដែកម្មសិទ្ធិការនៃដីប្រើ អាចប្រើប្រាស់សេវាភាពតែក្នុងព្រំដែនដែលបានកំណត់ក្នុងកិច្ចសន្យា~~
~~ដោយមិនអាចធ្វើនៅលើដីបំរើ ឬដីរបស់ខ្លួនឱ្យមានការប្រែប្រួលណាមួយដែលអាចមានឥទ្ធិពលធ្ងន់ធ្ងរដល់ស្ថានភាពនៃដីបំរើបានឡើយ ។~~

អនុផ្នែកទី ៤ : អំពីការផុតរលត់នៃសេវភាព

~~មាត្រា ១៦៧.~~

~~សេវភាពផុតរលត់ដោយ :~~

- ~~ការបញ្ចប់កិច្ចព្រមព្រៀងដែលបង្កើតសេវភាពនោះ~~
- ~~ដីប្រើនិងដីបំរើធ្លាក់ក្នុងដៃកម្មសិទ្ធិការតែម្នាក់ ឬ~~
- ~~មហន្តរាយទាំងស្រុងនៃដីដែលជាទីតាំងសេវភាពនោះ ។~~

មាតិកាទី ៤

អំពីសហកម្មសិទ្ធិ

~~អំពីកម្រងច្បាប់នៃកម្មសិទ្ធិ~~

~~ជំពូកទី ៩~~

~~អំពីកម្មសិទ្ធិអចិន្ត្រៃយ៍~~

~~មាត្រា ១៦៨.~~

~~កម្មសិទ្ធិអចិន្ត្រៃយ៍គឺជាកម្មសិទ្ធិលើទ្រព្យតែមួយដែលជារបស់បុគ្គលច្រើននាក់ ។ បុគ្គលទាំងនោះជាកម្មសិទ្ធិការអចិន្ត្រៃយ៍ ។~~
~~កម្មសិទ្ធិការអចិន្ត្រៃយ៍ម្នាក់ៗ មានចំណែករបស់ខ្លួនក្នុងទ្រព្យនោះ ប៉ុន្តែទ្រព្យនោះមិនអាចពុះចែកគ្នាបានឡើយ ។~~

~~មាត្រា ១៦៩.~~

~~ភាគហ៊ែនៃកម្មសិទ្ធិអចិន្ត្រៃយ៍ចាត់ទុកជាសើ្មគ្នា ។ ក្នុងការណីដែលការហ៊ែនចែកទ្រព្យមិនសើ្មគ្នា~~
~~កម្មសិទ្ធិការម្នាក់ៗមានសិទ្ធិនិងបន្ទុកសមាមាត្រទៅនឹងចំណែករបស់ខ្លួន ។~~
~~កម្មសិទ្ធិការម្នាក់ៗអាចលក់ចំណែកឬចុះកិច្ចសន្យាផ្សេងៗលើចំណែករបស់ខ្លួនបាន~~
~~ហើយម្ចាស់បំណុលរបស់គេម្នាក់ៗអាចរឹបអូសចំណែកនៃទ្រព្យរបស់អ្នកនោះបាន ។~~

~~មាត្រា ១៧០.~~

~~កម្មសិទ្ធិការអរិភាពគ្រប់គ្រងរួមលើកម្មសិទ្ធិអរិភាព លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះ ។~~

~~កម្មសិទ្ធិការអរិភាពម្នាក់ៗមាននាទី គ្រប់គ្រងដោ ធម្មតាដូចជាការជួសជុលថែទាំនិងការជាំដុះ~~

~~បើកម្មសិទ្ធិការអរិភាពរាគច្រើនមិនបានចាត់ឱ្យធ្វើអ្វីផ្សេងទៀតទេ ។~~

~~កិច្ចការសំខាន់ៗដូចជាការប្តូរជំណាំនិងការជួសជុលធំៗអាចសម្រេចបាន~~

~~លុះត្រាតែរាគច្រើននៃកម្មសិទ្ធិការអរិភាពដែលមានចំណែករួមគ្នាលើសពីពាក់កណ្តាលនៃទ្រព្យនោះបានយល់ព្រម ។~~

~~មាត្រា ១៧១.~~

~~កម្មសិទ្ធិការអរិភាពម្នាក់ៗត្រូវយកចិត្តទុកដាក់ថែទាំនិងការពារប្រយោជន៍រួម ។ កម្មសិទ្ធិការអរិភាពអាស្រ័យផលពីទ្រព្យ~~

~~និងប្រើប្រាស់ទ្រព្យក្នុងព្រំដែនដែលមិនប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិការអរិភាពដទៃឡើយ ។~~

~~ការព្រមព្រៀងគ្នាពីកម្មសិទ្ធិការអរិភាពទាំងអស់ដាការចាំបាច់ សំរាប់ការផ្ទេរសិទ្ធិ~~

~~ការបង្កើតសិទ្ធិភណ្ឌិកឬការផ្តាស់ប្តូរពោលដៅនៃទ្រព្យលើកលែងតែមានវិធានផ្សេងពីនេះ ។~~

~~មាត្រា ១៧២.~~

~~ចំណាយលើការគ្រប់គ្រង ការបង់ពន្ធនិងបន្ទុកផ្សេងទៀតលើទ្រព្យអរិភាព~~

~~ត្រូវទទួលរ៉ាប់រងដោយកម្មសិទ្ធិការអរិភាពទាំងអស់តាមសមាមាត្រនៃចំណែករៀងៗខ្លួន លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ ។~~

~~មាត្រា ១៧៣.~~

~~ភ្នាក់ងារណាមួយអាចត្រូវបានបង្ខំឱ្យនៅក្នុងអរិភាពកម្មបានទេ ។ កម្មសិទ្ធិការអរិភាពម្នាក់ៗ~~

~~អាចទាមទារឱ្យបែងចែកទ្រព្យអរិភាពនោះបាន ។~~

~~កម្មសិទ្ធិការអរិភាពទាំងឡាយអាចរក្សាទុកជាបណ្តោះអាសន្នដូរស្ថានភាពនៃអរិភាពកម្ម~~

~~ប៉ុន្តែស្ថានភាពបែបនេះមិនអាចចាប់បង្ខំឱ្យលើសពីរយៈពេល ៥ (ប្រាំ) ឆ្នាំបានឡើយ លើកលែងតែមានកិច្ចព្រមព្រៀងថ្មី ។~~

~~មាត្រា ១៧៤.~~

~~អរិភាពកម្មត្រូវចប់ដោយការបែងចែកទ្រព្យតាមរូបដើម ឬដោយការលក់ទ្រព្យ~~

~~ហើយចែកថ្លៃឬដោយកម្មសិទ្ធិការអរិភាពម្នាក់ឬច្រើននាក់ទទួលយកចំណែករបស់អ្នកដទៃ ។~~

~~ប្រសិនដាកម្មសិទ្ធិការអរិភាពមិនយល់ព្រមតាមអំពើរបៀបនៃការចែក~~

~~អ្នកទាំងនោះត្រូវប្តឹងទៅតុលាការដែលនឹងរៀបចំចែកទ្រព្យ ឬបើទ្រព្យនោះ តាលបើចែកទៅនាំឱ្យថយថ្លៃច្រើន~~

~~តុលាការអាចបង្គាប់ឱ្យលក់ទ្រព្យទាំងមូលទៅឱ្យតពីយជនឬទៅឱ្យកម្មសិទ្ធិការអរិភាពណាម្នាក់ក៏បាន ។~~

ជំពូកទី ១០
អំពីសហកម្មសិទ្ធិ

មាត្រា ១៧៥.-

សហកម្មសិទ្ធិគឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់បែងចែកតាមឡូត៍ ដែលម្នាក់ៗបានមួយចំណែកជាឯកជន ហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម ។

មាត្រា ១៧៦.-

សហកម្មសិទ្ធិករទាំងឡាយអាចរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រង និង វិធាននៃការថែទាំព្រមទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ជាពិសេសចំពោះផ្នែករួមដោយគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។
ក្នុងករណីដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះទេ សហកម្មសិទ្ធិត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយដែលបានកំណត់ពីមាត្រា ១៧៧ ដល់មាត្រា១៨៥ នៃច្បាប់នេះ ។

មាត្រា ១៧៧.-

សហកម្មសិទ្ធិករទាំងឡាយមានសិទ្ធិពេញលេញលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួមដោយសហកម្មសិទ្ធិករដទៃទៀត។ សហកម្មសិទ្ធិករទាំងនោះអាចផ្ទេរសិទ្ធិដោយសេរី ជួលឬបង្កើតផលុបភោគរៀបចំសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ដាក់ប៊ីប៉ូតែក ដាក់បញ្ចាំនូវចំណែកឯកជនរបស់ខ្លួន ។ ប៉ុន្តែ សហកម្មសិទ្ធិករមិនអាចបង្កើតសេវភាពលើចំណែកឯកជនរបស់ខ្លួននោះបានទេ ។

មាត្រា ១៧៨.-

រាល់ចំណែកនៃអគារឬដីសម្រាប់ការប្រើប្រាស់ផ្តាច់មុខនៃសហកម្មសិទ្ធិករណាមួយបង្កើតបានជាចំណែកឯកជន។
វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុត្រូវកំណត់អំពីប្រភេទនិងទំហំនៃចំណែកនោះ ។

មាត្រា ១៧៩.-

រាល់ចំណែកនៃអគារឬដីសម្រាប់ការប្រើប្រាស់ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងឡាយ ឬសហកម្មសិទ្ធិករខ្លះក្នុងចំណោមនោះបង្កើតបាន ជាចំណែករួម ។

ទ្រព្យរួមមានជាអាទិ :

- ដី ទីធ្លា ឧទ្យាននិងសួនច្បារ ផ្លូវ ច្រកចេញចូល
- ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្តាញទឹក ភ្លើង បណ្តាញឧស្ម័នដែលអាចឆ្លងកាត់ចំណែកឯកជន
- ទូរួម បំពង់និងក្បាលបំពង់ផ្សែង
- ទីកន្លែងនៃសេវារួម ។

សិទ្ធិបន្ទាប់បន្សំខាងក្រោមនេះក៏ត្រូវទុកជាកម្មសិទ្ធិរួមដែរ :

- សិទ្ធិជីករុករកវត្ថុធាតុដែលមានក្នុងដី
- សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យានឬសួនច្បារដែលជាចំណែករួម

- សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យានឬសួនច្បារទាំងនោះ
- សិទ្ធិនៃអឌ្ឍសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ
- សិទ្ធិលើកបន្តឱ្យខ្ពស់នូវអគារសំរាប់ប្រើប្រាស់រួមឬដែលមានកន្លែងច្រើនបង្កើតបានជាចំណែកឯកជនផ្សេងគ្នា ។

គ្មានករណីណាមួយដែលកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុតអាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬ លក់សិទ្ធិនៃការលើកបន្តនេះឡើយ ។

- បទប្បញ្ញត្តិនេះមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ ។

មាត្រា ១៨០.-

សហកម្មសិទ្ធិករដែលធ្វើឱ្យប៉ះពាល់ដល់ចំណែករួមនៃអគារឬដីដោយបានកែប្រែដើម្បីការប្រើប្រាស់ជាឯកជនឬសំរាប់លក់នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ ។ សហកម្មសិទ្ធិករនោះត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ២៥៧ នៃច្បាប់នេះ ។

ជនក្រៅពីសហកម្មសិទ្ធិករដែលដណ្តើមយកចំណែករួមសម្រាប់ជាទីលំនៅឯកជនរបស់ខ្លួន
នឹងត្រូវបង្ខំឱ្យសងកន្លែងដែលកាន់កាប់ខុសច្បាប់ហើយត្រូវធ្វើឱ្យមានសភាពដូចដើមវិញ ។

ក្នុងករណីណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចមិនអាចចេញប័ណ្ណសំគាល់សិទ្ធិឱ្យបុគ្គលនោះបានឡើយ ពុំនោះទេនឹងត្រូវចាត់ទុកជាអ្នកសមគំនិតនិងត្រូវទទួលខុសត្រូវរួមជាមួយដែរ ។អាជ្ញាធរមានភារកិច្ចបង្ខំឱ្យអ្នកកាន់កាប់ដោយខុសច្បាប់រុះរើចេញ ។

បញ្ញត្តិទាំងនេះក៏មានគោលដៅដាក់ទោសអ្នកមិនទទួលស្គាល់កម្មសិទ្ធិនិងលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈដោយផ្ទាល់និងជាសារវន្ត ហើយត្រូវអនុវត្តចំពោះការប៉ះពាល់ដែលមានកន្លងមកមុនការប្រកាសឱ្យប្រើច្បាប់នេះ ។

មាត្រា ១៨១.-

ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ ។ សហកម្មសិទ្ធិករត្រូវធានាការថែទាំចំណែករួម ។បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ ។

មាត្រា ១៨២.-

ជញ្ជាំងដែលខ័ណ្ឌចំណែកឯកជនត្រូវចាត់ទុកជាជញ្ជាំងអឌ្ឍសិទ្ធិដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់នេះ ។

មាត្រា ១៨៣.-

ចំណែករួមនិងសិទ្ធិបន្ទាប់បន្សំទាំងឡាយមិនអាចជាកម្មវត្ថុនៃការបែងចែកឬបង្ខំឱ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ ។

មាត្រា ១៨៤.-

សហកម្មសិទ្ធិករអាចបង្កើតអង្គការគ្រប់គ្រងដែលអាចជាក្រុមប្រឹក្សាភិបាលឬ/
និងគណៈកម្មការគ្រប់គ្រងដើម្បីទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ។ អង្គការគ្រប់គ្រងនេះត្រូវជ្រើសរើសដោយមហាសន្និបាតដែលមានការចូលរួមពីសហកម្មសិទ្ធិករទាំងអស់ដោយគិតតាមសមាមាត្រនៃសារៈសំខាន់នៃឡូតិ៍រៀងៗខ្លួន ។ អង្គការគ្រប់គ្រងធ្វើការសម្រេចចិត្តទាក់ទងទៅនឹងការថែទាំសហកម្មសិទ្ធិតាមមតិភាគច្រើន ។

សហកម្មសិទ្ធិករត្រូវគោរពតាមសេចក្តីសំរេចដែលបានដាក់ចេញដោយមហាសន្និបាត ជាពិសេសទាក់ទងទៅនឹងការថែទាំ និងការធ្វើឱ្យស្របទៅនឹងលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈនៃចំណែករួម ។

សហកម្មសិទ្ធិករណាម្នាក់ដែលមិនព្រមគោរពតាមការសម្រេចរបស់មហាសន្និបាត និង ដោះខ្លួនពីចំណែកនៃបន្ទុកដែលធ្លាក់មកលើខ្លួនអាចនឹងត្រូវបានប្តឹងទៅតុលាការដើម្បីបង្ខំឱ្យបង់បន្ទុកដែលត្រូវបង់ ។

ក្នុងករណីគ្មានការបង្កើតអង្គការគ្រប់គ្រង ការគ្រប់គ្រងសហកម្មសិទ្ធិត្រូវរ៉ាប់រងផ្ទាល់ដោយសហកម្មសិទ្ធិករទាំងអស់ដែលធ្វើការសម្រេចជាឯកច្ឆន្ទ ។ បើសិនគ្មានការយល់ព្រមណាមួយអាចកើតឡើងរវាងសហកម្មសិទ្ធិករទេ ដែលជាហេតុនាំឱ្យការថែទាំមិនបានល្អ ឬថយតម្លៃនៃសហកម្មសិទ្ធិ សហកម្មសិទ្ធិករទាំងអស់ក្រោយពីមានការព្រមព្រៀងគ្នាអាចប្តឹងទៅតុលាការឱ្យចាត់អ្នកគ្រប់គ្រងសហកម្មសិទ្ធិម្នាក់ ។ប្រាក់ឈ្នួលសំរាប់អ្នកគ្រប់គ្រងជាបន្ទុកនៃសហកម្មសិទ្ធិករទាំងអស់ ។

មាត្រា ១៨៥.-

អាជ្ញាធរមានសមត្ថកិច្ចអាចដាក់វិធានការឱ្យសហកម្មសិទ្ធិករ រ៉ាប់រងការថែទាំឱ្យល្អលើចំណែករួម ។

សោហ៊ុយនៃការថែទាំជាបន្ទុកនៃសហកម្មសិទ្ធិករ ដោយគិតតាមសមាមាត្រទៅនឹងតម្លៃនៃចំណែករៀងៗខ្លួន ។

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកនេះឬមិនគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់ នេះ ។

~~ជំពូកទី ១១~~
~~អំពីអចលនសិទ្ធិភាព~~

~~មាត្រា ១៨៦.-~~

~~អចលនសិទ្ធិភាពគឺជាទម្រង់មួយនៃកម្មសិទ្ធិរួមអនុវត្តទៅលើដីញ្ជាំងនិងកំពែងដែលនៅជ្រុងត្រង់ព័ន្ធចែកកម្មសិទ្ធិពីរជាប់គ្នា ។~~
~~កំពែងក្នុងន័យនៃច្បាប់នេះគឺសំដៅទៅលើស្មៅមភ្លោះ របងនិងរបើ ។~~

~~ផ្នែកទី ១ : អំពីដីញ្ជាំងអចលនសិទ្ធិ~~

~~មាត្រា ១៨៧.-~~

~~ការជួសជុលនិងការសាងសង់ដីញ្ជាំងអចលនសិទ្ធិឡើងវិញ~~
~~ជាបន្ទុកនៃអ្នកដែលមានសិទ្ធិលើទ្រព្យនោះតាមសមាមាត្រទៅនឹងសិទ្ធិនៃកម្មសិទ្ធិករ~~
~~ម្នាក់ៗ ។~~

~~វាល់កម្មសិទ្ធិករដែលពាក់ព័ន្ធអាចឱ្យរួចពីការចេញផ្តែជួសជុល ឬសាងសង់ដីញ្ជាំងអចលនសិទ្ធិឡើងវិញ~~
~~ដោយលះបង់សិទ្ធិនៃអចលនសិទ្ធិរបស់ខ្លួនលើកំពែងដែលជាដីញ្ជាំងអចលនសិទ្ធិមិនលំទ្រអគារដែលជារបស់ខ្លួនប៉ុណ្ណោះ ។~~

~~មាត្រា ១៨៨.-~~

~~កម្មសិទ្ធិករណាម្នាក់នៃដីញ្ជាំងអចលនសិទ្ធិមិនអាចចោះចូលជ្រៅទៅក្នុងដីញ្ជាំងអចលនសិទ្ធិ ឬ~~
~~ធ្វើការឬអ្វីដែលអាចបណ្តាលឱ្យខូចខាតដល់ដីញ្ជាំងអចលនសិទ្ធិ ដោយគ្មានការព្រមព្រៀងពីកម្មសិទ្ធិករម្ខាងទៀតឡើយ ។~~

ក្នុងការណែញ្ចូនការត្រមត្រៀងក្នុ ត្រូវឱ្យមានអាជ្ញាកណ្តាលជាអ្នកជំនាញដែលនឹងកំណត់មធ្យោបាយចាំបាច់សំរាប់ការប្តឹងដែលមិនរំខានដល់សិទ្ធិរបស់កម្មសិទ្ធិករណាម្នាក់ ។

មាត្រា ១៨៩.-

កម្មសិទ្ធិការម្នាក់ៗអាចសង់ជាប់នឹងជញ្ជាំងអគ្គិសិទ្ធិនិងជាក់ផ្តឹម និង រន្ធត

ចូលក្នុងជញ្ជាំងអគ្គិសិទ្ធិដោយទុកឱ្យសល់ប្រាំសង្ទីម៉ែត្រ តែការងារ នេះមិនត្រូវធ្វើឱ្យខូចដល់សិទ្ធិរបស់អ្នកម្ខាងទៀតឡើយ ។

ប្រសិនបើកម្មសិទ្ធិការម្ខាងទៀតនោះមានបំណង សង់ពីម្ខាងត្រង់កន្លែងនោះមកវិញដែរ

កម្មសិទ្ធិការនោះអាចមានសិទ្ធិទាមទារឱ្យបន្ថយផ្នែកនិងរន្ធតនោះមកត្រឹមកាត់កណ្តាលនៃកំរាស់ជញ្ជាំងវិញ ។

មាត្រា ១៩០.-

កម្មសិទ្ធិការនៃអចលនវត្ថុដែលនៅជាប់ជញ្ជាំងណាមួយរបស់កម្មសិទ្ធិការដទៃ មានសិទ្ធិធ្វើជញ្ជាំងនោះឱ្យទៅជាជញ្ជាំងអគ្គិសិទ្ធិទាំងស្រុង ឬមួយចំណែកដោយសង់ទៅកម្មសិទ្ធិការនៃជញ្ជាំងនោះទូវតង្កែពាក់កណ្តាលនៃចំណែកដែលខ្លួនចង់ធ្វើឱ្យទៅជាអគ្គិសិទ្ធិ ប្លកនឹងពាក់កណ្តាលតង្កែដីដែលសង់ជញ្ជាំងពីលើនោះ ។

មាត្រា ១៩១.-

កម្មសិទ្ធិការម្នាក់ៗអាចសង់បន្តជញ្ជាំងអគ្គិសិទ្ធិឱ្យខ្ពស់ជាងមុនបាន ប៉ុន្តែត្រូវចេញសោហ៊ុយក្នុងការសង់ ការជួសជុលថែទាំជញ្ជាំងដែលខ្ពស់ហួសកំណត់ដើមនោះតែម្នាក់ឯង ។ ក្រៅពីនេះ

កម្មសិទ្ធិការនោះត្រូវចេញសោហ៊ុយចំរាប់បន្ទុកដែលកើតមកពីការលើកកំពស់ហួស ទៅលើនោះឱ្យសេមភាគតង្កែផង ។

មាត្រា ១៩២.-

ប្រសិនបើជញ្ជាំងអគ្គិសិទ្ធិមិនទាំងមិនអាចទ្រទ្រង់កំពស់ដែលលើកទៅលើនោះបាន

អ្នកដែលចង់លើកឱ្យខ្ពស់នោះអាចរុះរើធ្វើជាថ្មីទាំងអស់ឡើងវិញដោយសោហ៊ុយផ្ទាល់ខ្លួន ។

ឯកំរាស់ជញ្ជាំងដែលត្រូវធ្វើលើសពីកំរាស់ដើមត្រូវសង់ជាក់ខាងលើដីរបស់ខ្លួន ។

មាត្រា ១៩៣.-

កម្មសិទ្ធិការម្ខាងទៀតដែលមិនបានជួយក្នុងការសង់ឱ្យឡើងខ្ពស់ បើត្រូវការយកសំណង់នោះទុកជារបស់អគ្គិសិទ្ធិនៃខ្លួនដែរ ត្រូវចេញថ្លៃសំណង់ដែលលើកឱ្យខ្ពស់ពាក់កណ្តាលប្លកនឹងពាក់កណ្តាលនៃថ្លៃដីដែលសង់ជញ្ជាំងលើសពីកំរាស់ដើមនោះ ។

ផ្នែកទី ២ : អំពីស្លាមឆ្នោះ រចនា និងអគ្គិសិទ្ធិ

មាត្រា ១៩៤.-

កំពែងអគ្គិសិទ្ធិដែលបានបង្កើតឡើងដោយស្មោមឆ្នោះក្តី ដោយរបងក្តី ដោយរឹតក្តី ត្រូវតែថែទាំដោយសោហ៊ុយរួម ។

តែបើកម្មសិទ្ធិការណាម្នាក់ចង់ដកខ្លួនចេញពីកាតព្វកិច្ចនេះ

កម្មសិទ្ធិការនោះអាចធ្វើបានដោយក្រាន់តែលះបង់អគ្គិសិទ្ធិរបស់ខ្លួនចោលប៉ុណ្ណោះ ។

ប៉ុន្តែបើស្មោមឆ្នោះឬរឹតនោះ ជាកន្លែងសម្រាប់បង្ហូរទឹកជាធម្មតា សេចក្តីសិទ្ធិការមិនអាចលះបង់អគ្គិសិទ្ធិរបស់ខ្លួនបានឡើយ ។

មាត្រា ១៩៥.-

~~កម្មសិទ្ធិការដែលមានជីជាប់នឹងភ្នែមភ្លោះ រថយ ឬភ្លឺណាមួយដែលមិនមែនជារបស់អភ្ជាសិទ្ធិទេ មិនអាចតម្រូវឲ្យម្ចាស់ភ្នែមភ្លោះ ម្ចាស់រថយ ម្ចាស់ភ្លឺនោះជាក់ភ្នែមភ្លោះ រថយឬភ្លឺនោះជារបស់អភ្ជាសិទ្ធិឲ្យខ្លួនបានឡើយ ។~~

~~មាត្រា ១៩៦.-~~

~~កម្មសិទ្ធិការនៃរថយអភ្ជាសិទ្ធិអាចជួសជុល កែលំអឬរុះរើរថយនោះរហូតដល់ត្រាំប្រទស់កម្មសិទ្ធិរបស់ខ្លួនបាន តែត្រូវធ្វើរថយត្រឹមជីរបស់ខ្លួនឡើងវិញ ។~~

~~សិទ្ធិនេះអាចប្រើបានក្នុងការណើបើភ្នែមភ្លោះឬភ្លឺអភ្ជាសិទ្ធិនោះ គ្រាន់តែប្រើប្រាស់ជារថយប៉ុណ្ណោះ ។~~

~~មាតិការាធិ ៥~~
~~អំពីក្រុតិភោគអចលនទត្តុ~~

~~មាត្រា ១៩៧.-~~

~~ទ្រព្យជាអចលនវត្ថុអាចបង្កើតជាប្រពិភោគលំអាប់ជាក់ធានាការសងបំណុលដោយកម្មសិទ្ធិការនៃទ្រព្យនោះតាមរយៈហ៊ីប៉ូតែក ឬ ការបញ្ចាំឬការជាក់ធានា ។~~

~~ជំពូករាធិ ១២~~
~~អំពីហ៊ីប៉ូតែក~~

~~មាត្រា ១៩៨.-~~

~~ហ៊ីប៉ូតែកគឺជាប្រពិភោគអាណ្តើកដែលបើកឲ្យម្ចាស់បំណុលប្តឹងសុំឲ្យលក់អចលនវត្ថុនោះ នៅពេលដែលកំណត់សង ទោះជាអចលនវត្ថុ នោះនៅលើដៃជនណាក៏ដោយ ដើម្បីយកប្រាក់មកសងខ្លួននិងម្ចាស់បំណុលដទៃទៀត ដែលជាអ្នកមានបុព្វសិទ្ធិ និងបុរីមានដោយមិនជាកអចលនវត្ថុនោះ ពីកម្មសិទ្ធិការទេ ។~~

~~មាត្រា ១៩៩.-~~

~~មានតែអចលនវត្ថុដែលបានចុះបញ្ជីសុរីយោជិទេ ទើបអាចជាកម្មវត្ថុនៃហ៊ីប៉ូតែកបាន ។~~

~~មាត្រា ២០០.-~~

~~ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិការនៃទ្រព្យដែលបានដាក់ហ៊ីប៉ូតែកជំនួសការសងបំណុលបានឡើយ ។~~

~~មាត្រា ២០១.-~~

~~កិច្ចសន្យាហ៊ីប៉ូតែកត្រូវរៀបចំតាមទ្រូបមន្តយ៉ាងតូច ចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចឬ អ្នកច្បាប់ណាម្នាក់ ដែលមានតីពីសេឡាទាក្នុងរឿងនេះ ។ កិច្ចសន្យាត្រូវតែចុះបញ្ជីនៅអង្គភាពសុរីយោជិ ។~~

~~អាជ្ញាធរមានសមត្ថកិច្ចក្នុងការពាក់ព័ន្ធកិច្ចសន្យាហ៊ីប៉ូតែក និង ទម្រង់នៃការចុះបញ្ជីនឹងកំណត់ដោយអនុក្រឹត្យ ។~~

~~មាត្រា ២០២.-~~

~~កិច្ចសន្យាហ៊ីប៉ូតែកត្រូវសរសេរបង្ហាញឲ្យច្បាស់តើស្ថានភាព និង ប្រភេទនៃទ្រព្យសេរីភាពឬបន្ទុកដែលកំណត់ដោយបទបញ្ជាទាំងឡាយនិងតម្លៃនៃទ្រព្យនោះ ។~~

~~មាត្រា ២០៣.-~~

~~ហ៊ីប៉ូតែកច្រែនបន្តបន្ទាប់ឮអាចត្រូវបានបង្កើតនៅលើទ្រព្យតែមួយ ។~~

~~ម្ចាស់បំណុលម្នាក់ៗប្រើសិទ្ធិតាមសមាមាត្រនៃការចុះលេខាចារឹកហ៊ីប៉ូតែករបស់ខ្លួន ។~~

~~មាត្រា ២០៤.-~~

~~ប្រសិនបើកម្មសិទ្ធិការនៃទ្រព្យដាក់ហ៊ីប៉ូតែកមិនសងបំណុលនៅពេលដល់កំណត់ត្រូវសង~~

~~ម្ចាស់បំណុលម្នាក់អាចប្តឹងសុំឱ្យលក់ទ្រព្យនោះបានដោយមិនគិតពីលំដាប់នៃហ៊ីប៉ូតែករបស់ពួកឡើយ ។~~

~~ម្ចាស់បំណុលហ៊ីប៉ូតែកនានាដែលត្រូវទទួលសងនៅពេលនោះដែរ តាមលំដាប់នៃហ៊ីប៉ូតែកនីមួយៗ ។~~

~~មាត្រា ២០៥.-~~

~~ទ្រព្យដែលកំពុងដាក់បញ្ចាំមិនអាចដាក់ហ៊ីប៉ូតែកបានឡើយ ។~~

~~ជំពូកទី ១៣~~

~~អំពីការបញ្ចាំអចលនវត្ថុ~~

~~មាត្រា ២០៦.-~~

~~ការបញ្ចាំអចលនវត្ថុគឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះ~~

~~ក្នុងបំណុលប្រគល់ឱ្យម្ចាស់បំណុលរបស់ខ្លួនទូទៅទ្រព្យមួយដើម្បីធានាការសងបំណុល ។~~

~~ម្ចាស់បំណុលមានសិទ្ធិសុំឱ្យលក់ទ្រព្យនោះដើម្បីសងបំណុលតាមបុព្វសិទ្ធិនិងបុរិមាដែលខ្លួនមានជាងម្ចាស់បំណុលដទៃទៀត ។~~

~~ការប្រើប្រាស់ទ្រព្យដាក់បញ្ចាំដោយម្ចាស់បំណុលអាចជំនួសការសងបំណុលនេះជាការប្រាក់តែមួយមុខ~~

~~ឬជាប្រាក់ដើមនិងការប្រាក់ផងក៏បាន បើសិនមានចែងក្នុងកិច្ចសន្យាបញ្ចាំ ។~~

~~មាត្រា ២០៧.-~~

~~កិច្ចសន្យាបញ្ចាំអចលនវត្ថុត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមរូបមន្តលិខិតយ៉ាងតូច~~

~~ដោយអាជ្ញាធរមានសមត្ថកិច្ចហើយត្រូវចុះបញ្ជីនៅអង្គភាព ឬការយោងដែ ។~~

~~មាត្រា ២០៨.-~~

~~ការបញ្ចាំអចលនវត្ថុចាត់ទុកជាបានការ ហើយពលរដ្ឋជនមិនអាចដំទាស់បាន លុះត្រាតែកិច្ចសន្យាបញ្ចាំនោះបានធ្វើតាមបញ្ញត្តិ~~

~~ដូចមានចែងក្នុងមាត្រា ២០៧ នៃច្បាប់នេះ ។~~

~~ការមិនបានចុះបញ្ជីនៅអង្គភាពឬការយោងដើម្បីកិច្ចសន្យាបញ្ចាំបណ្តាលឱ្យផ្តោះបង់ទិដ្ឋិប្រាតិភោគារណ៍ក~~

~~ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទាមទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ ។~~

~~មាត្រា ២០៩.-~~

~~ទ្រព្យជាប់កិច្ចសន្យាបញ្ចាំអចលនវត្ថុនឹងត្រូវសងមកកាន់បំណុលវិញដោយចាំបាច់~~

~~ចាប់ពីពេលដែលកាន់បំណុលបានសងបំណុលទាំងស្រុងរួចហើយ ។~~

ចំពោះកិច្ចសន្យាដែលមិនបានបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់សេវាក្នុងរយៈពេល ១០ (ដប់) ឆ្នាំគិតពីថ្ងៃដែលបានចុះ កិច្ចសន្យាបញ្ចាំមក បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារឱ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ចំពោះកិច្ចសន្យាដែលបានបញ្ជាក់ថ្ងៃកំណត់ឱ្យសងក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃផុតរយៈពេលសងបំណុល បើម្ចាស់បំណុលមិនបានដាក់ពាក្យប្តឹងទៅតុលាការដើម្បីទាមទារឱ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ ។

ការបាត់បង់ការធានានៃការដាក់បញ្ចាំនេះ ត្រូវឱ្យម្ចាស់បំណុលប្រគល់អចលនវត្ថុនិងប័ណ្ណឱ្យកូនបំណុលវិញ តែកូនបំណុលពុំបានរួចពីការសងបំណុលឡើយ ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទាមសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ ។

ការលើកសេងបញ្ចាំឬការលុបបង្ក្រាបបញ្ចាំត្រូវធ្វើសេចក្តីជូនដំណឹងបញ្ជាក់ជូនអ្នកមានកម្មសិទ្ធិ ។

មាត្រា ២១០.-

ក្នុងការណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិការនៃទ្រព្យជាប់កិច្ចសន្យាបញ្ចាំបានឡើយ ។ ខសន្យាណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

មាត្រា ២១១.-

កិច្ចសន្យាបញ្ចាំអចលនវត្ថុអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការឱ្យដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាព ដោយបុរិមាធិបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត ។

បើសិនជាក្នុងរយៈពេលនៃកិច្ចសន្យាបញ្ចាំ ម្ចាស់បំណុលដែលទទួលបញ្ចាំទិញអចលនវត្ថុដែលដាក់បញ្ចាំកិច្ចសន្យាទិញនេះត្រូវចុះបញ្ជីនៅអង្គភាពបុរិយោជី ពុំនោះទេនឹងត្រូវចាត់ទុកជាមោឃៈ ។

មាត្រា ២១២.-

ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យជាប់បញ្ចាំ អាចមានសិទ្ធិអាស្រ័យផលពីទ្រព្យនោះដូចជាផលបុប្ផរោគីដែរ លុះត្រាតែមានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ ។ ម្ចាស់បំណុលមានកាតព្វកិច្ចថែទាំរក្សាទុកទ្រព្យនោះឱ្យដូចជាទ្រព្យរបស់ខ្លួន ។ បើទ្រព្យនោះខូចខាតដោយសារតែប្រាំហុសពេញមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុលបាន ។

មាត្រា ២១៣.-

នៅពេលផុតរយៈពេលនៃកិច្ចសន្យាបញ្ចាំ ដោយកូនបំណុលបានសងប្រាក់រួចវិញក្តីប្តូរដោយផុតរយៈពេលប្តឹងដូចមានចែងក្នុងមាត្រា ២០៩ក្តី ម្ចាស់បំណុលត្រូវសងមកកូនបំណុលវិញនូវទ្រព្យប្តូរតម្លៃនៃទ្រព្យប្រសិនបើទ្រព្យនេះត្រូវបាននិនាសេដោយសារតែប្រាំហុសពេញមួយរបស់ម្ចាស់បំណុល ។

មាត្រា ២១៤.-

នៅថ្ងៃចប់កិច្ចសន្យាបញ្ចាំ បើយកូនបំណុលមកសុំសោះទ្រព្យវិញតែម្ចាស់បំណុលមិនព្រមឱ្យសោះ ម្ចាស់បំណុលត្រូវជំពាក់កូនបំណុលវិញនូវផលប្រយោជន៍ទុនដែលបានមកពីទ្រព្យជាប់បញ្ចាំដោយគិតចាប់តាំងពីថ្ងៃដែលកូនបំណុលសុំសោះមក ។

~~មាត្រា ២១៥.~~

~~បើទ្រព្យជាដី ហើយកិច្ចសន្យាបញ្ចាំមិនបានចែងឱ្យច្បាស់លាស់ពីថ្ងៃកំណត់លេងទេ ម្ចាស់បំណុលនៅតែមានសិទ្ធិយកផលឬផលទុនដែលជាផលកើតមកពីការយកចិត្តទុកដាក់របស់ខ្លួនពីការងាររបស់ខ្លួនធៀបពីទុនរបស់ខ្លួន ក្នុងរយៈដែលកូនបំណុលបុំលោះ ។~~

~~ប៉ុន្តែបើទ្រព្យជាផ្ទះ ហើយកិច្ចសន្យាបញ្ចាំមិនបានចែងឱ្យច្បាស់លាស់ពីថ្ងៃកំណត់លេងទេ ម្ចាស់បំណុលត្រូវប្រគល់ទ្រព្យជាក់បញ្ចាំនោះឱ្យកូនបំណុលពិតពីថ្ងៃដែលកូនបំណុលបានសងបំណុលរួច ។~~

~~មាត្រា ២១៦.~~

~~ការប្រាក់ត្រូវបានបញ្ឈប់ចាប់ពីថ្ងៃដែលកូនបំណុលបានសងបំណុលរួច មុនការបញ្ឈប់កិច្ចសន្យា ។~~

~~ការថ្មើសងបំណុលត្រូវបង្ហាញពីចំនួនធៀប ត្រូវកត់ត្រាក្នុងលិខិតដែលមានចុះហត្ថលេខាដោយម្ចាស់ប្តឹងថៅសង្កាត់ជាមួយនឹងហត្ថលេខាកូនបំណុលនិងសាក្សីពីរនាក់ ។~~

~~មាត្រា ២១៧.~~

~~ការបង់ពន្ធជារនៅតែជាបន្ទុកនៃកូនបំណុល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងម្ចាស់បំណុលនិងកូនបំណុល ។~~

~~មាត្រា ២១៨.~~

~~បើកូនបំណុលបានសងបំណុលគ្រប់ចំនួនហើយ ម្ចាស់បំណុលមិនអាចរក្សាទុកទ្រព្យ ដែលបានជាក់បញ្ចាំដោយយកសេចក្តីថាកូនបំណុលនៅជំពាក់បំណុលមួយផ្សេងទៀតបានទេ ទោះជាបំណុលក្រោយនេះដល់កំណត់ទារហើយក៏ដោយ លើកលែងតែមានកិច្ចសន្យាបញ្ចាំថ្មីមួយទៀតលើទ្រព្យដដែលនេះ ហើយបានរៀបចំតាមទម្រង់នៃច្បាប់ទៀតផង ។~~

~~កូនបំណុលអាចប្រើសិទ្ធិខាងលើនេះ លើទាយាទឬលើសិទ្ធិវន្តនៃម្ចាស់បំណុលបាន ។~~

~~ជំពូកធី ១៤~~
~~អំពីការដាក់ធានា~~

~~មាត្រា ២១៩.~~

~~ការដាក់ធានាគឺជាកិច្ចសន្យាមួយដែលបានសម្រេចឡើង ដើម្បីធានាការសងបំណុលដែលក្នុងនោះកូនបំណុលប្រគល់ទៅឱ្យម្ចាស់បំណុលរបស់ខ្លួន មិនមែនជាទ្រព្យទៅតែជាប័ណ្ណកម្មសិទ្ធិនៃទ្រព្យនោះដែលបានចុះនិទ្ទេសក្នុងបញ្ជីសុំរឹបយោជឺ ។~~

~~មាត្រា ២២០.~~

~~កិច្ចសន្យាដាក់ធានាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរូបមន្តយថាភូតនិងត្រូវចុះសេចក្តីថាកិច្ចសន្យាក្នុងបញ្ជីសុំរឹបយោជឺ ។~~

~~មាត្រា ២២១.~~

~~ក្នុងការណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិការនៃទ្រព្យជាប់កិច្ចសន្យាដាក់ធានាបានឡើយ ។ ខសន្យាណាដែលផ្ទុយនឹងបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។~~

~~កិច្ចសន្យាដាក់ធានាអនុញ្ញាតឱ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការ ឱ្យដាក់លក់អចលនវត្ថុដោយបង់ប៉ុណ្ណោះ ដើម្បីសងខ្លួន ជាអាទិភាពដោយបុរិមានិងបុព្វសិទ្ធិមុនម្ចាស់បំណុលដទៃទៀត ។~~

~~មាត្រា ២២២.~~

~~បើកូនបំណុលបានសងបំណុលនិងការប្រាក់រួចហើយតាមពេលកំណត់ឬមុនពេលកំណត់ ម្ចាស់បំណុលត្រូវបង្វិលប័ណ្ណកម្មសិទ្ធិមកកូនបំណុលវិញដោយធ្វើលេខាចារឹកលើកំសែងបន្ទុកក្នុងបញ្ជីសុរិយោដី ។~~

~~**មាត្រា ២២៣.-**~~

~~កូនបំណុលត្រូវរក្សាទុក ត្រប់ត្រងនិងប្រើប្រាស់ទ្រព្យរបស់ខ្លួន ប៉ុន្តែមិនអាចធ្វើអ្វីដែល នាំឱ្យបន្ថយតម្លៃ ទ្រព្យនោះបានជាជាច់ខាត ។~~

~~**មាត្រា ២២៤.-**~~

~~បិទ្ធិវន្តនៃកូនបំណុលនិងបិទ្ធិវន្តនៃម្ចាស់បំណុលមានកាតព្វកិច្ចនិងបិទ្ធិដូចគ្នានឹងកូនបំណុលឬម្ចាស់បំណុលរបស់ខ្លួនដែរ ។~~

~~**មាត្រា ២២៥.-**~~

~~ទាយាទឬប្រតិបិទ្ធិនៃកូនបំណុលត្រមទាំងសមាជិកទាំងឡាយនៃគ្រួសារដែលអាចប្រកាសថាជាសហកម្មសិទ្ធិការនៃទ្រព្យដាក់ធានា មានកាតព្វកិច្ចនិងបិទ្ធិដូចគ្នានឹងកូនបំណុលដែរ ។~~

មាតិកាទី ៦
អំពីសុរិយោដី
ជំពូកទី ១៥
អំពីរដ្ឋបាលសុរិយោដី

មាត្រា ២២៦.-

កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋ។ តាមគោលដៅនេះ រដ្ឋបាលសុរិយោដីក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់មានសមត្ថកិច្ចធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញប័ណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ពត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលអាចមានលើក្បាលដីនោះ ។

មាត្រា ២២៧.-

ក្បាលដីឬឯកតាសុរិយោដី គឺជាផ្ទៃដីមួយជាក់លាក់ស្ថិតនៅក្នុងឃុំ ឬ សង្កាត់តែមួយមិនពុះបំបែកដោយព្រំជាប់មិនដាច់ជារបស់ជនម្នាក់ឬច្រើននាក់ក្នុងករណីអវិភាគកម្មហើយប្រើប្រាស់ក្នុងរូបភាពតែមួយ ។

ចាត់ទុកជាព្រំជាប់មិនដាច់ដែលនាំឱ្យបំបែកក្បាលដីជាច្រើនក្បាលនោះគឺរបងផ្លូវសាធារណៈ ប្រឡាយ និង ផ្លូវទឹកដែលមានទទឹងយ៉ាងតិចពីរ ម៉ែត្រ ។

មាត្រា ២២៨.-

ការរៀបចំនិងការប្រព្រឹត្តទៅនៃរដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ២២៩.-

រដ្ឋបាលសុរិយោដីមានភារកិច្ចដូចតទៅ :

- ធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធតាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងស្បៀវភៅគោលបញ្ជីដី

- ធ្វើការពង្រឹងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ តាមនីតិវិធីដែលនឹងបញ្ញត្តិដោយអនុក្រឹត្យ
- អនុវត្តការអង្កេតវាស់វែងសុរិយោដីនៃក្បាលដីរួមមាន ការកំណត់ព្រំដី ការបំបែកក្បាលដី ការបង្រួមក្បាលដី និងការកែតម្រូវព្រំប្រទល់នៃក្បាលដី និងជាទូទៅរាល់ការប្រែប្រួលអំពីទំហំដែលបណ្តាលមកពីធម្មជាតិឬដោយស្ម័គ្រចិត្ត
- កសាងស្បៀវភៅគោលបញ្ជីដីហើយធ្វើលេខាចារឹកឈ្មោះកម្មសិទ្ធិករនិងរាល់ទិន្នន័យដែលប្រមូលបានទាក់ទងទៅលក្ខណៈរូប ទំហំនិងអត្តសញ្ញាណនៃអចលនវត្ថុ ទាំងនោះ
- ធ្វើចរន្តការនូវរាល់ការផ្លាស់ប្តូរប្រែប្រួលទាក់ទងទៅនឹងសិទ្ធិដែលកើតឡើងដោយកិច្ចសន្យាផ្ទេរដូចជា ការលក់ ការឱ្យ ការដូរសន្តតិកម្ម ឬពាក់ព័ន្ធនឹងការដូរ ប្រភេទឬស្ថានភាពនៃដីដូចជា ការសាងសង់ ការចាក់បំពេញដី ការជីកកកាយយកដីជាដើម
- អភិរក្សនូវរាល់ឯកសារសុរិយោដីដែលមានប្លង់សុរិយោដី បញ្ជីឈ្មោះ កម្មសិទ្ធិករ ស្បៀវភៅគោលបញ្ជីដី និងរាល់ឯកសារគតិយុត្តិទាក់ទងទៅនឹងក្បាលដីនីមួយៗ
- ចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុជូនកម្មសិទ្ធិករនិងលិខិតបញ្ជាក់ផ្សេងៗទៀតទាក់ទងទៅនឹងក្បាលដី
- មានភាតព្វកិច្ចប្រគល់ជូនជនដែលបានដាក់ពាក្យស្នើសុំប្លង់ថតចម្លងនិងឯកសារពត៌មានទាក់ទងទៅនឹងទីតាំង អត្តសញ្ញាណព្រំដី និងសិទ្ធិ ដែលទាក់ទងទៅនឹងក្បាលដី
- ធ្វើលេខាចារឹកនូវរាល់ប៊ីប៉ូតែក ការបញ្ចាំ ~~ការដាក់ធានា~~ *ផលុបភោគ* ការជួលរយៈពេលវែង ឬ សេវភាពដែលបានបង្កើតឡើងលើទ្រព្យជាអចលនវត្ថុ ហើយផ្តល់ពត៌មានទៅគ្រប់ជនដែលសាកសួរមករដ្ឋបាលសុរិយោដី អំពីស្ថានភាពនៃកម្មសិទ្ធិដែលជាកម្មវត្ថុនៃការដាក់ប៊ីប៉ូតែកដាក់បញ្ចាំ ~~ដាក់ធានា~~ *ផលុបភោគ*ការជួលរយៈពេលវែងឬសេវភាពនោះ ។

មាត្រា ២៣០.-

សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ចខាងលើត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ២៣១.-

រដ្ឋបាលសុរិយោដីថ្នាក់កណ្តាលជាអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រទទួលបន្ទុករៀបចំសម្របសម្រួល និងត្រួតពិនិត្យប្រតិបត្តិការទាំងឡាយនៃការវាស់វែងសុរិយោដីដែលធ្វើឡើងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និង រាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី កសាងបញ្ជីឈ្មោះ កម្មសិទ្ធិករ
កសាងស្បៀវភៅគោលបញ្ជីដីនិងចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។ក្រៅពីនេះអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រត្រូវកំណត់វិធីនិងស្តង់ដារទាក់ទងទៅនឹងឯកសារ ។

មាត្រា ២៣២.-

រដ្ឋបាលសុរិយោដីខេត្ត - ក្រុងឬ ស្រុក-ខ័ណ្ឌនីមួយៗត្រូវប្រតិបត្តិរាល់ការណែនាំពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។
រដ្ឋបាលសុរិយោដីខេត្ត-ក្រុងឬស្រុក-ខ័ណ្ឌ
ទទួលធ្វើសម្រង់សុរិយោដីដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដទៃទៀតកាន់កាប់ស្បៀវភៅគោលបញ្ជីដីធ្វើចរន្តការជាប្រចាំក្រោមការត្រួតពិនិត្យពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលរក្សាទុកឯកសារនិងផ្តល់ពត៌មានដល់អ្នកស្នើសុំ ។

មាត្រា ២៣៣.-

រដ្ឋបាលសុរិយោដីស្រុក-ខ័ណ្ឌ ត្រូវផ្ទៀច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំឬសង្កាត់ដែលពាក់ព័ន្ធ ។ មេឃុំឬចៅសង្កាត់ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបពិគ្រោះយោបល់ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុក-ខ័ណ្ឌនូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិនិងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន ។

ជំពូកទី ១៦
អំពីសម្រង់សុរិយោដី

មាត្រា ២៣៤.-

សម្រង់សុរិយោដីត្រូវធ្វើតាមបច្ចេកទេសនិងវិធីសាស្ត្រកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២៣៥.-

ក្នុងករណីចាំបាច់រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬ អង្គភាពយោធាឬនគរបាលឱ្យជួយជ្រោមជ្រែងដល់កិច្ចប្រតិបត្តិការធ្វើសម្រង់សុរិយោដីនៅនឹងកន្លែង ។

គ្មានសមត្ថកិច្ចណាក្រៅពីរដ្ឋបាលសុរិយោដី មានសិទ្ធិកំណត់កម្មសិទ្ធិករនៃក្បាលដី ប្រភេទ ដីឬទំហំដីបានឡើយ ។

មាត្រា ២៣៦.-

ជនទាំងឡាយ ជាពិសេសកម្មសិទ្ធិករនិងជនដែលពាក់ព័ន្ធមានកាតព្វកិច្ចចូលរួមនិងសហការក្នុងការធ្វើសម្រង់សុរិយោដី ។ ជនទាំងនោះត្រូវជួយសម្រួលដល់កិច្ចប្រតិបត្តិការវាស់វែងសុរិយោដីនិងធ្វើអត្តសញ្ញាណកម្មកម្មសិទ្ធិករ ហើយត្រូវរាយការណ៍អំពីការផ្លាស់ប្តូរទាំងអស់ដែលកើតមានទាក់ទងនឹងក្បាលដីរបស់ខ្លួននិងស្ថានភាពនៃទីតាំងនិងរាល់ការផ្ទេរសិទ្ធិនៃកម្មសិទ្ធិ ។

មាត្រា ២៣៧.-

ក្នុងករណីមានវិវាទកម្មអំពីទំហំនៃក្បាលដី ឬឈ្មោះនៃកម្មសិទ្ធិករកើតឡើងក្នុងពេលប្រតិបត្តិការធ្វើសម្រង់សុរិយោដី អ្នកទទួលខុសត្រូវនៃរដ្ឋបាលសុរិយោដី ត្រូវអញ្ជើញសាមីខ្លួនមកសម្រុះសម្រួល ។ ចំពោះវិវាទកម្មដែលកើតឡើងក្នុងតំបន់កំពុងធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ គណៈកម្មការរដ្ឋបាលមានភារៈសម្រុះសម្រួលវិវាទកម្មនេះ ។ បើការព្រមព្រៀងមិនអាចប្រព្រឹត្តទៅបាន អ្នកទទួលខុសត្រូវត្រូវបន្តធ្វើអង្កេតវាស់វែងសុរិយោដី ហើយកសាងកំណត់ហេតុនៃវិវាទនោះតែមិនមានសិទ្ធិអារកាត់ទេ ។

កាលបើវិវាទកម្មកើតមាននៅពេលប្រគល់ប័ណ្ណរដ្ឋបាលសុរិយោដីត្រូវប្រកាន់យកតែឈ្មោះកម្មសិទ្ធិករដែលបានចុះក្នុងបញ្ជីរបស់ខ្លួនប៉ុណ្ណោះ ។ គ្មានករណីណាដែលរដ្ឋបាលសុរិយោដីអាចកែប្រែ ឬប្រគល់ប័ណ្ណឱ្យបុគ្គលផ្សេងទៀតបានឡើយ ។

ជំពូកទី ១៧
អំពីបញ្ជីនិងឯកសារសុរិយោដី

មាត្រា ២៣៨.-

រដ្ឋបាលសុរិយោដីមានកាតព្វកិច្ចកសាងបង្កង់សុរិយោដីនិងសៀវភៅគោលបញ្ជីដី ។

បង្កង់សុរិយោដីគ្របដណ្តប់តំបន់ដែលបានធ្វើការវិនិច្ឆ័យ ដោយមានកំណត់ព្រំប្រទល់កម្មសិទ្ធិសាធារណៈ ឬ/និងកម្មសិទ្ធិឯកជនទាំងអស់ ហើយមានបញ្ជាក់អំពីប្រភេទដីដូចជា ដីដាំដុះ ដីព្រៃ ដីលិចទឹកដីសំរាប់សំណង់ឧស្សាហកម្មជាដើម ។ ការកសាងបង្កង់

សុរិយោដីត្រូវអនុវត្តតាមនីតិវិធីដែលត្រូវចែងក្នុងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដី ។ក្បាលដីកម្មសិទ្ធិនីមួយៗត្រូវមានលេខរបស់វា ។

សៀវភៅគោលបញ្ជីដីបង្ហាញចំពោះលេខក្បាលដីកម្មសិទ្ធិនីមួយៗនូវឈ្មោះកម្មសិទ្ធិករ និង មធ្យោបាយនៃការធ្វើអត្តសញ្ញាណកម្មក្បាលដីការពិពណ៌នាអំពីកម្មសិទ្ធិ ទំហំ ក្បាលដីសេវភាពនិងបន្ទុកផ្សេងៗលើក្បាលដី ។ រាល់ការកែប្រែទិន្នន័យទាំងឡាយត្រូវតែបានចុះបញ្ជីនៅពេលដែលរដ្ឋបាលសុរិយោដីបានទទួលដំណឹងនេះ។ បញ្ជីនេះ ត្រូវបានកាន់កាប់ជា ៣ (បី) ច្បាប់ដែលមួយច្បាប់ត្រូវបានរក្សាទុកនៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលនិងពីរច្បាប់ទៀតរក្សាទុកនៅរដ្ឋបាលសុរិយោដីខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ។

សៀវភៅគោលបញ្ជីដីបង្ហាញចំពោះលេខប័ណ្ណកម្មសិទ្ធិនូវប៊ីប៉ូតែក ការបញ្ចាំ ~~ការដាក់ធានា~~ *ផលុបរភោគ* និង ការជួលរយៈពេលវែងដែលអាចដាក់បន្ទុកលើកម្មសិទ្ធិនោះ ។

មាត្រា ២៣៩.-

ប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីមានតម្លៃត្រឹមត្រូវតាមច្បាប់និងមានអានុភាពច្បាស់លាស់ ។ ប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដី មិនត្រូវមានការឆូតលុប ការសរសេរត្រួត ការកែ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់ ។

រដ្ឋបាលសុរិយោដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការកាន់កាប់នូវបញ្ជីដី និង ភាពជាក់លាក់នៃប្រតិបត្តិការសម្រង់សុរិយោដី និងកិច្ចការអភិរក្សឯកសារ ។

មាត្រា ២៤០.-

ការសាកសួរពត៌មានសុរិយោដីមិនអាចត្រូវបានប្រកែកចំពោះជនដែលមានការទាក់ទងឡើយ ។ ពត៌មានដែលបានចុះក្នុងសៀវភៅគោលបញ្ជីដីជាកម្មវត្ថុនៃការប្រគល់ ច្បាប់ចម្លងដោយត្រូវបង់ប្រាក់ដែលបានកំណត់ក្នុងមាត្រា ២៣០ នៃច្បាប់នេះ ។

ជំពូកទី ១៨
អំពីប័ណ្ណទិញពត៌មានសុរិយោដី

មាត្រា ២៤១.-

រដ្ឋបាលសុរិយោដីអាចចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ វិញ្ញាបនប័ត្របញ្ជាក់ប៊ីប៉ូតែកសលាកប័ត្រពត៌មាននិងលិខិតបញ្ជាក់សុរិយោដីអំពីប្រភេទ ស្ថានភាពគតិយុត្តិលក្ខណៈរូបនិងបន្ទុកនៃក្បាលដី ដោយផ្អែកលើឯកសារនិងសៀវភៅគោលបញ្ជីដី ។

មាត្រា ២៤២.-

វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ត្រូវចេញឱ្យចំពោះតែកម្មសិទ្ធិករឬអ្នកមានសិទ្ធិស្របច្បាប់លើអចលនវត្ថុនោះតែប៉ុណ្ណោះ ។

មាត្រា ២៤៣.-

សលាកប័ត្រពត៌មានសុរិយោដីអាចត្រូវបានផ្តល់ឱ្យជនដែលបានស្នើសុំ ។ ភ្នាក់ងារដែលបានផ្តល់ពត៌មាននេះត្រូវទទួលខុសត្រូវចំពោះការផ្តល់ពត៌មានមិនត្រឹមត្រូវដល់អ្នកស្នើសំ ។ ពត៌មានដែលផ្តល់ឱ្យមិននាំឱ្យជាប់ការទទួលខុសត្រូវដល់រដ្ឋបាលសុរិយោដីទេ ។

មាត្រា ២៤៤.-

លិខិតបញ្ជាក់សុរិយោដីគឺជាមូលដ្ឋាននៃការអះអាងជាផ្លូវការមួយនៃលិខិតគតិយុត្តិ ។

កម្មសិទ្ធិអចលនវត្ថុកើតឡើង~~ដោយលិខិតលក់ អោយ ជួរឬជំរះមរតក ដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមាននីតិសម្បទាដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ~~ ***ដោយលិខិតជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើដោយ អាជ្ញាធរមានសមត្ថកិច្ច ។*** លិខិតទាំងនោះត្រូវតែតំកល់ទុកនៅរដ្ឋបាលសុរិយោដី ។

មាត្រា ២៤៥.-

~~លិខិតលក់ អោយ ជួរឬជំរះមរតកធ្វើឡើងជាឯកជនមិនអាចចុះបញ្ជីបានឡើយ ។ ពលរដ្ឋមិនអាចដំទាស់បានលុះត្រាតែលិខិតនោះធ្វើឡើងតាមបែបបទដែលបានកំណត់ក្នុងមាត្រា ២៤៤ នៃច្បាប់នេះ ។~~

កិច្ចសន្យាដើម្បីផ្ទេរកម្មសិទ្ធិលើ អចលនវត្ថុ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះបញ្ជីកិច្ចសន្យា នោះនៅរដ្ឋបាលសុរិយោដី ។

~~**មាត្រា ២៤៦.-**~~

~~ប្រសិនបើលិខិតលក់ អោយ ជួរ ឬ ជំរះមរតក បានធ្វើឡើងតាមរូបមន្តយថាភូតដោយបុគ្គលដែលមាននីតិសម្បទាប៉ុន្តែមិនបានចុះបញ្ជីនៅសុរិយោដីទេ លិខិតនោះនៅតែពិយ៉ាងអាចដំទាស់បាន~~
~~ហើយកម្មសិទ្ធិការពិរទិទ្ធិវត្ថុត្រូវទទួលខុសត្រូវដោយខ្លួនឯង ក្នុងការខកខានចុះបញ្ជីនេះ ។~~

មាតិកាទី ៧
អំពីទោសប្បញ្ញត្តិ
ជំពូកទី ១៩
អំពីការប៉ះពាល់កម្មសិទ្ធិ

មាត្រា ២៤៧.-

រាល់ការប៉ះពាល់កម្មសិទ្ធិ និង
សិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុអាចជាបទល្មើសព្រហ្មទណ្ឌអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ~~ហើយការខូចខាតទាំងឡាយដែលបណ្តាលមកពីអំពើនេះត្រូវដោះស្រាយដោយចំណែងរដ្ឋប្បវេណី~~ ។

មាត្រា ២៤៨.-

ត្រូវចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុជាបទល្មើសព្រហ្មទ័ណ្ឌក្នុងន័យនៃច្បាប់នេះមាន :

- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រំលោភកាន់កាប់អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី

- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែងរារាំងអ្នកកាន់កាប់ដោយសន្តិភាពឬភោគីនៃទ្រព្យមួយនៅក្នុងតំបន់មិនទាន់មានប្លង់សុរិយោដី ដែលរបបកម្មសិទ្ធិមិនទាន់បានពង្រឹងជាស្ថាពរតាមបញ្ញត្តិនៃច្បាប់នេះ

- រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ឬមិនប្រក្រតីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនស្របតាមមាត្រា១៧ មាត្រា ១៨ និងមាត្រា ១៩ នៃច្បាប់នេះ

- រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម ។

មាត្រា ២៤៩.-

ការប៉ះពាល់កម្មសិទ្ធិក្នុងន័យនៃមាត្រាខាងលើអាចជាទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬជាទង្វើរបស់សាមញ្ញជនដែលធ្វើដោយម្នាក់ឯងឬដោយផ្សំគំនិតជាមួយភ្នាក់ងាររបស់អាជ្ញាធរ ។

មាត្រា ២៥០.-

មន្ត្រីឬអាជ្ញាធរមានសមត្ថកិច្ចដែលបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើអចលនវត្ថុ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ។

ផ្នែកទី ១ : អំពីការប៉ះពាល់កម្មសិទ្ធិសាធារណៈ ឬឯកជនដោយសាមញ្ញជន
អនុផ្នែកទី ១ : អំពីការប៉ះពាល់កម្មសិទ្ធិឯកជន

មាត្រា ២៥១.-

ជនណាដែលបានក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

មាត្រា ២៥២.-

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្មឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥00.000(ប្រាំសែន) រៀល ដល់ ៣.000.000 (បីលាន)រៀល ឬ,និងដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦(ប្រាំមួយ) ខែ ។

មាត្រា ២៥៣.-

ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណឬកំពុងមានទំនាស់ក៏ដោយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥00.000 (មួយលានប្រាំសែន) រៀល ដល់ ២៥.000.000 (ម្ភៃប្រាំលាន) រៀល ឬ/និងដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២(ពីរ) ឆ្នាំ ដោយពុំទាន់គិតបញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស ។

~~បន្ថែមលើទោសខាងលើ អ្នកប្រព្រឹត្តអំពើហិង្សាត្រូវទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន ។~~

បើអំពើហិង្សាខាងលើត្រូវបានបញ្ជាពីជនដទៃទៀតក្រៅពីអ្នកបង្ក ហើយជននោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានេះក៏ត្រូវទទួលការផ្តន្ទាទោសដូចអ្នកប្រព្រឹត្តអំពើហិង្សាផ្ទាល់ដែរ ។

មាត្រា ២៥៤.-

គ្មានករណីណាមួយដែលអនុញ្ញាតឱ្យប្រើប្រាស់កម្លាំងឯកជន ដើម្បីធានាចំពោះការគោរពប័ណ្ណកម្មសិទ្ធិ ឬចំពោះការប្រតិបត្តិសេចក្តីសំរេចរបស់តុលាការក្នុងការបណ្តេញចេញឬក្នុងការបង្គាប់ឱ្យចាកចេញបានឡើយ ។

ជនណាដែលប្រើកម្លាំងឯកជនក្នុងហេតុផលនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.000.000 (បីលាន) រៀល ដល់ ២៥.000.000 (ម្ភៃប្រាំលាន)រៀល ឬ/និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២ (ពីរ)ឆ្នាំ ។

មាត្រា ២៥៥.-

ជនណាដែលបានលួចលក់ឬលួចបញ្ជាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣(បី) ឆ្នាំ ដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន ។

មាត្រា ២៥៦.-

កម្មសិទ្ធិករណាដែលបានធ្វើការដាំដុះលើដីរបស់ខ្លួន ឬប្រគល់ដី ឬ ជួលដីឱ្យតតិយជន ដាំដុះដោយចេតនានូវមុខដំណាំដែលច្បាប់ឬបទបញ្ជាហាមឃាត់ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១៥.000.000 (ដប់ប្រាំលាន)រៀល ដល់ ៤៥.000.000 (សែសិប ប្រាំលាន) រៀលឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ជាធរមាន ។

មាត្រា ២៥៧.-

សហកម្មសិទ្ធិករអវិភាគដែលធ្វើឱ្យប៉ះពាល់ដល់ចំណែករួម ដូចមានចែងក្នុងមាត្រា ១៨0 នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥00.000 (មួយលានប្រាំសែន) រៀលដល់ ៥.000.000 (ប្រាំបួនលាន)រៀល ។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ។

មាត្រា ២៥៨.-

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួមនៃសហកម្មសិទ្ធិខ្លួន ឬមិនគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈដូចមានចែងក្នុងមាត្រា ១៨៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥00.000(ប្រាំសែន)រៀល ដល់៣.000.000(បីលាន) រៀល ។

អនុផ្នែកទី ២ : អំពីការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ

មាត្រា ២៥៩.-

ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ដល់ ៥0.000.000(ហាសិបលាន) រៀល ឬ/និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

ចៅក្រមត្រូវមានកាតព្វកិច្ចចាកចេញពីទ្រព្យសម្បត្តិសាធារណៈនោះជាបន្ទាន់ ។ ចៅក្រមគ្មានសិទ្ធិទារកំរៃអំពីពលកម្មឬការរៀបចំដែលបាន ធ្វើលើទ្រព្យនោះឡើយ ។

ក្នុងករណីដែលអ្នកកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ មុនច្បាប់នេះចូលជាធរមានហើយមានឯកសារសំអាង និងបញ្ជាក់ជាក់លាក់ថាខ្លួនបានទិញពីជនណាម្នាក់អាចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តតាមវិធានច្បាប់ចំពោះបុគ្គលដែលបានលក់ទ្រព្យសម្បត្តិសាធារណៈនេះដោយខុសច្បាប់និង ដើម្បីជាប្រយោជន៍របស់ខ្លួនដែលបានរងគ្រោះដោយសារទង្វើនេះ ។ ទោះជាយ៉ាងណាក៏ដោយក៏ជនរងគ្រោះនេះពុំមានសិទ្ធិកាន់កាប់បន្តលើទ្រព្យសម្បត្តិសាធារណៈបានឡើយ ។

មាត្រា ២៦0.-

ជនណាដែលបានលើកចេញ ឬរំកិលចេញ ឬបំផ្លាញចោលនូវបង្គោលស៊ីម៉ង់ត៍ដៅ ចំណុចឋានលេខានិងទីតាំងផ្លាកសញ្ញាសុរិយោដី ត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច ។ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥00.000

(ប្រាំសែន) រៀល ដល់ ៣.000.000 (បីលាន) ឬ/និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែដោយមិនគិតដល់ព្យសនកម្មដែលបណ្តាលមកពី អំពើរបស់ខ្លួន ។

ផ្នែកទី ២ : អំពើការប៉ះពាល់កម្មសិទ្ធិសាធារណៈឬឯកជនដោយអាជ្ញាធររដ្ឋបាល

មាត្រា ២៦១.-

មន្ត្រីឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ជាក្តី ឬគ្មានបញ្ជាក្តីដើម្បីដកហូតអចលនវត្ថុពីអ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១0.000.000(ដប់លាន) រៀល ដល់ ២៥.000.000 (ម្ភៃប្រាំលាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

ចាត់ទុកជាការរំលោភមាន ការកែ្លងបន្លំ ការកសាងប័ណ្ណដោយបំពាន ការកៀបសង្កត់ឬវិធានការសម្ភារៈ ដើម្បីបណ្តេញចេញធ្វើ ឡើងចំពោះអ្នកកាន់កាប់អចលនវត្ថុ ។

បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សា ចារីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២ (ពីរ) ឆ្នាំថែមទៀត ។

អ្នកបញ្ជាដោយរំលោភត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តផ្ទាល់ដែរ ។

មាត្រា ២៦២.-

អាជ្ញាធរមានសមត្ថកិច្ចឬកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានរំលោភយកទ្រព្យជាអចលនវត្ថុក្នុងមណ្ឌលដែលខ្លួនមានភារកិច្ចការពារសណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខមកធ្វើជារបស់ខ្លួន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.000.000 (បីលាន) រៀលដល់៣0.000.000 (សាមសិបលាន) រៀល ឬ.និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៣.-

អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិកររបស់ភោគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ដល់ ១0.000.000 (ដប់លាន) រៀលនិងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៤.-

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.000.000(មួយលាន) រៀល ដល់ ៥.000.000(ប្រាំលាន) រៀល និង ត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

រាប់ចូលជាការរំលោភ ការផ្តល់ទិន្នន័យជាផ្លូវការខុស ការចេញប័ណ្ណកម្មសិទ្ធិខុស ការបិទបាំងប៊ីប៉ូតែកឬបន្ទុកផ្សេងៗ ការបោះគោលព្រំដីខុសដោយចេតនានិងរាល់ការធ្វេសប្រហែសក្នុងការធ្វើលេខាចារិកលើឯកសារសុរិយោដី ។

មាត្រា ២៦៥.-

រាល់ការប៉ះពាល់ធ្វើឡើង ដោយប្រឆាំងនឹងសិទ្ធិលើដីរបស់សហគមន៍ជនជាតិដើមភាគតិចដោយអាជ្ញាធរដែលទទួលខុសត្រូវគ្រប់គ្រងតំបន់ដែលអចលនវត្ថុនោះតាំងនៅ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.៥00.000 (មួយលានប្រាំសែន) រៀលដល់

៥.000.000 (ប្រាំបួនលាន)រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៦.-

ការប៉ះពាល់អចលនវត្ថុរបស់វត្ត ដោយបុគ្គលដែលទទួលបន្ទុកគ្រប់គ្រងត្រូវបង្ខំឱ្យសងទ្រព្យនោះវិញ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១.៥00.000 (មួយលានប្រាំសែន) រៀលដល់ ៥.000.000 (ប្រាំបួនលាន) រៀល ។

មាតិកាទី ៨
អវសានប្បញ្ញត្តិ

មាត្រា ២៦៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៦៨.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

សង្ខារុក្រម
ក . ខ . គ

កម្មសិទ្ធិ	: សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ ។សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យ ។
កម្មសិទ្ធិករ	: ម្ចាស់កម្មសិទ្ធិលើទ្រព្យ និង មានសិទ្ធិប្រើប្រាស់សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យដែលជារបស់ខ្លួន ។
កតិកាភេទ	: កិរិយាបដិសេធកិច្ចសន្យាណាមួយ ដោយមកពីកិច្ចសន្យានោះមានវិការៈដល់ប្រសគល់នៃការព្រមព្រៀងគ្នា ។ ក្នុងទីនោះកតិកាភេទបានន័យថាបដិសេធកិច្ចសន្យាលក់ចោល ដោយមកពីលក់អចលនវត្ថុមានវិការៈអាថិកំបាំង ។
កាតព្វកិច្ច	: ចំណងនៃសិទ្ធិដែលបង្ខំជនម្នាក់ឱ្យផ្ទេរកម្មសិទ្ធិ ឬសិទ្ធិណាមួយឱ្យបំពេញនូវកិច្ចការណាមួយ ឬឱ្យឈប់បំពេញនូវកិច្ចការណាមួយដល់ជនម្នាក់ទៀត ។
ការជំរះមរតក	: កិរិយាធ្វើបញ្ជីទ្រព្យសម្បត្តិរបស់ខ្មោចអោយដឹងថានៅសល់ប៉ុន្មាន បាត់ប៉ុន្មានដើម្បីនឹងចែកគ្នារវាងទាយាទ និង ទាយាទ ។

ការ្យ : ធលអ្វីទាំងពួងដែលកើតមកពីស្នាដៃជាងឬស្នាដៃសិល្បករ ។ ឧទា : តុ ទូ ជាការ្យរបស់ជាងឯប្រលោមលោកជាការ្យរបស់អ្នកនិពន្ធ ។

កើយ : រានហាលតូចគ្មានសរសរទ្រពីក្រោមទេតែមានបង្គាន់ដៃព័ទ្ធជុំវិញ។

កូនបំណុល : ជនជំពាក់ប្រាក់ ឬជំពាក់កាតព្វកិច្ចគេ ។

កំពែង : ស្មាមភ្លោះ របង ភ្ជឺ ។

ច . ឆ . ដ

ចរន្តការ : ការកត់ត្រាទុកជាប្រចាំក្នុងឯកសារសុរិយោដីនូវរាល់ការប្រែប្រួល ឬការផ្លាស់ប្តូរដោយយោងតាមឯកសារគតិយុត្ត។

ចារី : អ្នកប្រព្រឹត្ត អ្នកដៃដល់ ។

ច្បាប់ : លិខិតបទដ្ឋានគតិយុត្តដែលអនុម័តដោយអង្គការនីតិបញ្ញត្តិ (សភា) និងចូលជាធរមានតាមរយៈព្រះរាជក្រមប្រកាសអោយប្រើ ។

ឆន្ទានិសិទ្ធិ :

អំណាចដែលប្រគល់ដល់អាជ្ញាធរអោយរើសយកមធ្យោបាយណាមួយតាមចិត្តខ្លួនមកដោះស្រាយបញ្ហាណាមួយ ។

ជនជាតិដើមភាគតិច : ជនជាតិខ្មែរដើម ។

ដ . ត . ថ . ទ . ធ . ន

តតិយជន : ជនទីបី ឬភាគីទីបីក្នុងរឿង ។ អ្នកដទៃ ឬអ្នកក្រៅ ។ ឧទា : អ្នកលក់ និងអ្នកទិញ ជាភាគីទី១និងទី២ ។ អ្នកផ្សេងទៀតក្រៅពីអ្នកលក់ និងអ្នកទិញ ហៅថាតតិយជន ។

តីរហាន : ការ្យដែលបានកសាងនៅក្នុងកំពង់ផែ ឬលើច្រាំងទន្លេ សំរាប់នាវាចូលចត សំរាប់អ្នកដំណើរឡើងចុះនាវា និងសំរាប់ផ្ទុកទំនិញ និងដាក់ទំនិញចុះ ។

តែងតាំង : អោយមុខការ អោយគុណភាព ផ្តល់ឋានៈនាទី ។ ឧទា : ឈ្មោះ "ក" បានតែងតាំងឈ្មោះ "ខ"ជាទាយាទរបស់ខ្លួន ។

ផ្តោះសិទ្ធិ : ប្រាស់ចាកសិទ្ធិ បាត់បង់សិទ្ធិដោយហេតុទណ្ឌកម្ម ឬដោយហេតុមិនបានបំពេញលក្ខខណ្ឌដែលច្បាប់ឬកិច្ចសន្យាតម្រូវអោយបំពេញក្នុងរយៈពេលមានកំណត់ ។

ទាយាទ : អ្នកដែលច្បាប់តម្រូវអោយទទួលមរតកពីជនណាម្នាក់ ។ ឧទា : កូនជាទាយាទរបស់ឪពុកម្តាយចៅជាទាយាទ របស់ជីដូន ជីតា ដែលឥតមានបង្ហាញ្ញាតិជាតំណរង្ស ។

ទ្រព្យសម្បត្តិសាធារណៈ : ទ្រព្យដែលត្រូវរក្សាអោយគង់រូបតាមធម្មជាតិរបស់វា ដើម្បីទុកអោយអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅដូចជា : ស្ពាន ថ្នល់ ... ។ ល ។

ទ្រព្យទាំងអស់នេះស្ថិតនៅជាប្រយោជន៍សាធារណៈមិនអាចលក់ ដូរ និងគ្មានកំណត់អាជ្ញាយុកាលទេ ។

ទ្រព្យសម្បត្តិឯកជន : ទ្រព្យរបស់សង្គមដែលមិនសំរាប់ឱ្យជនក្នុងសង្គមនោះប្រើប្រាស់ជាសាធារណៈទូទៅទេ ជាសម្បត្តិដែលសង្គមអាចលក់ ដូរ ជួល ធ្វើអំណោយបាន ។

ធនលាភ : ផលដែលផ្តល់អោយមករាល់ឆ្នាំ ដូចជាការប្រាក់ ឈ្នួលដី ឈ្នួលផ្ទះជាដើម ។

ធម្មានុរូប : ដែលមានគុណភាពជាអ្វីមួយតាមច្បាប់ ។ ឧទា : ចៅហ្វាយស្រុកជាអាជ្ញាធរធម្មានុរូប ។ កូនដែលកើតពីឪពុក-ម្តាយដែលមានខាន់ស្លា ហៅថាកូនធម្មានុរូប ឬកូនមានខាន់ស្លា ។

និទាឃាទភាព : ភាពឥតអ្នកត្រូវទទួលមរតក ។

និទ្ទេស : សេចក្តីដែលចុះដោយសង្ខេបនៅលើរឹមទំព័រ ឬនៅខាងចុងទំព័រនៃលិខិតណាមួយ ។

និរាករណ៍ : ការលុបចោលលែងអោយប្រើច្បាប់នោះតទៅទៀត ។

នីត្យានុកូល : ដែលកើតមកពីច្បាប់ ដែលច្បាប់តាក់តែងមក ។

នីតិបុគ្គល : ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរតែដទៃទៀតពីសមាជិកនៃខ្លួន។ ឧទា : ពុទ្ធិកសមាគមជានីតិបុគ្គល ក្រុមហ៊ុនធ្វើស្ករ ក៏ជានីតិបុគ្គលដែរ ។

នីតិបុគ្គលនៃនីតិសាធារណៈ : ក្រុមរាជការសាធារណៈ ។ ឧទា : រដ្ឋ ខេត្ត ឃុំ ឬគ្រឹះ ស្ថានសាធារណៈ ដូចជាសកលវិទ្យាល័យជាដើម ។

នីតិបុគ្គលនៃនីតិឯកជន : សមាគម ក្រុមហ៊ុន ក្រុមមូលនិធិ ។

នីតិវិធី : វិធីដែលតុលាការប្រើប្រាស់ ដើម្បីចាត់ចែងរឿងក្តីតាំងពីដើមរហូតដល់ចប់ ។

នីតិសម្បទា : សមត្ថភាពដែលច្បាប់បើកអោយជនម្នាក់ៗមានយ៉ាងគ្រប់គ្រាន់ដើម្បីធ្វើការអ្វីមួយ ។

ប . ដ . ៣ . ត . ម

បទបញ្ជា : លិខិតបទដ្ឋានដែលចេញដោយអង្គការ ឬអាជ្ញាធរមានសមត្ថកិច្ច ។

បទប្បញ្ញត្តិ : សេចក្តីបញ្ញត្តិរបស់ច្បាប់ ឬរបស់មាត្រាណាមួយនៃច្បាប់ខសំខាន់របស់លិខិតក្នុងតុលាការ ។

បដិគាហាក : អ្នកទទួលអំណោយ

បដិប្បញ្ញត្តិ : ការតាំងបញ្ញត្តិផ្ទុយ ឬមិនស្រប ។

ប័ណ្ណ : លិខិតដែលមានរូបមន្តយថាភូត(ដែលមានរូបភាព និង ទម្រង់ត្រឹមត្រូវតាមច្បាប់) សំរាប់បញ្ជាក់សិទ្ធិណាមួយ ។

ប្លង់សុរិយោដី ឬផែនទីសុរិយោដី ឬប្លង់ក្បាលដី : ប្លង់រួមនៃដីតំបន់ណាមួយដែលមន្ត្រីជំនាញសុរិយោដីបានវាស់វែង គូរបំពេញយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់តាមបទដ្ឋានបច្ចេកទេស ហើយដាក់លេខក្បាលដីឬដីឡូត៍យ៉ាងច្បាស់លាស់ ។

បន្ទុក/ភារៈ/ធុរ : មុខការ/មុខងារ/អាណត្តិ/ប្រតិកម្មដែលជនណាម្នាក់ធ្វើ ឬបំពេញ ។

ឋាលិត : កូនកំព្រាជាអនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលនៃជនម្នាក់

បុព្វសិទ្ធិ : សិទ្ធិជាពិសេសដែលឱ្យដាច់ទៅលើមុខងារ ឬទៅលើក្រុមនីមួយៗ លើសពីអ្នកដទៃ ។

បុរិមា : សិទ្ធិដែលបើកអោយជនណាម្នាក់បានអ្វីមួយមុនជនឯទ្បើត ។

បេតិកភណ្ឌ : ទ្រព្យដែលជនម្នាក់ៗមាន និងបំណុលដែលជនម្នាក់ៗជំពាក់គេ ។ ទាំងទ្រព្យ ទាំងបំណុលរបស់ជនម្នាក់ៗហៅថា "បេតិកភណ្ឌ" ។

ប្រតិសិទ្ធ : អ្នកទទួលសិទ្ធបន្តពីគេដើម្បីប្រកបការរបស់ខ្លួនផង និង ជំនួសគេផង

ប្រធានសក្តិ : ព្រឹត្តិការណ៍ដែលកើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាននិងមិនអាចជំនះបាន ។

ប្រទានកម្ម : ការអោយ-អំណោយ ។

ប្រាតិភោគភណ្ឌិក : ការយកទ្រព្យទៅធានាបំណុល ។ ឧទា: កាបញ្ចាំស្រែជាប្រាតិភោគភណ្ឌិកអចលនវត្ថុ ។ ការបញ្ចាំខ្សែមាសជាប្រាតិភោគភណ្ឌិកចលនវត្ថុ ។ (ក្រមរដ្ឋប្បវេណីចាស់ប្រើប្រាតិភោគប្រត្យក្ស)

ផលទុន : ផល ឬ ចំណេញដែលកើតមកពីប្រាក់ទុន ឬពីមូលនិធិដែលគេយកទៅប្រកបមុខរបរណាមួយ ។

ផលធម្មជាតិ : ផលិតផលដែលកើតអំពីដីធ្លី ឬកូនសត្វស្រុកដែលកើតពីមេបាវា ។

ផលស៊ីវិល : ប្រាក់ដែលបានមកពីវត្ថុឬពីប្រាក់ដូចជាការប្រាក់ឬឈ្នួលផ្ទះជាដើម ។

ផលុបភោគ : សិទ្ធិបរិភោគ និងប្រើប្រាស់ផល និងផលទុនដែលកើតមកពីទ្រព្យជាកម្មសិទ្ធិរបស់អ្នកដទៃ ។

ផលុបភោគី : អ្នកបាននូវផលុបភោគ អ្នកស៊ីផល ។

ព្យសនកម្ម : ការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់រូបកាយក្តី ដល់សំភារៈក្តី ដល់ទឹកចិត្តក្តី ដែលបណ្តាលមកពីអំពើរបស់អ្នកដទៃ ។

ព្រឹត្តិការណ៍ : អ្វីៗដែលកើតមានឡើង ឬដែលប្រព្រឹត្តទៅ ។

ភតិសន្យាបតី : ម្ចាស់អចលនវត្ថុដែលដាក់អចលនវត្ថុជួលអោយអ្នកដទៃ ។

ភាគី : គូក្តី គូសញ្ញា ជនម្ខាងៗ នៃកិច្ចសន្យា ។

ភោគៈ : សិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្តោះអាសន្នមិនទាន់ស៊ប់ជារបស់ខ្លួនមែនទែនទេ ។" ភោគៈ " ជាពាក្យផ្ទុយនឹងកម្មសិទ្ធិដែលជាសិទ្ធិពេញបរិបូណ៌របស់ជនម្នាក់ៗ លើទ្រព្យណាមួយ ។ឧទា : ដីមានប្លង់សុរិយោដី ជាដីកម្មសិទ្ធិ ឯដីមិនទាន់មានប្លង់សុរិយោដី គឺជាដីភោគៈ ។

ភោគី : អ្នកទទួលបានភោគៈ ។

មធ្យោបាយ : អ្វីដែលជាគ្រឿងសំរាប់យកទៅដោះស្រាយកិច្ចការ ឬ បញ្ហាណាមួយ ។

មាតិកា : មេសេចក្តី ដើមសេចក្តី ចំណែកធំៗ នៃច្បាប់ ។ អត្ថបទច្បាប់ចែកចេញជាគន្លឹ គន្លឹចែកចេញជាមាតិកា មាតិកាចែកចេញជាជំពូក ជំពូកនិមួយៗចែកចេញជាផ្នែក ។

យ . រ . ល . ឝ

យថាហេតុ : ហេតុដែលពឹងផ្អែកទៅលើព្រឹត្តិការណ៍ណាមួយ គឺថាបើព្រឹត្តិការណ៍នោះកើតឡើងយ៉ាងណា ហេតុនោះ ក៏ត្រូវធ្វើយ៉ាងនោះដែរ ។

ឃ៉ : ចំណែកផ្ទះដែលចេញពីជញ្ជាំងទៅខាងមុខ ។

រូបមន្ត : ការងារដែលត្រូវបំពេញអោយមានរូបតាមច្បាប់កំណត់ ។

រូបវន្តបុគ្គល : បុគ្គលដែលមានរូបមែនៗ គឺមនុស្សមែន ។
ផ្ទុយនឹងនីតិបុគ្គលដែលជាមនុស្សដោយសន្មតតាមរយៀបច្បាប់ ។

លេខាចារឹក : ការកត់ត្រារឿងហេតុអ្វីមួយចូលក្នុងស្បៀវភៅ
ឬបញ្ជីតាមរូបមន្តដែលបានកំណត់ដើម្បីគ្រប់គ្រងអចលនវត្ថុ អោយបានត្រឹមត្រូវតាមច្បាប់ ។

លក្ខខណ្ឌ : គុណភាពដែលត្រូវមាន ឬខដែលត្រូវបំពេញអោយគ្រប់ចំនួន
ដើម្បីអោយបានសម្រេចបំណងណាមួយ ។

លក្ខណៈ : ភិនភាគ ឬកពារ កិរិយា បែបបទ ។

លទ្ធកម្ម : ការបានឡើងជាភោគីឬជាកម្មសិទ្ធិករនៃវត្ថុណាមួយដោយការងាររបស់ខ្លួនក្តី ដោយទិញក្តី
ដោយដូរក្តី ដោយសន្តតិកម្មក្តី ។

លិខិតយថាភូត : លិខិតធ្វើតាមរូបមន្តនៃច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម ។

វិធាន : មូលសាស្ត្រ ច្បាប់ បន្ទាត់ ។

វិធានការ : មធ្យោបាយ សេចក្តីប្រយ័ត្ន របៀបចាត់ចែងឡើងដើម្បីបង្ការ ឬទប់ទល់នឹងអ្វីមួយ ។

វិការៈអាថិកំបាំង : គុណវិបត្តិឬការខូចខាតនៃវត្ថុអ្វីមួយដែលបានលាក់
ហើយដែលគេពិនិត្យមើលលើកដំបូងទៅគ្មានឃើញថាវត្ថុនោះខូចខាតទេ
ប៉ុន្តែពេលយកវត្ថុនោះទៅប្រើប្រាស់ ប្រើពុំកើតឡើយ ។

ស . ហ

សន្តតិកម្ម : ការផ្ទេរតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់អោយទៅអ្នករស់ ។
មតិកឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ (អ្នកបន្តមតិក) ។

ស្បៀវភៅគោលបញ្ជីដី :

បញ្ជីគោលសំរាប់កត់ត្រានូវខ្លឹមសារនៃទិន្នន័យដែលបង្កើតជាស្ថានភាពនៃសិទ្ធិទាក់ទងទៅនឹងទ្រព
្យណាមួយ។ ទាក់ទងនឹងស្ថានភាពនេះ ជាទូទៅត្រូវបានកាន់កាប់ និង
ធ្វើចរន្តការតាមលំដាប់ពេលវេលា ។

សំរង់សុរិយោដី : សេចក្តីដកស្រង់នូវទិន្នន័យពាក់ព័ន្ធនឹងបច្ចេកទេស និង គតិយុត្តក្នុងវិស័យសុរិយោដី
ពីស្ថានភាពជាក់ស្តែងលើដី
យកមកកសាងជាឯកសារសុរិយោដីដើម្បីធានាសិទ្ធិស្របច្បាប់របស់កម្មសិទ្ធិករ ។

សម្បទាន : អចលនវត្ថុ (ដីធ្លី) ដែលរដ្ឋផ្តល់អោយរូបវន្តបុគ្គល ឬ នីតិបុគ្គល សំរាប់សង់លំនៅឋាន ឬ/និង
បង្កបង្កើនផលដោះស្រាយជីវភាពរស់នៅក្នុងទំហំដីតូច ពិសេសសំរាប់ ប្រជាពលរដ្ឋក្រីក្រ
(សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម)

ឬសំរាប់ធ្វើការដាំដុះធ្វើអាជីវកម្មកសិឧស្សាហកម្មក្នុងទំហំដីធំទូលាយ ពិសេសសំរាប់អ្នកវិនិយោគទុន (សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច) តាមរយៈកិច្ចសន្យាផ្តល់សម្បទានដោយត្រូវបង់ប្រាក់ជូនរដ្ឋ ។

សម្បទានិក : អ្នកទទួលបានសម្បទាន ។

សមាមាត្រ : ការប្រៀបរបស់អ្វីមួយដែលសម ដែលល្មមនឹងការឬនឹងរបស់មួយទៀត ។ ឧទា : ទណ្ឌកម្មដែលតុលាការបានផ្តន្ទានេះមានសមាមាត្រនឹងអំពើ ដែលជននោះបានប្រព្រឹត្តហើយ គឺថាសមរម្យនឹងអំពើនោះហើយ ។

សមូហភាព : ជនទាំងឡាយដែលមកជួមគ្នាជាក្រុម ឬជាសម្ព័ន្ធមួយ ។ មនុស្សទាំងអស់ក្នុងឃុំ ឬក្នុងស្រុក ឬក្នុងក្រុងណាមួយហៅថាសមូហភាព ។

សហកម្មសិទ្ធិ : កម្មសិទ្ធិតែមួយជារបស់ប្រជាជនច្រើននាក់ ។ ឧទា : ជនច្រើននាក់រួបរួមគ្នាទិញរថយន្តមួយ ។រថយន្តនោះជាសហកម្មសិទ្ធិរបស់ជនទាំងឡាយដែលទិញនោះ ។

សហកម្មសិទ្ធិករ : អ្នកដែលមានសហកម្មសិទ្ធិ ។

សហគមន៍ : អ្វីៗដែលជនទាំងឡាយយកមករួមគ្នា ។ ទ្រព្យសហគមន៍ គឺទ្រព្យដែលប្តី-ប្រពន្ធរកបានជាមួយគ្នា

សហទាយាទ : អ្នកដែលត្រូវចូលរួមក្នុងការចែកមតិកណាមួយ ។

សហព័ទ្ធ : ប្តី ឬប្រពន្ធ ឬ ទាំងប្តីទាំងប្រពន្ធ ។

ស្ថាពរ : មាំមួន ជាប់រហូត ។ ឧទា : សាលក្រមជាស្ថាពរគឺសាលក្រមដែលកាត់សេចក្តីជាស្រេចដាច់ខាតមិនត្រូវរុះរើទៀតទេ គឺថាគូក្តីមិនអាចប្តឹងឧទ្ធរណ៍ ប្តឹងសារទុក្ខបានឡើយ ។

សិទ្ធិវន្ត : អ្នកមានសិទ្ធិលើវត្ថុណាមួយ ។

សិល្បៈការ ឬ ការសិល្បៈ : សំណង់ធំៗមានសារៈសំខាន់ ធ្វើអំពីដែកឬ/និងស៊ីម៉ងត៍ ដូចជា ស្ពាន អង់តែនវិទ្យុ-ទូរទស្សន៍ ផ្លូវរូងក្នុងដីឬភ្នំ ។

សេវភាព : បន្ទុកដែលផ្កុកលើអចលនវត្ថុមួយ(ដីបំរើ ឬ ដីក្រោម) ដើម្បីជាប្រយោជន៍ដល់អចលនវត្ថុមួយទៀត (ដីប្រើ ឬ ដីលើ) ដែលជារបស់កម្មសិទ្ធិករផ្សេងទៀត ។ ឧទា : ស្រែក្រោមមានសេវភាពខាងទទួលទឹកពីស្រែលើ ។ ស្រែក្រោមហៅថាស្រែបំរើ ហើយស្រែលើហៅថាស្រែប្រើ ។

ហិតូបត្ថម្ភក : ជនដែលច្បាប់ចាត់អោយឃុំគ្រងទ្រព្យរបស់អនីតិជនឬទ្រព្យរបស់ ជនល្ងីល្ងើជាដើម ។

ឣ

អច្ចយទាន : សំបុត្របណ្តាំដែលផ្តាំអោយចែកទ្រព្យមតិកណាមួយអោយទៅជន ណាម្នាក់ ឬច្រើននាក់ ។

អឌ្ឍសិទ្ធិ	: ដែលមានសិទ្ធិពាក់កណ្តាលម្នាក់ ដែលជារបស់ជនពីរនាក់ និង ជាព្រំនៃកម្មសិទ្ធិនៃជនទាំងពីរនាក់នោះផង។ ឧទា : ជញ្ជាំងអឌ្ឍសិទ្ធិ គឺជញ្ជាំងរបស់ជនពីរនាក់ដែលមានផ្ទះជាប់គ្នា ។
អឌ្ឍសិទ្ធិភាព	: ភាពដែលជាអឌ្ឍសិទ្ធិ ។
អត្តសញ្ញាណ	: សញ្ញាទាំងអស់នៃជនម្នាក់ៗដែលជាគ្រឿងសំគាល់កុំអោយភាន់ច្រឡំ នឹងជនម្នាក់ទៀត ។
អត្តាធិនភាព	: ការបើកអោយក្មេងដែលនៅក្នុងអនីតិភាពនៅឡើយគ្រប់គ្រងខ្លួន និងទ្រព្យសម្បត្តិខ្លួនដោយខ្លួនឯង
អត្ថគាហក	: អ្នកដែលបានចំណេញ ឬបានកំរៃពីវត្ថុណាមួយ ពីគុណប្រយោជន៍អ្វីមួយ ឬពីឯកសិទ្ធិណាមួយ ។
អនុបយោគ	: ការលែងប្រើតាមការចាត់ការលុបនូវតម្យស្ថាននៃអគារសាធារណៈ។ នៅទីនេះច្បាប់អនុបយោគជាច្បាប់ដែលរំសាយពីប្រភេទទ្រព្យសម្បត្តិមួយទៅប្រភេទទ្រព្យសម្បត្តិមួយទៀត ដូចជារំសាយពីទ្រព្យសម្បត្តិសាធារណៈ មកជាសម្បត្តិឯកជនរបស់រដ្ឋជាដើម ។
អាណាព្យាបាល	: បុគ្គលដែលមានភារកិច្ចតំណាងអោយអនីតិជន ។
អវយវភេទ	: ការបាក់បែកអវយវៈ ។ ក្នុងច្បាប់ អវយវភេទបានន័យថា ការផ្ទេរសិទ្ធិខ្លះរបស់ខ្លួនលើកម្មសិទ្ធិណាមួយអោយទៅអ្នកដទៃ ។
អវិភាគកម្ម	: ភាពដែលចែកគ្នាមិនបាន ។ ឧទា : ផ្ទះមួយជាមរតករបស់កូន ៥នាក់ ពុះផ្ទះនោះចែកគ្នា ផ្ទះនោះនឹងអន្តរាយជាមិនខាន ។ ដូច្នេះផ្ទះនេះជាមរតកអវិភាគ ។
អសារកម្មសិទ្ធិ	: កម្មសិទ្ធិដែលឥតអោយផលដល់ម្ចាស់កម្មសិទ្ធិទេ ដោយហេតុថា ម្ចាស់កម្មសិទ្ធិនោះ អោយសិទ្ធិខ្លួនទៅ អ្នកដទៃស៊ីផលនៃកម្មសិទ្ធិនេះទាំងអស់ ។
អាជ្ញាធរ	: អ្នកទ្រទ្រង់អំណាច អ្នករាជការដែលកាន់អំណាច ។
អាជ្ញាយុកាល	: មធ្យោបាយម្យ៉ាងសំរាប់ដោះខ្លួនអោយរួចផុតពីកាតព្វកិច្ចណាមួយ កាលណាបើម្ចាស់កាតព្វកិច្ចនោះបណ្តែតបណ្តោយអោយជំពាក់យូរពេកមិនទារ ។
ឧបាគមនំ	: អំពើដែលឈានទៅដល់ ការឈានទៅទទួលបាន (ក្រមរដ្ឋប្បវេណី ចាស់ប្រើ សិទ្ធិដំណុះ) ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់
ស្តីពី
ការផ្តល់សិទ្ធិកម្ចីសិទ្ធិលើចំណែក ឯកជនដែរអគារសហកម្មសិទ្ធិ ដល់ជនបរទេស

ឆ្នាំ ២០០៧

ច្បាប់

ស្តីពី

ការផ្តល់សិទ្ធិកម្ចាសិទ្ធិលើចំណែក

ឯកជនទៅអគារសហកម្មសិទ្ធិ

ដល់ជនបរទេស

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

2/12

ព្រះរាជក្រម

នស/រកម/០៥១០/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខិតខត្តិយា ខេមរាវដ្ឋរាស្ត្រ ពុទ្ធិឫទ្ធាចរាមហាក្សត្រ
ខេមរាជនា សម្ភុហោតាស កម្ពុជឯករាជរដ្ឋបុរណាសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះ មានគោលដៅផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួមនៃអគារសហកម្មសិទ្ធិដល់ជនបរទេស ។

មាត្រា ២.-

ច្បាប់នេះ មានគោលបំណងដូចតទៅ :

- កំណត់អំពីគោលការណ៍ទូទៅ សិទ្ធិ និង កាតព្វកិច្ចទាំងឡាយសម្រាប់ជនបរទេសដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិផ្សេងទៀតដែលមានទំនាក់ទំនងនឹងចំណែករួម និង កំណត់អំពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិទាំងនោះ
- បង្កលក្ខណៈងាយស្រួលដល់ជនបរទេស ក្នុងការយកទុនមកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ជួយសម្រួលដល់ចុរកិច្ចរបស់វិនិយោគិនលើវិស័យសំណង់ ព្រមទាំងឆ្លើយតបទៅនឹងការកើនឡើងនៃទីផ្សារអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះជនបរទេស និង ពលរដ្ឋខ្មែរដែលមានកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

វាក្យស័ព្ទដែលប្រើក្នុងច្បាប់នេះមានន័យមន័យដូចតទៅ :

- **ជនបរទេស** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេសដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះមានសញ្ជាតិ ជំនឿ សាសនា ឬ មានដើមកំណើតពីពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើង ។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

Ksl

- **ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមច្បាប់** សំដៅដល់ជនបរទេសដែលមានសមត្ថភាពតាមច្បាប់កម្ពុជា និង បានចូលមកព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ។

- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារ ឬ សំណង់ដែលមានកម្មសិទ្ធិករច្រើនរស់នៅ ។ អគារសហកម្មសិទ្ធិ មានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា " ចំណែកឯកជន " និង មានចំណែកខ្លះជាលំហរួម សម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា " ចំណែករួម " ។

- **ចំណែកឯកជន** សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមការកាន់កាប់ និង ប្រើប្រាស់ជាឯកជនផ្តាច់មុខ ។

- **សហកម្មសិទ្ធិករលើចំណែកឯកជន** សំដៅដល់បុគ្គលដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន ។

- **ចំណែករួម** សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ ឬ ជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ជី ទីធ្លា ជណ្តើរ ជិបូល ឧច្ចាឧនិងសួនច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំងអឡុសិទ្ធ ទីកន្លែងនៃសេវាកម្មរួម ។

- **សហកម្មសិទ្ធិពិសេស** សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរួបជាជនបរទេស និងជាពលរដ្ឋខ្មែរលើអគារសហកម្មសិទ្ធិតែមួយ ដែលក្នុងនោះជនបរទេសនិងពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង មានសិទ្ធិកម្មសិទ្ធិអវិភាគពិសេសលើចំណែករួមនៃអគារសហកម្មសិទ្ធិ ។

- **សហកម្មសិទ្ធិករពិសេស** សំដៅដល់ជនបរទេសដែលមានសិទ្ធិសហកម្មសិទ្ធិពិសេស ។

- **កម្មសិទ្ធិអចិន្ត្រៃយ៍ពិសេស** សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរួបលើចំណែករួមនៃអគារសហកម្មសិទ្ធិ ដែលក្នុងនោះជនបរទេសមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម ហើយពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិអវិភាគលើចំណែករួម ដោយសារមានកម្មសិទ្ធិរួមលើចំណែកឯកជន ។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

Ksl

-ឃ្លីត សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួមនៃអគារសហកម្មសិទ្ធិ ។ ឃ្លីតនីមួយៗ មានតម្លៃខុសៗគ្នាទៅតាមទំហំតូច ឬ ធំនៃចំណែកឯកជន ហើយការគណនាត្រូវគិតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ ។

ជំពូកទី ២

គោលការណ៍ទូទៅ

មាត្រា ៥.-

ជនបរទេសដែលមានលក្ខណសម្បត្តិត្រប់គ្រាន់តាមផ្លូវច្បាប់ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម និងមានកាតព្វកិច្ចគោរពតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

មាត្រា ៦.-

ជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចាប់ពីជាន់ទី ១ (មួយ) ឡើងទៅ ។ ជាន់ផ្ទាល់ដី និង ជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ ។

ចំពោះអគារសហកម្មសិទ្ធិមួយកន្លែង សមាមាត្រ និង របៀបគិតតម្លៃនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់កម្មសិទ្ធិនេះ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ ។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិ ត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៅក្នុងអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម ។

ក្នុងករណីណាក៏ដោយ ក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសបានឡើយ ។

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតនៅក្នុងចំងាយ ៣០ (សាមសិប) គីឡូម៉ែត្រ ពីព្រំដែនគោកឡើយនិង

ROYAUME DU CAMBODGE
PALAIS ROYAL

តំបន់មួយចំនួនទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និង តំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី ៣ ជនបរទេសមានសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនស្មើចពលរដ្ឋខ្មែរដែរ ។

ជំពូកទី ៣

លទ្ធកម្មនៃសហកម្មសិទ្ធិពិសេស

មាត្រា ៧.-

សហកម្មសិទ្ធិពិសេស ត្រូវបានបង្កើត ផ្ទេរ កែប្រែដោយ :

- ការព្រមព្រៀងរវាងភាគីដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត
- សន្តតិកម្ម ។

មាត្រា ៨.-

ការផ្ទេរសហកម្មសិទ្ធិពិសេសដោយការព្រមព្រៀងមិនមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។

មាត្រា ៩.-

នៅពេលដែលសហកម្មសិទ្ធិករលើចំណែកឯកជនដែលជាពលរដ្ឋខ្មែរ បានផ្ទេរកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួនទៅជនបរទេស សហកម្មសិទ្ធិករពិសេសទទួលបានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង ទទួលបានត្រឹមតែសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួមតែប៉ុណ្ណោះ ។ ក្នុងករណីនេះ អតីតសហកម្មសិទ្ធិករលើចំណែកឯកជនជាពលរដ្ឋខ្មែរត្រូវមានសិទ្ធិរង់ខ្វះកម្មសិទ្ធិអវិភាគរបស់ខ្លួនលើចំណែករួម ។

ក្នុងករណីដែលសហកម្មសិទ្ធិករលើចំណែកឯកជនជាជនបរទេស បានផ្ទេរចំណែកឯកជនរបស់ខ្លួនមកឱ្យពលរដ្ឋខ្មែរ សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរត្រូវទទួលបានន្ទរសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង កម្មសិទ្ធិអវិភាគលើចំណែករួម ។

មាត្រា ១០.-

សន្តតិជនៃសហកម្មសិទ្ធិករពិសេស ត្រូវទទួលបន្តន្ទរសិទ្ធិ និង កាតព្វកិច្ចរបស់មតក-ជនដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

ក្នុងករណីដែលមរតកនៅទំនេរ ដោយគ្មានសន្តតិជនទទួលបន្ត ឬ សន្តតិជនចោះបង់ចោល ឬ មរតកមិនត្រូវបានចាត់ចែងឱ្យទៅជនណាមួយតាមបញ្ញត្តិច្បាប់ មរតកនៅទំនេរនោះ ត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

មាត្រា ១១.-

ក្នុងករណីដែលជនបរទេសណា ដែលបានទទួលការផ្ទេរ ឬ ទិញចំណែកឯកជន នៃអគារសហកម្មសិទ្ធិណាមួយ ដោយរំលោភបំពានលើមាត្រា ៦ នៃច្បាប់នេះ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ត្រូវទុកប្រតិបត្តិការនោះជាមោឃៈ ហើយភាគីដែលធ្វើប្រតិបត្តិការជាមួយគ្នាត្រូវធ្វើបដិទានត្រលប់វិញ ។

ជំពូកទី ៤

សិទ្ធិ និង កាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេស

ផ្នែកទី ១

សិទ្ធិ និង កាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេសលើចំណែកឯកជន

មាត្រា ១២.-

សហកម្មសិទ្ធិករពិសេសលើចំណែកឯកជន មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងលើចំណែកឯកជន ដែលជាកម្មសិទ្ធិរបស់ខ្លួន បានដោយសេរីក្នុងទំហំដែលច្បាប់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា ១៣.-

សហកម្មសិទ្ធិករពិសេសនៃចំណែកឯកជន មិនអាចប្រើប្រាស់ចំណែកឯកជនរបស់ខ្លួនក្នុងគោលបំណងណាមួយ បំពាន ឬ រាំងស្ទះដល់ការប្រើប្រាស់ ឬ រំខានដល់ជីវភាពរស់នៅរបស់សហកម្មសិទ្ធិករលើចំណែកឯកជនផ្សេងទៀតឡើយ ។

សហកម្មសិទ្ធិករពិសេសនៃចំណែកឯកជន មិនត្រូវប្រព្រឹត្តអំពើណាដែលនាំឱ្យប៉ះពាល់ដល់ការថែរក្សាអគារសហកម្មសិទ្ធិ ឬ អំពើផ្សេងទៀតដែលផ្ទុយនឹងប្រយោជន៍រួមរបស់សហកម្មសិទ្ធិករលើចំណែកឯកជនទាក់ទងនឹងការគ្រប់គ្រង ឬ ប្រើប្រាស់អគារសហកម្មសិទ្ធិឡើយ ។

មាត្រា ១៤.-

សហកម្មសិទ្ធិករពិសេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានកាតព្វកិច្ចនិងបន្ទុកផ្សេងៗដូចសហកម្មសិទ្ធិករខ្មែរដែរ ។ សហកម្មសិទ្ធិករពិសេសត្រូវគោរពរាល់កាតព្វកិច្ច និង/ឬ បន្ទុកដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិ និង/ឬ ច្បាប់ជាធរមាន ។

ផ្នែកទី ២

សិទ្ធិ និង កាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេសលើចំណែករួម

មាត្រា ១៥.-

ចំណែករួមត្រូវស្ថិតនៅក្នុងរបបកម្មសិទ្ធិអវិភាគពិសេស របស់សហកម្មសិទ្ធិករលើចំណែកឯកជនទាំងអស់ ។

សហកម្មសិទ្ធិករពិសេស មានត្រឹមសិទ្ធិប្រើប្រាស់ និង អាស្រ័យផលប៉ុណ្ណោះលើចំណែករួម ។

ROYAUME DU CAMBODGE • ROYAL PALACE • MINISTRY

Kol

មាត្រា ១៦.-

កម្មសិទ្ធិអវិភាគពិសេស និង សិទ្ធិបន្ទាប់បន្សំផ្សេងទៀតដែលទទួលស្គាល់ដោយច្បាប់ មិនអាចជាកម្មវត្ថុនៃការបែងចែក ចាត់ចែង និង បង្ខិឱ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ ។

មាត្រា ១៧.-

សហកម្មសិទ្ធិករពិសេស ត្រូវចូលរួមការចែទាំចំណែករួម ។ បន្ទុកនៃការចែទាំនេះត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬ មានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង ។

មាត្រា ១៨.-

សិទ្ធិប្រើប្រាស់ និង អាស្រ័យផល លើចំណែករួមរាប់បញ្ចូលទាំងដីដែលអគារសហកម្មសិទ្ធិតាំងនៅ ឬ ដីដែលរៀបចំដើម្បីជាទីធ្លាអគារ ដែលត្រូវបានកំណត់ថាជាចំណែករួម គឺជាសិទ្ធិដែលមិនត្រូវបានចាត់បង់ឡើយ ទោះបីជាអគារ ឬ ចំណែកឯកជននោះត្រូវបានចាត់បង់ក៏ដោយ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិទ្រុឌទ្រោម មិនអាចស្ថាក់នៅបាន ឬ ទទួលរងមហន្តរាយដោយប្រការណាមួយ ឬ ដោយវិធានការបង្ខិឱ្យរុះរើដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសុវត្ថិភាពរបស់អ្នកស្ថាក់នៅ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុល ឬ សាងសង់ជាថ្មីឡើងវិញ ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ ឬ តាមការព្រមព្រៀងគ្នាកន្លងមក ឬ តាមបទបញ្ជាផ្ទៃក្នុង ។ ការជួសជុល ឬ សាងសង់ឡើងវិញ ត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ស្តីពីលិខិតអនុញ្ញាតសាងសង់ និង ត្រូវរក្សាវចនាសម្ព័ន្ធដើមនៃអគារដដែល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ឬ មានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិទទួលរងនូវមហន្តរាយទាំងស្រុង ដោយអំពើរបស់មនុស្ស ឬ តាមរយៈប្រធានសភា ហើយសហកម្មសិទ្ធិករសញ្ជាតិខ្មែរ ឯកភាពគ្នាលក់ដីដែល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

Kol

អគារសហកម្មសិទ្ធិតាំងនៅ សហកម្មសិទ្ធិករពិសេសមានសិទ្ធិទទួលបានផ្លូវផលប្រយោជន៍ពីសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម ស្របតាមសមាមាត្រទៅនឹងផ្ទៃក្រឡានៃទំហំចំណែកឯកជនរបស់ខ្លួន ឬ តាមការព្រមព្រៀងគ្នាពីមុនមក ឬ បទបញ្ជាផ្ទៃក្នុង ។

ជំពូកទី ៥

នីតិវិធីនៃការចុះបញ្ជី និង ការចេញវិញ្ញាបនបត្រ

មាត្រា ១៩.-

បទប្បញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងយន្តការនីតិវិធីនៃការចុះបញ្ជី និង ការចេញវិញ្ញាបនបត្រ ត្រូវយកមកអនុវត្តឲ្យចំគ្នាផងដែរចំពោះនីតិវិធីនៃការចុះបញ្ជី និង ការចេញវិញ្ញាបនបត្រសម្រាប់សហកម្មសិទ្ធិពិសេសនៃអគារសហកម្មសិទ្ធ ។

គំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនជាសហកម្មសិទ្ធិករពិសេស និង កំណត់ត្រាបញ្ជាក់ផ្សេងៗអំពីសិទ្ធិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ជំពូកទី ៦

ទោសប្បញ្ញត្តិ

មាត្រា ២០.-

សហកម្មសិទ្ធិករពិសេសដែលធ្វើឱ្យប៉ះពាល់ចំណែករួមនៃអគារ ឬ ជីដោយចាន់តែប្រែជើម្បីការប្រើប្រាស់ជាឯកជន ឬ សម្រាប់លក់ នឹងត្រូវបង្ខំឱ្យរៀបចំរួចសភាពដើមវិញ ។ សហកម្មសិទ្ធិករនោះត្រូវទទួលទណ្ឌកម្មរួចមានចែងក្នុងមាត្រា ២៥៧ នៃច្បាប់ភូមិបាល ។

សហកម្មសិទ្ធិករពិសេសដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម ឬ មិនបានគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្មរួចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់ភូមិបាល ។

មាត្រា ២១.-

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដី ពាក់ព័ន្ធនឹងការចុះបញ្ជី ឬ ការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដល់សហកម្មសិទ្ធិករពិសេស ដោយបំពានលើបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៦៤ នៃច្បាប់ភូមិបាល ។

ជំពូកទី ៧
អន្តរប្បញ្ញត្តិ

មាត្រា ២២.-

ជនបរទេសណាដែលបានទទួលទិញ ឬទទួលការផ្ទេរចំណែកឯកជននៃអគារសហកម្មសិទ្ធិមុនច្បាប់នេះចូលជាធរមាន ហើយមិនស្របនឹងបញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវបានអនុញ្ញាតឱ្យធ្វើការដោះស្រាយដើម្បីឱ្យស្របតាមច្បាប់នេះឡើងវិញក្នុងរយៈពេល ០២ (ពីរ)ឆ្នាំ ។

ក្នុងករណីដែលមិនគោរពតាមកថាខណ្ឌទី ១ នោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីឱ្យលក់ចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះដោយបង្ខំ ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ២៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆកអរ

៣រស.១០០៥.៤១៥ នរោត្តម សីហមុនី

ចាឧយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចាឧជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ហត្ថលេខា
អ៊ឹម ឈុនលឹម

លេខ:៣៧៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

ឃុន ឌិនកេន

12/12

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ច្បាប់
ស្តីពី
ការអនុវត្តក្រមរដ្ឋប្បវេណី

ឆ្នាំ ២០១១

ព្រះរាជក្រម

នស/រកម/០៥២១/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា រក្សាឥស្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិត្រ្តាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស អង្គជ័យឯករាជរដ្ឋបូរណាសន្តិ សុគមន្តលា សិរីឥន្ទបុណ្យ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលរដ្ឋសភា បានអនុម័ត កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.- គោលដៅ

ច្បាប់នេះ បញ្ញត្តិអំពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ (តទៅហៅថា "ក្រមរដ្ឋប្បវេណី") ដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ១៣០៥ (កាលបរិច្ឆេទនៃការអនុវត្តជាអាទិ៍) នៃក្រមរដ្ឋប្បវេណី និង អំពីវិធានការអន្តរកាល និង ចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣០៥ នោះ ។

មាត្រា ២.- គោលបំណង

ច្បាប់នេះ មានគោលបំណងធានាស្ថិរភាពនៃទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី និង ធានាឲ្យមានការអនុវត្តបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ។

មាត្រា ៣.- វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះបញ្ហាដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី ។

មាត្រា ៤.- កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ។

មាត្រា ៥.- គោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណី

១-ក្រមរដ្ឋប្បវេណី មិនត្រូវអនុវត្តចំពោះបញ្ហាដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តដែលកំណត់នៅក្នុងមាត្រា ៤ (កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី) ខាងលើនេះ (តទៅហៅថា "កាលបរិច្ឆេទនៃការអនុវត្ត") ឡើយ លើកលែងតែមានបញ្ញត្តិផ្សេងទៀត។ ប៉ុន្តែទំនាក់ទំនងគតិយុត្តជាបន្តដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្ត ហើយនៅតែមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គិតត្រឹមពីកាលបរិច្ឆេទនៃការអនុវត្ត ។

២-អានុភាពដែលបានកើតឡើងដោយបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទម្លាប់នៃកម្ពុជានៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី មិនត្រូវបានរារាំងឡើយ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមានបញ្ញត្តិផ្សេងទៀតនៅក្នុងជំពូកទី ៥ (អន្តរប្បញ្ញត្តិ) នៃច្បាប់នេះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវរារាំងការយកក្រមរដ្ឋប្បវេណីមកអនុវត្តជាគោលការណ៍សមធម៌ ចំពោះបញ្ហាដែលកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ក្នុងករណីពុំមានបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទម្លាប់ ដែលកំណត់អំពីបញ្ហានេះ ឬ ក្នុងករណីមិនដឹងច្បាស់ថាមានបញ្ញត្តិទំនៀមទម្លាប់ ។

ជំពូកទី ២
បញ្ញត្តិសារធាតុ

មាត្រា ៦.- ការដោក់ជូនបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ទៅតុលាការ

១-តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ៧២ (ករណីយកកិច្ចធ្វើសេចក្តីពាយការណ៍អំពីការស្រាវជ្រាវទ្រព្យសម្បត្តិនីតិបុគ្គល) នៃក្រមរដ្ឋប្បវេណី គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គល ។

២-តុលាការដែលទទួលការដោក់ជូនបញ្ជីសារពើភ័ណ្ឌជាអាទិ៍ ពីនីតិបុគ្គល អាចស្រាវជ្រាវនីតិបុគ្គលនោះ បង្គាប់ឲ្យនីតិបុគ្គលនោះធ្វើនីតិវិធីដែលកំណត់ក្នុងមាត្រា ៧៨ (ធនក្ស័យនៅក្នុងពេលជម្រះបញ្ជី) នៃក្រមរដ្ឋប្បវេណីភ្លាមៗ និង ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត ដើម្បីធ្វើការជម្រះបញ្ជីឲ្យបានឆាប់ហ័សនិងត្រឹមត្រូវ ។

មាត្រា ៧.- ការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ

១-ការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ អាចបញ្ចាក់បានដោយប្រើ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" នៃលិខិតអនុសិដ្ឋដែលមាន "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" និងឯកសារចម្លងនៃលិខិតដែលត្រូវបានចុះនិទ្ទេសដោយក្រឡាបញ្ជីតុលាការ តាមវិធីខាងក្រោម :

ក-អ្នកបង្ហាញឆន្ទៈត្រូវយកមកនូវលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋ ឯកសារចម្លងនៃលិខិតនេះ និងរូបមន្តនៃ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" ឲ្យក្រឡាបញ្ជីតុលាការ ។

ប្រសិនបើក្រឡាបញ្ជីតុលាការអាចធ្វើឯកសារចម្លងនៃលិខិតនោះដោយខ្លួនឯង ក្រឡាបញ្ជីតុលាការអាចលើកលែងឲ្យអ្នកបង្ហាញធន្ធៈពីការបង្ហាញឯកសារចម្លងនៃលិខិតនោះបាន ។

ខ-ក្រឡាបញ្ជីតុលាការត្រូវ :

-ពិនិត្យ និង បញ្ជាក់ថា ឯកសារនោះពិតជាឯកសារចម្លងនៃលិខិតដែលនឹងត្រូវធ្វើជូនតាមរយៈលិខិតអនុសិដ្ឋ ឬ ធ្វើឯកសារចម្លងនៃលិខិតដែលនឹងត្រូវធ្វើជូនតាមរយៈលិខិតអនុសិដ្ឋនោះ

-ដាក់លិខិតដើមនៅក្នុងស្រោមសំបុត្រ និងបិទស្រោមសំបុត្រនោះ

-ចុះលេខដូចគ្នា និងបោះត្រាផ្លូវការនៅរឹមទំព័រនៃឯកសារចម្លង ស្រោមសំបុត្រ និង រូបមន្តនៃ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល"

-ចុះនិទ្ទេសលើឯកសារចម្លងថា បានធ្វើតាមបែបបទខាងលើនេះ

-ប្រគល់ឯកសារទាំងនេះ ទៅអ្នកបង្ហាញធន្ធៈ។

នៅពេលធ្វើនីតិវិធីខាងលើនេះ ក្រឡាបញ្ជីតុលាការត្រូវសរសេរថ្ងៃ ខែ ឆ្នាំ លេខ និង ឈ្មោះអ្នកបង្ហាញធន្ធៈនៅក្នុងសៀវភៅ ។

គ-អ្នកបង្ហាញធន្ធៈត្រូវធ្វើជូនឯកសារដើមដែលត្រូវបានដាក់ក្នុងស្រោមសំបុត្រ តាមបែបបទខាងលើនេះ តាមលិខិតអនុសិដ្ឋ ។

២-ដើម្បីធ្វើនីតិវិធីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកបង្ហាញធន្ធៈត្រូវបង់ពន្ធដែលត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលពន្ធនេះ ត្រូវបង្វែរចូលទៅថវិការដ្ឋ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងវិធីបញ្ជាក់ផ្សេងទៀតឡើយ ។

មាត្រា ៨.- និយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្តាពរ

"លិខិតដែលមានកាលបរិច្ឆេទស្តាពរ" ដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា ៤៥៩ (ឧបាទេ-សកម្មជោយការសេង) កថាខណ្ឌទី ២ នៃមាត្រា ៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) កថាខណ្ឌទី ២ នៃមាត្រា ៨៤១ (លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) និង កថាខណ្ឌទី ២ នៃមាត្រា ៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ តាមបញ្ញត្តិនៃកថាខណ្ឌទី ២

នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសេង) និង មាត្រា ៥១៣ (ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូត ។

ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវភ្លាយជាកាលបរិច្ឆេទស្តាពរ ។

ខ-លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា ។

ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវភ្លាយជាកាលបរិច្ឆេទស្តាពរ ។

គ-លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព។

ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវភ្លាយជាកាលបរិច្ឆេទស្តាពរ។

ឃ-លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្តាពរ ។

ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្តាពរនោះ ត្រូវភ្លាយជាកាលបរិច្ឆេទស្តាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

មាត្រា ៩.- អត្ថន័យនៃលិខិតយថាភូត

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្នើការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្នើការ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ ។

ខ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ (ការតតាំងនៃហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

គ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសាក្សីជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និង មាត្រា ១១៨១ (បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ កុងស៊ុលតាមបញ្ញត្តិនៃមាត្រានីមួយៗ ខាងលើនេះ ។

មាត្រា ១០.- ការអំណាត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវទទួលបន្ទុកកិច្ចការសារការីជាបណ្តោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេងនៅក្នុងច្បាប់មិនលើសពី ២ នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីរាជការសាធារណៈ ដែលមានបទពិសោធន៍ការងារផ្នែកវិស័យច្បាប់ និង មានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ។

២-ចៅក្រមដែលត្រូវបានកំណត់ថាជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវបានចាត់ទុកថា មានហេតុនៃការដកហូតសមត្ថកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្តីដែលខ្លួនបានចាត់ចែងកិច្ចការសារការី ។

៣-ចំពោះសារការី និងមន្ទីរសារការីដែលបានតែងតាំងនិងបង្កើតឡើងមុនច្បាប់នេះ ត្រូវបន្តមានសមត្ថកិច្ចបំពេញកិច្ចការសារការីស្របតាមក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ជាធរមាន ។

មាត្រា ១១.- សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់នេះ ដូចជាការផ្តល់សេចក្តីបញ្ជាក់លើលក្ខន្តិកៈ ការធ្វើលិខិតយថាភូត ជាអាទិ៍ ជាបណ្តោះអាសន្ន ។

២-ដើម្បីធ្វើលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៩ (អត្ថន័យនៃលិខិតយថាភូត) នៃច្បាប់នេះ មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវពិនិត្យ និង បញ្ជាក់អត្តសញ្ញាណរបស់ភាគីដោយសាក្សី ឬ សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ហើយក្រៅពីនេះត្រូវធ្វើការចាត់ចែងដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។

៣-បុគ្គលដែលប្រើប្រាស់សេវារបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបង់ពន្ធ ។ ចំណូលពន្ធនេះត្រូវបង្វែរចូលទៅថវិការដ្ឋ ។



៤-ការបង្កើតលិខិតយថាភូត ដែលត្រូវបានធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី ការប្រគល់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ដែលមានអានុភាពដូចគ្នានឹងច្បាប់ដើមនៃលិខិតយថាភូត និងចំណុចចាំបាច់ផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៥-ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ១២.- ការប្រកាសជាសាធារណៈ

១-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ១៩១ (កម្មសិទ្ធិវត្ថុបាត់) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដែលកំណត់ក្នុងកថាខណ្ឌដែលនោះ ដោយវិធីបិទប្រកាសដែលសរសេរអំពីប្រភេទ និង លក្ខណៈនៃវត្ថុរើស ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងដែលរើសវត្ថុនោះនៅកន្លែងបិទប្រកាសរបស់ប៉ុស្តិ៍នគរបាលនោះ ។

២-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) កថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) មាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍) ឬ កថាខណ្ឌទី ១ នៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈ ស្វែងរកសន្តតិជន) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

មាត្រា ១៣.- សិទ្ធិរបស់អ្នកសិទ្ធិកាន់ដី

១-ចំពោះកម្មសិទ្ធិលើដី "ការប្រើប្រាស់ និងការអាស្រ័យផលវត្ថុដែលជាកម្មសិទ្ធិ" ដែលកំណត់ក្នុងមាត្រា ១៣៨ (និយមន័យនៃកម្មសិទ្ធិ) នៃក្រមរដ្ឋប្បវេណី ត្រូវរួមបញ្ចូលការរៀបចំ ឬ ការកែប្រែដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធដើមនៃដី ស្របតាមការប្រើប្រាស់ដែលកម្មសិទ្ធិករចង់ធ្វើតាមការកំណត់នៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

២-ត្រូវចាត់ទុកជាការកែប្រែនូវប្រភេទ ឬ រចនាសម្ព័ន្ធដើមនៃដី ចំពោះការអនុវត្តកថាខណ្ឌទី ១ ខាងលើនេះ មានការគាស់រានដី ការកាប់ព្រៃឈើ ការជាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីកយកដីចេញ ការជីកអណ្តូងរ៉ែ ឬ កន្លែងយកថ្ម ការរៀបចំ ឬ ការធ្វើឲ្យស្ងួតដែនវារីជាតិ ការរៀបចំដីកសិកម្មទៅជាដីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្ម និង ការបង្កើតទីតាំងរោងចក្រ ជាអាទិ៍ ។

មាត្រា ១៤.- គោគៈ

១-ចំពោះដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ត្រូវបានចេញ ក្រៅពីត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់ភូមិបាលដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ (តទៅហៅថា "ច្បាប់ភូមិបាល ឆ្នាំ ២០០១") និង មាត្រា ២៤២ (ការការពារគោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់) នៃក្រមរដ្ឋប្បវេណី បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះដីនោះ ដោយចាត់ទុកថាគោគៈដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនោះ ត្រូវបានចេញជាកម្មសិទ្ធិ លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈគោគៈនោះ ។

២-បុគ្គលដែលទទួលការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឬ អនុប្បទានិករបស់បុគ្គលនោះ អាចបង្កើតសិទ្ធិប្រត្យក្ស ប្រើប្រាស់ និង អាស្រ័យផល ឬ សិទ្ធិប្រាតិភោគប្រត្យក្សបាន ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១៥.- ករណីលទ្ធកម្មកម្មសិទ្ធិ

១-ក្នុងករណីដែលបុគ្គលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៤ (គោគៈ) ខាងលើនេះ បានធ្វើលទ្ធកម្មកម្មសិទ្ធិលើដី ដោយយោងតាមបញ្ញត្តិនៃច្បាប់ភូមិបាល ឆ្នាំ ២០០១ សិទ្ធិដែលត្រូវបានបង្កើតលើដីនោះ មុនពេលលទ្ធកម្មនោះ ត្រូវក្លាយទៅជាសិទ្ធិដែលយកកម្មសិទ្ធិលើដីនោះ ឬ ដីដដែលជាកម្មវត្ថុនៃកម្មសិទ្ធិនោះមកធ្វើជាកម្មវត្ថុ ។

២-ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី ប្រសិនបើបញ្ហាអំពីអំឡុងពេលកើតឡើង ចំពោះសិទ្ធិដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវគណនា ចាប់ពីពេលដែលសិទ្ធិនោះត្រូវបានបង្កើតជាដំបូង ។ ប៉ុន្តែ ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មអំឡុងពេលនោះ ត្រូវគណនាចាប់ពីពេលដែលដីដែលនឹងត្រូវបានធ្វើលទ្ធកម្មនោះ បានក្លាយទៅជាកម្មវត្ថុនៃកម្មសិទ្ធិ ។

មាត្រា ១៦.- អន្តរប្បញ្ញត្តិ

បញ្ញត្តិនៃមាត្រា ៣៨ (អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) បញ្ញត្តិចាប់ពីមាត្រា ៤១ (អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តមានអត្ថិភាព) ដល់មាត្រា ៤៣ (អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវ

បានចុះបញ្ជី) និង បញ្ញត្តិចាប់ពីមាត្រា ៥៤ (ការធានាកាតព្វកិច្ច តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) ដល់មាត្រា ៥៧ (អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុមានអត្ថិភាព) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ត្រូវបានចេញនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ។

មាត្រា ១៧.- អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទិ៍

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០ (ដប់) ភាគរយទៅ ៣០ (សាមសិប) ភាគរយក្នុង ១ (មួយ) ឆ្នាំ ។

២-ចំពោះការព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ប្រសិនបើផលចែកនៃចំនួនប្រាក់សំណងការខូចខាតដែលបានកំណត់មុន នោះជាមួយនឹងប្រាក់ដើម លើសពីអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ភាគដែលលើសនោះត្រូវទុកជាមោឃៈ ។

៣-ប្រកាសខាងលើអាចកំណត់អត្រាដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើបាន ត្រឹមទំហំពី ១,២ ទៅ ២ ដង នៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

៤-កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីកូនបំណុលដែលបានបង់ផ្នែកលើស ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើ ត្រូវអនុវត្តចំពោះប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ដោយចាត់ទុកថា ប្រាក់ធានានោះជាការកំណត់ជាមុននូវចំនួននៃសំណងក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើនេះ ។

៦-ក្នុងករណីមិនមានការសន្យាពិសេសណាមួយស្តីពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ បញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺត

យ៉ាវនោះជាការប្រាក់ ក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណីនោះ ។

ជំពូកទី ៣
ការចុះបញ្ជីនីតិបុគ្គល

មាត្រា ១៨.- សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល

១-កិច្ចការដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល ។ បញ្ជីនីតិបុគ្គល ត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌ ។

មាត្រា ១៩.- បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គល

បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មាត្រា ២០.- ពាក្យសុំចុះបញ្ជីនីតិបុគ្គល

មាត្រា១១០ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

មាត្រា១១១ ..

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ៣ រោច ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩

ត.ស. ១៩៩៩.១៦៥៦

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ចិន ឈិន

ជា សុផារ៉ា

ខ្លឹមសម្ព័ន្ធនៃច្បាប់ស្តីពីសំណង់

សង្ខេបខ្លឹមសារ

១- ការងារសំណង់(construction work) សំដៅដល់ការងារសិក្សាគម្រោងប្តង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២- ការងារសិក្សាគម្រោងប្តង់(design work) សំដៅដល់ការងារគួរប្តង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្តីណែនាំបច្ចេកទេស និងការងារគួរប្តង់លម្អិត។

៣- ការងារវាស់វែង(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើឋានលេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្តង់ និងការងារសាងសង់។

៤- ការងារសាងសង់(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុលការងារកែប្រែ និងការដំឡើង។

៥- ការងារជួសជុល(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៦- ការងារកែប្រែ(modification work) សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៧- ការងាររុះរើ(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

៨- ការងារត្រួតពិនិត្យនិងបញ្ជាក់(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្តង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

៩- ការងារសិក្សាពិសោធ(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

១០- ការងារគ្រប់គ្រងគម្រោងសាងសង់(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រងគម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

១១. ការដកហូត(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ដោយអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ច។

១២. កិច្ចសន្យាម៉ៅការសាងសង់(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ឬរៃបន្តដើម្បីអនុវត្តការងារសាងសង់ឬរៃ។

១៣. គម្រោងប្លង់(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់ មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្តីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ឬរៃនិងការប្រើប្រាស់សំណង់។

១៤. តម្លៃនៃកិច្ចសន្យា(contract fee) សំដៅដល់កម្រៃឬតម្លៃថ្លៃរដទៃទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

១៥. ប្រធានសក្តិ(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

១៦. បទប្បញ្ញត្តិបច្ចេកទេសសំណង់(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេសលក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ជា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

១៧. បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

១៨. បន្ទុក(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

១៩. បរិក្ខារសំណង់(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ជាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាប៊ូរ៉ូប៊ីណេ ធើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត ទុយោ។

២០. ផលិតផលសំណង់(construction product) សំដៅដល់ផលិតផលសម្រេចឬពាក់កណ្តាលសម្រេចដែលកើតចេញពីការបង្កើតឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្ជាងសិលា ស៊ីម៉ងត៍ស៊ី ស្ពាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតការ៉ូ។

២១. ផលិតករ(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករឬជាអ្នកលក់។

២២. ម្ចាស់សំណង់(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

២៣. មន្ត្រីត្រួតពិនិត្យសំណង់(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២៤. វិការៈ(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

២៥. វិញ្ញាបនបត្រប្រើប្រាស់សំណង់(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

២៦. សំណង់ដែលមានសភាពគ្រោះថ្នាក់(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិតរាងកាយសុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

២៧. សំណង់(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យកម្មទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

២៨. សម្ភារៈសំណង់(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ជីឥដ្ឋ សេរ៉ាមិក ឈើ។

២៩. អ្នកសាងសង់(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬក្រុមជាងសំណង់។

៣០. អ្នកអភិវឌ្ឍអចលនវត្ថុ(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

៣១. អាជ្ញាធរមានសមត្ថកិច្ច(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣២. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

៣៣. អ្នកជំនាញក្នុងវិស័យសំណង់(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្តុះបណ្តាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធតម្លៃការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤. អ្នកគ្រប់គ្រងសំណង់(building manager) សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ
ស្តីពី
ការបង្កើតគណៈវិស្វកររកម្ពុជា

ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤១៣

ស្តីពី

ការបង្កើតគណៈទីសូរកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សហានតូមីជាតិសាសនា ភ្នែតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុគមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩

គ្រាស់បង្កាប់

ដូចតទៅ

បទប្បញ្ញត្តិទូទៅ

LE MINISTRE DU PALAIS ROYAL * ROYAUME DU CAMBODGE *

មាត្រា ១ ..

ត្រូវបានបង្កើតគណៈវិស្វករកម្ពុជា ដែលសរសេរកាត់ថា "**គ.វ.ក.**" ដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងវិស្វករ ចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២ ..

ព្រះរាជក្រឹត្យនេះមានគោលបំណងដូចតទៅ ÷

- រួមចំណែករៀបចំវិជ្ជាជីវៈវិស្វកម្មឱ្យកាន់តែល្អប្រសើរ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់វិស្វករ
- រួមចំណែកថែរក្សា និងលើកស្ទួយអត្តសញ្ញាណជាតិ
- ពង្រឹងសមត្ថភាពបច្ចេកទេសគ្រប់ជំនាញ និងពង្រីកធនធានមនុស្សឱ្យស្របតាមកាលៈទេសៈបច្ចុប្បន្ន និងអនាគត
- ធានាឱ្យការប្រកបវិជ្ជាជីវៈវិស្វកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងការទទួលខុសត្រូវខ្ពស់
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងផ្ទៃក្នុងវិស្វកម្មថ្នាក់ជាតិ និងទំនាក់ទំនងរវាងវិស្វកម្មជាតិ និងវិស្វកម្មអន្តរជាតិ
- ទទួលស្គាល់គុណភាពរបស់វិស្វករកម្ពុជា ដើម្បីឱ្យមានគោរម្យងារជាវិស្វករអាជីពជាតិ និងអន្តរជាតិ
- រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈវិស្វកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យស្របតាមតម្រូវការសង្គម។

មាត្រា ៣ ..

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះវិស្វកររខ្មែរ និងវិស្វកររបរទេសដែលបានចុះបញ្ជីនៅ **គ.វ.ក.**។ ព្រះរាជក្រឹត្យនេះមិនមានវិសាលភាពអនុវត្តចំពោះវិស្វករ ដែលកំពុងបំពេញការងារក្នុងក្របខណ្ឌក្រសួង និងស្ថាប័នរដ្ឋឡើយ។

មាត្រា ៤ ..

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះមានន័យដូចតទៅ ÷

- **វិស្វករ** សំដៅដល់រូបវន្តបុគ្គលខ្មែរ និងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញវិស្វកម្មដោយជោគជ័យនៅតាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- **វិស្វកររអាជីព** សំដៅដល់វិស្វកររខ្មែរ និងវិស្វកររបរទេស ដែលបានចុះឈ្មោះទទួលស្គាល់ក្នុងបញ្ជីនៃ **គ.វ.ក.** និងបានបំពេញលក្ខខណ្ឌស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- **វិស្វកររអាស៊ាន** សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិ ក្នុងប្រទេសជាសមាជិកអាស៊ាន និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មវិស្វកម្មរបស់អាស៊ាន ក្រោមការត្រួតពិនិត្យ និងវាយតម្លៃរបស់គណៈកម្មាធិការចុះបញ្ជីវិស្វកររអាស៊ាន
- **វិជ្ជាជីវៈវិស្វកម្ម** សំដៅដល់ការងារពាក់ព័ន្ធនឹងការសិក្សាគម្រោង ការអនុវត្ត និងលិខិតបទដ្ឋានបច្ចេកទេស ទាំងឡាយ ដែលទាក់ទងនឹងការងារវិស្វកម្ម។

ជំពូកទី២
ការរៀបចំនិងការប្រជ្រើសរើសនៃគណៈវិស្វកររកម្ពុជា
ផ្នែកទី១
ប្រធានកិត្តិយសនៃគណៈវិស្វកររកម្ពុជា

មាត្រា ៥ ..

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស នៃ **គ.ទ.ក.** ។

មាត្រា ៦ ..

ប្រធានកិត្តិយស នៃ **គ.ទ.ក.** ជាអធិបតីក្នុងមហាសន្និបាត **គ.ទ.ក.** និងផ្តល់អនុសាសន៍ដល់ **គ.ទ.ក.** ។

ផ្នែកទី២

មហាសន្និបាត

មាត្រា ៧ ..

- មហាសន្និបាតប្រចាំឆ្នាំ **គ.ទ.ក.** ត្រូវប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធាន ក្រុមប្រឹក្សា **គ.ទ.ក.**

- មហាសន្និបាត **គ.ទ.ក.** ប្រព្រឹត្តទៅ ០៥ (ប្រាំ) ឆ្នាំម្តង ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើស**អគ្គលេខាធិការ** និង អគ្គលេខាធិការរង

- មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា **គ.ទ.ក.ឬតាមការស្នើសុំ** ពីសំណាក់ចុះបញ្ជីយ៉ាងតិចចំនួន៣០ (សាមសិប) ភាគរយ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំ **ដោយ**មានភ្ជាប់ របៀបវារៈមកជាមួយផង។

មាត្រា ៨ ..

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មហាសន្និបាត **គ.ទ.ក.** ដូចមានចែងក្នុងមាត្រា ៧ **ត្រូវកំណត់ដោយ** បទបញ្ជាផ្ទៃក្នុង **គ.ទ.ក.** ។

ផ្នែកទី៣

ក្រុមប្រឹក្សាគណៈទិស្សការកម្ពុជា

មាត្រា ៩ ..

ក្រុមប្រឹក្សា **គ.ទ.ក.** មានសមាសភាពដូចតទៅ +

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
- ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិដែលមានបទពិសោធខាងវិស័យវិស្វកម្ម	អនុប្រធាន
- តំណាងក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម	សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល	សមាជិក
- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
- **អគ្គលេខាធិការ គ.ទ.ក.**	**សមាជិកអចិន្ត្រៃយ៍**

សមាសភាពក្រុមប្រឹក្សា **គ.ទ.ក.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

មាត្រា ១០ ..

ក្រុមប្រឹក្សា **គ.ទ.ក.** មានសិទ្ធិទាក់ទងនិងអញ្ជើញតំណាងក្រសួង ស្ថាប័ននានាដែលពុំមានចែងក្នុង**មាត្រា**៩ ខាងលើ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងតំណាងប្រទេសនានា តាមការចាំបាច់ដើម្បីចូលរួម**ប្រជុំ**ផ្តល់យោបល់ ក្នុងវិស័យអ្នកសម្រេចការណ៍។

មាត្រា ១១ ..

ក្រុមប្រឹក្សា គ.ទ.ក. មានភារកិច្ចដូចតទៅ ÷

- អនុម័តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ គ.ទ.ក.
- តាមដាននិងត្រួតពិនិត្យដំណើរការការងារ គ.ទ.ក.
- ផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋានអំពីការងារចាំបាច់
- សម្របសម្រួលនិងដោះស្រាយរាល់វិវាទផ្សេងៗរបស់ គ.ទ.ក.
- ផ្តល់យោបល់ក្នុងការចុះបញ្ជីវិស្វករអាជីព ការលើកទឹកចិត្ត និងការដាក់វិន័យ។

មាត្រា ១២ ..

ក្រុមប្រឹក្សា **គ.ទ.ក.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់ ០១ (មួយ)ឆ្នាំម្តង។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំជាវិសាមញ្ញបាន ។

ផ្នែកទី៤

អគ្គលេខាធិការដ្ឋាន

មាត្រា ១៣ ..

គ.ទ.ក. មានអគ្គលេខាធិការដ្ឋានមួយ ដែលមានតួនាទីជាអង្គភាពប្រតិបត្តិ និងមានភារកិច្ចដូចតទៅ ÷

- រៀបចំ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិស្វករ ដែលអនុម័តដោយក្រុមប្រឹក្សា **គ.ទ.ក.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ដំណើរការ **គ.ទ.ក.**
- ធានានិរន្តរភាពការងារនៃអគ្គលេខាធិការដ្ឋាន **គ.ទ.ក.**
- ផ្សព្វផ្សាយអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យវិស្វកម្មគ្រប់ជំនាញ និងចូលរួមរៀបចំច្បាប់ និងបទដ្ឋានគតិយុត្តទាំងឡាយ តាមការអញ្ជើញរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ជួយសម្រួលក្នុងការការពារកម្មសិទ្ធិបញ្ញារបស់វិស្វករអាជីព
- ពង្រឹងសមត្ថភាពចូលរួមក្នុងការប្រកួតប្រជែងដោយយុត្តិធម៌ និងស្មើភាពគ្នារវាងវិស្វករអាជីពកម្ពុជា និងវិស្វករបរទេស
- ធ្វើសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពវប្បធម៌នៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សា វគ្គបំប៉នជំនាញ និងការអប់រំក្រោយឧត្តមសិក្សា
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់វិស្វករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈវិស្វកម្មឱ្យមានការទទួលស្គាល់ក្នុងក្របខណ្ឌអាស៊ាន និងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈវិស្វកម្មរបស់វិស្វករអាជីពកម្ពុជា និងវិស្វករបរទេស
- ចុះបញ្ជីតំណត់គុណវុឌ្ឍិអាជីពវិជ្ជាជីវៈវិស្វកម្មរបស់រូបវន្តបុគ្គលឱ្យទៅជាវិស្វករអាជីព និងធានានិរន្តរភាព

ការចុះបញ្ជីវិស្វករអាជីព នៅព្រះរាជាណាចក្រកម្ពុជា

- ជ្រើសរើស និងវាយតម្លៃលើបេក្ខភាពវិស្វករអាជីពកម្ពុជា ដើម្បីឱ្យទៅជាវិស្វករអាស៊ាន
- រៀបចំគុណវុឌ្ឍិជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌របស់វិស្វករអាជីពដោយសហការជាមួយគ្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើកោសលវិច័យលើការអនុវត្តការងាររបស់វិស្វករអាជីព ក្នុងករណីមានទំនាស់ក្នុងការបំពេញវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារ **គ.ទ.ក.** ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ និងក្រុមប្រឹក្សា **គ.ទ.ក.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូន ដោយក្រុមប្រឹក្សា **គ.ទ.ក.** ។

មាត្រា ១៤ ..

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។ អគ្គលេខាធិការមានឋានៈទាបបំផុតស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈ**ទាបបំផុតស្មើ**អនុរដ្ឋលេខាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ទ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១៥ ..

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.ទ.ក.** ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដោយមហាសន្និបាត **គ.ទ.ក.**សម្រាប់អាណត្តិ ០៥ (ប្រាំ) ឆ្នាំ។

វិស្វករដែលមានសញ្ជាតិខ្មែរអាចឈរឈ្មោះឱ្យ**គ.ទ.ក.**បោះឆ្នោតជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងបានត្រូវមានឈ្មោះក្នុងបញ្ជីវិស្វករអាជីពយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ ហើយមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋណាមួយឡើយ ។

មាត្រា ១៦ ..

ករណីដែលអគ្គលេខាធិការ ឬអគ្គលេខាធិការរងណាម្នាក់ទទួលមរណភាព ឬលាឈប់ពីមុខងារក្នុង**អាណត្តិរបស់**ខ្លួន **គ.ទ.ក.**ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបញ្ចប់អាណត្តិ ស្របតាមបទបញ្ជាផ្ទៃក្នុង។

មាត្រា ១៧ ..

គ.ទ.ក. មាននិមិត្តសញ្ញា និងត្រាដោយឡែករបស់ខ្លួន។

ផ្នែកទី៥

ក្រុមប្រឹក្សាគណៈវិស្វករាជធានី ខេត្ត

មាត្រា ១៨ ..

គ.ទ.ក.អាចបង្កើតក្រុមប្រឹក្សាគណៈវិស្វករាជធានី ខេត្តបាន ក្នុងករណីដែលមានសមាជិកជា**វិស្វករចុះបញ្ជី**អាយុ ២០ (ម្ភៃ) រូបឡើងទៅ ដែលក្នុងនោះត្រូវមានវិស្វករអាជីពយ៉ាងតិច ០៥(ប្រាំ)រូប។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ទ.ក.** ។

ជំពូកទី៣

ការប្រកបវិជ្ជាជីវៈវិស្វកម្ម

មាត្រា ១៩ ..

វិស្វករ ដែលអាចក្លាយទៅជាវិស្វកររាជីពបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- បានចុះបញ្ជី **គ.ទ.ក.**
- គ្មានការហាមឃាត់ការប្រកបវិជ្ជាជីវៈនេះដោយតុលាការ និង
- បំពេញលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ទ.ក.** ។

មាត្រា ២០ ..

វិស្វកររាជីពអាចប្រកបវិជ្ជាជីវៈវិស្វកម្មដោយខ្លួនឯងបាន ដោយត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

វិស្វកររាជីពអាចប្រកបវិជ្ជាជីវៈវិស្វកម្មបានដោយមានការទទួលខុសត្រូវរបស់វិស្វកររាជីព។

មាត្រា ២១ ..

វិស្វករដែលបានបំពេញគ្រប់លក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១៩ ខាងលើត្រូវទទួលបានវិញ្ញាបនបត្រវិស្វកររាជីព ដែលចេញ ដោយ **គ.ទ.ក.** ។

មាត្រា ២២ ..

ជនបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅ **គ.ទ.ក.** និងត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២៣ ..

ការប្រកបវិជ្ជាជីវៈវិស្វកម្ម ត្រូវគោរពតាមក្រមសីលធម៌វិស្វករ ដែលអនុម័តដោយក្រុមប្រឹក្សា **គ.ទ.ក.** ។

មាត្រា ២៤ ..

វិស្វករខ្មែរនិងវិស្វកររបរទេស ដែលបានចុះបញ្ជី **គ.ទ.ក.**នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបង់ភាគទានប្រចាំឆ្នាំជូន **គ.ទ.ក.** ។

ប្រភេទនិងចំនួនទានដែលត្រូវបង់ជូន **គ.ទ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ទ.ក.** ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ២៥ ..

វិស្វករចុះបញ្ជី និងវិស្វករអាជីព អាចសុំព្យួរការប្រកបវិជ្ជាជីវៈរបស់ខ្លួនបាន តាមការកំណត់របស់ **គ.ទ.ក.**។

ជំពូកទី៤

គោរម្យងារកិត្តិយស

មាត្រា ២៦ ..

គ.ទ.ក. អាចផ្តល់គោរម្យងារជាវិស្វករកិត្តិយសជូនដល់វិស្វករអាជីព ក្រោយពីបានប្រកបវិជ្ជាជីវៈវិស្វកម្ម រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ។

គ.ទ.ក. អាចផ្តល់គោរម្យងារជាសមាជិកកិត្តិយសជូនដល់ឥស្សរជន ឬបុគ្គលទាំងឡាយណា ដែលបានឧបត្ថម្ភគាំទ្រផ្នែកថវិកា ឬ បច្ចេកទេសដល់ **គ.ទ.ក.** តាមការកំណត់របស់ក្រុមប្រឹក្សា **គ.ទ.ក.**។

មាត្រា ២៧ ..

គោរម្យងារជាវិស្វករកិត្តិយសអាចត្រូវដកវិញបាន ប្រសិនបើវិស្វកររូបនោះបានប្រព្រឹត្តផ្ទុយនឹងវិធានបច្ចេកទេស ឬក្រមសីលធម៌វិស្វករ ទោះបីការប្រព្រឹត្តនោះ នៅក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

ជំពូកទី៥

ក្រុមប្រឹក្សាវិន័យ

មាត្រា ២៨ ..

ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន ០៥ (ប្រាំ)រូប ដែលត្រូវតែងតាំងឡើងដោយប្រធានក្រុមប្រឹក្សា **គ.ទ.ក.** ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គ.ទ.ក.**និងសមាជិកនៃអគ្គលេខាធិការដ្ឋាន **គ.ទ.ក.**។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការសម្រេចដាក់វិន័យ ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង **គ.ទ.ក.**។

មាត្រា ២៩ ..

ក្រុមប្រឹក្សាវិន័យមានតួនាទីដូចតទៅ +

- ទទួលបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងវិស្វករដែលបានចុះបញ្ជីនៅ **គ.ទ.ក.**
- ដោះស្រាយវិវាទទាក់ទងនឹងវិជ្ជាជីវៈវិស្វករដែលបានចុះបញ្ជីនៅ **គ.ទ.ក.**
- ដាក់ទណ្ឌកម្មខាងវិន័យដល់វិស្វករណាដែលប្រព្រឹត្តផ្ទុយនឹងវិធានបច្ចេកទេស ឬក្រមសីលធម៌វិស្វករ។

មាត្រា ៣០ ..

វិស្វករដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្តឹងតវ៉ា ទៅប្រធាន ក្រុមប្រឹក្សា **គ.ទ.ក.** ប្រធានក្រុមប្រឹក្សា **គ.ទ.ក.** ត្រូវចាត់តាំងសមាជិកចំនួន ០៧ (ប្រាំពីរ) រូបផ្សេងទៀត ក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានោះ។ សេចក្តីសម្រេចចុងក្រោយនេះ ជាសេចក្តីសម្រេចចិទ្ធរឹតតែ។

បែបបទ និងនីតិវិធីនៃការតវ៉ា និងរយៈពេលនៃការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ឥ.ក.។

ជំពូកទី៦
ទណ្ឌកម្មខាងវិន័យ

មាត្រា ៣១ ..

ទណ្ឌកម្មខាងវិន័យរួមមាន ÷

- ការព្រមាន
- ការស្តីបន្ទោស
- ការព្យួរសិទ្ធិមួយរយៈពេលដែលពុំអាចលើសពី ០២ (ពីរ) ឆ្នាំ
- ការលុបឈ្មោះចេញពីបញ្ជី គ.ឥ.ក.ឬហួតហែរងារកិត្តិយស។

ការទទួលទណ្ឌកម្មខាងវិន័យ មិននាំឱ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌឡើយ។

ជំពូកទី៧
ប្រភពធនធាន

មាត្រា ៣២ ..

ប្រភពធនធានរបស់ គ.ឥ.ក. សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី ÷

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ភាគទានដែលបានពីសមាជិក គ.ឥ.ក.
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជនផ្សេងៗ។
- ជំនួយឥតសំណងផ្សេងៗ។

គ.ឥ.ក.មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ជំពូកទី៨
អន្តរប្បញ្ញត្តិ

មាត្រា ៣៣ ..

ក្នុងអាណត្តិដំបូង អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃ គ.ឥ.ក. ត្រូវតែងតាំងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រុមប្រឹក្សា គ.ឥ.ក.។

មាត្រា ៣៤ ..

វិស្វករទាំងឡាយដែលបាន និងកំពុង ឬមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្ម ត្រូវមកសុំបំពេញបែបបទ និងចុះឈ្មោះក្នុងបញ្ជី គ.ទ.ក. ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ។

ជំពូកទី៩

អវសានប្បញ្ញត្តិ

មាត្រា ៣៥ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៦ ..

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆនៈ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

៣ សាស.០៩០៤.៤១៦

លេខ : ៣៧៤ ច.ល

ជើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៤

រដ្ឋលេខាធិការអង្គព្រះរាជដ្ឋានគិយាល

ឈាង ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា ៣ មាត្រា ៤ និង មាត្រា ២២ នៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈវិស្វកររកម្ពុជា

ឆ្នាំ ២០១៦

ព្រះរាជក្រឹត្យ

នស/រកត/០២១៦/ ១៨៤

ស្តីពី

ការកែសម្រួលមាត្រា៣ មាត្រា៤ និងមាត្រា២២
នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា
ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិង្ករាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជ្ជបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • MINISTERE DU PALAIS ROYAL •

ត្រាស់បង្គាប់

មាត្រាមួយ ..

មាត្រា៣ មាត្រា៤ និងមាត្រា២២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

មាត្រា៣ថ្មី ..

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះវិស្វករខ្មែរនិងវិស្វកបរទេសដែលប្រកបវិជ្ជាជីវៈវិស្វកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៤ថ្មី ..

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **វិស្វករ** សំដៅដល់រូបវន្តបុគ្គលខ្មែរឬរូបវន្តបុគ្គលបរទេសដែលបានបញ្ចប់ការសិក្សាជំនាញវិស្វកម្ម ដោយជោគជ័យ នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- **វិស្វកចុះបញ្ជី** សំដៅដល់វិស្វកដែលបានចុះបញ្ជីនៅ **គ.វ.ក**.
- **វិស្វកអាជីព** សំដៅដល់រូបវន្តបុគ្គលខ្មែរឬរូបវន្តបុគ្គលបរទេស ដែលបានចុះឈ្មោះទទួលស្គាល់ក្នុងបញ្ជីនៃ **គ.វ.ក**. និងបានបំពេញលក្ខខណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- **វិស្វកអាស៊ាន** សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិ ក្នុងប្រទេសជាសមាជិកអាស៊ាននិងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មវិស្វកម្មរបស់អាស៊ាន ក្រោមការត្រួតពិនិត្យនិងវាយតម្លៃរបស់គណៈកម្មាធិការចុះបញ្ជីវិស្វកអាស៊ាន
- **វិជ្ជាជីវៈវិស្វកម្ម** សំដៅដល់ការងារជំនាញខាងការសិក្សាគម្រោង ការអនុវត្ត និងលិខិតបទដ្ឋានបច្ចេកទេសទាំងឡាយដែលទាក់ទងនឹងការងារវិស្វកម្ម។

មាត្រា២២ថ្មី ..

វិស្វកបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅ **គ.វ.ក**. និងត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រាពីរ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបី ..

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៦

ព្រះហស្តលេខា និងព្រះរាជលញ្ជីការ
នរោត្តម សីហមុនី

ការ. ១៦០៤. ១៨៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា
សុខ អាន

លេខ: ១៩៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ
ស្តីពីការកែសម្រួលមាត្រា ៧ មាត្រា ៩ និងមាត្រា ៣២ នៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈវិស្វកររកម្ពុជា

ឆ្នាំ ២០១៦

ន.ស/រកត/០៦១៧/៤២២

ព្រះរាជក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា៧ មាត្រា៩ និងមាត្រា៣២
នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហនភូមិន្ទាធិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិង្ករាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោកាស កម្ពុជឯករាជប្បរណាសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១៦/១៨៤ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៤ និងមាត្រា២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា មួយ..

មាត្រា៧ មាត្រា៩ និងមាត្រា៣២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា ត្រូវបានកែសម្រួលនិងបំពេញបន្ថែមដូចតទៅ៖

មាត្រា ៧ថ្មី..

មហាសន្និបាត

- មហាសន្និបាទ **គ.វ.ក.** ប្រព្រឹត្តិទៅ ០៥(ប្រាំ)ឆ្នាំម្តង ដើម្បីរៀបចំបោះឆ្នោតជ្រើសរើសអគ្គលេខាធិការ និងអគ្គលេខាធិការរង

- មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តិទៅបាន តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា **គ.វ.ក.** ឬតាមការ ស្នើសុំពីវិស្វកចុះបញ្ជីយ៉ាងតិចចំនួន ៣០(សាមសិប)ភាគរយ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំ ដោយមាន ភ្ជាប់របៀបវារៈមកជាមួយផង។

សន្និបាត

- សន្និបាតប្រចាំឆ្នាំ **គ.វ.ក.** ត្រូវប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានក្រុមប្រឹក្សា **គ.វ.ក.**។

មាត្រា ៩ថ្មី..

ក្រុមប្រឹក្សា **គ.វ.ក.** មានសមាសភាពដូចតទៅ៖

- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
- ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិ ដែលមានបទពិសោធខាងវិស័យវិស្វកម្ម	អនុប្រធាន
- តំណាងក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម	សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល	សមាជិក
- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
- អគ្គលេខាធិការ **គ.វ.ក.**	សមាជិកអចិន្ត្រៃយ៍

សមាសភាពក្រុមប្រឹក្សា **គ.វ.ក.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

មាត្រា ៣២ថ្មី..

ប្រភពធនធានរបស់ **គ.វ.ក.** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ
- ភាគទានដែលបានពីសមាជិក **គ.វ.ក.**
- ជំនួយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា ក្នុងប្រទេសនិងតំណាងផ្សេងៗ។

គ.វ.ក. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេស សម្រាប់បម្រើការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

មាត្រា ពីរ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា បី..

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៧

ទាន់សា. ១៧០៦. ជ.ប្រ.ស

ព្រះហស្តលេខា និងព្រះរាជលញ្ជកររ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រី
ប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា
ហត្ថលេខា
អ៊ុត សំហេង

លេខ: ៤៧២ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ
ស្តីពី
ការបង្កើតគណៈស្ថាបត្យកម្ម កម្ពុជា

ឆ្នាំ ២០១៧

ទទួលនៅ ន.ស.ស.ស.
លេខ 083
ថ្ងៃទី 10/01/12 11:20
ហត្ថលេខា

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ទទួលកាលបរិ
លេខ 125
ថ្ងៃទី 13/01/12 ម៉ោង 9:40
ហត្ថលេខា

នស/រកត/១២១១/១១២៤

ព្រះរាជក្រឹត្យ

ស្តីពី

ការបង្កើតគណៈស្ថាបត្យកររកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាស់បង្គាប់
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតគណៈស្ថាបត្យករកម្ពុជាដែលសរសេរជាអក្សរកាត់ថា **គ.ស.ក.** និងដែលមានគោលបំណងប្រមូលផ្តុំនិងគ្រប់គ្រងស្ថាបត្យករដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់វិជ្ជាជីវៈ គុណភាពស្នាដៃរបស់ស្ថាបត្យករ និងកិត្យានុភាពនៃស្ថាបត្យកម្មកម្ពុជា។

មាត្រា ២.-

ព្រះរាជក្រឹត្យនេះមានគោលដៅដូចតទៅៈ

- រួមចំណែករៀបចំវិជ្ជាជីវៈស្ថាបត្យកម្មឲ្យកាន់តែល្អប្រសើរ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ថាបត្យករ
- រួមចំណែកថែរក្សា ការពារ អភិវឌ្ឍស្ថាបត្យកម្មខ្មែរ និងលើកកម្ពស់អត្តសញ្ញាណជាតិ
- ពង្រឹងនិងលើកកម្ពស់សមត្ថភាពនិងគុណភាពបន្ថែមដល់ស្ថាបត្យករដែលប្រកបមុខរបរអាជីវកម្ម ដោយគោរពខ្ជាប់ខ្ជួននូវក្រមសីលធម៌
- ធានាឲ្យបានការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការការពារទេសភាពធម្មជាតិនិងបេតិកភណ្ឌជាតិ
- ពង្រឹងនិងបើកទូលាយទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ព្រមទាំងធ្វើសមាហរណកម្មស្ថាបត្យកម្មជាតិចូលក្នុងពិភពលោកនិងក្នុងតំបន់ ជាពិសេសក្នុងសមាគមជាមួយបណ្តាប្រទេសអាស៊ាន
- ទទួលស្គាល់ទេពកោសល្យរបស់ស្ថាបត្យករកម្ពុជា ដើម្បីឲ្យមានគោរមងារជាស្ថាបត្យករជាតិនិងអន្តរជាតិ
- រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈស្ថាបត្យកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឲ្យស្របតាមតម្រូវការសង្គមជាតិ តម្រូវការតំបន់ និងតម្រូវការពិភពលោក
- លើកទឹកចិត្តស្ថាបត្យករដែលបង្កើតទស្សនៈស្ថាបត្យកម្មថ្មីៗនិងស្ថាបត្យកម្ម ដែលមានលក្ខណៈជាអត្តសញ្ញាណជាតិគួបផ្សំនឹងលក្ខណៈទំនើប។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះស្ថាបត្យករខ្មែរនិងស្ថាបត្យកររបរទេសដែលមានឈ្មោះក្នុងបញ្ជី **គ.ស.ក.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ៤.-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ស្ថាបត្យកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារនិងការសាងសង់ទាំងក្នុងនិងក្រៅនៃសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេសនិងតាមសំណុំសោភណភាពដែលបានគ្រោងទុក ដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន។
- **ស្ថាបត្យករ** សំដៅដល់រូបវន្តបុគ្គលខ្មែរនិងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញស្ថាបត្យកម្មដោយជោគជ័យ តាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ស្ថាបត្យករចុះបញ្ជី** សំដៅដល់ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ហើយមិនទាន់បានបំពេញលក្ខខណ្ឌដើម្បីក្លាយជាស្ថាបត្យករ **គ.ស.ក.**។
- **ស្ថាបត្យករគ.ស.ក.** សំដៅដល់ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ហើយបានបំពេញលក្ខខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សា **គ.ស.ក.**និងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ស្ថាបត្យករអាស៊ាន** សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិក្នុងប្រទេសជាសមាជិកអាស៊ាននិងបានបំពេញលក្ខខណ្ឌត្រឹមត្រូវស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មស្ថាបត្យកម្មរបស់អាស៊ានក្រោមការត្រួតពិនិត្យនិងការវាយតម្លៃរបស់ក្រុមប្រឹក្សាស្ថាបត្យករអាស៊ាន។
- **វិជ្ជាជីវៈស្ថាបត្យកម្ម** សំដៅដល់រាល់ការងារពាក់ព័ន្ធនឹងការសិក្សា ការរៀបចំនិងការអនុវត្តគម្រោងប្លង់ស្ថាបត្យកម្ម និងលិខិតបទដ្ឋានបច្ចេកទេសទាំងឡាយដែលទាក់ទងនឹងការងារស្ថាបត្យកម្ម។

ជំពូកទី២
ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈស្ថាបត្យករកម្ពុជា
ផ្នែកទី១
ប្រធានកិត្តិយសនៃគណៈស្ថាបត្យករកម្ពុជា

មាត្រា ៥.-

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយសនៃ **គ.ស.ក.**។

ROYAUME DU CAMBODGE * MINISTERE DU PALAIS ROYAL *

មាត្រា ៦.-

ប្រធានកិត្តិយសនៃ **គ.ស.ក.** ជាអធិបតីក្នុងមហាសន្និបាត **គ.ស.ក.** និងផ្តល់អនុសាសន៍ណែនាំដល់ **គ.ស.ក.**។

ក្នុងករណីចាំបាច់ ប្រធានកិត្តយសនៃ **គ.ស.ក.**អាចប្រគល់ភារកិច្ចជូនឥស្សរជនណាមួយធ្វើជាតំណាងដើម្បីធ្វើជាអធិបតីក្នុងមហាសន្និបាត **គ.ស.ក.** ។

ផ្នែកទី២
ក្រុមប្រឹក្សាគណៈស្ថាបត្យកររកម្ពុជា

មាត្រា ៧.-

ក្រុមប្រឹក្សា **គ.ស.ក.** មានសមាសភាពដូចតទៅ៖

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ប្រធាន
- ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិឬឥស្សរជនកម្ពុជា ដែលមានបទពិសោធខាងវិស័យស្ថាបត្យកម្ម	អនុប្រធាន
- តំណាងក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម	សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល	សមាជិក
- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
- អគ្គលេខាធិការ **គ.ស.ក.**	សមាជិកអចិន្ត្រៃយ៍

សមាសភាពក្រុមប្រឹក្សា **គ.ស.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

មាត្រា ៨.-

ក្រុមប្រឹក្សា **គ.ស.ក.** មានសិទ្ធិទាក់ទងនិងអញ្ជើញតំណាងក្រសួង ស្ថាប័ននានាដែលពុំមានចែងក្នុងមាត្រា៧ខាងលើ សមាគម អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន អង្គការអន្តរជាតិ និងតំណាងប្រទេសនានាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ឬធ្វើជាអ្នកសង្កេតការណ៍។

មាត្រា ៩.-

ក្រុមប្រឹក្សា **គ.ស.ក.** មានភារកិច្ចដូចតទៅ៖

- អនុម័តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្ថាបត្យករ
- អនុម័តថវិកាប្រចាំឆ្នាំរបស់ **គ.ស.ក.**
- តាមដាននិងត្រួតពិនិត្យដំណើរការការងាររបស់ **គ.ស.ក.**
- ផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋានអំពីការងារចាំបាច់
- សម្របសម្រួលនិងដោះស្រាយរាល់វិវាទផ្សេងៗរបស់ **គ.ស.ក.**
- ផ្តល់យោបល់ក្នុងការចុះបញ្ជីស្ថាបត្យករ ការលើកទឹកចិត្ត និងការដាក់វិន័យ។

ROYAUME du CAMBODGE
MINISTERE du PALAIS ROYAL

មាត្រា ១០.-

ក្រុមប្រឹក្សា **គ.ស.ក.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់១(មួយ)ឆ្នាំម្តង។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សា **គ.ស.ក.** អាចកោះប្រជុំជាវិសាមញ្ញបាន។

ផ្នែកទី៣
អគ្គលេខាធិការដ្ឋាន

មាត្រា ១១.-

គ.ស.ក. ត្រូវមានអគ្គលេខាធិការដ្ឋានមួយដែលមានតួនាទីជាអង្គភាពប្រតិបត្តិនិងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្តាបត្យករដែលអនុម័តដោយក្រុមប្រឹក្សា **គ.ស.ក.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការ **គ.ស.ក.**
- ធានានិរន្តរភាពការងាររបស់អគ្គលេខាធិការដ្ឋាន
- ផ្សព្វផ្សាយអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យស្តាបត្យកម្មគ្រប់ជំនាញ និងចូលរួមរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងវិស័យស្តាបត្យកម្មតាមការអញ្ជើញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ជួយការពារកម្មសិទ្ធិបញ្ញារបស់ស្តាបត្យករចុះបញ្ជី
- ពង្រឹងសមត្ថភាពក្នុងការចូលរួមប្រកួតប្រជែងដោយយុត្តិធម៌និងស្មើភាពគ្នារវាងស្តាបត្យករចុះបញ្ជីកម្ពុជានិងស្តាបត្យករបរទេស
- ធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សាវគ្គបំប៉នជំនាញនិងការអប់រំឧត្តមសិក្សា
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់ស្តាបត្យករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈស្តាបត្យកម្មឲ្យមានការទទួលស្គាល់ក្នុងក្របខ័ណ្ឌអាស៊ាននិងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈស្តាបត្យកម្មរបស់ស្តាបត្យករចុះបញ្ជីស្តាបត្យករ **គ.ស.ក.** និងស្តាបត្យករបរទេស
- ចុះបញ្ជីកំណត់គុណវុឌ្ឍិអាជីពវិជ្ជាជីវៈស្តាបត្យកម្មរបស់រូបវន្តបុគ្គលឲ្យទៅជាស្តាបត្យករ **គ.ស.ក.** និងធានានិរន្តរភាពនៃការចុះបញ្ជីស្តាបត្យករនៅព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

- ជ្រើសរើសនិងវាយតម្លៃលើបេក្ខភាពស្ថាបត្យករ **គ.ស.ក.** ដើម្បីឲ្យទៅជាស្ថាបត្យករអាស៊ាន
- រៀបចំគុណវុឌ្ឍិជំនាញវិជ្ជាជីវៈនិងក្រមសីលធម៌របស់ស្ថាបត្យកចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** ដោយសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើការត្រួតពិនិត្យលើការអនុវត្តការងាររបស់ស្ថាបត្យកចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** ក្នុងករណីមានទំនាស់ក្នុងការបំពេញវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **គ.ស.ក.** ក្នុងកិច្ចប្រជុំប្រចាំឆ្នាំនិងក្រុមប្រឹក្សា **គ.ស.ក.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយក្រុមប្រឹក្សា **គ.ស.ក.**។

មាត្រា ១២.-

អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។ អគ្គលេខាធិការមានឋានៈទាបបំផុតស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈទាបបំផុតស្មើអនុរដ្ឋលេខាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១៣.-

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.ស.ក.** ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយមហាសន្និបាត **គ.ស.ក.** សម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ។

ស្ថាបត្យករមានសញ្ជាតិខ្មែរដែលអាចឈរឈ្មោះឲ្យមហាសន្និបាត **គ.ស.ក.** បោះឆ្នោតជាអគ្គលេខាធិការឬអគ្គលេខាធិការរងបាន ត្រូវមានឈ្មោះក្នុងបញ្ជីស្ថាបត្យករ **គ.ស.ក.** យ៉ាងតិច ៥(ប្រាំ)ឆ្នាំ ហើយមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយឡើយ។

មាត្រា ១៤.-

ក្នុងករណីដែលអគ្គលេខាធិការឬអគ្គលេខាធិការរងណាម្នាក់ទទួលមរណភាពឬលាឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួននោះ **គ.ស.ក.** ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបន្តបញ្ចប់អាណត្តិស្របតាមបទបញ្ជាផ្ទៃក្នុង។

មាត្រា ១៥.-

គ.ស.ក.មានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

ផ្នែកទី៤

ក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្ត

មាត្រា ១៦.-

គ.ស.ក. អាចបង្កើតក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្តបាន ក្នុងករណីមានសមាជិកស្ថាបត្យករចាប់ពី២០(ម្ភៃ)រូបឡើងទៅ ដែលក្នុងនោះត្រូវមានស្ថាបត្យករ **គ.ស.ក.** យ៉ាងតិច៥(ប្រាំ)រូប។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណៈស្តាបត្យកររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

ផ្នែកទី៥
មហាសន្និបាត

មាត្រា ១៧.-

មហាសន្និបាតប្រចាំឆ្នាំរបស់**គ.ស.ក.** ត្រូវប្រព្រឹត្តទៅតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សា**គ.ស.ក.**។

មហាសន្និបាត **គ.ស.ក.** ប្រព្រឹត្តទៅ៥(ប្រាំ)ឆ្នាំម្តង ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការនិងអគ្គលេខាធិការរង។

មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបានតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា **គ.ស.ក.**ឬតាមការស្នើសុំពីស្តាបត្យករ **គ.ស.ក.** យ៉ាងតិចចំនួន៣០(សាមសិប)ភាគរយ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំដោយមានភ្ជាប់របៀបវារៈមកជាមួយផង។

មាត្រា ១៨.-

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មហាសន្និបាត **គ.ស.ក.** ដូចមានចែងក្នុងមាត្រា១៧ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ស.ក.**។

ជំពូកទី៣
ការប្រកបវិជ្ជាជីវៈស្តាបត្យកម្ម

មាត្រា ១៩.-

ស្តាបត្យករដែលអាចក្លាយទៅជាស្តាបត្យករ **គ.ស.ក.** បានត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- គ្មានការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈនេះដោយតុលាការ
- បំពេញលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

មាត្រា ២០.-

ស្តាបត្យករដែលបានបំពេញគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៩ខាងលើ ត្រូវទទួលបានវិញ្ញាបនបត្រស្តាបត្យករ **គ.ស.ក.**ដែលចេញដោយ **គ.ស.ក.**។

មាត្រា ២១.-

ការប្រកបវិជ្ជាជីវៈស្តាបត្យកម្ម ត្រូវគោរពតាមក្រមសីលធម៌ស្តាបត្យករដែលអនុម័តដោយក្រុមប្រឹក្សា **គ.ស.ក.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា ២២.-

ស្ថាបត្យករបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈស្ថាបត្យកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** និងត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២៣.-

ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** នៅព្រះរាជាណាចក្រកម្ពុជាត្រូវបង់ភាគទានប្រចាំឆ្នាំជូន **គ.ស.ក.**។

ភាគទានដែលត្រូវបង់ជូន **គ.ស.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

មាត្រា ២៤.-

ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** អាចសុំព្យួរឬសុំលាឈប់ពីសមាជិក **គ.ស.ក.** បានតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

ជំពូកទី៤
គោរមងារ

មាត្រា ២៥.-

គ.ស.ក. អាចថ្វាយឬជូនគោរមងារជាមហាវរស្ថាបត្យករជាតិឬវរស្ថាបត្យករជាតិចំពោះឥស្សរជនជាន់ខ្ពស់ដែលមានគុណូបការៈក្នុងការដឹកនាំនិងស្ថាបនាជាតិ។

មាត្រា ២៦.-

គ.ស.ក. អាចផ្តល់គោរមងារជាស្ថាបត្យករជាតិជូនចំពោះស្ថាបត្យករ **គ.ស.ក.** ដែលបានប្រកបវិជ្ជាជីវៈស្ថាបត្យកម្មរយៈពេល១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ។

គ.ស.ក. អាចផ្តល់គោរមងារជាស្ថាបត្យករកិត្តិយសជូនចំពោះឥស្សរជនឬបុគ្គលទាំងឡាយណាដែលបានឧបត្ថម្ភគាំទ្រផ្នែកថវិកាឬបច្ចេកទេសចំពោះ **គ.ស.ក.** តាមការកំណត់របស់ក្រុមប្រឹក្សា **គ.ស.ក.**។

មាត្រា ២៧.-

គោរមងារជាស្ថាបត្យករជាតិអាចត្រូវដកហូតវិញបាន ប្រសិនបើស្ថាបត្យកររូបនោះបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករ។

ជំពូកទី៥
ក្រុមប្រឹក្សាវិន័យ

មាត្រា ២៨.-

ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន៥(ប្រាំ)រូប ដែលត្រូវតែងតាំងឡើងដោយប្រធានក្រុមប្រឹក្សា **គ.ស.ក.**ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គ.ស.ក.** និងសមាជិកនៃអគ្គលេខាធិការ

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការសម្រេចដាក់វិន័យត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ស.ក.**។

មាត្រា ២៩.-

ក្រុមប្រឹក្សាវិន័យមានតួនាទី ដូចតទៅ៖

- ទទួលបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ដោះស្រាយវិវាទទាក់ទងនឹងវិជ្ជាជីវៈរបស់ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ដាក់ទណ្ឌកម្មខាងវិន័យដល់ស្ថាបត្យករណាដែលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**។

មាត្រា ៣០.-

ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានក្រុមប្រឹក្សា **គ.ស.ក.**។ ប្រធានក្រុមប្រឹក្សា **គ.ស.ក.** ត្រូវចាត់តាំងសមាជិកចំនួន៧(ប្រាំពីរ)រូបផ្សេងទៀតក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានោះ។ សេចក្តីសម្រេចចុងក្រោយជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

បែបបទ នីតិវិធីនៃការតវ៉ា និងរយៈពេលនៃការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ស.ក.**។

ជំពូកទី៦
ទណ្ឌកម្មខាងវិន័យ

មាត្រា ៣១.-

ទណ្ឌកម្មខាងវិន័យរួមមាន៖

- ការស្តីបន្ទោស
- ការព្រមាន
- ការព្យួរសិទ្ធិមួយរយៈពេល ដែលមិនអាចលើសពី២(ពីរ)ឆ្នាំ
- ការលុបឈ្មោះចេញពីបញ្ជី **គ.ស.ក.** ឬដកហូតគោរមងារស្ថាបត្យករជាតិ។

ការទទួលទណ្ឌកម្មខាងវិន័យ មិននាំឲ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីនិងព្រហ្មទណ្ឌឡើយ។

ជំពូកទី៧
ប្រតិពន្ធធានធាន

មាត្រា ៣២.-

ប្រតិពន្ធធានរបស់ **គ.ស.ក.** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ភាគទានដែលបានពីសមាជិក **គ.ស.ក.**
- អំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍ សហគមអន្តរជាតិ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ចំណូលបានពីសកម្មភាពនានារបស់ **គ.ស.ក.**
- ជំនួយឥតសំណងផ្សេងៗ។

គ.ស.ក. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេសនិងសម្ភារៈផ្សេងៗ ទៀតពីប្រភពក្នុងនិងក្រៅប្រទេស សម្រាប់បម្រើការក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

ជំពូកទី៨
អន្តរប្បញ្ញត្តិ

មាត្រា ៣៣.-

ក្នុងអាណត្តិដំបូង អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃ **គ.ស.ក.** ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ប្រធានក្រុមប្រឹក្សា **គ.ស.ក.**។

ជំពូកទី៩
អវសានប្បញ្ញត្តិ

មាត្រា ៣៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣៥.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ ក្ដី ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ
នរោត្តម សីហមុនី

៨៧៩. ១១១២, ១១៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ថ្ងៃទី ១៤ ខ.ល
ត្រឹមត្រូវចំពោះច្បាប់
រាជធានីភ្នំពេញ ថ្ងៃ ទី ២ ខែ មករា ឆ្នាំ ២០១២
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អន្តរក្រឹត្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
លិខិតអនុញ្ញាតសាងសង់

ឆ្នាំ ១៩៩៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៨៦...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
លិខិតអនុញ្ញាតសាងសង់

* * * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៨៩៧/ ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទីកដី នគរោបនីយកម្ម និង សំណង់ ។
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុករបៀបវារៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សំរេច

<u>មាត្រា ១</u> : រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញអោយមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី ១ នៃអនុក្រឹត្យនេះ ។

ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់<u>សំណង់តូចតាចធ្វើអំពីឈើ ឬស្លឹក រុក្ខជាតិនានា</u> ពុំទាមទារអោយសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខមាលភាពនៃសំណង់ និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈ ចាំបាច់ សំរាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទបញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និង សំណង់ឯកជន ។

រាល់ការគោរពតួវបទបញ្ញត្តិដែលមានចែងក្នុងវគ្គទី ២នៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទបញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និង ប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទបញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីឱ្យស្របទៅស្ថានភាពមូលដ្ឋាន ដោយស្ថិតក្នុងបទបញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្ត-ក្រុង ។

អនុក្រឹត្យនេះមិនយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។
ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងក្លាដល់ប្រយោជន៍ ឬសោភ័ណភាពសាធារណៈ ការរុះជីត្រូវសំរេចដោយរាជរដ្ឋាភិបាល ឬតំណាងដែលបានទទួលសិទ្ធិប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

ភាគទី ១

លិខិតអនុញ្ញាតសាងសង់ និង លិខិតអនុញ្ញាតរុះរើ

ជំពូក ១

ភាពប្លកិច្ចនៃលិខិតអនុញ្ញាតសាងសង់

មាត្រា ២: **សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន**

រាល់ការសាងសង់ក្នុងទីក្រុង និង ទីប្រជុំជន ត្រូវមានលិខិតអនុញ្ញាតសាងសង់

រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ ។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និង ការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ដែរ ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការងារនេះកែប្រែ :

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ (Aspect des Bâtiments)
- ការធ្វើបង្គន់អនាម័យ និង ការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ ឥភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន (Locaux ouverts au public)
- ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយ ដូចជាលប់បំពាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ ល ។

ការសាងសង់ ឬ ការកែទ្រង់ទ្រាយបបរភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ (ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងឆេះ កន្លែងទទួលសាធារណៈជន) ។ ល ។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ម៉ាណូ ផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍-និងទូរគមនាគមន៍ ម៉ាណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតម្តាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និង សាលាខេត្តនឹងធ្វើការណែនាំដោយឡែក ។

មាត្រា ៣: **សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់**

- សំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំតិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់ធ្វើយ ។

- ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើលែងតែការជួសជុលនោះអាចបណ្តាលអោយប៉ះពាល់ដល់រួកជិតខាង ។

- បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីតំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ :

- ទីសក្ការៈបូជា
- សាលាសំណាក់សាធារណៈ
- បណ្តាការិយាល័យរបស់រដ្ឋសំរាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ

ចំពូក ២

សមត្ថកិច្ច នៃលេខាលិខិតអនុញ្ញាតសាងសង់

មាត្រា ៤ : **សមត្ថកិច្ចរបស់សាលាខេត្ត និង សាលាក្រុង**

៤.១ ខេត្ត-ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២ លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬ ដោយអភិបាលខេត្ត-ក្រុង ឬ អភិបាលរងដែលបានទទួលសិទ្ធិប្រទាន ។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ ទូវមូលហេតុច្បាស់លាស់ ។

មាត្រា ៥ : **សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល**

៥.១ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសំរេចផ្តល់ លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ :

- បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែលមានផ្ទៃក្រឡាក្រោលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ។

- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។

- បណ្តាអគារសំរាប់ការបង្កបង្កើនផលកសិកម្ម សំរាប់ធ្វើអាជីវកម្មពី ៥០០ឯកតាឡើងទៅ ។

- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអុយស្ស័យយាន និង ស្ថានីយរថយន្ត ។

- បណ្តាសំណង់សាធារណៈ និង ឯកជន ដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០

ម៉ែត្រទ្វេគុណ និងផ្តែកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ (វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ចាមពលទឹក...) ។

- បណ្តាសំណង់សំខាន់ ៗ ក្នុងទីដ្ឋានការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភ័ណ្ឌ ប្រវត្តិសាស្ត្រ ប្លូរាណវត្ថុ និង វប្បធម៌ ។
- ការកែប្រែបណ្តាអគារ ជាផលប្រយោជន៍បេតិកភ័ណ្ឌដែលបានកំណត់ទុក ។
- បណ្តាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយព្រាង្គព្រាសាទប្រវត្តិសាស្ត្រ។
- បណ្តាសំណង់ និង ការប្យ សំរាប់ការពារ និង អគារយោធា ។

៥.២ ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខា ដោយប្រធានគណៈកម្មាធិការជាតិរៀបចំទីកដីនគរោបនីយកម្ម និងសំណង់ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

ជំពូក ៦ : គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬ សាលាក្រុង

៦.១ សមត្ថកិច្ច

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។

មាត្រា៤.-

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ÷

- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខ របស់សហកម្មសិទ្ធិករនីមួយៗហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះជាលំហរួមសម្រាប់ការប្រើប្រាស់រួម របស់សហកម្មសិទ្ធិករទាំងអស់ហៅថា "ចំណែករួម"។
ប្រភេទនៃអគារសហកម្មសិទ្ធិទាំងនោះមានជាអាទិ៍ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែងនិងច្រើនជាន់ជាប់គ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀត ដែលមានរចនាសម្ព័ន្ធជាប់គ្នា។
- **ចំណែកឯកជន** សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្តាច់មុខ។
- **ចំណែករួម** សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់រួមជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ជី ទីធ្លា ជណ្តើរ ឧទ្យាន និងសួនច្បារ ផ្លូវ ស្ថាបត្យកម្ម ជញ្ជាំងអគ្គិសនី ទីកន្លែងនៃសេវាកម្មរួម។
- **អ្នកអភិវឌ្ឍអចលនវត្ថុ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ទុនវិនិយោគលើការរៀបចំនិងអគារសហកម្មសិទ្ធិ ក្នុងគោលបំណងសម្រាប់លក់ ឬជួល។

- **អ្នកអាណាព្យាបាល** សំដៅដល់បុគ្គលដែលមានភារកិច្ចតំណាងអនីតិជន ឬអសមត្ថជន។
- **ហិតូបត្ថម្ភក:** សំដៅដល់ជនដែលតុលាការចាត់តាំងឱ្យគ្រប់គ្រងលើ ជនដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។
- **ក្បាលដីសហកម្មសិទ្ធិ** សំដៅដល់ចំណែកដីនៃអគារសហកម្មសិទ្ធិ ដែលមានទីតាំងនិងទំហំជាក់លាក់ សម្រាប់ការសាងសង់អគារសហកម្មសិទ្ធិ ឬដែលមានអគារសហកម្មសិទ្ធិតាំងនៅ ហើយស្ថិតក្នុងគម្រោងបង់សាងសង់អគារសហកម្មសិទ្ធិ។ ក្បាលដី ឬចំណែកដីនៃអគារសហកម្មសិទ្ធិនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់។
- **ឡូតិ៍** សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួម នៃអគារសហកម្មសិទ្ធិ។ ឡូតិ៍នីមួយៗមានតម្លៃខុសៗគ្នាទៅតាមទំហំនៃចំណែកឯកជនតូច ឬធំ ហើយការគណនាត្រូវគិតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ។
- **សិទ្ធិជួលអចិន្ត្រៃយ៍** សំដៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែងចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ។

ជំពូកទី២

ការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ

មាត្រា៥...

រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ នៅព្រះរាជាណាចក្រកម្ពុជា ដោយគោរពតាមលក្ខខណ្ឌ និងបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ និងបទដ្ឋានគតិយុត្ត ពាក់ព័ន្ធផ្សេងទៀតជាធរមាន។

រូបវន្តបុគ្គលជានីតិជននិងមានសមត្ថភាពតាមផ្លូវច្បាប់ អាចជាកម្មសិទ្ធិករលើចំណែកឯកជននៃអគារសហកម្ម-សិទ្ធិ។ ប៉ុន្តែករណីនេះ ត្រូវបានលើកលែងចំពោះការបន្តមរតក របស់ទាយាទដែលជាអនីតិជន ឬអសមត្ថជនដោយអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិបាន តែតម្រូវឱ្យមានអ្នកអាណាព្យាបាល ឬហិតូបត្ថម្ភក:ជាអ្នកកាន់កាប់ជំនួសរហូតដល់អនីតិជន ឬអសមត្ថជននោះមានសមត្ថភាពពេញលេញតាមផ្លូវច្បាប់។ ចំពោះករណីនេះ អ្នកអាណាព្យាបាលឬហិតូបត្ថម្ភក: គ្មានសិទ្ធិចាត់ចែងនូវចំណែកឯកជននោះបានឡើយ លើកលែងតែមានការអនុញ្ញាតពីតុលាការ។

មាត្រា៦...

ការផ្តល់កម្មសិទ្ធិជូនសហកម្មសិទ្ធិករ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិប៉ុណ្ណោះ។ ចំពោះចំណែករួមត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៃអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម។

នីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវមានលក្ខណៈងាយស្រួល សាមញ្ញ គម្លាភាព និងស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ។

មាត្រា៧...

ក្បាលដីសម្រាប់សាងសង់អគារសហកម្មសិទ្ធិ ត្រូវតែជាក្បាលដីតែមួយ ដែលត្រូវបានចុះបញ្ជីរួចហើយ ឬកំពុងស្នើរសុំចុះបញ្ជីដីធ្លី។

ក្នុងករណីដែលសំណង់អគារសហកម្មសិទ្ធិមានច្រើនប្រភេទស្ថិតនៅក្បាលដីតែមួយ អ្នកអភិវឌ្ឍន៍ត្រូវស្នើសុំបំបែកក្បាលដីនៅរដ្ឋបាលស៊ុរិយោដី ទៅតាមប្រភេទ និងចំនួននៃអគារសហកម្មសិទ្ធិនីមួយៗ។ ការបំបែក

ក្បាលដីត្រូវធ្វើឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

អ្នកអភិវឌ្ឍអចលនវត្ថុ ឬបុគ្គលដែលបានឬកំពុងសាងសង់អគារសហកម្មសិទ្ធិ ត្រូវផ្ទាស់ប្តូរប្រភេទក្បាលដីឱ្យទៅជា ក្បាលដីសហកម្មសិទ្ធិ នៅរដ្ឋបាលសុរិយោដី នៅពេលផ្ទេរលើកដំបូង នៃចំណែកឯកជនណាមួយ លើកលែងតែអគារសហកម្មសិទ្ធិ ដែលបានសង់នៅលើដីជួលអចិន្ត្រៃយ៍ ។

នៅពេលផ្ទាស់ប្តូរប្រភេទក្បាលដីឱ្យទៅជា ក្បាលដីសហកម្មសិទ្ធិ អ្នកអភិវឌ្ឍអចលនវត្ថុ ឬបុគ្គលដែលបាន ឬកំពុងសាងសង់អគារសហកម្មសិទ្ធិលើក្បាលដីនោះ ត្រូវប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃក្បាលដីឱ្យរដ្ឋបាលសុរិយោដី ដើម្បីធ្វើលេខាចារឹក និងរក្សាទុក ហើយរដ្ឋបាលសុរិយោដី ត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនជំនួសវិញ ។

ការផ្ទាស់ប្តូរប្រភេទក្បាលដីឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ និងទម្រង់បែបបទផ្សេងទៀត អាចត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្បាលដីសហកម្មសិទ្ធិ ដែលអគារសហកម្មសិទ្ធិស្ថិតនៅ ជាទ្រព្យរួមរបស់សហកម្មសិទ្ធិករទាំងអស់ ។

មាត្រា៨.-

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលសាងសង់អគារសហកម្មសិទ្ធិត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយ មុននឹងប្រកាសលក់ឬជួលចំណែកឯកជននៃអគារសហកម្មសិទ្ធិ ។

បទបញ្ជាផ្ទៃក្នុងខាងលើនេះ ដែលជាការព្រមព្រៀងរវាងសហកម្មសិទ្ធិករ នៃអគារសហកម្មសិទ្ធិមិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមាន ។

ដើម្បីគ្រប់គ្រងអគារសហកម្មសិទ្ធិ សហកម្មសិទ្ធិករអាចបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ តាមការព្រមព្រៀងរវាងសហកម្មសិទ្ធិករ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

ការរៀបចំបទបញ្ជាផ្ទៃក្នុង ត្រូវស្របតាមគោលការណ៍ និងលក្ខខណ្ឌអប្បបរមានៃបទបញ្ជាផ្ទៃក្នុងគំរូ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ហើយដែលត្រូវចែងជាអាទិ៍ អំពី ÷

- សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ របស់សហកម្មសិទ្ធិករលើចំណែកឯកជននិងលើចំណែករួមដោយមិនផ្ទុយពីគោលការណ៍កម្មសិទ្ធិ ។
- ការកំណត់ពីសមាមាត្រនៃចំណាយរួមនានា របស់សហកម្មសិទ្ធិករ សម្រាប់ការថែទាំ ការជួសជុល ចំណែករួមការបង់ថ្លៃលើការប្រើប្រាស់សេវាសាធារណៈនានា ... ។ល។
- នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត ក្នុងករណីដែលសហកម្មសិទ្ធិករបង្កើតអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធិ ÷

ក)- តម្រូវឱ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុល ឬការថែទាំអគារសហកម្មសិទ្ធិ ឬការបង់ថ្លៃសេវាសាធារណៈនានា ។

ខ)- តម្រូវឱ្យមានសំឡេងគាំទ្រយ៉ាងតិច ៧៥ (ចិតសិបប្រាំ) ភាគរយ នៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់សម្រេចចិត្តក្នុងករណីដែលអគារចាស់ទ្រុឌទ្រោម មិនអាចប្រើប្រាស់បាន លើយត្រូវរុះរើចោល ឬសាងសង់អគារជាថ្មី ។ ក្នុងករណីមិនអាចរកការគាំទ្រយ៉ាងតិច ៧៥ (ចិតសិបប្រាំ) ភាគរយ បានដោយការវាយតម្លៃជាផ្លូវការដោយសមត្ថកិច្ចជំនាញ ត្រូវយកជាមូលដ្ឋានសម្រាប់ការស្នើរសុំ

មាត្រា៩.-

ការកំណត់ព្រំខណ្ឌនៃចំណែកឯកជន ដែលមានជញ្ជាំងអឡសិទ្ធិ ត្រូវកំណត់ត្រឹមពាក់កណ្តាលនៃកម្រាស់ជញ្ជាំងដែលខណ្ឌចំណែកឯកជននីមួយៗ។

ប៉ុ ប្អូនហាលជាប់ជាមួយចំណែកឯកជន និងប្រើប្រាស់ជាឯកជន ហើយដែលមិនប៉ះពាល់ដល់ការប្រើប្រាស់ជារួមរបស់សហកម្មសិទ្ធិករផ្សេងទៀត ត្រូវចាត់ទុកជាផ្នែកនៃចំណែកឯកជន។

ជំពូកទី៣

សិទ្ធិនិងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ

មាត្រា១០.-

សហកម្មសិទ្ធិករនីមួយៗ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួន លើកលែងតែមានការកម្រិតលក្ខខណ្ឌដោយច្បាប់ ឬបញ្ញត្តិផ្សេងទៀត។

មាត្រា១១.-

សហកម្មសិទ្ធិករនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានសិទ្ធិចាត់ចែងលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួម ដោយសហកម្មសិទ្ធិករដទៃទៀត និងមិនធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំនៃសំណង់ និងសោភ័ណភាពនៃអគារ។

សិទ្ធិចាត់ចែងចំណែកឯកជនរបស់សហកម្មសិទ្ធិករ ដូចជា ការលក់ ការផ្ទេរ ការជួល ប្រទានកម្ម ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការបង្កើតផលប្រភោគ ការប្រើប្រាស់និងអាស្រ័យនៅ ការដាក់ប៊ីប៉ូតែក និងការដាក់បញ្ចាំត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន។

សហកម្មសិទ្ធិករមិនអាចបង្កើតសេវភាព លើចំណែកឯកជនរបស់ខ្លួនបានទេ។

មាត្រា១២.-

រាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់រួម ឬសម្រាប់ជាប្រយោជន៍នៃសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិបង្កើតបានជាចំណែករួម។ ចំណែករួមមានជាអាទិ៍ ÷

- ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល
- ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្តាញទឹក ភ្លើង បណ្តាញឧស្ម័ន ប្រព័ន្ធលូទឹកស្អុយ ដែលអាចឆ្លងកាត់ចំណែកឯកជន
- ទ្វារ បំពង់ និងក្បាលបំពង់ផ្សែង និងដំបូល
- ទីកន្លែងសេវារួមផ្សេងៗដែលបានកំណត់ដោយឡែក ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុង
- សិទ្ធិបន្ទាប់បន្សំទាំងឡាយ ដូចមានចែងក្នុងមាត្រា១៧៩ នៃច្បាប់ភូមិបាល។

សហកម្មសិទ្ធិករនីមួយៗមានត្រឹមតែសិទ្ធិប្រើប្រាស់តែប៉ុណ្ណោះ លើចំណែករួម។ គ្មានការណីណាមួយអាចកែប្រែសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុត អាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិផ្តាច់ការលើកប្លន់នេះបានឡើយ។

មាត្រា១៣.-

សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុង ដែលកំណត់របៀបត្រប់ត្រង និងវិធាន នៃការថែទាំ ព្រមទាំងការបំពេញកាតព្វកិច្ចផ្សេង១ទៀត។

មាត្រា១៤.-

ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធករ។ សហកម្មសិទ្ធិករទាំងអស់ត្រូវធានាការថែទាំចំណែករួម។ បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយ១ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង។

មាត្រា១៥.-

សិទ្ធិលើក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ ជាសិទ្ធិដែលមិនត្រូវបានបាត់បង់ឡើយ ទោះបីអគារ ឬ ចំណែកឯកជននោះបានខូចខាតក៏ដោយ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រេះទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយ ដោយប្រការណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុល ឬសាងសង់ឡើងវិញ ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយ១ ឬតាមការព្រមព្រៀងគ្នាកន្លងមកដូចជា កិច្ចសន្យាដោយឡែក ឬបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ។ កិច្ចសន្យាដោយឡែកត្រូវស្របតាមស្មារតីនៃបទបញ្ជាផ្ទៃក្នុង។ ការជួសជុល ឬសាងសង់ឡើងវិញ ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ប្រសិនបើសហកម្មសិទ្ធិករឯកភាពគ្នាក្នុងការបែងចែកដី ឬលក់ដីដែលអគារសហកម្មសិទ្ធិនោះស្ថិតនៅការបែងចែកត្រូវអនុវត្តតាមគោលការណ៍សមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយ១ ឬតាមការព្រមព្រៀងគ្នា ពីមុនមក ប្រសិនបើមានចែងនៅក្នុងកិច្ចសន្យាដោយឡែក ឬបទបញ្ជា ផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ។

ប្រសិនបើអ្នកអភិវឌ្ឍអចលនវត្ថុ បានសាងសង់អគារសហកម្មសិទ្ធិលើដីជួលពីបុគ្គលទីបី នោះអាជ្ញាយុកាលនៃសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជន និងសិទ្ធិប្រើប្រាស់លើចំណែករួម មានត្រឹមតែរយៈពេល ដូចបានកំណត់ក្នុងកិច្ចសន្យាជួលដីអចិន្ត្រៃយ៍ រវាងអ្នកអភិវឌ្ឍអចលនវត្ថុ និងម្ចាស់ដីប៉ុណ្ណោះ។ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ មានភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

ជំពូកទី៤
យន្តការនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

មាត្រា១៦.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មានសមត្ថកិច្ចធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ជូនសហកម្មសិទ្ធិករទាំងអស់តាមនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ។

មានតែអគារសហកម្មសិទ្ធិដែលបានសាងសង់រួចចប់សព្វគ្រប់ តាមច្បាប់និងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះ ទើបអាចជាកម្មវត្ថុនៃការចុះបញ្ជីចំណែកឯកជនបាន។

មាត្រា១៧.-

ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវដំណើរការដូចតទៅ ÷

១- សហកម្មសិទ្ធិករចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវស្នើសុំចុះបញ្ជីចំណែកឯកជនរបស់ខ្លួន នៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

សហកម្មសិទ្ធិករត្រូវបំពេញពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដោយបញ្ជាក់ច្បាស់អំពីអត្តសញ្ញាណ និងព័ត៌មានទាំងឡាយនៃចំណែកឯកជនរបស់ខ្លួន ឱ្យបានត្រឹមត្រូវនិងត្រូវភ្ជាប់ មកជាមួយនូវ ÷

- វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់
- ឯកសារបង្ហាញស្ថាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិ ដោយបញ្ជាក់ពីចំនួនជាន់ ចំនួនចំណែកឯកជន ដោយមានលេខយោងនិងព័ត៌មានអំពីចំណែករួមនៃអគារ
- បទបញ្ជាផ្ទៃក្នុង
- ឯកសារបញ្ជាក់អត្តសញ្ញាណសហកម្មសិទ្ធិករ
- ឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន។

២- ពាក្យស្នើសុំត្រូវយកទៅដាក់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលអគារសហកម្មសិទ្ធិនោះស្ថិតនៅ។ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ។

៣- ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យទម្រង់និងឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ហើយបញ្ជូនពាក្យស្នើសុំចុះបញ្ជីនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ក្នុងរយៈពេល៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ដើម្បីពិនិត្យនិងសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជី។

៤- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យសម្រេច ក្នុងរយៈពេល ៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ លើពាក្យស្នើសុំចុះបញ្ជីនេះ។

៥- ក្រោយពីមន្ទីរសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការជូនដំណឹងរយៈពេល១ (មួយ) សប្តាហ៍ មុនកាលបរិច្ឆេទនៃការចុះប្រមូលទិន្នន័យ។

៦- មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល១ (មួយ) សប្តាហ៍យ៉ាងយូរ ត្រូវចុះសហការជាមួយមន្ត្រីឃុំ សង្កាត់ អ្នកអភិវឌ្ឍអចលនវត្ថុ ឬតំណាងនិងសហកម្មសិទ្ធិករ ដើម្បីប្រមូលនិងផ្ទៀងផ្ទាត់ទិន្នន័យ នៅទីតាំងជាក់ស្តែង ដើម្បីបំពេញទម្រង់បែបបទប្រមូលទិន្នន័យ។

៧- ក្រោយប្រមូលទិន្នន័យជាក់ស្តែងអំពីចំណែកឯកជននៃអគារសហកម្មសិទ្ធិរួច មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទាំងអស់ និងលើកយោបល់ក្នុងរយៈពេល ១ (មួយ) សប្តាហ៍ មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេចឱ្យបិទផ្សាយទិន្នន័យជាសាធារណៈ។

ប្រសិនបើមានភាពមិនច្បាស់លាស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត អាចស្វែងរកព័ត៌មានបន្ថែម ឬចាត់តាំងមន្ត្រីជំនាញដើម្បីចុះស៊ើបអង្កេត ឬបញ្ជាក់បន្ថែមក្នុងរយៈពេល១ (មួយ) សប្តាហ៍យ៉ាងយូរ។

៨- ក្រោយពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត បានសម្រេចឱ្យបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបានរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបិទផ្សាយជាសាធារណៈ នូវលទ្ធផលនៃការប្រមូលទិន្នន័យរយៈពេល១ (មួយ) សប្តាហ៍

ដើម្បីឱ្យសហកម្មសិទ្ធិករទាំងអស់និងអ្នកមានផលប្រយោជន៍ អាចតវ៉ាឬស្នើធ្វើការកែតម្រូវ។ ការបិទផ្សាយជាសាធារណៈត្រូវអនុវត្តនៅទីតាំងអចលនវត្ថុផ្ទាល់ និងនៅសាលាឃុំ សង្កាត់ ដែលអចលនវត្ថុនោះស្ថិតនៅ។

ក្នុងករណីមានការតវ៉ា ឬវិវាទ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវព្យាយាមសម្រុះសម្រួលស្វែងរកការឯកភាពគ្នា។

ក្នុងករណីមិនអាចរកការស្រុះស្រួលគ្នាបាន ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនករណីវិវាទនេះទៅតុលាការ ដើម្បីដោះស្រាយតាមនីតិវិធីច្បាប់ជាធរមាន។

៩- ផុតរយៈពេលនៃការបិទផ្សាយប្រសិនបើគ្មានបណ្តឹងតវ៉ា ឬប្រសិនបើរាល់វិវាទត្រូវបានដោះស្រាយរួចរាល់ ហើយមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវធ្វើការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ តាមការស្នើសុំរបស់សហកម្មសិទ្ធិករក្នុងរយៈពេល ១ (មួយ) សប្តាហ៍យ៉ាងយូរ។

មាត្រា១៨.-

ចំណែកឯកជននីមួយៗ ត្រូវចុះបញ្ជីក្នុងស្បៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ។ ក្នុងស្បៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវកត់ត្រាទិន្នន័យលម្អិតអំពីចំណែកឯកជន និងម្ចាស់កម្មសិទ្ធិនៃចំណែកឯកជន ដោយមានបញ្ជាក់ជាអាទិ៍ ឈ្មោះសហកម្មសិទ្ធិករ ទំហំ ទីតាំង ប្រភេទ ទ្រព្យនៃចំណែកឯកជន។

ស្បៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងទម្រង់បែបបទផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា១៩.-

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលត្រូវបានចេញជូនសហកម្មសិទ្ធិករ តាមការស្នើសុំ ត្រូវកត់ត្រាទិន្នន័យដែលមានជាអាទិ៍ លេខយោងសម្គាល់ចំណែកឯកជន ទំហំ ទីតាំង ប្រភេទទ្រព្យ នៃចំណែកឯកជន។

គំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានភ្ជាប់ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

រដ្ឋបាលសុរិយោដីត្រូវរៀបចំកម្មវិធីកុំព្យូទ័រ សម្រាប់បញ្ចូលទិន្នន័យចំណែកឯកជននៃអគារសហកម្មសិទ្ធិ នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីរក្សាទុកជាឯកសារ។

មាត្រា២០.-

រាល់ការផ្ទេរសិទ្ធិតាមរយៈការលក់ ការដូរ ប្រទានកម្ម និងការបន្តមរតក សហកម្មសិទ្ធិករឬអ្នកទទួលសិទ្ធិត្រូវស្នើធ្វើចរន្តការនូវរាល់ការប្រែប្រួលនោះ នៅរដ្ឋបាលសុរិយោដី។ កិច្ចប្រតិបត្តិការក្នុងការផ្ទេរសិទ្ធិនេះ ត្រូវប្រើរយៈពេល២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ។ អ្នកទទួលសិទ្ធិបន្តមានសិទ្ធិ និងកាតព្វកិច្ច ដូចសហកម្មសិទ្ធិករមុនៗដែរ។

រាល់ការដាក់ប៊ីប៊ូតែក ការដាក់បញ្ចាំ និងការជួលអចិន្ត្រៃយ៍នូវចំណែកឯកជនរបស់ខ្លួន សហកម្មសិទ្ធិករ និងអ្នកពាក់ព័ន្ធត្រូវទៅធ្វើលេខាចរិកលើវិញ្ញាបនបត្រសម្គាល់ ម្ចាស់ចំណែកឯកជននោះនៅរដ្ឋបាលសុរិយោដី។

មាត្រា២១.-

រាល់ការផ្ទាស់ប្តូរប្រភេទក្បាលដីដើម មកជាក្បាលដីសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី។

រាល់ការបំបែកក្បាលដីទៅតាមប្រភេទនិង/ឬចំនួនអគារសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី ។

រាល់ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាសុរិយោដី និងបង់ពន្ធប្រថាប់ត្រាជូនរដ្ឋតាមច្បាប់កំណត់ ។

ជំពូកទី៥

អន្តរប្បញ្ញត្តិ

មាត្រា២២.-

ចំពោះប្រភេទអគារសហកម្មសិទ្ធិ ដែលបានសាងសង់មុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ហើយដែលមានសហកម្មសិទ្ធិករច្រើននាក់រស់នៅ ការស្នើសុំចុះបញ្ជីចំណែកឯកជន ពុំតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់ និងឯកសារបង់ស្ថាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា១៧ ចំណុចទី១ ឡើយ ។

ចំពោះប្រភេទអគារសហកម្មសិទ្ធិ ដែលបានសាងសង់ក្រោយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ រហូតដល់អនុក្រឹត្យនេះចូលជាធរមាន ហើយដែលអគារសហកម្មសិទ្ធិនោះ ពុំមានលិខិតអនុញ្ញាតសាងសង់ ការស្នើសុំចុះបញ្ជីចំណែកឯកជនតម្រូវឱ្យធ្វើនិយតកម្មលើប្លង់ស្ថាបត្យកម្ម នៃអគារសហកម្មសិទ្ធិជាមុនសិន ។

មាត្រា២៣.-

ចំពោះប្រភេទអគារសហកម្មសិទ្ធិដែលបានសាងសង់មុនអនុក្រឹត្យនេះចូលជាធរមាន ការស្នើសុំចុះបញ្ជីចំណែកឯកជនតម្រូវឱ្យសហកម្មសិទ្ធិករទាំងអស់រៀបចំបទបញ្ជាផ្ទៃក្នុងជាមុនសិន ស្របតាមខ្លឹមសារអប្បបរមាដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ ។ ក្នុងករណីដែលសហកម្មសិទ្ធិករមិនអាចស្រុះស្រួលគ្នាក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុងទេ ការស្នើសុំចុះបញ្ជីចំណែកឯកជននឹងត្រូវកំណត់ដោយចៅសង្កាត់ដោយឡែក ។

មាត្រា២៤.-

ចំពោះអគារជាភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ឬជាផ្ទះល្វែងដែលមានច្រើនល្វែង និងច្រើនជាន់ជាប់គ្នា ហើយមានម្ចាស់ជាកម្មសិទ្ធិករតែម្នាក់ ហើយដែលមានបំណងផ្ទេរចំណែកឯកជនណាមួយនៃអគារទៅឱ្យបុគ្គលដទៃ ការចុះបញ្ជីចំណែកឯកជនត្រូវអនុលោមតាមស្មារតីនៃអនុក្រឹត្យនេះ លើកលែងតែករណីដែលការផ្ទេរនេះអនុវត្តទៅលើផ្ទះល្វែងមួយជង់ពីលើដល់ក្រោមទៅឱ្យបុគ្គលតែមួយ ។ ការផ្ទេរចុងក្រោយនេះ ត្រូវអនុវត្តតាមនីតិវិធីដែលមានកន្លងមក ។

ជំពូកទី៦

នានាសប្បញ្ញត្តិ

មាត្រា២៥.-

សហកម្មសិទ្ធិករ ដែលធ្វើឱ្យប៉ះពាល់ចំណែករួមនៃអគារ ឬដីដោយបានកែប្រែដើម្បីការប្រើប្រាស់ជាឯកជនផ្ទាល់ ឬសម្រាប់លក់ នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ។ សហកម្មសិទ្ធិករនោះនឹងត្រូវទទួលខុសត្រូវចំពោះការខូចខាតណាមួយ ដែលបានកើតឡើងក្នុងមាត្រា២៥៧ នៃច្បាប់ភូមិបាល ។

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម ឬមិនបានគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់ភូមិបាល ។

ជំពូកទី៧
អវសានប្បញ្ញត្តិ

មាត្រា២៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា២៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ត្រប់ក្រសួងស្ថាប័ន អភិបាលរាជធានី ត្រប់អភិបាលខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៧
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គំរូបទបញ្ជាផ្ទៃក្នុង

សម្រាប់ការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

នៃអគារសហកម្មសិទ្ធិឈ្មោះ .....

អាសយដ្ឋាន : .....

.....

សង់លើក្បាលដីសហកម្មសិទ្ធិ

លេខយោង : .....

អនុលោមតាមច្បាប់ភូមិបាលថែលថែងអំពីសហកម្មសិទ្ធិ សហកម្មសិទ្ធិករទាំងអស់បានព្រមព្រៀងគ្នាលើការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ ឈ្មោះ..... ទាមួយនឹងឧបសម្ព័ន្ធទាំងឡាយមួយនេះទៅ :

ជំពូកទី១

គោលការណ៍ទូទៅ

ប្រការ ១..

១.១. បទបញ្ជាផ្ទៃក្នុងសម្រាប់អគារសហកម្មសិទ្ធិឈ្មោះ..... មានគោលដៅកំណត់បន្ថែមអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ដោយអនុលោមតាមសិទ្ធិ និងកាតព្វកិច្ច ដូចមានចែងក្នុងជំពូកទី ១០ នៃច្បាប់ភូមិបាល។

១.២. បទបញ្ជាផ្ទៃក្នុងនេះអនុវត្តដូចគ្នាចំពោះសហកម្មសិទ្ធិករទាំងអស់ និងចំពោះអ្នកជួលផ្ទៃកាន់កាប់ជាន់ដីអ្នក ដោយគ្មានករណីលើកលែងឡើយ។

១.៣. បទបញ្ជាផ្ទៃក្នុងនេះជាផ្នែកមួយនៃកិច្ចសន្យាផ្ទេរវាងសហកម្មសិទ្ធិករដែលតម្រូវឱ្យអ្នកទទួលបានសិទ្ធិជាសហកម្មសិទ្ធិករថ្មី ចុះហត្ថលេខានិងគោរពតាម។

១.៤. អ្នកលក់ចំណែកឯកជន ត្រូវបង្ហាញបទបញ្ជាផ្ទៃក្នុងនេះដល់អ្នកទិញ ដោយភ្ជាប់បទបញ្ជាផ្ទៃក្នុងនេះជាលក្ខខណ្ឌមួយនៃការលក់ មិនអាចតវ៉ាបាន ។ អ្នកទិញត្រូវយល់ព្រមនិងចុះហត្ថលេខាលើបទបញ្ជាផ្ទៃក្នុងនេះ ដែលជាផ្នែកមួយនៃកិច្ចសន្យាលក់។

១.៥. សហកម្មសិទ្ធិករ និងអ្នកដែលមានផលប្រយោជន៍លើអគារសហកម្មសិទ្ធិទាំងអស់ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងនេះ ច្បាប់និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងរក្សាសណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ ការគោរពសិទ្ធិអ្នកដទៃ និងការបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធានាភាពសុខដុមរវាងសហកម្មសិទ្ធិករទាំងអស់។

ជំពូកទី ២

សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់សហកម្មសិទ្ធិករ

ប្រការ ២.- ចំណែកឯកជន

២.១. ចំណែកឯកជន សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្តាច់មុខ តាមតំនូសបង្ហាញ និងបញ្ជីសារពើភណ្ឌ ដូចមានភ្ជាប់មកជាមួយបទបញ្ជាផ្ទៃក្នុងនេះ។

២.២. សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិត្រប់គ្រាន់ក្នុងការកាន់កាប់និងប្រើប្រាស់ផ្តាច់មុខលើចំណែកឯកជនរបស់ខ្លួន រួមបញ្ចូលទាំងអចលនវត្ថុទាំងអស់ដែលមាននៅក្នុងចំណែកឯកជន ដូចជាជញ្ជាំងខាងក្នុង ទ្វារទាំងអស់ រួមទាំងទ្វារចូលទៅក្នុងផ្ទះជង ផ្ទៃបង្ហួចខាងក្នុង ផ្ទៃការ៉ូ ផ្ទៃជញ្ជាំង ពិដាន គ្រឿងបំពាក់បច្ចេកទេសទាំងអស់សម្រាប់ការប្រើប្រាស់ផ្តាច់មុខនៅក្នុងចំណែកឯកជន ផ្ទះបាយ និងទូខោអាវ។

២.៣. យ៉ាដែលជាប់ជាមួយនឹងចំណែកឯកជន និងបានប្រើប្រាស់ជាឯកជន ត្រូវគណនាបញ្ចូលជាចំណែកឯកជន ប្រសិនបើមិនប៉ះពាល់ដល់ការប្រើប្រាស់ចំណែកឯកជនរបស់សហកម្មសិទ្ធិករផ្សេងទៀត ឬចំណែករួម។

២.៤. សហកម្មសិទ្ធិករនៃចំណែកឯកជនមានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួនតាមការកម្រិតលក្ខខណ្ឌដោយច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងនេះ ។ ឧទាហរណ៍ កម្មសិទ្ធិករអាចលក់ ឬជួលចំណែកឯកជនរបស់ខ្លួន ប្រើប្រាស់ជាប្រាតិភោគអចលនវត្ថុ ដាក់បញ្ចាំ ឬដាក់ប៊ីប៉ូតែក ឬមានសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ។

២.៥. សហកម្មសិទ្ធិករនីមួយៗត្រូវគោរពសិទ្ធិនៃកម្មសិទ្ធិករដទៃក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួន។ ការប្រើប្រាស់ចំណែកឯកជននេះ ត្រូវហាមឃាត់ប្រសិនបើការប្រើប្រាស់នោះបង្កការប៉ះពាល់ឬខូចខាតដល់ចំណែករួមឬចំណែកឯកជនផ្សេងទៀត។

២.៦. សហកម្មសិទ្ធិករត្រូវបង្កលក្ខណៈងាយស្រួលដល់បុគ្គលដែលត្រូវមកធ្វើការថែទាំ ជួសជុលផ្នែករួម និងឯកជនសិទ្ធិករមិនអាចទាមទារសំណង ឬតម្លៃតបស្នងណាមួយអំពីការបង្កលក្ខណៈងាយស្រួលក្នុងការជួសជុលថែទាំនេះទេ។

ប្រការ ៣.- ចំណែករួម

៣.១. ចំណែកដែលនៅសល់ពីចំណែកឯកជន ត្រូវបានចាត់ទុកជាចំណែករួម។ ចំណែករួមសំដៅដល់ដី និងរាល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលជាកម្មវត្ថុសម្រាប់ការប្រើប្រាស់រួម ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្តើរ ឧទ្យាន និង សួនច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំង ទីកន្លែងនៃសេវាកម្មរួម...

៣.២. សហកម្មសិទ្ធិករទាំងអស់ គឺជាម្ចាស់នៃចំណែករួម ។ ចំណែករួមនេះ មិនអាចយកមកប្រើប្រាស់ផ្តាច់មុខដោយបុគ្គលណាមួយឡើយ។ ចំណែករួមជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ។

៣.៣. ចំណែកទាំងឡាយដូចខាងក្រោមត្រូវបានចាត់ទុកជាចំណែករួម :

ក) ដី ទីធ្លាក្នុងរបង សួនច្បារ ផ្លូវ ច្រកចេញចូល ចំណតរថយន្ត សួនច្បារ កន្លែងកីឡា

ខ) ជញ្ជាំង និងជញ្ជាំងទ្រទ្រង់អគារ ឧបករណ៍ប្រើប្រាស់រួមគ្នា ដូចជាបណ្តាញទឹក ភ្លើង បណ្តាញ ឧស្ម័ន ទោះបីជាបណ្តាញនោះរត់កាត់តាមចំណែកឯកជនក៏ដោយ

គ) ទ្លួម បំពង់ និងក្បាលបំពង់ផ្សែង និងដំបូល

ឃ) ទីកន្លែងនៃសេវារួមផ្សេងៗទៀត។

ង) សិទ្ធិបន្ទាប់បន្សំទាំងឡាយដូចមានចែងក្នុងមាត្រា ១៧៩ នៃច្បាប់ភូមិបាល។

៣.៤. សិទ្ធិលើក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនេះ ជាសិទ្ធិដែលមិនបាត់បង់ឡើយ ទោះជាអគារសហកម្មសិទ្ធិនេះត្រូវខូចខាត ឬទទួលរងមហន្តរាយទាំងស្រុងក៏ដោយ។

ប្រការ ៤.. ការចាត់ចែងចំណែកឯកជន

៤.១. សិទ្ធិចាត់ចែងលើចំណែកឯកជនរបស់សហកម្មសិទ្ធិករ ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

៤.២. នៅពេលផ្ទេរសិទ្ធិលើចំណែកឯកជន តាមរយៈការលក់ ការដូរ ប្រទានកម្ម និងការបន្តមរតក សិទ្ធិចាត់ចែងលើចំណែកឯកជនរបស់សហកម្មសិទ្ធិករ រួមទាំងកាតព្វកិច្ចទាំងអស់ ត្រូវផ្ទេរទៅឱ្យអ្នកទទួលសិទ្ធិបន្ត ឬសហកម្មសិទ្ធិករថ្មី។

៤.៣. អ្នកផ្ទេរសិទ្ធិ ឬអ្នកលក់ និង/ឬ អ្នកទទួលសិទ្ធិបន្ត ឬអ្នកទិញត្រូវស្នើសុំធ្វើចរន្តការនូវការផ្ទេរសិទ្ធិនេះនៅរដ្ឋបាលសុរិយោដី។

៤.៤. អ្នកផ្ទេរសិទ្ធិឬអ្នកទិញ និង/ឬ អ្នកទទួលសិទ្ធិបន្ត ឬអ្នកទិញត្រូវទទួលខុសត្រូវលើការចំណាយថ្លៃសេវា និងការបង់ពន្ធផ្សេងៗជូនរដ្ឋតាមច្បាប់កំណត់។

៤.៥. ផ្ទៃខាងក្នុងនៃចំណែកឯកជនដែលមើលពុំឃើញពីខាងក្រៅ សហកម្មសិទ្ធិករអាចរៀបចំនិងជួសជុលបាន តែមិនអាចប៉ះពាល់រចនាសម្ព័ន្ធដើម និងមិនអាចផ្ទុកទម្ងន់លើសពីការកំណត់ ឬធ្វើអ្វីបណ្តាលឱ្យប៉ះពាល់ដល់អ្នកជិតខាង ឬដែលបង្កគ្រោះថ្នាក់ដល់ភាពរឹងមាំនិងសុវត្ថិភាពនៃសំណង់ ឬធ្វើឱ្យខូចដល់សោភ័ណភាពនៃអគារសហកម្មសិទ្ធិទាំងមូលទេ។

៤.៦. សហកម្មសិទ្ធិករ ឬអ្នកជួលចំណែកឯកជន ដែលបានលក់ឬជួលបន្តចំណែកឯកជនក្នុងអគារសហកម្មសិទ្ធិនេះ ត្រូវដោះយកទៅជាមួយខ្លួននូវអចលនវត្ថុពីភ័ព្វវាសនាទាំងឡាយ ដែលនៅភ្ជាប់ជាមួយអ្នកជួលសហកម្មសិទ្ធិនេះមកវិញ។

ជំពូកទី ៣

ការគ្រប់គ្រងអគារសហកម្មសិទ្ធិ

ប្រការ ៥.-

៥.១. សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិដែលមានកម្មសិទ្ធិករចាប់ពី ៥ ឡើងទៅ ត្រូវរៀបចំអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធិ ដោយការបង្កើតជាក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ដើម្បីទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ ដោយអនុលោមតាមមាត្រា ១៨៤ នៃច្បាប់ភូមិបាល ។ ករណីមានការផ្ទេរកម្មសិទ្ធិលើចំណែកឯកជន អ្នកទទួលសិទ្ធិបន្ត ឬសហកម្មសិទ្ធិករថ្មី ត្រូវក្លាយជាសមាជិកនៃអគារសហកម្មសិទ្ធិជាស្វ័យប្រវត្តិ។

៥.២. សហកម្មសិទ្ធិករទាំងអស់ត្រូវរៀបចំមហាសន្និបាតដើម្បីតែងតាំងក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ និងដើម្បីកំណត់ពីការផ្តល់សិទ្ធិសម្រេចចិត្ត ក្នុងករណីអវត្តមានសមាជិកខ្លះ។ ការសម្រេចចិត្តទាំងឡាយត្រូវផ្អែកលើភាគរយនៃសហកម្មសិទ្ធិករ។

៥.១. នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្តត្រូវអនុវត្តដូចតទៅ :

ក-តម្រូវឱ្យមានសម្លេងគាំទ្រភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុល ឬការថែទាំអគារសហកម្មសិទ្ធិ ឬការបង់ថ្លៃសេវាសាធារណៈនានា។

ខ-តម្រូវឱ្យមានសម្លេងគាំទ្រយ៉ាងតិច ៧៥ ភាគរយនៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តក្នុងករណីដែលអគារចាស់ទ្រុឌទ្រោមមិនអាចប្រើប្រាស់បាន ហើយតម្រូវឱ្យធ្វើការរុះរើអគារ ឬសាងសង់អគារជាថ្មី។ ក្នុងករណីមិនអាចរកការគាំទ្រ ៧៥ ភាគរយបាន នោះការវាយតម្លៃជាផ្លូវការលើស្ថានភាពអគាររបស់សមត្ថកិច្ចជំនាញត្រូវយកជាមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ។

ជំពូកទី ៤

សមាមាត្រនៃការចំណាយលើការជួសជុល ការថែទាំ និងការចំណាយផ្សេងៗ

ប្រការ ៦.-

៦.១. សហកម្មសិទ្ធិករនីមួយៗ ទទួលខុសត្រូវក្នុងការជួសជុល ថែទាំ និង/ឬបន្ទុកផ្សេងៗទៀតលើចំណែកឯកជនរបស់ខ្លួន។

៦.២. សហកម្មសិទ្ធិករទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នាក្នុងការជួសជុល ថែទាំ និងបន្ទុកផ្សេងៗទៀតលើចំណែករួមឱ្យបានសមស្រប។ ការចំណាយទាក់ទងនឹងការប្រើប្រាស់ ការជួសជុល ការបង្កើត និងបន្ទុក

ផ្សេងៗទៀតលើចំណែករួម ត្រូវគិតជាភាគរយទៅតាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃចំណែកឯកជនរបស់កម្មសិទ្ធិករនីមួយៗ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

ប្រការ ៧.-

វិវាទទាំងឡាយដែលកើតឡើងរវាងសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ត្រូវដោះស្រាយជាជំហានដំបូង ដោយការសម្រុះសម្រួលក្នុងក្របខណ្ឌនៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការគ្រប់គ្រងអគារសហកម្មសិទ្ធិ ។ ក្នុងករណីដែលមិនអាចដោះស្រាយបាន វិវាទនេះនឹងត្រូវដោះស្រាយដោយតុលាការ។

ប្រការ ៨.-

បទបញ្ជាផ្ទៃក្នុងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃដែលអ្នកទទួលសិទ្ធិក្លាយជាសហកម្មសិទ្ធិករពេញលក្ខណៈច្បាប់លើចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

ថ្ងៃទី..... ខែ..... ឆ្នាំ.....

អ្នកផ្ទេរសិទ្ធិ **អ្នកទទួលសិទ្ធិ**

ឈ្មោះ ..... **ឈ្មោះ.....**

ឧបសម្ព័ន្ធទី ២
នៃអនុក្រឹត្យលេខ ១២៧.អនក្រ.បក
ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩
ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន

លេខ : .....

ក្បាលដីសហកម្មសិទ្ធិលេខ : .....
រាជធានី/ខេត្ត : .....
ក្រុង/ស្រុក/ខណ្ឌ : .....
ឃុំ/សង្កាត់ : .....
ភូមិ : .....
ផ្លូវ : .....

អគារសហកម្មសិទ្ធិឈ្មោះ : .....
បម្រុងស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី..... ខែ ..... ឆ្នាំ .....
ទំហំចំណែកឯកជនសរុប : ..... ម^{2}
ជាន់ទី : .....
ភាគរយនៃចំណែកឯកជនធៀបនឹងទំហំសរុបអគារសហកម្មសិទ្ធិ ..... %

ជើង

មាត្រដ្ឋាន : .....

យោង :
- បទបញ្ជាផ្ទៃក្នុងលេខ .....
  ចុះថ្ងៃទី ..... ខែ..... ឆ្នាំ.....

ធ្វើនៅ ..... ថ្ងៃទី ..... ខែ..... ឆ្នាំ .....
តាម. រដ្ឋមន្ត្រីទទួលបន្ទុកការងារ នគរូបនីយកម្ម និងសំណង់

អ្នកសារ : បើលោកអ្នកបានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន នៃអគារសហកម្មសិទ្ធិនេះ ដោយបានចំណែកជាកម្មសិទ្ធិ ទទួលចំណែក-ប្រើប្រាស់ទទួលបញ្ជាំ ឬហ៊ុមព័ទ្ធតែក្តី ឬជួលរយៈពេលវែង ចូរលោកអ្នកកុំភ្លេចនាំម្ចាស់ចំណែកឯកជន ទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីសុំរយៈដើម្បីផ្ទាស់ឈ្មោះ ឬធ្វើលេខាធរិក នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុនេះតាំងនៅ ព្រោះកាលបើមិនបានបំពេញកិច្ចទាំងនេះទេ អចលវត្ថុនោះនឹងទុកជាការធានាប្រាក់លោកអ្នកក៏មិនកើត ឬទុកជាកម្មសិទ្ធិរបស់លោកអ្នកក៏ពុំបាន។

ចុះបញ្ជីលេខ : ..... អក្សរសញ្ញាខ្នុន : .....

ចំណែកឯកជនលេខ : ..... ជាន់ (BLOCK) លេខ : ..... ជាន់ទី : ..... ប្លង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី .... ខែ..... ឆ្នាំ .....

ប្រភេទសំណង់ : ..... រូបភាពប្រើប្រាស់ : ..... លក្ខណៈនៃការប្រើប្រាស់ : .....

តារាងដាំសង្ខេប

អត្តានុក្រមដ្ឋានម្ចាស់សិទ្ធិជួលរបស់ម្ចាស់ដីនៃចំណែកឯកជន				ការផ្លាស់ប្តូរ		សេចក្តីផ្សេងៗ
ទំហំដីនៃចំណែកឯកជន (ម)	នាមត្រកូល នាមខ្លួន / ប្រភេទទ្រព្យ	ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត	សាវតារ	លេខយោងដែលសម្គាល់លិខិតសញ្ញា ឬសាលក្រមតុលាការ	បន្ទុកលើចំណែកឯកជន	
១	២	៣	៤	៥	៦	៧

ច្បាប់ចម្លង ត្រឹមត្រូវ ដើម ទំព័រ ទី ២ នៃ ទំព័រ

ឧបសម្ព័ន្ធទី ៣
នៃអនុក្រឹត្យលេខ១៦២...អនក្រ.បក
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៩
ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន

លេខ : .....

ក្បាលដីសហកម្មសិទ្ធិលេខ : .....
រាជធានី/ខេត្ត : .....
ស្រុក/ខណ្ឌ /ក្រុង : .....
ឃុំ/សង្កាត់ : .....
ភូមិ : .....
ផ្លូវ : .....

អគារសហកម្មសិទ្ធិឈ្មោះ : .....
បង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី..... ខែ ..... ឆ្នាំ .....
ទំហំចំណែកឯកជនសរុប : ..... ម^{2}
ជាន់ទី : .....
ភាគរយនៃចំណែកឯកជនធៀបនឹងទំហំសរុបអគារសហកម្មសិទ្ធិ ..... %
រយៈពេលជួលចំណែកឯកជន ..... ឆ្នាំ ចាប់ពី ..... ដល់.....

ជើង

មាត្រដ្ឋាន : .....

យោង :
- វិញ្ញាបនបត្រសំគាល់សិទ្ធិជួលដីលេខ .....
ចុះថ្ងៃទី ..... ខែ..... ឆ្នាំ .....
រយៈពេល ..... ឆ្នាំ ចាប់ពី..... ដល់.....
- បទបញ្ជាផ្ទៃក្នុងលេខ .....
ចុះថ្ងៃទី ..... ខែ..... ឆ្នាំ.....

ធ្វើនៅ ..... ថ្ងៃទី ..... ខែ..... ឆ្នាំ .....
តំ. រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ចំណាំ : លើលោកអ្នកបានទទួលវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន នៃអគារសហកម្មសិទ្ធិនេះ ដោយបាត់បង់ប្រៃសណីយ៍បត្រ ទទួលទិញ-ផ្ទេរក្តី ទទួលបញ្ចាំ ឬហ៊ីប៉ូតែកក្តី ឬជួលអចិន្ត្រៃយ៍ ចូរលោកអ្នកកុំភ្លេចទាំម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន ទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីជ្ជាស់ឈ្មោះ ឬធ្វើលេខាចរិក នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុនេះតាំងនៅ ព្រោះកាលបើមិនបានបំពេញកិច្ចទាំងនេះទេ អចលវត្ថុនោះ និងទុកជាការធានាប្រាក់លោកអ្នកក៏មិនកើត ឬទុកជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជនក៏ពុំបាន។

ចុះបញ្ជីលេខ : ..... អក្ខរសញ្ញាខ្លួន : .....

ចំណែកឯកជនលេខ : ..... ជាន់ (BLOCK) លេខ : ..... ជាន់ទី : ..... ឬម៉ង់ស្ថាបត្យកម្មនៃលិខិតអនុញ្ញាតសាងសង់ចុះថ្ងៃទី .... ខែ..... ឆ្នាំ .....

ប្រភេទសំណង់ : ..... រូបភាពប្រើប្រាស់ : ..... លក្ខណៈនៃការប្រើប្រាស់ : .....

តារាងផ្ទៃសំណង់

លក្ខានុក្រមដ្ឋានអ្នកស៊ីឈ្នួលឯកជន				កន្លែងសម្គាល់		សេចក្តីផ្សេងៗ
ទំហំទំនងចំណែកឯកជន (ម²)	នាមត្រកូល នាមខ្លួន / ប្រភេទទ្រព្យ	ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត	សាវតា	លេខចារឹកដោយសង្កេបនៃលិខិត សញ្ញា ឬសាលក្រមតុលាការ	បន្ទុកលើចំណែកឯកជន	
១	២	៣	៤	៥	៦	៧

ច្បាប់ចម្លងត្រឹមត្រូវ ដែលបានធ្វើឡើងតាមច្បាប់ដើម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការកំណត់ចំនួនសមាមាត្រនិងរបៀប
តិតគួចំណែកឯកជនដែលអាចជា
កម្មសិទ្ធិរបស់ជនបរទេស
នៅក្នុងអគារសកម្មសិទ្ធិ

ឆ្នាំ ២០១០



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧២ . អស.យ.ច

អនុក្រឹត្យ
ស្តីពី
ការកំណត់ចំនួនសមាមាត្រ និងរបៀបគិតគូរចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេស នៅក្នុងអគារសហកម្មសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៩/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំទីកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការផ្តល់សិទ្ធិ កម្មសិទ្ធិ លើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដល់ជនបរទេស
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែសីហា ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០

សម្រួច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅកំណត់ចំនួនសមាមាត្រ និងរបៀបគិតគូរចំណែកឯកជននៃអគារសហកម្មសិទ្ធិមួយកន្លែងដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសនៅក្នុងអគារសហកម្មសិទ្ធិនៅព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២

ចំនួនសមាមាត្រ និងរបៀបគិតគូរនៃចំណែកឯកជន ដែលត្រូវផ្តល់ជូនជនបរទេស

មាត្រា២.-

ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ អាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិមួយកន្លែងមិនលើសពី ៧០ (ចិតសិប) ភាគរយនៃទំហំផ្ទៃក្រឡានៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិ។

មាត្រា៣.-

នៅពេលចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិជូនជនបរទេសរួចបាលសុរិយោដីត្រូវកត់ត្រាបញ្ចូលក្នុងនោះនូវសមាមាត្រនៃទំហំផ្ទៃក្រឡាចំណែកឯកជននីមួយៗធៀបនឹងទំហំផ្ទៃក្រឡានៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិ។

ជំពូកទី៣

អវសានប្បញ្ញត្តិ

មាត្រា៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ប៉ុស្តិ៍កាល័យសម្តេចនាយករដ្ឋមន្ត្រី
- ប៉ុស្តិ៍កាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងបុរី

ឆ្នាំ ២០១៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងបុរី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស



- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើង
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការគ្រប់គ្រងបុរី ព្រមទាំងគោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការចុះបញ្ជីដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត នៅក្នុងបរិវេណនៃបុរី។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- ធានាការពារសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់កម្មសិទ្ធិករនៃដីឡូត៍ និងកម្មសិទ្ធិករនៃដីឡូត៍ដែលមានសំណង់លំនៅឋាន និងសំណង់ផ្សេងទៀត ព្រមទាំងកម្មសិទ្ធិករនៃចំណែកឯកជន នៃអគារសហកម្មសិទ្ធិនៅក្នុងបរិវេណនៃបុរី
- សម្រួលដល់ការងារគ្រប់គ្រងបុរី និងការគ្រប់គ្រងដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតនៅក្នុងបរិវេណនៃបុរី
- សម្រួលដល់កម្មសិទ្ធិករនៃលំនៅឋាន និងសំណង់ផ្សេងទៀត ក្នុងបរិវេណនៃបុរី ក្នុងការលក់ ការដូរ ការធ្វើអំណោយ ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការដាក់ប៊ីប៉ូតែក និងការដាក់បញ្ចាំនូវកម្មសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់
- ធានាការពារលម្ហសាធារណៈនានា និងរក្សាសោភណភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងបរិវេណនៃបុរី
- បង្កលក្ខណៈងាយស្រួលដល់វិនិយោគិន ក្នុងការសាងសង់បុរីក្នុងគោលបំណងសម្រាប់លក់ ឬជួល នៅព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះបុរីគ្រប់ប្រភេទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤.-

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

- **បុរី** សំដៅដល់ទីតាំងមួយដែលត្រូវបានរៀបចំ ជាដីឡូត៍ ជាសំណង់លំនៅឋាន សំណង់ផ្សេងៗ លម្អ សាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅលើក្បាលដីតែមួយ ស្របតាមគម្រោងប្លង់សរុបរបស់បុរី ដែលបានទទួលការអនុញ្ញាតជាផ្លូវការ។
- **ក្បាលដី** សំដៅដល់ក្បាលដីដែលអ្នកអភិវឌ្ឍបុរី ប្រើប្រាស់ជាទីតាំងសម្រាប់រៀបចំបុរី។ ក្បាលដីរបស់បុរីចែកចេញជាដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលអាចមានកម្មសិទ្ធិករ ដោយឡែកៗ លើដីឡូត៍ លើប្រភេទលំនៅឋាន និងអគារនីមួយៗ។ លំនៅឋាននៅក្នុងបរិវេណបុរី មានជាអាទិ៍ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ អគារសហកម្មសិទ្ធិ ផ្ទះល្វែង និងប្រភេទសំណង់ផ្សេងទៀត។
- **ដីឡូត៍** សំដៅដល់ចំណែកនៃដី ដែលចែកចេញពីក្បាលដី ជាទីតាំងនៃបុរី ហើយដែលអ្នកអភិវឌ្ឍបុរីបានរៀបចំទៅតាមប្រភេទសំណង់ ដូចមានកំណត់ក្នុងប្លង់សរុបរបស់បុរី។
- **ផ្លូវចេញចូល** សំដៅដល់ផ្លូវដែលមានកំណត់ នៅក្នុងប្លង់សរុបរបស់បុរី ដែលបានសម្រេចជាផ្លូវការ និងត្រូវចាត់ចូលជាផ្លូវរបស់បុរី សម្រាប់ការប្រើប្រាស់រួម របស់កម្មសិទ្ធិករទាំងអស់ នៅក្នុងបុរី។
- **អ្នកអភិវឌ្ឍបុរី** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ទុនវិនិយោគលើការសាងសង់បុរី។
- **ប្លង់សរុបរបស់បុរី** សំដៅដល់ប្លង់ទីតាំងដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត មានមាត្រដ្ឋាន ១:២០០ ឬ ១:៥០០ នៅលើក្បាលដី មួយដែលនៅលើប្លង់សរុបនេះ បញ្ជាក់ពីការបោះទីតាំងនៃដីឡូត៍ និងទីតាំងនៃសំណង់ក្នុងក្បាលដីដែលជាកម្មវត្ថុនៃពាក្យសុំឈ្មោះ ឬលេខផ្លូវធំ តូច និងទំហំផ្លូវច្រកចេញចូល ក្នុងបរិវេណបុរី ជួរតម្រង់នៃអគារ ទំហំដីនិងក្រឡាផ្ទៃដីឡូត៍នីមួយៗ ច្បាស់លាស់ចម្ងាយរវាងអគារនីមួយៗ ចម្ងាយពីអគារទៅព្រំប្រទល់ក្បាលដី ព្រមទាំងមានការរៀបចំផ្នែកផ្សេងទៀតនៃដីទំនេរ (ដាំដំណាំ សួនច្បារ និងចំណតរថយន្ត) របង កន្លែងតភ្ជាប់បណ្តាញលូសាធារណៈ សម្រាប់បញ្ចេញទឹកកខ្វក់ ទីតាំងអាងបង្កន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ទីតាំងទុកដាក់សំណល់រឹង និងបណ្តាញប្រព័ន្ធបង្ហូរទឹក បណ្តាញទឹកស្អាត មាននិមិត្តសញ្ញា និងអក្សរកាត់ប្រើក្នុងសន្ទីកប្លង់។
- **ប្លង់ស្ថាបត្យកម្ម** សំដៅដល់ប្លង់ដែលជាផ្នែកស្ថាបត្យកម្ម បង្ហាញលើការរៀបចំអគារមួយ ដែលមានមាត្រដ្ឋាន ១:២០០ ឬ ១:១០០ និង១:៥០ មានជាអាទិ៍ : ប្លង់អគារគ្រប់ជាន់ ប្លង់ដំបូល ប្លង់មុខភាពនៃអគារគ្រប់ទិស ប្លង់ពុះបណ្តោយនិងទទឹងអគារ ប្លង់បណ្តាញក្រោមដី ប្លង់អាងបង្កន់អនាម័យ និងតារាងគណនាផលធ្យៀបផ្ទៃបាតសំណង់ និងសន្ទស្សន៍នៃការប្រើប្រាស់។
- **សន្តតិជន** សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។
- **សន្តតិកម្ម** សំដៅដល់ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។
- **មតកជន** សំដៅដល់ជនដែលបានស្លាប់ទៅហើយ។

ជំពូកទី២
ការគ្រប់គ្រងបុរី

មាត្រា ៥.-

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលស្ថិតក្នុងបរិវេណនៃបុរី លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្សេងពីនេះ។

មាត្រា ៦.-

ក្បាលដីសម្រាប់សាងសង់បុរី ត្រូវតែជាក្បាលដីតែមួយ ដែលត្រូវបានចុះបញ្ជីរួចហើយនៅក្នុងស្បៀវភៅគោលបញ្ជីដីធ្លី ឬស្បៀវភៅចុះបញ្ជីអចលនវត្ថុ។ ក្នុងករណីដែលក្បាលដីសម្រាប់សាងសង់បុរីមានច្រើនក្បាលដី អ្នកអភិវឌ្ឍបុរី ត្រូវធ្វើការបង្រួមក្បាលដីឲ្យទៅជាក្បាលដីតែមួយជាមុនសិន លើកលែងតែក្បាលដីសម្រាប់សាងសង់បុរី មានផ្លូវសាធារណៈ និង/ឬផ្លូវទឹកដែលមានទទឹងយ៉ាងតិច ២ ម៉ែត្រឆ្លងកាត់។

ក្នុងករណីដែលក្បាលដីសម្រាប់សាងសង់បុរី ស្ថិតនៅក្នុងឃុំ សង្កាត់ខុសៗគ្នា ហើយក្បាលដីនៅជាប់គ្នា អ្នកអភិវឌ្ឍបុរី ត្រូវធ្វើការបង្រួមក្បាលដីនៅក្នុងឃុំ សង្កាត់នីមួយៗដោយឡែកពីគ្នា ប៉ុន្តែអ្នកអភិវឌ្ឍបុរីត្រូវរក្សាទុកព្រំប្រទល់ រវាងឃុំ សង្កាត់ទាំងនោះ ជាលម្ហសាធារណៈស្របតាមបញ្ញត្តិនគរូបនីយកម្ម។

ក្នុងករណី ដែលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត មានច្រើនប្រភេទលើប្លង់សរុបតែមួយ នៅពេលផ្ទេរលើកដំបូងនូវដីឡូត៍ ឬដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត អ្នកអភិវឌ្ឍបុរី ត្រូវស្នើសុំបំបែកក្បាលដីរបស់បុរីទៅជាដីឡូត៍ ទៅតាមប្រភេទនិងចំនួនដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់នីមួយៗ ផ្សេងទៀតស្របតាមប្លង់សរុបរបស់បុរី ទៅរដ្ឋបាលសុរិយោដី ។ ការបង្រួមក្បាលដី និងការបំបែកក្បាលដីត្រូវធ្វើឲ្យស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មាត្រា ៧.-

មុននឹងស្នើសុំការសម្រេចលើប្លង់សរុបរបស់បុរី អ្នកអភិវឌ្ឍបុរី ត្រូវពិគ្រោះយោបល់ឲ្យឯកភាពគ្នាជាមុនសិន ជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ លើប្លង់សរុបរបស់បុរី ក្នុងគោលដៅធ្វើឲ្យស្របនឹងបទបញ្ជាទូទៅនៃការប្រើប្រាស់ដី ឬផែនការប្រើប្រាស់ដី ប្រសិនបើមាន។

អ្នកអភិវឌ្ឍបុរី មិនអាចកែប្រែប្លង់សរុបរបស់បុរី ដែលបានសម្រេចជាផ្លូវការ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់រួចហើយ នោះបានទេ។ ការកែប្រែប្លង់សរុបរបស់បុរី អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាត ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្ទាប់ពីមានការយល់ព្រមពីកម្មសិទ្ធិករផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ៤ ចំណុច ខ នៃមាត្រា១២ នៃអនុក្រឹត្យនេះ។

ប្លង់ស្ថាបត្យកម្មនៃសំណង់លំនៅឋាន និង/ឬសំណង់អគារផ្សេងទៀត ត្រូវគោរពតាមច្បាប់ និងបទ-ប្បញ្ញត្តិជាធរមាន ។

មាត្រា ៨.-

អ្នកអភិវឌ្ឍបុរី ត្រូវរៀបចំឲ្យ មានហេដ្ឋារចនាសម្ព័ន្ធអប្បបរមា ស្របតាមទំហំផ្ទៃដីរបស់បុរីមាន ៖

- សំណង់អគារមានអគារលំនៅឋាន និងសំណង់ផ្សេងទៀត
- លម្ហសាធារណៈដូចជា សួនច្បារ ចំណតរថយន្ត លម្ហសេវារួមនានា ជាដើម
- ផ្លូវចេញចូលបុរី និងរបងបុរី
- បណ្តាញទឹកស្អាត លូបង្ហូរទឹកកខ្វក់ និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ទីតាំងទុកដាក់សំណល់រឹង បណ្តាញ អគ្គិសនី និងទូរគមនាគមន៍ ប្រព័ន្ធសុវត្ថិភាព និងការពារអគ្គីភ័យដោយបំពាក់ក្បាលបំពង់ទឹកសម្រាប់ ពន្លត់អគ្គីភ័យ ។

មាត្រា ៩.-

លម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបងបុរី ត្រូវចុះបញ្ជីជាកម្មសិទ្ធិអវិភាគរបស់កម្មសិទ្ធិករក្នុងបុរី សម្រាប់ការប្រើប្រាស់រួមរបស់កម្មសិទ្ធិករទាំងអស់ នៅក្នុងបុរី លើកលែងតែលម្ហឯកជន ឬសួនច្បារឯកជន ដែលជាផ្នែកនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ឯកជនផ្សេងទៀត ដែលមានដីឡូត៍ដោយឡែកនីមួយៗ ស្របតាមប្លង់សរុបរបស់បុរីដែលបានសម្រេចរួចហើយ ។

មាត្រា ១០.-

នីតិវិធីនៃការចុះបញ្ជីដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ត្រូវមានលក្ខណៈសាមញ្ញ ងាយស្រួល និងមានតម្លាភាព ។

មាត្រា ១១.-

សន្តតិជននៃមតកជននីមួយៗ ដែលមានកម្មសិទ្ធិលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ក្នុងបុរី មានសិទ្ធិទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។ ក្នុងករណីដែលមរតកនៅទំនេរ ដោយគ្មានសន្តតិជនទទួលបន្ត ឬសន្តតិជនបោះបង់ចោល ឬមរតកមិនត្រូវបានចាត់ចែងទៅឲ្យជនណាមួយ តាមបញ្ញត្តិច្បាប់ជាធរមាន មរតកនៅទំនេរនោះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មាត្រា ១២.-

អ្នកអភិវឌ្ឍបុរី ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយ មុននឹងប្រកាសលក់ ឬជួលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលបានសាងសង់ក្នុងបុរី ។ បទបញ្ជាផ្ទៃក្នុងជាលក្ខខណ្ឌមួយនៃការលក់ទិញ ជួលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ ផ្សេងទៀត ក្នុងបុរី ។

បទបញ្ជាផ្ទៃក្នុងខាងលើនេះ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមានទេ។

ដើម្បីគ្រប់គ្រងបុរី កម្មសិទ្ធិករត្រូវបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរីមួយ តាមការព្រមព្រៀងរវាងកម្មសិទ្ធិករ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

ការរៀបចំបទបញ្ជាផ្ទៃក្នុង ត្រូវស្របតាមគោលការណ៍ និងលក្ខខណ្ឌអប្បបរមា នៃបទបញ្ជាផ្ទៃក្នុងគំរូ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ហើយដែលត្រូវចែងជាអាទិ៍ ៖

- សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត លើការថែទាំនិងជួសជុលសេវារួមនានា
- ការកំណត់ពីសមាមាត្រនៃចំណាយរួមនានារបស់កម្មសិទ្ធិករ សម្រាប់ការថែទាំឬការជួសជុលសេវារួម សេវាសន្តិសុខ ព្រមទាំងការបង់ថ្លៃលើការប្រើប្រាស់សេវាសាធារណៈនានា
- នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត ក្នុងករណីដែលកម្មសិទ្ធិករបង្កើតអង្គការគ្រប់គ្រងបុរី ៖

ក. តម្រូវឲ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុលសេវារួម សេវាសន្តិសុខ ឬការបង់ថ្លៃសេវាសាធារណៈនានា។

ខ. តម្រូវឲ្យមានសំឡេងគាំទ្រយ៉ាងតិច ៧៥% នៃកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែប្រែបង់សរុបរបស់បុរី ការជួសជុលលំនៅឋាន ឬសំណង់ផ្សេងទៀត ដែលខុសពីរចនាសម្ព័ន្ធដើមនៃបង់ស្ថាបត្យកម្ម។ ក្នុងករណីមិនអាចរកការគាំទ្រ ៧៥% បាននោះ ការវាយតម្លៃជាផ្លូវការរបស់សមត្ថកិច្ចជំនាញ ត្រូវយកជាមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ។

ជំពូកទី៣

សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍបុរី និងរបស់កម្មសិទ្ធិករក្នុងបុរី

ផ្នែកទី ១ : សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍបុរី

មាត្រា ១៣.-

នៅពេលផ្ទេរលើកដំបូងនូវដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ណាមួយ ឲ្យទៅជនដទៃ អ្នកអភិវឌ្ឍបុរី ត្រូវស្នើសុំបំបែកក្បាលដីទៅតាមប្រភេទនិងចំនួននៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត នៅរដ្ឋបាលសុរិយោដី លើកលែងតែបុរីណាដែលបានសាងសង់ លើដីជួលអចិន្ត្រៃយ៍ពីបុគ្គលដទៃ។

អ្នកអភិវឌ្ឍបុរីត្រូវប្រកាសប្រាប់អ្នកទិញនូវដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត អំពីប្រភេទក្បាលដី ដែលខ្លួនបានសាងសង់ជាបុរីថា ជាក្បាលដីកម្មសិទ្ធិរបស់ខ្លួន ឬក្បាលដីជួលអចិន្ត្រៃយ៍ ពីអ្នកដទៃ ឬក្បាលដីជាប់បន្ទុកផ្សេងៗ។

មាត្រា ១៤.-

មុននឹងប្រកាសលក់ឬដួលដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលសាងសង់ក្នុងបុរី អ្នកអភិវឌ្ឍបុរីត្រូវមានលិខិតបញ្ជាក់ពីសារធនភាព និងប្រភពហិរញ្ញប្បទានច្បាស់លាស់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លិខិតបញ្ជាក់នេះត្រូវចេញឲ្យអ្នកអភិវឌ្ឍបុរីក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ។

មាត្រា ១៥.-

នៅពេលផ្ទេរលើកដំបូងនូវដីឡូត៍ ដីឡូត៍លំនៅឋាននិងដីសំណង់ផ្សេងទៀតណាមួយ ក្រៅពីក្បាលដីអគារសហកម្មសិទ្ធិ អ្នកអភិវឌ្ឍបុរី ត្រូវប្រគល់បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃក្បាលដីឲ្យរដ្ឋបាលសុរិយោដី ដើម្បីធ្វើលេខាចារីកនិងរក្សាទុកជាឯកសារ ហើយរដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីឡូត៍នីមួយៗ ជូនអ្នកអភិវឌ្ឍបុរីជាជំនួសវិញ មុននឹងផ្ទេរទៅឲ្យអ្នកទិញ។

ទោះបីជា ក្បាលដីទាំងឡាយ ត្រូវបានបំបែកតាមមាត្រា១៣ និងកថាខណ្ឌទី ១ នៃមាត្រា១៥ នៃអនុក្រឹត្យនេះក្តី ក៏ក្បាលដីទាំងអស់ នៅតែមានក្នុងប្លង់សរុបរបស់បុរីដដែល ដោយកម្មសិទ្ធិករទាំងអស់នៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ត្រូវគោរពតាមប្លង់សរុបរបស់បុរី។

មាត្រា ១៦.-

ប្រសិនបើ អ្នកអភិវឌ្ឍបុរី បានសាងសង់បុរី នៅលើដីដួលអចិន្ត្រៃយ៍ពីបុគ្គលដទៃ នោះអាជ្ញាយុកាលនៃសិទ្ធិដួលអចិន្ត្រៃយ៍ លើលំនៅឋានគ្រប់ប្រភេទ ឬលើសំណង់ផ្សេងទៀតនៅក្នុងបុរី មានត្រឹមតែរយៈពេលដូចបានកំណត់ ក្នុងកិច្ចសន្យាដួលដីអចិន្ត្រៃយ៍ រវាងអ្នកអភិវឌ្ឍបុរី និងម្ចាស់ដីតែប៉ុណ្ណោះ។ ភតិកៈដែលបានទទួលនូវសិទ្ធិ ឬអ្នកដួលអចិន្ត្រៃយ៍លើអចលនវត្ថុក្នុងបុរី អាចទទួលបានវិញ្ញាបនបត្រសម្គាល់សិទ្ធិដួលអចិន្ត្រៃយ៍ ដូចមានចែងក្នុងអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការដួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច។

មាត្រា ១៧.-

អ្នកអភិវឌ្ឍបុរី ត្រូវគោរពតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ជាពិសេស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ផ្នែកទី ២ : សិទ្ធិ និងកាតព្វកិច្ចរបស់កម្មសិទ្ធិករ

មាត្រា ១៨.-

សហកម្មសិទ្ធិករលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលមាននៅក្នុងបុរី មានសិទ្ធិ និងកាតព្វកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ។

មាត្រា ១៩.-

កម្មសិទ្ធិករផ្សេងទៀតនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតក្នុងបុរី មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ខ្លួន។

សិទ្ធិចាត់ចែងលើដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត របស់កម្មសិទ្ធិករ ដូចជាការលក់ ការដូរ ការជួល ប្រទានកម្ម ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការបង្កើតផលុបភោគ ការប្រើប្រាស់ និងអាស្រ័យនៅ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំ ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីច្បាប់ជាធរមាន។

មាត្រា ២០.-

កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុង ដែលកំណត់របៀបគ្រប់គ្រង និងវិធាននៃការថែទាំ ព្រមទាំងការបំពេញកាតព្វកិច្ចផ្សេងៗទៀត ដែលច្បាប់បានកំណត់។

ជំពូកទី៤

យន្តការ និងនីតិវិធីនៃការចុះបញ្ជីដីឡូត៍ ដីឡូត៍លំនៅឋាន និងអចលនវត្ថុផ្សេងទៀតនៅក្នុងបុរី

មាត្រា ២១.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចំពោះលំនៅឋានដែលមានទម្រង់ជាចំណែកឯកជន នៃអគារសហកម្មសិទ្ធិ និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ជូនកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតដែលមានក្នុងបុរី។

មាត្រា ២២.-

ចំពោះលំនៅឋានដែលមានទម្រង់ជាចំណែកឯកជននៃអគារសហកម្មសិទ្ធិ ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ។

ចំពោះប្រភេទដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងៗទៀត ដែលមាននៅក្នុងបុរី ត្រូវចុះបញ្ជីតាមបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ២៣.-

ការបង្រួមក្បាលដីដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី។

រាល់ការបំបែកក្បាលដីទៅជាដីឡូត៍តាមប្រភេទ និងចំនួនដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ទីមួយៗ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី ។

រាល់ការផ្ទេរសិទ្ធិលើដី និងលំនៅឋាននៅក្នុងបុរីត្រូវបង់ថ្លៃសេវាសុរិយោដី និងបង់ពន្ធប្រថាប់ត្រាជូនរដ្ឋ តាមច្បាប់កំណត់។

ជំពូកទី៥

បញ្ញត្តិដោយឡែក

មាត្រា ២៤.-

មាត្រា៨ នៃអនុក្រឹត្យនេះ មិនអនុវត្តទេ ចំពោះបុរីដែលបានសាងសង់រួចហើយមុនអនុក្រឹត្យនេះ ចូលជាធរមាន ឬគម្រោងបុរីដែលមានប្លង់សរុប និងប្លង់ស្ថាបត្យកម្មដែលបានទទួលការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចរួចហើយ។

មាត្រា ២៥.-

ចំពោះសំណង់ផ្ទះល្វែង មិនមែនជាលក្ខណៈបុរី ការចុះបញ្ជីផ្ទះល្វែងទាំងនោះ ត្រូវអនុវត្តតាមបទដ្ឋាន-គតិយុត្តជាធរមាន ដោយបំបែកក្បាលដីតាមប្លង់ផ្ទះល្វែង ឬសំណង់នីមួយៗនៅក្នុងគម្រោងផ្ទះល្វែង។

អ្នកអភិវឌ្ឍសំណង់ផ្ទះល្វែង និងកម្មសិទ្ធិករទាំងឡាយ នៅក្នុងគម្រោងសំណង់ផ្ទះល្វែង ដែលប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ទទួលបានការយល់ព្រមពីក្រសួងស្ថាប័នមានសមត្ថកិច្ចរួចហើយនោះ មិនអាចធ្វើការកែប្រែប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ឬជួសជុលផ្ទះល្វែង ឬសំណង់ទាំងឡាយនៅក្នុងគម្រោងសំណង់ផ្ទះល្វែង ខុសពីប្លង់សរុប និងប្លង់ស្ថាបត្យកម្មឡើយ។

រាល់ការកែសម្រួលប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ឬកែប្រែជួសជុលផ្ទះល្វែង ឬសំណង់ទាំងឡាយនៅក្នុងគម្រោងសំណង់ផ្ទះល្វែងខុសពីប្លង់សរុប និងប្លង់ស្ថាបត្យកម្ម ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ផ្លូវចេញចូល និងលម្ហសាធារណៈនានា ដែលមាននៅក្នុងបរិវេណសំណង់ផ្ទះល្វែងទាំងនោះ ត្រូវចាត់ទុកជាទ្រព្យសាធារណៈរបស់រដ្ឋ។

មាត្រា ២៦.-

សំណង់គ្រប់ប្រភេទ ដែលស្ថិតក្នុងតំបន់ដែលមានលក្ខណៈជាបុរី ទោះបីមានឈ្មោះអ្វីក៏ដោយ ក៏ត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះ។

មាត្រា ២៧.-

ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬអ្នកអភិវឌ្ឍដែលមានក្បាលដីច្រើនផ្សេងគ្នា ហើយមានព្រំជាប់គ្នា ត្រូវស្នើសុំបង្រួមក្បាលដី នៅរដ្ឋបាលសុរិយោដីតាមនីតិវិធីជាធរមាន លើកលែងតែក្បាលដីនៃតំបន់ សេដ្ឋកិច្ចពិសេស មានផ្លូវសាធារណៈ និង/ឬផ្លូវទឹកដែលមានទទឹងយ៉ាងតិច ០២ ម៉ែត្រឆ្លងកាត់។ ក្នុងករណីដែលក្បាលដី

ដីសម្រាប់អភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ស្ថិតក្នុងនៅក្នុងឃុំ សង្កាត់ខុសៗគ្នា ហើយក្បាលដីនៅជាប់គ្នា ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬអ្នកអភិវឌ្ឍត្រូវធ្វើការបង្រួមក្បាលដីនៅក្នុងឃុំ សង្កាត់នីមួយៗដោយឡែកពីគ្នា ប៉ុន្តែត្រូវរក្សាទុកព្រំប្រទល់ រវាងឃុំ សង្កាត់ទាំងនោះ ជាលម្ហសាធារណៈស្របតាមញ្ញត្តិ នគរូបនីយកម្ម។

ការចុះបញ្ជីអចលនវត្ថុទាំងឡាយ ដែលស្ថិតនៅក្នុងបរិវេណនៃតំបន់សេដ្ឋកិច្ចពិសេស ដែលបង្កើតឡើងស្របតាមអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចកិច្ចពិសេស ត្រូវអនុវត្តតាមនីតិវិធីដែលមានជាធរមាន ដោយបំបែកក្បាលដីតាមប្រភេទទីតាំងសំណង់នីមួយៗ នៅក្នុងបង្គប់សរុបនៃតំបន់សេដ្ឋកិច្ចពិសេស។

រាល់ការផ្ទេរសិទ្ធិលើអចលនវត្ថុក្នុងតំបន់សេដ្ឋកិច្ចពិសេស និងការផ្ទេរសិទ្ធិលើអចលនវត្ថុដែលបណ្តាលមកពីការផ្លាស់ប្តូរ ឬការរំលាយបញ្ជូលគ្នា នូវគម្រោងវិនិយោគទាំងឡាយ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ស្របតាមនីតិវិធីជាធរមាន។

លម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបងនៅក្នុងបរិវេណនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវចាត់ទុកជាទ្រព្យអវិភាគរបស់កម្មសិទ្ធិករ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ រាល់ការសាងសង់ ការថែទាំ និងការជួសជុលលម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបង ដូចមានចែងក្នុងកថាខណ្ឌនេះ គឺជាបន្ទុករបស់ម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬអ្នកអភិវឌ្ឍ ឬជាបន្ទុករបស់កម្មសិទ្ធិករទាំងអស់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ស្របតាមការការព្រមព្រៀងរវាងម្ចាស់តំបន់ និង/ឬអ្នកអភិវឌ្ឍ និងកម្មសិទ្ធិករនៃដីឡូត៍ ឬសំណង់ផ្សេងទៀត នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ លម្ហសាធារណៈ សួនច្បារ ផ្លូវចេញចូល លម្ហសេវារួម និងរបងនៃតំបន់សេដ្ឋកិច្ចពិសេស ត្រូវចុះបញ្ជីជាកម្មសិទ្ធិអវិភាគរបស់កម្មសិទ្ធិករ ក្នុងតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ការប្រើប្រាស់រួមរបស់កម្មសិទ្ធិករទាំងអស់ នៅក្នុងតំបន់។

ក្រៅពីសួនច្បារ ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រានេះ អាចមានសួនច្បារខ្លះនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលជាផ្នែកនៃដីឡូត៍ ឬដីឡូត៍លំនៅឋាន ឬដីសំណង់ឯកជនផ្សេងទៀត ត្រូវចាត់ទុកជាសួនច្បារឯកជន។

កម្មសិទ្ធិករទាំងអស់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ត្រូវអនុវត្តនូវគម្រោងទាំងឡាយ នៅលើដីឡូត៍របស់ខ្លួន ស្របតាមបង្គប់សរុបរបស់តំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការសម្រេចជាផ្លូវការរួចហើយ។

ជំពូកទី៦

អវសានប្បញ្ញត្តិ

មាត្រា ២៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ២៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ៤ ឆ្នាំ ២០១១

ទាយអរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៩
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ឧបសម្ព័ន្ធ

អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ២ ឆ្នាំ ២០១១ ស្តីពីការគ្រប់គ្រងបុរី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូបទបញ្ជាផ្ទៃក្នុង
សម្រាប់ការគ្រប់គ្រងបុរី
នៃសំណង់បុរី .....

ទីតាំងបុរី : .....

.....

អនុលោមតាមអនុក្រឹត្យលេខ.... ....អនក្រ.បក ចុះថ្ងៃទី.... .... ខែ.... .... ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី កម្មសិទ្ធិករទាំងអស់នៃដីឡូត៍ ដីឡូត៍លំនៅឋាន និងសំណង់ផ្សេងទៀតដែលស្ថិតក្នុងបុរីឈ្មោះ.... .... បានព្រមព្រៀងគ្នាលើការគ្រប់គ្រង និងប្រើប្រាស់បុរី តាមលក្ខខណ្ឌទាំងឡាយដូចតទៅ៖

ប្រការ ១.. គោលការណ៍ទូទៅ

១.១. បទបញ្ជា ផ្ទៃក្នុងនេះកំណត់អំពីការគ្រប់គ្រង និងការប្រើប្រាស់ដីឡូត៍ ដីឡូត៍លំនៅឋាន និងសំណង់ផ្សេងទៀត នៃបុរីឈ្មោះ..... ព្រមទាំងកំណត់បន្ថែមអំពីសិទ្ធិ និងកាតព្វកិច្ច របស់កម្មសិទ្ធិករទាំងអស់នៃដីឡូត៍ ដីឡូត៍លំនៅឋាន និងសំណង់ផ្សេងទៀតនៅក្នុងបុរីដោយអនុលោមតាមសិទ្ធិ និងកាតព្វកិច្ច ដូចមានចែងក្នុងជំពូកទី ៣ នៃអនុក្រឹត្យលេខ.....អនក្រ.បក ស្តីពីការគ្រប់គ្រងបុរី និងបទដ្ឋានពាក់ព័ន្ធដទៃទៀតជាធរមាន។

១.២. បទបញ្ជាផ្ទៃក្នុងនេះជាផ្នែកមួយនៃកិច្ចសន្យាផ្ទេរកម្មសិទ្ធិរវាងកម្មសិទ្ធិករចាស់ និងកម្មសិទ្ធិករថ្មី លើដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតនៅក្នុងបុរី ហើយដែលកម្មសិទ្ធិករថ្មីត្រូវគោរពតាម។

១.៣. កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត ព្រមទាំងអ្នកដែលមានផលប្រយោជន៍ទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងនេះ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងត្រូវរក្សាសណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ ការគោរពសិទ្ធិអ្នកដទៃ និងការបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធានាភាពសុខដុម រវាងកម្មសិទ្ធិករទាំងអស់។

១.៤. ប្រសិនបើ នៅក្នុងបុរីមានសំណង់អគារសហកម្មសិទ្ធិ នោះសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិត្រូវអនុវត្តផងដែរ នូវសិទ្ធិនិងកាតព្វកិច្ច ដូចមានចែងក្នុងអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ។

ប្រការ ២.- ការរក្សា និងការគោរពតាមប្លង់សរុបរបស់បុរី និងប្លង់ស្ថាបត្យកម្ម

អ្នកអភិវឌ្ឍន៍បុរី និងកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតនៃបុរី មិនអាចកែប្រែលំនៅឋាន ឬសំណង់ផ្សេងទៀតឱ្យខុសពីប្លង់សរុបរបស់បុរី និងប្លង់ស្ថាបត្យកម្មបុរី ដែលបានទទួលការសម្រេចពីអាជ្ញាធរមានសមត្ថកិច្ចរួចហើយនោះឡើយ។ ការកែប្រែត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យលេខ.....អនក្រ.បក ស្តីពីការគ្រប់គ្រងបុរី និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតជាធរមាន។

ប្រការ ៣.- សិទ្ធិ កាតព្វកិច្ច និងការធានារ៉ាប់រងខុសត្រូវរបស់កម្មសិទ្ធិករនីមួយៗ

៣.១. កម្មសិទ្ធិករនីមួយៗនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬសំណង់ផ្សេងទៀត នៅក្នុងបុរី មានសិទ្ធិពេញលេញក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផល ផ្តាច់មុខលើចំណែកកម្មសិទ្ធិឯកត្តជនរបស់ខ្លួន តាមការកម្រិតលក្ខខណ្ឌដោយច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងនេះ ដូចជាកម្មសិទ្ធិករអាចលក់ដូរ-ផ្ទេរអំណោយ-បន្តមរតក ឬជួលចំណែកកម្មសិទ្ធិឯកត្តជនរបស់ខ្លួន អាចបង្កើតជាប្រាតិភោគសម្រាប់ដាក់បញ្ចាំ ឬដាក់ប៊ីប៉ូតែក ឬបង្កើតសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ ឬជាផលុបភោគជាដើម។

៣.២. កម្មសិទ្ធិករនីមួយៗត្រូវគោរពសិទ្ធិរបស់កម្មសិទ្ធិករដទៃក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួន។ ការប្រើប្រាស់ ចំណែកឯកជននេះ ត្រូវហាមឃាត់ប្រសិនបើការប្រើប្រាស់នោះបង្កការប៉ះពាល់ ឬខូចខាត ដល់ទីកន្លែងនៃសេវារួម ឬកម្មសិទ្ធិឯកជនផ្សេងទៀត។

៣.៣. កម្មសិទ្ធិករត្រូវបង្កលក្ខណៈងាយស្រួលដល់បុគ្គលដែលត្រូវមកធ្វើការថែទាំ ជួសជុល ឬធ្វើសេវាកម្មរួមផ្សេងៗ។ កម្មសិទ្ធិករ មិនអាចទាមទារសំណង ឬតម្លៃតបស្នងណាមួយអំពីការបង្កលក្ខណៈងាយស្រួលក្នុងការជួសជុល ថែទាំសេវាកម្មរួមនេះឡើយ។

៣.៤. ផ្ទៃខាងក្នុងនៃលំនៅឋាន ឬ សំណង់ផ្សេងទៀតក្នុងបុរី ដែលមើលពុំឃើញពីខាងក្រៅ កម្មសិទ្ធិករ អាចរៀបចំ និងជួសជុលបាន តែមិនអាចប៉ះពាល់រចនាសម្ព័ន្ធដើម ឬធ្វើអ្វីបណ្តាលឱ្យប៉ះពាល់ដល់អ្នកជិតខាង ឬធ្វើឱ្យខូចដល់សោភ័ណភាពនៃបុរីឡើយ ។

៣.៥. សមាប់ករណីលំនៅឋាន ឬ សំណង់ផ្សេងទៀត ដែលមានជញ្ជាំងអឌ្ឍសិទ្ធិ កម្រាល ឬ សរសរទ្រទ្រង់រួមជាមួយលំនៅឋាន ឬ សំណង់ដទៃទៀត កម្មសិទ្ធិករមិនត្រូវផ្ទុកទម្ងន់លើសពីការកំណត់ ឬ ធ្វើសកម្មភាពណាដែលបង្កគ្រោះថ្នាក់ ដល់ភាពរឹងមាំនិងសុវត្ថិភាពនៃសំណង់ឡើយ ។

៣.៦. កម្មសិទ្ធិករនីមួយៗមានចំនួនសំឡេងស្របតាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃដីឡូត៍ ដីឡូត៍លំនៅឋាន និង ដីសំណង់ផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ខ្លួន ។

ប្រការ ៤.- សិទ្ធិ ភាតព្វកិច្ច និងការឆន្ទួលខុសត្រូវលើទីកន្លែងនៃសេវារួមនានា

៤.១. ទីកន្លែងនៃសេវារួមនៃបុរីនីមួយៗ អាចមានលក្ខណៈខុសគ្នាតាមស្ថានភាពជាក់ស្តែងនៃបុរីនីមួយៗ ដែល ទីកន្លែងទាំងនោះ អាចមានជាអាទិ៍ ៖

ក) លម្ហសាធារណៈដូចជា សួនច្បារ កន្លែងហាត់ប្រាណ ចំណតរថយន្ត ជាដើម

ខ) ផ្លូវចេញចូលបុរី របងបុរី

គ) បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី និងទូរគមនាគមន៍ ប្រព័ន្ធសុវត្ថិភាព និងការពារអគ្គីភ័យ បណ្តាញឧស្ម័ន ដែលជាប្រភពផ្តត់ផ្តង់កម្មសិទ្ធិករទាំងឡាយនៅក្នុងបុរី ទោះបីជាបណ្តាញនោះរត់កាត់តាមចំណែកឯកជនក៏ដោយ

ឃ) ទីកន្លែងនៃសេវារួមផ្សេងៗទៀត ... ។

៤.២. កម្មសិទ្ធិករទាំងអស់ មានសិទ្ធិប្រើប្រាស់ទីកន្លែងនៃសេវារួម។ ទីកន្លែងនៃសេវារួមនេះ មិនអាចយកមក ប្រើប្រាស់ផ្តាច់មុខដោយបុគ្គលណាមួយឡើយ ។

៤.៣. កម្មសិទ្ធិករនីមួយៗនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត នៅក្នុងបុរី ត្រូវទទួលខុសត្រូវអំពីការប្រើប្រាស់ សិទ្ធិរបស់ខ្លួនលើទីកន្លែងនៃសេវារួម និងមិនត្រូវប្រើប្រាស់ដោយរំលោភបំពាន ឬ ធ្វើសកម្មភាពណា ដែលអាចបង្កឱ្យខូចខាតដល់សេវារួមទាំងនោះឡើយ ។

៤.៤. កម្មសិទ្ធិករទាំងអស់នៃលំនៅឋាន ឬសំណង់ផ្សេងទៀត នៅក្នុងបុរី មានកាតព្វកិច្ចចូលរួមបង់ថ្លៃចំណាយលើការថែទាំ ជួសជុល ឬ ផ្លាស់ប្តូរថ្មី នូវសេវារួមទាំងនោះ តាមសមាមាត្រនៃទំហំផ្ទៃក្រឡានៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬ ដីសំណង់ផ្សេងទៀតដែលតាំងនៅក្នុងបុរី ឬ តាមការព្រមព្រៀងផ្សេងពីនេះ ។

៤.៥. កម្មសិទ្ធិករណាដែលមិនព្រមចូលរួមទទួលបន្ទុកចំណាយខាងលើនេះ ឬមិនគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ប្រការ ៥.- ការចាត់ចែងលើកម្មសិទ្ធិឯកត្តជនន័មួយៗ

៥.១. សិទ្ធិចាត់ចែងលើកម្មសិទ្ធិឯកត្តជន នៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬ ដីសំណង់ផ្សេងទៀតក្នុងបុរី ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៥.២. នៅពេលផ្ទេរសិទ្ធិលើដីឡូត៍ ដីឡូត៍លំនៅឋាន ឬ ដីសំណង់ផ្សេងទៀត តាមរយៈការលក់ ការដូរ ការធ្វើអំណោយ និងការបន្តមរតក នោះសិទ្ធិចាត់ចែងលើដីឡូត៍ ដីឡូត៍លំនៅឋាន ឬ ដីសំណង់ផ្សេងទៀត រួមទាំងកាតព្វកិច្ចទាំងអស់ត្រូវផ្ទេរទៅឱ្យអ្នកទទួលសិទ្ធិបន្ត ឬកម្មសិទ្ធិករថ្មីដែរ។

៥.៣. អ្នកផ្ទេរសិទ្ធិ ឬអ្នកលក់ និង/ឬ អ្នកទទួលសិទ្ធិបន្ត ឬ អ្នកទិញត្រូវស្នើសុំធ្វើចរន្តការ នូវការផ្ទេរសិទ្ធិនេះ នៅរដ្ឋបាលសុរិយោដី។

៥.៤. អ្នកផ្ទេរសិទ្ធិឬអ្នកលក់ និង/ឬ អ្នកទទួលសិទ្ធិបន្ត ឬអ្នកទិញត្រូវទទួលខុសត្រូវលើការចំណាយផ្នែសេវានានា និងការបង់ពន្ធផ្សេងៗជូនរដ្ឋតាមច្បាប់កំណត់។

ប្រការ ៦.- ការគ្រប់គ្រងបុរី

៦.១. កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀតនៃបុរី ត្រូវរៀបចំអង្គការគ្រប់គ្រងបុរី ដោយបង្កើតជាក្រុមប្រឹក្សាភិបាល ឬ គណៈកម្មការគ្រប់គ្រង ដើម្បីទទួលបន្ទុកកិច្ចការផ្សេងៗ ដែលពាក់ព័ន្ធនឹងសេវាកម្មរួមនៅក្នុងបុរី ដែលមានសមាសភាពដូចចែងក្នុងចំណុច ៦.២ និងមានភារកិច្ចចម្បងៗដូចមានរៀបរាប់ក្នុង ចំណុច ៦.៣.។

៦.២. ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ត្រូវជ្រើសរើសពីក្នុងចំណោមកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតនៅក្នុងបុរី តាមរយៈការបោះឆ្នោតក្នុងមហាសន្និបាត។
ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងត្រូវមានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ប្រធាន ០១ រូប
- អនុប្រធាន ០១ រូប
- សមាជិកអចិន្ត្រៃយ៍ ០១ រូប
- លេខាធិការ ០១ រូប និងហេរញ្ញិក ០១ រូប : ជាជំនួយការដល់ក្រុមប្រឹក្សាភិបាល ឬ គណៈកម្មការគ្រប់គ្រង លើការងាររដ្ឋបាល និងហិរញ្ញវត្ថុ។

៦.៣. ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង មានភារកិច្ចចម្បងៗជាអាទិ៍ ៖

- ធ្វើទំនាក់ទំនងជាមួយគ្រប់កម្មសិទ្ធិករ នៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងៗនៅក្នុងបុរី
- ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ច
- ធ្វើទំនាក់ទំនងជាមួយអ្នកផ្តល់ ឬផ្តត់ផ្គង់សេវាកម្មនានា ដើម្បីជួយសម្រួលដល់កម្មសិទ្ធិករ
- រៀបចំការប្រជុំ ឬ មហាសន្និបាត ដើម្បីសម្រេចលើកិច្ចការរួម ឬ ការជ្រើសតាំងក្រុមប្រឹក្សាភិបាល ឬ គណៈកម្មការគ្រប់គ្រងថ្មី

- សម្របសម្រួលរវាងកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត នៅក្នុងបុរី ក្នុងករណីដែលមានការខ្វែងគំនិតគ្នាពាក់ព័ន្ធនឹងការប្រើប្រាស់ទីកន្លែងរួមនានារបស់បុរី។

៦.៤. កម្មសិទ្ធិករទាំងអស់ត្រូវរៀបចំមហាសន្និបាតដើម្បីជ្រើសរើសក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរី និងដើម្បីកំណត់ពីការផ្តល់សិទ្ធិសម្រេចនានា។ សេចក្តីសម្រេចទាំងឡាយត្រូវផ្អែកលើភាគរយនៃកម្មសិទ្ធិករ ដូចមានចែងក្នុងចំណុច ៦.៥ ។

៦.៥. ដើម្បីសម្រេចលើកិច្ចការអ្វីមួយ ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ត្រូវអនុវត្តតាមនីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត ដូចខាងក្រោម ៖

ក- តម្រូវឱ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុលឬការថែទាំសេវារួម សេវាសន្តិសុខ ឬការបង់ថ្លៃសេវាសាធារណៈនានា ដូចមានចែងក្នុងប្រការ ៤ ខាងលើ។

ខ- តម្រូវឱ្យមានសំឡេងគាំទ្រយ៉ាងតិច ៧៥ ភាគរយ នៃកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្ត ពាក់ព័ន្ធនឹងការកែប្រែបង់សរុបរបស់បុរី ការជួសជុលលំនៅឋាន ឬសំណង់ផ្សេងទៀត ដែលខុសពីរចនាសម្ព័ន្ធដើមនៃបង់ស្ថាបត្យកម្ម។ ក្នុងករណីមិនអាចរកការគាំទ្រ ៧៥ ភាគរយបាននោះ ការវាយតម្លៃជាផ្លូវការលើស្ថានភាពអគាររបស់សមត្ថកិច្ចជំនាញត្រូវយកជាមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ។

៦.៦. នៅក្នុងបរិវេណបុរី មិនអនុញ្ញាតឱ្យកម្មសិទ្ធិករណាមួយ ធ្វើសកម្មភាពផ្ទុយនឹងច្បាប់ ឬប្រព្រឹត្តិអំពើណាដែលប៉ះពាល់ដល់សីលធម៌ ឬសណ្តាប់ធ្នាប់សង្គមឡើយ។

ប្រការ ៧.- សមាមាត្រនៃការចំណាយលើការជួសជុល ការថែទាំ និងការចំណាយផ្សេងៗលើសេវាកម្មរួម

៧.១. កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតក្នុងបុរី ត្រូវទទួលខុសត្រូវក្នុងការជួសជុល ថែទាំ និង /ឬបន្ទុកផ្សេងៗទៀតលើចំណែកឯកជនរបស់ខ្លួន។ ការជួសជុល មិនអាចឱ្យខុសពីរចនាសម្ព័ន្ធដើមនៃបង់សរុបរបស់បុរី និងបង់ស្ថាបត្យកម្មឡើយ។

៧.២. កម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន ឬ ដីសំណង់ផ្សេងទៀតក្នុងបុរី ត្រូវទទួលខុសត្រូវរួមគ្នាក្នុងការជួសជុល ថែទាំ និង/ឬបន្ទុកផ្សេងៗទៀតលើសេវាកម្មរួមនានា។ ការចំណាយទាក់ទងនឹងការប្រើប្រាស់ ការជួសជុល ការថែទាំ និង/ឬបន្ទុកផ្សេងៗទៀតលើសេវាកម្មរួមនេះ ត្រូវគិតជា ភាគរយទៅតាមសមាមាត្រ នៃទំហំផ្ទៃក្រឡាកម្មសិទ្ធិឯកជនរបស់កម្មសិទ្ធិករនីមួយៗ។

៧.៣. ការចំណាយដែលជាបន្ទុករបស់សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ដែលមាននៅក្នុងបុរី ត្រូវឱ្យក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិនោះទទួលខុសត្រូវ ក្នុងការសម្របសម្រួលរវាងសហកម្មសិទ្ធិករ។

ប្រការ ៨.- វិវាទលើការប្រើប្រាស់ដី និង/ឬសេវារួម

វិវាទទាំងឡាយដែលកើតឡើងរវាងកម្មសិទ្ធិករនៃដីឡូត៍ ដីឡូត៍លំនៅឋាន និងដីសំណង់ផ្សេងទៀត នៅក្នុងបរិវេណនៃបុរី ពាក់ព័ន្ធនឹងការប្រើប្រាស់សេវារួម ឬការប្រើប្រាស់ដីក្នុងបុរី ត្រូវដោះស្រាយជាជំហានដំបូង ដោយការសម្រុះសម្រួលក្នុងក្របខណ្ឌនៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរី ដោយផ្អែកលើមូលដ្ឋាននៃបទប្បញ្ញត្តិរបស់បុរី និងបទប្បញ្ញត្តិស្ថាបត្យកម្ម ដែលសម្រេចជាផ្លូវការសម្រាប់ការសាងសង់បុរី។ ក្នុងករណីដែលមិនអាចដោះស្រាយបាន វិវាទនេះនឹងត្រូវដោះស្រាយដោយតុលាការ។

ប្រការ ៩.-ប្រសិទ្ធភាពអនុវត្ត

បទបញ្ជាផ្ទៃក្នុងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃដែលអ្នកទទួលសិទ្ធិក្លាយជាកម្មសិទ្ធិករពេញលក្ខណៈ ច្បាប់លើដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀតនៃបុរី។

ថ្ងៃទី ..... ខែ..... ឆ្នាំ .....

អ្នកផ្ទេរសិទ្ធិ **អ្នកទទួលសិទ្ធិ**

ឈ្មោះ ..... ឈ្មោះ.....

ថ្ងៃទី ..... ខែ..... ឆ្នាំ .....

ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងបុរី

ប្រធាន

(ហត្ថលេខា និងត្រា)

.....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការបង្កើតមន្ទីរពិសោធន៍
គណៈវិស្វកររកម្ពុជា

ឆ្នាំ ២០១៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៦៣.អន.ក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើតនិងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ ៖

ត្រូវបានបង្កើតនិងដាក់ឲ្យដំណើរការមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ដែលសរសេរជាអក្សរឡាតាំងថា [illegible] ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈវិស្វករកម្ពុជា ដោយមានអគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជា សម្របសម្រួលក្នុងដំណើរប្រព្រឹត្តទៅរបស់ **ម.ព.ខ.ក.** នេះ។

មាត្រា២ .-

ម.គ.ខ.ក. ត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ផ្តល់ឲ្យគណៈវិស្វករកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ត្រួតពិនិត្យ វិភាគ តាមដាន និងធ្វើកោសលវិច័យ លើការប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា
- សហការបណ្តុះបណ្តាលបំប៉នវិជ្ជាជីវៈវិស្វកម្មជាក់ស្តែងដល់វិស្វករចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈវិស្វកម្មគ្រប់មុខជំនាញទាំងទ្រឹស្តីទាំងបទពិសោធ ឲ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមស្តង់ដាកំណត់ ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារពលកម្មក្នុងស្រុក តំបន់ និងអន្តរជាតិ
- បង្កលក្ខណៈងាយស្រួលដល់គណៈវិស្វករកម្ពុជា ដើម្បីធ្វើការសិក្សា វិភាគ វាយតម្លៃគុណភាពសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- តាមដានការងារអនុវត្តរបស់វិស្វករអោយជីពដើម្បីធ្វើការណែនាំផ្ទៃកបច្ចេកទេសក្នុងការងារវិស្វកម្ម ដើម្បីធានានូវក្រមសីលធម៌វិជ្ជាជីវៈ គុណភាព សោភណភាព និងការសន្សំសំចៃ
- សហការជាមួយដៃគូអភិវឌ្ឍឬក្រុមហ៊ុនឯកជននានា ដើម្បីឲ្យ **ម.គ.ខ.ក.** មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវានិងអភិវឌ្ឍខ្លួន។

ជំពូកទី២
តួនាទីនិងភារកិច្ច

មាត្រា៣ .-

ម.គ.ខ.ក. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសថ្មីៗតាមសម័យនិយម លើមុខជំនាញវិស្វកម្ម ព្រមទាំងចូលរួមសហការកសាងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធវិជ្ជាជីវៈវិស្វកម្ម ដើម្បីធ្វើការផ្សព្វផ្សាយដល់វិស្វករសម្រាប់អនុវត្តទូទាំងប្រទេស
- កំណត់ពីស្តង់ដានៃគុណភាពប្រភេទសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- សហការជាមួយមន្ទីរពិសោធន៍ដែលមានស្រាប់ នៅតាមក្រសួង មន្ទីរ សហគ្រាស គ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីទទួលបាននូវស្តង់ដាបទដ្ឋានបច្ចេកទេសជាតិមួយសម្រាប់ផ្សព្វផ្សាយនិងអនុវត្ត
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេស កោសលវិច័យ ពិនិត្យកំហុសឆ្គងក្នុងវិស័យវិស្វកម្មដល់វិស្វករចុះបញ្ជី
- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជនដើម្បីឲ្យ **ម.គ.ខ.ក.** មានសមត្ថភាពពេញលក្ខណសម្បត្តិក្នុងការផ្តល់សេវា និងបណ្តុះបណ្តាល បង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្មដល់វិស្វករចុះបញ្ជី
- ទទួលកម្មសិក្សាការីអ្នកបច្ចេកទេស សម្រាប់បណ្តុះបណ្តាលឲ្យមានវិជ្ជាជីវៈជំនាញពិតប្រាកដ
- រៀបចំសារណាបច្ចេកទេស ដោយផ្អែកលើនិន្នន័យដែលទទួលបាន ក្នុងពេលបំពេញបេសកកម្ម និងតួនាទីភារកិច្ចរបស់ខ្លួន។

មាត្រា៤ .-

សិទ្ធិនិងការទទួលខុសត្រូវរបស់ប្រធាន **ម.គ.ខ.ក.** ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងលក្ខខណ្ឌ តួនាទីការកិច្ច និងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវា។

លក្ខខណ្ឌតួនាទីការកិច្ច និងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវាគំរូជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ជំពូកទី៣
ការគ្រប់គ្រងបុគ្គលិក

មាត្រា៥ .-

ម.គ.ខ.ក. ត្រូវបានដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូបដែលមានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលមានឋានៈស្មើអគ្គនាយករង។

ប្រធាន **ម.គ.ខ.ក.** ត្រូវទទួលខុសត្រូវក្នុងការរៀបចំដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

ប្រធាន **ម.គ.ខ.ក.** ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនិងដំណើរការការងារជូនប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា។

បុគ្គលិកបម្រើការងារនៅ **ម.គ.ខ.ក.** ជាមន្ត្រីមុខងារសាធារណៈឬមន្ត្រីជាប់កិច្ចសន្យារបស់គណៈវិស្វករកម្ពុជា។

មាត្រា៦ .-

ម.គ.ខ.ក. ត្រូវបានអនុញ្ញាតឱ្យប្រើគ្រាដោយឡែក។

ជំពូកទី៤
រចនាសម្ព័ន្ធ

មាត្រា៧ .-

ម.គ.ខ.ក. មានបីផ្នែក តាមរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកបច្ចេកទេស
- ផ្នែកសហប្រតិបត្តិការនិងផ្តល់សេវា។

ផ្នែកនីមួយៗត្រូវដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។ ការកំណត់តួនាទីការកិច្ចនិងការងារទទួលខុសត្រូវរបស់ប្រធានផ្នែកនីមួយៗ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **ម.គ.ខ.ក.**។

មាត្រា៨ .-

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងការកិច្ចដូចតទៅ៖

- ចាត់ចែង ចរាចរណ៍និងគ្រប់គ្រងឯកសាររដ្ឋបាល
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារ

- គ្រប់គ្រងបុគ្គលិក រៀបចំការងារបៀវត្សរ៍ពលកម្ម ប្រាក់កម្រៃ របបឧបត្ថម្ភ ឬប្រាក់លើកទឹកចិត្ត ដល់បុគ្គលិកក្របខ័ណ្ឌមុខងារសាធារណៈនិងបុគ្គលិកជាប់កិច្ចសន្យា
- រៀបចំ តាក់តែងលិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាលនានា និងធ្វើកំណត់ហេតុប្រជុំ
- ធ្វើរបាយការណ៍ការងារនិងកំណត់ហេតុផ្សេងៗរបស់ថ្នាក់ដឹកនាំ
- ធ្វើរបាយការណ៍សរុបលទ្ធផលនិងសកម្មភាពការងាររបស់ **ម.គ.ខ.ក.** ជាប្រចាំ និងធ្វើរបាយការណ៍បូកសរុបការងារប្រចាំខែ ឆមាស និងប្រចាំឆ្នាំ
- ប្រមូលទិន្នន័យស្តីពីសកម្មភាពការងារ និងលើកគម្រោងថវិកាសម្រាប់ដំណើរការ **ម.គ.ខ.ក.**
- ផ្គត់ផ្គង់និងគ្រប់គ្រងមូលដ្ឋានសម្ភារៈបរិក្ខារ **ម.គ.ខ.ក.**
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិ សម្ភារៈ និងបញ្ជីសារពើភណ្ឌ។

មាត្រា៩ .-

ផ្នែកបច្ចេកទេស មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូល ពិនិត្យ វិភាគ និងចងក្រងទិន្នន័យលទ្ធផលការងាររបស់ **ម.គ.ខ.ក.** កំណត់ស្តង់ដាបទដ្ឋានបច្ចេកទេសមួយ ដើម្បីធ្វើការផ្សព្វផ្សាយនិងអនុវត្តទូទាំងប្រទេស
- វិភាគនិងកំណត់ស្តង់ដាគុណភាពនៃប្រភេទ សម្ភារៈបរិក្ខារ សម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- ផ្តល់យោបល់បច្ចេកទេសលើការអនុវត្តគម្រោងវិស្វកម្មក្នុងករណីមានភាពមិនប្រក្រតី
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេសដល់វិស្វករអាជីព ជៀសវាងនូវកំហុសឆ្គងក្នុងការអនុវត្តការងារវិស្វកម្ម
- ប្រមូលផ្តុំនិងចងក្រងនូវទិន្នន័យដែលទទួលបាន ក្នុងពេលបំពេញតួនាទីភារកិច្ចរបស់ខ្លួន
- លើកគម្រោងនៃតម្រូវការនិងការថែទាំសម្ភារៈបរិក្ខារបច្ចេកទេសរបស់ **ម.គ.ខ.ក.**។

មាត្រា១០ .-

ផ្នែកសហប្រតិបត្តិការនិងផ្តល់សេវាមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជននានាក្នុងការអភិវឌ្ឍ និងផ្តល់សេវារបស់ **ម.គ.ខ.ក.**
- សហការជាមួយផ្នែកអប់រំនិងបណ្តុះបណ្តាលនៃអគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា និងដៃគូអភិវឌ្ឍ រៀបចំផែនការសម្រាប់បណ្តុះបណ្តាល បង្ហាត់បង្រៀនបច្ចេកទេស បង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្មដល់វិស្វករចុះបញ្ជី។

ជំពូកទី៥
ប្រភពធនធាន

មាត្រា១១ .-

ប្រភពធនធានថវិការបស់ **ម.គ.ខ.ក.**៖

- ថវិកាជាតិដែលជាឧបសម្ព័ន្ធនៃថវិការបស់គណៈវិស្វករកម្ពុជា
- ថវិកាដែលបានមកពីការបែងចែកកម្រៃសេវា
- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងពីប្រភពផ្សេងៗទៀត

មាត្រា១២ .-

ការកំណត់ថ្លៃសេវានិងការបែងចែកកម្រៃសេវាជាមួយដៃគូអភិវឌ្ឍឬក្រុមហ៊ុនឯកជននានា ត្រូវធ្វើឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា អគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមហាគ្តលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា

សុខ អាន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រង និង ប្រើប្រាស់អគារសហកម្មសិទ្ធិ

ឆ្នាំ ២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា១៦និងមាត្រា១៧ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៩ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រាមួយ .-

មាត្រា១៦និងមាត្រា១៧នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ ត្រូវបានកែសម្រួលដូចតទៅ៖

មាត្រា១៦ .-ថ្មី

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចធ្វើការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិជូនសហកម្មសិទ្ធិករទាំងអស់តាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ។

មានតែអគារសហកម្មសិទ្ធិដែលបានសាងសង់នូវគ្រឿងផ្គុំសំណង់អគារទាំងមូល១០០%និងបានរៀបចំខណ្ឌជញ្ជាំងចំណែកឯកជនរួចរាល់តាមប្លង់អនុញ្ញាត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះ ទើបអាចជាកម្មវត្ថុនៃការចុះបញ្ជីចំណែកឯកជនបាន។

មាត្រា១៧ .-ថ្មី

ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវដំណើរការដូចតទៅ៖

១- សហកម្មសិទ្ធិករចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវស្នើសុំចុះបញ្ជីចំណែកឯកជនរបស់ខ្លួននៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

សហកម្មសិទ្ធិករត្រូវបំពេញពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដោយបញ្ជាក់ច្បាស់អំពីអត្តសញ្ញាណនិងព័ត៌មានទាំងឡាយនៃចំណែកឯកជនរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងត្រូវភ្ជាប់មកជាមួយនូវ៖

- លិខិតអនុញ្ញាតសាងសង់
- វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់ ឬលិខិតបញ្ជាក់ការសាងសង់សម្រេចបានដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា១៦ថ្មីខាងលើនេះ
- ឯកសារប្លង់ស្តាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិដោយបញ្ជាក់ពីចំនួនជាន់ ចំនួនចំណែកឯកជនដោយមានលេខយោងនិងព័ត៌មានអំពីចំណែករួមនៃអគារ
- បទបញ្ជាផ្ទៃក្នុង
- ឯកសារបញ្ជាក់អត្តសញ្ញាណសហកម្មសិទ្ធិករ
- ឯកសារពាក់ព័ន្ធផ្សេងទៀតប្រសិនបើមាន។

២- ពាក្យស្នើសុំត្រូវយកទៅដាក់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារសហកម្មសិទ្ធិនោះស្ថិតនៅ។ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ។

៣- ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យទម្រង់និងឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ហើយបញ្ជូន

ពាក្យស្នើសុំចុះបញ្ជីនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេល៣(បី)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ ដើម្បីពិនិត្យនិងសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជី។

៥- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យសម្រេច ក្នុងរយៈពេល៣(បី)ថ្ងៃនៃថ្ងៃធ្វើការលើពាក្យស្នើសុំចុះបញ្ជីនេះ។

៥- ក្រោយពីមន្ទីរសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការជូនដំណឹងរយៈពេល១(មួយ)សប្តាហ៍មុនកាលបរិច្ឆេទនៃការចុះប្រមូលទិន្នន័យ។

៦- មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល១(មួយ)សប្តាហ៍យ៉ាងយូរត្រូវចុះសហការជាមួយមន្ត្រីឃុំ សង្កាត់ អ្នកអភិវឌ្ឍ អចលនវត្ថុឬតំណាងនិងសហកម្មសិទ្ធិករដើម្បីប្រមូលនិងផ្ទៀងផ្ទាត់ទិន្នន័យនៅទីតាំងជាក់ស្តែងដើម្បី បំពេញទម្រង់បែបបទប្រមូលទិន្នន័យ។

៧- ក្រោយប្រមូលទិន្នន័យជាក់ស្តែងអំពីចំណែកឯកជននៃអគារសហកម្មសិទ្ធិរួច មន្ត្រីជំនាញ នៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំ ឯកសារទាំងអស់និងលើកយោបល់ក្នុងរយៈពេល១(មួយ)សប្តាហ៍ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេចឱ្យបិទផ្សាយទិន្នន័យជាសាធារណៈ។

ប្រសិនបើមានភាពមិនច្បាស់លាស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត អាចស្វែងរកព័ត៌មានបន្ថែមឬចាត់តាំងមន្ត្រីជំនាញដើម្បីចុះស៊ើបអង្កេតឬបញ្ជាក់បន្ថែម ក្នុងរយៈពេល១(មួយ)សប្តាហ៍យ៉ាងយូរ។

៨- ក្រោយពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត បាន សម្រេចឱ្យបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបានរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌត្រូវបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការ ប្រមូលទិន្នន័យរយៈពេល១(មួយ)សប្តាហ៍ដើម្បីឱ្យសហកម្មសិទ្ធិករទាំងអស់និងអ្នកមានផលប្រយោជន៍ អាចតវ៉ាឬស្នើឱ្យធ្វើការកែតម្រូវ។ ការបិទផ្សាយជាសាធារណៈត្រូវអនុវត្តនៅទីតាំងអចលនវត្ថុផ្ទាល់ និងនៅសាលាឃុំ សង្កាត់ ដែលអចលនវត្ថុនោះស្ថិតនៅ។

ក្នុងករណីមានការតវ៉ាឬវិវាទ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវព្យាយាមសម្រុះសម្រួលស្វែងរកការឯកភាពគ្នា។

ក្នុងករណីមិនអាចរកការស្រុះស្រួលគ្នាបាន ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនករណីវិវាទនេះទៅតុលាការដើម្បីដោះស្រាយតាមនីតិវិធីច្បាប់ជាធរមាន។

៩- ផុតរយៈពេលនៃការបិទផ្សាយប្រសិនបើគ្មានបណ្តឹងតវ៉ា ឬប្រសិនបើរាល់វិវាទត្រូវបាន ដោះស្រាយរួចរាល់ហើយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវ

ធ្វើការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិតាមការស្នើសុំរបស់សហកម្មសិទ្ធិករក្នុងរយៈពេល១ (មួយ)សប្តាហ៍យ៉ាងយូរ។

មាត្រាពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបី .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ឧត្តរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

ឆ្នាំ ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះមានគោលបំណងធានា៖

- គុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌នៃនគរូបនីយកម្ម
- ការការពារសិទ្ធិនិងផលប្រយោជន៍សាធារណៈនិងឯកជន ក្នុងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- ការលើកកម្ពស់តម្លៃវប្បធម៌ ការអភិវឌ្ឍបៃតង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ព្រមទាំងបង្កើនការបង្ការនិងការទប់ស្កាត់គ្រោះមហន្តរាយ
- ការយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួល សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរា និងកុមារ។

មាត្រា២ .-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន នៅព្រះរាជាណាចក្រកម្ពុជា ឲ្យមាន៖

- មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្តល់ការងារ ការសិក្សា កន្លែងលំហែកម្សាន្ត និងការធ្វើចរាចរណ៍ប្រកបដោយសុខភាព សោភណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពងាយស្រួល
- ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កិច្ចការពារបរិស្ថាន ការពារជាតិ សន្តិសុខស្បៀង និងការថែរក្សា សម្បត្តិវប្បធម៌
- ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈរាជធានី ក្រុង និងទីប្រជុំជន
- តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងទីក្រុងនិងជនបទ ដោយផ្អែកលើលក្ខណៈភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ការតម្រង់ទិសច្បាស់លាស់ដែលអាចដឹងមុនបាននូវការអភិវឌ្ឍនៅរាជធានី ក្រុង និងទីប្រជុំជន

មាត្រា៣ .-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ ព្រមទាំងដីរបស់បុគ្គលឯកជនក្នុងរាជធានី ក្រុង និងទីប្រជុំជន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់អភិរក្សពិសេសដែលមានចែងដោយបទប្បញ្ញត្តិដោយឡែក។

មាត្រា៤ .-

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានពន្យល់ក្នុងសទ្ទានុក្រមភ្ជាប់ជាឧសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ជំពូកទី២
គោលការណ៍

មាត្រា៥ .-

កិច្ចការនគរូបនីយកម្មត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តទីក្រុងជាមូលដ្ឋានបង្អែក សម្រាប់ការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឲ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាព និងមានសមធម៌។

ជំពូកទី៣
យន្តការ សមត្ថកិច្ច និងតារកិច្ច

មាត្រា៦ .-

យន្តការសម្រាប់ធ្វើផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានដូចតទៅ៖

១- នៅថ្នាក់ជាតិ មានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដែលត្រូវផ្តួចផ្តើមរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិនិងនៅតាមតំបន់។

២- នៅថ្នាក់ក្រោមជាតិ រួមមាន៖

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ដែលត្រូវផ្តួចផ្តើមរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ស្រុក ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខណ្ឌ ដែលត្រូវផ្តួចផ្តើមរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវផ្តួចផ្តើមរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់។

យន្តការនៅថ្នាក់ក្រោមជាតិដែលបានរៀបរាប់ខាងលើត្រូវធ្វើការសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការរៀបចំផែនការរូបវន្តទីក្រុង។

មាត្រា៧ .-

យន្តការ សមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិបានកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិនិងព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា៨ .-

យន្តការ សមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ដោយអនុក្រឹត្យលេខ**៧៧**អនក្រ.បក ចុះថ្ងៃទី**០៧** ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា៩ .-

យន្តការ សមត្ថកិច្ច ភារកិច្ច និងនីតិវិធី សម្រាប់រៀបចំផែនការប្រើប្រាស់ដី ឃុំ សង្កាត់ បានកំណត់ដោយអនុក្រឹត្យលេខ**៧២** អនក្រ.បក ចុះថ្ងៃទី**០៥** ខែឧសភា ឆ្នាំ**២០០៩** ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

ជំពូកទី៤
ផែនការរូបវន្តនិងនីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង
ផ្នែកទី១
ផែនការរូបវន្តទីក្រុង

មាត្រា១០ .-

ផែនការរូបវន្តទីក្រុងរួមមាន៖

១- ប្លង់គោលប្រើប្រាស់ដី

២- ផែនការប្រើប្រាស់ដី

៣- ប្លង់លម្អិតនគរូបនីយកម្ម។

មាត្រា១១ .-

ប្លង់គោលប្រើប្រាស់ដីត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : ត្រូវប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គមកិច្ច ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ។

២- ការកំណត់ចក្ខុវិស័យ : ត្រូវសិក្សានិងកំណត់ចក្ខុវិស័យអភិវឌ្ឍនិងអភិរក្ស សម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំចំពោះថ្នាក់ក្រុង ស្រុក ខណ្ឌ និងយ៉ាងតិច២០(ម្ភៃ)ឆ្នាំចំពោះថ្នាក់រាជធានី។

៣- ការកំណត់យុទ្ធសាស្ត្រ: ត្រូវសិក្សានិងកំណត់យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្ស ដើម្បីសម្រេចបាននូវចក្ខុវិស័យមាន៖

- យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សទីក្រុង
- យុទ្ធសាស្ត្រប្រើប្រាស់ដី
- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច
- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច
- យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងកាកសំណល់
- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ។

៤- គំនូសប្លង់សម្រាប់ប្លង់គោលប្រើប្រាស់ដីមានដូចជា៖

៤.១- ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

- ប្លង់បង្ហាញទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់និន្នាការនៃការពង្រីកនៃទីក្រុង
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ។

៤.២- ប្លង់អនាគតកាល ស្របតាមចក្ខុវិស័យ មានដូចជា៖

- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកប្រភេទប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់គម្រោងពង្រីកទីក្រុង
- ប្លង់គ្រប់គ្រងកាកសំណល់រឹង
- ប្លង់គ្រប់គ្រងកាកសំណល់រាវ។

៥- សេចក្តីណែនាំអនុវត្តនិងគ្រប់គ្រងការអភិវឌ្ឍ : ត្រូវរៀបចំបញ្ជីគម្រោងនិងផែនការសកម្មភាពតាមលំដាប់អាទិភាព សម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងសេចក្តីណែនាំសម្រាប់ការអនុវត្តនិងការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់។

៦- ឯកសារឧបសម្ព័ន្ធ។

៧- ឯកសារទាំងអស់ ត្រូវចងក្រងជារបាយការណ៍បច្ចេកទេស។

ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុង ស្ថិតក្នុងលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

ប្លង់គោលប្រើប្រាស់ដីរាជធានី ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយអនុក្រឹត្យ។

ប្លង់គោលប្រើប្រាស់ដីក្រុងនិងទីប្រជុំជន ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា១២ .-

ផែនការប្រើប្រាស់ដីត្រូវមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : មានជាអាទិ៍ទិន្នន័យរូបវន្ត នគរូបនីយកម្ម ការប្រើប្រាស់ដី សំណង់ លំនៅឋាន សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ធនធានធម្មជាតិ ផែនទី និងរូបភាព។

២- ការកំណត់យុទ្ធសាស្ត្រ : ត្រូវកំណត់យុទ្ធសាស្ត្រឲ្យស្របតាមប្លង់គោល។

៣- គំនូសប្លង់ក្នុងផែនការប្រើប្រាស់ដីមានដូចជា៖

៣.១- ប្លង់សម្រង់ទិន្នន័យស្ថានភាពបច្ចុប្បន្ន

- ប្លង់បង្ហាញទីតាំង
- ប្លង់បង្ហាញព្រំប្រទល់សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីឬផែនការប្រើប្រាស់ដី
- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់កំណត់ប្រភេទប្រើប្រាស់ដី
- ប្លង់កំណត់តំបន់ប្រើប្រាស់ដី
- ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ធ្លាគម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់។

៣.២- ប្លង់អនាគតកាលមានដូចជា៖

- ប្លង់ដង់ស៊ីតេប្រជាជន
- ប្លង់បែងចែកតំបន់ប្រើប្រាស់ដី
- ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈ
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់បង្ហាញពីទិសដៅប្រើប្រាស់ដី
- ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ធ្លាគម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់។

៤- បទបញ្ជាប្រើប្រាស់ដី ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់គ្រប់ប្រភេទ។

៥- ឯកសារនិងឧបសម្ព័ន្ធ។

ផែនការប្រើប្រាស់ដីរាជធានី ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយអនុក្រឹត្យ។

ផែនការប្រើប្រាស់ដីក្រុង ត្រូវដាក់ឲ្យប្រើជាផ្លូវការដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា១៣ .-

ប្លង់លម្អិតនគរូបនីយកម្មមានទំហំការងារអប្បបរមាដូចខាងក្រោម៖

១- ការប្រមូលនិងវិភាគទិន្នន័យ : ផ្អែកតាមទិន្នន័យប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

២- គំនូសប្លង់លម្អិតនគរូបនីយកម្មមានដូចជា៖

- ប្លង់បង្ហាញពីទីតាំង
- ប្លង់សរុប ដោយមានកំណត់ព្រំប្រទល់
- ប្លង់លម្អិតការប្រើប្រាស់ដី
- ប្លង់បណ្តាញផ្លូវថ្នល់
- ប្លង់លំហសាធារណៈនិងផ្ទៃបៃតង
- ប្លង់សន្ទស្សន៍ប្រើប្រាស់ដី
- ប្លង់ឆ្នាគម្លាតសំណង់និងប្លង់តម្រង់ជួរ
- ប្លង់កំណត់កម្ពស់សំណង់
- ប្លង់គំហើញសំណង់និងរចនាសម្ព័ន្ធ
- ប្លង់នេត្រាទស្សន៍ឬគំរូសំណាក។

ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

ផ្នែកទី២
នីតិវិធីនៃការធ្វើផែនការរួចវន្តទីក្រុង

មាត្រា១៤ .-

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៦០(ហុកសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ និងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាបសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីរាជរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃ

ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេល ស្របតាមទំហំការងារជាក់ស្តែងដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា១៥ .-

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុងនិងប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ព្រមទាំងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាពនិងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា១៦ .-

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ព្រមទាំងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យ និងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយ

រយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះអាចត្រូវបានបន្តែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្តែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន ត្រូវសម្រេចដាក់ឲ្យប្រើប្រាស់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា១៧ .-

ការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តរបស់ទីក្រុង ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី សម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈដូចដំណើរការធ្វើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីនៅទីក្រុងដែរ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅទីក្រុងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។
ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីដែលបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីដែរ។

ក្នុងករណីដែលទីប្រជុំជនមានទីតាំងស្ថិតនៅលើតំបន់ប្រសព្វរវាងរដ្ឋបាលថ្នាក់ក្រោមជាតិពីរឬច្រើន រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះត្រូវសហការគ្នារៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅតំបន់នោះ។

មាត្រា១៨ .-

សេចក្តីណែនាំបច្ចេកទេសនិងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុងនិងប្លង់លម្អិតនគរូបនីយកម្ម ព្រមទាំងវិធីដោះស្រាយការតវ៉ាផ្សេងៗ ត្រូវកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ជំពូកទី៥
បទប្បញ្ញត្តិនៃការប្រើប្រាស់ដី

មាត្រា១៩ .-

ប្រព័ន្ធផែនការប្រើប្រាស់ដីនៅទីក្រុងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា២ប្រភេទ រួមមាន៖

១- ប្រភេទដីអាចសាងសង់បាន

២- ប្រភេទដីកម្រិតការសាងសង់។

ផ្នែកទី១
អំពីប្រភេទដីអាចសាងសង់បាន

មាត្រា២០ .-

ប្រភេទដីអាចសាងសង់បាន ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់លំនៅឋាន រួមមាន៥(ប្រាំ)ប្រភេទ៖
- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប(ផ្ទះ: ភូមិគ្រឹះ: ឬពាក់កណ្តាលភូមិគ្រឹះ:)
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប(ផ្ទះ:ល្វែងឬផ្ទះ:ជាប់គ្នា)
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យម
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់
- តំបន់លំនៅឋានចម្រុះ។

២- តំបន់ពាណិជ្ជកម្ម រួមមាន២(ពីរ)ប្រភេទ៖
- តំបន់ពាណិជ្ជកម្ម
- តំបន់ពាណិជ្ជកម្មចម្រុះ។

៣- តំបន់ឧស្សាហកម្ម រួមមាន៣(បី)ប្រភេទ៖
- តំបន់ឧស្សាហកម្ម
- តំបន់ឧស្សាហកម្មស្រាល
- តំបន់ឧស្សាហកម្មចម្រុះ។

៤- តំបន់ចម្រុះ

៥- តំបន់ដឹកជញ្ជូន

៦- តំបន់ទេសចរណ៍

៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ

៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង

៩- តំបន់វប្បធម៌និងសាសនា

១០- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ការបែងចែកតំបន់ក្នុងប្រភេទដីអាចសាងសង់បាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២១ .-

ជលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយសម្រាប់ប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

១- តំបន់លំនៅឋាន៖
- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប មិនឲ្យលើសពី៧៥%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋាន ដែលមានកម្ពស់មធ្យម មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋាន ដែលមានកម្ពស់ខ្ពស់ មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋានចម្រុះ មិនឲ្យលើសពី៦៥%នៃផ្ទៃដីឡូត៍

២- តំបន់ពាណិជ្ជកម្ម៖	
- តំបន់ពាណិជ្ជកម្ម	មិនឲ្យលើសពី៧៥%នៃផ្ទៃដីឡូត៍
- តំបន់ពាណិជ្ជកម្មចម្រុះ	មិនឲ្យលើសពី៧០%នៃផ្ទៃដីឡូត៍។
៣- តំបន់ឧស្សាហកម្ម៖	
- តំបន់ឧស្សាហកម្ម	មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់ឧស្សាហកម្មស្រាល	មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់ឧស្សាហកម្មចម្រុះ	មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។
៤- តំបន់ចម្រុះ	មិនឲ្យលើសពី៧០%នៃផ្ទៃដីឡូត៍។
៥- តំបន់ដឹកជញ្ជូន	មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។
៦- តំបន់ទេសចរណ៍	មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។
៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ	មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។
៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង	មិនឲ្យលើសពី១០%នៃផ្ទៃដីឡូត៍។
៩- តំបន់វប្បធម៌និងសាសនា	មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។
១០- តំបន់ផ្សេងៗមួយចំនួនទៀត	មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ខាងលើនេះ មិនយកមកអនុវត្តនៅតំបន់ណាដែលមានការប្រើប្រាស់ដីអនុម័តជាផ្លូវការរួចហើយមុនអនុក្រឹត្យនេះចូលជាធរមាន។ ក្នុងស្ថានភាពនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តតាមផែនការប្រើប្រាស់ដីនោះ។

ចំពោះករណីសំណង់ថ្មី សាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ ត្រូវរៀបចំឲ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០(សាមសិប)ភាគរយនៃផ្ទៃដីដែលនៅសល់ពីការសាងសង់នេះ។

បន្ថែមលើសួនច្បារជ្រាបទឹក គ្រប់ដីឡូត៍ស្នើសុំការសាងសង់ ត្រូវកំណត់ឲ្យដាំដើមឈើស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីបង្កើនផ្ទៃក្រឡាបៃតងក្នុងទីក្រុង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល។

ផ្ទៃក្រឡាដីឡូត៍១៥០(មួយរយហាសិប)ម៉ែត្រក្រឡា ត្រូវដាំដើមឈើឲ្យបានយ៉ាងតិច១(មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនដើមឈើត្រូវកំណត់យកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ការកំណត់និងការគណនាផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍និងបទដ្ឋានលម្អិតនៃការរៀបចំផ្ទៃបៃតង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍នៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើម រៀបចំដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនិងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា២២ .-

សន្ធស្សន៍ប្រើប្រាស់ដីត្រូវកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការនិងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ធស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

សន្ធស្សន៍ប្រើប្រាស់ដីអតិបរមានៅក្នុងប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវកំណត់ដូចខាងក្រោម៖

១- តំបន់លំនៅឋាន :	
- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប	មិនឲ្យលើសពី១,៥
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប	មិនឲ្យលើសពី១,៥
- តំបន់លំនៅឋាន ដែលមានកម្ពស់មធ្យម	មិនឲ្យលើសពី៣,០
- តំបន់លំនៅឋាន ដែលមានកម្ពស់ខ្ពស់	មិនឲ្យលើសពី៥,០
- តំបន់លំនៅឋានចម្រុះ	មិនឲ្យលើសពី៥,០។
២- តំបន់ពាណិជ្ជកម្ម :	
- តំបន់ពាណិជ្ជកម្ម	មិនឲ្យលើសពី១២
- តំបន់ពាណិជ្ជកម្មចម្រុះ	មិនឲ្យលើសពី១០។
៣- តំបន់ឧស្សាហកម្ម :	
- តំបន់ឧស្សាហកម្ម	មិនឲ្យលើសពី៣,០
- តំបន់ឧស្សាហកម្មស្រាល	មិនឲ្យលើសពី៣,០
- តំបន់ឧស្សាហកម្មចម្រុះ	មិនឲ្យលើសពី៣,០។
៤- តំបន់ចម្រុះ	មិនឲ្យលើសពី១០។
៥- តំបន់ដឹកជញ្ជូន	មិនឲ្យលើសពី៣,០។
៦- តំបន់ទេសចរណ៍	មិនឲ្យលើសពី៥,០។
៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ	មិនឲ្យលើសពី៥,០។
៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង	មិនឲ្យលើសពី០,៣។
៩- តំបន់វប្បធម៌និងសាសនា	មិនឲ្យលើសពី២,០។
១០- តំបន់ផ្សេងៗ មួយចំនួនទៀត	មិនឲ្យលើសពី៥,០។

ការកំណត់សន្ធស្សន៍ប្រើប្រាស់ដីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៣ .-

ដើម្បីធានាការរៀបចំផែនការរូបវន្តទីក្រុង ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ការពង្រីកទីក្រុង និងការប្រើប្រាស់ដីក្នុងទីក្រុងប្រកបដោយប្រសិទ្ធភាព ដង់ស៊ីតេប្រជាជនអតិបរមាសម្រាប់ការពង្រីកប្រភេទដីអាចសាងសង់បានត្រូវកំណត់យ៉ាងតិច១២០(មួយរយម្ភៃ)នាក់ក្នុងមួយហិកតា។

ផ្នែកទី២
ប្រភេទដីកម្រិតការសាងសង់

មាត្រា២៤ .-

ប្រភេទដីកម្រិតការសាងសង់ ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់កសិកម្ម

២- តំបន់ព្រៃឈើ

៣- តំបន់ធនធានទឹក

៤- តំបន់ការពារ។

៥- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

គម្រោងអភិវឌ្ឍនិងការសាងសង់នៅក្នុងតំបន់នេះត្រូវគោរពតាមនីតិវិធីនិងក្របខណ្ឌគតិយុត្តជាធរមាននិងតម្រូវឲ្យមានលិខិតអនុញ្ញាតប្តូរប្រភេទនៃការប្រើប្រាស់ដីឲ្យទៅជាប្រភេទដីអាចសាងសង់បានជាមុន។

មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឲ្យសាងសង់សំណង់លំនៅឋានផ្ទាល់ខ្លួនបានដែលពុំមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្ម រោងចក្រសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

ការកំណត់ប្រភេទដីកម្រិតការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៥ .-

ផលធៀបរវាងផ្ទៃក្រឡាបាតសំណង់និងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយ នៅក្នុងប្រភេទដីកម្រិតការសាងសង់នៅទីក្រុង ត្រូវកំណត់៣០(សាមសិប)ភាគរយ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ ត្រូវរៀបចំឲ្យមានសួនច្បារដែលអាចជ្រាបទឹកយ៉ាងតិច៥០(ហាសិប)ភាគរយនៃផ្ទៃដីដែលនៅសល់ពីការសាងសង់នេះ។

ផ្ទៃក្រឡាដីឡូត៍១០០(មួយរយ)ម៉ែត្រក្រឡាត្រូវដាំដើមឈើឲ្យបានយ៉ាងតិច១(មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។ ក្នុងការគណនាបើលទ្ធផលជាចំនួនទសភាគ ចំនួនដើមឈើត្រូវកំណត់យកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

មាត្រា២៦ .-

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាសម្រាប់ប្រភេទដីកម្រិតការសាងសង់នៅទីក្រុង ត្រូវកំណត់ត្រឹម១,៥(មួយកន្លះ)។

កាលណាសំណង់ថ្មីមួយ ត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្នែកទី៣
អំពីបទប្បញ្ញត្តិរួមសម្រាប់ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់

មាត្រា២៧ .-

លក្ខណៈបរិស្ថាននៃការងារនគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

មាត្រា២៨ .-

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ មិនគិតបញ្ចូលផ្ទៃក្រឡាកម្រាលសំណង់ជាន់ក្រោមដី ជាន់ផ្ទាល់ដី ដែលមានតែសរសរឥតមានរៀបជញ្ជាំង ផ្ទៃក្រឡាកម្រាលសំណង់គម្របជណ្តើរ ផ្ទៃក្រឡាកម្រាលសំណង់លំហក្រោមដំបូលដែលមានកម្ពស់តិចជាង១,៨០(មួយក្បៀសប្រាំបី)ម៉ែត្រ ផ្ទៃក្រឡាលំហផ្តល់ពន្ធី សួនច្បារខាងក្នុងអគារ និងផ្ទៃក្រឡាកម្រាលសំណង់ដែលបម្រើសុខុមាលភាពសហគមន៍ក្នុងអគារលំនៅឋាន។

ការគណនាសន្ទស្សន៍ប្រើប្រាស់ដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូនីយកម្ម និងសំណង់។

ប្លង់សន្ទស្សន៍ប្រើប្រាស់ដីនៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

មាត្រា២៩ .-

ក្នុងករណីដែលម្ចាស់សំណង់ស្នើសុំសាងសង់លើសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដីដូចបានចែងក្នុងមាត្រា២២និងមាត្រា២៦នៃអនុក្រឹត្យនេះ ម្ចាស់សំណង់ត្រូវបង់ប្រាក់ជូនរដ្ឋជាមុន។ ថវិកាដែលបានមកពីការបង់ប្រាក់ពីការសាងសង់លើសសន្ទស្សន៍នៃការប្រើប្រាស់ដីនេះ:មួយចំណែកត្រូវបង់ចូលថវិការដ្ឋ មួយចំណែកទៀតត្រូវផ្តល់ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមួយចំណែកទៀតត្រូវផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលសំណង់នោះតាំងនៅ។

ចំនួនទឹកប្រាក់ដែលត្រូវបង់ជូនរដ្ឋនិងការបែងចែកថវិកា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការស្នើសុំសាងសង់លើសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដីដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើមិនត្រូវបានអនុញ្ញាតជូនឡើយ ក្នុងករណីការស្នើសុំសាងសង់នោះមានផលប៉ះពាល់ជាអវិជ្ជមានដល់សុវត្ថិភាព សុខុមាលភាព សោភណភាព សណ្តាប់ធ្នាប់សាធារណៈ សុខដុមនីយកម្ម និងបរិស្ថាន។

មាត្រា៣០ .-

កម្ពស់អគារនៅទីក្រុង ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានតំបន់ ប្រភេទអគារ ទំហំដីឡូត៍ ទំហំទទឹងផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលសំណង់នោះតាំងនៅ និងលើលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ភូមិសាស្ត្រ វប្បធម៌ ជាសុកភាព សុខភាព និងសោភណភាព ស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែងរបស់ខ្លួន និងអនុវត្តតាមវិធីសាស្ត្រណាមួយ ដូចខាងក្រោម:

១- វិធីសាស្ត្រទី១ : ការកំណត់កម្ពស់ជាម៉ែត្រ ឬ

- អគារកម្ពស់ទាប ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី១១
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ។

២- វិធីសាស្ត្រទី២ : ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ឬ

- ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ដូចមានចែងនៅក្នុងមាត្រា២២ មាត្រា២៧ និងមាត្រា២៧ នៃអនុក្រឹត្យនេះ។

៣- វិធីសាស្ត្រទី៣ : ការកំណត់កម្ពស់តាមប្លង់ទ្រេត ឬ

- អគារកម្ពស់ទាប ត្រូវបានអនុវត្តក្នុងករណីដែលទំហំទទឹងផ្លូវតូចជាងឬស្មើ៩(ប្រាំបួន)ម៉ែត្រ ដោយកម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ក)
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ខ)
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (គ)។

៤- វិធីសាស្ត្រទី៤ : ការកំណត់កម្ពស់អគារ ដោយប្រើប្រាស់វិធីសាស្ត្រខាងលើពីរឬបីរួមគ្នា។

កម្ពស់អតិបរមានិងអប្បបរមាតាមជាន់នីមួយៗនៃអគារ ត្រូវកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ស្របទៅតាមប្រភេទនៃការប្រើប្រាស់អគារ និងតាមទីតាំងភូមិសាស្ត្រ។ ទោះជាយ៉ាងណាកម្ពស់អគារអប្បបរមាសម្រាប់មួយជាន់ៗកំណត់ត្រឹម២,៨ម៉ែត្រ សម្រាប់អគារស្នាក់នៅ។

ប្លង់កម្ពស់អគារនៃរាជធានី និងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ចំនួន (ក) (ខ) និង(គ) នឹងត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ការកំណត់កម្ពស់នៃអគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣១ .-

ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ត្រូវបានកំណត់ដូចខាងក្រោម:

ចំពោះទីតាំងដែលមានប្លង់ធ្លាគម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមប្លង់តម្រង់ជួរមានស្រាប់ស្របច្បាប់ ឬតាមផែនការប្រើប្រាស់ដីដែលបានធ្វើការព្យាករសម្រាប់លទ្ធភាពពង្រីកផ្លូវ នាពេលអនាគត។

ចំពោះទីតាំងដែលពុំមានប្លង់ធ្លាគម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមបទដ្ឋានដូចខាងក្រោម:

១- អគារកម្ពស់ទាប

- ធ្លាគម្លាតខាងមុខយ៉ាងតិច៤(បួន)ម៉ែត្រ។ គម្លាតនេះ អាចកំណត់យ៉ាងតិច២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង និងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ
- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២(ពីរ)ម៉ែត្រ។

២- អគារកម្ពស់មធ្យម

- ប្រភេទទី១ : អគារមានកម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី៨
  - ធ្លាគម្លាតខាងមុខយ៉ាងតិច៤(បួន)ម៉ែត្រ។ គម្លាតនេះអាចកំណត់យ៉ាងតិច២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង និងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ
  - ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២(ពីរ)ម៉ែត្រ។

-ប្រភេទទី២ : អគារមានកម្ពស់ចាប់ពីជាន់ទី៩ដល់ជាន់ទី១១

- ធ្លាគម្លាតខាងមុខយ៉ាងតិច៥(ប្រាំ)ម៉ែត្រ។ គម្លាតនេះ អាចកំណត់យ៉ាងតិច២,៥(ពីរម៉ែត្រកន្លះ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ
- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥(ពីរម៉ែត្រកន្លះ)ម៉ែត្រ។

ក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ ត្រូវរៀបចំឲ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្របឬក្នុងអគារសម្រាប់សាធារណៈ ដែលមានទំហំទទឹងយ៉ាងតិច២(ពីរ)ម៉ែត្រ ដើម្បីលើកទឹកចិត្តដល់ថ្មើរជើង។

បទដ្ឋានបច្ចេកទេសកំណត់គម្លាតអប្បបរមាក្នុងដីឡូត៍បន្ថែមពីការកំណត់ខាងលើ សម្រាប់ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់ធ្លាគម្លាតអគារនៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ និងសម្រេចដាក់ឲ្យប្រើប្រាស់ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

មាត្រា៣២ .-

បទដ្ឋានទំហំដីឡូត៍បច្ចេកទេស ត្រូវបានកំណត់ឡើង ដើម្បីធានាការរៀបចំផែនការរូបវន្តទីក្រុង ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដី ឲ្យមានសោភណភាព មានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាព។

ទំហំដីឡូត៍បច្ចេកទេសអប្បបរមា សម្រាប់តំបន់លំនៅឋាន ត្រូវបានកំណត់តាមប្រភេទ ដូចខាងក្រោម៖

១- តំបន់លំនៅឋានមានកម្ពស់ទាប
- តំបន់លំនៅឋានដាច់ពីគ្នា(ភូមិគ្រឹះឬពាក់កណ្តាលភូមិគ្រឹះ) មានទំហំដីយ៉ាងតិច១០ម x ២០ម
- តំបន់លំនៅឋានជាប់គ្នា(ផ្ទះល្វែងឬផ្ទះជាប់គ្នា) មានទំហំដីយ៉ាងតិច៨ម x ១៥ម។

២- តំបន់លំនៅឋានមានកម្ពស់មធ្យម
- ប្រភេទទី១(ពីជាន់ទី៣ដល់ជាន់ទី៨) មានទំហំដីយ៉ាងតិច១៥ម x ២៥ម
- ប្រភេទទី២(ពីជាន់ទី៩ដល់ជាន់ទី១១) មានទំហំដីយ៉ាងតិច២០ម x ៣០ម។

៣- តំបន់លំនៅឋានមានកម្ពស់ខ្ពស់
- ប្រភេទទី១(ពីជាន់ទី១២ដល់ជាន់ទី១៨) ទំហំដីឡូត៍ចាប់ពី១៥០០ម^{2}ឡើងទៅ
- ប្រភេទទី២(ពីជាន់ទី១៩ឡើងទៅ) ទំហំដីឡូត៍ចាប់ពី៣០០០ម^{2}ឡើងទៅ

ការកំណត់ទំហំដីឡូត៍បច្ចេកទេសខាងលើនេះ មិនយកមកអនុវត្តចំពោះទំហំដីឡូត៍ដែលមានរួចហើយ និងដែលមានទំហំតូចជាងការកំណត់ខាងលើនេះ។

ទំហំដីឡូត៍បច្ចេកទេសអប្បបរមា សម្រាប់តំបន់លំនៅឋានផ្សេងទៀត តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម និងតំបន់កសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៣ .-

ការប្តូរប្រភេទនៃការប្រើប្រាស់ដីពីប្រភេទដីកម្រិតការសាងសង់ទៅជាប្រភេទដីអាចសាងសង់បាន ត្រូវធ្វើតាមរយៈ៖

- ការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតឲ្យមានទីក្រុងឬទីប្រជុំជនថ្មី និងផែនការអភិវឌ្ឍក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

- ការផ្តួចផ្តើមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងទស្សនៈជំនាញ ដើម្បីបំពេញតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកិច្ច
- ការផ្តួចផ្តើមរបស់អាជ្ញាធររាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត អាស្រ័យតាមតម្រូវការនៃកំណើនប្រជាជន ដែលមានដង់ស៊ីតេប្រជាជនក្នុងប្រភេទដីអាចសាងសង់បាន លើសពីកម្រិតអតិបរមា ដូចមានចែងក្នុងមាត្រា២៣
- ការស្នើសុំរបស់ម្ចាស់ដីឬអ្នកវិនិយោគ ក្នុងគោលបំណងធ្វើការអភិវឌ្ឍដីពិតប្រាកដ និងស្របតាមលក្ខណៈបច្ចេកទេសនៃនគរូបនីយកម្ម។

ការស្នើសុំប្តូរប្រភេទនៃការប្រើប្រាស់ដី ពីប្រភេទដីកម្រិតការសាងសង់មកជាប្រភេទដីអាចសាងសង់បានអាចធ្វើទៅបាន លុះត្រាតែមានការធ្វើផែនការប្រើប្រាស់ដីសម្រាប់ដីដែលសុំប្តូរ និងផែនការចនាសម្ព័ន្ធរូបវន្តសាធារណៈឲ្យបានច្បាស់លាស់និងបានយល់ព្រមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ដើម្បីស្នើសុំប្តូរប្រភេទនៃការប្រើប្រាស់ដី សាមីសំណើត្រូវរៀបចំគម្រោងផែនការមេអភិវឌ្ឍ និងសាងសង់ឲ្យមានផ្ទៃដីសម្រាប់បណ្តាញផ្លូវថ្នល់ ឲ្យបានយ៉ាងតិច២៥(ម្ភៃប្រាំ)ភាគរយនៃផ្ទៃដីសរុបក្នុងប្រភេទដីអាចសាងសង់បាន និងផ្ទៃក្រឡាលំហសាធារណៈនិងផ្ទៃបៃតង១០(ដប់)ភាគរយនៃផ្ទៃដីសរុបឬ១០(ដប់)ម៉ែត្រក្រឡា សម្រាប់មនុស្សម្នាក់។

ការប្តូរប្រភេទនៃការប្រើប្រាស់ដីដែលទាក់ទងនឹងដីរដ្ឋ ត្រូវអនុវត្តតាមច្បាប់ នីតិវិធី និងបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីនិងបែបបទនៃការរៀបចំឯកសារស្នើសុំប្តូរប្រភេទនៃការប្រើប្រាស់ដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៤ .-

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវមានគ្រប់គ្រាន់តាមតម្រូវការនៃប្រភេទអគារនីមួយៗ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ និងទីតាំងសាធារណៈ។

ចំនួនចំណតរថយន្តអប្បបរមាសម្រាប់អគារក្នុងដីឡូត៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អគារលំនៅឋានរួមមាន៖

- លំនៅឋានដាច់(ភូមិគ្រឹះ និងពាក់កណ្តាលភូមិគ្រឹះ)	ផ្ទៃក្រឡាកម្រាល១០០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- លំនៅឋានជាប់(ផ្ទះល្វែង និងផ្ទះជាប់គ្នា)	ផ្ទៃក្រឡាកម្រាល១២០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារស្នាក់នៅរួមប្រភេទប្រណីត	ផ្ទៃក្រឡាកម្រាល១០០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារស្នាក់នៅរួមប្រភេទមធ្យម	ផ្ទៃក្រឡាកម្រាល១២០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារស្នាក់នៅរួមប្រភេទធម្មតា	ផ្ទៃក្រឡាកម្រាល១៥០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង។

២- អគារពាណិជ្ជកម្ម រួមមាន៖

- ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន និងក្លឹបកម្សាន្ត	ផ្ទៃក្រឡាកម្រាល២០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
	និងផ្ទៃក្រឡាកន្លែងរាំ១ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- ផ្សារទំនើប	ផ្ទៃក្រឡាកម្រាល៥០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- ផ្សារ ឬ កន្លែងលក់ដូរ	ផ្ទៃក្រឡាកម្រាល៥០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង

- អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាល៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៣- អគារឧស្សាហកម្ម រួមមាន៖

- អគាររោងចក្រ ផ្ទៃក្រឡាកម្រាល២៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងក្រឡាផ្ទៃកម្រាល១២៥០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាល៤០០ម²ត្រូវមានចំណតរថយន្តតូច១កន្លែង និង ផ្ទៃក្រឡាកម្រាល២០០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

៤- អគារសិក្សាធិការ អប់រំ និងកីឡា រួមមាន៖

- អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាកម្រាល២០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាកម្រាល៣០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- មជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៥- អគារសុខភាព រួមមាន៖

- អគារមន្ទីរពេទ្យ ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- ក្លឹបហាត់ប្រាណនិងសុខភាព ផ្ទៃក្រឡាកម្រាល១២០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៦- អគារសាលមហោស្រព សាលប្រជុំ ពិធី និងរោងភាពយន្ត រួមមាន៖

- អគារមហោស្រព រោងភាពយន្ត សាលជួបជុំ និងពិធី ផ្ទៃក្រឡាកម្រាល៣០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៣០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

៧- អគារសណ្ឋាគារនិងផ្ទះសំណាក់ រួមមាន៖

- អគារសណ្ឋាគារ ចំនួនបន្ទប់៥បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារផ្ទះសំណាក់ ចំនួនបន្ទប់១០បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង។

៨- អគារការិយាល័យសាធារណៈនិងការិយាល័យឯកជន រួមមាន៖

- អគាររដ្ឋបាលនិងការិយាល័យឯកជន ផ្ទៃក្រឡាកម្រាល ១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៩- ស្ថានីយប្រេងឥន្ធនៈ រួមមាន៖

- ស្ថានីយប្រេងឥន្ធនៈ ផ្ទៃក្រឡាកម្រាល១០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល១០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

១០- អគារការិយាល័យដឹកជញ្ជូន រួមមាន៖

- អគារការិយាល័យដឹកជញ្ជូន ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

១១- អគារផ្សេងៗរួមមាន៖

- អគារផ្សេងៗ ផ្ទៃក្រឡាកម្រាល១៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ដែលបានកំណត់ខាងលើនេះ ជាចំនួនអប្បបរមាដែលត្រូវមានជាចាំបាច់ សម្រាប់ការអភិវឌ្ឍនិងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនចំណតនេះត្រូវយកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ក្នុងករណីអគារបម្រើមុខងារចម្រុះ ការគណនាចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវគណនាតាមប្រភេទមុខងារនីមួយៗ ហើយបូកសរុបបញ្ចូលគ្នា ទើបទទួលបានចំនួនចំណតសរុប សម្រាប់អគារទាំងមូល។

ការរៀបចំចំណតយានយន្តនៅទីសាធារណៈនិងឯកជនត្រូវមានចំណតសម្រាប់ជនពិការនិងជនងាយរងគ្រោះ។

បទដ្ឋានចំណតយានយន្ត ទំហំចំណត និងលក្ខណៈបច្ចេកទេសសម្រាប់ចំណតក្នុងដីឡូត៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះបទដ្ឋានកំណត់ទីតាំងចំណតយានយន្តនិងទំហំចំណតសម្រាប់ចំណតសាធារណៈក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការចេញលិខិតអនុញ្ញាតសាងសង់ណាមួយចំពោះប្រភេទអគារខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិចំនួនចំណតអប្បបរមានៃមាត្រា៣៣នេះ។

ជំពូកទី៦

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈ

មាត្រា៣៥ .-

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈមានដូចខាងក្រោម៖

១- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ រួមមាន៖

- បណ្តាញផ្លូវសាធារណៈ
- បរិក្ខារសាធារណៈ ដូចជាប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍។ល។
- ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ ដូចជា ទីលានចាក់សំរាម ឡោងចក្រកែច្នៃសំរាម ប្រព័ន្ធលូអាងប្រព្រឹត្តកម្មទឹកកខ្វក់។ល។
- ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងហានិភ័យផ្សេងៗ។

២- សំណង់សម្រាប់ផ្តល់សេវាជូនសាធារណជនរួមមាន៖

- អគាររដ្ឋបាលសាធារណៈ អគារសិក្សាសាធារណៈ មន្ទីរពេទ្យសាធារណៈ
- ចំណតយានយន្តសាធារណៈ ចំណតរថយន្តក្រុង ចំណតរថយន្តឈ្នួល ស្ថានីយរថភ្លើងសម្រាប់អ្នកដំណើរ ស្ថានីយចែកចាយទំនិញ ផែសូត មជ្ឈមណ្ឌលផ្គត់ផ្គង់ភស្តុភាកម្ម។ល។ ត្រូវរៀបចំសម្រាប់មនុស្សទូទៅនិងជនពិការ និងមិនត្រូវស្ថិតនៅលើចិញ្ចើមផ្លូវសាធារណៈសម្រាប់ថ្មើរជើងឡើយ។

៣- លំហសាធារណៈរួមមាន៖

- សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា ទីលានកម្សាន្ត។

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជននិងលំហសាធារណៈ ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការនិងជនងាយរងគ្រោះ។

នៅពេលដំណើរការអនុវត្តគម្រោងអភិវឌ្ឍនានា ដើម្បីផលប្រយោជន៍សាធារណៈដែលប៉ះពាល់ដល់កម្មសិទ្ធិឯកជនស្របច្បាប់ ការដកហូតកម្មសិទ្ធិមួយផ្នែកឬទាំងស្រុង ត្រូវអនុវត្តតាមច្បាប់អស្សាមិសូណៅ។

ផ្នែកទី១
អំពីហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

មាត្រា៣៦ .-

ទំហំសមាមាត្រដីសម្រាប់បម្រើឲ្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវកំណត់យ៉ាងតិច២៥(ម្ភៃប្រាំ) ភាគរយនៃប្រភេទដីអាចសាងសង់បាន។

រាល់គម្រោងអភិវឌ្ឍន៍ទីក្រុងត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រានេះ។

មាត្រា៣៧ .-

បណ្តាញផ្លូវនៅទីក្រុង ត្រូវបានបែងចែកដូចខាងក្រោម៖

ប្រភេទទី១- មហាវិថី

ប្រភេទទី២- វិថី

ប្រភេទទី៣- អនុវិថី

ប្រភេទទី៤- ផ្លូវបម្រើឱ្យការដឹកជញ្ជូនសំខាន់ៗ

ប្រភេទទី៥- ផ្លូវថ្មើរជើង។

មាត្រា៣៨ .-

គម្លាតចន្លោះរវាងមហាវិថីមួយទៅមហាវិថីមួយ ឬពីវិថីមួយទៅវិថីមួយ ឬពីផ្លូវមួយទៅផ្លូវមួយ និងទំហំផ្លូវនីមួយៗដូចមានចែងក្នុងមាត្រា៣៦ខាងលើ ត្រូវគោរពតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនិងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៣៩ .-

ការរៀបចំផែនការរូបវន្តទីក្រុងត្រូវរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈនិងផ្ទៃបៃតងអប្បបរមាមានជាអាទិ៍ បណ្តាញផ្លូវ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធបង្ហូរទឹកកខ្វក់ ប្រព័ន្ធបង្ហូរទឹកភ្លៀង អាងស្តុកទឹក អាងប្រព្រឹត្តកម្មទឹកកខ្វក់ ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ ក្បាលបំពង់ទឹកសម្រាប់ពន្លត់អគ្គិភ័យ បណ្តាញអគ្គិសនី ព្រមទាំងបណ្តាញទូរគមនាគមន៍។

មាត្រា៤០ .-

ការរៀបចំផែនការរូបវន្តទីក្រុង ត្រូវកំណត់ឲ្យបានច្បាស់អំពីផែនការបន្សាំនិងកាត់បន្ថយនៃការប្រែប្រួលអាកាសធាតុ ដើម្បីកំណត់ទីតាំងដែលងាយបង្កឲ្យមានគ្រោះអគ្គិភ័យ និងហានិភ័យផ្សេងៗជាយថាហេតុ ដើម្បីរៀបចំឲ្យមានការការពារច្បាស់លាស់ចំពោះសុវត្ថិភាពសាធារណៈ សុខុមាលភាពសាធារណៈ បរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងជីវិតមនុស្ស។

សេចក្តីពិពណ៌នាលម្អិតអំពីគ្រោះអគ្គិភ័យនិងហានិភ័យផ្សេងៗជាយថាហេតុ ត្រូវចែងក្នុងរបាយការណ៍បច្ចេកទេសនៃការរៀបចំផែនការរូបវន្តទីក្រុង។

មាត្រា៤១ .-

បទដ្ឋានទំហំដីសម្រាប់អភិវឌ្ឍបណ្តាញផ្លូវក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

បទដ្ឋានបច្ចេកទេសលម្អិតអំពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងបរិក្ខារសាធារណៈក្នុងទីក្រុងជាអាទិ៍ ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង ប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ និងការគ្រប់គ្រងគ្រោះអគ្គិភ័យ និងហានិភ័យផ្សេងៗ។ល។ ត្រូវកំណត់ដោយក្រសួង ស្ថាប័នជំនាញ។

ផ្នែកទី២
សំណង់ផ្តល់សេវាដូនសាធារណជន

មាត្រា៤២ .-

ការរៀបចំផែនការរូបវន្តទីក្រុង ត្រូវរៀបចំឲ្យមានអគារបម្រើសេវាសាធារណៈគ្រប់គ្រាន់ទៅតាមតម្រូវការចាំបាច់ដូចជាសាលារៀន មណ្ឌលសុខភាព អគាររដ្ឋបាលជាដើម ដើម្បីធានាការផ្តល់នូវសេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងមានសមធម៌។ គ្រប់អគារបម្រើសេវាសាធារណៈ ត្រូវមានរៀបចំសម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ និងជនចាស់ជរាផង។

មាត្រា៤៣ .-

ដើម្បីធានាបាននូវការអប់រំប្រកបដោយប្រសិទ្ធភាពនិងមានសមធម៌ ការរៀបចំផែនការរូបវន្តទីក្រុងត្រូវរៀបចំឲ្យមានសាលារៀនតាមបទដ្ឋាន ដូចខាងក្រោម៖

- សាលាមត្តេយ្យសិក្សា ត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥០០(ប្រាំរយ)ម៉ែត្រ ឬភូមិមួយត្រូវមានសាលាមត្តេយ្យសិក្សាមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។
- សាលាបឋមសិក្សាត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥០០(ប្រាំរយ)ម៉ែត្រ ឬភូមិមួយត្រូវមានសាលាបឋមសិក្សាមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។
- អនុវិទ្យាល័យត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៣ ០០០(បីពាន់)ម៉ែត្រ ឬឃុំមួយត្រូវមានអនុវិទ្យាល័យមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។
- វិទ្យាល័យត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់៥ ០០០(ប្រាំពាន់)ម៉ែត្រ ឬស្រុកមួយត្រូវមានវិទ្យាល័យមួយយ៉ាងតិចឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង។

មាត្រា៤៤ .-

បទដ្ឋានបច្ចេកទេសលម្អិតអំពីការរៀបចំអគាររដ្ឋបាលសាធារណៈ អគារសេវាសុខភាពសាធារណៈ ចំណតសាធារណៈ អគារស្ថានីយអ្នកដំណើរសាធារណៈ អគារប្រៃសណីយ៍។ល។ ត្រូវកំណត់ដោយក្រសួង ស្ថាប័នជំនាញ។

ផ្នែកទី៣
អំពីលំហសាធារណៈ

មាត្រា៤៥ .-

ការរៀបចំលំហសាធារណៈនិងផ្ទៃបៃតងក្នុងប្រភេទដីអាចសាងសង់បាន ត្រូវកំណត់១(មួយ)ហិកតា សម្រាប់មនុស្ស១ ០០០(មួយពាន់)នាក់ ឬមានទំហំយ៉ាងតិច៥(ប្រាំ)ភាគរយ នៃផ្ទៃដីសរុបក្នុងប្រភេទដីអាចសាងសង់បាន។ លំហសាធារណៈ ត្រូវមានរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់មនុស្សទាំងអស់គ្នារួមទាំងជនពិការជនចាស់ជរា និងជនអសមត្ថភាព។

មាត្រា៤៦ .-

លំហសាធារណៈនិងផ្ទៃបៃតង មានជាអាទិ៍៖

១- សួនកុមារសម្រាប់វ័យមត្តេយ្យសិក្សានិងបឋមសិក្សាលេងនិងហាត់កីឡា បំពាក់ដោយឧបករណ៍និងសម្ភារៈដែលមានសុវត្ថិភាព និងជួយដល់ការរីកចម្រើននៃការវិវត្តរបស់កុមារ ចំពោះអាយុផ្សេងៗគ្នា

សុខភាពល្អ។ សួននេះអាចមានទំហំ២ ០០០(ពីរពាន់)ម៉ែត្រក្រឡា និងត្រូវមានរបងការពារសុវត្ថិភាព ហើយត្រូវមានចម្ងាយពីសួនមួយទៅសួនមួយយ៉ាងច្រើន១(មួយ)គីឡូម៉ែត្រ ឬនៅជាប់នឹងសាលាមត្តេយ្យសិក្សា ឬបឋមសិក្សា។

២- សួនច្បារភូមិសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងសហគមន៍ឬតំបន់លំនៅឋាននីមួយៗដែលអាចប្រើប្រាស់ដោយផ្ទាល់និងមិនផ្ទាល់។ សួននេះអាចមានទំហំ៥ ០០០(ប្រាំពាន់)ម៉ែត្រក្រឡា និងត្រូវមានចម្ងាយពីសួនមួយទៅសួនមួយយ៉ាងច្រើន២(ពីរ)គីឡូម៉ែត្រ។

៣- សួនច្បារសង្កាត់សម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងសង្កាត់និងតំបន់ជិតខាងនូវសកម្មភាពសម្រាកកម្សាន្ត លំហែ និងកីឡា។ សួននេះអាចមានទំហំ៥(ប្រាំ)ហិកតា។

៤- សួនច្បារទីក្រុងសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងទីក្រុងនូវសកម្មភាពសម្រាកកម្សាន្ត លំហែ និងកីឡា។ សួននេះអាចមានទំហំ១០(ដប់)ហិកតា។

៥- សួនតំបន់ជាសួនខ្នាតធំដែលប្រើប្រាស់សម្រាប់តំបន់ឬទីក្រុងច្រើន ក្នុងគោលបំណងថែរក្សាទេសភាពនិងសោភណភាពធម្មជាតិ ដែលប្រើប្រាស់សម្រាប់ការធ្វើដំណើរនិងការបោះជំរុំទេសចរណ៍ និងកម្សាន្ត របស់ប្រជាពលរដ្ឋក្នុងទីក្រុង។ សួននេះ អាចមានទំហំ៥០(ហាសិប)ហិកតា។

៦- ឧទ្យានរុក្ខសាស្ត្ររៀបចំដាំដុះរុក្ខជាតិដ៏សំបូរបែប ក្នុងគោលបំណងការសិក្សាស្រាវជ្រាវ ការកម្សាន្ត និងការទស្សនា។ ឧទ្យាននេះត្រូវបានប្រជាពលរដ្ឋចូលចិត្តធ្វើដំណើរ ទេសចរណ៍ និងកម្សាន្តជាលក្ខណៈគ្រួសារ ហើយចំណាយពេលវេលាស្មើរពេញមួយថ្ងៃ។ ឧទ្យាននេះមានទំហំអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

៧- ឧទ្យានសួនសត្វរៀបចំចិញ្ចឹមសត្វព្រៃដ៏សំបូរបែប ក្នុងគោលបំណងការសិក្សាស្រាវជ្រាវ ការកម្សាន្ត និងការទស្សនា។ ឧទ្យាននេះត្រូវបានប្រជាពលរដ្ឋចូលចិត្តធ្វើដំណើរទេសចរណ៍ និងកម្សាន្តជាលក្ខណៈគ្រួសារ។ ឧទ្យាននេះមានទំហំអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

៨- សួនតាមដងផ្លូវ បណ្តាញបៃតងដែលរៀបចំដាំដើមឈើលើសួនច្បារនិងតាមដង ផ្លូវដើម្បីតភ្ជាប់បណ្តាញបៃតងនៅក្នុងទីក្រុង។ ទំហំបណ្តាញបៃតងនេះអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

មាត្រា៤៧ .-

ក្នុងករណីចាំបាច់ សួនច្បារទាំង៨ប្រភេទខាងលើអាចមានទំហំតូចជាងទំហំកំណត់ខាងលើ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទំហំនោះត្រូវមានលក្ខណៈសមស្របសម្រាប់ឲ្យសាធារណជននិងសហគមន៍អាចប្រើប្រាស់បានហើយដែលមានចែងក្នុងនីតិវិធីបច្ចេកទេសលម្អិតអំពីការរៀបចំលំហសាធារណៈនិងផ្ទៃបៃតង។

បទដ្ឋានបច្ចេកទេសអំពីការរៀបចំលំហសាធារណៈនិងផ្ទៃបៃតង ត្រូវកំណត់ដោយក្រសួងឬស្ថាប័នជំនាញ។

ការរៀបចំផែនការរូបវន្តទីក្រុង គម្រោងអភិវឌ្ឍន៍ទីក្រុង និងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃជំពូកនេះ។

ជំពូកទី៧
ការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង និងការសាងសង់ទីក្រុង

មាត្រា៤៨ .-

ទីក្រុងត្រូវបានអនុវត្តតាមរយៈគម្រោងសាងសង់ គម្រោងអភិវឌ្ឍក្នុងទីក្រុង និងគម្រោងអភិរក្សក្នុងទីក្រុង ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ដី ការកែលម្អ និងបំពេញបន្ថែមហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈនិងបរិស្ថានល្អស្អាត ដើម្បីធានាបាននូវការអភិវឌ្ឍនិងការអភិរក្ស ប្រកបដោយចីរភាព សមធម៌

និងការធ្វើសមាហរណកម្ម។ ការអភិវឌ្ឍទីក្រុងត្រូវគិតអំពីតម្រូវការខាងលំនៅឋានសមស្រប និងមានតុល្យភាពរវាងលទ្ធភាពដែលគ្រួសារក្រីក្រនិងអ្នកមានប្រាក់ចំណូលទាប អាចរកបានលំនៅឋានសមរម្យ និងតម្រូវការសេដ្ឋកិច្ចរបស់រដ្ឋនិងផ្នែកឯកជន។

មាត្រា៤៩ .–

គម្រោងអភិវឌ្ឍក្នុងទីក្រុង រួមមាន៖

១- គម្រោងអភិវឌ្ឍដី

  ១.១- គម្រោងប្តូរប្រភេទនៃការប្រើប្រាស់ដី

  ១.២- គម្រោងបង្រួមក្បាលដី

  ១.៣- គម្រោងបំបែកក្បាលដី។

២- គម្រោងកែសម្រួលក្បាលដី

៣- គម្រោងអភិវឌ្ឍទីក្រុងឡើងវិញ

៤- គម្រោងអភិវឌ្ឍទីតាំងថ្មី

៥- គម្រោងអភិវឌ្ឍលំនៅឋាន

៦- គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម

៧- គម្រោងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

៨- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង

៩- គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍

១០-គម្រោងចែករំលែកដី

១១-គម្រោងអភិវឌ្ឍផ្សេងៗ។

គម្រោងអភិរក្សក្នុងទីក្រុង រួមមាន៖

១-គម្រោងអភិរក្សតំបន់បៃតង

២-គម្រោងអភិរក្សសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រ

៣-គម្រោងអភិរក្សទេសភាពទីក្រុង

៤-គម្រោងអភិរក្សរមណីយដ្ឋានវប្បធម៌

៥-គម្រោងអភិរក្សផ្សេងៗ។

មាត្រា៥០ .–

គម្រោងអភិវឌ្ឍក្នុងទីក្រុង រួមមាន៖

១- គម្រោងអភិវឌ្ឍដី ត្រូវបានអនុវត្តក្នុងគោលដៅផ្លាស់ប្តូរប្រភេទនៃការប្រើប្រាស់ដី កែសម្រួលតំបន់ប្រើប្រាស់ដីឡើងវិញ ដើម្បីធ្វើការអភិវឌ្ឍទីក្រុង មានជាអាទិ៍ការបង្រួមក្បាលដីឬការបំបែកក្បាលដី ដោយត្រូវគោរពតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងធានាបាននូវបទដ្ឋានអប្បបរមានៃការប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ព្រមទាំងលក្ខខណ្ឌបរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ច។

  ១.១- គម្រោងប្តូរប្រភេទនៃការប្រើប្រាស់ដី ត្រូវបានអនុវត្តដោយការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមមាត្រា៣២នៃអនុក្រឹត្យនេះ។

  ១.២- គម្រោងបង្រួមក្បាលដី ត្រូវបានអនុវត្តដោយការបូកបញ្ចូលក្បាលដីដែលស្ថិតនៅជាប់គ្នាទាំងអស់ក្នុងក្របខ័ណ្ឌនៃគម្រោង ដើម្បីរៀបចំជាប្លង់ប្រើប្រាស់ដីសមាហរណកម្មមួយសម្រាប់ការអភិវឌ្ឍ

និងការសាងសង់ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

១.៣- គម្រោងបំបែកក្បាលដីត្រូវបានអនុវត្តដោយការបំបែកក្បាលដីមួយជាដីឡូត៍បច្ចេកទេសច្រើន សម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

២- គម្រោងកែសម្រួលក្បាលដី ត្រូវបានអនុវត្តដោយការរៀបចំក្បាលដីឡើងវិញ ដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួមនិងការយល់ព្រមបរិច្ចាគដីពីម្ចាស់ដីឡូត៍ទាំងអស់ ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

៣- គម្រោងអភិវឌ្ឍទីក្រុងឡើងវិញ ត្រូវបានអនុវត្តនៅតំបន់ណាមួយនៃទីក្រុង ក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនលទ្ធភាពប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាពនិងសោភណភាព តាមរយៈការផ្ទេរសិទ្ធិលើដីនិងអគារទៅជាសិទ្ធិលើផ្ទៃក្រឡាកម្រាលអគារថ្មីដែលមានតម្លៃស្មើនៅក្នុងគម្រោងនេះ ដោយមានការចូលរួមនិងយល់ព្រមពីម្ចាស់ដីឡូត៍ ឬតាមតម្រូវការនៃការអភិវឌ្ឍទីក្រុង ស្របតាមច្បាប់។

៤- គម្រោងអភិវឌ្ឍទីតាំងថ្មី ត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែមនូវតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវមុខងាររបស់ទីក្រុងសម្រាប់ការរស់នៅ ការសម្រាកលំហែកម្សាន្ត ការមានការងារធ្វើ និងការធ្វើចរាចរប្រកបដោយសុវត្ថិភាពនិងសោភណភាព។

៥- គម្រោងអភិវឌ្ឍន៍លំនៅឋាន ត្រូវបានអនុវត្តក្នុងគោលបំណងធានាបាននូវសុខភាព ជាសុកភាព សោភណភាព និងសុខដុមរមណីយកម្មសម្រាប់ការស្នាក់នៅ ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ដល់ការស្នាក់នៅ។

៦- គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម ត្រូវបានអនុវត្តក្នុងគោលដៅធានាបាននូវការងកភាព និងសុខដុមនីយកម្មសម្រាប់ឧស្សាហកម្ម ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ផ្សេងៗដល់សុខភាព។

៧- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុវត្តស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥។ ការធ្វើប្លង់គោលនិងផែនការប្រើប្រាស់ដីសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ត្រូវតែធានាបាននូវបទដ្ឋានអប្បបរមានៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈ ព្រមទាំងធានាបាននូវការធ្វើសមាហរណកម្មនៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់នេះ ទៅនឹងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ឬផែនការថ្មីនៃទីក្រុង ខេត្ត តំបន់ និងជាតិ។

៨- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែម ឬបង្កើតថ្មីនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដើម្បីឲ្យឆ្លើយតបនឹងកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធសាធារណៈទីក្រុង ខេត្ត តំបន់ និងជាតិ។

៩- គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍ត្រូវបានអនុវត្តក្នុងគោលដៅទាក់ទាញការវិនិយោគវិស័យទេសចរណ៍ និងលើកកម្ពស់គុណភាពសេវាទេសចរណ៍ ស្របតាមគោលនយោបាយ ទេសចរណ៍នៅកម្ពុជា

១០-គម្រោងចែករំលែកដី ត្រូវបានអនុវត្តក្នុងគោលដៅកែលម្អស្ថានភាព លក្ខខណ្ឌរស់នៅ និងសោភណភាព នៃសហគមន៍ ឲ្យទទួលបានលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ សមស្រប។ គម្រោងចែករំលែកដី ត្រូវធ្វើឡើងដោយមានការឯកភាពពីម្ចាស់ដី និង/ឬ សហគមន៍ និងអ្នកវិនិយោគ ក្នុងការចែករំលែកផលប្រយោជន៍គ្នាទៅវិញទៅមក។

១១-គម្រោងអភិវឌ្ឍផ្សេងៗ ត្រូវបានអនុវត្តដើម្បីបំពេញបន្ថែម និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍទីក្រុង ក្នុងគោលបំណងធានាបាននូវសុខភាព ជាសុកភាព សោភណភាព និងសុខដុមនីយកម្ម សម្រាប់ការស្នាក់នៅ។

មាត្រា៥១ .-

គម្រោងអភិរក្សក្នុងទីក្រុង រួមមាន៖

១-គម្រោងអភិរក្សតំបន់បៃតង ត្រូវបានអនុវត្តក្នុងគោលបំណងធានាបាននូវគុណភាពបរិស្ថានរស់នៅ សុវត្ថិភាពស្បៀង ប្រព័ន្ធបៃតង និងរួមចំណែកទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។

២-គម្រោងអភិរក្សសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រ ត្រូវបានអនុវត្តក្នុងគោលបំណងរក្សាអត្តសញ្ញាណប្រវត្តិសាស្ត្រ ការវិវត្តនៃទីក្រុង និងផលប្រយោជន៍ជាតិ។

៣-គម្រោងអភិរក្សទេសភាពទីក្រុង ត្រូវបានអនុវត្តក្នុងគោលបំណងរក្សាទេសភាពធម្មជាតិ ពិសេសនៅទីតាំងណាមួយនៃទីក្រុង ដើម្បីលើកម្ពស់សោភណភាពទីក្រុងនិងទេសចរណ៍។

៤-គម្រោងអភិរក្សរមណីយដ្ឋានវប្បធម៌ ត្រូវបានអនុវត្តក្នុងគោលបំណងរក្សាអត្តសញ្ញាណរមណីយដ្ឋានវប្បធម៌ជាតិ ដើម្បីលើកម្ពស់វិស័យវប្បធម៌និងទេសចរណ៍។

៥-គម្រោងអភិរក្សផ្សេងៗ ត្រូវបានអនុវត្តក្នុងគោលបំណងបំពេញបន្ថែម និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិរក្សទីក្រុង និងតំបន់ជុំវិញ ដើម្បីធានាបាននូវគុណភាពបរិស្ថានរស់នៅ ទេសភាពធម្មជាតិ អត្តសញ្ញាណប្រវត្តិសាស្ត្រ និងវប្បធម៌ជាតិ។

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំយុទ្ធសាស្ត្រ និងផែនការគម្រោងអភិរក្ស ដោយត្រូវចុះបញ្ជីស្ថាបត្យកម្ម ស្នាដៃស្ថាបត្យកម្ម ទីតាំង ទេសភាព និងការអភិរក្សផ្សេងៗ ស្របតាមគោលការណ៍បច្ចេកទេសដើម្បីធានាការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងមានអត្តសញ្ញាណច្បាស់លាស់។

គោលការណ៍បច្ចេកទេសអភិរក្ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឬ/និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។

មាត្រា៥២ .-

គម្រោងសាងសង់ រួមមានការសាងសង់ដែលត្រូវបានស្នើឡើងដោយរូបវន្តបុគ្គលឬនីតិបុគ្គលគ្រប់ប្រភេទនៅលើដីដោយអនុលោមតាមលិខិតអនុញ្ញាតសាងសង់និងបទប្បញ្ញត្តិពាក់ព័ន្ធ។

មាត្រា៥៣ .-

គម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវគោរពឲ្យបាននូវលក្ខខណ្ឌអប្បបរមានៃបទប្បញ្ញត្តិប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ដូចមានចែងក្នុងជំពូកទី៥និងជំពូកទី៦នៃអនុក្រឹត្យនេះ។

គម្រោងអភិវឌ្ឍក្នុងទីក្រុងដែលពាក់ព័ន្ធនឹងដីរដ្ឋ ត្រូវមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលជាមុនសិន។ រាល់ការងារពាក់ព័ន្ធនឹងផ្នែកបច្ចេកទេសនគរូបនីយកម្មនិងសំណង់នៃគម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវទទួលបានការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់គម្រោងអភិវឌ្ឍក្នុងទីក្រុងដែលពាក់ព័ន្ធនឹងដីរបស់បុគ្គលឯកជន ត្រូវទទួលការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់គម្រោងអភិវឌ្ឍក្នុងទីក្រុងដែលពាក់ព័ន្ធនឹងប្រព័ន្ធស្ថានីយចម្រោះទឹកកខ្វក់ ទឹកស្អាត អគ្គិសនី ប្រព័ន្ធបង្ហូរទឹកកខ្វក់ បណ្តាញផ្លូវថ្នល់ ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ។ល។ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងត្រូវមានការចូលរួមយោបល់ពីក្រសួង ឬស្ថាប័នជំនាញពាក់ព័ន្ធ។

មាត្រា៥៤ .-

ក្នុងការអនុវត្តគម្រោងអភិវឌ្ឍក្នុងទីក្រុង ម្ចាស់គម្រោងត្រូវទទួលបន្ទុកលើការចំណាយទាំងអស់លើការអភិវឌ្ឍ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈ ចំពោះទីតាំងដីដែលត្រូវធ្វើការកែប្រែប្រភេទដីនៃការប្រើប្រាស់ដីឬមុខងារតំបន់ប្រើប្រាស់ដីជាមុន។ ដោយឡែកចំពោះគម្រោងដែលស្ថិតនៅក្នុងប្រភេទដីអាចសាងសង់បាន អាជ្ញាធរសាធារណៈ ត្រូវទទួលបន្ទុកលើការចំណាយសម្រាប់ការអភិវឌ្ឍ និងការសាងសង់ចាប់ពីមហាវិថីនិងសួនច្បារទីក្រុងឡើងទៅ។ រាល់ការចំណាយចំពោះផ្លូវថ្នល់និងសួនច្បារផ្សេងៗទៀតដែលស្ថិតក្នុងគម្រោងអភិវឌ្ឍក្នុងទីក្រុង ជាបន្ទុករបស់ម្ចាស់គម្រោង។

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈទាំងអស់នៃគម្រោងអភិវឌ្ឍក្នុងទីក្រុង ត្រូវចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ លើកលែងតែផ្លូវច្រកចេញចូល លំហសាធារណៈ សួនច្បារ លំហនៃសេវារួម របងបុរី និងតំបន់ផ្សេងទៀតដែលមានលក្ខណៈជាបុរី ទោះបីមានឈ្មោះអ្វីក៏ដោយ ត្រូវចុះបញ្ជីជាទ្រព្យអវិភាគរបស់កម្មសិទ្ធិករដោយអនុលោមតាមស្មារតីនៃអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី។

មាត្រា៥៥ .-

នីតិវិធីនៃការអនុវត្តគម្រោងអភិវឌ្ឍក្នុងទីក្រុងនិងគម្រោងអភិរក្សក្នុងទីក្រុងនិងការសាងសង់ទីក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៨
ការគ្រប់គ្រងការអភិវឌ្ឍទីក្រុង ការអភិរក្សទីក្រុង និងការសាងសង់ទីក្រុង

មាត្រា៥៦ .-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងកិច្ចការនគរូបនីយកម្ម និងសំណង់ដើម្បីធានាបាននូវការអភិវឌ្ឍ និងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព សមធម៌ សុខដុមនីយកម្ម និងសមាហរណកម្ម។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើប្រតិភូកម្មការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្មនិងសំណង់ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ទៅតាមតម្រូវការ និងស្ថានភាពសមត្ថភាពស្របតាមបទប្បញ្ញត្តិជាធរមាន។ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ ជាសេនាធិការផ្ទាល់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការងារនេះ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរួមរបស់អភិបាលរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ។

មាត្រា៥៧ .-

ដើម្បីធានាបាននូវការគ្រប់គ្រងកិច្ចការបច្ចេកទេសនគរូបនីយកម្មនិងសំណង់និងជាគ្រឹះនៃភាពស្របច្បាប់ ការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទ ត្រូវមានស្នើសុំលិខិតអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និង/ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។ ការអភិវឌ្ឍអចលនវត្ថុដែលត្រូវមានលិខិតអនុញ្ញាតរួមមាន៖

១- ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការពង្រីកអគារ និងការសង់បន្ថែមពីលើអគារដែលមានស្រាប់ ការប្តូរមុខងារប្រើប្រាស់អគារ ការប្តូរទ្រង់ទ្រាយអគារ ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់ និងការកែប្រែទិដ្ឋភាពខាងក្រៅនៃអគារដែលមានស្រាប់ ការជួសជុល និងរុះរើ។

២- ការសាងសង់ឬការប្តូរទ្រង់ទ្រាយអគារដែលអាចបង្កគ្រោះថ្នាក់អគ្គិភ័យ ដូចជា ការដាក់ស៊ីទែនកន្លែងស្តុកផលិតផលតេលសិលា រោងជាងផលិតគ្រឿងឆេះ។ល។

៣- ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍និងទូរគមនាគមន៍ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ក៏ដូចជាការដាក់រចនាសម្ព័ន្ធនៅលើដីនិងអគារ។

៤- ការអភិវឌ្ឍដី (ការកែប្រែរចនាសម្ព័ន្ធដើមនៃដី ការចាក់ដីបំពេញ ការជីកយកដីចេញ ការបង្រួមក្បាលដី ការបំបែកក្បាលដី ការប្តូរប្រភេទនៃការប្រើប្រាស់ដី និងការប្តូរមុខងារតំបន់ប្រើប្រាស់ដី។ល។)។

៥- គម្រោងអភិវឌ្ឍទីក្រុង ដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។

៦- ការផ្លាស់ប្តូរលក្ខណៈគតិយុត្តផ្សេងៗទៀត មានជាអាទិ៍ ការពន្យារសុពលភាពនៃលិខិតអនុញ្ញាតដែលហួសសុពលភាព ការផ្ទេរឈ្មោះក្នុងលិខិតអនុញ្ញាត។ល។

ដើម្បីឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល ការសាងសង់ថ្មីឬការជួសជុលលំនៅឋានតូចតាច និងពុំមានលក្ខណៈជាការធ្វើពាណិជ្ជកម្មមិនតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋាន និងបិទការដ្ឋានឡើយ ហើយដែលត្រូវកំណត់នៅក្នុងអនុក្រឹត្យដោយឡែក។

មាត្រា៥៨ .-

សំណុំលិខិតស្នើសុំការអនុញ្ញាតអភិវឌ្ឍអចលនវត្ថុទាំងអស់ ត្រូវសរសេរជាភាសាខ្មែរដែលជាភាសាផ្លូវការ។ ភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាបរទេសផ្សេងទៀត អាចសរសេរនៅខាងក្រោមភាសាខ្មែរ ដែលមានទំហំអក្សរតូចជាងភាសាខ្មែរ។ សំណុំលិខិតស្នើសុំការអភិវឌ្ឍអចលនវត្ថុ ត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេលកំណត់មួយមុនការសម្រេចផ្តល់លិខិតអនុញ្ញាតជូន ដើម្បីទទួលបណ្តឹងតវ៉ានិងធានាទប់ស្កាត់ទំនាស់នៃការប្រើប្រាស់ដី

នីតិវិធីនិងសំណុំឯកសារសម្រាប់ការស្នើសុំការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និង/ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

មាត្រា៥៩ .-

រូបវន្តនិងនីតិបុគ្គលដែលធ្វើអាជីវកម្មលើសេវាបច្ចេកទេស ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែចុះបញ្ជីនិងទទួលការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

នីតិវិធីនិងលក្ខខណ្ឌនៃការវាយតម្លៃនិងការចុះបញ្ជីរូបវន្តបុគ្គលឬនីតិបុគ្គលដែលត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មលើសេវាបច្ចេកទេស ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់

សម្រាប់ការអភិវឌ្ឍដី ការអភិរក្ស និងការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៦០ .-

លិខិតអនុញ្ញាតការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវគោរពតាមផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដែលបានអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការរួច។

ក្នុងករណីពុំទាន់មានផែនការរៀបចំដែនដី ប្លង់គោលនិងផែនការប្រើប្រាស់ដី ដែលបានអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ការផ្តល់លិខិតអនុញ្ញាតការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យនេះនិងបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងសំណង់ពាក់ព័ន្ធ ដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

បទប្បញ្ញត្តិបច្ចេកទេសលម្អិតសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

មាត្រា៦១ .-

គោលការណ៍ យន្តការ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតសាងសង់ជួសជុលនិងរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

ជំពូកទី៩
អធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ

មាត្រា៦២ .-

មន្ត្រីមានសមត្ថកិច្ចដែលចុះធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ ត្រូវអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានគតិយុត្តជាធរមាន ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

មាត្រា៦៣ .-

អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ មានសិទ្ធិនិងភារកិច្ចដូចខាងក្រោម:

- ត្រួតពិនិត្យការអភិវឌ្ឍអចលនវត្ថុនិងសុវត្ថិភាពការងារនៅខាងក្នុងនិងជុំវិញបរិវេណការដ្ឋានសំណង់
- តម្រូវឲ្យម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុផ្តល់ព័ត៌មាននិងបង្ហាញគ្រប់លិខិតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ
- បញ្ជាឲ្យកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ផ្អាកការដ្ឋានសាងសង់ជាបណ្តោះអាសន្ន
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- ហាមឃាត់ជាបណ្តោះអាសន្ននូវការប្រើប្រាស់អគារឬការធ្វើអាជីវកម្មលើអគារ
- បំពេញភារកិច្ចផ្សេងទៀតដែលបានប្រគល់ជូនដោយអាជ្ញាធរធម្មានុរូប។

មាត្រា៦៤ .-

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលមិនសុខចិត្តចំពោះវិធានការបញ្ជាឲ្យកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ ផ្អាកការដ្ឋានសាងសង់ជាបណ្តោះអាសន្ន ឃាត់ទុកជាបណ្តោះអាសន្ននូវសម្ភារៈ ឧបករណ៍ គ្រឿងចក្រ មធ្យោបាយផ្សេងៗដែលមាននៅក្នុងការដ្ឋានសាងសង់ ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ហាមឃាត់ជាបណ្តោះអាសន្ននូវការ

ប្រើប្រាស់អគារ ឬការធ្វើអាជីវកម្មលើអគាររបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ អាចធ្វើបណ្តឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចខាងលើ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី១០
ទណ្ឌកម្ម

មាត្រា៦៥ .-

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការដកហូតលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន
- ការព្យួរ ការដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- ការបង្ខំឲ្យរុះរើនិងស្តារឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្នែកការធ្វើអាជីវកម្មលើអគារ
- ការពិន័យអន្តរការណ៍។

មាត្រា៦៦ .-

ទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា៦៦ខាងលើ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរមានសមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតអភិវឌ្ឍ លិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ លិខិតបើកនិងបិទការដ្ឋាន។

មាត្រា៦៧ .-

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យ ចំពោះអំពើល្មើសដូចមានចែងខាងលើត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរំលត់បណ្តឹងអាជ្ញា។

មាត្រា៦៨ .-

អាជ្ញាធរមានសមត្ថកិច្ចអាចចេញលិខិតព្រមានចំពោះម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ក្នុងករណីដែលមានកំហុសមិនធ្ងន់ធ្ងរក្នុងការអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មាត្រា៦៩ .–

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលធ្វើការអភិវឌ្ឍអចលនវត្ថុដោយគ្មានលិខិតអនុញ្ញាតអភិវឌ្ឍឬសាងសង់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៨០ ០០០(ប្រាំបីម៉ឺន)រៀល សម្រាប់ផ្ទៃក្រឡា១ម៉ែត្រក្រឡានៃផ្ទៃក្រឡាសំណង់ដែលបានសាងសង់រួច ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៤០ ០០០(បួនម៉ឺន)រៀល សម្រាប់ផ្ទៃក្រឡា១ម៉ែត្រក្រឡានៃផ្ទៃក្រឡាសំណង់ដែលបានសាង សង់រួច ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០ ០០០(ពីរម៉ឺន)រៀល សម្រាប់ផ្ទៃក្រឡា១ម៉ែត្រក្រឡានៃផ្ទៃក្រឡាសំណង់ដែលបានសាងសង់រួច ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

បន្ថែមលើការពិន័យអន្តរការណ៍ខាងលើនេះ: ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតសាងសង់ ដើម្បីឲ្យសំណង់ស្របច្បាប់ ដោយកែសម្រួលតាមបទដ្ឋានបច្ចេកទេស។

ករណីកំហុសធ្ងន់ធ្ងរប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងភាពសុខដុមនីយកម្មនៃតំបន់ឬអចលនទ្រព្យជិតខាង ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុត្រូវធ្វើការកែតម្រូវ ឬអាចត្រូវបង្ខំឲ្យរុះរើចេញទាំងស្រុង ដោយម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុទទួលបន្ទុកលើការចំណាយទាំងអស់។

មាត្រា៧០ .–

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍដែលធ្វើការអភិវឌ្ឍអចលនវត្ថុដោយខុសពីលិខិតអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុង០១ម៉ែត្រក្រឡានៃផ្ទៃក្រឡាដែលលើសពីលិខិតអនុញ្ញាតសាងសង់
- ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុងកម្ពស់១ម៉ែត្រដែលលើសនិងចំនួន១០ ០០០(មួយម៉ឺន)រៀលក្នុង១ម៉ែត្រគូបនៃមាឌអគារដែលលើសពីលិខិតអនុញ្ញាតសាងសង់
- ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុងធ្លាគម្លាត១០សង់ទីម៉ែត្រដែលលើស ក្នុងករណីកំហុសដែលខុសធ្លាគម្លាតពីព្រំដីមកអគារពីលិខិតអនុញ្ញាត និង១០ ០០០(មួយម៉ឺន)រៀល ក្នុង១ម៉ែត្រគូបនៃមាឌអគារដែលលើសទាំងអស់ ដោយសារលើសគម្លាត។

បន្ថែមលើការពិន័យអន្តរការណ៍ខាងលើនេះ: ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាត ដើម្បីឲ្យសំណង់ស្របច្បាប់ ដោយកែសម្រួលតាមបទដ្ឋានបច្ចេកទេស។

ករណីកំហុសធ្ងន់ធ្ងរប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងភាពសុខដុមនីយកម្មនៃតំបន់ ឬអចលនទ្រព្យជិតខាង ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុត្រូវធ្វើការកែតម្រូវ ឬអាចត្រូវបង្ខំឲ្យរុះរើ ដោយម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុទទួលបន្ទុកលើការចំណាយទាំងអស់។

មាត្រា៧១ .–

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុឬសាងសង់ ដោយគ្មានលិខិតអនុញ្ញាតបើកការដ្ឋានត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៥០០ ០០០(ប្រាំសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ១០០ ០០០(មួយសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយ ឬច្រើនដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់
- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- បង្ខំឲ្យរុះរើនិងស្តារឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្នែកការធ្វើអាជីវកម្មលើអគារ។

មាត្រា៧២ .-

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុដោយគ្មានលិខិតបិទការដ្ឋានត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៥០០ ០០០(ប្រាំសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ១០០ ០០០(មួយសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្នែកការធ្វើអាជីវកម្មលើអគារ។

មាត្រា៧៣ .-

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុ ដោយប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ៥០០ ០០០(ប្រាំសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ១០០ ០០០(មួយសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ព្យួរឬដកហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់
- បង្ខំឲ្យរុះរើនិងស្តារឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្នែកការធ្វើអាជីវកម្មលើអគារ។

មាត្រា៧៤ .-

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែល៖

ក. មិនព្រមបញ្ឈប់ការដ្ឋានសាងសង់តាមបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចឬមិនប្រើប្រាស់សិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៦៥នៃអនុក្រឹត្យនេះ ឬ

ខ. រារាំងឬប្រកែកមិនព្រមឲ្យសមត្ថកិច្ចជំនាញចូលត្រួតពិនិត្យការដ្ឋានសាងសង់ ឬ

គ. ប្រកែកមិនព្រមផ្តល់ព័ត៌មានឬបង្ហាញលិខិតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុដល់សមត្ថកិច្ចជំនាញក្នុងពេលចុះពិនិត្យការដ្ឋានសំណង់ ឬ

ឃ. ប្រើប្រាស់មធ្យោបាយណាមួយដើម្បីជាឧបសគ្គដល់ការត្រួតពិនិត្យការដ្ឋានសំណង់របស់អង្គភាពជំនាញមានសមត្ថកិច្ច។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ២ ០០០ ០០០(ពីរលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០០ ០០០(ពីរសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់

- ឲ្យរឹបអូសហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ឬវិញ្ញាបនបត្រអភិវឌ្ឍអចលនវត្ថុ
- បង្ខំឲ្យរុះរើនិងស្តារឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

មាត្រា៧៥ .-

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលធ្វើការអភិវឌ្ឍអចលនវត្ថុ ដែលបានធ្វើការផ្ទេរលិខិតអនុញ្ញាតសាងសង់ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ២ ០០០ ០០០(ពីរលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០០ ០០០(ពីរសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់
- ឲ្យរឹបអូសហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់។

មាត្រា៧៦ .-

ក្រុមហ៊ុនសាងសង់ដែលធ្វើអាជីវកម្មម៉ៅការសាងសង់ ដែលមានវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ផុតសុពលភាពត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត៣។

មាត្រា៧៧ .-

ការបង្កឲ្យខូចខាត ប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសុខដុមនីយកម្មនៃតំបន់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសាងសង់កម្រិត៣។

ក្រុមហ៊ុនសាងសង់អាចទទួលរងបន្ថែមនូវទណ្ឌកម្មឲ្យរឹបអូសហូតវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់។

ចាត់ទុកជាការបង្កឲ្យខូចខាត ប៉ះពាល់ដល់សោភណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសុខដុមនីយកម្មនៃតំបន់ នូវករណីដូចខាងក្រោម៖

- ការដ្ឋានសាងសង់ ជួសជុល ឬរុះរើដែលគ្មានរបងហ៊ុមព័ទ្ធ គ្មានសំណាញ់ការពារសុវត្ថិភាពបង្គសំឡេងរំខាន និងគ្មានប៉ាន់ណូសម្រាប់សំគាល់ការដ្ឋានសាងសង់
- ការដ្ឋានសាងសង់ពុំមានឧបករណ៍ការពារសុវត្ថិភាពគ្រប់គ្រាន់ដល់បុគ្គលិក អ្នកបច្ចេកទេសគ្រប់គ្រងការដ្ឋាន និងកម្មករ
- ការបំពុលបង្កឡើងពីការដ្ឋានសាងសង់ ជួសជុល ឬរុះរើ និងការបំពុលបណ្តាលមកពីការធ្វេសប្រហែសធ្វើឲ្យធ្លុះធ្លាយឃ្លាំងស្តុកឧទ្ធារនិងអាងប្រេងឥន្ធនៈ
- ការដ្ឋានសាងសង់ដែលប្រើគ្រឿងចក្រ បរិក្ខារលើកស្ទួច ហើយធ្វើឲ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ឬមិនបានបំពាក់ភ្លើងសញ្ញាសំគាល់នៅពេលយប់

- ការបង្ហូរទឹកបេតុងពីរថយន្តដឹកបេតុងឬពីរថយន្តបូមបេតុង និងទឹកស៊ីម៉ងត៍ដែលបានបង្ហូរចេញពីការដ្ឋានសាងសង់លើចិញ្ចើមផ្លូវថ្នល់ លូសាធារណៈ និងទីតាំងសាធារណៈ
- ការដ្ឋានសាងសង់ដែលគ្មានអ្នកបច្ចេកទេស ឬវិស្វករ ឬស្ថាបត្យករ ជាអ្នកគ្រប់គ្រងនិងទទួលខុសត្រូវ
- ខកខានមិនបានរុះរើ សំអាតនិងអនុវត្តតាមសេចក្តីជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច។

មាត្រា៧៨ .-

ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ដែលមានវិញ្ញាបនបត្រប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ផុតសុពលភាពត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត១
- ៤ ០០០ ០០០(បួនលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត២
- ៣ ០០០ ០០០(បីលាន)រៀល ចំពោះក្រុមហ៊ុនសិក្សាគម្រោងប្លង់កម្រិត៣។

មាត្រា៧៩ .-

អាជ្ញាធរមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការនិងអាចសុំឲ្យរឹបអូសសម្ភារៈ បរិក្ខារ ឧបករណ៍ផ្សេងៗទៀត ដោយអនុលោមតាមនីតិវិធីជាធរមាន ក្នុងករណីបុគ្គលដែលត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

មាត្រា៨០ .-

មន្ត្រីមានសមត្ថកិច្ចណាដែលប្រកែកមិនព្រមទទួលពិនិត្យលើសំណុំលិខិតស្នើសុំការអនុញ្ញាតសាងសង់ ជួសជុល រុះរើ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ដោយគ្មានមូលហេតុត្រឹមត្រូវដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ ប្រសិនបើមាន។

សមត្ថកិច្ចជំនាញនគរូបនីយកម្មនិងសំណង់ឬមន្ត្រីដែលមានភារកិច្ចចុះត្រួតពិនិត្យការដ្ឋានសំណង់ ដែលពុំបានជំទាស់ទៅលើការអភិវឌ្ឍអចលនវត្ថុដែលមិនស្របទៅនឹងលិខិតអនុញ្ញាតសាងសង់ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌប្រសិនបើមាន។

ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល ចំពោះមន្ត្រីជំនាញណាដែលចុះទៅត្រួតពិនិត្យការដ្ឋានសាងសង់ជួសជុល ឬរុះរើ ដោយគ្មានលិខិតបញ្ជាបេសកកម្ម។

ជំពូកទី១១
បទប្បញ្ញត្តិដោយឡែក

មាត្រា៨១ .-

រាល់ការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ ការចេញវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវផ្ទៃកនគរូបនីយកម្មនិងសំណង់ ការចេញលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ការចេញលិខិតបិទការដ្ឋានសាងសង់ និងការផ្តល់លិខិតអនុញ្ញាតគោលការណ៍បច្ចេកទេសលើការអភិវឌ្ឍអចលនវត្ថុនិងការសាងសង់ សេវាបច្ចេកទេសសាងសង់ពិគ្រោះយោបល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យគុណភាពសំណង់ និងសាងសង់ ត្រូវតែបង់កម្រៃសេវានគរូបនីយកម្មនិងសំណង់។

ការគណនាតម្លៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវឈរលើមូលដ្ឋាននៃទំហំផ្ទៃក្រឡាដី ទំហំផ្ទៃក្រឡាសំណង់ និងសន្ទស្សន៍ប្រើប្រាស់ដី និងសំណង់នៃគម្រោងទាំងមូល។

តម្លៃសោហ៊ុយសេវានិងមូលដ្ឋានសម្រាប់គណនា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៨២ .-

ចំណូលកម្រៃសេវាដូចមានចែងក្នុងមាត្រា៦១ខាងលើនេះ ត្រូវបែងចែកមួយផ្នែកចូលថវិការដ្ឋ មួយផ្នែកសម្រាប់គាំទ្រការងារបច្ចេកទេសនគរូបនីយកម្មនិងសំណង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង មួយផ្នែកទៀតសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

ការបែងចែកចំណូលបានមកពីកម្រៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី១២
អន្តរប្បញ្ញត្តិ

មាត្រា៨៣ .-

ការប្រើប្រាស់ដីឬអគារដែលកើតមានមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបានអនុញ្ញាតឲ្យបន្តការប្រើប្រាស់តាមលក្ខខណ្ឌមានស្រាប់នាពេលបច្ចុប្បន្ន ក្នុងករណីដែលមិនបង្កគ្រោះថ្នាក់ឬមហន្តរាយដល់សុខុមាលភាពសាធារណៈ សុវត្ថិភាពសាធារណៈ បរិស្ថាន ប្រវត្តិសាស្ត្រ និងវប្បធម៌។

មាត្រា៨៤ .-

លក្ខខណ្ឌដែលមានចែងក្នុងអនុក្រឹត្យនេះនឹងត្រូវយកទៅអនុវត្តចំពោះតែប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្មដែលបានរៀបចំក្រោយពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

ចំពោះប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម ដែលកំពុងដំណើរការរៀបចំនិងបានរៀបចំហើយ ប៉ុន្តែមិនទាន់បានអនុម័តដាក់ឲ្យប្រើប្រាស់ ត្រូវបានអនុញ្ញាតឲ្យបន្តរៀបចំបញ្ចប់និងដាក់ស្នើសុំការអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ ជាប្លង់បឋមដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវខិតខំជំរុញការរៀបចំបន្តបញ្ចប់ និងដាក់ស្នើសុំការអនុម័ត ឲ្យប្រើប្រាស់ជាផ្លូវការនូវប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និង/ឬប្លង់លម្អិតនគរូបនីយកម្ម នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

ចំពោះគម្រោងអភិវឌ្ឍអចលនវត្ថុនិងសាងសង់ដែលបានដាក់ស្នើសុំលិខិតអនុញ្ញាតមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តនីតិវិធីស្នើសុំ ដោយអនុលោមតាមនីតិវិធីដែលបានធ្វើពីមុន។

ចំពោះគម្រោងអភិវឌ្ឍអចលនវត្ថុនិងសាងសង់ដែលកំពុងដំណើរការអភិវឌ្ឍនិងសាងសង់មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តដំណើរការសាងសង់ ស្របតាមលិខិតអនុញ្ញាតដែលបានចេញជូនម្ចាស់សំណើ។

លិខិតអនុញ្ញាតឲ្យអភិវឌ្ឍអចលនវត្ថុ ដែលបានចេញជូនម្ចាស់សំណើមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវបន្តសុពលភាពអនុវត្តរហូតដល់អស់សុពលភាព។

ជំពូកទី១៣
អវសានប្បញ្ញត្តិ

មាត្រា៨៥ .-

បទប្បញ្ញត្តិដែលមានអានុភាពនៅពេលដែលអនុក្រឹត្យត្រូវបានអនុវត្ត ហើយផ្ទុយនឹងអត្ថន័យនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងអនុក្រឹត្យនេះ។

មាត្រា៨៦ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥
ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
សង្ខានុក្រម

ការអភិវឌ្ឍដី សំដៅដល់ការប្តូរប្រភេទនៃការប្រើប្រាស់ដីទៅជាប្រភេទមួយផ្សេងទៀត តាមរយៈការបង្រួមក្បាលដី ការបំបែកក្បាលដី ការកែទម្រង់ដី និងការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដី សម្រាប់គោលដៅនៃការសាងសង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

ការបង្រួមក្បាលដី សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឲ្យក្លាយទៅជាក្បាលដីតែមួយ ដើម្បីធ្វើផែនការអភិវឌ្ឍទីក្រុង សម្រាប់ធ្វើសមាហរណកម្មនិងធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សេវាសាធារណៈ សំដៅធានាចីរភាព សមធម៌ តុល្យភាព សុខភាព និងភាពងាយស្រួលនៃទីក្រុង។

ការបំបែកក្បាលដី សំដៅដល់ការបំបែកក្បាលដីតែមួយទៅជាក្បាលដីច្រើន សម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

ការកែសម្រួលក្បាលដី សំដៅដល់ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួម ព្រមទាំងបង្កើនលទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

ការប្តូរប្រភេទនៃការប្រើប្រាស់ដី សំដៅដល់ការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

តំបន់លំនៅឋានដាច់គ្នាកម្ពស់ទាប សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដាច់ពីគ្នា ឬជាប់គ្នាមួយចំហៀងដែលមានកម្ពស់ទាប ដូចជា ភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះក្នុងដីឡូត៍ដែលមានធ្លាគម្លាតជុំវិញ អគារស្នាក់នៅ អាគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានជញ្ជាំងជាប់គ្នាដែលមានកម្ពស់ទាប ដូចជា ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់លំនៅឋានកម្ពស់មធ្យម សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់មធ្យម ដូចជា ភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់លំនៅឋានកម្ពស់ខ្ពស់ សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ ដូចជា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់លំនៅឋានចម្រុះ សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានច្រើនប្រភេទ ដូចជា លំនៅឋានជាប់គ្នា លំនៅឋានពាក់កណ្តាលជាប់គ្នា លំនៅឋានដាច់ពីគ្នា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ពាណិជ្ជកម្ម សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មនានា ដូចជាអគារការិយាល័យ ធនាគារ រោងកុន រោងល្ខោន ភោជនីយដ្ឋាន សណ្ឋាគារ ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញ។ល។ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ពាណិជ្ជកម្មចម្រុះ សំដៅដល់តំបន់ដែលមានមុខងារពាណិជ្ជកម្ម សម្រាប់បម្រើដល់លំនៅឋាននិងការស្នាក់នៅ មានដូចជាហាងលក់ដូរនិងទីផ្សារតូចៗដែលលក់ដូរទំនិញនិងសេវាកម្ម ដើម្បីផ្គត់ផ្គង់និងគាំទ្រដល់ការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានប្រចាំថ្ងៃ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ឧស្សាហកម្ម សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតធំដែលមានជាតិពុលខ្ពស់ ដូចជារោងចក្រ រោងសិប្បកម្មខ្នាតធំ ឃ្លាំង យានដ្ឋាន។ល។ ហើយមិនអនុញ្ញាតឲ្យសាងសង់លំនៅឋាននៅតំបន់នេះឡើយ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ឧស្សាហកម្មស្រាល សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតតូចដែលមានជាតិពុលតិច ឬ មធ្យម ដូចជារោងចក្រ រោងសិប្បកម្មខ្នាតតូច ឃ្លាំង យានដ្ឋាន។ល។ ហើយអាចអនុញ្ញាតឲ្យសាងសង់លំនៅឋាននៅតំបន់នេះបាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ឧស្សាហកម្មចម្រុះ សំដៅដល់តំបន់ដែលមានមុខងារចម្រុងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មនិងសេវាកម្ម។ គ្រប់អគាររោងចក្រទាំងអស់ត្រូវបានអនុញ្ញាតឲ្យសាងសង់ លើកលែងតែអគារដែលមានផលប៉ះពាល់បរិស្ថានខ្ពស់។ តំបន់នេះអាចអនុញ្ញាតឲ្យមានលំនៅឋាននិងអគារពាណិជ្ជកម្ម ដូចជា សាលារៀន មន្ទីរពេទ្យ សាកលវិទ្យាល័យ ភោជនីយដ្ឋាន រោងកុន ឃ្លាំង យានដ្ឋាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ចម្រុះ សំដៅដល់តំបន់ដែលអាចប្រើប្រាស់ពហុមុខងារ សម្រាប់លំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្ម ដោយធានាបានបរិស្ថានរស់នៅ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ដឹកជញ្ជូន សំដៅដល់តំបន់ដែលមានមុខងារចម្រុងសម្រាប់សាងសង់អគារហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មបម្រើដល់វិស័យដឹកជញ្ជូននិងគមនាគមន៍ជាអាទិ៍ ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ដ កំពង់ផែ ផែសូត ឃ្លាំង មជ្ឈមណ្ឌលចែកចាយទំនិញ និងតស្ថានភ្នំ មជ្ឈមណ្ឌលទូរគមនាគមន៍។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដី កំណត់ដោយអនុក្រឹត្យនេះ។

តំបន់ទេសចរណ៍ សំដៅតំបន់សម្រាប់សាងសង់អគារបម្រើដល់វិស័យទេសចរណ៍ និងកម្សាន្ត រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។

តំបន់រដ្ឋបាលនិងសេវាសាធារណៈ សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈ ដូចជាទីស្តីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់លំហសាធារណៈនិងផ្ទៃបៃតង សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលំហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់ សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់វប្បធម៌និងសាសនា សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ ដែលបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងសាសនា ដូចជា ប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទាន ពុទ្ធិកសាកលវិទ្យាល័យ។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់កសិកម្ម សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់វិស័យកសិកម្ម ដូចជាវាលស្រែ ចម្ការ សួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ ថ្នាលបណ្តុះកូនឈើ កន្លែងចិញ្ចឹមត្រី បង្ការ ក្តាម សិប្បកម្មបម្រើដល់កសិកម្ម ។ល។ តំបន់នេះអាចសាងសង់លំនៅឋានរបស់កសិករ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

តំបន់ព្រៃឈើ សំដៅដល់តំបន់ផ្ទៃព្រៃឈើនិងគម្របព្រៃឈើ ដែលត្រូវការពារ ថែរក្សា និងដាំបន្ថែម ដូចជាព្រៃស្រោង ព្រៃរបោះ ព្រៃការពារ ព្រៃអភិរក្ស ព្រៃលិចទឹក។ល។

តំបន់ធនធានទឹក សំដៅដល់តំបន់ផ្ទៃទឹកនិងប្រភពទឹកដែលត្រូវថែរក្សានិងការពារ ដូចជាសមុទ្រ ទន្លេ ព្រែក ស្ទឹង អូរ ប្រឡាយ បឹង ទំនប់ សំណង់ធារាសាស្ត្រ។ល។

តំបន់ការពារ សំដៅដល់តំបន់ធម្មជាតិនិងទស្សនីយភាពដែលត្រូវការពារ ដើម្បីបម្រើឲ្យវិស័យបរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ ការអប់រំ និងការកម្សាន្ត ដូចជាឆ្នេរសមុទ្រ ចំណីទន្លេ ភ្នំឧទ្យានជាតិ តំបន់ដីសើម តំបន់ជីវធម្មជាតិ។ល។

ទីក្រុង សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

នគរូបនីយកម្ម សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ដែលមានតំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។

ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី(ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់)ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

ប្លង់លម្អិតនគរូបនីយកម្ម សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុងឬជាគម្រោងអភិវឌ្ឍទីក្រុងដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយឬច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំ ការរចនាទម្រង់ រូបរាង និងសោភណភាព នៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្ម ត្រូវគោរពតាមផែនការប្រើប្រាស់ដី។

ប្លង់ទ្រេត សំដៅដល់ប្លង់សម្រាប់កំណត់កម្ពស់អតិបរមានៃសំណង់។ ប្លង់នេះត្រូវបានកំណត់ឡើងដោយសមាមាត្រនៃទំហំទទឹងផ្លូវនិងការចុយធ្លាគម្លាតនៃអគារជាមួយនឹងកម្ពស់អគារដើម្បីធានាឲ្យមានចរន្តពន្លឺ ចរន្តខ្យល់ និងបរិស្ថានរស់នៅល្អពីអគារមួយទៅអគារមួយទៀត ព្រមទាំងធានាភាពសុខដុមនីយកម្មនៃស្ថាបត្យកម្មក្នុងតំបន់ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ប្រភេទដីអាចសាងសង់បាន សំដៅដល់ប្រភេទដីដែលជំរុញឲ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លំហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ប្រភេទដីកម្រិតការសាងសង់ សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

បទដ្ឋានទំហំដីឡូត៍បច្ចេកទេស សំដៅដល់ទំហំដីឡូត៍ដែលកំណត់ដោយប្រវែងក្បាលដីនិងជម្រៅដី ហើយត្រូវបានកំណត់ឡើង ដើម្បីធានាការរៀបចំ ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធនិងការអភិវឌ្ឍដី ឲ្យមានសោភណភាព មានសណ្តាប់ធ្នាប់។

ផែនការរូបវន្តទីក្រុង សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីធានាការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ក្នុងទីក្រុងឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភណភាព និងសមធម៌។ ផែនការរូបវន្តទីក្រុង មានប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

ផែនការប្រើប្រាស់ដី សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដីតំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ភូមិសាស្ត្រ និងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើ

សមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

ម្ចាស់សំណង់ សំដៅដល់ម្ចាស់សិទ្ធិលើអគារឬសំណង់។

ដង់ស៊ីតេប្រជាជន សំដៅដល់អនុបាតរវាងចំនួនប្រជាជននិងផ្ទៃក្រឡាដី ក្នុងវិសាលភាពជាក់លាក់ណាមួយ។

សំណង់សិល្បការ សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀត ដែលផ្តល់នូវសុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាពដល់ផ្លូវថ្នល់។

សន្នស្សន៍ប្រើប្រាស់ដី សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ ដែលសំណង់នោះតាំងនៅ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ សំដៅដល់រូបវន្តឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ ដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ ស្របតាមសមត្ថកិច្ច។

មន្ត្រីមានសមត្ថកិច្ច សំដៅដល់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា៣0 មាត្រា ៣៤ មាត្រា៣៨ មាត្រា៥0 មាត្រា៧៤ និង មាត្រា៨២ នៃអនុក្រឹត្យ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន

ឆ្នាំ ២០១៥



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ...៣៤..អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៨/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រាមួយ .-

មាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

មាត្រា៣០ .- ថ្មី

កម្ពស់អគារនៅទីក្រុង ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានតំបន់ ប្រភេទអគារ ទំហំដីឡូត៍ ទំហំទទឹងផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលសំណង់នោះតាំងនៅ និងលើលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ភូមិសាស្ត្រ វប្បធម៌ ជាសុកភាព សុខភាព និងសោភណភាព ស្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែងរបស់ខ្លួន និងអនុវត្តតាមវិធីសាស្ត្រណាមួយ ដូចខាងក្រោម៖

១- វិធីសាស្ត្រទី១ : ការកំណត់កម្ពស់ជាម៉ែត្រ ឬ

- អគារកម្ពស់ទាប ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី១១
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ។

២- វិធីសាស្ត្រទី២ : ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ឬ

- ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ដូចមានចែងនៅក្នុងមាត្រា២២ មាត្រា២៦ និងមាត្រា២៨ នៃអនុក្រឹត្យនេះ។

៣- វិធីសាស្ត្រទី៣ : ការកំណត់កម្ពស់តាមប្លង់ទ្រេត ឬ

- អគារកម្ពស់ទាប ត្រូវបានអនុវត្តក្នុងករណីដែលទំហំទទឹងផ្លូវតូចជាងឬស្មើ៩(ប្រាំបួន)ម៉ែត្រ ដោយកម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ក)
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ខ)
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (គ)។

៤- វិធីសាស្ត្រទី៤ : ការកំណត់កម្ពស់អគារ ដោយប្រើប្រាស់វិធីសាស្ត្រខាងលើពីរឬបីរួមគ្នា។

កម្ពស់អតិបរមានិងអប្បបរមាតាមជាន់នីមួយៗនៃអគារ ត្រូវកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ស្របទៅតាមប្រភេទនៃការប្រើប្រាស់អគារ និងតាមទីតាំងភូមិសាស្ត្រ។ ទោះជាយ៉ាងណាកម្ពស់អគារអប្បបរមាសម្រាប់មួយជាន់ៗកំណត់ត្រឹម២,៨ម៉ែត្រ សម្រាប់អគារស្នាក់នៅ។

ប្លង់កម្ពស់អគារនៃរាជធានី និងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ចំនួន (ក) (ខ) និង(គ) នឹងត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ការកំណត់កម្ពស់នៃអគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៤ _ ថ្មី

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវមានគ្រប់គ្រាន់តាមតម្រូវការនៃប្រភេទអគារនីមួយៗ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ និងទីតាំងសាធារណៈ។

ចំនួនចំណតរថយន្តអប្បបរមាសម្រាប់អគារក្នុងដីឡូត៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អគារលំនៅឋានរួមមាន៖

- លំនៅឋានដាច់(ភូមិគ្រឹះ និងពាក់កណ្តាលភូមិគ្រឹះ)	ផ្ទៃក្រឡាកម្រាល១០០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- លំនៅឋានជាប់(ផ្ទះល្វែង និងផ្ទះជាប់គ្នា)	ផ្ទៃក្រឡាកម្រាល១២០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារស្នាក់នៅរួមប្រភេទប្រណីត	ផ្ទៃក្រឡាកម្រាល១០០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារស្នាក់នៅរួមប្រភេទមធ្យម	ផ្ទៃក្រឡាកម្រាល១២០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារស្នាក់នៅរួមប្រភេទធម្មតា	ផ្ទៃក្រឡាកម្រាល១៥០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង។

២- អគារពាណិជ្ជកម្ម រួមមាន៖

- ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន និងភ្លឺបកម្សាន្ត	ផ្ទៃក្រឡាកម្រាល២០ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង
	និងផ្ទៃក្រឡាកន្លែងរាំ១ម²	ត្រូវមានចំណតរថយន្តតូច១កន្លែង

- ផ្សារទំនើប ផ្ទៃក្រឡាកម្រាល៥០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
- ផ្សារ ឬ កន្លែងលក់ដូរ ផ្ទៃក្រឡាកម្រាល៥០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាល៥០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង។

៣- អគារឧស្សាហកម្ម រួមមាន៖

- អគាររោងចក្រ ផ្ទៃក្រឡាកម្រាល២៥០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងក្រឡាផ្ទៃកម្រាល១២៥០ម^{2}ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាល៤០០ម^{2}ត្រូវមានចំណតរថយន្តតូច១កន្លែង និង
  ផ្ទៃក្រឡាកម្រាល២០០០ម^{2}ត្រូវមានចំណតរថយន្តធំ១កន្លែង។

៤- អគារសិក្សាធិការ អប់រំ និងកីឡា រួមមាន៖

- អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាកម្រាល១០០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាកម្រាល២០០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាកម្រាល៣០០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
- មជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាកម្រាល១០០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង។

៥- អគារសុខភាព រួមមាន៖

- អគារមន្ទីរពេទ្យ ផ្ទៃក្រឡាកម្រាល១០០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
- ក្លឹបហាត់ប្រាណនិងសុខភាព ផ្ទៃក្រឡាកម្រាល១២០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង។

៦- អគារសាលមហោស្រព សាលប្រជុំ ពិធី និងរោងភាពយន្ត រួមមាន៖

- អគារមហោស្រព រោងភាពយន្ត
  សាលជួបជុំ និងពិធី ផ្ទៃក្រឡាកម្រាល៣០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងផ្ទៃក្រឡាកម្រាល៣០០ម^{2}ត្រូវមានចំណតរថយន្តធំ១កន្លែង។

៧- អគារសណ្ឋាគារនិងផ្ទះសំណាក់ រួមមាន៖

- អគារសណ្ឋាគារ ចំនួនបន្ទប់៥បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារផ្ទះសំណាក់ ចំនួនបន្ទប់១០បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង។

៨- អគារការិយាល័យសាធារណៈនិងការិយាល័យឯកជន រួមមាន៖

- អគាររដ្ឋបាលនិងការិយាល័យ
  ឯកជន ផ្ទៃក្រឡាកម្រាល ១០០ម^{2}
  ត្រូវមានចំណតរថយន្តតូច១កន្លែង។

៩- ស្ថានីយប្រេងឥន្ធនៈ រួមមាន៖

- ស្ថានីយប្រេងឥន្ធនៈ ផ្ទៃក្រឡាកម្រាល១០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងផ្ទៃក្រឡាកម្រាល១០០ម^{2}ត្រូវមានចំណតរថយន្តធំ១កន្លែង។

១០- អគារការិយាល័យដឹកជញ្ជូន រួមមាន៖

- អគារការិយាល័យដឹកជញ្ជូន ផ្ទៃក្រឡាកម្រាល១០០ម^{2} ត្រូវមានចំណតរថយន្តតូច១កន្លែង
  និងផ្ទៃក្រឡាកម្រាល៥០០ម^{2}ត្រូវមានចំណតរថយន្តធំ១កន្លែង។

១១- អគារផ្សេងៗរួមមាន៖

- អគារផ្សេងៗ ផ្ទៃក្រឡាកម្រាល១៥០ម^2 ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម^{2}ត្រូវមានចំណតរថយន្តធំ១កន្លែង។

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ដែលបានកំណត់ខាងលើនេះ ជាចំនួនអប្បបរមាដែលត្រូវមានជាចាំបាច់ សម្រាប់ការអភិវឌ្ឍនិងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនចំណតនេះត្រូវយកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ក្នុងករណីអគារបម្រើមុខងារចម្រុះ ការគណនាចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវគណនាតាមប្រភេទមុខងារនីមួយៗ ហើយបូកសរុបបញ្ចូលគ្នា ទើបទទួលបានចំនួនចំណតសរុប សម្រាប់អគារទាំងមូល។

ការរៀបចំចំណតយានយន្តនៅទីសាធារណៈនិងឯកជនត្រូវមានចំណតសម្រាប់ជនពិការនិងជនងាយរងគ្រោះ។

បទដ្ឋានចំណតយានយន្ត ទំហំចំណត និងលក្ខណៈបច្ចេកទេសសម្រាប់ចំណតក្នុងដីឡូត៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះបទដ្ឋានកំណត់ទីតាំងចំណតយានយន្តនិងទំហំចំណតសម្រាប់ចំណតសាធារណៈក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការចេញលិខិតអនុញ្ញាតសាងសង់ណាមួយចំពោះប្រភេទអគារខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិចំនួនចំណតអប្បបរមានៃមាត្រា៣៨នេះ។

មាត្រា៣៨ _ ថ្មី

គម្លាតចន្លោះរវាងមហាវិថីមួយទៅមហាវិថីមួយ ឬពីវិថីមួយទៅវិថីមួយ ឬពីផ្លូវមួយទៅផ្លូវមួយ និងទំហំផ្លូវនីមួយៗដូចមានចែងក្នុងមាត្រា៣៧ខាងលើ ត្រូវគោរពតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនិងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៥០ _ ថ្មី

គម្រោងអភិវឌ្ឍក្នុងទីក្រុង រួមមាន៖

១- គម្រោងអភិវឌ្ឍដី ត្រូវបានអនុវត្តក្នុងគោលដៅផ្លាស់ប្តូរប្រភេទនៃការប្រើប្រាស់ដី កែសម្រួលតំបន់ប្រើប្រាស់ដីឡើងវិញ ដើម្បីធ្វើការអភិវឌ្ឍទីក្រុង មានជាអាទិ៍ការបង្រួមក្បាលដីឬការបំបែកក្បាលដី ដោយត្រូវគោរពតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងធានាបាននូវបទដ្ឋានអប្បបរមានៃការប្រើប្រាស់ដី ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងលំហសាធារណៈ ព្រមទាំងលក្ខខណ្ឌបរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ច។

១.១- គម្រោងប្តូរប្រភេទនៃការប្រើប្រាស់ដី ត្រូវបានអនុវត្តដោយការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមមាត្រា៣៣នៃអនុក្រឹត្យនេះ។

១.២- គម្រោងបង្រួមក្បាលដី ត្រូវបានអនុវត្តដោយការបូកញ្ចូលក្បាលដីដែលស្ថិតនៅជាប់គ្នាទាំងអស់ក្នុងក្របខ័ណ្ឌនៃគម្រោង ដើម្បីរៀបចំជាប្លង់ប្រើប្រាស់ដីសមាហរណកម្មមួយសម្រាប់ការអភិវឌ្ឍនិងការសាងសង់ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

១.៣- គម្រោងបំបែកក្បាលដីត្រូវបានអនុវត្តដោយការបំបែកក្បាលដីមួយជាដីឡូត៍បច្ចេកទេសច្រើនសម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី និងហេដ្ឋារចនាសម្ព័ន្ធ។

២- គម្រោងកែសម្រួលក្បាលដី ត្រូវបានអនុវត្តដោយការរៀបចំក្បាលដីឡើងវិញ ដើម្បីធ្វើឲ្យប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លំហសាធារណៈ និងសេវាសាធារណៈ ដោយមានការចូលរួម និងការយល់ព្រមបរិច្ចាគដីពីម្ចាស់ដីឡូត៍ទាំងអស់ ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។

៣- គម្រោងអភិវឌ្ឍទីក្រុងឡើងវិញ ត្រូវបានអនុវត្តនៅតំបន់ណាមួយនៃទីក្រុង ក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនលទ្ធភាពប្រើប្រាស់ដីឲ្យមានប្រសិទ្ធភាពនិងសោភណភាព តាមរយៈការផ្ទេរសិទ្ធិលើដីនិងអគារទៅជាសិទ្ធិលើផ្ទៃក្រឡាកម្រាលអគារថ្មីដែលមានតម្លៃស្មើនៅក្នុងគម្រោងនេះ ដោយមានការចូលរួមនិងយល់ព្រមពីម្ចាស់ដីឡូត៍ ឬតាមតម្រូវការនៃការអភិវឌ្ឍទីក្រុង ស្របតាមច្បាប់។

៤- គម្រោងអភិវឌ្ឍទីតាំងថ្មី ត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែមនូវតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ស្របតាមយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវមុខងាររបស់ទីក្រុងសម្រាប់ការរស់នៅ ការសម្រាកលំហែកម្សាន្ត ការមានការងារធ្វើ និងការធ្វើចរាចរប្រកបដោយសុវត្ថិភាពនិងសោភណភាព។

៥- គម្រោងអភិវឌ្ឍន៍លំនៅឋាន ត្រូវបានអនុវត្តក្នុងគោលបំណងធានាបាននូវសុខភាព ជាសុកភាព សោភណភាព និងសុខដុមរមណីយកម្មសម្រាប់ការស្នាក់នៅ ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ដល់ការស្នាក់នៅ។

៦- គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម ត្រូវបានអនុវត្តក្នុងគោលដៅធានាបាននូវការឯកភាព និងសុខដុមនីយកម្មសម្រាប់ឧស្សាហកម្ម ដោយតម្រូវឲ្យអ្នកប្រើប្រាស់ដីដែលខុសមុខងារនៃតំបន់នេះប្រែមកជាមុខងារដូចគ្នា ដើម្បីជៀសវាងផលប៉ះពាល់ផ្សេងៗដល់សុខភាព។

៧- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានអនុវត្តស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥។ ការធ្វើប្លង់គោលនិងផែនការប្រើប្រាស់ដីសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ត្រូវតែធានាបាននូវបទដ្ឋានអប្បបរមានៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងលំហសាធារណៈ ព្រមទាំងធានាបាននូវការធ្វើសមាហរណកម្មនៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់នេះ ទៅនឹងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ឬផែនការថ្មីនៃទីក្រុង ខេត្ត តំបន់ និងជាតិ។

៨- គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីត្រូវបានអនុវត្តក្នុងគោលដៅបំពេញបន្ថែម ឬបង្កើតថ្មីនូវតម្រូវការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដើម្បីឲ្យឆ្លើយតបនឹងកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីក្រុង ដោយធានាបាននូវសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធសាធារណៈទីក្រុង ខេត្ត តំបន់ និងជាតិ។

៩- គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍ត្រូវបានអនុវត្តក្នុងគោលដៅទាក់ទាញការវិនិយោគវិស័យទេសចរណ៍ និងលើកកម្ពស់គុណភាពសេវាទេសចរណ៍ ស្របតាមគោលនយោបាយ ទេសចរណ៍នៅកម្ពុជា។

១០-គម្រោងចែករំលែកដី ត្រូវបានអនុវត្តក្នុងគោលដៅកែលម្អស្ថានភាព លក្ខខណ្ឌរស់នៅ និងសោភណភាពនៃសហគមន៍ ឲ្យទទួលបានលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាសាធារណៈ សមស្រប។ គម្រោងចែករំលែកដី ត្រូវធ្វើឡើងដោយមានការឯកភាពពីម្ចាស់ដី និង/ឬ សហគមន៍ និងអ្នកវិនិយោគ ក្នុងការចែករំលែកផលប្រយោជន៍គ្នាទៅវិញទៅមក។

១១-គម្រោងអភិវឌ្ឍផ្សេងៗ ត្រូវបានអនុវត្តដើម្បីបំពេញបន្ថែម និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍទីក្រុង ក្នុងគោលបំណងធានាបាននូវសុខភាព ជាសុកភាព សោភណភាព និងសុខដុមនីយកម្ម សម្រាប់ការស្នាក់នៅ។

មាត្រា៦៦ .- ថ្មី

ទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា៦៥ខាងលើ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធរមានសមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតអភិវឌ្ឍ លិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ លិខិតបើកនិងបិទការដ្ឋាន។

មាត្រា៧៤ .- ថ្មី

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែល៖

ក. មិនព្រមបញ្ឈប់ការដ្ឋានសាងសង់តាមបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចឬមិនប្រើប្រាស់សិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៦៤នៃអនុក្រឹត្យនេះ ឬ

ខ. រារាំងឬប្រកែកមិនព្រមឲ្យសមត្ថកិច្ចជំនាញចូលត្រួតពិនិត្យការដ្ឋានសាងសង់ ឬ

គ. ប្រកែកមិនព្រមផ្តល់ព័ត៌មានឬបង្ហាញលិខិតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុដល់សមត្ថកិច្ចជំនាញក្នុងពេលចុះពិនិត្យការដ្ឋានសំណង់ ឬ

ឃ. ប្រើប្រាស់មធ្យោបាយណាមួយដើម្បីជាឧបសគ្គដល់ការត្រួតពិនិត្យការដ្ឋានសំណង់របស់អង្គភាពជំនាញមានសមត្ថកិច្ច។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ២ ០០០ ០០០(ពីរលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ជាតិ
- ១ ០០០ ០០០(មួយលាន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់រាជធានី ខេត្ត
- ២០០ ០០០(ពីរសែន)រៀល ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ។

ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ អាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ដកហូតលិខិតអនុញ្ញាតសាងសង់
- ពុះឬដកហូតវិញ្ញាបនបត្រប្រកបរាជីវកម្មសាងសង់ឬវិញ្ញាបនបត្ររកិវឌ្ឍអចលនវត្ថុ
- បង្ខំឲ្យរុះរើនិងស្តារបនាឡើងវិញឲ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ឬប្រែប្រួលដោយអំពើល្មើស
- ការហាមឃាត់មិនឲ្យប្រើប្រាស់អគារឬផ្អាកការធ្វើអាជីវកម្មលើអគារ។

មាត្រា៨២ .- ថ្មី

ចំណូលកម្រៃសេវាដូចមានចែងក្នុងមាត្រា៨១ខាងលើនេះ ត្រូវបែងចែកមួយផ្នែកចូលថវិការដ្ឋ មួយផ្នែកសម្រាប់គាំទ្រការងារបច្ចេកទេសនគរូបនីយកម្មនិងសំណង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង មួយផ្នែកទៀតសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

ការបែងចែកចំណូលបានមកពីកម្រៃសេវានគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រាពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាចុង _

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៥
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា១២
អនុក្រឹត្យស្តីពីការបង្កើតគណៈ
ទិស្វកររកម្ពុជា

ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :៨០.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា១២ អនុក្រឹត្យលេខ ៤៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការបង្កើតបន្ទាយមានជ័យសោធន៍គណៈវិស្វករកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សា ដែលស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា

- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រាមួយ.-

មាត្រា១២ នៃអនុក្រឹត្យលេខ ៤៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ត្រូវបានធ្វើការកែសម្រួល ដូចតទៅ÷

មាត្រា ១២ថ្មី.-

ការកំណត់ថ្លៃសេវានិងការបែងចែកកម្រៃសេវាជាមួយដៃគូអភិវឌ្ឍ ឬក្រុមហ៊ុនឯកជននានា ត្រូវធ្វើឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រាពីរ.-

ការកំណត់ថ្លៃសេវានិងការបែងចែកកម្រៃសេវាជាមួយដៃគូអភិវឌ្ឍ ឬក្រុមហ៊ុនឯកជននានា ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

មាត្រាបី.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រាបួន.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបួន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ចំណាត់ថ្នាក់សំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ៨៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ចំណាត់ថ្នាក់សំណង់ និងគោលជៅ
ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៨/០២៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងពេលចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រក្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រក្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១ ៖

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដើម្បីការពារទប់ស្កាត់គ្រោះថ្នាក់អគ្គិភ័យ។

មាត្រា២ ៖

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីសមត្ថកិច្ចគ្រប់គ្រង ត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៃសំណង់ និងគោលដៅ ដើម្បីបង្ការ និងការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមពីគ្រោះថ្នាក់អគ្គិភ័យ។

មាត្រា៣ ៖

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើសំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៤ ៖

វាក្យស័ព្ទសំខាន់ៗដែលមានប្រើក្នុងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យត្រូវបានបន្ថែមក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម ៖

- អគ្គិភ័យ សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន។
- ការបង្ការអគ្គិភ័យ សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាពមិនឱ្យមានអគ្គិភ័យកើតឡើង។
- ចំណាត់ថ្នាក់សំណង់ សំដៅដល់សំណង់ដែលត្រូវបានកំណត់ឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងអនុក្រឹត្យនេះ។
- គោលដៅ សំដៅដល់ទីកន្លែងនានា និងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង។
- ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់គំនូរទាំងឡាយដែលត្រូវបានកំណត់យ៉ាងច្បាស់ និងលម្អិតអំពីការបំពាក់ឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់ការបង្ការ និងការពន្លត់អគ្គិភ័យ។

- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុង និងឬក្រៅសំណង់ និងគោលដៅ និងវិធានការនានាដើម្បីបង្ការ ទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ។
- មធ្យោបាយ សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការ និងពន្លត់អគ្គិភ័យ។

ជំពូកទី ២

សមត្ថកិច្ចត្រួតត្រួច និងត្រួតពិនិត្យ

មាត្រា៥ ៖

ក្រសួងមហាផ្ទៃមានសមត្ថកិច្ច៖

- ត្រួតពិនិត្យប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យលើរាល់សំណង់ និងគោលដៅឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស
- ត្រួតពិនិត្យឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់បំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យស្របតាមបទដ្ឋានបច្ចេកទេស
- ត្រួតពិនិត្យទីតាំងស្ថុក ដាក់លក់ឧបករណ៍ សម្ភារៈ បរិក្ខារបង្ការ និងពន្លត់អគ្គិភ័យ
- បញ្ជាក់ទទួលស្គាល់លើគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
- ចេញលិខិតផ្ទាកសកម្មភាពបណ្តោះអាសន្នដល់ផ្នែកណាមួយនៃសំណង់ និងគោលដៅ ដែលខ្វះលក្ខខណ្ឌ និងវិធានការបង្ការ និងពន្លត់អគ្គិភ័យ។

មាត្រា៦ ៖

ចំពោះតម្រូវការត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ រាល់សំណង់ និងគោលដៅដែលជាមូលដ្ឋានកងទ័ព ឬគោលដៅរក្សាការសម្ងាត់ទាក់ទងនឹងសន្តិសុខជាតិ ឬក្នុងស្ថានទូត ស្ថានកុងស៊ុល ស្ថានតំណាងបរទេស និវេសនដ្ឋាន ឬស្ថានតំណាងអង្គការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាមីពាក់ព័ន្ធ។ ក្នុងករណីមានសំណើពីក្រសួងសាមីពាក់ព័ន្ធ អង្គភាពបង្ការ និងពន្លត់អគ្គិភ័យនៃក្រសួងមហាផ្ទៃ អាចជួយគាំទ្រលើផ្នែកបច្ចេកទេសបាន។

មាត្រា៧ ៖

ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មអំណាចដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យរាល់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

មាត្រា៨ ៖

ក្រសួងមហាផ្ទៃ អាចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូជំនាញផ្នែកបច្ចេកទេសប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅលើកកម្ពស់វិជ្ជាជីវៈ និងបច្ចេកទេសនៃការត្រួតពិនិត្យប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។

មាត្រា៩ ៖

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យដែលចុះត្រួតពិនិត្យលើសំណង់ និងគោលដៅ ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន សញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម ជូនម្ចាស់សំណង់ ឬជនដែលខ្លួនត្រូវទំនាក់ទំនង និងត្រូវមានកំណត់ហេតុត្រឹមត្រូវច្បាស់លាស់។

មាត្រា១០ ៖

រយៈពេល និងកម្រៃសេវានៃការផ្តល់លិខិតបញ្ជាក់ទទួលស្គាល់ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បែបបទ និងនីតិវិធីក្នុងការបញ្ជាក់ទទួលស្គាល់ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា១១ ៖

អគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញលិខិតព្រមាន និងពិន័យអន្តរការណ៍ចំពោះម្ចាស់សំណង់ និងម្ចាស់គោលដៅទាំងឡាយណាដែលបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យមិនត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស ឬមិនបានបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

ជំពូកទី ៣
ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

មាត្រា១២ ៖

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវបានកំណត់ចំណាត់ថ្នាក់ដូចខាងក្រោម៖

ក-ចំណាត់ថ្នាក់ទី១ : សំណង់ ឬគោលដៅពាណិជ្ជកម្មទាក់ទងនឹងការផលិត ការលក់ ការកែច្នៃ ការស្តុកស្តានីយប្រេង និងការប្រើប្រាស់ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះ និងងាយផ្ទុះឆេះ។

ខ-ចំណាត់ថ្នាក់ទី២ : ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពរបស់រដ្ឋ គ្រឹះស្ថានសាធារណៈ និងឯកជន។

គ-ចំណាត់ថ្នាក់ទី៣ : សំណង់ ឬគោលដៅនៃទីប្រជុំជនដែលមានប្រជាជនរស់នៅច្រើនកុះករ អគារសហកម្មសិទ្ធិ បុរីលំនៅឋាន ឬលំនៅឋានមានលក្ខណៈបុរី បណ្តុំអគារពាណិជ្ជកម្មធំៗ រោងភាពយន្ត រោងមហោស្រព សារមន្ទីរជាតិ បណ្ណសារជាតិ បណ្ណាល័យជាតិ ទីកន្លែងសប្បាយភាព ភ្ជួបកំសាន្ត ស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍ ស្ថានីយទូរគមនាគមន៍ ក្រុមហ៊ុនគោលដៅស្រាវជ្រាវវិទ្យាសាស្ត្រ អាកាសយានដ្ឋាន ស្ថានីយរាជាយស្ទ័យយាន កំពង់ផែ យានដ្ឋាន និងចំណតយានយន្ត។

ឃ-ចំណាត់ថ្នាក់ទី៤ : សំណង់ ឬគោលដៅដែលស្ថិតនៅតំបន់ភ្នំ តំបន់ព្រៃ តំបន់អភិរក្ស រមណីយដ្ឋាន ស្ថានីយអគ្គិសនី វារីអគ្គិសនី រោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម និងការដ្ឋានរ៉ែ។

ង-ចំណាត់ថ្នាក់ទី៥ : អគារពាណិជ្ជកម្មខ្នាតតូច និងផ្សារ។

មាត្រា១៣ ៖

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ៖

ក-សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលចាប់ពី ៣.០០០(បីពាន់)ម៉ែត្រក្រឡា និង/ឬ មានកម្ពស់ចាប់ពី ៥(ប្រាំ)ជាន់ឡើង ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬផ្ទុកចំនួនមនុស្សចាប់ពី ២០០(ពីររយ)នាក់ និង/ឬចំនួនបន្ទប់ចាប់ពី ២៥(ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តចាប់ពី ១០០(មួយរយ)គ្រឿង។

ខ-ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិតកែច្នៃសាធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះចាប់ពី ១០.០០០(មួយម៉ឺន)លីត្រ និង/ឬ ៥.០០០ (ប្រាំពាន់)គីឡូក្រាមឡើង។

គ-សំណង់សំខាន់ៗក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាន ទេសចរណ៍ និងសាសនា។

មាត្រា១៤ ...

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត៖

ក-សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលក្រោម ៣.០០០(បីពាន់)ម៉ែត្រក្រឡា និង/ឬមានកម្ពស់ ៤(បួន)ជាន់ចុះ ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬផ្ទុកចំនួនមនុស្សក្រោម ២០០(ពីរយ)នាក់ និង/ឬចំនួនបន្ទប់ក្រោម ២៥(ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តក្រោម ១០០(មួយរយ)គ្រឿង

ខ-ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិតកែច្នៃសាធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះក្រោម ១០.០០០(មួយម៉ឺន)លីត្រ និង/ឬ ៥.០០០(ប្រាំពាន់)គីឡូក្រាម។

មាត្រា១៥ ...

ចំពោះសំណង់ និងគោលដៅដែលពាក់ព័ន្ធដល់រោងចក្រ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មដែលបានចំណាត់ថ្នាក់ដូចខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ។

ចំពោះការអនុញ្ញាត ឬបញ្ជាក់ប្លង់សុវត្ថិភាពបច្ចេកទេសឧស្សាហកម្ម និងសិប្បកម្ម ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ជំពូកទី ៤

ភារកិច្ចរបស់ម្ចាស់សំណង់ ឬម្ចាស់គោលដៅ

មាត្រា១៦ ...

ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ត្រូវមានគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មុនដំណើរការសាងសង់។

គំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវបានសិក្សា និងគូរដោយអ្នកជំនាញមានវិជ្ជាជីវៈ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។

ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ចាំបាច់ត្រូវទទួលបានលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

បែបបទ និងនីតិវិធីនៃការស្នើសុំរបស់ម្ចាស់សំណង់ និងម្ចាស់គោលដៅ ដូចមានចែងក្នុងមាត្រា១៦ នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា១៧ ...

ម្ចាស់សំណង់ ឬម្ចាស់គោលដៅមុនការរុះរើ និងជួសជុល កែតម្រូវទៅលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវស្នើសុំលិខិតអនុញ្ញាតពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដូចមានចែងក្នុងមាត្រា១៣ មាត្រា១៨ និងមាត្រា១៩ នៃអនុក្រឹត្យនេះ។

ជំពូកទី ៥

ទោសប្បញ្ញត្តិ

មាត្រា១៨ ..

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្គាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យចំពោះបទល្មើសដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នីតិវិធីនៃការចាត់ចែងប្រាក់ពិន័យដែលបានមកពីការផ្តន្ទាទោសដោយតុលាការ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មាត្រា១៩ ..

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យ រូបណាដែលធ្វេសប្រហែស ខកខាន ឬធ្វើជាភ្លេចភ្លាំង ខ្វះការទទួលខុសត្រូវ មិនបានបំពេញការកិច្ចត្រឹមត្រូវ ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មផ្នែករដ្ឋបាល។ ក្នុងករណីធ្ងន់ធ្ងរត្រូវទទួលទោសតាមច្បាប់ជាធរមាន។

មាត្រា២០ ..

នីតិបុគ្គល ឬរបៀនបុគ្គល ដែលជាម្ចាស់សំណង់ ឬម្ចាស់គោលដៅ មិនគោរពអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យនេះត្រូវ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០.០០០.០០០ (ដប់លាន)រៀល
- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំផ្អាកការសាងសង់ជាបណ្តោះអាសន្ន។

មាត្រា២១ ..

ម្ចាស់សំណង់ និងម្ចាស់គោលដៅ មិនបានអនុវត្តស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដែលមានក្នុងគំនូរប្លង់សាងសង់រួម ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យជាប្រាក់ ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល និងតម្រូវឱ្យធ្វើការកែតម្រូវឱ្យស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យជាមុនសិន។

មាត្រា២២ ..

ម្ចាស់សំណង់ និងម្ចាស់គោលដៅដំណើរការសាងសង់គ្មានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមិនមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវផ្អាកសកម្មភាពជាបណ្តោះអាសន្ន និងត្រូវពិន័យជាប្រាក់មិនលើសពី ១០.០០០.០០០(ដប់លាន)រៀល។

ក្នុងករណីមិនរៀងចាល ត្រូវពិន័យជាប្រាក់ទ្វេដង។

មាត្រា២៣ ..

ម្ចាស់សំណង់ និងម្ចាស់គោលដៅដែលធ្វើការរុះរើ ជួសជុល ឬកែតម្រូវប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ មិនបានសុំការអនុញ្ញាតជាមុន ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនរៀងចាលត្រូវពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល។

មាត្រា២៤ ..

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

ជំពូកទី ៦
អន្តរប្បញ្ញត្តិ

មាត្រា២៥ .-

ក្នុងរយៈពេល ២៤ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់សំណង់ និងម្ចាស់គោលដៅដែលបានសាងសង់រួច ឬកំពុងដំណើរការសាងសង់ពុំមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវមកបំពេញបែបបទស្នើសុំលិខិតបញ្ជាក់ ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ស្របតាមអនុក្រឹត្យនេះ។

ជំពូកទី ៧
អនុសាននប្បញ្ញត្តិ

មាត្រា២៦ .-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា២៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមការកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៦ ខ្មែរ ១៣ កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ចេត្រ ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីសូមមហត្តលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ជូចក្នុងមាត្រា ២៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការព្យួរ និងការដកហូត វិញ្ញាបនបត្រប្រើប្រាស់សំណង់

ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២២៦.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការពួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ ន.ស. ៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- អនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ២២៥អនក្រ.បក ចុះថ្ងៃទី ៣០ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ ..

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការពង្រ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការប្រើប្រាស់សំណង់ ការបូរមុខងារប្រើប្រាស់សំណង់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ និងការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ក្នុងគោលបំណងដើម្បីធានាសន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន។

មាត្រា២ ..

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៣ ..

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់** សំដៅដល់ការងារពិនិត្យ ពិសោធន៍ វិភាគ គណនា និងវាយតម្លៃអំពីគុណភាពនិងសុវត្ថិភាពនៃសំណង់មានស្រាប់ក្នុងដំណាក់កាលនៃការប្រើប្រាស់សំណង់។

២- **ចំណាត់ថ្នាក់សំណង់** សំដៅដល់ការរៀបចំជាប្រភេទ ជាថ្នាក់ឬក្រុមនៃសំណង់ទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗ។

៣- **ការប្រើប្រាស់សំណង់** សំដៅដល់ការប្រើប្រាស់ ការអាស្រ័យផល និងការចាត់ចែងសំណង់។

៤- **ប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** សំដៅដល់ផែនទីប្រើប្រាស់ដីសាធារណៈរបស់រដ្ឋសម្រាប់គ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្ហសាធារណៈ ដែលសិក្សានិងរៀបចំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត តាមបទដ្ឋានបច្ចេកទេសរៀបចំដែនដី និងនគរូបនីយកម្ម និងអនុម័តដោយរដ្ឋបាលរាជធានី ខេត្ត។

៥- **មុខងារប្រើប្រាស់សំណង់** សំដៅដល់គោលបំណងចម្បងនៃការប្រើប្រាស់សំណង់។

៦- **មុខងារសមាសភាគសំណង់** សំដៅដល់មុខងារទាំងឡាយនៃផ្នែកនីមួយៗរបស់សំណង់ ដែលផ្សំគ្នាសម្រាប់បង្កើតមុខងារប្រើប្រាស់សំណង់។

៧- **យន្តការច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

៨- **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

៩- **សំណង់** សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងម៉ូ ស្ថាបត្យការទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

១០- **សំណង់ដែលមានសភាពគ្រោះថ្នាក់** សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

១១- **អគារពហុមុខងារ** សំដៅដល់អគារដែលមានលម្ហតែមួយឬច្រើនដែលអាចបំពេញមុខងារប្រើប្រាស់ច្រើនយ៉ាងនៅពេលខុសៗគ្នា។

១២- **អគារប្រើប្រាស់ចម្រុះ** សំដៅដល់អគារដែលមានផ្នែកផ្សេងៗពីគ្នាហើយផ្នែកទាំងនោះមានមុខងារប្រើប្រាស់ផ្សេងៗគ្នា។

១៣- **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ជំពូកទី២
សមត្ថកិច្ច

មាត្រា៤ ..

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងការប្រើប្រាស់សំណង់គ្រប់ប្រភេទ។

មាត្រា៥ ..

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការពិរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងការប្តូរមុខងារប្រើប្រាស់សំណង់ទៅតាមបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់។

ជំពូកទី៣
លក្ខខណ្ឌនៃការប្រើប្រាស់សំណង់

មាត្រា៦ ..

រាល់ការប្រើប្រាស់សំណង់ ត្រូវមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្នជាមុន លើកលែងតែសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- ប្រើប្រាស់សំណង់ទៅតាមមុខងារប្រើប្រាស់សំណង់
- ប្រើប្រាស់សំណង់ដោយអនុលោមតាមបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសនៃការប្រើប្រាស់សំណង់
- ប្រគល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់របស់ខ្លួនជូនអាជ្ញាធរមានសមត្ថកិច្ចជាទៀងទាត់តាមការកំណត់របស់ច្បាប់ស្តីពីសំណង់
- យកចិត្តទុកដាក់ថែទាំសំណង់និងចាត់ចែងជួសជុលផ្នែកនៃសំណង់ដែលខូចខាត
- រាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចអំពីសភាពគ្រោះថ្នាក់នៃសំណង់។

ម្ចាស់សំណង់មានកាតព្វកិច្ចធានាឱ្យការប្រើប្រាស់ ការអាស្រ័យផល និងការចាត់ចែងសំណង់របស់ខ្លួនគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះ។

មាត្រា៧ ..

មុខងារប្រើប្រាស់សំណង់ ត្រូវកំណត់នៅក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ចំណាត់ថ្នាក់សំណង់តាមមុខងារប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៨ ..

រាល់ការប្តូរមុខងារប្រើប្រាស់សំណង់ទាំងមូលឬដោយផ្នែក ត្រូវមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មីជាមុន លើកលែងតែសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ការប្តូរមុខងារសមាសភាគសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងធ្វើសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម មិនតម្រូវឱ្យមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មីឡើយ។

មាត្រា៩ ..

ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្រោយការងារសាងសង់សំណង់ទាំងមូលត្រូវបានបញ្ចប់ជាស្ថាពរ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់អគារពហុមុខងារ ត្រូវមានកត់ត្រាមុខងារប្រើប្រាស់ទាំងអស់នៃអគារនោះ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់អគារប្រើប្រាស់ចម្រុះ ត្រូវមានកត់ត្រាមុខងារប្រើប្រាស់ទាំងអស់តាមផ្នែកនីមួយៗនៃអគារនោះ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់មានសុពលភាពជាអចិន្ត្រៃយ៍ ទោះបីកម្មសិទ្ធិករនៃសំណង់ត្រូវបានផ្លាស់ប្តូរក៏ដោយ។

នៅពេលមានការផ្ទេរកម្មសិទ្ធិនៃដីឬសិទ្ធិកាន់កាប់ដីដែលសំណង់នោះតាំងនៅ និង/ឬការផ្ទេរកម្មសិទ្ធិនៃសំណង់ឬគម្រោងសាងសង់នោះត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានពីវិញ្ញាបនបត្រប្រើប្រាស់សំណង់ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្ទេរទៅឱ្យកម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់។ ក្នុងករណីនេះ កម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់ អាចស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

ក្នុងករណីវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរឬដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច ការប្រើប្រាស់សំណង់នោះ ត្រូវបានហាមឃាត់។

មាត្រា១០ ..

ម្ចាស់សំណង់អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន ដើម្បីអាចប្រើប្រាស់ផ្នែកនៃសំណង់ដែលបានសាងសង់រួច។

បុគ្គលដែលបានទទួលវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានកាតព្វកិច្ចរៀបចំដំឡើងរបាំងឬមធ្យោបាយផ្សេងទៀត សម្រាប់ខណ្ឌផ្នែកនៃសំណង់ដែលត្រូវបានអនុញ្ញាតឱ្យចូលប្រើប្រាស់ពីផ្នែកនៃសំណង់ដែលមិនទាន់សាងសង់រួចដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់សំណង់។

វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានសុពលភាពត្រឹមថ្ងៃដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានផ្តល់ជូនសម្រាប់សំណង់ទាំងមូល។

មាត្រា១១ ..

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋាន ត្រូវដាក់តាំងបង្ហាញវិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់អ្នកប្រើប្រាស់។

ជំពូកទី៤
លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់

មាត្រា១២ ..

លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែនៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ឬដីដែលកាន់កាប់ដោយស្របច្បាប់ ស្របតាមប្លង់សុរិយោដី ប្លង់លម្អិតនគរូបនីយកម្ម ផែនការប្រើប្រាស់ដី ប្លង់គោលប្រើប្រាស់ដី ឬប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- ការងារសាងសង់ ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើបានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់មានគ្រឿងធ្មឹអាចទ្រាល់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់សំណង់
- សំណង់មានសុវត្ថិភាពអគ្គិភ័យ អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- សំណង់មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាព អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែដោយប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា។

មាត្រា១៣ ..

លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានដូចខាងក្រោម៖

- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែនៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ឬដីដែលកាន់កាប់ដោយស្របច្បាប់ ស្របតាមប្លង់សុរិយោដី ប្លង់លម្អិតនគរូបនីយកម្ម ផែនការប្រើប្រាស់ដី ប្លង់គោលប្រើប្រាស់ដី ឬប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- គ្រឿងធ្មឹសំណង់សំខាន់ៗមានជាអាទិ៍គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ ជញ្ជាំងទ្របន្ទុកនៃសំណង់ទាំងមូលត្រូវបានសាងសង់ ជួសជុល ឬកែប្រែរួចនិងមានសុវត្ថិភាព

- ការងារសាងសង់ ការងារជួសជុល ឬការងារកែប្រែផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន បានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានសុវត្ថិភាពអគ្គិភ័យអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាពអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន ត្រូវបានសាងសង់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា
- ការប្រើប្រាស់ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន អាចអនុញ្ញាតឱ្យការងារសាងសង់ផ្នែកផ្សេងទៀតនៃសំណង់បន្តដំណើរការបានដោយសុវត្ថិភាព។

មាត្រា១៤ ..

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវធ្វើជាភាសាខ្មែរនិងដាក់នៅយន្តការច្រកចេញចូលតែមួយ។

បង្កាន់ដៃទទួលពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនម្ចាស់សំណើតែក្នុងករណីសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់មានលក្ខណៈមិនត្រឹមត្រូវ យន្តការច្រកចេញចូលតែមួយត្រូវស្នើជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើឱ្យធ្វើការកែតម្រូវ។

កំលុងពេលនៃការកែតម្រូវសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថនៃការសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ ។

មាត្រា១៥ ..

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

រាល់ចម្លើយបដិសេធរបស់អាជ្ញាធរមានសមត្ថកិច្ច ចំពោះការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ការមិនសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្នុងរយៈពេលដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាអាជ្ញាធរមានសមត្ថកិច្ចបានផ្តល់ការអនុញ្ញាតដល់ម្ចាស់សំណើដោយតុណ្ហីភាព។ ក្នុងករណីនេះ ការប្រើប្រាស់សំណង់ត្រូវស្របតាមមុខងារប្រើប្រាស់សំណង់ដែលបានកំណត់ក្នុងកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។

មាត្រា១៦ ..

សំណុំឯកសារស្តីពីការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវតម្កល់ទុករហូតដល់ពេលសំណង់នោះត្រូវបានរុះរើទាំងស្រុងនៅ៖

- អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណុំឯកសារស្តីពីវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលគម្រោងប្តង់ស្ថាបត្យកម្មមានតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍។

មាត្រា១៧ ..

អ្នកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំ និងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាពិនិត្យនិងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាពិនិត្យនិងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទនិងបរិបថនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៥
លក្ខខណ្ឌនិងនីតិវិធីនៃការប្តូរមុខងារប្រើប្រាស់សំណង់

មាត្រា១៨ .-

ការស្នើសុំប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវធ្វើឡើងដោយម្ចាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ច អនុញ្ញាតឱ្យប្តូរមុខងារប្រើប្រាស់សំណង់ដោយផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។

ក្នុងករណីការប្តូរមុខងារប្រើប្រាស់សំណង់តម្រូវឱ្យមានការជួសជុល ការកែប្រែ ការដំឡើងបរិក្ខារសំណង់ឬផលិតផលសំណង់ ឬការរុះរើផ្នែកនៃសំណង់ដែលប៉ះពាល់សោភណភាពខាងក្រៅ រចនាសម្ព័ន្ធទ្រទ្រង់ ឬដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើជាមុន និងត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី ក្រោយការងារជួសជុល ការងារកែប្រែ ការងារដំឡើង ឬការងាររុះរើនោះត្រូវបានបញ្ចប់។

មាត្រា១៩ .-

លក្ខខណ្ឌនៃការប្តូរមុខងារប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- សំណង់មានគ្រឿងធ្វើអាចទ្រាល់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់ថ្មីរបស់សំណង់
- ការងារជួសជុល ការងារកែប្រែ ការងារដំឡើង ឬការងាររុះរើសម្រាប់បម្រើមុខងារប្រើប្រាស់ថ្មីបានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់មានសុវត្ថិភាពអគ្គិភ័យចំពោះមុខងារប្រើប្រាស់ថ្មី អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- សំណង់មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាព អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ការងារជួសជុល ការងារកែប្រែ ឬការងារដំឡើងសម្រាប់បម្រើមុខងារប្រើប្រាស់ថ្មីដោយប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា។

មាត្រា២០ ..

បញ្ហត្តិស្តីពីកន្លែងទទួលពាក្យស្នើសុំ ការផ្តល់បង្កាន់ដៃទទួលពាក្យស្នើសុំ ការសម្រេចលើពាក្យស្នើសុំ និងកម្រៃសេវានៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះកន្លែងទទួលពាក្យស្នើសុំ ការផ្តល់បង្កាន់ដៃទទួលពាក្យស្នើសុំ ការសម្រេចលើពាក្យស្នើសុំ និងកម្រៃសេវានៃការប្តូរមុខងារប្រើប្រាស់សំណង់។

បែបបទនិងបរិបថនៃការប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៦

លក្ខខណ្ឌនិងនីតិវិធីនៃការព្យួរនិងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

មាត្រា២១ ..

អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចព្យួរឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះបាន ក្នុងករណីសំណង់នោះលែងមានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

អាជ្ញាធរមានសមត្ថកិច្ច អាចហាមឃាត់ការប្រើប្រាស់សំណង់មួយផ្នែក ដោយមិនព្យួរឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីផ្នែកនៃសំណង់នោះ គ្មានសុវត្ថិភាពក្នុងការប្រើប្រាស់ ហើយផ្នែកដទៃទៀត អាចប្រើប្រាស់បានដោយសុវត្ថិភាព។

មាត្រា២២ ..

អាជ្ញាធរមានសមត្ថកិច្ច ត្រូវព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់បង្ហាញថាសំណង់នោះ ពុំមានសុវត្ថិភាពក្នុងការប្រើប្រាស់។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អំពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយតម្រូវឱ្យម្ចាស់សំណង់ធ្វើការជួសជុល កែប្រែ ឬរុះរើសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អំពីការអនុញ្ញាតឱ្យប្រើប្រាស់សំណង់ឡើងវិញ ក្នុងករណីម្ចាស់សំណង់បានធ្វើការជួសជុល កែប្រែ ឬរុះរើតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។

មាត្រា២៣ ..

អាជ្ញាធរមានសមត្ថកិច្ច អាចដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីណាមួយដូចខាងក្រោម៖

១- សំណង់បានបាត់បង់សុវត្ថិភាពផ្នែកគ្រឿងធ្ងិកម្រិតធ្ងន់ធ្ងរនិងមិនអាចជួសជុល កែប្រែ ឬរុះរើតាមលក្ខណៈបច្ចេកទេសដើម្បីធ្វើឱ្យមានសុវត្ថិភាពឡើងវិញ។

២- សំណង់មានសភាពគ្រោះថ្នាក់កម្រិតធ្ងន់ធ្ងរតាមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់អំពីការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយតម្រូវឱ្យម្ចាស់សំណង់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដូចមានកំណត់ក្នុងអនុក្រឹត្យនេះតាមស្ថានភាពជាក់ស្តែងនីមួយៗ។

បែបបទនិងបរិបថនៃការព្យួរនិងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៧
ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

មាត្រា២៤ ..

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- សម្រាប់សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋាន ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

២- សម្រាប់សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋាន ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

៣- សម្រាប់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់២(ពីរ)ឆ្នាំម្តងយ៉ាងយូរ។

៤- សម្រាប់បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវធ្វើរៀងរាល់១(មួយ)ឆ្នាំម្តងយ៉ាងយូរ។

សម្រាប់សំណង់ដែលមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយ ត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះ។

ចំពោះការអនុញ្ញាតឱ្យប្រើប្រាស់សំណង់ដោយតុណ្ហីភាព ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយ ត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ គិតចាប់ពីថ្ងៃអនុញ្ញាតដោយតុណ្ហីភាពនោះ។

ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៥ ..

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវអនុវត្តដោយ៖

១- ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងមន្ត្រីត្រួតពិនិត្យសំណង់នៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- មន្ត្រីត្រួតពិនិត្យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣- មន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

៤- អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងិសំណង់ ឬអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក។

មាត្រា២៦ ..

មន្ត្រីត្រួតពិនិត្យសំណង់ ត្រូវជ្រើសរើសក្នុងចំណោមថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលជាអ្នកវិជ្ជាជីវៈ និងដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល ផ្នែកភូគព្ភសាស្ត្រ ផ្នែកមេកានិក ផ្នែកអគ្គិសនី ផ្នែកទឹក ឬផ្នែកវិស្វកម្មដទៃទៀត។

មន្ត្រីត្រួតពិនិត្យសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មន្ត្រីត្រួតពិនិត្យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលរាជធានី ខេត្តសាមី។

មន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលក្រុង ស្រុក ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលក្រុង ស្រុក សាមី។

មន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលខណ្ឌ ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលរាជធានីភ្នំពេញ។

គោលការណ៍ បែបបទ និងនីតិវិធីនៃការតែងតាំងមន្ត្រីត្រួតពិនិត្យសំណង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យបានស្របតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

លក្ខណសម្បត្តិ និងលក្ខណវិនិច្ឆ័យសម្រាប់ជ្រើសរើសមន្ត្រីត្រួតពិនិត្យសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៧ ..

រាល់ចំណាយសម្រាប់ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

មាត្រា២៨ ..

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់ មានកាតព្វកិច្ចប្រគល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ជូនអាជ្ញាធរមានសមត្ថកិច្ចយ៉ាងយូរ៣០(សាមសិប)ថ្ងៃក្រោយថ្ងៃផុតកំណត់ ដែលតម្រូវឱ្យអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ HS

មាត្រា២៩ ..

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៨
ការប្រើប្រាស់សំណង់ដែលមានសភាពគ្រោះថ្នាក់

មាត្រា៣០ ..

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យនិងតាមដានរាល់សំណង់ដែលមានសភាពគ្រោះថ្នាក់ ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់របស់ខ្លួន និងធ្វើបច្ចុប្បន្នកម្មបញ្ជីនោះជាប្រចាំ។

មាត្រា៣១ ..

សំណង់ដែលមានសភាពគ្រោះថ្នាក់ មានដូចខាងក្រោម៖

- សំណង់ដែលមានគ្រឿងផ្គុំសំណង់ មិនអាចទ្រាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់សំណង់
- សំណង់ដែលគ្មានសុវត្ថិភាពអគ្គិភ័យ អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- សំណង់ដែលត្រូវបានសាងសង់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលមិនអាចធានាគុណភាពសំណង់និងសុវត្ថិភាពឬសុខភាពរបស់អ្នកប្រើប្រាស់ឬសាធារណជនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬស្តង់ដាកម្ពុជា
- សំណង់ដែលងាយរងគ្រោះថ្នាក់ដោយកត្តាខាងក្រៅដែលបង្កឡើងដោយមនុស្សឬធម្មជាតិមានជាអាទិ៍ ការបាក់ដី ការធ្លាក់ថ្ម ទឹកជំនន់ អគ្គិភ័យ
- សំណង់ដែលមានកត្តាប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកប្រើប្រាស់ ឬសាធារណជនមានជាអាទិ៍ កង្វះអនាម័យ កង្វះខ្យល់ កង្វះពន្លឺ សំណើម ការជ្រាបទឹក ការពុកផុយ។

មាត្រា៣២ ..

កម្មសិទ្ធិករនៃសំណង់ដែលស្ថិតក្នុងបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវផ្តល់កិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តតាមការណែនាំនិងវិធានការបញ្ចៀសគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់និងសាធារណជន។

ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់ដែលស្ថិតក្នុងបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ មានកាតព្វកិច្ចរាយការណ៍អំពីស្ថានភាពនិងការប្រែប្រួលនៃសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់មានជាអាទិ៍ការជូនដំណឹងជាសាធារណៈ ការតម្រូវឱ្យជួសជុលឬកែប្រែសំណង់ ការកម្រិតការប្រើប្រាស់ ការហាមប្រើប្រាស់ ការហ៊ុមព័ទ្ធសំណង់ ការហាមចូល ការកំណត់បរិវេណសុវត្ថិភាព ការជម្លៀស និងការតម្រូវឱ្យរុះរើសំណង់ទាំងមូលឬមួយផ្នែកទៅតាមកម្រិតហានិភ័យនៃគ្រោះថ្នាក់ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

ក្នុងករណីម្ចាស់សំណង់មិនធ្វើការរុះរើសំណង់តាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការរុះរើសំណង់នោះដោយផ្ទាល់ ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

មាត្រា៣៣ ..

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៩
ការប្រើប្រាស់អគារសហកម្មសិទ្ធិនិងសំណង់ក្នុងបុរី

មាត្រា៣៤ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់សម្រាប់អគារសហកម្មសិទ្ធិឬសំណង់នៅក្នុងបុរី លុះត្រាតែចំណែករួមនិងចំណែកឯកជននៃអគារសហកម្មសិទ្ធិឬបុរីនោះ ត្រូវបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដីជាមុន។

បញ្ញត្តិស្តីពីយន្តការនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះយន្តការនិងនីតិវិធីនៃការចុះបញ្ជីចំណែករួមនៃអគារសហកម្មសិទ្ធិ។

មាត្រា៣៥ ..

សម្រាប់គម្រោងអភិវឌ្ឍអគារសហកម្មសិទ្ធិឬបុរី លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន ត្រូវបន្ថែមលក្ខខណ្ឌនៃការបញ្ចប់ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋានមានជាអាទិ៍ ជណ្តើរ ជណ្តើរយន្ត ប្រព័ន្ធអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធទឹកកខ្វក់ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រព័ន្ធលូ ផ្លូវ ប្រព័ន្ធបំភ្លឺសាធារណៈ។

មាត្រា៣៦ ..

ចំពោះអគារសហកម្មសិទ្ធិ វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវផ្តល់សម្រាប់ចំណែកឯកជននីមួយៗ។ វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់ចំណែករួម ត្រូវរក្សាទុកដោយគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិនិងចម្លងជូនសហកម្មសិទ្ធិករទាំងអស់។

ចំពោះបុរី វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវផ្តល់សម្រាប់សំណង់ដែលមានកម្មសិទ្ធិករដោយឡែកៗ។

វិញ្ញាបនបត្រប្រើប្រាស់សំណង់សម្រាប់ចំណែករួមឬកម្មសិទ្ធិអវិភាគ ត្រូវរក្សាទុកដោយគណៈកម្មការគ្រប់គ្រងបុរី ព្រមទាំងចម្លងជូនកម្មសិទ្ធិករទាំងអស់នៅក្នុងបុរី។

មាត្រា៣៧ ..

ការប្រើប្រាស់អគារសហកម្មសិទ្ធិនិងសំណង់នៅក្នុងបុរី ត្រូវអនុលោមតាមបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិឬបុរី និងតាមបទដ្ឋានគតិយុត្តជាធរមាន។

ការប្រើប្រាស់ចំណែករួមនិងចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិនិងការគ្រប់គ្រងបុរី។

បែបបទនិងនីតិវិធីនៃការគ្រប់គ្រងការប្រើប្រាស់អគារសហកម្មសិទ្ធិនិងសំណង់នៅក្នុងបុរី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៨ ..

ម្ចាស់នៃចំណែកឯកជនទាំងអស់នៃអគារសហកម្មសិទ្ធិនិងកម្មសិទ្ធិករទាំងអស់នៃបុរី ត្រូវទទួលបន្ទុករួមគ្នាទៅតាមសមាមាត្រនៃផ្ទៃក្រឡាកម្រាលសំណង់របស់ចំណែកឯកជននីមួយៗ ឬផ្ទៃក្រឡាដីឡូត៍ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត ចំពោះរាល់ចំណាយលើការងារសម្រាប់ចំណែករួមដូចខាងក្រោម៖

- ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់
- ការងារជួសជុល ការងារកែប្រែសំណង់ តាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច
- ការងាររុះរើសំណង់មួយផ្នែកឬសំណង់ទាំងមូលដើម្បីអនុវត្តវិធានការរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ចៀសគ្រោះថ្នាក់។

សមាមាត្រគិតជាភាគរយនៃចំណាយសម្រាប់ចំណែករួម ដែលម្ចាស់ចំណែកឯកជននីមួយៗនៃអគារសហកម្មសិទ្ធិនិងកម្មសិទ្ធិករទាំងអស់នៃបុរីត្រូវទទួលខុសត្រូវ ត្រូវកំណត់ជាមុនដោយបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិឬបុរីនោះ។

ជំពូកទី១០
ការប្តឹងតវ៉ា

មាត្រា៣៩ ..

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

ជំពូកទី១១
ទណ្ឌកម្ម

មាត្រា៤០ ..

ទណ្ឌកម្មក្នុងអនុក្រឹត្យនេះរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ

- ការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ការហាមឃាត់ការចាត់ចែងនិងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់
- ការហាមឃាត់ការប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋាន
- ការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម
- ការពិន័យអន្តរការណ៍។

មាត្រា៤១ ..

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងការហាមឃាត់ការប្រើប្រាស់ ការចាត់ចែង ឬការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់ជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចទៅតាមបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ច អាចផ្សាយការព្រមាន ការព្យួរ ឬការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ជាសាធារណៈនៅក្នុងសារព័ត៌មានឬតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ការហាមឃាត់ការប្រកបអាជីវកម្ម និងការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធតាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

មាត្រា៤២ ..

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះបុគ្គលដែលបានប្រព្រឹត្តន្ូវអំពើណាមួយដូចខាងក្រោម៖

- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅលំនៅឋានមិនត្រឹមត្រូវតាមមុខងារប្រើប្រាស់សំណង់ដូចមានកំណត់ក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់មិនអនុលោមតាមបទដ្ឋានគតិយុត្តឬបទដ្ឋានបច្ចេកទេសនៃការប្រើប្រាស់សំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ដោយមិនបានប្រគល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពលើសំណង់របស់ខ្លួនជូនអាជ្ញាធរមានសមត្ថកិច្ចតាមការកំណត់របស់ច្បាប់ស្តីពីសំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅអាជីវកម្មដោយមិនបានយកចិត្តទុកដាក់ក្នុងការចាត់ចែងថែទាំឬជួសជុលផ្នែកនៃសំណង់ដែលខូចខាត។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចេញលិខិតព្រមានជូនទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ដោយតម្រូវឱ្យគោរពតាមបទដ្ឋានគតិយុត្តជាធរមានឬតម្រូវឱ្យធ្វើការជួសជុល កែប្រែ និង/ឬ រុះរើសំណង់ឬផ្នែកនៃសំណង់ដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់។

មាត្រា៤៣ ..

ត្រូវព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់រយៈពេលមិនលើសពី៣(បី)ខែ ចំពោះអំពើល្មើសណាមួយដូចខាងក្រោម៖

- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋានខុសពីមុខងារប្រើប្រាស់សំណង់ ដូចមានកំណត់ក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ខុសពីការណែនាំដូចមានកំណត់ក្នុងលិខិតព្រមានរបស់អាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់អំពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយតម្រូវឱ្យធ្វើការជួសជុល កែប្រែ និង/ឬ រុះរើសំណង់ឬផ្នែកនៃសំណង់ដែលពុំមានសុវត្ថិភាពក្នុងការប្រើប្រាស់។

ក្នុងកំលុងពេលដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរ ការប្រើប្រាស់សំណង់ឬការធ្វើអាជីវកម្មនៅក្នុងសំណង់នោះ ត្រូវបានហាមឃាត់។

បុគ្គលដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងកំលុងពេលដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះត្រូវបានព្យួរ ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីសំណង់។ ក្នុងករណីនេះ មន្ត្រីអធិការកិច្ចសំណង់ត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

មាត្រា៤៤ ..

ត្រូវដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំពោះការមិនអនុវត្តតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចដូចមានកំណត់ក្នុងលិខិតជូនដំណឹងស្តីពីការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់អំពីការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយបញ្ជាក់អំពីមូលហេតុ វិធានការ និងការតម្រូវនានា ដើម្បីធានាសុវត្ថិភាពម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណជន។

មាត្រា៤៥ ..

ត្រូវហាមឃាត់ការចាត់ចែង ការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់ ការប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋាន ឬការផ្សព្វផ្សាយពាណិជ្ជកម្ម ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់
- សំណង់ដែលម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ មិនបានអនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច
- សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរឬដកហូត។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់អំពីការហាមឃាត់ដោយបញ្ជាក់អំពីមូលហេតុនិងការតម្រូវនានា ដើម្បីធានាសុវត្ថិភាពម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណជន។

មាត្រា៤៦ ..

ត្រូវពិន័យអន្តរការណ៍ ចំពោះបុគ្គលដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានន្លូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ជាប្រាក់ចំនួនដូចខាងក្រោម៖

- ៨០ ០០០ ០០០ (ប៉ែតសិបលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ២០ ០០០ ០០០ (ម្ភៃលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ២ ០០០ ០០០ (ពីរលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលបុគ្គលល្មើសធ្លាប់ទទួលរងន្លូវការពិន័យអន្តរការណ៍ម្តងរួចហើយ ប៉ុន្តែនៅបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

មាត្រា៤៧ ..

ត្រូវពិន័យអន្តរការណ៍ ចំពោះបុគ្គលដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋានដោយខុសពីមុខងារប្រើប្រាស់សំណង់ដូចមានកំណត់នៅក្នុងវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះ ជាប្រាក់ចំនួនដូចខាងក្រោម៖

- ៤០ ០០០ ០០០ (សែសិបលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ១០ ០០០ ០០០ (ដប់លាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ១ ០០០ ០០០ (មួយលាន)រៀល សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលបុគ្គលល្មើសធ្លាប់ទទួលរងន្លូវការពិន័យអន្តរការណ៍ម្តងរួចហើយ ប៉ុន្តែនៅបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

មាត្រា៤៨ ..

ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវដំឡើងជាពីរដង។ ករណីការខកខានបង់ប្រាក់ពិន័យអន្តរការណ៍លើសពី ៦០(ហុកសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាបីដង។ ករណីការខកខានបង់ប្រាក់ពិន័យអន្តរការណ៍ផុតរយៈពេល៩០(កៅសិប)ថ្ងៃ មន្ត្រីអធិការកិច្ចសំណង់ ត្រូវចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

មាត្រា៤៩ ..

បុគ្គលដែលក្លែងបន្លំឯកសារឬផ្តល់ព័ត៌មានមិនពិតដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីទទួលបានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្លែងបន្លំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

មាត្រា៥០ ..

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬបដិសេធផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី១២
អន្តរប្បញ្ញត្តិ

មាត្រា៥១ ..

លិខិតបិទការដ្ឋានសំណង់ដែលបានផ្តល់មុនអនុក្រឹត្យនេះចូលជាធរមាន មានតម្លៃស្មើនឹងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ចំពោះសំណង់ដែលមានលិខិតបិទការដ្ឋានសំណង់រួចហើយ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយ ត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន។

មាត្រា៥២ ..

ចំពោះសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់និងដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ប៉ុន្តែមិនទាន់មានលិខិតបិទការដ្ឋានសំណង់ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមគោលការណ៍ដូចមានចែងក្នុងមាត្រា១០៦នៃច្បាប់ស្តីពីសំណង់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ក្នុងករណីនេះ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់លើកទីមួយត្រូវអនុវត្តក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

មាត្រា៥៣ ..

ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន អាចអនុវត្តផងដែរដោយ៖

១- អ្នកវិជ្ជាជីវៈដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្តង់ផ្នែកគ្រឿងធ្មឹសំណង់។

២- អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្តង់សំណង់ផ្នែកគ្រឿងធ្មឹសំណង់។

៣- ក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្តង់។

៤- ក្រុមហ៊ុនដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្តង់សំណង់ទូទៅឬផ្នែកគ្រឿងធ្ងុំសំណង់។

ជំពូកទី១៣
អវសានប្បញ្ញត្តិ

មាត្រា៥៤ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥៥ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ ពោច ខែ បឋមៈ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា៥៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
លិខិតអនុញ្ញាតសាងសង់

ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

លិខិតអនុញ្ញាតសាងសង់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីសមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធី ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ក្នុងគោលបំណង ដើម្បីៈ

- ធានាគុណភាព សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- ធានាការងារសាងសង់ឬរុះរើឱ្យត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់ ដើម្បីរក្សាសោភណភាព បរិស្ថានល្អ និងសណ្តាប់ធ្នាប់សាធារណៈ
- ការពារដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- ធានាគុណភាពនិងភាពត្រឹមត្រូវនៃការរៀបចំដែនដីនិងនគរូបនីយកម្ម
- បង្ការនិងទប់ស្កាត់វិវាទក្នុងការងារសាងសង់ឬរុះរើ
- បង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

មាត្រា២ .-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៣ ..

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១. **ការងារដី** សំដៅដល់ការងារកែប្រែរចនាសម្ព័ន្ធដីដែលបម្រើដល់ការងារសាងសង់ មានជាអាទិ៍ ការងារឈូសឆាយដី ការងារជីកដី ការងារចាក់បំពេញដី ការងារបង្ហាប់ដី ការងារពង្រឹងគុណភាពដី។

២. **ការងារដំឡើង** សំដៅដល់ការងារដំឡើងផលិតផលសំណង់ឬការងារបំពាក់បរិក្ខារសំណង់ភ្ជាប់ទៅនឹងផ្នែកនៃសំណង់ មានជាអាទិ៍គ្រឿងផ្គុំសំណង់ ជញ្ជាំង ដំបូលនៃសំណង់សម្រាប់ការប្រើប្រាស់ជាបណ្តោះអាសន្នឬជាប់លាប់។

៣. **ការងារសាងសង់សំណង់ថ្មី** សំដៅដល់ការងារសាងសង់ដែលចាប់ផ្តើមពីការងារដីឬការងារគ្រឹះ ការងារគ្រឿងផ្គុំ ការងារជញ្ជាំង ការងារដំឡើងរហូតដល់ការងារបង្ហើយដើម្បីបង្កើតសំណង់ថ្មីមួយ។

៤. **គ្រឿងផ្គុំសំណង់** សំដៅដល់រចនាសម្ព័ន្ធរបស់សំណង់ មានជាអាទិ៍គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ ជណ្តើរ ជញ្ជាំងទ្របន្ទុក គ្រឿងផ្គុំដំបូល និងគ្រឿងផ្គុំផ្សេងទៀតដែលមានមុខងារទ្របន្ទុក។

៥. **ជញ្ជាំងទប់ដី** សំដៅដល់សំណង់ឬសិល្បការ ដែលសាងសង់សម្រាប់ទប់ការរអិលដី ការបាក់ដី ឬសម្ភាធដីផ្សេងទៀតនិងដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬសំណង់ការងារទឹក។

៦. **ឋបនីយភណ្ឌ** សំដៅដល់គ្រឿងផ្គុំឬគ្រឿងឧបករណ៍ សម្ភារៈ បរិក្ខារដែលតម្កល់ទុកវត្ថុឬផលិតផលគ្រឿងឆេះដែលអាចបង្កអគ្គិភ័យផ្សេងៗជាយថាហេតុ និងដែលត្រូវទុកដាក់ឱ្យបានល្អ។

៧. **ផ្ទៃក្រឡាកម្រាលសំណង់** សំដៅដល់ផ្ទៃក្រឡាកម្រាលសំណង់ដែលធ្វើការសាងសង់។

៨. **មន្ត្រីមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៩. **មុខងារសមាសភាគសំណង់** សំដៅដល់មុខងារទាំងឡាយនៃផ្នែកនីមួយៗរបស់សំណង់ដែលផ្សំគ្នាសម្រាប់បង្កើតមុខងារប្រើប្រាស់សំណង់។

១០. **យន្តការច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

១១. **លិខិតបញ្ជាក់អនុលោមភាព** សំដៅដល់លិខិតចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដើម្បីបញ្ជាក់អំពីអនុលោមភាពនៃសំណង់ឬការងារសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

១២. **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

១៣. **សលាកបត្រក្បាលដី** សំដៅដល់ឯកសារផ្តល់ដោយរដ្ឋបាលសុរិយោដី ដែលមានបង្ហាញកម្មសិទ្ធិករនៃដី ទីតាំងនៃដី និយាមកាចំណុចព្រំដី និងទំហំនៃដី។

១៤. **សៀវភៅបន្ទុក** សំដៅដល់កម្រងឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការអនុវត្តការងារសាងសង់ ឬរុះរើ មានជាអាទិ៍ផែនការការងារ សេចក្តីណែនាំបច្ចេកទេស វិធីសាស្ត្រ និងឯកសារបច្ចេកទេសដទៃទៀត។

១៥. **សំណង់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ** សំដៅដល់សំណង់ជាកេរដំណែលបន្សល់ទុកពីមនុស្សជំនាន់មុនដែលមានចរិតវិទ្យាសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រ បុរាណវិទ្យា សិល្បៈ សាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ និងដែលបានចុះបញ្ជីសារពើភណ្ឌ បេតិកភណ្ឌស្របតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌។

១៦. **សំណង់មិនមែនអគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីឬអចលនវត្ថុដទៃទៀតសម្រាប់ទ្រទ្រង់កដែលត្រូវបានសិក្សាឡើងមិនមែនសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍បង្គោលអង់តែនទូរសព្ទ បង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍ សំណង់ពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មភាពផ្នែកដោនស្ត្រីម បង្គោលអគ្គិសនី ដងទង់ ប៉ម ខ្លោងទ្វារ អាងស្តុកទឹកខ្ពស់ពីដី ស្តូប បដិមា កន្ត្រកវិល។

១៧. **សំណង់លំនៅឋាន** សំដៅដល់សំណង់ដែលមានមុខងារប្រើប្រាស់ជាទីលំនៅអចិន្ត្រៃយ៍។

១៨. **អគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីសម្រាប់ទ្រទ្រង់កដែលត្រូវបានសិក្សាឡើងសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍សំណង់លំនៅឋាន សណ្ឋាគារ អគារការិយាល័យ មន្ទីរពេទ្យ អគារសិក្សា បណ្ណាល័យ រោងភាពយន្ត សារមន្ទីរ សាលមហោស្រព ផ្សារ រោងចក្រ ស្ថានីយអ្នកដំណើរ។

១៩. **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២០. **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងធ្មឹសំណង់ គម្រោងប្លង់រុះរើ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក លិខិតបញ្ជាក់អនុលោមភាព វិញ្ញាបនបត្រប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ឯកសារសិក្សាសមិទ្ធិលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត។

ជំពូកទី២
សមត្ថកិច្ច

មាត្រា៤ .-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងសំណង់គ្រប់ប្រភេទ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ប្លែកផ្ទៃក្រឡាកម្រាលសំណង់ថ្មី សរុបលើសពី៣ ០០០ (បីពាន់)ម៉ែត្រក្រឡា
- អគារដែលមានកម្ពស់ខ្ពស់ជាង១១(ដប់មួយ)ជាន់ឡើងទៅរួមទាំងជាន់ផ្ទាល់ដី
- សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង៥(ប្រាំ)ម៉ែត្រ
- ជញ្ជាំងទប់ដីដែលមានកម្ពស់ខ្ពស់ជាង៥(ប្រាំ)ម៉ែត្រ
- ឋបនីយភណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យដូចជាស្ថានីយឬដេប៉ូស្តុក លក់ ឬចែកចាយប្រេងឥន្ធនៈ ឧស្ម័ន ឬផលិតផលតេលសិលាដទៃទៀត ពោងឬស៊ីទែនស្តុកប្រេងឥន្ធនៈ ឧស្ម័ន សារធាតុងាយឆេះ ឬផលិតផលតេលសិលាដទៃទៀត និងរោងជាងដែលមានផលិតផលងាយឆេះ
- អាងតម្កល់ឬស្តុកទឹកដែលមានកម្ពស់ខ្ពស់ជាង១៥(ដប់ប្រាំ)ម៉ែត្រ ឬមានចំណុះលើសពី៥០(ហាសិប)ម៉ែត្រគុប
- សំណង់សម្រាប់បម្រើវិស័យកីឡា ទេសចរណ៍ និងវប្បធម៌ មានជាអាទិ៍ពហុកីឡដ្ឋាន ទីលានវាយកូនហ្គោល ទីលានកីឡាប្រណាំង សួនកម្សាន្ត អាងហែលទឹក សារមន្ទីរ សាលមហោស្រព សាលសន្និសីទ រោងភាពយន្ត
- សំណង់នៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ឬតំបន់ការពារផ្សេងទៀត
- អគារ ប៉ម ឬសំណង់នៅក្នុងស្ថានីយអ្នកដំណើរតាមរថយន្ត ស្ថានីយអាយស្ព័យយាន កំពង់ផែ អាកាសយានដ្ឋាន និងស្ថានីយវារីអគ្គិសនី ដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬផ្នែកនៃសំណង់ការងារទឹក
- សំណង់អគារ ប៉ម ឬខ្លោងទ្វារនៅតាមច្រកទ្វារអន្តរជាតិ
- បង្គោលអង់តែនទូរសព្ទនិងបង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ខ្ពស់ជាង៣០(សាមសិប)ម៉ែត្រ។

មាត្រា៥ ..

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ១១(ដប់មួយ)ជាន់រួមទាំងជាន់ផ្ទាល់ដី ដោយគ្មានឬមានជាន់ក្រោមដីក្នុង

ជម្រៅរាក់ជាងឬស្មើ៥(ប្រាំ)ម៉ែត្រ លើកលែងសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ ឬកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី៥០០(ប្រាំរយ)ម៉ែត្រក្រឡា និងតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- របងថ្មឬបេតុងដែលមានកម្ពស់ខ្ពស់ជាង៣(បី)ម៉ែត្រ
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ទាបជាងឬស្មើ៣០(សាមសិប)ម៉ែត្រ។

មាត្រា៦ ..

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារដូចខាងក្រោម៖

- សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ៤(បួន)ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី
- ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ឬកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា
- របងថ្មឬបេតុងដែលមានកម្ពស់ទាបជាងឬស្មើ៣(បី)ម៉ែត្រ។

មាត្រា៧ ..

រាជរដ្ឋាភិបាលឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យសាងសង់ឬរុះរើ ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលជាការសម្ងាត់របស់ជាតិ មានជាអាទិ៍សំណង់សម្រាប់បោះពុម្ពរូបិយបណ្ណ តម្កល់ និងរក្សាទុករូបិយវត្ថុ
- សំណង់សម្រាប់បម្រើដល់សន្តិសុខជាតិនិងការការពារជាតិ មានជាអាទិ៍សំណង់លេណដ្ឋាន ឃ្លាំងស្តុកអាវុធនិងគ្រឿងយុទ្ធភណ្ឌ និងសំណង់បម្រើដល់ការប្រយុទ្ធ។

ជំពូកទី៣

គោលការណ៍ទូទៅនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់

មាត្រា៨ .-

រាល់ការសាងសង់ឬរុះរើ ត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច លើកលែងតែការងារមួយចំនួនដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ។

រាល់ចម្លើយបដិសេធរបស់អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច ចំពោះការស្នើសុំលិខិតអនុញ្ញាត ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ការមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត ក្នុងរយៈពេលដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច បានផ្តល់ការអនុញ្ញាតដល់ម្ចាស់សំណើដោយតុណ្ហីភាព។

សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានពីលិខិតអនុញ្ញាតដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្ទេរទៅឱ្យកម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់ នៅពេលមានការផ្ទេរកម្មសិទ្ធិនៃដីឬសិទ្ធិកាន់កាប់ដី និង/ឬការផ្ទេរកម្មសិទ្ធិនៃសំណង់ឬគម្រោងសាងសង់នោះត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីជាធរមាន។

មាត្រា៩ .-

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់លិខិតអនុញ្ញាត អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចនោះ ត្រូវចេញលិខិតជូនដំណឹងនិងតម្រូវឱ្យម្ចាស់សំណើមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនវិញ។

ក្នុងករណីម្ចាស់សំណើមិនមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនក្នុងរយៈពេល ៣០(សាបសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច អាចសម្រេចមិនរក្សាទុកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតនោះបាន។

មាត្រា១០ .-

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវយកទៅដាក់នៅ៖

១. ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់លិខិតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត សម្រាប់លិខិតផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣. ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់លិខិតផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

បង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត អាចផ្តល់ជូនម្ចាស់សំណើតែក្នុងករណីសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់។

ក្នុងករណី សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មានលក្ខណៈមិនត្រឹមត្រូវ យន្តការច្រកចេញចូលតែមួយ ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើឱ្យធ្វើការកែតម្រូវ។

កំលុងពេលនៃការកែតម្រូវសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថនៃការសម្រេចលើពាក្យស្នើសុំឡើយ។

មាត្រា១១ .-

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំនិងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា១២ .-

សំណុំឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវតម្កល់ទុករយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំនៅ៖

- អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះលិខិតអនុញ្ញាតផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះលិខិតអនុញ្ញាតផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណុំឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដែលគម្រោងប្តង់ស្ថាបត្យកម្មមានតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍។

ជំពូកទី៤
លិខិតអនុញ្ញាតសាងសង់

មាត្រា១៣ .-

មានតែកម្មសិទ្ធិករនៃដីនិងអ្នកដែលបានកាន់កាប់ដីស្របច្បាប់ ទើបអាចអនុញ្ញាតឱ្យសាងសង់សំណង់នៅលើដីនោះបាន។

ការងារសាងសង់ មិនអាចអនុញ្ញាតនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់បានឡើយ។

មាត្រា១៤ .-

ការងារសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិត ឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីការងារសាងសង់នោះអនុវត្តនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់ក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

មាត្រា១៥ .-

សំណង់ដែលការងារសាងសង់មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ មានដូចខាងក្រោម៖

- សំណង់អគារផ្ទាល់ដីដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើដោយមានកម្រាលខណ្ឌធ្វើពីឈើ ផ្ទះតៀមធ្វើពីឈើឬថ្ម នៅទីជនបទឬស្រែចម្ការ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១០០(មួយរយ)

ម៉ែត្រក្រឡា មានកម្ពស់ទាបជាងឬស្មើ៥(ប្រាំបួន)ម៉ែត្រ និងមិននៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ

- សំណង់មិនមែនបេតុងដែលសាងសង់ផ្ទាល់ដីសម្រាប់ប្រើប្រាស់ជាបណ្តោះអាសន្ន មានជាអាទិ៍ បង្គោល ដងទង់ វេទិកា រោង តូប ឬគ្រឿងផ្គុំដទៃទៀតសម្រាប់ប្រារព្ធពិធីផ្សេងៗ
- សំណង់នៅក្នុងបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ២០(ម្ភៃ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រ
- របងដែលមិនធ្វើអំពីថ្មឬបេតុង។

មាត្រា១៦ .-

ការងារកែប្រែដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រុបន្ទុក គ្រឿងផ្គុំសំណង់ និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ មានជាអាទិ៍ៈ

- ការប្តូរពណ៌ផ្ទៃកខាងក្នុង
- ការប្តូរទ្រង់ទ្រាយផ្ទៃកខាងក្នុងនៃសំណង់ ដូចជាបង្កាន់ដៃសុវត្ថិភាព ពិតានដែលមិនធ្វើពីបេតុងដែក ជញ្ជាំងខណ្ឌបន្ទប់ដែលមិនទ្រុបន្ទុក
- ការប្តូរមុខងារសមាសភាគសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងផ្គុំសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម។

មាត្រា១៧ .-

មុននឹងធ្វើការសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា១៨ .-

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ និងត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិឬសិទ្ធិកាន់កាប់ស្របច្បាប់នៃដីដែលសំណង់តាំងនៅ សលាកបត្រក្បាលដី គម្រោងប្លង់ស្ថាបត្យកម្ម និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់។

មាត្រា១៩ .-

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយ

នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ២៥(ម្ភៃប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

មាត្រា២០ .-

លិខិតអនុញ្ញាតសាងសង់ អស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតសាងសង់នោះ។

ក្នុងករណីម្ចាស់សំណង់បានទទួលលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រយៈពេលនៃសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវចាប់ផ្តើមរាប់ឡើងវិញគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច អាចបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់បានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់មានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ត្រូវបានធ្វើមកអាជ្ញាធរមានសមត្ថកិច្ចតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតសាងសង់
- គ្មានការកែប្រែគម្រោងប្តង់ស្ថាបត្យកម្មដើមនៃលិខិតអនុញ្ញាតសាងសង់
- មិនទាន់មានការចាប់ផ្តើមសាងសង់នៅការដ្ឋានសំណង់។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់។

មាត្រា២១ .-

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៥
លិខិតអនុញ្ញាតជួសជុល

មាត្រា២២ .-

ការងារជួសជុលសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវមានលិខិតអនុញ្ញាតជួសជុលជាមុន។

មាត្រា២៣ .-

ការងារជួសជុលដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រូបន្ទុក គ្រឿងផ្គុំសំណង់ ទ្រង់ទ្រាយដើម និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជួសជុលឡើយ មានជាអាទិ៍ៈ

- ការជួសជុលផ្នែកខាងក្នុងដែលមានការខូចខាត ឬការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កគ្រោះថ្នាក់ជាយថាហេតុ
- ការកោសលាបនិង/ឬការបូកបន្ថែមផ្នែកខាងក្នុងអគារ
- ការកែលម្អនិង/ឬការប្តូរពិតានដែលមិនធ្វើពីបេតុងដែក
- ការកែលម្អនិង/ឬការប្តូរឬការបំពាក់បរិក្ខារនិងផលិតផលសំណង់នៅខាងក្នុង មានជាអាទិ៍ការ៉ូ ក្រដាសបិទជញ្ជាំង ជញ្ជាំងកញ្ចក់ សន្លឹកទ្វារ សន្លឹកបង្អួច ម៉ាស៊ីនត្រជាក់
- ការកែលម្អនិង/ឬការប្តូរឬការបំពាក់បរិក្ខារសំណង់ មានជាអាទិ៍បរិក្ខារបន្ទប់ទឹក គ្រឿងបន្លាស់ជណ្តើរយន្ត បណ្តាញខ្សែទូរគមនាគមន៍ និងបរិក្ខារអគ្គិសនី មានជាអាទិ៍ខ្សែភ្លើង ខ្សែអុបទិក អំពូលកង្ហារ។

មាត្រា២៤ .-

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិលើសំណង់ លិខិតអនុញ្ញាតសាងសង់ គម្រោងប្តង់ស្ថាបត្យកម្ម គម្រោងប្តង់គ្រឿងផ្គុំសំណង់ វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារជួសជុល។

មាត្រា២៥ .-

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវកំណត់ដូចខាងក្រោមៈ

១- យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុលដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣. យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

មាត្រា២៦ .-

លិខិតអនុញ្ញាតជួសជុលអស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតជួសជុលនោះ។

លិខិតអនុញ្ញាតជួសជុល អាចបន្តសុពលភាពបានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតជួសជុលមានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតជួសជុលត្រូវបានធ្វើ តាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតជួសជុល
- គ្មានការកែប្រែគម្រោងប្តង់ស្ថាបត្យកម្មឬគម្រោងប្តង់គ្រឿងធ្ងុំសំណង់ដើមនៃលិខិតអនុញ្ញាតជួសជុល
- មិនទាន់មានការចាប់ផ្តើមជួសជុលនៅការដ្ឋានសំណង់។

ការងារជួសជុលត្រូវបានចាត់ទុកថាបានចាប់ផ្តើម កាលណាការងារដំបូងត្រូវបានអនុវត្តចំពោះផ្នែកណាមួយនៃសំណង់។

ការដ្ឋានសំណង់ដែលបានចាប់ផ្តើមដំណើរការជួសជុល ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញលើសពី ៦(ប្រាំមួយ)ខែ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតជួសជុល មុននឹងបន្តដំណើរការជួសជុល។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតជួសជុល។

មាត្រា២៧ .-

មុននឹងធ្វើការជួសជុលដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុលដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៨ .-

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតជួសជុលដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតជួសជុលដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៦

លិខិតអនុញ្ញាតរុះរើ

មាត្រា២៩ .-

ការងាររុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវមានលិខិតអនុញ្ញាតរុះរើជាមុន។

មាត្រា៣០ .-

ការស្នើសុំលិខិតអនុញ្ញាតរុះរើ ត្រូវធ្វើដោយម្ចាស់សំណង់។

សំណង់ដែលកំពុងមានវិវាទអំពីកម្មសិទ្ធិ មិនអនុញ្ញាតឱ្យរុះរើឡើយ។

មាត្រា៣១ .-

ការងាររុះរើសំណង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីសំណង់នោះកំពុងមានវិវាទអំពីកម្មសិទ្ធិក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

មាត្រា៣២ .-

មុននឹងធ្វើការរុះរើដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងាររុះរើដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៣ .-

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរុះរើ ត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិនៃសំណង់ គម្រោងប្តង់ស្ថាបត្យកម្ម គម្រោងប្តង់រុះរើ និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងាររុះរើ។

មាត្រា៣៤ .-

បញ្ហត្តិស្តីពីរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតរុះរើ។

មាត្រា៣៥ .-

បញ្ហត្តិស្តីពីលក្ខខណ្ឌសុពលភាព ការស្នើសុំបន្តសុពលភាព និងការអនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះលក្ខខណ្ឌសុពលភាព ការស្នើសុំបន្តសុពលភាព និងការអនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតរុះរើ។

ការបន្តសុពលភាពលិខិតអនុញ្ញាតរុះរើ មិនត្រូវមានការកែប្រែគម្រោងប្តង់រុះរើនៃសំណង់ដែលបានកំណត់ក្នុងលិខិតអនុញ្ញាតរុះរើដើមឡើយ។

មាត្រា៣៦ .-

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតរុះរើដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតរុះរើដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៧
លិខិតអនុញ្ញាតបើកការដ្ឋានសំណង់

មាត្រា៣៧ .-

ការចាប់ផ្តើមដំណើរការការងារសាងសង់សំណង់ថ្មី ការងារកែប្រែ ការងារដំឡើង និងការងាររុះរើ ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុនស្របតាមលិខិតអនុញ្ញាតសាងសង់ឬរុះរើសំណង់នោះ។

ការដ្ឋានសំណង់ដែលបានចាប់ផ្តើមដំណើរការ ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញ លើសពី១(មួយ)ឆ្នាំ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ មុននឹងបន្តដំណើរការសាងសង់ឬរុះរើ។

មាត្រា៣៨ .-

ការងារសាងសង់សំណង់ថ្មីត្រូវបានចាត់ទុកថាបានចាប់ផ្តើមដំណើរការ នៅពេលដែលការងារដីឬការងារគ្រឹះដំបូងត្រូវបានអនុវត្ត។ ការងារកែប្រែត្រូវបានចាត់ទុកថាបានចាប់ផ្តើម កាលណាផ្នែកណាមួយនៃសំណង់ឬបរិក្ខារសំណង់ឬផលិតផលសំណង់ត្រូវបានផ្លាស់ប្តូរ។ ការងារដំឡើងត្រូវបានចាត់ទុកថាបានចាប់ផ្តើម កាលណាផ្នែកណាមួយនៃបរិក្ខារសំណង់ឬផលិតផលសំណង់ ត្រូវបានភ្ជាប់ទៅនឹងសំណង់។

ការងាររុះរើត្រូវបានចាត់ទុកថាបានចាប់ផ្តើមដំណើរការ នៅពេលដែលផ្នែកដំបូងនៃសំណង់ត្រូវបានដកឬរើចេញ។

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ឬរុះរើក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ម្ចាស់សំណើអាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

មាត្រា៣៩ .-

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ ត្រូវមានភ្ជាប់លិខិតអនុញ្ញាតសាងសង់ គម្រោងប្តង់គ្រឿងផ្គុំសំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ សៀវភៅបន្ទុកនៃការងារ

សាងសង់ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់ និង វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងារុះរើ ត្រូវមានភ្ជាប់លិខិត អនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ គម្រោងប្តង់គ្រឿងផ្គុំសំណង់ គម្រោងប្តង់រុះរើ សៀវភៅបន្ទុកនៃ ការងាររុះរើ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងាររុះរើ និង វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។

ក្នុងករណីសំណង់ត្រូវបានអនុញ្ញាតឱ្យសាងសង់ឬរុះរើដោយតុណ្ហីភាព សំណុំឯកសារស្នើសុំលិខិត អនុញ្ញាត បើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ឬរុះរើ ត្រូវមានភ្ជាប់បង្កាន់ដៃទទួលពាក្យស្នើសុំ លិខិតអនុញ្ញាតសាងសង់ឬរុះរើ និងឯកសារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

ត្រូវបានរាប់បញ្ចូលជាឯកសារបច្ចេកទេស លិខិតឯកភាពជាគោលការណ៍របស់ក្រសួង ស្ថាប័ន ឬ រដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

មាត្រា៤០ .-

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវកំណត់ដូច ខាងក្រោម៖

១- យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិត អនុញ្ញាតបើកការដ្ឋានសំណង់ដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិត អនុញ្ញាតបើកការដ្ឋានសំណង់ដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋាន សំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣- យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាត បើកការដ្ឋានសំណង់ដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

មាត្រា៤១ .-

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អស់សុពលភាពក្នុងករណីណាមួយដូចខាងក្រោម៖

- ការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិត អនុញ្ញាតបើកការដ្ឋានសំណង់នោះ

- ការដ្ឋានសំណង់បានផ្អាកដំណើរការរយៈពេលលើសពី១(មួយ)ឆ្នាំ
- លិខិតអនុញ្ញាតសាងសង់ឬរុះរើអស់សុពលភាព ត្រូវបាននិរាករឬប្រកាសមោឃភាពដោយអាជ្ញាធរមានសមត្ថកិច្ចឬដោយតុលាការ។

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់អាចបន្តសុពលភាពបានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់មានដូចខាងក្រោម:

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវបានធ្វើតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់
- គ្មានការកែប្រែគម្រោងប្តង់ស្ថាបត្យកម្ម គម្រោងប្តង់គ្រឿងធ្មឹសំណង់ ឬគម្រោងប្តង់រុះរើដើមនៃលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ ឬលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

មាត្រា៤២ ៖

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៨

លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត សម្រាប់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ

មាត្រា៤៣ ៖

ការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ត្រូវគោរពតាមលក្ខខណ្ឌនិងនីតិវិធីសម្រាប់សំណង់ទូទៅដែរ។

ការស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ត្រូវមានលិខិតអនុញ្ញាតអភិវឌ្ឍដីផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចជាមុន។

ការសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ អាចអនុញ្ញាតឱ្យធ្វើឡើងតាមដំណាក់កាលស្របតាមផែនការ ដូចមានកំណត់ក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី។

មាត្រា៤៤ .-

ការស្នើសុំលិខិតអនុញ្ញាតសាងសង់ដោយបំបែកជាគម្រោងតូចៗនៃគម្រោងអភិវឌ្ឍនៃបណ្តុំផ្ទះល្វែង ឬគម្រោងបណ្តុំលំនៅឋានក្នុងគោលដៅអាជីវកម្មដែលមានម្ចាស់សំណង់តែមួយ មានម្ចាស់ដីតែមួយ និងស្ថិតនៅលើក្បាលដីតែមួយ ត្រូវហាមឃាត់។

មាត្រា៤៥ .-

គម្រោងសាងសង់បណ្តុំផ្ទះល្វែង ឬបណ្តុំលំនៅឋានក្នុងគោលដៅអាជីវកម្មដែលស្ថិតនៅលើក្បាលដីតែមួយ ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន មុននឹងអនុញ្ញាតឱ្យធ្វើការបំបែកក្បាលដី។

គម្រោងសាងសង់អគារសហកម្មសិទ្ធិក្នុងគោលដៅអាជីវកម្មដែលស្ថិតនៅលើក្បាលដីតែមួយ ត្រូវអនុវត្តការងារសាងសង់គ្រឿងផ្គុំសំណង់អគារទាំងមូលមួយរយភាគរយ និងបានរៀបចំខណ្ឌជញ្ជាំង ចំណែកឯកជនរួចរាល់តាមប្លង់អនុញ្ញាត មុននឹងអនុញ្ញាតឱ្យធ្វើការបំបែកជាចំណែកឯកជន។

ជំពូកទី៩
ការប្តឹងតវ៉ា

មាត្រា៤៦ .-

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

មាត្រា៤៧ .-

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្តែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ដូចមានកំណត់ក្នុងលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួលតាមនីតិវិធីជាធរមាន។

ជំពូកទី១០
ទណ្ឌកម្ម

មាត្រា៤៨ .-

បុគ្គលដែលក្លែងបន្លំឯកសារឬផ្តល់ព័ត៌មានមិនពិតដល់អាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ចដើម្បីទទួលបានលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងអនុក្រឹត្យនេះ ឬក្លែងបន្លំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្ត

សុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

មាត្រា៤៩ .-

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ឬបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី១១
អន្តរប្បញ្ញត្តិ

មាត្រា៥០ .-

លិខិតបទដ្ឋាននិងគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលអនុវត្តមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋាននិងគោលការណ៍ណែនាំថ្មីមកជំនួស។

លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលបានផ្តល់ជូនម្ចាស់សំណង់មុនអនុក្រឹត្យនេះចូលជាធរមាន នៅបន្តសុពលភាពរហូតថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតទាំងនោះ។

មាត្រា៥១ .-

ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលបានដាក់នៅយន្តការច្រកចេញចូលតែមួយមុនអនុក្រឹត្យនេះចូលជាធរមាន អាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ច ត្រូវបន្តដំណើរការពិនិត្យនិងសម្រេចរហូតដល់ចប់នីតិវិធី។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចត្រូវអនុវត្តគោលការណ៍ឬលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងអនុក្រឹត្យនេះដែលផ្តល់ប្រយោជន៍ដល់ម្ចាស់សំណើ។

មាត្រា៥២ .-

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុលសំណង់ដែលបានសាងសង់រួចមុនអនុក្រឹត្យនេះចូលជាធរមានដោយមានឬគ្មានលិខិតអនុញ្ញាតសាងសង់ ត្រូវភ្ជាប់លិខិតបិទការដ្ឋានសំណង់ ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងឯកសារបច្ចេកទេសផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យនេះ។

ជំពូកទី១២

អវសានប្បញ្ញត្តិ

មាត្រា៥៣ .-

អនុក្រឹត្យលេខ៨៦ អនក្រ.បក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ ឫស្សភ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមជ្រាបថា
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃ
ការត្រួតពិនិត្យនិងបញ្ជាក់
សំណង់

ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២២៥អនក្រ.បក

អនុក្រឹត្យ
ស្តីពី
លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ ន.ស.៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៦/១៨៤ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពី ការកែសម្រួលមាត្រា៣ មាត្រា៤ និងមាត្រា២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៥២២ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី ការកែសម្រួលមាត្រា៧ មាត្រា៩ និងមាត្រា៣២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យ លេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាត សាងសង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះ កំណត់អំពីប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ លក្ខខណ្ឌនិង នីតិវិធីនៃការផ្តល់ ការបញ្ចប់សុពលភាព ការបន្តសុពលភាព ការព្យួរ និងការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ និងលក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្នុងគោលបំណងដើម្បីៈ

- ធានាគុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់ សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- ធានាការងារសិក្សាគម្រោងប្តង់ ការងារសាងសង់ និងការងាររុះរើអនុលោមតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់
- ធានាគណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់
- បង្កើនជំនឿទុកចិត្តរបស់សាធារណជនលើសំណង់

- ជំរុញការវិនិយោគនៅក្នុងវិស័យសំណង់និងទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

មាត្រា២ ..

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៣ ..

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់លើគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

២- **ប្លង់សម្រង់សំណង់** សំដៅដល់ប្លង់សំណង់ដែលគួរតាមទិន្នន័យស្រង់ចេញពីសំណង់ដែលគ្មានប្លង់សម្រង់តាមការសាងសង់ជាក់ស្តែង។

៣- **លិខិតបញ្ជាក់អនុលោមភាព** សំដៅដល់លិខិតចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដើម្បីបញ្ជាក់អំពីអនុលោមភាពនៃសំណង់ឬការងារសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

៤- **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

៥- **សេចក្តីណែនាំបច្ចេកទេស** សំដៅដល់វិធីសាស្ត្រ វិធាន ឬបទដ្ឋានបច្ចេកទេសសម្រាប់អនុវត្តក្នុងការសិក្សាគម្រោងប្លង់ ការផលិត ការសាងសង់ឬរុះរើតាមមុខជំនាញ មានជាអាទិ៍ ការងារដី ការងារស្វូចលើកដាក់ ការងារធ្វើគ្រឹះ ការងារក្តារពុម្ព ការងារបេតុងដែក ការងារមេកានិក ការងារអគ្គិសនី ការងារបណ្តាញទឹក ការងារសុវត្ថិភាពអគ្គិភ័យ។

៦- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៧- **អ្នកកាន់អាជ្ញាបណ្ណ** សំដៅដល់អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលបានទទួលសិទ្ធិ ផ្តល់ដោយអាជ្ញាបណ្ណនិងដែលមានគោត្តនាមនិងនាមឬនាមករណ៍នៅលើអាជ្ញាបណ្ណ។

៨- **អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់ក្រុមការងារនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៩- **ឯកសារបច្ចេកទេស** សំដៅដល់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់ របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ របាយការណ៍ស្តីពីការធ្វើកោសល្យវិច័យសំណង់ ប្លង់សម្រង់សំណង់ ឬលិខិតបញ្ជាក់អនុលោមភាព។

ជំពូកទី២
សមត្ថកិច្ច

មាត្រា៤ .-

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងលើការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ជំពូកទី៣
ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

មាត្រា៥ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មាន៤(បួន)ប្រភេទដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់។

៤- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក។

មាត្រា៦ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ មាន២ (ពីរ)កម្រិតដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់សំណង់គ្រប់ប្រភេទ។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា៧ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម មាន៣(បី)កម្រិតដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្មនិងសម្រាប់ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មសម្រាប់សំណង់គ្រប់ប្រភេទ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្តង់ស្ថាបត្យកម្មនិងសម្រាប់ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្តង់ស្ថាបត្យកម្មនិងសម្រាប់ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

មាត្រា៨ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់ មាន៣(បី)កម្រិតដូចខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់កម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គ្រឿងធ្ងុំសំណង់ គម្រោងប្តង់គ្រឿងធ្ងុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងធ្ងុំសំណង់សម្រាប់សំណង់គ្រប់ប្រភេទ។

២_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់កម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គ្រឿងធ្ងុំសំណង់ គម្រោងប្តង់គ្រឿងធ្ងុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងធ្ងុំសំណង់សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់កម្រិត៣ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គ្រឿងធ្ងុំសំណង់ គម្រោងប្តង់គ្រឿងធ្ងុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងធ្ងុំសំណង់សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

មាត្រា៩ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក មាន៣(បី)កម្រិត ដូចខាងក្រោម៖

១_ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្តង់ប្រព័ន្ធមេកានិក អគ្គិសនី និងទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី និងទឹកសម្រាប់សំណង់គ្រប់ប្រភេទ។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្តង់ប្រព័ន្ធមេកានិក អគ្គិសនី និងទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី និងទឹកសម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត៣ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈតាមមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងប្តង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី ឬទឹក សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ជំពូកទី៤
លក្ខខណ្ឌនៃការផ្តល់ ការបញ្ចប់សុពលភាព និងការបន្តសុពលភាព អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

មាត្រា១០ .-

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ១ ០០០ ០០០ ០០០(មួយពាន់លាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច២០(ម្ភៃ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៣(បី)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៥(ប្រាំ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល មេកានិក អគ្គិសនី ទឹក ឬភូគព្ភសាស្ត្រ និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១១ .-

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ២(ពីរ)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៤(បួន)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល មេកានិក អគ្គិសនី ទឹក ឬភូគព្ភសាស្ត្រ និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច ១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១២ ..

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច២០(ម្ភៃ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៣(បី)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១៣ ..

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៣០០ ០០០ ០០០(បីរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ២(ពីរ)រូបជាស្ថាបត្យករដែលម្នាក់ៗមានបទពិសោធន៍យ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ

- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១៤ ..

អ្នកវិជ្ជាជីវៈដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈជាស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

មាត្រា១៥ ..

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្មុំសំណង់កម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច២០(ម្ភៃ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៥(ប្រាំ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល ៤(បួន)រូបនិងផ្នែកភូគព្ភសាស្ត្រ១(មួយ)រូបនិងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១៦ ..

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្មុំសំណង់កម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៣០០ ០០០ ០០០(បីរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៤(បួន)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល ៣(បី)រូបនិងផ្នែកភូគព្ភសាស្ត្រ១(មួយ)រូបនិងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ

- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១៧ ..

អ្នកវិជ្ជាជីវៈដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងិសំណង់កម្រិតពាត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិលនិងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

មាត្រា១៨ ..

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត១ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ៣០០ ០០០ ០០០(បីរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក និងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៤(បួន)រូបជាវិស្វករដែលមានមុខជំនាញផ្នែកសំណង់ស៊ីវិល មេកានិក អគ្គិសនី និងទឹក និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១៩ ..

ក្រុមហ៊ុនដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត២ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម មានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងសំណង់ និងមានដើមទុនយ៉ាងតិច ១០០ ០០០ ០០០(មួយរយលាន)រៀល
- មាននាយកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ១(មួយ)រូបជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក និងដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានអ្នកបច្ចេកទេសជាអ្នកវិជ្ជាជីវៈ៣(បី)រូបជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី និងទឹក និងដែលម្នាក់ៗមានបទពិសោធន៍ក្នុងមុខជំនាញយ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ

- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា២០ .-

អ្នកវិជ្ជាជីវៈដែលអាចទទួលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត៣ ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈជាវិស្វករដែលមានមុខជំនាញផ្នែកមេកានិក អគ្គិសនី ឬទឹក ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច១០(ដប់)ឆ្នាំ
- មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

មាត្រា២១ .-

ក្នុងករណីនាយកបច្ចេកទេសរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ ឬត្រូវបានតុលាការប្រកាសក្សីយធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ ឬត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលនាយកបច្ចេកទេសនោះធ្លាប់ស្នាក់នៅ ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវតែងតាំងនាយកបច្ចេកទេសថ្មីនិងស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃប្រកាសរបស់តុលាការឬថ្ងៃប្រកាសសាលក្រមឬសាលដីកាស្ថាពរ។

ក្នុងករណីក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ សម្រេចប្តូរនាយកបច្ចេកទេសឬអ្នកបច្ចេកទេសក្រុមហ៊ុនត្រូវស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃសម្រេចប្តូរ។

ក្នុងកំលុងពេលរង់ចាំការសម្រេចយល់ព្រមលើការតែងតាំងនាយកបច្ចេកទេសថ្មី ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមហ៊ុនត្រូវតែងតាំងនាយកបច្ចេកទេសស្តីទី១(មួយ)រូប ដោយជ្រើសរើស ក្នុងចំណោមអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនដែលមានមុខជំនាញសមមូលនឹងមុខជំនាញរបស់នាយកបច្ចេកទេសដែលត្រូវបានប្តូរ។

មាត្រា២២ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចចេញបានតែមួយដងគត់ លើកលែងករណីដែលអាជ្ញាបណ្ណបានបាត់បង់ រហែក ឬខូច ឬមានការប្តូរប្រធានក្រុមហ៊ុនឬនាយកបច្ចេកទេស។ ក្នុងករណីនេះអ្នកកាន់អាជ្ញាបណ្ណ ត្រូវដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៣ .-

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មានសុពលភាព៣(បី)ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ និងអាចបន្តជាថ្មីបាន។

ការដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើនៅក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃមុនកាលបរិច្ឆេទផុតសុពលភាព។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយប្រកាស។ ក្នុងករណីនេះ អាជ្ញាបណ្ណថ្មីត្រូវមានការបញ្ជាក់អំពីកាលបរិច្ឆេទនៃការផ្តល់អាជ្ញាបណ្ណលើកដំបូង។

ក្នុងរយៈពេលនៃការពិនិត្យសម្រេចលើពាក្យស្នើសុំបន្តសុពលភាព អាជ្ញាបណ្ណចាស់នៅបន្តសុពលភាពរហូតដល់ថ្ងៃដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចលើពាក្យស្នើសុំនោះ។

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលផុតសុពលភាព អាចបន្តអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដែលត្រូវបានបង្កើតឡើងនៅក្នុងកំលុងពេលដែលអាជ្ញាបណ្ណនោះមានសុពលភាព ប៉ុន្តែមិនអាចបង្កើតកិច្ចសន្យាផ្តល់សេវាកម្មថ្មីឡើយ។

មាត្រា២៤ .-

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មដោយស្ម័គ្រចិត្តមុនកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ។ ក្នុងករណីនេះ អ្នកកាន់អាជ្ញាបណ្ណត្រូវបញ្ជាក់អះអាងជាលាយលក្ខណ៍អក្សរថាបានអនុវត្តចប់សព្វគ្រប់នូវកាតព្វកិច្ចទាំងឡាយដែលបានបង្កើតឡើងដោយកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបញ្ចប់សុពលភាពអាជ្ញាបណ្ណដោយប្រកាស។

ការបញ្ចប់សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មិនធ្វើឱ្យអ្នកស្នើសុំរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កឡើងដល់អតិថិជនឬអ្នកដទៃដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ខ្លួនឡើយ។

ជំពូកទី៥

នីតិវិធីនៃការផ្តល់ ការបញ្ចប់សុពលភាព និងការបន្តសុពលភាព អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

មាត្រា២៥ .-

ពាក្យស្នើសុំអាជ្ញាបណ្ណ ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ពាក្យស្នើសុំបញ្ចប់សុពលភាព និងពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងដាក់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ពាក្យស្នើសុំបញ្ចប់សុពលភាព និងពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្នុងរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

រាល់ចម្លើយបដិសេធចំពោះពាក្យស្នើសុំអាជ្ញាបណ្ណ ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ពាក្យស្នើសុំបញ្ចប់សុពលភាព និងពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុ។

មាត្រា២៦ .-

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ អ្នកដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី អ្នកដាក់ពាក្យស្នើសុំបញ្ចប់សុពលភាព និងអ្នកដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់អាជ្ញាបណ្ណ ការចេញសន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំនិងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាផ្តល់អាជ្ញាបណ្ណ ការចេញសន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្ត សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា២៧ .-

បែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៦

លក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់

មាត្រា២៨ .-

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើការត្រួតពិនិត្យនិងវិភាគលើទម្រង់ ការគណនា ការអនុវត្តបទប្បញ្ញត្តិ និងការប្រតិបត្តិការងារ ដើម្បីធ្វើការបញ្ជាក់អំពីអនុលោមភាពនៃគម្រោងប្លង់ អនុលោមភាពនៃការងារសាងសង់ឬរុះរើ ឬអនុលោមភាពនៃសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

មាត្រា២៩ .-

សំណង់និងការងារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់សំណង់ មានដូចខាងក្រោម៖

១- គម្រោងប្តង់ប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើ មុនអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធ។

២- ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត។

៣- សំណង់ដែលត្រូវបានសាងសង់ថ្មី ជួសជុល កែប្រែ ឬប្តូរមុខងារប្រើប្រាស់សំណង់ មុនអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

៤- សំណង់និងបរិក្ខារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពជាទៀងទាត់។

៥- សំណង់ដែលមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់លើឯកសារបច្ចេកទេស ការងារសាងសង់ឬរុះរើ ឬសំណង់ដទៃទៀត។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំនៃសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា៣០ .-

ក្នុងការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

- អនុវត្តការងារតាមប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- អនុវត្តការងារដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- អនុវត្តការងារតាមបែបបទនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់
- អនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់
- គោរពក្រមសីលធម៌វិជ្ជាជីវៈឬធានាថានាយកបច្ចេកទេសនិងអ្នកបច្ចេកទេសគោរពក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣១ ..

ក្នុងការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់និងចេញលិខិតបញ្ជាក់អនុលោមភាព។

មាត្រា៣២ ..

រាល់ឯកសារបច្ចេកទេសចេញដោយអ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខា ត្រា និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈនោះ។

រាល់ឯកសារបច្ចេកទេសចេញដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខារបស់អ្នកបច្ចេកទេសពាក់ព័ន្ធ ហត្ថលេខាទទួលខុសត្រូវរបស់នាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ។

នាយកបច្ចេកទេសស្តីទី គ្មានសិទ្ធិចុះហត្ថលេខាលើឯកសារបច្ចេកទេសចេញដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ឡើយ។

មាត្រា៣៣ ..

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបវិជ្ជាជីវៈឬការប្រកបអាជីវកម្មរបស់ខ្លួន និងចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបវិជ្ជាជីវៈរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខាទទួលខុសត្រូវ ត្រា និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈនោះ។

របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបអាជីវកម្មរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមានហត្ថលេខារបស់អ្នកបច្ចេកទេសពាក់ព័ន្ធនិងហត្ថលេខាទទួលខុសត្រូវរបស់នាយកបច្ចេកទេសនិងត្រារបស់ក្រុមហ៊ុន។

មាត្រា៣៤ ..

នាយកបច្ចេកទេសនិងអ្នកបច្ចេកទេសនៃក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងអ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវមកទទួលការបណ្តុះបណ្តាលអំពីការអនុវត្តការងាររបស់ខ្លួនតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៥ ..

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់និងការងារកោសល្យវិច័យសំណង់តាមសំណើរបស់តុលាការ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬម្ចាស់សំណង់។

មាត្រា៣៦ ..

បែបបទនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៧
ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់
អនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

មាត្រា៣៧ ..

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ សម្រាប់សំណង់ គម្រោងប្តង់ និងការងារសាងសង់ឬរុះរើសំណង់របស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀតតាមសំណើរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចទទួលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់របស់បុគ្គលឯកជន។

ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ឬការងារកោសល្យវិច័យសំណង់ តាមសំណើរបស់តុលាការ ក្រសួងស្ថាប័នពាក់ព័ន្ធ ឬបុគ្គលឯកជន។

មាត្រា៣៨ ..

សមាសភាពនៃក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវជ្រើសរើសក្នុងចំណោមថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ និងដែលមានបទពិសោធន៍ការងារផ្នែកស្ថាបត្យកម្ម ផ្នែកសំណង់ស៊ីវិល ផ្នែកភូគព្ភសាស្ត្រ ផ្នែកមេកានិក ផ្នែកអគ្គិសនី ផ្នែកទឹក ឬផ្នែកវិស្វកម្មដទៃទៀត។

សមាសភាពនៃក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៣៩ ..

ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់ របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ប្តង់សម្រង់សំណង់ ឬរបាយការណ៍នៃការធ្វើកោសល្យវិច័យសំណង់។

ក្រោយពីបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវចេញលិខិតបញ្ជាក់អនុលោមភាពដោយមានហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៤០ ..

សេវាត្រួតពិនិត្យនិងបញ្ជាក់លើសំណង់របស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀតដែលអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនតម្រូវឱ្យមានការបង់កម្រៃសេវាឡើយ។

ម្ចាស់សំណង់ជាបុគ្គលឯកជនដែលទទួលសេវាត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៨
ស្ថាបត្យករឬវិស្វករនិងក្រុមហ៊ុនសញ្ជាតិបរទេស

មាត្រា៤១ ..

ស្ថាបត្យករឬវិស្វករនិងក្រុមហ៊ុនសញ្ជាតិបរទេស មានសិទ្ធិប្រកបវិជ្ជាជីវៈឬអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់តាមលក្ខខណ្ឌដូចមានចែងក្នុងអនុក្រឹត្យនេះ។

មាត្រា៤២ ..

ស្ថាបត្យករឬវិស្វករសញ្ជាតិបរទេសដែលស្នើសុំប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជាជានាយកបច្ចេកទេសឬជាអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះបញ្ជីការនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា
- បានបំពេញលក្ខខណ្ឌតម្រូវដើម្បីប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- មានសិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានសិទ្ធិប្រកបការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៤៣ ..

ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចគ្នានឹងក្រុមហ៊ុនសញ្ជាតិខ្មែរដែរ។

ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ដែលស្នើសុំប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានបំពេញលក្ខខណ្ឌតម្រូវដើម្បីប្រកបអាជីវកម្ម
- ត្រូវមានភ្នាក់ងារតំណាងដោយមានលិខិតប្រគល់សិទ្ធិដែលបញ្ជាក់ពីភាពស្របច្បាប់និងចុះហត្ថលេខាដោយប្រធានក្រុមហ៊ុន និង
- ត្រូវមានការិយាល័យតំណាងពាណិជ្ជកម្មឬការិយាល័យទំនាក់ទំនងឬបុត្រសម្ព័ន្ធក្រុមហ៊ុនដែលមានអាសយដ្ឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី៩
ការប្តឹងតវ៉ា

មាត្រា៤៤ .-

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិប្តឹងតវ៉ាតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

ជំពូកទី១០
ទណ្ឌកម្ម

មាត្រា៤៥ .-

ទណ្ឌកម្មក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរអាជ្ញាបណ្ណ
- ការដកហូតអាជ្ញាបណ្ណ។

មាត្រា៤៦ .-

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរអាជ្ញាបណ្ណ និងការដកហូតអាជ្ញាបណ្ណ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចផ្សាយការព្រមាន ការព្យួរ ឬការដកហូតអាជ្ញាបណ្ណជាសាធារណៈនៅក្នុងសារព័ត៌មានឬតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

មាត្រា៤៧ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដែលមិនគោរពតាមលក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ដូចមានចែងក្នុងអនុក្រឹត្យនេះ។

មាត្រា៤៨ .-

ត្រូវព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងរយៈពេលមិនលើសពី៦(ប្រាំមួយ)ខែដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាអ្នកវិជ្ជាជីវៈដែលបានប្រព្រឹត្តន្ូវអំពើណាមួយដូចខាងក្រោម៖

- មិនអនុវត្តតាមការណែនាំដូចមានចែងនៅក្នុងលិខិតព្រមានរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- លែងបំពេញលក្ខខណ្ឌតម្រូវដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ

- បានប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ឬក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ក៏ប៉ុន្តែមានការបញ្ជាក់ពីគ្រូពេទ្យជំនាញថាអាចជាសះស្បើយឡើងវិញក្នុងរយៈពេលនៃការព្យួរ។

ត្រូវព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងរយៈពេលមិនលើសពី១(មួយ)ឆ្នាំ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាក្រុមហ៊ុនដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនអនុវត្តតាមការណែនាំដូចមានកំណត់ក្នុងលិខិតព្រមានរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបអាជីវកម្ម
- លែងបំពេញលក្ខខណ្ឌតម្រូវដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបអាជីវកម្ម
- មិនបានប្តូរអភិបាលរបស់ក្រុមហ៊ុនដែលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ ឬត្រូវបានតុលាការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ ឬត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលអភិបាលនោះធ្លាប់ស្នាក់នៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសរបស់តុលាការឬថ្ងៃប្រកាសសាលក្រមឬសាលដីកាស្ថាពរ
- មិនបានប្តូរនាយកបច្ចេកទេសឬអ្នកបច្ចេកទេសដែលបានបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃបាត់បង់នីតិសម្បទា។

ក្នុងរយៈពេលដែលអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវបានព្យួរ អ្នកកាន់អាជ្ញាបណ្ណមិនអាចបង្កើតកិច្ចសន្យាផ្តល់សេវាកម្មថ្មីនិងមិនអាចចុះហត្ថលេខាលើឯកសារបច្ចេកទេសពាក់ព័ន្ធការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ឡើយ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយសេចក្តីសម្រេច។

មាត្រា៤៩ .-

ត្រូវដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាអ្នកវិជ្ជាជីវៈដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនបានអនុវត្តតាមការណែនាំដូចមានចែងនៅក្នុងសេចក្តីសម្រេចស្តីពីការព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានប្រព្រឹត្តខុសធ្ងន់ធ្ងរចំពោះក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ឬក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់

- បាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដូចមានចែងនៅក្នុងច្បាប់ស្តីពីសំណង់
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញថាមិនអាចជាសះស្បើយឡើងវិញក្នុងរយៈពេលនៃការព្យួរ
- បានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលអភិបាលនោះធ្លាប់ស្នាក់នៅ។

ត្រូវដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិជាធរមាន ចំពោះអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាក្រុមហ៊ុនដែលបានប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

- មិនបានអនុវត្តតាមការតម្រូវដូចមានចែងនៅក្នុងសេចក្តីសម្រេចស្តីពីការព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលត្រូវបានដកហូត អាចស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់សាជាថ្មីក្រោយរយៈពេល៥ (ប្រាំ)ឆ្នាំគិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយប្រកាស។

បែបបទនិងបរិបថនៃការព្យួរនិងការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា៥០.-

បុគ្គលដែលក្លែងបន្លំឯកសារឬផ្តល់ព័ត៌មានមិនពិតដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីទទួលបានអាជ្ញាបណ្ណ សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដូចមានចែងក្នុងអនុក្រឹត្យនេះ ឬក្លែងបន្លំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬប្រកាសស្តីពីការបញ្ចប់សុពលភាព ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

មាត្រា៥១ .-

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ការចេញសន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី១១
អន្តរប្បញ្ញត្តិ

មាត្រា៥២ .-

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមានតាមសំណើរបស់ម្ចាស់សំណង់។ ក្នុងករណីនេះ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើប្លង់សម្រង់សំណង់ និងរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនម្ចាស់សំណង់ដើម្បីប្រើប្រាស់សម្រាប់បំពេញបែបបទស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។

មាត្រា៥៣ .-

អ្នកស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដែលគ្មានវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន ត្រូវតម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជាទៅតាមប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណ។

មាត្រា៥៤ .-

ចំនួនទឹកប្រាក់អប្បបរមាដែលអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន ត្រូវបានកំណត់ដូចខាងក្រោម៖

១- ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១។

២- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២។

៣- ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១។

៤- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២។

៥- ៥០ ០០០ ០០០(ហាសិបលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣។

៦- ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្មិសំណង់កម្រិត១។

៧- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្មិសំណង់កម្រិត២។

៨- ៥០ ០០០ ០០០(ហាសិបលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្ទុំសំណង់កម្រិត៣។

៩- ៣០០ ០០០ ០០០(បីរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត១។

១០- ១០០ ០០០ ០០០(មួយរយលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត២។

១១- ៥០ ០០០ ០០០(ហាសិបលាន)រៀល សម្រាប់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក កម្រិត៣។

មាត្រា៥៥ .-

ប្រាក់ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវដាក់តម្កល់ជាសាច់ប្រាក់នៅក្នុងគណនីទោលរតនាគារជាតិ ដែលបើកនៅធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ អាចដកវិញបានក្នុងករណីដូចខាងក្រោម៖

១- អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណ។

២- អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ផុតសុពលភាព។

៤- អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ បានទទួលវិញ្ញាបនបត្រធានារ៉ាប់រងផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥៦ .-

អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវដាក់ពាក្យស្នើសុំដកប្រាក់តម្កល់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំដកប្រាក់តម្កល់ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ធនាគារជាតិនៃកម្ពុជា ត្រូវបង្វិលសាច់ប្រាក់ជូនម្ចាស់វិញ តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចស្នើសុំបង្កប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា ក្នុងករណីដែលក្រសួងពិនិត្យឃើញថា អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ កំពុងមានវិវាទជាមួយអតិថិជនរបស់ខ្លួន ក្នុងការអនុវត្តកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងបានធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់អតិថិជននោះឬបានបង្កការខូចខាតដល់អ្នកដទៃ។

មាត្រា៥៧ .-

បែបបទនិងបរិបថនៃការអនុញ្ញាតឱ្យដកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី១២
អវសានប្បញ្ញត្តិ

មាត្រា៥៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ បឋម ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមហាគ្លលេខា
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីតម្រង អតិថិជនក្រុងបួកគោ

ឆ្នាំ ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៨.....អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
-បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "ប្លូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ"
-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងប្លូកគោ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

មាត្រា ២.-

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងប្លូកគោ អាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងប្លូកគោ មុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្តង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងរដ្ឋបាលខេត្តពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១ ទាត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

ជា សុផារ៉ា

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ត្រូវនឹងថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៩

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ

ចក្ខុវិស័យឆ្នាំ២០៣៥

មាតិកា

ទំព័រ

១-សេចក្តីផ្តើម ១

២-ចក្ខុវិស័យ ៣

២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម ៣

២.២-ចក្ខុវិស័យ ៣

៣-គោលបំណង និងគោលដៅ ៣

៣.១-គោលបំណង ៣

៣.២-គោលដៅ ៣

៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សគ្រោងអភិវឌ្ឍក្រុងបូកគោ ៤

៤.១-យុទ្ធស្រាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព ៤

៤.១.១-ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម ៤

៤.១.២-យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី ៥

៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍ទិសំយទេសចរណ៍ ១២

៤.២.១-តំបន់ទេសចរណ៍ ១៣

៤.២.២-ផលិតផលទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានទេសចរណ៍ ១៣

៤.២.៣-ខ្សែទស្សនាកម្សាន្ត ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍ ១៤

៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស ១៤

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម ១៤

៤.៣.១-អ័ក្សទេសចរណ៍-ពាណិជ្ជកម្ម ១៥

៤.៣.២-ផ្លូវថ្នល់ ១៥

៤.៣.៣-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ១៥

៤.៣.៤-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌ ១៦

៤.៣.៥-ការផ្គត់ផ្គង់ទឹកស្អាត ១៦

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច ១៧

៤.៥-យុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាន ធនធានធម្មជាតិ និងការអភិវឌ្ឍបៃតង ១៧

៤.៥.១-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង ១៧

៤.៥.២-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ ១៨

៤.៥.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ១៨

៤.៥.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ ១៩

៤.៦-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ ១៩

៤.៧-យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន ១៩

៥-ផែនការសកម្មភាព ២០

៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម ២០

៥.២-ការផ្សព្វផ្សាយ ២០

៥.៣-ការអនុវត្តគម្រោងតាមវិស័យ ២១

៥.៣.១-ការអភិវឌ្ឍក្រុង ២១

៥.៣.២-ការអភិវឌ្ឍវិស័យទេសចរណ៍ ២១

៥.៣.៣-ការដឹកជញ្ជូន ២២

៥.៣.៤-ការគ្រប់គ្រងបរិស្ថាន ២២

៥.៣.៥-ការគ្រប់គ្រងសំណល់រឹង ២២

៥.៣.៦-ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ ២៣

៥.៣.៧-ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត ២៣

៥.៣.៨-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍ ២៣

៥.៤-ការអនុវត្តផែនការរយៈពេលខ្លី មធ្យម និងវែង ២៤

៥.៤.១-ការអនុវត្តផែនការរយៈពេលខ្លី ២៤

៥.៤.២-ការអនុវត្តរយៈពេលមធ្យម ២៤

៥.៤.៣-ការអនុវត្តរយៈពេលវែង ២៤

៥.៥-គម្រោងអាទិភាព ២៤

៦-ធនធានហិរញ្ញវត្ថុ ២៥

៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ២៥

៧.១-យន្តការ ២៥

៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ២៥

៧.៣-តារាកិច្ច នីតិវិធី និងគោលការណ៍ ២៦

៨-សេចក្តីសន្និដ្ឋាន ២៧

ឯកសារយោងសម្គាល់ ២៨

១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ខេត្តកំពតស្ថិតនៅទិសនិរតីក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានរមណីយដ្ឋានឋានសួគ៌ប្លកគោ និងជាសមាជិកក្តីបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ជាគោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិល្អឯកពេញនិយមបំផុតនៅព្រះរាជាណាចក្រកម្ពុជា។ ខេត្តមានព្រំប្រទល់ជាប់នឹងសមុទ្រ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកែប និងប្រទេសវៀតណាម។ សក្តានុពលធនធានធម្មជាតិជាច្រើន ដូចជា ព្រៃភ្នំ សត្វព្រៃ ទឹកផ្លាក់ កោះ សត្វសមុទ្រ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃកោងកាង ឆ្នេរខ្សាច់ ស្រែអំបិល ប៉ែថ្មកំបោរ ដីកសិកម្ម និងមានសក្តានុពលទេសចរណ៍ធម្មជាតិ ជាច្រើនមានដូចជា សំណង់បេតិកភណ្ឌក្រុងកំពត រមណីយដ្ឋានទេសចរណ៍ធម្មជាតិឋានសួគ៌ប្លកគោ ល្អាងភ្នំកំពង់ត្រាច ព្រែកត្នោត ភ្នំសិដាអោន ទឹកឈូ ប្រាសាទភ្នំឈ្មោក សួនសត្វទឹកឈូ ទឹកផ្លាក់ បឹថ្នាក់ ទំនប់ប្រទាក់ក្រឡា ទំនប់ម្ជិច និងរមណីយដ្ឋានភ្នំដួង សហគមន៍ទេសចរណ៍ព្រែកត្នោត ត្រពាំងសង្កែ តែបថ្មី សហគមន៍ទេសចណ៍លក និងតំបន់កម្សាន្តឆ្នេរសមុទ្រព្រែកអំពិល។ សក្តានុពលទេសចរណ៍ទាំងអស់នេះបានធ្វើឱ្យខេត្តកំពតមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សស្មើរគ្រប់វិស័យ ដូចជា វិស័យសំណង់ កសិកម្ម ឧស្សាហកម្ម សិប្បកម្ម ប៉ែ ថាមពល សេដ្ឋកិច្ច ទេសចរណ៍ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។

ដោយពិនិត្យទៅលើសក្តានុពល ក៍ដូចជាប្រវត្តិសាស្ត្រ ក្រុមការងារបច្ចេកទេសនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះធ្វើការសិក្សាស្រាវជ្រាវក្នុងភូមិសាស្ត្រឧទ្យានជាតិព្រះមុនីវង្ស “ប្លកគោ” ឃើញថា ទីតាំងនេះជាអតីតទីក្រុងប្រវត្តិសាស្ត្រនៅឆ្នាំ ១៩២៥-១៩៦២ ដ៏មានសក្តានុពល ដែលមានអាកាសធាតុត្រជាក់ល្បរិសុទ្ធ ទេសភាពធម្មជាតិតំបន់ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា និងជាគោលដៅទេសចរណ៍

ប្រណីតកម្រិតខ្ពស់ និងមានហេដ្ឋារចនាសម្ព័ន្ធជាទីក្រុងរដ្ឋបាលដែលបានបន្សល់ទុករហូតមកដល់បច្ចុប្បន្ន ដូចជា អគាររដ្ឋបាល ព្រះរាជដំណាក់ លំនៅឋាន អគារសេវាកម្ម សាលាក្រុង ប្រៃសណីយ៍ អគារសុរិយោដី សាលារៀន វត្តអារាម ព្រះវិហារកាតូលិក គិលានដ្ឋាន ប៉ុស្តិ៍នគរបាល ទីបញ្ជាការយោធា សណ្ឋាគារ ស្ថានីយទឹកស្អាត ស្ថានីយអគ្គិសនី ទំនប់ទឹកបារាំង។ល។

ផ្អែកតាមរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិជាសេនាធិការ បានផ្តួចផ្តើមសិក្សានិងរៀបចំប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានទីតាំងស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" នៃភូមិសាស្ត្រខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ មានផ្ទៃក្រឡាប្រមាណ ២៧ ៩៤៣ ហិកតា ស្មើនឹង ១៨,០៩% នៃផ្ទៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ទំហំ ១៥៤ ៥៤២ ហិកតា អនុលោមតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ និងអនុក្រឹត្យ លេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍន៍ក្រុងបូកគោប្រកបដោយចីរភាព។

ប្លង់គោលប្រើប្រាស់ដីនេះត្រូវបានកសាងឡើងដោយការសិក្សាច្បាស់លាស់លើកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ អនុក្រឹត្យស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជនជាដើម។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោនេះ ត្រូវបានរៀបចំឡើងដោយមានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់កម្រិតក្នុងរយៈពេលបច្ចុប្បន្ននិងនៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិជាពិសេសអភិរក្សតំបន់ទីក្រុងប្រវត្តិសាស្ត្រ។

២-ចក្ខុវិស័យ

២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី" និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ គឺសំដៅរៀបចំនិងអភិវឌ្ឍ **«ភ្នំបូកគោ ជាក្រុងឆ្លាតវៃ ទេសចរណ៍ប្រវត្តិសាស្ត្រ បៃតង ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា»** តាមរយៈការជំរុញ ÷ ១).កំណត់គោលនយោបាយ និងបទដ្ឋានគតិយុត្តបង្កើតជាក្រុងសម្រាប់លំនៅឋាន សម្រាកលម្ហែកម្សាន្ត សិក្សា ការងារ និងធុរកិច្ច ប្រកបដោយសុខភាព គុណភាពបរិស្ថានល្អ និងជាទិសដៅទេសចរណ៍ដ៏ប្រណីតកម្រិតខ្ពស់ សម្រាប់ការទាក់ទាញ និងប្រកួតប្រជែងក្នុងតំបន់និងអន្តរជាតិ ២).ការពារនិងអភិរក្សក្រុងប្រវត្តិសាស្ត្រ ធនធានធម្មជាតិ ថែរក្សាប្រភពទឹកធម្មជាតិ ទេសភាព និងអាកាសធាតុភ្នំ-សមុទ្រ ៣).កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន លំហសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសមាហរណកម្មតភ្ជាប់ក្នុងតំបន់ ៤).ទាក់ទាញលើកទឹកចិត្ត និងគាំទ្រដល់ការវិនិយោគសាធារណៈ និងឯកជន ដើម្បីអភិវឌ្ឍធុរកិច្ច អភិវឌ្ឍផលិតផលទេសចរណ៍សម្បូរបែបប្រកបដោយគុណភាពខ្ពស់ និងជំរុញកំណើនសេដ្ឋកិច្ច និង ៥).អភិបាលកិច្ចល្អ និងអភិវឌ្ឍធនធានមនុស្ស។

៣-គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានគោលបំណង និងគោលដៅ ដូចខាងក្រោម÷

៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានគោលបំណង "ធានាការគ្រប់គ្រង និងអភិបាលកិច្ចទីប្រជុំជនភ្នំបូកគោឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈការធ្វើសមាហរណកម្ម ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយគុណភាព តុល្យភាព សមធម៌ និងចីរភាព"។

៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ មានគោលដៅ÷

- ការពារនិងអភិរក្សក្រុងប្រវត្តិសាស្ត្រ បរិស្ថាន និងធនធានធម្មជាតិ ទេសភាព និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា

- គ្រប់គ្រងការប្រើប្រាស់ដី និងនគរូបនីយកម្ម ប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្ម
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ចទាក់ទាញ គាំទ្រដល់ការវិនិយោគសាធារណៈនិងវិស័យឯកជន ដើម្បីសមធម៌សង្គម និងផ្តល់ការងារ
- គ្រប់គ្រងដីរដ្ឋ បរិស្ថាន និងធនធានធម្មជាតិ ជំរុញអភិវឌ្ឍន៍បៃតង និងការបង្ការទប់ស្កាត់គ្រោះមហន្តរាយ ជាក្រុងគោលដៅទេសចរណ៍ស្អាត ឆ្អាតវៃ គ្មានថង់ប្លាស្ទិក និងមេដែកឆក់ប្រកបដោយគុណភាព និងភាពប្រកួតប្រជែងខ្ពស់នៅភាគខាងត្បូងអាស៊ាន
- លើកកម្ពស់គុណភាព ប្រសិទ្ធភាព នៃការគ្រប់គ្រង ការកែលម្អ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាភាពសុខដុមនីយកម្មសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយ និងឆ្លើយតបបានល្អតាមតម្រូវការរបស់ប្រជាពលរដ្ឋទូទៅ និងតម្រូវការគ្រប់គ្រងជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សគម្រោងអភិវឌ្ឍក្រុងបូកគោ

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្តង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោត្រូវបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ចនិងការធ្វើសមាហរណកម្ម ការអភិវឌ្ឍនិងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម÷

៤.១-យុទ្ធស្រាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

៤.១.១ - ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម

- រៀបចំបទដ្ឋានគតិយុត្ត និងបច្ចេកទេស សម្រាប់បង្កើតនិងគ្រប់គ្រងក្រុងបូកគោ ជាក្រុងឆ្អាតវៃ ប្រវត្តិសាស្ត្រ បៃតង ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំហេដ្ឋារចនាសម្ព័ន្ធនិងសោភ័ណភាពក្រុងមាន ចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ភ្លើងបំភ្លឺ ផ្ទាំកសញ្ញាចរាចរ ឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ គុណភាពបរិស្ថានល្អ សមស្របជាក្រុងទេសចរណ៍ប្រវត្តិសាស្ត្រ ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំកសាងមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លំហសាធារណៈ កំណត់ប្រភេទនិងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង ឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយសុខភាពល្អ សម្រាប់មនុស្សទាំងអស់គ្នា
- កសាងបណ្តាញទឹកស្អាត បណ្តាញអគ្គិសនី គ្រប់គ្រងសំណល់រឹងនិងរាវ តាមលក្ខណៈបច្ចេកទេស និងប្រកបដោយគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភ័ណភាពក្រុង

- រៀបចំនិងកំណត់រចនាបទអគារ ពណិអគារ និងកំណត់ផ្ទាកសញ្ញាផ្សាយពាណិជ្ជកម្ម តាមដងផ្លូវនិង តាមតំបន់ឱ្យមានសណ្តាប់ធ្នាប់និងសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ ប្តង់ លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ ស្របតាមទីតាំងភូមិសាស្ត្រ
- គ្រប់គ្រងការអភិវឌ្ឍ និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍរួបរួន ជាពិសេសបណ្តាញ ផ្លូវ ស្ថានីយចម្រោះទឹកស្អាត ប្រព័ន្ធលូនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ អាងបង្កន់អនាម័យ ដោយជំរុញ ការអភិវឌ្ឍ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខា និងសេវាកម្មទីក្រុងជាមុន
- ពង្រឹងសមត្ថភាពមន្ត្រីធ្វើផែនការអភិវឌ្ឍ និងគ្រប់គ្រងការអភិវឌ្ឍ ជាពិសេសប្រសិទ្ធភាពនៃគណៈ កម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្ត ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ជាសេនាធិការក្នុងការគ្រប់គ្រង និងអនុវត្តន៍ការងាររៀបចំដែនដីនិងនគរូបនីយកម្ម។

៤.១.២-យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី

ផ្អែកលើអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ អនុក្រឹត្យ លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស"បូកគោ" និង ឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" គម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរ ប្រភេទគឺ ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់។ ឧទ្យានជាតិព្រះមុនីវង្សនេះមានផ្ទៃដី សរុប ១៥៤ ៤៥៨ ហិកតា ត្រូវបានកំណត់ជាប្រភេទដីអាចសាងសង់បានមានចំនួន ២៧ ៩៤៣ ហិកតា ស្មើនឹង ១៨,០៩% នៃផ្ទៃដីឧទ្យាន និងប្រភេទដីកម្រិតការសាងសង់មានចំនួន ១២៦ ៥១៥ ហិកតា ស្មើនឹង ៨១,៩១ % នៃ ផ្ទៃដីឧទ្យានទាំងមូល។ ផ្ទៃដីដែលបានធ្វើអនុប្រយោគ និងបានប្រគល់ជូនក្រុមហ៊ុន សុខា អ្ងតែល ចំនួន ១៨ ៩៨៧ ហិកតា អនុក្រឹត្យលេខ ៥៩ អនក្របក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

ក)-ប្រភេទដីកម្រិតការសាងសង់

ផ្អែកតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដាក់ឱ្យប្រើប្រាស់ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងអនុក្រឹត្យលេខ ៥៩ អនក្របក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១ស្តីពីការកំណត់ តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព អនុក្រឹត្យស្តីពីការធ្វើអនុប្រយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដីតំបន់ប្រើប្រាស់ដោយចិរភាព នៃតំបន់ឧទ្យានជាតិព្រះមុនីវង្ស"បូកគោ" ក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តព្រះសីហនុចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១១ និងបទដ្ឋានគតិយុត្តជាធរមាន ប្រភេទដីកម្រិតការសាងសង់ត្រូវបានកំណត់ជាតំបន់ ដូចខាងក្រោម÷

១. តំបន់ការពារនៃឧទ្យានជាតិព្រះមុនីវង្ស÷ មានផ្ទៃដីទំហំ ៨១ ២៥៧ ហិកតា ស្មើនឹង ៥២,៦១% នៃផ្ទៃដី ឧទ្យានព្រះមុនីវង្សបូកគោ នៅសល់ក្រោយពីជួលឱ្យទៅក្រុមហ៊ុន សុខាអ្ងតែល និងរៀបចំជាតម្រាង

អភិវឌ្ឍក្រុងបូកគោ។ តាមការចុះសិក្សានៅទីតាំងជាក់ស្តែង តំបន់នេះមានរូបភាពប្រើប្រាស់ជាទីក្រុងប្រវត្តិសាស្ត្រ ភ្នំ ធនធានទឹក ព្រៃឈើ ផ្លូវគមនាគមន៍ និងតំបន់កសិកម្ម។

២. តំបន់ធនធានទឹក÷ រួមមានអូរ ប្រឡាយ ត្រពាំង ស្ទឹង អាងស្តុកទឹក មានផ្ទៃទឹកប្រមាណ ១ ០៩៤ ហិកតា ស្មើនឹង ០,៧១% នៃផ្ទៃដីឧទ្យានព្រះមុនីវង្ស (មិនគិតតំបន់ធនធានទឹកដែលមាននៅក្នុងដីក្រុមហ៊ុន សុខា អូតែល)។ តំបន់នេះ ជាសក្តានុពលដ៏សំខាន់ដែលត្រូវស្តារ ការពារ និងថែរក្សា ដើម្បីប្រើប្រាស់សម្រាប់គាំទ្រដល់ការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធរំដោះទឹកជំនន់ អាងប្រព្រឹត្តិកម្មទឹកកខ្វក់តាមបែបធម្មជាតិ ផ្លូវទឹក និងវិស័យកសិកម្ម ព្រោះផលិតផលកសិកម្មធម្មជាតិនេះជាធាតុសំខាន់ក្នុងការផ្គត់ផ្គង់ជាអាហារ សម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។

៣. តំបន់កសិកម្ម÷ ដីកសិកម្មជាសួនសត្វ មានទំហំផ្ទៃដីប្រមាណ ១៦០ ហិកតា ស្មើនឹង ០,១០% នៃផ្ទៃដីឧទ្យានព្រះមុនីវង្ស។ តំបន់នេះត្រូវ÷

- រក្សាផ្ទៃដីកសិកម្ម ដែលមានសក្តានុពល សម្រាប់ដំណាំស្រូវ ការចិញ្ចឹមសត្វ ដាំបន្លែ និងវារិវប្បកម្ម ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមបណ្តាំគោលប្រើប្រាស់ដីនេះ
- ធ្វើផែនការគ្រប់គ្រងផ្ទៃដីកសិកម្មដោយធ្វើការកំណត់ និងបែងចែកតំបន់សក្តានុពលកសិកម្មឱ្យបានច្បាស់លាស់
- អនុវត្តផែនការពង្រីកក្រុងតាមបច្ចេកទេសទំនើប ដើម្បីកាត់បន្ថយជាអតិបរមាដល់ផ្ទៃដីកសិកម្មដែលបានបម្រុងទុក និងពង្រីកដីកសិកម្មបន្ថែមនៅតាមទីជម្រាលភ្នំ។

៤. តំបន់ដីក្រុមហ៊ុន សុខា អូតែល÷ តំបន់នេះមានទំហំប្រមាណ ១៨ ៩៨៧ ហិកតា ស្មើនឹង ១២,២៥% នៃផ្ទៃដីឧទ្យានព្រះមុនីវង្ស។ ទីតាំងនេះត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុន សុខា អូតែល បង្កើតជាមជ្ឈមណ្ឌលទេសចរណ៍ ការស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីកម្រិតការសាងសង់ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន ស្របតាមអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីការអភិវឌ្ឍដី។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្ម ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ០,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ១០% ឆ្ងាគម្លាតអគារខាងមុខយ៉ាងតិ ១០ ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្តាលគម្លាតអគារខាងមុខ កម្ពស់អគារអតិបរមាស្មើនឹង ៨ ម៉ែត្រ សួនច្បារដែលអាចជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច ៦៥% នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច ១ ដើម សម្រាប់ផ្ទៃក្រឡាដីឡូត៍ ៤៩ ម៉ែត្រក្រឡា។

ខ)-ប្រភេទដីអាចសាងសង់បាន

គម្រោងអភិវឌ្ឍក្រុងបូកគោ ត្រូវបានបែងចែកជា ៨ ទីតាំងធំៗ ហើយទីតាំងនីមួយៗត្រូវបានកំណត់ការប្រើប្រាស់ដីជាតំបន់ ហើយតំបន់នីមួយៗត្រូវមានបទប្បញ្ញត្តិនៃការប្រើប្រាស់ផ្សេងៗគ្នា។

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ២០៣៥ ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជា ៩ តំបន់សំខាន់ៗ រួមមាន តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់ទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាកម្មសាធារណៈ តំបន់លំហសាធារណៈនិងផ្នែបៃតង តំបន់វប្បធម៌ និងសាសនា និងតំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ការដាំដើមឈើ ជួរតម្រង់ ធ្លាគម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្ទឹកកខ្វក់ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិជាធរមាន និងបែងចែកជាតំបន់ប្រើប្រាស់ដី ដូចខាងក្រោម៖

១. តំបន់លំនៅឋាន÷ តំបន់នេះស្ថិតនៅគម្រោងអភិវឌ្ឍទាំង ៨ ទីតាំង នៃគម្រោងអភិវឌ្ឍក្រុងបូកគោ មានផ្ទៃដីប្រមាណ ៣ ៣៩០ ហិកតា ស្មើនឹង ៣៧,៨៥% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ។ តំបន់លំនៅឋានត្រូវបានបែងចែកជាតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប តំបន់លំនៅឋានដែលមានកម្ពស់មធ្យម តំបន់លំនៅឋានមានកម្ពស់ខ្ពស់ និង តំបន់លំនៅឋានចម្រុះ។ តំបន់នេះត្រូវបានកំណត់និងបែងចែកជា៖

- បទប្បបញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ១,០
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
  - សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
  - ធ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៤ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ២ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
  - ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។
- បទប្បបញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ១,៥
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
  - សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
  - ធ្លាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៤ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ២ ម៉ែត្រ

- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានដែលមានកម្ពស់មធ្យមត្រូវកំណត់÷
- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ឆ្ងាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៦ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ៣ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានកម្ពស់ខ្ពស់ត្រូវកំណត់÷
- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ឆ្ងាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ៨ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ៣,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំនៅឋានចម្រុះត្រូវកំណត់÷
- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ៦០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ឆ្ងាគម្លាតអប្បបរមាខាងមុខជាប់ផ្លូវ ១០ ម៉ែត្រ ខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច ៤ ម៉ែត្រ

- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

២. តំបន់ពាណិជ្ជកម្ម÷ តំបន់នេះមានផ្ទៃដីប្រមាណ ៨២១ ហិកតា ស្មើនឹង ៩,១៧% នៃផ្ទៃដីអាចសាងសង់បានក្នុងតំបន់គម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតនៅគម្រោងទី ១ និងទី ៣ ដល់ទី ៨ និងត្រូវបែងចែកជាតំបន់ពាណិជ្ជកម្មជាផ្សារ និងតំបន់ពាណិជ្ជកម្មចម្រុះ ដែលត្រូវជំរុញអភិវឌ្ឍលម្ហសាធារណៈ និងផ្ទៃបៃតងឱ្យបានសមស្រប។ តំបន់នេះត្រូវបានកំណត់និងបែងចែកជា៖

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ពាណិជ្ជកម្មជាផ្សារ ត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៦០%
  - សួនច្បារជ្រាបទឹកយ៉ាងតិច ៣០% នៃផ្ទៃដីឡូត៍សរុប
  - ឆ្ងាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៦ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៣ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
  - ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ៥០ ម៉ែត្រការ៉ែ។

– បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ពាណិជ្ជកម្មចម្រុះ ត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមាស្មើនឹង ៧០%
  - សួនច្បារជ្រាបទឹកយ៉ាងតិច ២០% នៃផ្ទៃដីឡូត៍សរុប
  - ឆ្ងាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៦ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៣ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
  - ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ៥០ ម៉ែត្រការ៉ែ។

៣. តំបន់ចម្រុះ÷ តំបន់នេះមានផ្ទៃដីប្រមាណ ៣៨០ ហិកតា ស្មើនឹង ៤,២២% នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅក្នុងគម្រោងអភិវឌ្ឍទាំង ៨ ទីតាំង ដូចបានកំណត់ក្នុងផែនទី លាយឡំក្នុងតំបន់លំនៅឋាន តំបន់ទេសចរណ៍ និងតំបន់ពាណិជ្ជកម្ម មានមុខងារប្រើប្រាស់ច្រើនយ៉ាង ដូចជា សិប្បកម្ម ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ និងសេវាកម្មផ្សេងៗ ។ តំបន់នេះត្រូវបានយកចិត្តទុកដាក់ដោយធានាបាននូវបរិស្ថានល្អ និងរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ចម្រុះត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- កំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ២,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៧០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ៣០% នៃផ្ទៃដីឡូត៍សរុប
- ឆ្ងាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ២,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

៤. តំបន់ដឹកជញ្ជូន÷ តំបន់នេះមានផ្ទៃដីប្រមាណ ៦៤៤ ហិកតា ស្មើនឹង ៧,១៧% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ រួមមាន ប្រព័ន្ធផ្លូវ និងចំណតរថយន្តផ្សេងៗ។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ដឹកជញ្ជូនត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៦០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ឆ្ងាគម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ២,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់

ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉េ។

៥. តំបន់ទេសចរណ៍÷ តំបន់នេះមានផ្ទៃដីប្រមាណ ៨៥៦ ហិកតា ស្មើនឹង ៩,៥១% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតនៅក្នុងគម្រោងអភិវឌ្ឍទាំង ៨ ទីតាំង លើកលែងតែក្នុងគម្រោង

ទី ៥។ តំបន់ទេសចរណ៍ត្រូវរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ទេសចរណ៍ត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- កំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ១,៥
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ផ្លាតម្លាតអប្បបរមាផ្នែកខាងមុខជាប់ផ្លូវ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ២,៥ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

៦. តំបន់រដ្ឋបាលនិងសេវាសាធារណៈ÷ តំបន់នេះមានផ្ទៃដីប្រមាណ ៩៩៥ ហិកតា ស្មើនឹង ១១,១១% នៃផ្ទៃដីអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតក្នុងគម្រោងទី ១ ទី ២ ទី ៥ ដល់ទី ៨។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់រដ្ឋបាលនិងសេវាសាធារណៈត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនិងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៦០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ផ្លាតម្លាតអប្បបរមាផ្នែកខាងមុខ ៨ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៤ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

៧. តំបន់លំហសាធារណៈ និងផ្ទៃបៃតង÷ សួនច្បារសាធារណៈ មានផ្ទៃដីប្រមាណ ១ ១០២ ហិកតា ស្មើនឹង ១២,៣០% នៃផ្ទៃដីដែលអាចសាងសង់បានក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោទាំង ៨ ទីតាំង។ ក្រៅពីនេះ ផ្ទៃបៃតងជាតំបន់ទ្រនាប់ តំបន់កសិកម្ម និងតំបន់ការពារ ស្ថិតក្នុងតំបន់កម្រិតការសាងសង់ មានប្រមាណ ១២៥ ៤២១ ហិកតា ស្មើនឹង ៨០,២០% នៃផ្ទៃដីឧទ្យានជាតិព្រះមុនីវង្ស។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់លំហសាធារណៈ ត្រូវកំណត់÷

- សំណង់សាធារណៈត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ

- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ០,៣
- សួនច្បារសាធារណៈ និងដាំដើមឈើកំណត់បង្ហាញអំពីអត្តសញ្ញាណទីតាំងភូមិសាស្ត្រ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវរៀបចំចំណតរថយន្តសម្រាប់សាធារណៈ
- ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការ និងជនងាយរងគ្រោះ។

៨. តំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស÷ តំបន់នេះមានផ្ទៃដីទំហំប្រមាណ ៦៣៧ ហិកតា ស្មើនឹង ៧,១១% នៃផ្ទៃដីដែលអាចសាងសង់បាននៃគម្រោងអភិវឌ្ឍក្រុងបូកគោ។ តំបន់នេះ រួមមាន ស្ថានីយចម្រោះទឹកស្អាត អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងទីលានទុកដាក់សំរាម។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសត្រូវកំណត់÷

- សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,០
- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង ៥០%
- សួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីឡូត៍សរុប
- ឆ្ងាយម្តាតអប្បបរមាផ្នែកខាងមុខ ៨ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង ៤ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍ ១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច ១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញាត្តិចែងផ្សេងពីនេះ
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ/ស្របតាមលក្ខណៈធម្មជាតិនៃតំបន់
- ត្រូវមានចំណតរថយន្តតូច ១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់ ១០០ ម៉ែត្រការ៉ែ។

គម្រោងអភិវឌ្ឍ និងសាងសង់ក្នុងប្រភេទដីអាចសាងសង់បាននេះ តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន ស្របតាមអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ប្រកាសលេខ ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៥ ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី និងប្រកាសលេខ ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីការអភិវឌ្ឍដី។

៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍទេសចរណ៍តំបន់ ក៏ដូចជានៅទូទាំងប្រទេសកម្ពុជា។ តំបន់អភិវឌ្ឍក្រុងបូកគោមានសក្តានុពលទេសចរណ៍ជាច្រើន ដូចជា ធនធានធម្មជាតិលើភ្នំ ឆ្នេរសមុទ្រ ព្រៃឈើ សត្វព្រៃ ទេសភាព អាកាសធាតុ និងតំបន់រមណីយដ្ឋានទេសចរណ៍នានា ជាពិសេសរមណីយដ្ឋានទសចរណ៍ឋានសួគ៌បូកគោ និងរមណីយដ្ឋានទេសចរណ៍ក្នុងខេត្តជាច្រើនទៀត ហើយជាគោលដៅទេសចរណ៍ពេញនិយមសម្រាប់ការស្នាក់នៅ និងលំហែកម្សាន្ត។

គម្រោងអភិវឌ្ឍក្រុងបូកគោនេះ បានតភ្ជាប់ជាមួយតំបន់ឆ្នេរដែលស្ថិតនៅក្នុងច្រករបៀងទេសចរណ៍ភាគខាងត្បូង ជាតារាះនាទិសនិរតីនៃប្រទេសកម្ពុជា រួមមាន ខេត្តកំពត កែប ព្រះសីហនុ និងខេត្តកោះកុង ដែលជាប៉ូលទេសចរណ៍ដ៏មានសារៈសំខាន់។ បច្ចុប្បន្ន ភាពល្បីល្បាញនៃភ្នំបូកគោ បានបំពេញតួនាទីស្នូលក្នុងការជម្រុញការអភិវឌ្ឍទេសចរណ៍តំបន់ភ្នំ ភ្ជាប់ជាមួយឆ្នេរសមុទ្រ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ផ្នែកឯកជន រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ គ្រប់ទីកន្លែងដែលមានសក្តានុពលទេសចរណ៍វប្បធម៌ និងធម្មជាតិ ត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរទៅទស្សនា និងរៀបចំយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍នៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋាន គឺជាអាទិភាព។

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ រួមមាន÷

៤.២.១-តំបន់ទេសចរណ៍

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍសំណង់ស្ថាបត្យកម្មលក្ខណៈខ្មែរ វប្បធម៌ សាសនា ដោយផ្សាភ្ជាប់នឹងទេសភាពវប្បធម៌ធម្មជាតិមានព្រៃឈើ សមុទ្រនិងភ្នំ
- ជំរុញអនុវត្តសេចក្តីថ្លែងការណ៍បូកគោ ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការអភិវឌ្ឍទីក្រុងតំបន់ឆ្នេរសមុទ្រប្រកបដោយនិរន្តរភាព
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- បង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងផលិតផលទេសចរណ៍ រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិពរណ៌ផលិតផលក្នុងស្រុក
- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សារពេលរាត្រី លំនៅឋានទេសចរណ៍ បង្កភាពងាយស្រួលដល់ភ្ញៀវទេសចរ
- កែលម្អ និងរៀបចំផ្លូវមេ ផ្លូវដីកជញ្ជួន ផ្លូវសម្រាប់យានយន្ត ផ្លូវថ្មើរជើង និងបណ្តាញបៃតង ធានាបាននូវសោភ័ណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ ពិសេសនៅតាមកន្លែងកម្សាន្ត និងកន្លែងស្នាក់នៅ
- លើកកម្ពស់អនាម័យចំណីអាហារ និងប្រព័ន្ធត្រួតពិនិត្យស្តង់ដារ។

៤.២.២-ផលិតផលទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានទេសចរណ៍

- ជំរុញការរៀបចំអភិវឌ្ឍន៍ផលិតផលទេសចរណ៍ធម្មជាតិតាមព្រៃភ្នំ អភិវឌ្ឍការធ្វើដំណើរតាមរយៈការស្គាននយោលទេសចរណ៍ក្នុងព្រៃឈើ ដើម្បីគយគន់ព្រៃឈើ សមុទ្រ ព្រះអាទិត្យរះលិច ហ្វឹងជ្រលក់លើអាកាស ទេសភាពលំនៅឋាន ស្រូបយកខ្យល់អាកាសបរិសុទ្ធ និងទឹកផ្លែឈើ

- រៀបចំសួនច្បារកម្សាន្ត និងទេសភាពធម្មជាតិ សម្រាប់ភ្ញៀវទេសចរ ប្រជាជននៅមូលដ្ឋាន និងកុមារមនុស្សវ័យចាស់
- បង្កើតចំការកង្ហារលើភ្នំសម្រាប់វិស័យថាមពល និងទស្សនាកម្សាន្ត
- រៀបចំឱ្យមានតំបន់ទេសចរណ៍សម្រាកកម្សាន្តបឹងហ្គាឡូ តាមមាត់ទឹក និងតាមជម្រាលភ្នំ
- អភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ សាសនា ជាព្រលឹងរបស់ភ្នំ របស់ជាតិ និងតំបន់
- អភិវឌ្ឍទេសចរណ៍ទេសភាពតាមជម្រាលភ្នំ ការដាំដើមឈើ-ផ្កា ការធ្វើកសិកម្មសេរីរាង្គមានស្ថេរបូកគោ ប៉េងប៉ោះ ផ្កាបំពង់ឡោម ចំការតែ
- អភិវឌ្ឍឱ្យមានស្ពាន និងផ្លូវសម្រាប់ដើរលម្ហែកាយ និងស្រូបខ្យល់អាកាសតាមព្រៃភ្នំ
- អភិវឌ្ឍផ្ទះលម្ហែសម្រាក រីហ្សត ភោជនីយដ្ឋាន ក្លឹបកម្សាន្ត កន្លែងហាត់កីឡា តាមទីជម្រាលភ្នំ ការប្រណាំងទូកក្នុងបឹងលើភ្នំ។

៤.២.៣-ខ្សែទស្សនាកម្សាន្ត ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍
- រៀបចំកម្មវិធីបុណ្យជាតិ និងព្រឹត្តិការណ៍ទាក់ទាញទេសចរណ៍។

៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស

- បណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដារទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ទេសចរណ៍
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈលើវិស័យទេសចរណ៍
- ចលនាផ្នែកឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

ឧទ្យានជាតិព្រះមុនីវង្ស ស្ថិតក្នុងខេត្តចំនួន ៣ គឺ ខេត្តកំពត ព្រះសីហនុ និងខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នឧទ្យាននេះប្រើផ្លូវសំខាន់មួយភ្ជាប់ពីផ្លូវជាតិលេខ ៣ មកកាត់តាមរមណីយដ្ឋានឋានសួគ៌បូកគោ និងភ្ជួរទៅដល់លើកំពូលភ្នំ។ ហេដ្ឋារចនាសម្ព័ន្ធគម្រោងអភិវឌ្ឍក្រុងបូកគោត្រូវពង្រឹង និងលើកកម្ពស់សម្រាប់វិស័យទេសចរណ៍ សេដ្ឋកិច្ច បរិស្ថាន និងសង្គម រួមមាន÷

៤.៣.១-អ័ក្សទេសចរណ៍-ពាណិជ្ជកម្ម

- តភ្ជាប់ផ្លូវមេពីផ្លូវជាតិលេខ ៣ ត្រង់ចំណុចច្រកចូលរមណីយដ្ឋានឋានសួគ៌បូកគោ ឆ្លងកាត់ឧទ្យានជាតិព្រះមុនីវង្ស កាត់តាមរមណីយដ្ឋានឋានសួគ៌បូកគោ មកគម្រោងអភិវឌ្ឍក្រុងបូកគោទាំង ៨ ទីតាំង និងតភ្ជាប់ទៅផ្លូវជាតិលេខ ៤ ត្រង់ចំណុចជិតភូមិសាស្ត្រស្ទឹងច្រាល
- សាងសង់ផ្លូវមេតភ្ជាប់សំខាន់ ចេញពីគម្រោងអភិវឌ្ឍក្រុងបូកគោក្នុងទីតាំងគម្រោងទី ១ ភ្ជាប់ទៅផ្លូវជាតិលេខ ៤ ត្រង់ចំណុចទីប្រជុំជនស្រុកកំពង់សិលា ខេត្តព្រះសីហនុ
- សាងសង់ផ្លូវមេតភ្ជាប់រវាងតំបន់រមណីយដ្ឋានឋានសួគ៌បូកគោ ទៅនឹងគម្រោងអភិវឌ្ឍក្រុងបូកគោទាំង ៨ ទីតាំង។

៤.៣.២-ផ្លូវថ្នល់

យុទ្ធសាស្ត្រស្តារអភិវឌ្ឍន៍ និងការពារបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធនៃគម្រោងអភិវឌ្ឍក្រុងបូកគោ មានដូចខាងក្រោម÷

- ស្តារនិងជួសជុល និងពង្រីកផ្លូវជាតិលេខ ៣២ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ និងប្រើប្រាស់សម្រាប់ទេសចរណ៍ ពាណិជ្ជកម្ម
- រៀបចំកសាង និងកែលម្អផ្លូវក្នុងក្រុងឱ្យមានគុណភាព សុវត្ថិភាព និងសោភ័ណភាព ស្របតាមគោលការណ៍អភិវឌ្ឍន៍បៃតង
- រៀបចំចំណតរថយន្តសាធារណៈឱ្យស្របតាមបទដ្ឋានទីក្រុងទេសចរណ៍ស្អាត
- សាងសង់ផ្លូវក្រវាត់ក្រុងតភ្ជាប់គម្រោងទីតាំងអភិវឌ្ឍទាំង ៨ ទីតាំង ដើម្បីងាយស្រួលធ្វើចរាចរនិងបញ្ចៀសការកកស្ទះចរាចរណ៍
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធ តភ្ជាប់ផ្នែកកណ្តាលក្រុង ទៅកាន់ភាគខាងជើង និងភាគខាងត្បូងក្រុង ជាពិសេសតំបន់រមណីយដ្ឋានឋានសួគ៌បូកគោ ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ។

៤.៣.៣-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- សិក្សា និងរៀបចំចំការកង្ហារអគ្គិសនីសម្រាប់ជាប្រភពថាមពលបម្រើដល់តំបន់
- ធ្វើឱ្យប្រសើរឡើង និងអភិវឌ្ឍវិស័យថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម
- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ប្រជាជននៅក្នុងក្រុង
- បន្ត និងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់យានយន្តប្រើអាគុយ។

៤.៣.៤-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

- រៀបចំលម្ហសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្ស គ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការ ឱ្យទទួលបាននូវសេវា ប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការនៅតាមទីសាធារ ណៈ អគារសាធារណៈនិងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិត ស្របតាមអនុក្រឹត្យស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជននិង កីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែង សង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាន ស្របតាមបទដ្ឋាន បច្ចេកទេសរបស់ក្រសួងសុខាភិបាល
- បង្កើតមជ្ឈមណ្ឌលថែទាំសុខភាព ថែទាំវេជ្ជសាស្ត្រ និងខ្យល់អាកាសធម្មជាតិ។

៤.៣.៥-ការផ្គត់ផ្គង់ទឹកស្អាត

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោដោយផ្ទាល់។ អាជ្ញាធរខេត្ត ក្រុង និងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំប្រព័ន្ធផ្គត់ផ្គងទឹកមេ ឱ្យបានមុនការសាងសង់សំណង់ផ្សេងៗ និងពង្រីក បន្ថែមបណ្តាញចែកចាយដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ តម្រូវការសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតក្នុង តំបន់គម្រោងអភិវឌ្ឍក្រុងបូកគោគឺមានដូចខាងក្រោម÷

- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដានប្រភពទឹក ដើម្បីធានានូវបរិមាណទឹកស្អាតពីអាងស្តុកទឹក
- សិក្សាប្រភពទឹកផ្សេងៗ ពិសេសប្រភពទឹកបានមកពីផ្នែរងទឹកភ្លៀង របស់អាងស្តុកទឹកទាំងពីរន្លែង របស់ក្រុង និងធានាថាមិនមានការបំពុល ដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់ក្រុង
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗដើម្បីការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្រប តាមការរីកចម្រើន និងការប្រើប្រាស់
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹក ស្របតាមបទដ្ឋានបច្ចេកទេស។
- សិក្សា និងសាងសង់អាងស្តុកទឹក និងពង្រីកបណ្តាញចែកចាយទឹកបន្ថែម។

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

- យកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះជាពិសេសប្រជាជនដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- ជម្រុញឱ្យសហគមន៍ទទួលបានការគាំទ្រ និងលើកទឹកចិត្តពីផ្នែកសាធារណៈ សង្គមស៊ីវិល និងសេវាកម្មសុខភាព
- ជម្រុញការអភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទ ឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបាន ដើម្បីលើកកម្ពស់កម្រិតជីវភាព
- សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យបានការរស់នៅរបស់ប្រជាជនក្នុងតំបន់ប្រកបដោយសន្តិសុខ និងសុវត្ថិភាព។

៤.៥-យុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាន ធនធានធម្មជាតិ និងការអភិវឌ្ឍបៃតង

៤.៥.១-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

ទីលានចាក់សំរាមរបស់គម្រោងអភិវឌ្ឍក្រុងបូកគោ បានរៀបចំចំនួន ២ ទីតាំង ស្ថិតនៅផ្នែកខាងលិចក្រុងមួយកន្លែង និងខាងកើតក្រុងមួយកន្លែងទៀត និងមានចំងាយ ៥ គីឡូម៉ែត្រ ពីទីប្រជុំជនក្រុង។ ទីតាំងទាំងពីរនេះមានទំហំនិងចំងាយសមស្របសម្រាប់ទុកដាក់សំរាម។ ដូចនេះ ដើម្បីគ្រប់គ្រងសំណល់រឹងឱ្យបានល្អ សម្រាប់ទីតាំងទាំងពីរនេះ ត្រូវមានយន្តការ និងបទដ្ឋានបច្ចេកទេសដូចខាងក្រោម÷

- រៀបចំបង្កើតទីលានចាក់សំរាមដោយមានការអនុញ្ញាត និងគោរពតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងបរិស្ថាន
- បង្កើនការផ្សព្វផ្សាយដល់ប្រជាជនពីការញែកសំរាម ហើយអាចពង្រីកបន្ថែមនៅតាមសាលា និងទីសាធារណៈផ្សេងៗទៀត
- ផ្តល់លេខកូដធុងញែកសំរាមតាមពិណ ឬថង់សំរាមស្រាលៗដល់អ្នករើសសំរាម
- ជំរុញការសហការវាងកន្លែងគរសំរាមមានស្រាប់ ដើម្បីញែក និងកាត់បន្ថយបរិមាណសរីរាង្គនៃសំណល់
- អ្នករើសសំរាមអាចទទួលបានវគ្គបណ្តុះបណ្តាល បង្កើនចំណេះដឹងស្វែងយល់ពីកាកសំណល់ដើម្បីផលិតសម្ភារៈ ធ្វើឱ្យការងារកាន់តែល្អប្រសើរសម្រាប់អ្នករើសសំរាមជាមួយនឹងទីកន្លែងធ្វើការសមរម្យនៅក្នុងរោងដែលមានខ្យល់ចេញចូលល្អ ដើម្បីចៀសវាងបានពីតំបន់មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ
- ផ្តល់សម្ភារៈធ្វើការប្រកបដោយសុវត្ថិភាព និងទុនសម្រាប់ការបណ្តុះបណ្តាល
- បង្កើតយន្តការ និងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុង
- រៀបចំមធ្យោបាយប្រមូលសំណល់រឹង និងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដារទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង

- ជំរុញឱ្យមានការអនុវត្តគោលការណ៍ ការកាត់បន្ថយការប្រើប្រាស់ឡើងវិញ និងការកែច្នៃ លើការគ្រប់គ្រងសំណល់រឹង បង្កើតគម្រោងជីកំប៉ុស្ដិ៍
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់វិស័យឯកជន និងសាធារណៈ។

៤.៥.២-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

ភូមិសាស្ត្រនិងសណ្ឋានដីជាខ្ពង់រាបនេះ ធ្វើឱ្យមានការលំបាលដល់ការគ្រប់គ្រងសំណល់រាវដែលចេញពីអគារលំនៅឋាន ពាណិជ្ជកម្ម ទេសចរណ៍ និងរដ្ឋបាលសេវាសាធារណៈ នៃគម្រោងអភិវឌ្ឍក្រុងបូកគោ ប៉ុន្តែលំហូរទឹកភ្លៀងមានទិសដៅច្បាស់លាស់ និងចាក់ចូលទៅក្នុងគន្លងដីដែលមានរយៈកម្ពស់ទាប ជាហេតុធ្វើឱ្យងាយនឹងលាយលំគ្នារវាងទឹកភ្លៀង និងទឹកកខ្វក់ និងប៉ះពាល់ដល់អាងស្តុកទឹកស្អាតសម្រាប់ផ្គត់ផ្គង់ដល់ក្រុង។ គម្រោងបានសិក្សារកទីតាំងដីចំនួន ៣ ទីតាំង ដែលមានទំហំសរុបប្រមាណ ១០០ ហិកតា សម្រាប់ធ្វើជាអាងប្រព្រឹត្តិកម្មទឹកកខ្វក់របស់ក្រុង។ ដូចនេះដើម្បីគ្រប់គ្រងសំណល់រាវឱ្យបានល្អ ត្រូវមានបទដ្ឋានបច្ចេកទេស និងយន្តការដូចខាងក្រោម÷

- អាជ្ញាធរក្រុង និងស្ថាប័នមានសមត្ថកិច្ចត្រូវគ្រប់គ្រង និងថែរក្សាឱ្យបានប្រភពធនធានទឹកធម្មជាតិដូចជា អូរ ប្រឡាយ អាងស្តុកទឹក បឹងធម្មជាតិ ផ្លូវទឹកផ្សេងៗ សម្រាប់ជាប្រព័ន្ធលូទឹកភ្លៀង អាងស្តុកទឹកជំនន់ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់តាមបច្ចេកទេសទំនើបដែលមានការអនុញ្ញាតពីក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ
- រៀបចំ និងកសាងប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងបរិស្ថាន មុននឹងបង្ហូរចូលបំពង់លូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់ សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្ម និងអាងបង្កន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាព ដែលជាតារៈនៅទីសន្ទីរតី។

៤.៥-៣. ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

ការបែងចែកតំបន់ប្រើប្រាស់ដី សម្រាប់ការការពារបរិស្ថានមានដូចខាងក្រោម÷

- តំបន់អភិវឌ្ឍនគរូបនីយកម្ម
- តំបន់ការពារនៃឧទ្យានជាតិព្រះមុនីវង្សបូកគោ
- តំបន់ទ្រនាប់ក្រុង
- តំបន់ធនធានទឹក រួមមាន អូរ ប្រឡាយ អាងស្តុកទឹក ស្ទឹង បឹង បណ្តាញផ្លូវទឹក
- តំបន់កសិកម្ម តាមរយៈជំរុញបង្កើតសួនបន្លែសេរីរាង្គ រក្សាអត្តសញ្ញាណស្លែបូកគោ ដំណាំតែ រុក្ខជាតិផ្កាបំពង់ឡោម និងរុក្ខជាតិធម្មជាតិច្រើនទៀត។

៤.៥.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារ និងថែរក្សាភ្នំ ព្រៃឈើ បឹង អូរ និងប្រព័ន្ធបណ្តាញផ្លូវទឹក ស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារ និងថែរក្សាព្រៃក្នុងតំបន់ទីជម្រាល ដើម្បីធានាការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីន តាមរយៈការផ្តត់ផ្តង់អគ្គិសនីពីចំការអគ្គិសនីឱ្យបានច្រើនបំផុតក្នុងតំបន់ក្រុង
- ការលើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថានក្នុងតំបន់កណ្តាលក្រុង និងក្នុងទឹក
- លើកកម្ពស់ចំណេះដឹងបរិស្ថានដល់ប្រជាជន និងរៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាន ដោយមានការចូលរួមពីវិស័យឯកជន។

៤.៦-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

គម្រោងអភិវឌ្ឍក្រុងបូកគោ ស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស ដែលមានភូមិសាស្ត្រជាតំបន់ភ្នំ ខ្ពង់រាប និងជាប់មាត់សមុទ្រ ជាហេតុធ្វើឱ្យទីតាំងនេះ តែងតែទទួលរងគ្រោះរាំងស្ងួត ខ្យល់កន្ត្រាក់ និងអាកាសធាតុត្រជាក់ខ្លាំង។ ដូចនេះ ដើម្បីទប់ស្កាត់ផលប៉ះពាល់ពីគ្រោះមន្តរាយទាំងអស់នេះបានទាន់ពេលវេលា ត្រូវមានយន្តការ និងយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម÷

- ការពារធនធានធម្មជាតិ ជីវចម្រុះ ព្រៃឈើ និងតំបន់ឆ្នេរ ដើម្បីរក្សាបានតុល្យភាពបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ដោយមានការដាំដើមឈើឱ្យបានច្រើននៅតំបន់លម្ហសាធារណៈ និងតាមលំនៅឋាន
- ត្រូវរៀបចំប្រព័ន្ធរំដោះទឹកភ្លៀងដូចជា ស្តារអូរ ប្រឡាយ បឹង ត្រពាំង រៀបចំទំនប់ទឹក អាងស្តុកទឹក និងបណ្តាញផ្លូវទឹកផ្សេងៗទៀត
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពកាយយកដីភ្នំ និងការកាប់ទន្ទ្រានព្រៃ
- រាល់គម្រោងអភិវឌ្ឍន៍ក្នុងតំបន់នេះចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពង្រឹងយន្តការ និងមធ្យោបាយសម្រាប់បង្ការទប់ស្កាត់គ្រោះមហន្តរាយ
- លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឧទ្យានដោយសិក្សានិងរៀបចំផែនការប្រើប្រាស់ដី ឱ្យបានគ្រប់ជ្រុងជ្រោយ
- អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

៤.៧-យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋាន គឺជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍន៍ក្រុង និងបរិស្ថាន ចាំបាច់ត្រូវ÷

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើង

- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ជាពិសេសសម្រាប់ការគ្រប់គ្រងអភិវឌ្ឍន៍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការចាក់ដី ការអភិវឌ្ឍដី និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភ័ណភាព និងបរិស្ថានទីក្រុង។

៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងបង្គប់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ រដ្ឋបាលខេត្តពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ដូចខាងក្រោម÷

៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុង ត្រូវរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម ទាក់ទងនឹងការងារមួយចំនួនដូចខាងក្រោម÷

- ផែនទីព្រំប្រទល់ភូមិ សង្កាត់ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធមានស្រាប់
- ផែនទីប្រើប្រាស់ដីបច្ចុប្បន្ន
- ផែនការប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ
- បង្គប់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗបន្តពីផែនការប្រើប្រាស់ដីរបស់ក្រុង
- ផែនទីកំណត់កម្ពស់អគារ និងសន្ទស្សន៍ប្រើប្រាស់ដីតាមតំបន់
- ផែនទីកំណត់ទីតាំងលំហសាធារណៈ
- ផែនទីកំណត់តំបន់អភិវឌ្ឍជាអាទិភាព។

៥.២-ការផ្សព្វផ្សាយ

រៀបចំប្រជុំផ្សព្វផ្សាយបង្គប់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោនេះ ដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ និងតាមរយៈគេហទំព័រ ឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្ត។

៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍក្រុង ទេសចរណ៍ ការដឹកជញ្ជូន កសិកម្ម និងការផ្សព្វផ្សាយផលិតផល ការគ្រប់គ្រងបរិស្ថាន ធនធានទឹកនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងគ្រប់គ្រងសំណល់រាវ និងការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍ មានដូចខាងក្រោម÷

៥.៣.១-ការអភិវឌ្ឍក្រុង

- រៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធតំបន់គម្រោងអភិវឌ្ឍទាំង ៨ ទីតាំង តាមជំហាន ដូចជា ផ្លូវ ភ្លើង ស្ពាន ប្រព័ន្ធលូបង្ហូរទឹកភ្លៀង ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងសួនច្បារសាធារណៈ
- កសាងផែនការប្រើប្រាស់ដីលម្អិតរបស់គម្រោង និងប្តង់លម្អិតនគរូបនីយកម្ម
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ លើការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ធ្វើទំនប់ឬទ្វារទឹកសម្រាប់ទប់ទឹកចំនួន ២ ទីតាំង ដើម្បីរក្សាទឹកទុកប្រើបប្រាស់
- ធ្វើផែនការអភិវឌ្ឍន៍ និងអភិរក្សតំបន់ការពារឧទ្យានជាតិព្រះមុនីវង្សបូកគោ
- កសាងផ្លូវមេតភ្ជាប់ពីផ្លូវជាតិលេខ៣ មកទីតាំងគម្រោងអភិវឌ្ឍក្រុងបូកគោ និងភ្ជាប់ទៅផ្លូវជាតិលេខ ៤ ចំនួន ២ ទីតាំង
- រៀបចំ និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

៥.៣.២-ការអភិវឌ្ឍវិស័យទេសចរណ៍

- រៀបចំបទដ្ឋានគតិយុត្តគាំទ្រសំណង់ស្ថាបត្យកម្មលក្ខណៈខ្មែរ វប្បធម៌ សាសនា ដោយផ្សាភ្ជាប់នឹងទេសភាពវប្បធម៌ធម្មជាតិមានព្រៃឈើ សមុទ្រនិងភ្នំ
- ផ្សព្វផ្សាយផលិតផលទេសចរណ៍ រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិពរណ៌ផលិតផលក្នុងស្រុក
- រៀបចំផ្លូវទេសចរណ៍ សុវត្ថិភាព គុណភាពទេសចរណ៍ និងបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា
- អភិវឌ្ឍន៍ផលិតផលទេសចរណ៍ធម្មជាតិតាមព្រៃភ្នំ អភិវឌ្ឍការធ្វើដំណើរតាមខ្សែកាប ស្ពានយោល ទេសចរណ៍ក្នុងព្រៃឈើ ដើម្បីគយគន់ព្រៃឈើ សមុទ្រ ព្រះអាទិត្យរះ-លិច ទេសភាពលំនៅឋាន ស្រូបយកខ្យល់អាកាសបរិសុទ្ធ និងទឹកធ្លាក់
- រៀបចំសួនច្បារកម្សាន្ត និងទេសភាពធម្មជាតិ សម្រាប់ភ្ញៀវទេសចរ និងមនុស្សគ្រប់វ័យ
- បង្កើតចំការកង្ហារលើភ្នំសម្រាប់វិស័យថាមពល និងទស្សនាកម្សាន្ត
- អភិវឌ្ឍតំបន់ទេសចរណ៍វប្បធម៌ និងសាសនា
- អភិវឌ្ឍទេសចរណ៍ទេសភាពតាមជម្រាលភ្នំ ការដាំដើមឈើ ផ្កា ការធ្វើកសិកម្ម
- អភិវឌ្ឍឱ្យមានស្ពាន និងផ្លូវសម្រាប់ដើរលម្ហែកាយ និងស្រូបខ្យល់អាកាសតាមព្រៃភ្នំ
- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍

- រៀបចំកម្មវិធីបុណ្យជាតិ និងព្រឹត្តិការណ៍ទាក់ទាញទេសចរណ៍
- បណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដារទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ទេសចរណ៍
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈលើវិស័យទេសចរណ៍
- ចលនាផ្នែកឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។
- សាងសង់មណ្ឌលព័ត៌មានទេសចរណ៍
- ពង្រឹងភ្នាក់ងារគ្រប់គ្រង និងផ្តល់សេវាព័ត៌មានដល់ភ្ញៀវទេសចរ។

៥.៣.៣-ការដឹកជញ្ជូន

- កសាងផ្លូវភ្ជាប់ពីផ្លូវជាតិលេខ ៣ ទៅទីតាំងគម្រោងអភិវឌ្ឍក្រុងបូកគោ និងភ្ជាប់ទៅផ្លូវជាតិលេខ ៤
- សាងសង់រុក្ខវិថី ឬមហាវិថី វិថី អនុវិថី ផ្លូវចែលចាយក្នុងគម្រោងអភិវឌ្ឍក្រុង
- បន្តសាងសង់បណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០៣៥
- លើកកម្ពស់ស្ថាប័ន និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- ស្តារ និងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗ
- រៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈ និងពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

៥.៣.៤-ការគ្រប់គ្រងបរិស្ថាន

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រមូលមូលនិធីពីសេវាកម្មធនធានធម្មជាតិ
- គ្រប់គ្រងនិងការពារឧទ្យានជាតិព្រះមុនីវង្ស។

៥.៣.៥-ការគ្រប់គ្រងសំណល់រឹង

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់
- ពង្រឹងក្រុមការងារតាមដាន និងត្រួតពិនិត្យការប្រមូលសំរាម
- ពង្រឹងក្រុមកម្មករសម្អាតគម្រោងអភិវឌ្ឍក្រុងបូកគោ
- រៀបចំសេចក្តីជូនដំណឹង និងដាក់ផ្ទាំងប៉ាណូកំណត់ពេលវេលាប្រមូលសំរាមតាមគោលដៅ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់តម្លៃសេវាប្រមូលសំរាមទីក្រុង តាមគោលការណ៍ណែនាំថ្មី
- អប់រំផ្សព្វផ្សាយអំពីសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីណែនាំស្តីពីការទុកដាក់ការពារសំណល់គ្រោះថ្នាក់

- ផលិតផ្នាំងប៉ាណូអប់រំផ្សព្វផ្សាយ និងតាមវិទ្យុ
- ចុះធ្វើកិច្ចសន្យាគាំពារបរិស្ថានលើអាជីវកម្មពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ក្នុងក្រុង
- ចុះត្រួតពិនិត្យតាមដានលើអាជីវកម្មពាក់ព័ន្ធនឹងការបញ្ចេញសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីជូនដំណឹងអំពីការញែកសំរាម
- ផ្សព្វផ្សាយ និងណែនាំអំពីការញែកសំរាម សំណល់រឹង និងអនុវត្តជាក់ស្តែងដោយដាក់ធុងសំរាមក្នុងសាលាជាគំរូ
- អនុវត្តន៍វិធានការច្បាប់ និងជាកពិន័យ
- សហការជាមួយជំនាញដើម្បីផលិតខ្លឹមសារអប់រំបរិស្ថាន។

៥.៣.៦-ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ

- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន សំណង់អគារសេវាកម្មសាធារណៈ និងឯកជន ត្រូវរៀបចំអាងបង្កន់អនាម័យ និងអាងចម្រោះទឹកកខ្វក់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- រៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងប្រព័ន្ធលូបង្ហូរដែលស្មើឡើង
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវធ្វើចម្រោះទឹក ឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលទៅតំបន់ធនធានទឹក
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថានអនាម័យ។

៥.៣.៧-ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត

- ត្រួតពិនិត្យអ្នកប្រើប្រាស់បណ្តាញផ្គត់ផ្គង់ទឹកស្អាត
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹកទាំងពីរទីតាំង
- អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹករហូតដល់ឆ្នាំ២០៣៥
- អភិវឌ្ឍធនធានទឹកផ្សេងទៀត
- អភិវឌ្ឍស្ថានីយ៍ចម្រោះទឹកស្អាត និងប្រព័ន្ធផ្គត់ផ្គង់ទឹកឱ្យបានមុនប្រជាជនមកស្នៅ។

៥.៣.៨-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍

- បំពាក់បណ្តាញផ្គត់ផ្គង់អគ្គិសនីដល់គម្រោងទាំង ៨ ទីតាំង
- ដំឡើងបណ្តាញអគ្គិសនីបំភ្លឺតាមដងវិថី
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យដល់តំបន់អភិវឌ្ឍក្រុង
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី
- ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ជា អំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយមន្ទិលបរិស្ថាន
- បង្កើតចំការអគ្គិសនីសម្រាប់ជាប្រភពថាមពលអគ្គិសនីប្រកបដោយចីរភាពរបស់ក្រុង
- ពង្រីកបណ្តាញទូរគមនាគមន៍។

៥.៤-ការអនុវត្តផែនការរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពចែកចេញជា ៣ ដំណាក់កាល គឺសម្រាប់ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដូចខាងក្រោម÷

៥.៤.១-ការអនុវត្តផែនការរយៈពេលខ្លី

- ផែនទីប្រើប្រាស់ដីបច្ចុប្បន្នក្រុង
- ផែនទីព្រំប្រទល់ភូមិ សង្កាត់ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធក្រុង
- គម្រោងអាទិភាព
- ផែនការប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ដោយកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី និងសំណង់។

៥.៤.២-ការអនុវត្តរយៈពេលមធ្យម

គម្រោងសំខាន់ៗតាមវិស័យក្រៅពីគម្រោងអាទិភាព។

៥.៤.៣-ការអនុវត្តរយៈពេលវែង

- គម្រោងពង្រីកក្រុង ចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុន ដូចជា បណ្តាញផ្លូវ និងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ទឹកភ្លៀង អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ប្តង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗ ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង មានជាអាទិ៍ តំបន់រដ្ឋបាល តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់សេវាកម្ម តំបន់អភិរក្ស លម្ហសាធារណៈ និងតំបន់បម្រុងទុកសម្រាប់ជាប្រយោជន៍សាធារណៈ និងការអភិវឌ្ឍនាពេលអនាគត ដើម្បីគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងគោលការណ៍អភិវឌ្ឍបៃតង សំដៅធ្វើឱ្យទីក្រុងក្លាយជាទីកន្លែងរស់នៅល្អ ប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព។

៥.៥-គម្រោងអាទិភាព

- កសាងក្រុងឱ្យមានសោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់
- កសាងសមត្ថភាពធ្វើផែនការក្រុង
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលទេសចរណ៍
- លើកកម្ពស់គុណភាពទេសចរណ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ ឯកជន
- អភិវឌ្ឍតំបន់ពាណិជ្ជកម្មឱ្យមានកន្លែងទុកដាក់សំរាម លូបង្ហូរទឹកកខ្វក់ ចំណតរថយន្ត កន្លែងលើកដាក់ទំនិញ កន្លែងភ្ញៀវឡើងចុះរថយន្ត
- រៀបចំភ្លើងបំភ្លឺផ្លូវ ផ្លាកសញ្ញាទិសដៅចរាចរណ៍ សួនច្បារ និងផ្លូវថ្មើរជើងសម្រាប់អ្នកដំណើរ
- អភិវឌ្ឍធនធានមនុស្ស និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលកសិកម្ម
- ស្តារ និងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗ

- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងទីប្រជុំជនក្រុង
- រៀបចំ និងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងក្របខណ្ឌគតិយុត្តជាធរមាន
- បង្កើតភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការគ្រប់គ្រងសំណល់រឹង និងរាវ
- អនុវត្តគោលគំនិត "ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ" សំណល់រឹង
- ការពារ និងថែរក្សាប្រវត្តិសាស្ត្រ ធម្មជាតិ ទេសភាព ភ្នំសមុទ្រ
- អភិរក្សធនធានធម្មជាតិ ដោយស្តារឡើងវិញនូវគម្របព្រៃឈើ
- ជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍។

៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោមានជាអាទិ៍÷

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

៧.១-យន្តការ

យន្តការថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្នុវិស័យឆ្នាំ២០៣៥ មាន÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្ត មាន÷ រដ្ឋបាលខេត្តពាក់ព័ន្ធ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តពាក់ព័ន្ធ មន្ទីរ អង្គភាពជំនាញ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្នុវិស័យឆ្នាំ២០៣៥ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត មានជាអាទិ៍÷ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីដែនជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប

ត្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ អនុក្រឹត្យស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "ប្លកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" គោលនយោបាយដីធ្លី (សៀវភៅសដីធ្លី) គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៧.៣-តួនាទី ទំនួលខុសត្រូវ និងគោលការណ៍

រដ្ឋបាលខេត្តពាក់ព័ន្ធ ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសេនាធិការ មានភារកិច្ច÷

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដី គម្រោងអភិវឌ្ឍក្រុងបូកគោ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពវិស័យឯកជន ដៃគូអភិវឌ្ឍន៍និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណងគោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ៥ ឆ្នាំ កម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងម្លងលម្អិតនគរូបនីយកម្មថ្នាក់ក្រុង
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីនេះ ក្នុងរយៈពេល ៥ ឆ្នាំម្តង ស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះជូនក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដី និងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដែលជាកត្តាគួរសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព។

៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយ **ឈ្នះ-ឈ្នះ** និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោត្រូវបានរៀបចំឡើង និងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោលដ៏មានសារៈសំខាន់ សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យ ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣៥ គឺ **«ភ្នំបូកគោ ជាក្រុងឆ្លាតវៃ ទេសចរណ៍ប្រវត្តិសាស្ត្រ បៃតង ធម្មជាតិ និងអាកាសធាតុ ភ្នំ-សមុទ្រដ៏ពិសិដ្ឋគ្មានពីរនៃព្រះរាជាណាចក្រកម្ពុជា»** តាមរយៈការជំរុញ ÷ ១).កំណត់គោលនយោបាយ និងបទដ្ឋានគតិយុត្តបង្កើតជាក្រុង សម្រាប់លំនៅឋាន សម្រាកលម្ហែកម្សាន្ត សិក្សា ការងារ និងធុរកិច្ច ប្រកបដោយសុខភាព គុណភាពបរិស្ថានល្អ និងជាទិសដៅទេសចរណ៍ដ៏ប្រណីតកម្រិតខ្ពស់ សម្រាប់ការទាក់ទាញ និងប្រកួតប្រជែងក្នុងតំបន់និងអន្តរជាតិ ២).ការពារនិងអភិរក្សក្រុងប្រវត្តិសាស្ត្រ ធនធានធម្មជាតិ ថែរក្សាប្រភពទឹកធម្មជាតិ ទេសភាព និងអាកាសធាតុភ្នំ-សមុទ្រ ៣).កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន លំហសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសមាហរណកម្មតភ្ជាប់ក្នុងតំបន់ ៤).ទាក់ទាញលើកទឹកចិត្ត និងគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជន ដើម្បីអភិវឌ្ឍធុរកិច្ច អភិវឌ្ឍផលិតផលទេសចរណ៍សម្បូរបែបប្រកបដោយគុណភាពខ្ពស់ និងជំរុញកំណើនសេដ្ឋកិច្ច និង ៥).អភិបាលកិច្ចល្អ និងអភិវឌ្ឍធនធានមនុស្ស និងដើម្បីរួមចំណែកអភិវឌ្ឍន៍និងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនផ្នែកធុរកិច្ច និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្តតាមដាន និងវាយតម្លៃចំពោះប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជំរុញការផ្សព្វផ្សាយ និងអនុវត្តន៍តាមប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដើម្បីធានាការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ហើយត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ឯកសារភ្ជាប់សម្គាល់

- ផែនទីប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ ២០៣៥
- ផែនទីបណ្តាញផ្លូវសំខាន់ៗនៃគម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ ២០៣៥
- ផែនទីឧទ្យានជាតិព្រះមុនីវង្ស "បូកគោ"
- ផែនទីតំបន់ការពារក្នុងគម្រោងអភិវឌ្ឍក្រុងបូកគោ
- ផែនទីរូបថតពីលើអាកាសគម្រោងអភិវឌ្ឍក្រុងបូកគោ
- គម្រោងអភិវឌ្ឍក្រុងបូកគោ ចក្ខុវិស័យឆ្នាំ ២០៣៥។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
គណៈកម្មាធិការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ

ផែនទីបង្ហាញតំបន់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបុកគោ ចក្ខុវិស័យឆ្នាំ២០៣៥

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៩



សញ្ញាសម្គាល់ផែនទី

- ព្រំប្រទល់ខេត្តជាតិព្រះមុនីវង្ស បុកគោ
- ផ្លូវជាតិ
- មហាវិថី
- វិថី
- រដ្ឋវិថី

I-ប្រភេទដីសេដ្ឋកិច្ចសង្គម

- តំបន់លំនៅឋាន
- តំបន់ពាណិជ្ជកម្ម
- តំបន់ឧស្សាហកម្ម
- តំបន់ឧស្សាហកម្មស្បែកជើង
- តំបន់សេវាកម្ម
- តំបន់ផ្លាស់ប្តូរ និងសេវាសាធារណៈ
- តំបន់ស្មូនក្នុងរមណីយដ្ឋាន និងផ្នែរបៃតង
- តំបន់ព្រៃឈើ និងដីចម្ការ
- តំបន់ឈូកបាតស្ទឹង ដីខ្សាច់ និងបាតទន្លេ

II-ប្រភេទដីកសិកម្ម និងធនធានធម្មជាតិ

- តំបន់កសិកម្ម
- តំបន់ធនធានទឹក
- តំបន់ការពារ ធនធានជាតិព្រះមុនីវង្ស បុកគោ

ផែនទីព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា ឬប្រទេសកម្ពុជា ឬកម្ពុជា ជាប្រទេសមួយស្ថិតនៅក្នុងតំបន់ឧបទ្វីបឥណ្ឌូចិន ដែលមានព្រំប្រទល់ជាប់ទិសឦសានជាមួយនឹងសាធារណរដ្ឋប្រជាមានិតឡាវ ទិសបូព៌ាជាប់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាម និងទិសនិរតីជាប់នឹងឈូងសមុទ្រថៃ។ ប្រទេសកម្ពុជាមានផ្ទៃក្រឡា ១៨១ ០៣៥ គីឡូម៉ែត្រ ក្រឡា។ ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានរយៈបណ្តោយពី ១០២ អក្សរផ្តាត់ ១០៨ អក្សរ ទិសបូព៌ាពី ១០ អក្សរផ្តាត់ ១៥ អក្សរ។

ផែនទីព្រះរាជាណាចក្រកម្ពុជា

ឧទ្យានជាតិព្រះមុនីវង្ស "បុកគោ" អាចមានឋានៈជាតំបន់ការពារធម្មជាតិ ប្រភេទ ទី ៥ ស្ថិតនៅក្នុងខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ មានក្រឡាដែលមានទីតាំងស្ថិតនៅចន្លោះរយៈបណ្តោយ ១០៣ ៤៥ និង ១០៣ ៥៣ អាក់ អឡោង និងរយៈទទឹងចន្លោះ ១១ ៣០ និង ១១ ៤០ ខាងជើង ដែលមានផ្ទៃក្រឡាសរុប ៣៨២ ៤០០ ហិកតា។ ឧទ្យានជាតិព្រះមុនីវង្ស "បុកគោ" ដែលមានឧទ្ទេសនាមតាមឈ្មោះភ្នំបុកគោ ដែលមានកម្ពស់ ៣៣៦ ម៉ែត្រ ស្ថិតនៅក្នុងឃុំបុកគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានចម្ងាយប្រមាណ ៣០ គីឡូម៉ែត្រ ពីទីរួមខេត្តព្រះសីហនុ និង ១៥ គីឡូម៉ែត្រ ពីទីរួមស្រុកព្រៃនប់ ដែលមានចម្ងាយប្រមាណ ២៣០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ឧទ្យានជាតិព្រះមុនីវង្ស "បុកគោ" ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកំណត់ព្រំប៉ន់ឧទ្យានជាតិព្រះមុនីវង្ស "បុកគោ" និងឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ"។



និយាមការតភ្ជាប់ឧទ្យានជាតិព្រះមុនីវង្ស បុកគោ

ID	X	Y	ID	X	Y
A	402810	1168653	N	394181	1227998
B	400650	1168148	O	396796	1232460
C	395184	1171052	P	395566	1236924
D	387286	1171587	Q	402616	1238796
E	384045	1174392	R	404316	1232325
F	378487	1187086	S	406537	1231627
G	377158	1195536	T	408004	1225468
H	379176	1205847	U	408004	1215883
I	384777	1209233	V	403996	1210001
J	383146	1220836	W	404999	1197997
K	390001	1228888	X	408869	1180152
L	390000	1231510	Y	404933	1173146
M	392423	1231605	Z	405501	1170055

ក្រុមការងារគាំទ្របច្ចេកទេសតំបន់
គណៈកម្មាធិការជាតិគណៈកម្មាធិការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ

១.ឯកឧត្តម ប៉ែន សុជល រដ្ឋលេខាធិការ	ប្រធាន
២.ឯកឧត្តម ឃស់ ឆោមណារ៉ាទី អនុរដ្ឋលេខាធិការ	អនុប្រធាន
៣.ឯកឧត្តម ហង្ស សុភ សំភារ អគ្គលេខាធិការរង	អនុប្រធាន
៤.ឯកឧត្តម លី រស្មី អគ្គលេខាធិការរង	សមាជិក
៥.លោក ឱម សុទ្ធារិទ្ធិ ប្រធានអាជ្ញាធរដែនដីបឹងបឹងទេស	សមាជិក
៦.លោក អេង ពិសាល អនុប្រធានអាជ្ញាធរដែនដីបឹងបឹងទេស	សមាជិក

ប្រភពផែនទី

មាត្រដ្ឋាន ១:៣០ ០០០

6 3 0 គ.ម 6

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំផែនដីខេត្តព្រះសីហនុ

ឆ្នាំ ២០១៨

ក្រសួង.ជ.ន.ស.
លេខ 2731
ថ្ងៃទី 20.6.19
ហត្ថលេខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...ន.ស.រក...

អនុក្រឹត្យ
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

មាត្រា ២.-

ផែនការរៀបចំដែនដីខេត្តព្រះសីហនុអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីខេត្តព្រះសីហនុមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលផែនការរៀបចំដែនដីខេត្តព្រះសីហនុ ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ ១ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

ជា សុផារ៉ា

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ជួចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង

ឆ្នាំ ២០១៨

រដ្ឋបាលខេត្ត.ជ.ន.ស.
ចេញ 1532
ថ្ងៃទី 20.6.19
ហត្ថលេខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៨០...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ **៧៧** អនក្រ.បក ចុះថ្ងៃទី**០៧** ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ **៧៦** អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា **៧៤** និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

មាត្រា ២.-

ផែនការរៀបចំដែនដីខេត្តបាត់ដំបងអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីខេត្តបាត់ដំបងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ទុធ ១ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីចុះហត្ថលេខា
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

ជា សុផារ៉ា

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
- ជួពមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្តូរ និងសាងសង់

ឆ្នាំ ១៩៩៩

(2443) (5291)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ៨៧៩ ប្រក/ប.ន.ស

ច្បាប់

ស្តីពី

ការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុន
សិក្សាគំនោងប្លង់ និង សាងសង់

* * * * *

រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ /នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីតាំងដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ . បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ . បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៩ ស្តីពីលិខិតអនុប្បាតសាងសង់
- តាមការចាំបាច់របស់ក្រសួង : ។

អាសយដ្ឋាន : លេខ ៨៧១ - ៨៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ ចិតបត្រមែក ខណ្ឌ ចំការមន ក្រុង ភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277 , e-mail : in. c lin. @ Camnet. Com. Kh

(444)43

ប្រការ ១.-

សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងបឋម និង សាងសង់ទាំងអស់ដែលធ្វើសកម្មភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ប្រការ ២.-

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបឋម ត្រូវបានបែងចែកជាបួន ប្រភេទ :

ក-ប្រភេទទី១ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ក.១ ស្ថាបត្យករយ៉ាងតិច ៣ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ ឆ្នាំ ។

ក.២ វិស្វករយ៉ាងតិច ៥ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេងៗ យ៉ាង តិច ៥ ឆ្នាំ ។

ក.៣ វិស្វកររំលែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ក.៤ អ្នកបច្ចេកទេសជំនាញមធ្យមមួយចំនួនសមស្រប ។

ក.៥ បទពិសោធន៍លើការងារសិក្សាគំរោងដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃសិក្សាគំរោងយ៉ាងតិចចំនួន ៨០០.០០០.០០០ រៀល ។

ក.៦ ដើមទុនយ៉ាងតិចចំនួន ២០០.០០០.០០០រៀល ដែលទទួលស្គាល់ ដោយ ធនាគារស្របច្បាប់ ។

ខ-ប្រភេទទី២ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ខ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

ខ.២ វិស្វករយ៉ាងតិច ៤នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេងៗ យ៉ាងតិច ៤ ឆ្នាំ ។

ខ.៣ វិស្វកររំលែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍លើការងារមុខជំនាញយ៉ាងតិច ៦ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.៤ អ្នកបច្ចេកទេសជំនាញមធ្យមមួយចំនួនសមស្រប ។

ខ.៥ បទពិសោធន៍លើការងារសិក្សាគំរោង ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតំលៃសិក្សាគំរោងយ៉ាងតិចចំនួន ២០០.០០០.០០០រៀល ។

ខ.៦ ដើមទុនយ៉ាងតិចចំនួន ៨០.០០០.០០០រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

គ-ប្រភេទទី៣ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

គ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ ។

គ.២ វិស្វករយ៉ាងតិច ៣នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេងៗយ៉ាងតិច ៣ឆ្នាំ ។

គ.៣ វិស្វកររំលែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុង សហគ្រាស និង ក្រុមហ៊ុន ។

គ.៤ អ្នកបច្ចេកទេសជំនាញមធ្យមមួយចំនួនសមស្រប ។

ខ.៥ ដើមទុនយ៉ាងតិចចំនួន ២០.០០០.០០០ រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

ឃ -ប្រភេទទី៤ : ជាអ្នកវិនិច្ឆ័យបុគ្គល :

ឃ.១ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំដោយមានការទទួលស្គាល់ពីក.ជ.រដ្ឋាភិបាល ។

ឃ.២ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាងតិច ៥ឆ្នាំ ។

ឃ.៣ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ ។

ឃ.៤ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំ។

ឃ.៥ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ ឆ្នាំ ។

ឃ.៦ វិស្វករស្ថិតនៅខេត្តក្រុង ដែលគ្មានស្ថាបត្យករ និង អ្នកបច្ចេកទេសសំណង់អគារ ឬ សំណង់ស៊ីវិល ។

ឃ.៧ អ្នកបច្ចេកទេសថ្នាក់មធ្យមសំណង់អគារ ឬ សំណង់ស៊ីវិលស្ថិតនៅខេត្ត ក្រុង ដែលគ្មានស្ថាបត្យករ និង វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ។

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបឋម អាចសុំតម្លើងឋានៈរបស់ខ្លួនទៅពេលណាផ្នែកសហគ្រាស និង ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ២នេះ និង មានលិខិតបញ្ជាក់ពីការបង់តាទ្វេរទាត់ជូនផង ។

ប្រការ ៣.-

សហគ្រាស និង ក្រុមហ៊ុនសាងសង់ ត្រូវបានបែងចែកជាបួនប្រភេទ :

ក -ប្រភេទទី១ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ក.១ ចំនួនវិស្វករ ២នាក់ និង ស្ថាបត្យករ ២នាក់ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ ទៅក្នុងនោះវិស្វករ ១នាក់ ទទួលបន្ទុកជានាយកបច្ចេកទេស និង ស្ថាបត្យករ ១នាក់ ជានាយកគំរោង ។

ក.២ វិស្វកយ៉ាងតិច ៦នាក់ ទទួលបន្ទុកជំនាញផ្សេង១ (អគ្គិសនី មេកានិច ទឹក កុតក្តាសាស្ត្រ ហ៊ានលេខា)

ក.៣ ដើមទុនយ៉ាងតិចចំនួន ៤០០.០០០.០០០រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

ក.៤ បទពិសោធន៍ការងារសាងសង់ដែលធ្លាប់ធ្វើអនុវត្តន៍ក្នុងមកហើយដែលមានតម្លៃយ៉ាងតិចចំនួន ២០.០០០.០០០.០០០រៀល ។

ខ-ប្រភេទទី២ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ខ.១ ចំនួនវិស្វករ ១នាក់ និង ស្ថាបត្យករ ១នាក់ មានបទពិសោធន៍ការងារក្នុងមុខជំនាញ យ៉ាងតិច ៨ឆ្នាំ ទៅក្នុងនោះវិស្វករមានតួនាទីជាទាយកបច្ចេកទេស និង ស្ថាបត្យករ ជាទាយកគំរោង ទៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.២ វិស្វកយ៉ាងតិច ៤នាក់ ទទួលបទុកជំនាញជ្រើង។ (អគ្គីសនី មេកានិច ទឹក ភូគព្ភសាស្ត្រ ហានលេខា)

ខ.៣ ដើមទុនយ៉ាងតិចចំនួន ១២០.០០០.០០០រៀល ដោយមានការទទួលស្គាល់ពីធនាគារស្របច្បាប់ ។

ខ.៤ បទពិសោធន៍លើការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិច ចំនួន ៤.០០០.០០០.០០០រៀល ។

គ-ប្រភេទទី៣ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

គ.១ ចំនួនវិស្វករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ឆ្នាំ មានតួនាទី ជាទាយកបច្ចេកទេសនៃសហគ្រាស និង ក្រុមហ៊ុន ។

គ.២ វិស្វករ ២នាក់ ដែលទទួលបទុកជំនាញជ្រើង ។

គ.៣ ដើមទុនយ៉ាងតិច ២០.០០០.០០០រៀល ដោយមានការទទួលស្គាល់ពីធនាគារស្របច្បាប់ ។

ឃ-ប្រភេទទី៤ : ជាក្រុមជាងសំណង់ :

ឃ.១ មេជាងដែលមានស្នាដៃ និង បទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ ។

ឃ.២ ជាងសំណង់មួយចំនួនសមស្រប ។

សហគ្រាស និង ក្រុមហ៊ុនសាងសង់ អាចសុំតម្លើងឋានៈប្រភេទ របស់ខ្លួនទៅពេលណា ដែលសហគ្រាស និង ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ៣ខាងលើ និង មានលិខិត បញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

ប្រការ ៤ :

អាជ្ញាធរដែលមានសមត្ថកិច្ចបើក បិទ ជ្រាក តាមដាន និង ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់ សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងបឹង និងសាងសង់ មាន :

១-ត្រួសរៀបចំរៀបចំ ឧតន្តរចិយកម្ម និង សំណង់

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំហ្លួងបឹង និង សាងសង់
- ប្រកាសបិទ ជ្រាកអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបឹង និង សាងសង់
- តាមដាន ត្រួតពិនិត្យត្រប់សកម្មភាពអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបឹង និង សាងសង់ ។

២-ចង្អុរវៀចទំដែនដី ទន្លុបទីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង

- ទទួលបន្ទុកសំរបសំរួល ដើម្បីលើកសំណើជូនក្រសួងធ្វើសេចក្តីសំរេចក្នុងការចេញលិខិតអនុញ្ញាត បើក បិទ ជ្រាក ការប្រកបអាជីវកម្មសិក្សាគំរោងបួម និង សាងសង់របស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបួម និងសាងសង់

- តាមដាន ត្រួតពិនិត្យសកម្មភាពរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបួម និងសាងសង់ នៅក្នុងមូលដ្ឋានរបស់ខ្លួន និងរាយការណ៍ជូនក្រសួងដើម្បីពិនិត្យដោះស្រាយ ។

ប្រការ ៥ .-

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបួម់ និង សាងសង់ទាំងអស់ ដែលមានបំណងធ្វើអាជីវកម្ម សិក្សាគំរោងបួម់ និង សាងសង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

រូបវន្តបុគ្គល (ឃ៦-ឃ៧) និង ក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្មទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ។

ប្រការ ៦ .-

ចំពោះ :

១- សហគ្រាស និង ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេង១កន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

២- រូបវន្តបុគ្គល (ឃ៦-ឃ៧) និង ក្រុមជាងសំណង់ ដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេង១ កន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ។

ប្រការ ៧.-

ទម្រង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងបួម់ និង សាងសង់ត្រូវមានលក្ខខណ្ឌដូចតទៅ :

១- ប្រធានសហគ្រាស និង ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

២- ប្រធានសហគ្រាស និង ក្រុមហ៊ុនត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ។

៣- នាយកបច្ចេកទេសនៃសហគ្រាស និង ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

៤- សំណុំឯកសារដែលត្រូវបំពេញរួមមាន :

- ពាក្យសុំប្រកបអាជីវកម្ម

- ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុន ដោយមានចិទ្រូបថត ទំហំ ៤ x ៦

- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុនដែលមានថ្នៃទីស្នាក់ការកណ្តាលកម្មនៅសាលា ខេត្ត ក្រុង — ២ ច្បាប់
- លិខិតជ្រើសរើសរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុន (ច្បាប់ដើម) — ១ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេសដោយមានចិទ្រូបថតទំហំ ៤ x ៦ — ៤ ច្បាប់
- លក្ខន្តិកៈរបស់សហគ្រាស និង ក្រុមហ៊ុន — ៤ ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាសនិងក្រុមហ៊ុន និងអាជ្ញាធរសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រតិបត្តិអាជីវកម្ម — ៤ ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាសនិងក្រុមហ៊ុនៈ និងវិស្វករដែលជានាយកបច្ចេកទេស — ៤ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្ររបស់អ្នកបច្ចេកទេសដែលមានថ្នៃទីស្នាក់ការកណ្តាលកម្មនៅសាលាខេត្ត ក្រុង — ៤ ច្បាប់
- បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និង អង្គភាពលេខរបស់សហគ្រាស និង ក្រុមហ៊ុន — ៤ ច្បាប់
- ឯកសារស្នាដៃ — ២ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខារសិក្សាគំរោងបូម (*សំរាប់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងបូម*) — ៤ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខារគ្រឿងសំណង់ (*សំរាប់សហគ្រាស និង ក្រុមហ៊ុនសាងសង់*) — ២ ច្បាប់
- ឯកសារធនាគារ — ៤ ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ (ច្បាប់ដើម) — ១ ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម — ១ ច្បាប់

ប្រការ ៨.-

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលមានបំណងប្រតិបត្តិអាជីវកម្មសិក្សាគំរោងបូម ឬ ជួលយោបល់ ពិគ្រោះបច្ចេកទេស និងសាងសង់ ទៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមកចុះបញ្ជីទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលកំពុងប្រតិបត្តិអាជីវកម្មសិក្សាគំរោងបូម ឬ ជួលយោបល់ពិគ្រោះបច្ចេកទេសទៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ដែរ ។

ប្រការ ៩.-

រាល់ការចុះបញ្ជី ការចេញលិខិតអនុញ្ញាត សហគ្រាសនិងក្រុមហ៊ុនសិក្សាគំរោងបូម និង សាងសង់ រូបវន្តបុគ្គល និង ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ១០.-

លិខិតអនុញ្ញាតប្រតិបត្តិអាជីវកម្មសិក្សាគំរោងបូម និង សាងសង់មានសុពលភាពរយៈពេល ៣ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។ ๆ๔

(២៣) (៤៤៩)

រយៈពេល៣០ថ្ងៃមុនជុំតកំណត់សុពលភាព សហគ្រាស និង ក្រុមហ៊ុន ធ្វើអាជីវកម្មសិក្សាគំរោងបួម៉ និង សាងសង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាជាថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ក្នុងករណីសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតប្រភេទអាជីវកម្ម សហគ្រាស និង ក្រុមហ៊ុនត្រូវធ្វើពាក្យសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតចាស់ និង បង្កាន់ដៃបង់ពន្ធអាករថ្មី ។

ក្នុងករណីសុំតម្លើងឋានៈប្រភេទ សហគ្រាស និង ក្រុមហ៊ុនត្រូវធ្វើបែបបទស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ សំរេច ។

សហគ្រាស និង ក្រុមហ៊ុនត្រូវតំកល់ទុកវេចយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រាល់ដំណាច់ឆ្នាំទីមួយ ១ ។

ប្រការ ១១.-

ត្រូវប្រកាសជ្ញាក ឬ បិទ ចំពោះសហគ្រាស ឬ ក្រុមហ៊ុនសិក្សាគំរោងបួម៉ និង សាងសង់ទាំងឡាយណាដែលប្រកបអាជីវកម្មសិក្សាគំរោងបួម៉ និង សាងសង់ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ប្រការ ១២.-

នាយកខុទ្ទកាល័យ អគ្គនាយកវេជ្ជបាល អគ្គនាយកសំណង់ អគ្គនាយករៀបចំដែនដីនិងនគរូបនីយកម្ម អគ្គនាយកសុរិយោដីនិងភូមិសាស្ត្រ អធិការ និង ប្រធានមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១៣.-

ប្រកាសនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ១៩៩៩

អ៊ឹម ងួនឈុន

ចម្លងជូន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១៦
- ឯកសារ-កាលប្បវត្តិ

Law Management 408/7/99

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីការគ្រប់គ្រងការដ្ឋាន
សំណង់

ឆ្នាំ ២០០១

(ស.ន.ន)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ៣៧ ប្រ.ក/ស.ណ.

ប្រកាស

ស្តីពី

ការគ្រប់គ្រងការដ្ឋានសំណង់

រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ ០៤ /នស /៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីតាំងដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ /បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៨៦ / អនក្រ / បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ / បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានីភ្នំពេញ និង ខេត្ត ក្រុង
- បានឃើញប្រកាស លេខ ៧៥ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់
- បានឃើញប្រកាស លេខ ៧៦ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីកូនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង កូនាទី ភារកិច្ច របស់បណ្តាការិយាល័យក្រោមឱវាទ
- ផ្អែកលើសភាពការណ៍នៃស្ថានភាពសំណង់បច្ចុប្បន្ន ។

ប្រកាសនេះ មានគោលបំណងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ និង សុវត្ថិភាព ក្នុងការដ្ឋាន សំណង់ ព្រមទាំងពង្រឹងការអនុវត្តបទប្បញ្ញត្តិនានាដែលទាក់ទងនឹងការសាងសង់ដើម្បីលើកកម្ពស់គុណភាព និង សោភ័ណភាព។

ប្រការ ២.-

អាចអនុញ្ញាតឱ្យបើកការដ្ឋានដំណើរការបានចំពោះតែសំណង់ណាដែល សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងមៀការសាងសង់ មានលិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ចេញឱ្យដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ។

ប្រការ ៣.-

ការដ្ឋាននីមួយ១ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។

លិខិតអនុញ្ញាតបើកការដ្ឋានត្រូវសុំនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ក្នុងរយៈពេលមួយខែយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ។

សំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានមាន :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតសាងសង់.

៣-កិច្ចសន្យារវាងម្ចាស់សំណង់ និង សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងមៀការសាងសង់

៤-លិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ របស់សហគ្រាស ក្រុមហ៊ុន ឬក្រុមជាងមៀការសាងសង់ ដែលទទួលសំណង់នោះ ។

ប្រការ ៤.-

ការដ្ឋានសំណង់នីមួយ១ត្រូវ :

-តំណាងជាប្រចាំ លិខិតបើកការដ្ឋាន . គំនូរបច្ចេកទេស តាមមុខជំនាញការងារសំណង់ . ផែនការអនុវត្តការងារ ក្នុងដំណាក់កាលនីមួយ១នៃការសាងសង់ . និង ឯកសារ ពាក់ព័ន្ធ ទុកសម្រាប់ភ្នាក់ងារសំណង់តាមដានត្រួតពិនិត្យ

-មានអ្នកបច្ចេកទេសសំណង់សម្រាប់ទទួលខុសត្រូវក្នុងការងារសាងសង់ ហើយមានការពិភាក្សាធ្វើយ៉ាងណាផ្តល់ពត៌មានជូនដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ

-ដាក់ផ្ទាំងគំនូរសំណង់ ដែលមានឈ្មោះសំណង់ នៃអគារត្រូវសាងសង់ . ក្រុមហ៊ុនសំណង់ . ម្ចាស់សំណង់ . ស្ថាបត្យករ . វិស្វករ . ផែ្នកគ្រឡាសំណង់ . លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានជាដើម

-មានភ្លើងដើម្បីបំភ្លឺ និង ត្រូវមានប្រដាប់សម្រាប់ពន្លត់អគ្គីភ័យជាប្រចាំ

-បន្ថយការខាងដោយស្ងៀសសំលេង ផ្សែង ធូលី និង ជលប៉ះពាល់ដទៃទៀត ឱ្យស្ថិតនៅក្នុងកំរិត និង ពេល

រវាលមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន ។

ប្រការ ៥.-

ការដ្ឋានទីមួយ។ ត្រូវហ៊ុមព័ទ្ធដោយរបងមានកម្ពស់ ២ម៉ែត្រ យ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឱ្យធ្វើលើចំហៀមថ្នល់ ។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទចាំងបណ្តោះអាសន្នលើចំហៀមថ្នល់សាធារណៈ ត្រូវរក្សាឱ្យមានចន្លោះផ្លូវដើរលើចំហៀមថ្នល់ និង ធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬ កំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី ៥ម៉ែត្រឡើងទៅ ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព ។

ប្រការ ៦.-

ការដ្ឋានត្រូវមានសណ្តាប់ធ្នាប់ និង អនាម័យ ជាប្រចាំ តាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់ពេលបញ្ចប់ការដ្ឋាន ។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការ រៀបចំសណ្តាប់ធ្នាប់ និង អនាម័យដែលបណ្តាលមកពីការទុកដាក់សម្ភារៈ ឬ កាកសំណល់ឱ្យប៉ះពាល់ផ្លូវសាធារណៈ ឬ ហូរធ្លាក់ចូលក្នុងអាងត្រួតពិនិត្យ នៃបណ្តាលូ និង ប្រឡាយទឹក ។

ប្រការ ៧.-

ការិយាល័យការងារ ឃ្លាំងផ្ទុកសម្ភារៈ ជម្រកកម្មករ គ្រឿងចក្រ និង សកម្មភាពសាងសង់ត្រូវរៀបចំ និងប្រក្រឹត្តទៅនៅក្នុងរបងហ៊ុមព័ទ្ធនៃការដ្ឋាន ឬ ការដ្ឋានរលាប ឬទីកន្លែងដែលធានាបានសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ។

ប្រការ ៨.-

ចំពោះសំណង់ដែលត្រូវប្រើគ្រឿងចក្របរិក្ខារលើកស្ទួច ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវ :

-សុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងផ្គុំសំណង់ ហើយធ្វើផ្លូវកាងជាបណ្តោះអាសន្ន

-បំពាក់ភ្លើងសញ្ញាសម្គាល់ លើផ្លូវដែលបិទ ដើម្បីសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈនៅពេលយប់ ។

ប្រការ ៩.-

ក្នុងករណីការសាងសង់មានបុកសសរគ្រឹះ ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវ :

-មានកាតព្វកិច្ចអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ដែលមានសមត្ថកិច្ចចូលពិនិត្យក្នុងការដ្ឋាន

-ជ្រើសរើងការប៉ះពាល់ដល់គ្រឿងផ្គុំផ្ទៃក្រោមដី

-ធានាសុវត្ថិភាពអគារដែលស្ថិតនៅជុំវិញបរិវេណការដ្ឋាន

-រៀបចំសណ្តាប់ធ្នាប់ការងារឱ្យបានសមស្រប តាមលក្ខណៈបច្ចេកទេស។

ប្រការ ១០.-

ម្ចាស់សំណង់ និង អ្នកមើលការសាងសង់ត្រូវបំពាក់ប្រដាប់ការពារសុវត្ថិភាព មានមួកសុវត្ថិភាព ស្រោមដៃ . ស្បែកជើង . ខ្សែក្រវាត់សុវត្ថិភាពសម្រាប់ឈរនៅទីខ្ពស់ និង ឧបករណ៍ការពារដទៃទៀតដល់ប៉ុគ្គលិក កម្មករជាប្រចាំក្នុងការដ្ឋាន ។

ប្រការ ១១.-

ពេលសាងសង់រួចជាស្ថាពរ ម្ចាស់សំណង់ត្រូវផ្ញើរជាយការណ៍ស្តីពីដំណើរការសាងសង់របស់ខ្លួន និង សុំលិខិតបិទការដ្ឋានសំណង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង។

សំណុំឯកសារដើម្បីសុំលិខិតបិទការដ្ឋាន :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋាន

៣-របាយការណ៍អំពីដំណើរការសាងសង់ ។

ប្រការ ១២.-

ពេលទទួលបានលិខិតបិទការដ្ឋានរួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ នៃ សំណង់នោះទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តក្រុង មុនបើកការប្រើប្រាស់ ។

ប្រការ ១៣.-

ពេលបញ្ចប់ការដ្ឋានសាងសង់ជាស្ថាពរ ម្ចាស់សំណង់ត្រូវរុះរើ របងហ៊ុមព័ទ្ធការដ្ឋាន និង ដឹកជញ្ជូនកាកសំណល់ឱ្យបានស្អាត។

ប្រការ ១៤.-

ការដ្ឋានដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិដូចមានចែងក្នុងប្រការ៧ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការងារការដ្ឋានជាបណ្តោះអាសន្ន ។ក្នុងករណីម្ចាស់ការដ្ឋានរឹងរូសនៅតែបន្តការសាងសង់អាជ្ញាធរមានសមត្ថកិច្ចត្រូវមានវិធានការដកហូត សម្ភារៈសាងសង់ទាំងនោះ ហើយចាត់ចែងទៅតុលាការ ។

ការដ្ឋានដែលប្រព្រឹត្តល្មើសនឹងករណីដូចមានចែងក្នុងប្រការ៤.៧.៩.១០.១១ និង ប្រការ១២ មន្ត្រីជំនាញមានសមត្ថកិច្ចត្រូវធ្វើការណែនាំឱ្យម្ចាស់សំណង់បំពេញលក្ខខណ្ឌខ្វះខាតទាំងនោះ ឬ ធ្វើលិខិតជូនដំណឹងឱ្យកែតម្រូវចំណុចខុសឆ្គងនឹងបទដ្ឋានដែលបានអនុញ្ញាត ឬខុសនឹង នគរូបនីយប្បញ្ញត្តិ ។ ក្រោយបានទទួលលិខិតជូនដំណឹងរយៈពេល១៥ថ្ងៃ បើគ្មានការកែតម្រូវទេ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការដ្ឋានជាបណ្តោះអាសន្ន ។ក្នុងករណីម្ចាស់សំណង់

(459) ៤៥

មិនព្រមអនុវត្តតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរុះរើ រឹបអូសសម្ភារៈសាងសង់ទាំងអស់ ហើយប្តឹងទៅតុលាការ ។

ការដ្ឋានដែលស្នើសុំការអនុញ្ញាតដូចមានចែងក្នុងប្រការ ៥ . ៦ និងប្រការ ៨ អាជ្ញាធរមានសមត្ថកិច្ចត្រូវជាកាតព្វកិច្ច ហើយបង្ខំឱ្យម្ចាស់ការដ្ឋានអនុវត្តតាមការណែនាំអំពីរបៀបរបបសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ។ ក្នុងករណីម្ចាស់សំណង់មិនគោរពតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរឹបអូសសម្ភារៈសំណង់ទាំងនោះ ។

ប្រការ ១៥.-

ការដ្ឋានដែលត្រូវបានផ្តាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ក្នុងប្រការទី ១៤ នៃប្រកាសនេះត្រូវបានអនុញ្ញាតឱ្យបើកតាមផ្លូវច្បាប់ជាថ្មីឡើងវិញ លុះត្រាតែបានបំពេញលក្ខខណ្ឌត្រប់ត្រាន់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ។

សំណុំបែបបទនៃការបើកការដ្ឋានឡើងវិញ មានដូចខាងក្រោម :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋានចាស់

៣-លិខិតផ្តាកការដ្ឋាន

៤-លិខិតបញ្ជាក់អំពីការបំពេញបានសព្វគ្រប់ នៃ លក្ខខណ្ឌខ្វះខាត ។

ប្រការ ១៦.-

ម្ចាស់សំណង់ និងអ្នកមៀតការសាងសង់ ត្រូវគោរពច្បាប់ការងារ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ១៧.-

នាយកខុទ្ទកាល័យ អគ្គនាយក នៃ គ្រប់អគ្គនាយកដ្ឋាន ប្រធាន មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១៧
- ឯកសារ-សាលមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស

ស្តីពីការកែសម្រួលប្រការ៧ និងប្រការ ១០ នៃប្រកាសស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្តូរ និងសាងសង់

ឆ្នាំ ២០០៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ ១.៦៦.....ប្រក.ដនស/អសណ

ប្រកាស
ស្តីពី

ការកែសំរួល ប្រការ៧ និង ប្រការ១០ នៃប្រកាសលេខ ៧៥ប្រក/ដនស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់

ឧេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/ន.ស/៩៤ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីកដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- យោងតាមការចាំបាច់របស់ក្រសួង

<u>សំរេច</u>

ប្រការ ១.-

ត្រូវបានកែសំរួលប្រការ ៧ និងប្រការ ១០ នៃប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញាឆ្នាំ ...
ការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងបួង និង សាងសង់ ដូចខាងក្រោម :

ប្រការ ៧ថ្មី.-

ទំរង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងបួង និងសាងសង់ត្រូវមានលក្ខខណ្ឌដូចតទៅ :

១- ប្រធានសហគ្រាស និងក្រុមហ៊ុនត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ។

២- នាយកបច្ចេកទេសនៃសហគ្រាស និងក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

៣- សំណុំឯកសារដែលត្រូវបំពេញរួមមាន :

- ពាក្យសុំប្រកបអាជីវកម្ម ៣ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និងក្រុមហ៊ុនដោយមានបិទរូបថតទំហំ ៤X ៦ ៣ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានសហគ្រាស និងក្រុមហ៊ុន ៣ច្បាប់
- លិខិតបញ្ជាក់ទីលំនៅរបស់ប្រធានសហគ្រាស និងក្រុមហ៊ុន ពីសាលាឃុំ សង្កាត់ ១ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេសដោយមានបិទរូបថតទំហំ ៤X ៦ ៣ច្បាប់
- លក្ខន្តិក:របស់សហគ្រាស និងក្រុមហ៊ុន ដែលមានធ្វើនីត្យានុកូលកម្មនៅសាលាខេត្ត ក្រុង ៣ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាស និងក្រុមហ៊ុន និងសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម ៣ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាស ក្រុមហ៊ុន និងអ្នកបច្ចេកទេស ដែលជានាយកបច្ចេកទេស ឬជានាយកគំរោង ៣ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្ររបស់អ្នកបច្ចេកទេសដែលមានធ្វើនីត្យានុកូលកម្មនៅសាលាខេត្ត ក្រុង ៣ច្បាប់
- បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និងអង្គការលេខរបស់សហគ្រាស និងក្រុមហ៊ុន ៣ច្បាប់
- បញ្ជីសំភារៈបរិក្ខារសិក្សាគំរោងបួង់ សំរាប់សហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងបួង់ ៣ច្បាប់
- បញ្ជីសំភារៈបរិក្ខារគ្រឿងចក្រសំណង់ សំរាប់សហគ្រាស និងក្រុមហ៊ុនសាងសង់ ៣ច្បាប់
- ឯកសារបញ្ជាក់ដើមទុនពីធនាគារ សំរាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង ១ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ ឬ ប័ណ្ណចាំតង់ សំរាប់សហគ្រាស និងក្រុមហ៊ុនសុំបន្តសុពលភាព ១ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម សំរាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង ១ច្បាប់
- ឯកសារស្នាដៃ សំរាប់សហគ្រាស និងក្រុមហ៊ុនប្រភេទទី១ និងទី២ ៣ច្បាប់

ប្រការ ១០ថ្មី.-

លិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគំរោងបួង់ និងសាងសង់មានសុពលភាព ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។

រយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព សហគ្រាស និងក្រុមហ៊ុនធ្វើអាជីវកម្មសិក្សាគំរោងបួង់ និង សាងសង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្នុងករណីសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម សហគ្រាស និងក្រុមហ៊ុនត្រូវធ្វើពាក្យសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតចាស់ និងបង្កាន់ដៃបង់ពន្ធអាករ ឬប័ណ្ណប៉ាតង់ប្រចាំឆ្នាំចុងក្រោយ ។

ក្នុងករណីសុំតម្លើងឋានៈប្រភេទ សហគ្រាស និងក្រុមហ៊ុនត្រូវធ្វើបែបបទស្នើសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសំរេច ។

សហគ្រាស និង ក្រុមហ៊ុនត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ ២.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី ប្រចាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
-ដូចប្រការ២
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីការគ្រប់គ្រង រូបភន្ត
សិក្ខាគម្រោងប្លង់

ឆ្នាំ ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ១.៩.៦.ប្រក.ដនស/អសណ

ប្រកាស

ស្តីពី

ការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្តូច

ឧេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/ន.ស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីតជជជដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្តូង និង សាងសង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សំរេច

ប្រការ ១.-

ប្រកាសនេះមានវិសាលភាពអនុវត្តលើរូបវន្តបុគ្គលជាស្ថាបត្យករ ឬវិស្វករ ដែលធ្វើការសិក្សាគំរោងប្តូងនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។ រូបវន្តបុគ្គលទាំងនោះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ ២.-

ក្នុងន័យនៃប្រកាសនេះ វាក្យស័ព្ទ :

- រូបវន្តបុគ្គលសំដៅដល់អ្នកសិក្សាគំរោងបួង មានលក្ខណៈជាបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស
- សិក្សាគំរោងបួងសំដៅដល់ការសិក្សាគំរោងបួងដែលពាក់ព័ន្ធនឹងការសាងសង់ ។

ប្រការ ៣.-

ស្ថាបត្យករ ឬវិស្វករដែលធ្វើការសិក្សាគំរោងបួងតាមមុខជំនាញរបស់ខ្លួនជារូបវន្តបុគ្គល ត្រូវមកបំពេញបែបបទសុំចុះឈ្មោះជារូបវន្តបុគ្គលសិក្សាគំរោងបួងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (នាយកដ្ឋានសិក្សាគំរោងបួងនៃអគ្គនាយកដ្ឋានសំណង់) ដើម្បីមានសិទ្ធិក្នុងការសិក្សាគំរោងបួងសំណង់ផ្សេងៗ និងមានការទទួលស្គាល់ពីក្រសួងនូវបទពិសោធន៍មុខវិជ្ជាជីវៈជំនាញដែលខ្លួនមាន ។

ក្រសួងមិនទទួលស្គាល់រាល់ការចុះហត្ថលេខាបញ្ជាក់លើរាល់ឯកសារ គំរោងបួងរបស់ស្ថាបត្យករ ឬវិស្វករណាដែលមិនបានមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះទេ ។

ប្រការ ៤.-

រាល់រូបវន្តបុគ្គលដែលមានចំណង ឬកំពុងធ្វើការសិក្សាគំរោងបួងនៅព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែរ ។

ប្រការ ៥.-

ដើម្បីចុះបញ្ជីរូបវន្តបុគ្គលសិក្សាគំរោងបួង ស្ថាបត្យករ ឬវិស្វករត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

- មានសញ្ញាបត្រស្ថាបត្យករ ឬសញ្ញាបត្រវិស្វករ
- មានបទពិសោធន៍ការងារក្នុងមុខជំនាញ ដែលធ្លាប់បានអនុវត្តការងារសិក្សាគំរោងបួងកន្លងមក នៅតាមបណ្តាអង្គភាព ស្ថាប័ន ក្រុមហ៊ុនឯកជន អង្គការនានា ។ល។
- មានលិខិតបញ្ជាក់ការសិក្សា ឬវិញ្ញាបនបត្រផ្សេងៗនៃវគ្គបំពាក់បំប៉ន ឬបណ្តុះបណ្តាលបន្ថែមផ្តែកមុខជំនាញជាក់ខ្លួនប្រសិនបើមាន ។

ប្រការ ៦.-

១- ស្ថាបត្យករជារូបវន្តបុគ្គលសិក្សាគំរោងបួងស្ថាបត្យកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

ក- កិតិចថ្នាក់ទី១ : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

ខ- កិតិចថ្នាក់ទី២ : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

គ_ **កំរិតទី៣** : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ ឆ្នាំ ។

២~ វិស្វករជារូបវន្តបុគ្គលសិក្សាគំរោងបួងគ្រឿងផ្គុំសំណង់ ឬបួងវិស្វកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

ក_ **កំរិតទី១** : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

ខ_ **កំរិតទី២** : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

គ_ **កំរិតទី៣** : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ ឆ្នាំ ។

ប្រការ ៧.~

ការកំណត់កំរិតរូបវន្តបុគ្គលត្រូវពិនិត្យសំរេចដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ ៨.~

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចដូចតទៅ :

- វាយតំលៃរូបវន្តបុគ្គលដែលស្នើសុំចុះបញ្ជី
- តាមដានត្រួតពិនិត្យសកម្មភាពរបស់រូបវន្តបុគ្គលក្នុងពេលសិក្សាគំរោងបួង
- ស៊ើបអង្កេតពេលមានបណ្តឹងតវ៉ាចំពោះរូបវន្តបុគ្គល និងធ្វើការសំរបសំរួលការងារពាក់ព័ន្ធផ្នែកវិស្វកម្មនិងស្ថាបត្យកម្ម
- ស្នើសុំព្យួរ ឬដកយកវិញ្ញាបនបត្រពីរូបវន្តបុគ្គលណាដែលប្រព្រឹត្តខុសលក្ខណៈបច្ចេកទេស មិនគោរពកាតព្វកិច្ច និងសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ។

ប្រការ ៩.~

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចចេញវិញ្ញាបនបត្រសិក្សាគំរោងបួង និងចេញលិខិតបិទប្បដ្ឋាក ការសិក្សាគំរោងបួងរបស់រូបវន្តបុគ្គល ។

ប្រការ ១០.~

សំណុំឯកសារនៃពាក្យសុំសិក្សាគំរោងបួងរបស់រូបវន្តបុគ្គលរួមមាន :

- ពាក្យសុំសិក្សាគំរោងបួង ៣ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់រូបវន្តបុគ្គល មានបិទរូបថតទំហំ ៤ x ៦ ៣ច្បាប់
- អត្តសញ្ញាណប័ណ្ណរបស់រូបវន្តបុគ្គល (ថតចំលង) ៣ច្បាប់
- លិខិតបញ្ជាក់ទីលំនៅរបស់រូបវន្តបុគ្គល ពីឃុំ សង្កាត់ (ច្បាប់ដើម) ១ច្បាប់
- សញ្ញាបត្ររបស់រូបវន្តបុគ្គលដែលមានធ្វើនីត្យានុកូលកម្មបញ្ជាក់ពីសាលាខេត្ត ក្រុង ១ច្បាប់
- កិច្ចសន្យាការងាររវាងរូបវន្តបុគ្គលជាមួយនឹងអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៣ច្បាប់

- បញ្ជីសំភារៈបរិក្ខារសិក្សាគំរោងបួង ៣ច្បាប់
-ឯកសារស្នាដៃ សំរាប់រូបវន្តបុគ្គលកំរិតទី១ និងកំរិតទី២ ៣ច្បាប់

ប្រការ ១១.-

សំណុំឯកសារពាក្យសុំសិក្សាគំរោងបួង ត្រូវដាក់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ក្នុងករណីសំណុំឯកសារនៃពាក្យសុំចុះបញ្ជីមានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់ និងបន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងផ្តល់ជូនវិញ្ញាបនបត្រសិក្សាគំរោងបួង ជូនម្ចាស់សំណើក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីពិនិត្យឃើញថា លិខិតស្នាមណាមួយនៃសំណុំឯកសារពាក្យសុំ មានភាពមិនច្បាស់លាស់ ឬមិនគ្រប់គ្រាន់ សាមីខ្លួនត្រូវបំពេញបន្ថែមតាមការណែនាំរបស់នាយកដ្ឋានសិក្សាគំរោងបួង ។

ប្រការ ១២.-

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រសិក្សាគំរោងបួង នឹងអាចចូលរួមក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាលនានាតាមការអញ្ជើញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីលើកកំពស់សមត្ថភាព និងគុណភាពវិជ្ជាជីវៈលើការងារជំនាញ ។

ប្រការ ១៣.-

រាល់រូបវន្តបុគ្គលសិក្សាគំរោងបួងអាចសុំតម្លើងឋានៈកិរិតរបស់ខ្លួន នៅពេលណាដែលរូបវន្តបុគ្គលនោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយការវាយតំលៃក្នុងការតំលើងឋានៈនេះ ត្រូវពិនិត្យសំរេចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ ១៤.-

រូបវន្តបុគ្គលដែលប្រកបអាជីវកម្មសិក្សាគំរោងបួង ត្រូវបង់ពន្ធអាករតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ប្រការ ១៥.-

វិញ្ញាបនបត្រសិក្សាគំរោងបួងរបស់រូបវន្តបុគ្គលមានសុពលភាព ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។ ក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព រូបវន្តបុគ្គលត្រូវដាក់ពាក្យសុំបន្តសុពលភាពសិក្សាគំរោងបួង សាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

រូបវន្តបុគ្គលត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅរាល់ដំណាច់ឆ្នាំនីមួយៗ ។

ប្រការ ១៦.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបិទឬផ្អាកការសិក្សាគំរោងបួង ចំពោះរូបវន្តបុគ្គល ដែលគ្មានវិញ្ញាបនបត្រសិក្សាគំរោងបួង និងចំពោះរូបវន្តបុគ្គលទាំងឡាយណាដែលវិញ្ញាបនបត្រសិក្សាគំរោងបួងហួសសុពលភាព ឬមិនគោរពតាមសីលធម៌វិជ្ជាជីវៈ និងតាមការណែនាំរបស់សមត្ថកិច្ចជំនាញ ។

ប្រការ ១៧.-

ស្ថាបត្យករ ឬវិស្វករដែលបានចុះបញ្ជី និងបានបំពេញកាតព្វកិច្ចស្របតាមគោលការណ៍សីលធម៌វិជ្ជាជីវៈមានទេពកោសល្យ មានស្នាដៃឆ្នើម មានគុណបំណាច់ និងមនសិការបំរើប្រទេសជាតិក្នុងការងារវិជ្ជាជីវៈរបស់ខ្លួន នឹងត្រូវទទួលស្គាល់ និងលើកសរសើរ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថាជាស្ថាបត្យករឆ្នើម ឬជាវិស្វករឆ្នើម ។

ប្រការ ១៨.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល :
- ការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ១៨
- គ្រប់មន្ទីរ ប.ន.ស.ស ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសរួម
ស្តីពីការគ្រប់គ្រងអាជីវកម្ម
អតិថិជនអចលនទ្រព្យ

ឆ្នាំ ២០១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:...សហវ...

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩

ប្រកាស
ស្តីពី
ការគ្រប់គ្រងអាជីវកម្មអតិថិជនឆមាស

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់សារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើវិសោធនកម្មច្បាប់នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែមនិងការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ អនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារនិង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១២៦ អនក្រ/បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ អគារសហកម្មសិទ្ធិ
- បានឃើញ អនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧
- បានឃើញ ប្រកាសលេខ ២១៦ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ១៤៩៧ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- យោងការចាំបាច់ក្នុងការគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុ ។

ស ម្រ ច

ជំពូក ទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១ .គោលដៅ

ប្រកាសនេះមានគោលដៅបង្កើតនូវយន្តការនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់ អាជ្ញាប័ណ្ណដល់បុគ្គលអភិវឌ្ឍអចលនវត្ថុដែលកំពុងតែធ្វើធុរកិច្ច ឬនឹងត្រូវធ្វើធុរកិច្ច ព្រមទាំងបង្កើតនូវវិធានការណានានាដើម្បីគ្រប់គ្រងការអភិវឌ្ឍវិស័យអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ .គោលបំណង

ប្រកាសនេះកំណត់នូវបទប្បញ្ញត្តិផ្សេងៗដែលមានគោលបំណងដូចខាងក្រោម ÷

- ដើម្បីកែលំអ និងតម្រង់ទិសដល់បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ដែលកំពុងធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ដើម្បីជំរុញឱ្យមានការអភិវឌ្ឍអចលនវត្ថុមួយដែលមានការទុកចិត្ត និងទទួលយកបានតាមរយៈការត្រួតពិនិត្យគម្រោងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ គ្រប់គ្រងគម្រោងហិរញ្ញវត្ថុ គណនីអភិវឌ្ឍអចលនវត្ថុ និងការធ្វើសវនកម្មលើការអនុវត្តកិច្ចសន្យាទិញ-លក់
- បង្កើនទំនុកចិត្តរបស់អតិថិជនក្នុងការវិនិយោគលើអចលនវត្ថុ
- ធានាទំនិរន្តរភាពសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍអចលនវត្ថុឱ្យស្របតាមលក្ខណៈជាតិ និងស្តង់ដារអន្តរជាតិ
- ទប់ស្កាត់រាល់ការអភិវឌ្ឍអចលនវត្ថុដែលគ្មានភាពច្បាស់លាស់ និងគ្មានការអនុញ្ញាតត្រឹមត្រូវ
- បង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗ ។

ប្រការ ៣ .ការបកស្រាយ និង អត្ថន័យនៃពាក្យគន្លឹះ

- **ក្រសួង** សំដៅដល់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ វិញ្ញត្តិ ឬការជូនដំណឹងនៃការអភិវឌ្ឍអចលនវត្ថុតាមរយៈ÷

(ក) ការផ្សព្វផ្សាយនៅក្នុងសារព័ត៌មាន ការសែត ទស្សនាវដ្តី គេហទំព័រ ឬក្នុងទ្រង់ទ្រាយជាកូនសៀវភៅផ្សាយពាណិជ្ជកម្មតូចៗ ឬក្នុងទ្រង់ទ្រាយផ្សេងៗទៀត ឬ

(ខ) ការបង្ហាញនៅតាមរបង ជញ្ជាំង បង្គោល ជំរំបូល ស្លាកសញ្ញា ក្រណាត់ សរសរ ។ល។ ឬ

(គ) ការផ្សព្វផ្សាយតាមរយៈភាពយន្ត ឬតាមការទំនាក់ទំនងផ្សេងៗ

(ឃ) ការផ្សព្វផ្សាយតាមរយៈពីមាត់មួយទៅមាត់មួយ ឬជាលាយលក្ខណ៍អក្សរ មិនថាប្រភេទដូចគ្នា ឬខុសគ្នាដូចដែលមានចែងក្នុងចំណុច (ក) ដល់ (គ) ។

- **អាជ្ញាធរពាក់ព័ន្ធ** សំដៅដល់ អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធដល់ការអនុញ្ញាតលើគម្រោងអភិវឌ្ឍអចលនវត្ថុ ដើម្បីឱ្យប្រតិបត្តិការសាងសង់ប្រព្រឹត្តិទៅដោយស្របច្បាប់ ដោយរាប់បញ្ចូលទាំងក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណផ្តល់សេវាអគ្គិសនី ទូរស័ព្ទ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ ។

- **អចលនវត្ថុ** សំដៅដល់ ដីសម្រាប់សាងសង់ សំណង់អគារ និងសំណង់ផ្សេងៗ រួមបញ្ចូលទាំងអ្វីៗគ្រប់យ៉ាងដែលមាននៅលើ និងនៅក្រោមដី គិតទាំងវត្ថុដែលតាំងភ្ជាប់ជាអចិន្ត្រៃយ៍នៅលើដីនោះ ទោះបីវត្ថុនោះកើតឡើងដោយធម្មជាតិ ឬក៏កើតឡើងដោយសិប្បនិមិត្តក៏ដោយ ។

- **បុគ្គលអភិវឌ្ឍអចលនវត្ថុ** សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ ។ បុគ្គលអភិវឌ្ឍអចលនវត្ថុមានបីប្រភេទគឺ ÷

(ក) បុគ្គលប្រភេទទី ១ : បុគ្គលអភិវឌ្ឍអចលនវត្ថុដែលមានដើមទុនរបស់ខ្លួនទាំងស្រុង ដោយមិនពឹងពាក់ធនធានហិរញ្ញវត្ថុពីអតិថិជនដើម្បីសាងសង់សំណង់អគារផ្សេងៗ រហូតដល់បញ្ចប់គម្រោងជាស្ថាពរទើបប្រកាសលក់ជូនអតិថិជន ។

(ខ) បុគ្គលប្រភេទទី ២ : បុគ្គលអភិវឌ្ឍអចលនវត្ថុដែលមានមូលនិធិបរទេសជាទុនចំបង ឬដែលប្រើប្រាស់ប្រាក់កម្ចីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនានា ដើម្បីសាងសង់គម្រោងរហូតដល់បញ្ចប់គម្រោងជាស្ថាពរទើបប្រកាសលក់ជូនអតិថិជន ។

(គ) បុគ្គលប្រភេទទី ៣ : បុគ្គលអភិវឌ្ឍអចលនវត្ថុដែលអនុវត្តគម្រោងដោយកៀរគរធនធានហិរញ្ញវត្ថុជាមុនពីអតិថិជន ដើម្បីធ្វើការអភិវឌ្ឍអចលនវត្ថុ ឬបុគ្គលទាំងឡាយណាដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ប្រភេទទី ១ និងទី ២ ខាងលើ ។

- **ការអភិវឌ្ឍអចលនវត្ថុ** សំដៅដល់គម្រោង ឬការសាងសង់ សំណង់អគារ ឬសំណង់ផ្សេងៗ សម្រាប់ស្នាក់នៅ ដែលមានទំហំចាប់ពី ៤ ល្វែង ឬ ចាប់ពី ៣ ភូមិគ្រឹះ ឬ ចាប់ពី ៤ ឃ្នូតឡើងទៅ (ចំពោះសំណង់អគារស្នាក់នៅរួម និង សហវិជិតរាជ្យ) ក្នុងគោលបំណងសម្រាប់លក់ ឬជួល ។ ចំពោះសំណង់គ្រប់ប្រភេទដែលសាងសង់ឡើងក្នុងគោលបំណងដើម្បីស្នាក់នៅផ្ទាល់ខ្លួនមិនត្រូវបានអនុវត្តដោយប្រកាសនេះឡើយ ។

- **គណនីអភិវឌ្ឍអចលនវត្ថុ** សំដៅដល់គណនីដែលត្រូវបានបើក និងថែរក្សាដោយបុគ្គលអភិវឌ្ឍអចលនវត្ថុនៅធនាគារពាណិជ្ជណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរក្សាប្រាក់កក់ ឬប្រាក់បង់តាមដំណាក់កាលរបស់អតិថិជន ។ គណនីនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានរួមគ្នាដោយក្រុមការងារអន្តរក្រសួង និងធនាគារពាណិជ្ជដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានបើក ។

- **គណនីគម្រោងអភិវឌ្ឍអចលនវត្ថុ** សំដៅដល់គណនីដែលត្រូវបានបើក និងថែរក្សាដោយបុគ្គលអភិវឌ្ឍអចលនវត្ថុនៅធនាគារណាមួយសម្រាប់រក្សាប្រាក់កម្ចីពីប្រភពផ្សេងៗ ដែលមិនមែនជាប្រាក់កក់ ឬប្រាក់បង់តាមដំណាក់កាលរបស់អតិថិជន ។ គណនីនេះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមការងារអន្តរក្រសួងឡើយ។

- **ក្រុមហ៊ុនវិស្វកម្មឯករាជ្យ** សំដៅដល់ ក្រុមហ៊ុនសិក្សាគម្រោងប្លង់ក្នុងស្រុក ឬបរទេស ឬបុគ្គលដែលទទួលបានវិញ្ញាបនប័ត្រប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការរៀបចំវិធានការ និងការត្រួតពិនិត្យមើលដំណើរការសាងសង់គម្រោង ។

- **អាជ្ញាប័ណ្ណ** សំដៅដល់ អាជ្ញាប័ណ្ណផ្តល់ជូនដូចដែលមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ។

- **ក្រុមការងារអន្តរក្រសួង** សំដៅដល់ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- **អតិថិជន** សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានទំនាក់ទំនងអាជីវកម្មលើផ្នែកអចលនវត្ថុជាមួយនឹងបុគ្គលអភិវឌ្ឍអចលនវត្ថុ ។

- **ការប្រកាសលក់** សំដៅដល់ការផ្សព្វផ្សាយព័ត៌មានដូចមានចែងក្នុងប្រការ ១០ ជាសាធារណៈ ដើម្បីសម្រួលដល់ការលក់ផ្ទះ ភូមិគ្រឹះ យូនីតនៃអគារស្នាក់នៅរួម ឬនៃសហវិជិតរាជ្យ ដែលធ្វើដោយបុគ្គលអភិវឌ្ឍអចលនវត្ថុ ។

ជំពូក ទី ២

ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

ផ្នែក ទី ១

អាជ្ញាប័ណ្ណ

ប្រការ ៤ .ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

ដើម្បីដំណើរការអាជីវកម្មអភិវឌ្ឍអចលនវត្ថុទៅបាន បុគ្គលអភិវឌ្ឍអចលនវត្ថុទាំង ៣ ប្រភេទ ត្រូវបំពេញពាក្យស្នើសុំអាជ្ញាប័ណ្ណទៅតាមទម្រង់ដែលបានរៀបចំដោយក្រុមការងារនៅលេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ដែលមានទីតាំងនៅការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធមួយចំនួនដូចខាងក្រោម ÷

(ក) បុគ្គលអភិវឌ្ឍអចលនវត្ថុប្រភេទទី ១ និង ទី ២ ត្រូវភ្ជាប់មកជាមួយនូវឯកសារ ÷

- លក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម
- លិខិតថ្កោលទោសរបស់នាយកក្រុមហ៊ុនចេញដោយក្រសួងយុត្តិធម៌ (ចំពោះជនជាតិខ្មែរ)
- លិខិតថ្កោលទោសរបស់នាយកក្រុមហ៊ុនចេញដោយប្រទេសសាមី (ចំពោះជនបរទេស)
- ឋតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា (ចំពោះអ្នកស្នើសុំអាជ្ញាប័ណ្ណជាជនបរទេស)
- គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍអចលនវត្ថុនៅតាមតំបន់នីមួយៗ (ប្រសិនបើមាន)
- លិខិតអនុញ្ញាតសាងសង់ និងលិខិតបើកការដ្ឋានដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ។
- លិខិតបញ្ជាក់របស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុអំពីដើមទុនដែលបុគ្គលប្រភេទទី ១ ឬទី ២ មាន (ដើមទុនសម្រាប់អភិវឌ្ឍគម្រោងទាំងមូល ឬតាមដំណាក់កាល)
- ប័ណ្ណធានារ៉ាប់រងដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយទៅលើការៈទទួលខុសត្រូវការដ្ឋាន និងធានារ៉ាប់រងការដ្ឋានដែលទិញដោយម្ចាស់សំណង់ ឬដោយក្រុមហ៊ុនសាងសង់

- ថតចម្លងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ វិញ្ញាបនប័ត្រជួលរយៈពេលវែងដែលមានធ្វើនីត្យានុកូលកម្មនៅសាលារាជធានី ខេត្ត ។
- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលស្នើដោយក្រុមការងារអន្តរក្រសួង ។

(ខ) បុគ្គលអភិវឌ្ឍអចលនវត្ថុប្រភេទទី ៣ ត្រូវភ្ជាប់មកជាមួយនូវឯកសារ ÷

- លក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម
- លិខិតថ្កោលទោសរបស់នាយកក្រុមហ៊ុនចេញដោយក្រសួងយុត្តិធម៌ (ចំពោះជនជាតិខ្មែរ)
- លិខិតថ្កោលទោសរបស់នាយកក្រុមហ៊ុនចេញដោយប្រទេសសាមី (ចំពោះជនបរទេស)
- ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន និងទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា (ចំពោះអ្នកស្នើសុំអាជ្ញាប័ណ្ណជាជនបរទេស)
- គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍអចលនវត្ថុនៅតាមតំបន់នីមួយៗ (ប្រសិនបើមាន)
- លិខិតអនុញ្ញាតសាងសង់ លិខិតបើកការដ្ឋាន និងគម្រោងប្លង់ស្ថាបត្យកម្មដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត
- លេខគណនីអភិវឌ្ឍអចលនវត្ថុដែលបើកដោយបុគ្គលអភិវឌ្ឍអចលនវត្ថុនៅធនាគារពាណិជ្ជណាមួយសម្រាប់គម្រោងដែលត្រូវអភិវឌ្ឍ
- ឯកសារតំកល់ប្រាក់ធានាដូចមានចែងក្នុងប្រការ ១៥ នៃប្រកាសនេះ
- បំណុលធានារ៉ាប់រងដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយទៅលើភារៈទទួលខុសត្រូវការដ្ឋាន
- ថតចម្លងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ វិញ្ញាបនប័ត្រជួលរយៈពេលវែងដែលមានធ្វើនីត្យានុកូលកម្មនៅសាលារាជធានី ខេត្ត
- ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលស្នើដោយក្រុមការងារអន្តរក្រសួង ។

រាល់ការខកខានមិនបានផ្តល់ឯកសារ ឬផ្តល់ព័ត៌មានក្លែងបន្លំមកក្រុមការងារអន្តរក្រសួងចំពោះចំណុចណាមួយក្នុងប្រការនេះ នឹងត្រូវចាត់ទុកជាការលើសទៅនឹងប្រកាសនេះ ។

ក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំពេញលេញ ក្រុមការងារអន្តរក្រសួងមានសិទ្ធិផ្តល់អាជ្ញាប័ណ្ណដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬ បដិសេធមិនផ្តល់អាជ្ញាប័ណ្ណជូនប្រសិនបើអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលបានកំណត់ ។

ការផ្តល់អាជ្ញាប័ណ្ណត្រូវបានគម្រូវដាច់ដោយឡែកពីគ្នាសម្រាប់គម្រោងសាងសង់នីមួយៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដូចគ្នា ។

ប្រការ ៥ .ប្រភេទអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណអភិវឌ្ឍអចលនវត្ថុនឹងត្រូវផ្តល់ជូនទៅតាមប្រភេទ ឬទំហំនៃការអភិវឌ្ឍអចលនវត្ថុ ។ ទម្រង់អាជ្ញាប័ណ្ណដែលនឹងផ្តល់ជូនត្រូវបានកំណត់ដោយក្រុមការងារអន្តរក្រសួង ។

ប្រការ ៦ .ថ្លៃអាជ្ញាប័ណ្ណ និង សុពលភាព

ថ្លៃអាជ្ញាប័ណ្ណ និងសុពលភាពត្រូវបានកំណត់ទៅតាមប្រភេទ និងទំហំនៃការអភិវឌ្ឍដូចខាងក្រោម÷

ក/សំណង់ផ្ទះល្វែង

ទំហំ	ថ្លៃអាជ្ញាប័ណ្ណ(រៀល)	សុពលភាពអាជ្ញាប័ណ្ណ
ចាប់ពី ០៤ ល្វែង-១០ ល្វែង	១ ៥០០ ០០០	០២ ឆ្នាំ
ចាប់ពី ១១ ល្វែង-៥០ ល្វែង	៣ ០០០ ០០០	០៣ ឆ្នាំ
ចាប់ពី ៥១ ល្វែង-១០០ ល្វែង	៥ ០០០ ០០០	០៤ ឆ្នាំ
ចាប់ពី ១០១ ល្វែងឡើងទៅ	៨ ០០០ ០០០	០៥ ឆ្នាំ

ខ/សំណង់ភូមិគ្រឹះ

ទំហំ	ថ្លៃអាជ្ញាប័ណ្ណ(រៀល)	សុពលភាពអាជ្ញាប័ណ្ណ
ចាប់ពី ០៣ ភូមិគ្រឹះ-១០ ភូមិគ្រឹះ	៣ ០០០ ០០០	០៣ ឆ្នាំ
ចាប់ពី ១១ ភូមិគ្រឹះ-៥០ ភូមិគ្រឹះ	៦ ០០០ ០០០	០៤ ឆ្នាំ
ចាប់ពី ៥១ ភូមិគ្រឹះឡើងទៅ	១១ ០០០ ០០០	០៥ ឆ្នាំ

គ/សំណង់អគារស្នាក់នៅរួម (Apartment) **ឬ សហវិជ្ជិតរាជ្យ** (Condominium)

ទំហំ	ថ្លៃអាជ្ញាប័ណ្ណ(រៀល)	សុពលភាពអាជ្ញាប័ណ្ណ
ចាប់ពី ០៤- ១០ យូនីត	១ ៥០០ ០០០	០២ ឆ្នាំ
ចាប់ពី ១១-៥០ យូនីត	៣ ០០០ ០០០	០៣ ឆ្នាំ
ចាប់ពី ៥១- ១០០ យូនីត	៥ ០០០ ០០០	០៣ ឆ្នាំ
ចាប់ពី ១០១- ២០០ យូនីត	៨ ០០០ ០០០	០៤ ឆ្នាំ
ចាប់ពី ២០១- ៤០០ យូនីត	១០ ០០០ ០០០	០៥ ឆ្នាំ
ចាប់ពី ៤០០ យូនីតឡើងទៅ	១២ ០០០ ០០០	០៥ ឆ្នាំ

ប្រការ ៧ .ការស្នើបន្តអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណគ្រប់ប្រភេទមានសុពលភាពដូចចែងក្នុងប្រការ ៦ នៃប្រកាសនេះ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ប្រសិនបើការសាងសង់មិនទាន់បានបញ្ចប់តាមកិច្ចសន្យាទិញ-លក់ ឬជួល បុគ្គលអភិវឌ្ឍ

អចលនវត្ថុ ដែលមិនមានលិខិតអនុញ្ញាតបិទការដ្ឋានពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងស៊ុរិយោដីរាជធានី ខេត្តទេ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាប័ណ្ណឱ្យបាន ៦០ ថ្ងៃ មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព និងត្រូវបង់ថ្លៃអាជ្ញាប័ណ្ណសាជាថ្មីដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ។

ក្នុងរយៈពេល ៤៥ ថ្ងៃគិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំពេញលេញ ក្រុមការងារអន្តរក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណ ដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬ មិនបន្តអាជ្ញាប័ណ្ណជូនប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រុមការងារអន្តរក្រសួងបានកំណត់ ។

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលស្នើសុំបន្តសុពលភាពអាជ្ញាប័ណ្ណត្រូវបំពេញពាក្យស្នើសុំទៅតាមទម្រង់បែបបទដូចដែលបានរៀបចំជូនដោយក្រុមការងារ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធមួយចំនួនដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ និងបញ្ជាក់ឱ្យបានច្បាស់ពីលក្ខណៈផ្លាស់ប្តូរណាមួយរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ ។

រាល់ការខកខានមិនបានផ្តល់ឯកសារ ឬផ្តល់ព័ត៌មានក្លែងបន្លំមកក្រុមការងារអន្តរក្រសួងចំពោះចំណុចណាមួយក្នុងប្រការនេះ នឹងត្រូវចាត់ទុកជាការល្មើស ហើយត្រូវទទួលការផាកពិន័យដូចមានចែងក្នុងប្រការ ២៥ នៃប្រកាសនេះ ។

ប្រការ ៨ .ការដកហូត ឬការផ្អាកអាជ្ញាប័ណ្ណ

ក្រុមការងារអន្តរក្រសួងមានសិទ្ធិដកហូត ឬផ្អាកអាជ្ញាប័ណ្ណ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិករណីដូចខាងក្រោម ÷

- ពុំបានចាប់ផ្តើមអនុវត្តគម្រោងក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ
- ពុំបានអនុវត្តឱ្យបានត្រឹមត្រូវទៅតាមខ្លឹសារនៃប្រកាស និងសារាចរណែនាំ ព្រមទាំងលិខិតបទដ្ឋានផ្សេងៗទៀតដែលចេញដោយក្រុមការងារអន្តរក្រសួងទៅតាមដំណាក់កាលនីមួយៗ
- ក្រោយពីទទួលបានការណែនាំពីក្រុមការងារ ព្រមទាំងទទួលការផាកពិន័យ ហើយអ្នកកាន់អាជ្ញាប័ណ្ណនៅតែប្រព្រឹត្តិល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ
- ខកខានមិនបានកាន់កាប់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ
- ខកខានមិនបានបង់ពន្ធប៉ាតង់អភិវឌ្ឍអចលនវត្ថុ និងមិនបានបំពេញបែបបទបង់ពន្ធតាមនីតិវិធីសារពើពន្ធត្រឹមត្រូវដោយមានលិខិតបញ្ជាក់ពីអគ្គនាយកដ្ឋានពន្ធដារ ក្រោយពីទទួលបានអាជ្ញាប័ណ្ណរយៈពេល ៣ (បី)ខែ
- ករណីបុគ្គលអភិវឌ្ឍអចលនវត្ថុអសាធនភាព ឬស្ម័យធន ឬប្រព្រឹត្តិល្មើសក្នុងការធ្វើអាជីវកម្ម
- ការប្រកាសលក់ដោយគ្មានលិខិតបិទការដ្ឋានសាងសង់ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងស៊ុរិយោដី

រាជធានី ខេត្ត ឬគ្មានការអនុញ្ញាត ឬផ្សព្វផ្សាយខុសពីខ្លឹមសារដែលបានអនុញ្ញាតពីក្រុមការងារអន្តរក្រសួង

- ខកខានមិនបានរាយការណ៍ពីការកែប្រែនៃការប្រកាសលក់ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ
- ក្រោយពីធ្វើសវនកម្មទៅឃើញថា មានការខុសគ្នាពាក់ព័ន្ធទៅនឹងរបាយការណ៍បញ្ចប់គម្រោង និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុ ដូចមានចែងក្នុងប្រការ ១៩ ប្រការ ២៣ និងប្រការ ២៤ នៃប្រកាសនេះ ដែលបានដាក់ជូនមកក្រុមការងារអន្តរក្រសួងនៅដំណាក់កាលនីមួយៗ
- ប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ឬ ប្រព្រឹត្តិបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច ហើយដែលក្រុមការងារយល់ថា មិនសមស្របជាអ្នកកាន់អាជ្ញាប័ណ្ណ ។

ផ្នែកទី ២

ការប្រកាសផ្សាយពាណិជ្ជកម្ម

ប្រការ ៩ .ការប្រកាស /ការផ្សាយពាណិជ្ជកម្ម លក់ ឬជួល

រាល់ការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួលដែលធ្វើឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម ÷

(ក) បើមិនទាន់បានលិខិតអនុញ្ញាតសាងសង់ និងលិខិតបើកការដ្ឋានសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីសាលារាជធានី ខេត្ត និងមិនទាន់បានទទួលអាជ្ញាប័ណ្ណអភិវឌ្ឍអចលនវត្ថុពីក្រុមការងារអន្តរក្រសួងទេ បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ មិនត្រូវធ្វើការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួល ឬធ្វើការប្រមូលប្រាក់ជាសាធារណៈតាមគ្រប់វិធីសាស្ត្រដោយរួមទាំងការកក់ប្រាក់ ការបង់រំលោះ ការបង់ប្រាក់មុនពីអតិថិជនបានឡើយ ។

(ខ) បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ ត្រូវផ្តល់ជូនក្រុមការងារអន្តរក្រសួងនូវរាល់ព័ត៌មានទាំងឡាយដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ មុនពេលប្រកាស/ផ្សាយពាណិជ្ជកម្មលក់ ឬជួល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។ ប្រសិនបើមានការផ្លាស់ប្តូរព័ត៌មានពីការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួលដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ បុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវផ្តល់ជូនក្រុមការងារអន្តរក្រសួងពីការផ្លាស់ប្តូរនោះ ។

(គ) រាល់ការផ្សព្វផ្សាយដែលនាំឱ្យមានការយល់ខុស ឬផ្សាយពាណិជ្ជកម្មនូវពាក្យមិនពិតនឹងត្រូវទទួលការដាកពិន័យដូចមានចែងក្នុងប្រការ ២៥ នៃប្រកាសនេះ ។

(ឃ) ក្រុមការងារអន្តរក្រសួងមានសិទ្ធិអនុញ្ញាត ឬមិនអនុញ្ញាតឱ្យធ្វើការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួលដោយមាន ឬដោយគ្មានលក្ខខណ្ឌ ឬបដិសេធមិនអនុញ្ញាតជូនទាំងស្រុងតែម្តង ប្រសិនបើក្រុមការងារអន្តរក្រសួងយល់ឃើញថា រាល់ការប្រកាស/ការផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬជួលនោះជាការឆបោក ឬនាំឱ្យមានការយល់ច្រឡំ ។

(ង) ការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួលអចលនវត្ថុ ត្រូវបានតម្រូវដាច់ដោយឡែកពីគ្នាសម្រាប់គម្រោងសាងសង់នីមួយៗ ។

ប្រការ ១០. ព័ត៌មានលំអិតដែលត្រូវរាប់បញ្ចូលក្នុងការប្រកាស /ការផ្សាយពាណិជ្ជកម្មលក់ ឬ ជួល

រាល់ការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួលដែលធ្វើឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ ត្រូវតែបង្ហាញអំពីព័ត៌មានលំអិតមួយចំនួនដូចជា ÷

(ក) លេខអាជ្ញាប័ណ្ណ និងកាលបរិច្ឆេទសុពលភាពអាជ្ញាប័ណ្ណ

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណ ឬភ្នាក់ងារដែលទទួលសិទ្ធិពីបុគ្គលអភិវឌ្ឍអចលនវត្ថុ ។

(គ) សិទ្ធិជាកម្មសិទ្ធិករលើដី ។ ប្រសិនបើដីនោះជាដីភតិសន្យាត្រូវបង្ហាញពីកាលបរិច្ឆេទផុតកំណត់ និងសំណុំបែបបទ ព្រមទាំងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃការប្រើប្រាស់ដីនោះ ។

(ឃ) ត្រូវរៀបរាប់លំអិតអំពីគោលបំណងនៃការអភិវឌ្ឍអចលនវត្ថុ

(ង) ឈ្មោះគម្រោងអភិវឌ្ឍអចលនវត្ថុ

(ច) កាលបរិច្ឆេទរបស់គម្រោងដែលរំពឹងត្រូវបញ្ចប់

(ឆ) តម្លៃនៃប្រភេទអចលនវត្ថុនីមួយៗដែលត្រូវលក់

(ជ) ចំនួននៃប្រភេទអចលនវត្ថុដែលមាន

(ឈ) ឈ្មោះអាជ្ញាធរមានសមត្ថកិច្ចដែលអនុញ្ញាតលើគម្រោងអភិវឌ្ឍអចលនវត្ថុ និងលេខយោង

(ញ) គំរូប័ណ្ណ សៀវភៅ ឬស្លាកយីហោ និងរូបភាពផ្សាយពាណិជ្ជកម្ម ស្តីអំពីគម្រោងអភិវឌ្ឍអចលនវត្ថុ ព្រមទាំងតម្លៃដែលត្រូវលក់ ដែលត្រូវផ្តល់ជូនអតិថិជន។

ប្រការ ១១ .ការប្រកាស ឬការផ្សាយពាណិជ្ជកម្មលក់ ឬជួល ដែលត្រូវហាមឃាត់

ក្រុមការងារអន្តរក្រសួង ហាមឃាត់រាល់ការប្រកាស/ការផ្សាយពាណិជ្ជកម្មលក់ ឬជួល ទោះបីតាមរយៈរូបភាព ឬជាអក្សរ អ្វីក៏ដោយដែលនាំឱ្យប៉ះពាល់ដល់ ÷

(ក) ព្រះមហាក្សត្រ ឬសមាជិករាជវង្សានុវង្ស

(ខ) ប្រមុខរាជរដ្ឋាភិបាល អភិបាលសាលារាជធានី ខេត្ត ថ្នាក់ដឹកនាំគ្រប់ថ្នាក់ និងមន្ត្រីរាជការគ្រប់ប្រភេទ

(គ)រាល់ព័ត៌មានពាក់ព័ន្ធនឹង ÷

- សមាជិកព្រឹទ្ធសភា និងរដ្ឋសភា
- អគារ និង ទីធ្លាសាធារណៈ
- រាល់កិច្ចការពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាលនៃប្រទេសផ្សេងៗ ឬអង្គការអន្តរជាតិធំៗ ។

ផ្នែកទី ៣

កិច្ចសន្យាទិញ-លក់ ឬជួល

ប្រការ ១២ . ការភ្ជាប់ខ្លួនជាតាគីចុះកិច្ចសន្យាលក់ ឬ ជួលអចលនទ្រព្យ

បុគ្គលអភិវឌ្ឍអចលនវត្ថុណាដែលមិនមែនជាម្ចាស់កម្មសិទ្ធិដីធ្លីសម្រាប់ធ្វើការអភិវឌ្ឍអចលនវត្ថុ គឺមិនអនុញ្ញាតឱ្យចុះកិច្ចសន្យាពាក់ព័ន្ធនឹងការលក់ ឬជួលអចលនវត្ថុក្នុងគម្រោងអភិវឌ្ឍអចលនវត្ថុនោះឡើយ លើកលែងតែម្ចាស់កម្មសិទ្ធិដីធ្លីនោះយល់ព្រមជាលាយលក្ខណ៍អក្សរលើការលក់ ឬជួលដីឱ្យបុគ្គលអភិវឌ្ឍអចលនវត្ថុនោះ ក្នុងគោលបំណងជាក់លាក់អ្វីមួយដូចដែលមានចែងក្នុងកិច្ចសន្យាលក់ ឬជួលទៅតាមនីតិវិធីដែលច្បាប់បានកំណត់ ។

ប្រការ ១៣ .កិច្ចសន្យាទិញ - លក់

រាល់កិច្ចសន្យាទិញ-លក់ ឬជួលអចលនវត្ថុ និងផ្នែកពាក់ព័ន្ធនានានៃសំណង់ដែលជាប់ដី និងមិនជាប់ដី ធ្វើឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុជាមួយនឹងអតិថិជន ត្រូវតែបន្ថែមនូវធាតុចូលមួយចំនួនដូចខាងក្រោម ÷

(ក) ព័ត៌មាននៃកិច្ចសន្យាទិញ-លក់ ឬជួលដី

- ឈ្មោះរបស់អ្នកលក់ ឬជួល និងអតិថិជន ដោយបញ្ជាក់អំពីភេទ ថ្ងៃខែឆ្នាំ កំណើត សញ្ជាតិ អត្តសញ្ញាណប័ណ្ណ និងអាសយដ្ឋានរស់នៅបច្ចុប្បន្ន
- ទីតាំង ទំហំ និងតម្លៃដីដែលបានព្រមព្រៀងគ្នា
- នីតិវិធី និងយន្តការនៃការទូទាត់ថ្លៃទិញ-លក់ ឬជួល
- កិច្ចសន្យាសាងសង់ និងការផ្តល់សេវាគ្រប់គ្រងអគារ
- សិទ្ធិក្នុងការរំលាយកិច្ចសន្យា
- កាតព្វកិច្ចរបស់អ្នកទិញ-អ្នកលក់ ឬគូភាគីក្នុងកិច្ចសន្យាជួល (ដោយរួមទាំងការយឺតយ៉ាវក្នុងការបង់ប្រាក់ និងការពន្យាពេលនៃការសាងសង់)
- សុពលភាពនៃកិច្ចសន្យា

- ប្រសិនបើដីអភិវឌ្ឍអចលនវត្ថុជាដីជួលពីឯកជន បុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវបញ្ជាក់អំពីរយៈពេលដែលអតិថិជនមានសិទ្ធិកាន់កាប់លើអចលនវត្ថុនោះ អំពីថ្ងៃខែចាប់ផ្តើម និងថ្ងៃខែដែលត្រូវបញ្ចប់នៃការជួលដី ។

(ខ) ព័ត៌មាននៃកិច្ចសន្យាទិញ- លក់ ឬជួលផ្ទះ

- ឈ្មោះរបស់អ្នកលក់ ឬអ្នកជួលនិង អតិថិជន ដោយបញ្ជាក់អំពីភេទ ថ្ងៃខែឆ្នាំ កំណើត សញ្ជាតិ អត្តសញ្ញាណប័ណ្ណ និង អាសយដ្ឋានរស់នៅបច្ចុប្បន្ន
- ទីតាំង ទំហំ និងតម្លៃអចលនវត្ថុដែលបានព្រមព្រៀងគ្នា
- ឈ្មោះ ទីតាំង របស់ធនាគារ និងលេខគណនីអភិវឌ្ឍអចលនវត្ថុដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានបើក
- នីតិវិធី និងយន្តការនៃការទូទាត់ថ្លៃទិញ- លក់ ឬជួល
- សិទ្ធិក្នុងការលុបចោលកិច្ចសន្យា
- កាតព្វកិច្ចរបស់អ្នកទិញ អ្នកលក់ ឬគ្នាគីក្នុងកិច្ចសន្យាជួល
- ការធានានូវគុណភាព និងសុវត្ថិភាពសំណង់
- សុពលភាពនៃកិច្ចសន្យា

- ប្រសិនបើដីអភិវឌ្ឍអចលនវត្ថុជាដីសម្បទាន ឬដីជួលពីរដ្ឋ បុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវបញ្ជាក់អំពីរយៈពេលដែលអតិថិជនមានសិទ្ធិកាន់កាប់លើអចលនវត្ថុនោះ អំពីថ្ងៃខែចាប់ផ្តើម និងថ្ងៃខែ ដែលត្រូវបញ្ចប់នូវសិទ្ធិសម្បទាន ឬសិទ្ធិជួលដីនោះ។

ផ្នែកទី ៤

គណនីអភិវឌ្ឍអចលនវត្ថុ

ប្រការ ១៤ .កាតព្វកិច្ចរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុពាក់ព័ន្ធទៅនឹងគណនីអភិវឌ្ឍអចលនវត្ថុ

បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ដែលស្នើសុំអាជ្ញាប័ណ្ណពីក្រុមការងារអន្តរក្រសួងត្រូវមានកាតព្វកិច្ចដូចខាងក្រោម ÷

(ក)មុនពេលដាក់ពាក្យសុំអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ បុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវបើកគណនីអភិវឌ្ឍអចលនវត្ថុរបស់ខ្លួននៅធនាគារពាណិជ្ជណាមួយនៅព្រះរាជាណាចក្រកម្ពុជា ។

(ខ)ក្នុងរយៈពេល ១៤ ថ្ងៃក្រោយពីធ្វើវិញ្ញត្តិ(ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរដោយអតិថិជន) អតិថិជនត្រូវផ្តល់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផ្តល់ហិរញ្ញប្បទានដល់ខ្លួននៅអោយបុគ្គលអភិវឌ្ឍអចលនវត្ថុ ហើយបុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវជូនព័ត៌មាននៅអ្នកផ្តល់ហិរញ្ញប្បទានរបស់អតិថិជននូវឈ្មោះ និងអាសយដ្ឋានរបស់ធនាគារ និងលេខគណនីដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានបើក ។

ប្រការ ១៥ .ការតំកល់ប្រាក់ធានា

មុនពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ បុគ្គលអភិវឌ្ឍអចលនវត្ថុប្រភេទទី ៣ ត្រូវតំកល់ប្រាក់ធានាចំនួន ២% (ពីរភាគរយ) នៃតម្លៃគម្រោងវិនិយោគសរុប ឬគម្រោងវិនិយោគតាមដំណាក់កាលនីមួយៗតាមវិធីសាស្ត្រណាមួយដូចខាងក្រោម ÷

(ក) ជាសាច់ប្រាក់សុទ្ធនៅក្នុងគណនីប្រាក់តំកល់របស់ក្រុមការងារអន្តរក្រសួង

(ខ) ប័ណ្ណ ឬលិខិតធានាពីធនាគារពាណិជ្ជក្នុងស្រុកណាមួយដែលមានតម្លៃស្មើទឹកប្រាក់ខាងលើ ។

ប្រាក់តំកល់ធានាខាងលើនេះមិនអាចដកយកទេវិញបានទេ លុះត្រាតែបុគ្គលអភិវឌ្ឍអចលនវត្ថុបានបញ្ចប់គម្រោងរបស់ខ្លួនជាស្ថាពរ ឬដើម្បីដោះស្រាយសាធនភាពរបស់ខ្លួនតាមការវាយតម្លៃរបស់ក្រុមការងារអន្តរក្រសួង ។ បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតបិទការដ្ឋានពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ប្រាក់ធានាខាងលើនេះ អាចដកយកទេវិញបានក្នុងរយៈពេល ៧ ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានដាក់ពាក្យសុំដកប្រាក់ធានា ។

ប្រការ ១៦ .ប្រាក់កក់គ្រប់ប្រភេទរបស់អតិថិជន

ប្រាក់កក់ ឬប្រាក់ត្រូវបង់តាមដំណាក់កាលទាំងអស់របស់អតិថិជន ត្រូវបង់ដោយផ្ទាល់ទៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុដូចមានចែងក្នុងកិច្ចសន្យាទិញ-លក់ ឬជួលអចលនវត្ថុ។

ប្រការ ១៧ .ការបង់ប្រាក់ទៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុរបស់អ្នកផ្តល់ហិរញ្ញប្បទាន

ក្នុងរយៈពេល ៧ ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីទទួលបានវិក្កយបត្រស្នើសុំឱ្យបង់ប្រាក់ពីបុគ្គលអភិវឌ្ឍអចលនវត្ថុទៅតាមភាគរយនៃសំណង់ដែលបានសាងសង់រួច អ្នកផ្តល់ហិរញ្ញប្បទានឱ្យអតិថិជនត្រូវបង់ប្រាក់នោះដោយផ្ទាល់ទៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ ដោយភ្ជាប់មកវិញនូវរបាយការណ៍នៃការបង់ប្រាក់នោះជូនទៅបុគ្គលអភិវឌ្ឍអចលនវត្ថុ និងទៅអ្នកទិញ ឬអ្នកជួលដើម្បីបញ្ជាក់ថាការទូទាត់បានធ្វើរួចហើយ ។

ប្រការ ១៨ .ការរក្សាប្រាក់កម្ចី

បុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវរក្សាប្រាក់កម្ចីគ្រប់ប្រភេទដែលខ្លួនទទួលបានហិរញ្ញប្បទានពីប្រភពផ្សេងៗនៅក្នុងគណនីគម្រោងអភិវឌ្ឍអចលនវត្ថុ ដែលបើក និងថែរក្សាដោយឡែកដោយបុគ្គលអភិវឌ្ឍអចលនវត្ថុនៅធនាគារពាណិជ្ជនៅកម្ពុជា ដើម្បីបំពេញការសាងសង់របស់គម្រោងនោះតែមួយគត់ ។ គណនីគម្រោងអភិវឌ្ឍអចលនវត្ថុនេះ មិនស្ថិតនៅក្រោមការត្រួតពិនិត្យដោយក្រុមការងារអន្តរក្រសួងឡើយ ។

ប្រការ ១៩ .គោលបំណងនៃការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុ

គ្មានប្រាក់ចំណែកណាមួយនៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុត្រូវបានអនុញ្ញាតឱ្យដកឡើយ រហូតដល់ការសាងសង់បានចប់សព្វគ្រប់ លុះត្រាតែការដកនោះសម្រាប់គោលបំណងនៃការចំណាយដូចខាងក្រោម ÷

(ក) បង់ពន្ធប្រថាប់ត្រា និងពន្ធផ្សេងៗ តាមច្បាប់សារពើពន្ធ ការចំណាយនានាដែលស្ថិតក្នុងគម្រោង និងការវាយតំលៃដីដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបាន និងកំពុងអភិវឌ្ឍ ។

(ខ) ឈ្នួលផ្ទះ ការបង់ការប្រាក់ និងថ្លៃចំណាយផ្សេងៗឱ្យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានខ្ចីសម្រាប់អភិវឌ្ឍអចលនវត្ថុ ។

(គ) សងរំលោះដើមទុនមួយផ្នែក ឬទាំងអស់រហូតទាល់តែអស់រួចរាល់នូវប្រាក់ដែលបានខ្ចីសម្រាប់អភិវឌ្ឍអចលនវត្ថុទៅតាមសមាមាត្រនៃអចលនវត្ថុដែលបានអភិវឌ្ឍ និងបានលក់រួចរាល់ ។

(ឃ) សងថ្លៃដីដែលទិញដោយមិនប្រើប្រាក់កម្ចីសម្រាប់ធ្វើការអភិវឌ្ឍទៅតាមចំនួនទឹកប្រាក់ដូចខាងក្រោម ÷

- ទឹកប្រាក់ស្មើនឹង ១០ % នៃថ្លៃទិញតាមកិច្ចសន្យាទិញ- លក់អចលនវត្ថុនៅពេលដែលអតិថិជនបានបង់ជូនទៅបុគ្គលអភិវឌ្ឍអចលនវត្ថុតាមកិច្ចសន្យាទិញ- លក់អចលនវត្ថុបានចំនួនទឹកប្រាក់ ៥៥ % ហើយ

- បុគ្គលអភិវឌ្ឍអចលនវត្ថុអាចដកទឹកប្រាក់ចំនួន ១០% បន្ថែមទៀត ក្នុងករណីដែលអតិថិជនបានបង់ជូនខ្លួន ៦៥ % ។ ការដកប្រាក់សម្រាប់ចំណាយនេះ ត្រូវតែសមាមាត្រទៅតាមចំនួនអចលនវត្ថុដែលបានលក់ ។

- លក្ខខណ្ឌនៃវិធានលើការសងថ្លៃដីខាងលើនេះ ត្រូវបានយកមកអនុវត្តសម្រាប់ការដកលើកទី៣ និង ការដកបន្តបន្ទាប់ទៀត ។

(ង) ការបង់សងវិញ ឬការទូទាត់សងរំលោះ ដោយផ្អែកទៅតាមកិច្ចសន្យាទិញ- លក់ដែលធ្វើឡើងរវាងបុគ្គលអភិវឌ្ឍអចលនវត្ថុជាមួយនឹងអតិថិជន ។

(ច) សេវាផ្នែកច្បាប់ផ្សេងៗដូចជា ÷

- បទប្បញ្ញត្តិចានាប្រាក់កក់ដើម្បីការពារសុវត្ថិភាពប្រាក់កម្ចីសម្រាប់ការអភិវឌ្ឍអចលនវត្ថុ
- បទប្បញ្ញត្តិផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍអចលនវត្ថុ ។

(ឆ) បុព្វលាភធានារ៉ាប់រង (ប្រាក់តំកល់ធានារ៉ាប់រង) ថ្លៃស្ថាបត្យករ វិស្វករ និងថ្លៃពិគ្រោះយោបល់ដែលពាក់ព័ន្ធដល់ការអភិវឌ្ឍអចលនវត្ថុ ។

(ជ) ការងារផ្សេងៗមានជាអាទិ ÷

- ការសិក្សាពិសោធដី
- ការងាររៀបចំការដ្ឋាន
- ការងារគ្រឹះ

- ការងារសាងសង់អគារ
- ការងារខាងក្រៅអគារ
- ការងារការដ្ឋាន និងព្រំប្រទល់ផ្ទះល្វែងនីមួយៗ
- ការងារហេដ្ឋារចនាសម្ព័ន្ធ
- ការដោះស្រាយលើផលប៉ះពាល់ផ្សេងៗ
- កិច្ចការផ្សេងៗដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍអចលនវត្ថុទៅតាមការកំណត់ដូចមានចែងក្នុងអាជ្ញាប័ណ្ណដែលផ្តល់ជូនដោយក្រុមការងារអន្តរក្រសួង ។

(ឈ) ការប្រើប្រាស់ទឹក ភ្លើងអគ្គិសនី និងការតបណ្តាញទឹក ភ្លើងអគ្គិសនីចូលតំបន់អភិវឌ្ឍអចលនវត្ថុ

(ញ) ការទូទាត់ចំណាយស្របច្បាប់ផ្សេងៗដែលទាក់ទងទៅនឹងស្ថាប័នពាក់ព័ន្ធការអភិវឌ្ឍអចលនវត្ថុ។

(ដ) ការធានាប្រាក់កក់ដើម្បីការពារសុវត្ថិភាពប្រាក់កម្ចីសម្រាប់ការអភិវឌ្ឍអចលនវត្ថុ ។

(ឋ) ការងាររដ្ឋបាលផ្សេងៗសម្រាប់ការអភិវឌ្ឍអចលនវត្ថុ តែការចំណាយនេះអាចដកបានតែ ១០ % នៃតម្លៃគម្រោងស្មើសុំតាមដំណាក់កាលប៉ុណ្ណោះ លុះត្រាតែមានការបញ្ជាក់ពីស្ថាបត្យករ ឬវិស្វករដែលទទួលបន្ទុកមើលការខុសត្រូវលើការអភិវឌ្ឍអចលនវត្ថុនោះ ហើយត្រូវគោរពទៅតាមគោលការណ៍នៃការទូទាត់តាមដំណាក់កាលនីមួយៗ ។

(ឌ) ការចុះត្រួតពិនិត្យបុគ្គលអភិវឌ្ឍអចលនវត្ថុរបស់ក្រុមការងារអន្តរក្រសួងទៅតាមការចាំបាច់

(ឍ) ការទូទាត់សងការខូចខាតផ្សេងៗពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ ។

(ណ) សេវាកម្មកម្រៃជើងសាររបស់បុគ្គលជួញដូរអចលនវត្ថុដែលអតិបរមានៃកម្រៃជើងសារ ៥%

(ត) សម្រាប់មូលហេតុត្រឹមត្រូវផ្សេងៗ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមការងារអន្តរក្រសួង និងដោយគោរពតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានបើកគណនីអភិវឌ្ឍអចលនវត្ថុ ។

រាល់ការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុដូចមានចែងក្នុងប្រការនេះ ត្រូវសមាមាត្រនឹងទំហំសំណង់ដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានអនុវត្តជាក់ស្តែង ។

ប្រការ ២០ .លក្ខន្តិកៈនៃការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុ

រាល់ពេលដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុត្រូវមានលិខិតធានា ឬឯកសារបញ្ជាក់អំពីលទ្ធផលនៃគម្រោងអភិវឌ្ឍអចលនវត្ថុនេះពីវិស្វករឯករាជ្យដែលមានវិញ្ញាបនប័ត្របញ្ជាក់ទទួលស្គាល់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានអាជ្ញាប័ណ្ណប្រកបអាជីវកម្មជាវិស្វករឯករាជ្យពីក្រុមការងារអន្តរក្រសួង ។ បុគ្គលអភិវឌ្ឍអចលនវត្ថុអាចជ្រើសរើសវិស្វករឯករាជ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចបានរៀបរាប់ជូនខាងលើដោយខ្លួនឯង ។

ឯកសារបញ្ជាក់របស់វិស្វករឯករាជ្យនេះ ត្រូវបញ្ជូនទៅឱ្យធនាគារពាណិជ្ជណាមួយ ដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានបើកគណនីអភិវឌ្ឍអចលនវត្ថុរបស់ខ្លួននៅទីនោះ ដើម្បីស្នើសុំដកប្រាក់ទៅតាមសមាមាត្រដែលបុគ្គលអភិវឌ្ឍអចលនវត្ថុធ្វើបាន ។ ក្រោយពីបើកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុហើយ បុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវផ្តល់ឯកសារបើកប្រាក់នេះមកក្រុមការងារអន្តរក្រសួងដើម្បីជ្រាបជារបាយការណ៍ និងរក្សាទុកជាឯកសារ ។ ប្រសិនបើមានការសង្ស័យក្រុមការងារអន្តរក្រសួងមានសិទ្ធិចុះត្រួតពិនិត្យដល់ទីកន្លែង ។

ក្នុងករណីពិនិត្យឃើញថា បុគ្គលអភិវឌ្ឍអចលនវត្ថុបានអនុវត្តត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាសនេះ ហើយការស្នើសុំដកប្រាក់សមាមាត្រទៅនឹងទំហំការងារដែលធ្វើបាន ដូច្នេះវិស្វករឯករាជ្យត្រូវចេញឯកសារបញ្ជាក់ជូនបុគ្គលអភិវឌ្ឍអចលនវត្ថុ ក្នុងរយៈពេល ២ ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ដោយគិតចាប់ពីថ្ងៃចុះត្រួតពិនិត្យ ដើម្បីអោយបុគ្គលអភិវឌ្ឍអចលនវត្ថុនោះអាចយកឯកសារទៅស្នើសុំដកប្រាក់ពីធនាគារ។

ផ្នែកទី ៥

ក្រុមការងារអន្តរក្រសួង

ប្រការ ២១ .តួនាទី តារកិច្ច របស់ក្រុមការងារអន្តរក្រសួង

ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

(ក)រៀបចំតាក់តែងគោលនយោបាយអភិវឌ្ឍន៍ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងផ្តល់អាជ្ញាប័ណ្ណដល់បុគ្គលអភិវឌ្ឍអចលនវត្ថុ ។

(ខ)ចុះពិនិត្យជាក់ស្តែងដល់ទីកន្លែងអភិវឌ្ឍន៍អចលនវត្ថុទៅតាមការចាំបាច់ក្នុងការគ្រប់គ្រងវិស័យនេះ

(គ)ផ្តល់អាជ្ញាប័ណ្ណដល់បុគ្គលអភិវឌ្ឍអលនវត្ថុ ។

(ឃ)ពិនិត្យ និងផ្តល់ការអនុញ្ញាតផ្សាយពាណិជ្ជកម្ម និងការប្រកាសលក់ ។

(ង)តាមដាន និងត្រួតពិនិត្យគណនីអភិវឌ្ឍអចលនវត្ថុ ។

(ច)ដាក់ទណ្ឌកម្មរដ្ឋបាលចំពោះអ្នកមិនគោរពលក្ខខណ្ឌតម្រូវនានា ។

(ឆ)ធ្វើរបាយការណ៍ប្រចាំឆមាសអំពីការអភិវឌ្ឍវិស័យអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជាជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយចំលងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងមហាផ្ទៃ ។

(ជ)ការងារផ្សេងៗទៀតពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការត្រួតពិនិត្យការអភិវឌ្ឍអចលនវត្ថុតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

ប្រការ ២២ .ការត្រួតពិនិត្យ

ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុមានសិទ្ធិដូចខាងក្រោម ÷

(ក)ប្រធានក្រុមការងារអន្តរក្រសួងអាចចាត់មន្ត្រីជំនាញរបស់ខ្លួនដើម្បីចុះត្រួតពិនិត្យដល់ទីកន្លែងលើឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មអភិវឌ្ឍអចលនវត្ថុបានគ្រប់ពេលវេលា ។ បុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីជំនាញរបស់ក្រុមការងារអន្តរក្រសួងក្នុងការពិនិត្យបញ្ជីស្តាម និងឯកសារផ្សេងៗ ។

(ខ)ក្នុងករណីចាំបាច់ប្រធានក្រុមការងារមានសិទ្ធិជួលអ្នកឯកទេសផ្នែកគណនេយ្យ និងសវនកម្មឱ្យចូលរួមក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងមានសិទ្ធិថតចម្លងនូវឯកសារផ្សេងៗតាមតម្រូវការដើម្បីត្រួតពិនិត្យ ចំពោះការចំណាយលើអ្នកឯកទេសផ្នែកគណនេយ្យ និងសវនកម្មនេះ ជាបន្ទុករបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ ។

(គ)ក្នុងករណីរកឃើញថា បុគ្គលអភិវឌ្ឍអចលនវត្ថុបានធ្វើឱ្យខូចផលប្រយោជន៍របស់អតិថិជន ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ប្រាក់ដែលមាននៅក្នុងគណនីអភិវឌ្ឍអចលនវត្ថុ ដើម្បីបន្តការអភិវឌ្ឍឱ្យបានចប់ជាស្ថាពរ ។

ផ្នែកទី ៦
របាយការណ៍

ប្រការ ២៣ .របាយការណ៍ប្រចាំត្រីមាស

បុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវផ្តល់របាយការណ៍ស្តីពីការអភិវឌ្ឍអចលនវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសមកក្រុមការងារអន្តរក្រសួងឱ្យបានមុនថ្ងៃទី ១៥ នៃខែទី ១ ត្រីមាសបន្ទាប់ និងត្រូវបញ្ជាក់ថា ពិត និងត្រឹមត្រូវ ។

ចំពោះរបាយការណ៍ដែលពាក់ព័ន្ធនឹងការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុ ត្រូវតែបញ្ជាក់ថារាល់ការដកប្រាក់ធ្វើឡើងដោយស្របទៅតាមការណែនាំដែលមានចែងក្នុងប្រកាសនេះ ។

ប្រការ ២៤ .របាយការណ៍បញ្ចប់គម្រោង ឬរបាយការណ៍ប្រចាំឆ្នាំ

ក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយពីបញ្ចប់គម្រោងអភិវឌ្ឍអចលនវត្ថុ ឬចុងឆ្នាំនៃគម្រោងនីមួយៗបុគ្គលអភិវឌ្ឍអចលនវត្ថុត្រូវផ្តល់ឱ្យក្រុមការងារអន្តរក្រសួងនូវរបាយការណ៍ស្តីពីការអភិវឌ្ឍអចលនវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុនៃគម្រោង ឬឆ្នាំសារពើពន្ធកន្លងមកដែលត្រូវបានត្រួតពិនិត្យដោយស្នងការគណនេយ្យឯករាជ្យណាមួយដែលមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្នែកទី ៧

ធនធានមនុស្ស

ប្រការ ២៥ .ការពិន័យវិន័យ

បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងឡាយណាដែលល្មើសទៅនឹងបទប្បញ្ញត្តិ និងលក្ខខណ្ឌនានាដែលមាន ចែងក្នុងប្រកាសនេះ នឹងត្រូវទទួលទណ្ឌកម្មដូចជា ការព្យួរអាជ្ញាប័ណ្ណ ឬ ការដកហូតអាជ្ញាប័ណ្ណ ឬ/និង ទទួលការផាកពិន័យទៅតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្តឹងទៅតុលាការអនុវត្តទណ្ឌកម្មទៅតាមច្បាប់ជាធរមាន ។

ផ្នែកទី ៨

សិទ្ធិប្តឹងតវ៉ារបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ

ប្រការ ២៦ .សិទ្ធិប្តឹងតវ៉ា

ក្នុងករណីបុគ្គលអភិវឌ្ឍអចលនវត្ថុ មិនយល់ស្របចំពោះការសម្រេចណាមួយរបស់ក្រុមការងារអន្តរក្រសួង បុគ្គលអភិវឌ្ឍអចលនវត្ថុមានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងរយៈពេល ១៤ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចនោះ។

ជំពូកទី ៣

អន្តរប្បញ្ញត្តិ

ប្រការ ២៧ .ទិដ្ឋានអន្តរកាល

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលបានប្រកបអាជីវកម្មកន្លងមកដោយគ្មានអាជ្ញាប័ណ្ណពីក្រុមការងារអន្តរក្រសួងនៅតែអាចប្រកបអាជីវកម្មរបស់ខ្លួនបានដដែល ប៉ុន្តែក្រោយពីប្រកាសនេះចូលជាធរមានបុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ត្រូវតែគោរពទៅតាមលក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ ។

បទប្បញ្ញត្តិនេះមិនមានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាទិញ- លក់ឬការប្រកាសលក់/ការផ្សាយពាណិជ្ជកម្មអចលនវត្ថុដែលបានធ្វើឡើងនៅមុនពេលដែលប្រកាសនេះចូលជាធរមាននោះឡើយ ។

ចំពោះបុគ្គលអភិវឌ្ឍអចលនវត្ថុដែលកន្លងមកមានបំណុលពន្ធ ឬកខ្វានមិនបានបំពេញកាតព្វកិច្ចសារពើពន្ធត្រូវចូលខ្លួនមកដោះស្រាយនៅអគ្គនាយកដ្ឋានពន្ធដារ ។ ក្រុមការងារអន្តរក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណជូនបុគ្គលអភិវឌ្ឍអចលនវត្ថុបាន លុះត្រាតែមានលិខិតបញ្ជាក់ពីអគ្គនាយកដ្ឋានពន្ធដារពីការបំពេញកាតព្វកិច្ចសារពើពន្ធរួចហើយ ។

ជំពូក ទី ៤

អនុសាសនប្បញ្ញត្តិ

ប្រការ ២៨ .និរាករណ៍

ប្រកាសលេខ ៥៤៨ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណសម្រាប់បុគ្គលអភិវឌ្ឍអចលនវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ២៩ .ការអនុវត្តប្រកាស

ក្រុមការងារអន្តរក្រសួង អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយក ខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធដ៏ទៃទៀតក្រោមឱវាទក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងបុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុង ការអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទួបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាម ឃន់

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី-ខេត្ត

«ដើម្បីជូនជ្រាប និងសហការអនុវត្ត»

- ដូចមានក្នុងប្រការ ២៩

«ដើម្បីអនុវត្ត»

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសរួម
ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត

ឆ្នាំ ២០០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម
និងសំណង់
លេខ : ១២៧ ប្រក.មជ.ដនស

ប្រកាសរួម
ស្តីពី
ការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត

ឯកឧត្តមអគ្គបណ្ឌិត រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង
ឯកឧត្តម រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ... ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែល ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ...

ប្រការ១ .-

ប្រកាសនេះ មានគោលដៅពង្រឹងការអនុវត្តបទប្បញ្ញត្តិទាក់ទង ដែលទាក់ទងទៅនឹងវិស័យសំណង់ ដើម្បីបង្កើនសោភ័ណភាព គុណភាព សុវត្ថិភាពសំណង់ ធានាបរិស្ថានល្អ និង ទប់ស្កាត់ការសាងសង់ គ្មានលិខិតអនុញ្ញាតសាងសង់ ការសាងសង់ខុសពីលិខិតអនុញ្ញាត គ្មានលិខិតអនុញ្ញាតប៉ែកការដ្ឋាន គ្មានលិខិតអនុញ្ញាតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ការរុះរើ និងជួសជុល ដោយគ្មានលិខិតអនុញ្ញាត និងការជួសជុលខុសពីលិខិតអនុញ្ញាត។

ប្រការ២ .-

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានភោជនីយដ្ឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរព្រះរាជាណាចក្រ ខេត្ត ត្រូវសហការគ្នាដើម្បីធ្វើការណែនាំ និងផ្សព្វផ្សាយច្បាប់ អនុក្រឹត្យ ប្រកាស ប្រកាសរួម លិខិតបទដ្ឋាន និងឯកសារគតិយុត្តនានា ដែលពាក់ព័ន្ធ ទៅនឹងការគ្រប់គ្រងសំណង់គ្រប់ប្រភេទដល់ស្ថាប័ន អង្គភាព អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អ្នកវិនិយោគទុន និងសាធារណជន ឱ្យបានទូលំទូលាយ ដើម្បីចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

ប្រការ៣ .-

មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត មានភារកិច្ចដូចតទៅ :

១-ទទួលខុសត្រូវតាមដានការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការសាងសង់ និងឯកសារបច្ចេកទេសនានា នៅគ្រប់ការដ្ឋានសំណង់ទាំងអស់ក្នុងភូមិសាស្ត្ររបស់ខ្លួន

២-ចុះត្រួតពិនិត្យគ្រប់ការដ្ឋានសំណង់ជាប្រចាំ ទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយក្រសួង ទាំងសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយសាលារាជធានី ខេត្ត

៣-ក្នុងករណីពិនិត្យឃើញថា មានសំណង់មិនប្រក្រតីមន្ទីរត្រូវ :

-រាយការណ៍ជាបន្ទាន់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមគ្រប់រូបភាព ដើម្បីក្រសួងមានមូលដ្ឋានក្នុងការចេញលិខិតផ្អាកការដ្ឋានសំណង់ និងមានវិធានការតាមច្បាប់ក្នុងករណីពិនិត្យឃើញថា ការដ្ឋានសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយក្រសួង អនុវត្តខុសពីបទប្បញ្ញត្តិបច្ចេកទេស និងចម្លងសេចក្តីរាយការណ៍ខាងលើនេះមួយច្បាប់ជូនសាលារាជធានី ខេត្ត ដើម្បីជ្រាបជារបាយការណ៍

-រាយការណ៍ជាបន្ទាន់មកសាលារាជធានី ខេត្ត តាមគ្រប់រូបភាពដើម្បីសាលារាជធានី ខេត្ត ធ្វើវិធានការតាមច្បាប់ក្នុងករណីពិនិត្យឃើញថា ការដ្ឋានសំណង់ដែលជាសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដោយសាលារាជធានី ខេត្ត អនុវត្តខុសពីបទប្បញ្ញត្តិបច្ចេកទេស និងចម្លងសេចក្តីរាយការណ៍ខាងលើនេះមួយច្បាប់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីជ្រាបជារបាយការណ៍។

ប្រការ៤ .-

អាជ្ញាធររាជធានី-ខេត្ត មានភារកិច្ចដូចតទៅ :

- រក្សាសណ្តាប់ធ្នាប់សាធារណៈ នៅគ្រប់ការដ្ឋានសំណង់
- ចូលរួមទប់ស្កាត់ការសាងសង់ ការរុះរើ ជួសជុលគ្មានលិខិតអនុញ្ញាត ឬការសាងសង់ ការរុះរើ ជួសជុលខុសពីលិខិតអនុញ្ញាតតាមការស្នើសុំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត។

ប្រការ៥ .-

ការផ្តល់លិខិតអនុញ្ញាតសាងសង់ និងជួសជុលសំណង់ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអាជ្ញាធររាជធានី-ខេត្ត ស្របតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

ប្រការ៦ .-

អគ្គនាយកដ្ឋានជំនាញ នៃក្រសួងទាំងពីរ និងអាជ្ញាធររាជធានី-ខេត្ត ត្រូវទទួលខុសត្រូវតាមដាន ត្រួតពិនិត្យ និងសហការឱ្យបានល្អ ដើម្បីអនុវត្តប្រកាសអន្តរក្រសួងនេះ ដោយភាពឱ្យមានប្រសិទ្ធភាព។

ប្រការ៧ .-

អគ្គលេខាធិការ. នៃអគ្គលេខាធិការដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ អភិបាលរាជធានី-ខេត្ត អគ្គនាយក នៃអគ្គនាយកដ្ឋានជំនាញ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និងប្រធានមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យលោកជំទាវបណ្ឌិតសភាចារ្យ នាយករដ្ឋមន្ត្រី ម៉ែន សំអន
- ខុទ្ទកាល័យសម្តេចវិបុលសេនាភក្តី នាយករដ្ឋមន្ត្រី ប៊ិន ឈិន
- ដើម្បីចាត់ដាក់
- ដើម្បីជ្រាបនិង
- ដើម្បីអនុវត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីការកែសម្រួលប្រការ២ និង ប្រការ៣ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

ឆ្នាំ ២០០៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ..៤៧៣.....ប្រក.ដនស/អសណ

ប្រកាស

ស្តីពី

ការកែសំរួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ ៣២ប្រក/សណ

ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់



ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីការការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៨/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីកដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

-យោងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

-យោងតាមការចាំបាច់របស់ក្រសួង

<u>សេចក្តីប្រកាស</u>

ប្រការ ១.-

ត្រូវបានកែសំរួលប្រការ ២ និងប្រការ ៣ នៃប្រកាសលេខ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ដូចខាងក្រោម :

<u>ប្រការ២(ថ្មី)</u>: អាចផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់បានចំពោះតែម្ចាស់សំណង់ណា ដែលមានលិខិតអនុញ្ញាតសាងសង់ ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី-ខេត្ត ។

<u>ប្រការ៣(ថ្មី)</u> : ការដ្ឋាននីមួយៗអាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។ លិខិតអនុញ្ញាតបើកការដ្ឋាន ត្រូវសុំនៅអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ស្របតាមសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ។ សំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានរួមមាន :

១-សំណុំឯកសារពាក្យសុំរបស់ម្ចាស់សំណង់ ។

២-លិខិតអនុញ្ញាតសាងសង់ ។

៣-បួងស្តាបត្យកម្មដែលបានអនុញ្ញាត ។

៤-បួងគ្រឿងផ្គុំសំណង់ ។

ប្រការ ២.-

បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ស្នើ ឈុនលីម

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលារាជធានី-ខេត្ត
-ដូចប្រការ៣
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុន វិស្វកម្មឯករាជ្យ សម្រាប់គ្រប់គ្រង អាជីវកម្មអភិវឌ្ឍអចលនវត្ថុ

ឆ្នាំ ២០១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ២០៤ សហវ/២០១៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

ប្រកាស
ស្តីពី
ការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនទិស្សកម្មឯករាជ្យ សម្រាប់គ្រប់គ្រងអាជីវកម្មអតិថិជនវត្ត

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់សារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើវិសោធនកម្មច្បាប់នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែមនិងការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ អនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារនិង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១២៦ អនក្រ/បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ អគារសហកម្មសិទ្ធិ
- បានឃើញ អនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧
- បានឃើញ ប្រកាសលេខ ២១៦ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ១៤៩៧ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ១២២២ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ
- បានឃើញ ប្រកាសលេខ ០៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្តង់ និងសាងសង់
- បានឃើញ ប្រកាសលេខ ០៣៥ ប្រក.ដនស/អសណ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលប្រការ ៦ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្តង់
- បានឃើញ ប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្តង់
- យោងការចាំបាច់ក្នុងការគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុ ។

សម្រួច

ប្រការ ១: - គោលបំណង

ក្នុងគោលបំណងឈានទៅរកគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងប្រកាសលេខ ១២២២ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រេចចេញប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនវិស្វកម្មឯករាជ្យសម្រាប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលមានខ្លឹមសារដូចតទៅ ÷

ប្រការ២: - ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

វិស្វករសំណង់អគារដែលបញ្ចប់ការសិក្សា និងបានឆ្លងកាត់បទពិសោធន៍ការងារជាក់ស្តែងក្នុងមុខជំនាញដែលមានវិញ្ញាបនប័ត្រអាជីវកម្មសាងសង់ ឬសិក្សាគម្រោងប្លង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសមាជិកគណៈវិស្វករកម្ពុជាដែលមានការទទួលស្គាល់ និងមានការយល់ព្រមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបសេវាកម្មជាក្រុមហ៊ុនវិស្វកម្មឯករាជ្យទៅតាមទម្រង់ដែលបានរៀបចំដោយក្រុមការងារអន្តរក្រសួង នៅលេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលមានទីតាំងនៅការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ៣: - ថ្លៃអាជ្ញាប័ណ្ណ

អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបសេវាកម្មជាក្រុមហ៊ុនវិស្វកម្មឯករាជ្យ ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណចំនួន ២.000.000៛ (ពីរលានរៀល)។

ថ្លៃអាជ្ញាប័ណ្ណត្រូវបង់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ តាមដីកាអមរបស់ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ។

ប្រការ៤: - សុពលភាពអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាប័ណ្ណឱ្យបាន ៣០ ថ្ងៃ មុនពេលអាជ្ញាប័ណ្ណនោះអស់សុពលភាព និងត្រូវបង់ថ្លៃបន្តដូចការស្នើសុំលើកដំបូងដែរ ។

ក្រុមការងារអន្តរក្រសួងមានសិទ្ធិបន្តអាជ្ញាប័ណ្ណ ដោយមានដាក់ ឬមិនមានដាក់លក្ខខណ្ឌ ឬ មិនបន្តអាជ្ញាប័ណ្ណជូន ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវណាមួយដែលក្រុមការងារអន្តរក្រសួងបានកំណត់ ។

ប្រការ៥: - ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ

ក្រុមការងារអន្តរក្រសួងមានសិទ្ធិព្យួរ ឬដកហូតអាជ្ញាប័ណ្ណ នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណមិនបានគោរពទៅតាមលក្ខខណ្ឌណាមួយដូចមានចែងនៅក្នុងប្រកាសនេះ ឬមានចែងនៅក្នុងវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់វិស្វករឯករាជ្យ ។

ក្នុងករណីព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ក្រុមការងារអន្តរក្រសួងនឹងចេញលិខិតជាលាយលក្ខណ៍អក្សរស្តីពីការព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណដោយបញ្ជាក់ពីមូលហេតុនៃការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណនោះ ។

បន្ទាប់ពីការព្យួរ ឬដកហូតអាជ្ញាប័ណ្ណហើយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបញ្ឈប់ជាបន្ទាន់នូវការផ្តល់សេវាកម្មជាវិស្វករឯករាជ្យតទៅទៀត រហូតដល់មានការសម្រេចជាថ្មីពីក្រុមការងារអន្តរក្រសួង ទើបអាចបន្តសេវាកម្មរបស់ខ្លួនបាន ។

ប្រការ៦: - កាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ

បន្ថែមពីលើការគោរពទៅតាមវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់វិស្វករ ឯករាជ្យ អ្នកកាន់អាជ្ញាប័ណ្ណត្រូវមានកាតព្វកិច្ចដូចតទៅ ÷

- ត្រូវអនុវត្តការងាររបស់ខ្លួនឱ្យបានហ្មត់ចត់ និងច្បាស់លាស់មុននឹងចេញលិខិតធានា ឬឯកសារបញ្ជាក់អំពីភាពពេញលេញនៃគំរោងអភិវឌ្ឍអចលនវត្ថុ របស់បុគ្គលអភិវឌ្ឍអចលនវត្ថុដែលខ្លួនទទួលខុសត្រូវ ដើម្បីស្នើសុំដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុទៅតាមសមាមាត្រដែលបុគ្គលអភិវឌ្ឍអចលនវត្ថុធ្វើបាន
- ត្រូវរក្សាឯកសារវាយតម្លៃសម្រាប់ធ្វើជាភស្តុតាងក្នុងការស៊ើបអង្កេត និងសម្រាប់តម្រូវការផ្សេងៗទៀតតាមស្ថានភាពជាក់ស្តែង
- ត្រូវទទួលខុសត្រូវទាំងស្រុងទៅលើកិច្ចការ និងរបាយការណ៍ដែលខ្លួនបានធ្វើ
- ត្រូវផ្តល់សេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- ត្រូវប្រកាន់ឯករាជ្យភាព និងមិនលំអៀងក្នុងការអនុវត្តកាតព្វកិច្ចវិជ្ជាជីវៈ
- មិនត្រូវទទួលធ្វើការងារណាដែលមិនស្ថិតនៅក្នុងសមត្ថភាពវិជ្ជាជីវៈ ឬដែលខ្លួនមិនយល់ដឹងនោះឡើយ
- មិនត្រូវធ្វើការបញ្ជាក់ទៅលើការងារណាដែលខ្លួនមិនបានធ្វើ ឬដែលខ្លួនមិនបានត្រួតពិនិត្យនោះឡើយ

- មិនត្រូវទទួលការងារពីអតិថិជនឡើយក្នុងករណីដែលខ្លួនមិនអាចបំពេញការងារតាមពេលកំណត់បាន
- ត្រូវធ្វើវិញ្ញត្តិដល់ក្រុមការងារអន្តរក្រសួង (ដោយមូលហេតុសមរម្យ /កំណត់ពេលវេលា ច្បាស់លាស់) នូវការប្រែប្រួល ឬការយឺតយ៉ាវលើសេវារបស់ខ្លួន
- ត្រូវផ្តល់នូវឯកសារដែលខ្លួនបានត្រួតពិនិត្យពេញលេញ មកក្រុមការងារអន្តរក្រសួងឱ្យបានទៀងទាត់ និងទាន់ពេលវេលា ហើយឯកសារនោះត្រូវតែបញ្ជាក់ថា ការងារដែលខ្លួនបានចុះត្រួតពិនិត្យពិតជាត្រឹមត្រូវ និង ច្បាស់លាស់តាមលទ្ធផលការងារដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានអនុវត្តមែន
- ត្រូវវាយការណ៍មកក្រុមការងារអន្តរក្រសួងឱ្យបានទាន់ពេលវេលាពីការលំបាក និងភាពមិនប្រក្រតី ដែលបង្កឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុដែលខ្លួនបំពេីការងារជូន
- មិនត្រូវផ្តល់សេវាជូនបុគ្គលអភិវឌ្ឍអចលនវត្ថុណាដែលពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ
- មិនត្រូវពន្យាការសំរេច ឬការបញ្ជាក់លើលិខិតស្នើសុំដកប្រាក់របស់អតិថិជនដោយពុំបានបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ឡើយ
- មិនត្រូវមានចេតនាពន្យារ ឬអូសបន្លាយការងារត្រួតពិនិត្យឡើយ ។

ប្រការ៧: - ការត្រួតពិនិត្យ

ក្នុងករណីមានការសង្ស័យ ប្រធានក្រុមការងារអន្តរក្រសួងអាចចាត់មន្ត្រីជំនាញរបស់ខ្លួនដើម្បីចុះត្រួតពិនិត្យដល់ទីកន្លែងលើឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការងារវាយតម្លៃរបស់អ្នកកាន់អាជ្ញាប័ណ្ណ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីជំនាញរបស់ក្រុមការងារអន្តរក្រសួងក្នុងការពិនិត្យបញ្ជីស្តាម និងឯកសារផ្សេងៗ ។

ប្រការ៨: - ការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុសឆ្គង

ក្រុមការងារអន្តរក្រសួង មានសិទ្ធិដកហូតការងារ ឬអាជ្ញាប័ណ្ណប្រកបសេវាកម្មជាវិស្វកររងករាជ្យ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនគោរពប្រតិបត្តិតាមការណែនាំដូចមានចែងក្នុងប្រកាសនេះ ឬមានចែងក្នុងវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈនោះទេ ។ បន្ថែមលើនោះក្រុមការងារអន្តរក្រសួងត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាអាណាព្យាបាលគ្រប់គ្រងលើវិជ្ជាជីវៈរបស់អ្នកកាន់អាជ្ញាប័ណ្ណឱ្យបានជ្រាបអំពីបទល្មើសដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្ត ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ជាធរមាន ។

ប្រការ៩: - រដាយការណ៍បញ្ចប់គម្រោង

ក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវផ្តល់របាយការណ៍វាយតំលៃបញ្ចប់គម្រោងសាងសង់ របស់បុគ្គលអភិវឌ្ឍអចលនវត្ថុ មកក្រុមការងារអន្តរក្រសួងឱ្យបានមុនពេលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចេញលិខិតបិទការដ្ឋានសាងសង់។

ប្រការ១០: - ការអនុវត្តប្រកាស

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ គ្រប់នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធជំទៃទៀតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណវិស្វកម្មឯករាជ្យ បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១០

អនុប្រធានអចិន្ត្រៃយ៍ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

គាត ឃន់

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន

« ដើម្បីជូនជ្រាប »

កន្លែងទទួល:

- ដូចមានក្នុងប្រការ ១០

« ដើម្បីអនុវត្ត »

- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីការអនុញ្ញាតដួសដុលសំណង់អគារ

ឆ្នាំ ២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ: ...០៧៤..... ប្រក/អសណ

ប្រកាស
ស្តីពី
ការអនុញ្ញាតជួសជុលសំណង់អគារ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- បានឃើញប្រកាសរួមលេខ ១២២៩ ប្រក.មជ.ដនស រវាងក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត
- តាមការចាំបាច់របស់ក្រសួង

សម្រេច

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet Com. Kh

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះមានគោលបំណង៖

- ផ្តល់ភាពស្របច្បាប់នៃសំណង់
- ធានាសុវត្ថិភាពលើការងារជួសជុលកែលម្អសំណង់អគារ
- បង្កើនការជឿទុកចិត្តពីសាធារណជននិងម្ចាស់សំណង់លើគុណភាពសំណង់តាមរយៈការតាមដានត្រួតពិនិត្យរបស់អ្នកបច្ចេកទេសជំនាញលើការជួសជុលអគារ ។

ប្រការ២.-

ប្រកាសនេះមានគោលដៅដូចតទៅ ៖

- ទប់ស្កាត់ការជួសជុលសំណង់អគារដែលគ្មានលិខិតអនុញ្ញាតជួសជុលឬខុសពីលិខិតអនុញ្ញាតជួសជុល
- ពង្រឹងអនុវត្តការងារបទប្បញ្ញត្តិនានា ដែលទាក់ទងនឹងសុវត្ថិភាពសណ្តាប់ធ្នាប់ សោភ័ណភាព គុណភាពសំណង់ បរិស្ថាននិងជៀសវាងផលប៉ះពាល់ផ្សេងៗបណ្តាលមកពីការជួសជុលកែលម្អសំណង់អគារដែលមិនស្របតាមគំនូរប្លង់ នគរូបនីយប្បញ្ញត្តិ បទដ្ឋានបច្ចេកទេស រចនាសម្ព័ន្ធក្រោមដី និងឯកសារនានាដែលបានអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

ប្រការ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជាលើកលែងតែសំណង់ធារាសាស្ត្រ សំណង់ស្ពានថ្មល់ សំណង់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ សំណង់ពាក់ព័ន្ធវិស័យការពារជាតិ រាល់ការជួសជុលអគារទាំងឡាយដែលមិនបណ្តាលឲ្យប៉ះពាល់ដល់សំណង់ជិតខាង ឬសមត្ថភាពគ្រឿងផ្គុំសំណង់ និងរាល់ការជួសជុលតូចតាច ។

ប្រការ៤.-

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

- ការជួសជុលសំណង់ សំដៅដល់ការជួសជុលនូវចំណែកណាមួយនៃសំណង់ដែលខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ដោយថាហេតុ
- គំនូរប្លង់ សំដៅដល់គំនូរប្លង់ស្តាបត្យកម្មនិងប្លង់វិស្វកម្ម ដែលគូរដោយអ្នកបច្ចេកទេសជំនាញស្របតាមបទដ្ឋានបច្ចេកទេសសំណង់និងមានមាត្រដ្ឋានកំណត់ច្បាស់លាស់
- គ្រឿងផ្គុំសំណង់ សំដៅដល់រចនាសម្ព័ន្ធអគាររួមមាន គ្រឹះ សសរ ធ្នឹម កម្រាល គ្រឿងផ្គុំដំបូល ជណ្តើរ ជញ្ជាំងរងបន្ទុក និងគ្រឿងផ្គុំសំណង់ផ្សេងទៀត ដែលគ្រោងឡើងសម្រាប់ទ្រទម្ងន់

- ស្ថាប័នមានសមត្ថកិច្ចឬស្ថាប័នជំនាញ សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ
- ស្ថាបត្យកម្ម សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារ និងការសាងសង់ទាំងក្នុងនិងក្រៅនៃសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេស និងតាមសំណុំសោភ័ណភាពដែលបានគ្រោងទុកដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន
- អ្នកបច្ចេកទេសជំនាញ សំដៅដល់មន្ត្រីជំនាញរបស់រដ្ឋនិងអ្នកបច្ចេកទេសជំនាញរបស់ក្រុមហ៊ុនមានជាអាទិ៍ ស្ថាបត្យករ វិស្វករ អ្នកបច្ចេកទេសខាងវិស័យសំណង់
- អ្នកពាក់ព័ន្ធ សំដៅដល់អ្នកបច្ចេកទេសជំនាញ ក្រុមហ៊ុនត្រួតពិនិត្យការដ្ឋាន សហគ្រាសទទួលការសាងសង់ រូបវន្តបុគ្គលប្រចាំការដ្ឋាន ភ្នាក់ងារអង្កេតការដ្ឋាន និងអ្នកជិតខាង
- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់ក្រសួងស្ថាប័នរដ្ឋ ឬរដ្ឋបាលមូលដ្ឋានថ្នាក់ក្រោមជាតិ
- ថ្ងៃធ្វើការ សំដៅដល់ថ្ងៃធ្វើការជាផ្លូវការកំណត់ដោយរាជរដ្ឋាភិបាល
- ការជូនដំណឹងតូចតាច សំដៅដល់ការកោសលាប និង/ឬការសម្អាតខាងក្នុងអគារ ។

ជំពូកទី២
សមត្ថកិច្ចគ្រប់គ្រង

ប្រការ៥.-

រូបវន្តបុគ្គលឬនីតិបុគ្គលមានសិទ្ធិស្នើសុំធ្វើការជូនដំណឹងសំណង់អគារគ្រប់ប្រភេទលើកលែងតែសំណង់ណាដែលមានចែងលើកលែងក្នុងប្រការ៣ ។ លិខិតអនុញ្ញាតជូនដំណឹង ត្រូវបានផ្តល់ជូនដោយស្ថាប័នមានសមត្ថកិច្ចតាមការស្នើសុំរបស់ម្ចាស់សំណង់ ឬតំណាងស្របច្បាប់របស់ខ្លួន មុនចាប់ផ្តើមដំណើរការជូនដំណឹង។

ឯកសារស្នើសុំលិខិតអនុញ្ញាតជូនដំណឹង មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ៦.-

លិខិតអនុញ្ញាតជូនដំណឹងត្រូវចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចរៀងៗខ្លួន។

ចំពោះអគារដែលបានសាងសង់មុនឆ្នាំ១៩៩៨ ការស្នើសុំជូនដំណឹងអគារទាំងនោះមិនតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ទេ ។

ចំពោះអគារដែលបានសាងសង់ក្នុងចន្លោះឆ្នាំ១៩៩៨ ដល់មុនពេលចេញប្រកាសនេះ ហើយគ្មានលិខិតអនុញ្ញាតសាងសង់និងគ្មានទំនាស់ ស្ថាប័នមានសមត្ថកិច្ចអាចចេញលិខិតអនុញ្ញាតជូនដំណឹងជូនម្ចាស់សំណង់បាន ដោយម្ចាស់សំណង់ត្រូវធ្វើកិច្ចសន្យាធានានិងទទួលខុសត្រូវលើគុណភាពសំណង់ សុវត្ថិភាពអ្នកជិតខាង និងសណ្តាប់ធ្នាប់សាធារណៈ។

ប្រការ៧.-

ចំពោះសំណង់អគារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ននានា មុនពេលជួសជុល ម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតជួសជុលពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ លើកលែងតែសំណង់ដែលមានចែង លើកលែងក្នុងប្រការ៣នៃប្រកាសនេះ ឬសំណង់អគារណាដែលមានលិខិតបទដ្ឋានគតិយុត្តកំណត់ដោយឡែក ។

ប្រការ៨.-

សេចក្តីជូនដំណឹងស្តីពីការស្នើសុំជួសជុល ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃចាប់ ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំដោយបិទផ្សាយនៅកន្លែងគ្រោងធ្វើការជួសជុល។ ក្នុងករណីចាំបាច់បន្ទាន់ ការជួសជុលអាចប្រព្រឹត្តទៅបានមុនផុតកំណត់រយៈពេល១៥(ដប់ប្រាំ) ថ្ងៃនៃសេចក្តីជូនដំណឹងខាងលើដោយយោងទៅលើការវាយតម្លៃរបស់ស្ថាប័នមានសមត្ថកិច្ច។

សេចក្តីជូនដំណឹងខាងលើត្រូវធ្វើឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាល ក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចសម្រេចលើលិខិតអនុញ្ញាតជួសជុលរៀងៗខ្លួន ។

ជំពូកទី៣
បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុល

ប្រការ៩.-

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានសំណង់ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរ ឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់
- ការិយាល័យកិច្ចការទូទៅត្រូវបញ្ជូនពាក្យស្នើសុំ និងឯកសារភ្ជាប់ទៅការិយាល័យជួសជុល និងថែទាំ នៃនាយកដ្ឋានសំណង់ ដើម្បីពិនិត្យ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថាពាក្យស្នើសុំ និងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ

- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុលត្រូវចាប់រាប់ពីថ្ងៃទទួលឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ការិយាល័យជួសជុលនិងថែទាំ ត្រូវចុះពិនិត្យទីតាំងជួសជុលជាក់ស្តែងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ០៨ (ប្រាំបី)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់ពិនិត្យសម្រេច
- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

ប្រការ១០.-

បរិបទនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត មានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរឬបកប្រែជាភាសាខ្មែរចំនួន ០៧ច្បាប់
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថា ពាក្យសុំសុំនិងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំនៅមានលក្ខណៈពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ
- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវចាប់រាប់ពីថ្ងៃទទួលឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទាំងនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ដើម្បីពិនិត្យសម្រេចតាមសមត្ថកិច្ច
- ការិយាល័យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ក្នុងរយៈពេល០២(ពីរ)ថ្ងៃ ។ បើមានការខ្វះខាតអាចស្នើឲ្យ

អ្នកស្នើសុំលិខិតអនុញ្ញាតជួសជុលបំពេញន្ថែមក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ (រយៈពេលនេះមិនរាប់បញ្ចូលក្នុងបរិបថនៃការចេញលិខិតអនុញ្ញាតជួសជុល១៥(ដប់ប្រាំ)ថ្ងៃទេ)

- ការិយាល័យសំណង់ត្រូវចុះពិនិត្យទីតាំងជាក់ស្តែងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំមន្ទីរពិនិត្យនិងសម្រេច
- ថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ១១.-

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌមានដូចតទៅ ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរ ឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថាពាក្យស្នើសុំនិងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំនៅមានលក្ខណៈពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ
- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់ និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវចាប់រាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ផ្នែកសំណង់នៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យទីតាំងជាក់ស្តែងនិងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច
- ថ្នាក់ដឹកនាំនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ១២.~

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌដែលទទួលបានប្រតិភូកម្មមុខងារមានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យច្រកចេញចូលតែមួយរបស់សាលាក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់ ។ ការទទួលពាក្យសុំត្រូវចុះកាលបរិច្ឆេទនិងចេញបង្កាន់ដៃទទួលពាក្យ
- រាល់ការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវអនុវត្តតាមបែបបទរដ្ឋបាលរបស់សាលាក្រុង ស្រុក ខណ្ឌ បន្ទាប់ពីបានទទួលយោបល់របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ
- រាល់លិខិតអនុញ្ញាតជួសជុលដែលផ្តល់ដោយសាលាក្រុង ស្រុក ខណ្ឌ ច្រកចេញចូលតែមួយ ត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារទាំងនេះចំនួន០១ច្បាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និង០១ច្បាប់មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ។

ប្រការ១៣.~

លិខិតអនុញ្ញាតជួសជុល ត្រូវចាត់ទុកថាបានយល់ព្រម បើពុំមានចម្លើយណាមួយពីស្ថាប័នមានសមត្ថកិច្ចក្រោយពីថ្ងៃដាក់ពាក្យស្នើសុំចំនួន២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ១៤.~

សោហ៊ុយសេវានៃការចេញលិខិតអនុញ្ញាតជួសជុល ត្រូវអនុវត្តតាមស្មារតីនៃប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ១៥.~

លិខិតអនុញ្ញាតជួសជុលអស់សុពលភាព ប្រសិនបើការងារជួសជុលពុំដំណើរការក្នុងរយៈពេល០៣(បី)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតជួសជុល ។

លិខិតអនុញ្ញាតនេះ អាចពន្យាពេលបានតែមួយដងគត់ ប្រសិនបើម្ចាស់សំណង់មានមូលហេតុសមស្រប ។

ក្នុងករណីដែលការងារជួសជុលត្រូវបានផ្អាកលើសពី៣០(សាមសិប)ថ្ងៃ ដោយគ្មានមូលហេតុសមស្រប ស្ថាប័នមានសមត្ថកិច្ចត្រូវបង្ខំឲ្យម្ចាស់សំណង់បញ្ចប់ការងារជួសជុលនេះក្នុងរយៈពេលមួយជាកំណត់ អាស្រ័យលើទំហំការងារ និងការវាយតម្លៃជាក់ស្តែងរបស់មន្ត្រីជំនាញ ដើម្បីរក្សានូវសោភ័ណភាព សុវត្ថិភាពការដ្ឋាននិងសណ្តាប់ធ្នាប់សាធារណៈ ។

ជំពូកទី៤
ការត្រួតពិនិត្យការដ្ឋានជួសជុល កាតព្វកិច្ចរបស់ម្ចាស់សំណង់
និងបណ្តឹងតវ៉ា

ប្រការ១៦.-

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិត្រួតពិនិត្យតាមដានការដ្ឋានជួសជុលនិងឯកសារពាក់ព័ន្ធនឹងការជួសជុលបានគ្រប់ពេលវេលា។ បើពិនិត្យឃើញថា ការជួសជុលមិនស្របតាមលិខិតអនុញ្ញាតជួសជុលនិងមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសជំនាញ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ឬអគ្គនាយកដ្ឋានសំណង់ ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរឲ្យម្ចាស់សំណង់ធ្វើការកែតម្រូវជាបន្ទាន់ឲ្យស្របតាមលិខិតអនុញ្ញាតជួសជុលនិងតាមបទដ្ឋានបច្ចេកទេសជំនាញ ។

ក្នុងករណីដែលម្ចាស់សំណង់មិនព្រមធ្វើតាមការណែនាំខាងលើនេះ ស្ថាប័នជំនាញមានសិទ្ធិបញ្ឈប់ការជួសជុល ឬចេញលិខិតផ្អាកការដ្ឋាន និងឲ្យម្ចាស់សំណង់ធ្វើការកែតម្រូវជារលើកទី២ឲ្យបានត្រឹមត្រូវក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលលិខិតណែនាំជាផ្លូវការ។

ប្រសិនបើម្ចាស់សំណង់ នៅតែរឹងរូសមិនព្រមអនុវត្តទៅតាមការណែនាំខាងលើនេះ មន្ត្រីជំនាញមានសិទ្ធិស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយដល់ការអនុវត្តន៍ឲ្យមានប្រសិទ្ធភាព។

ប្រការ១៧.-

ត្រូវបានហាមឃាត់ ៖

- ការដាក់តាំងគរសម្ភារៈសំណង់លើផ្លូវសាធារណៈ
- ការតាំងការដ្ឋានលយទៅលើចិញ្ចើមផ្លូវសាធារណៈលើសពីពីរភាគបីនៃចិញ្ចើមផ្លូវ
- ការបង្ហូរនិងការចោលកាកសំណល់ពីការដ្ឋានសំណង់មកផ្លូវនិងទីសាធារណៈ ។

ម្ចាស់ការដ្ឋានសំណង់ត្រូវ ៖

- ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់ក្នុងរយៈពេលដំណើរការជួសជុល
- រុះរើ សម្អាតការដ្ឋានជួសជុល និងយកចេញនូវសម្ភារៈបរិក្ខាគ្រឿងចក្រ និងកាកសំណល់ពីការដ្ឋានជួសជុលក្នុងរយៈយ៉ាងយូរពីរសប្តាហ៍ក្រោយពេលចប់ការងារជួសជុល ។

ប្រការ១៨.-

ក្នុងពេលដំណើរការជួសជុល ម្ចាស់សំណង់និងអ្នកពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងវិធានផ្សេងៗដែលបណ្តាលមកពីការធ្វេសប្រហែស ឬការជួសជុលមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសំណង់ ។

ប្រការ១៩.-

ក្នុងករណីមានបណ្តឹងតវ៉ាដែលទាក់ទងនឹងការស្នើសុំជួសជុលឬការជួសជុល អ្នកប្តឹងតវ៉ាអាចប្តឹងទៅស្ថាប័នមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតជួសជុលឲ្យជួយដោះស្រាយទំនាស់ ។ ស្ថាប័នមានសមត្ថកិច្ចត្រូវផ្អាកដំណើរការនៃការស្នើសុំលិខិតអនុញ្ញាតជួសជុលឬផ្អាកការជួសជុលជាបណ្តោះអាសន្នសិន រង់ចាំធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់នេះ ។

ក្នុងករណីដែលការសម្របសម្រួលខាងលើមិនអាចធ្វើបាន អ្នកប្តឹងតវ៉ាអាចប្តឹងទៅតុលាការដើម្បីដោះស្រាយតាមនីតិវិធីនៃច្បាប់ ។

ជំពូកទី៥
អំពីសំណង់ចាស់

ប្រការ២០.-

រាល់សំណង់អគារចាស់ទ្រុឌទ្រោមមិនអាចស្នាក់នៅបាន និងអាចបង្កគ្រោះថ្នាក់ដោយប្រការណាមួយដែលមានការវាយតម្លៃច្បាស់លាស់ពីស្ថាប័នជំនាញ អាជ្ញាធរមានសមត្ថកិច្ចតាមសំណើរបស់ស្ថាប័នជំនាញត្រូវជូនដំណឹងដល់ម្ចាស់សំណង់ ឬកម្មសិទ្ធិករដែលស្នាក់នៅក្នុងអគារនោះ ដោយបង្ខំឲ្យធ្វើការរុះរើ ឬជួសជុលជាបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងជៀសវាងគ្រោះថ្នាក់ជាយថាហេតុ ។ ការជួសជុលត្រូវធ្វើឲ្យស្របតាមបទដ្ឋានបច្ចេកទេសសំណង់ ។

ក្នុងករណីដែលម្ចាស់សំណង់មិនព្រមជួសជុលតាមសេចក្តីជូនដំណឹងខាងលើចំនួន២(ពីរ)ដង ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះការខូចខាតឬគ្រោះថ្នាក់ទាំងឡាយដែលកើតឡើងដោយការមិនព្រមជួសជុលសំណង់របស់ខ្លួន ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

ប្រការ២១.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

ប្រការ២២.-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ.កុម្ភៈ.. ឆ្នាំ២០១៣

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលីម

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-គ្រប់សាលារាជធានីខេត្ត
-ដូចប្រការ២១
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីវិធានគណនាសន្ទស្សន៍
ប្រើប្រាស់ដី

ឆ្នាំ ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ:...២១៧...ប្រក.ដ.ន.ស

ប្រកាស
ស្តីពី
វិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel / Fax : 023 215 279 / (855-23) 215 660 / 023 217 031 គេហទំព័រ www.mlmupc.gov.kh /

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

ប្រការ ២.

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី ដើម្បីកំណត់អំពីលទ្ធភាពនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់សំណង់អគារគ្រប់ប្រភេទ។

ប្រការ ៣.

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍនិងការសាងសង់អគារនៅព្រះរាជាណាចក្រកម្ពុជា លើកលែងចំពោះសំណង់អគារទាំងឡាយណាដែលពុំតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ប្រការ ៤.

វាក្យស័ព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមាននិយមន័យ ដូចខាងក្រោម៖

- **សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់មេគុណកំណត់ពីលទ្ធភាពនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់។
- **ផ្ទៃក្រឡាកម្រាលសំណង់សរុប** សំដៅដល់ផលបូកនៃផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់និង អគារដែលមាននៅក្នុងដីឡូត៍នៃគម្រោងសាងសង់។ ការគណនាផ្ទៃក្រឡាកម្រាលសំណង់ សរុបត្រូវគិតយកពីអ័ក្សនៃសសរ ឬជញ្ជាំងខាងក្រៅ។
- **ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ** សំដៅដល់ផ្ទៃក្រឡាកម្រាលសំណង់ដែលត្រូវគិតសន្ទស្សន៍ ដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ។
- **ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។

ជំពូកទី ២
វិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី

ប្រការ ៥.

សន្ទស្សន៍ប្រើប្រាស់ដី ត្រូវកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះស្ថិតនៅ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយបន្ថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ទៅលើផ្ទៃក្រឡាកម្រាលនៃសំណង់ថ្មី។ល។

$$\text{សន្ទស្សន៍ប្រើប្រាស់ដី} = \frac{\text{ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ}}{\text{ផ្ទៃក្រឡាដីឡូត៍}}$$

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ = ផ្ទៃក្រឡាកម្រាលសំណង់សរុប – ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍។

ប្រការ ៦.

របៀបគណនាជាក់ស្តែងនៃសន្ទស្សន៍ប្រើប្រាស់ដី ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ ផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៧.

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ គឺជាផលបូកនៃផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់ និងអគារដែលមាននៅក្នុងដីឡូត៍នៃគម្រោងសាងសង់ ដោយដកចេញនូវផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍។

ផ្ទៃក្រឡាសំណង់លើកលែងសន្ទស្សន៍ ជាអាទិ៍៖

- ផ្ទៃក្រឡាកម្រាលជាន់ក្រោមដីដែលមិនមែនជាបន្ទប់រស់នៅ
- ផ្ទៃក្រឡាកម្រាលជាន់ផ្ទាល់ដីដែលមានតែសសរឥតមានរៀបជញ្ជាំង
- ផ្ទៃក្រឡាកម្រាលសំណង់លម្ហក្រោមដំបូលដែលមានកម្រិតកម្ពស់ទាបជាង ១,៨០ (មួយម៉ែត្រប៉ែតសិប)
- ផ្ទៃក្រឡាលម្ហផ្តល់ពន្លឺ
- ផ្ទៃក្រឡាកម្រាលសួនច្បារខាងក្នុងអគារ
- ផ្ទៃក្រឡាកម្រាលសំណង់ដែលបម្រើសុខុមាលភាពសហគមន៍ក្នុងអគារលំនៅឋាន ដូចជាកន្លែងហាត់ប្រាណ អាងហែលទឹក បន្ទប់ស្ទឹម បន្ទប់សូណា បន្ទប់ទឹក និងបន្ទប់ផ្លាស់សម្លៀកបំពាក់សម្រាប់ប្រើប្រាស់ក្នុងសហគមន៍
- ផ្ទៃក្រឡាកម្រាលដំបូលទែរ៉ាស់ វានហាល និងយ៉ក្នុងមុំពន្លឺ ៤៥° (សែសិបប្រាំ) ដីក្រៃ ដែលមានដំបូលនិងគ្មានជញ្ជាំងក្រៅ
- ផ្ទៃក្រឡាកម្រាលកន្លែងចំណតយានយន្ត រចនាសម្ព័ន្ធសម្រាប់ចំណតយានយន្ត និងកន្លែងទុកដាក់កាកសំណល់ ដែលមានជញ្ជាំងទាបជាង ១,៤០ (មួយម៉ែត្រសែសិប)
- ផ្ទៃក្រឡាកម្រាលសំណង់បន្ទប់ជណ្តើរ បន្ទប់អគ្គិសនី និងបន្ទប់មេកានិក
- ផ្ទៃក្រឡាកម្រាលដែលរៀបចំសម្រាប់ផលិតផលកសិកម្មប្រចាំគ្រួសារ សម្រាប់ចិញ្ចឹមសត្វនិងសម្ភារៈកសិកម្ម ក្នុងប្រភេទដីកម្រិតការសាងសង់។

ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបសម្រាប់គណនាសន្ទស្សន៍ ត្រូវគណនាពីអ័ក្សនៃសសរ ឬជញ្ជាំងខាងក្រៅ។

ជំពូកទី ៣
អវសានបញ្ញត្តិ

ប្រការ ៨..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៩..

នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..៣០.. ខែ..ធ្នូ.. ឆ្នាំ២០១៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ុម សុនលឹម

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត

"ដើម្បីជូនជ្រាប"
- ដូចប្រការ ៩ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ២១៧ប្រក.ដ.ន.ស ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៥
ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី

I. រូបមន្តវិធានគណនា

១.ការគណនាសន្ទស្សន៍ប្រើប្រាស់ដី

សន្ទស្សន៍ប្រើប្រាស់ដីត្រូវបានគណនាតាមរូបមន្ត៖

$$FAR = \frac{FA_{TC}}{SA_T} \qquad (១)$$

- **FAR** (Floor Area Ratio) = សន្ទស្សន៍ប្រើប្រាស់ដី
- FA_{TC} (Total Covered Floor Areas) = ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ (ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍)
- SA_T (Total Site Area) = ផ្ទៃក្រឡាសរុបនៃដីឡូត៍ដែលសំណង់នោះតាំងនៅ

ឬ $$FAR = \frac{FA_T - FA_{TUC}}{SA_T} \qquad (២)$$

<u>សម្គាល់:</u> (១) និង (២)ជារូបមន្តទូទៅ ។

២.ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ

$$FA_{TC} = FA_T - FA_{TUC} \qquad (៣)$$

- FA_T (Total Floor Areas) = ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់
- FA_{TUC} (Total Uncovered Floor Areas) = ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍

<u>សម្គាល់:</u> ការគណនា FA_{TUC} អនុវត្តតាមប្រការ៧ នៃប្រកាសនេះ។

៣.ការគណនាផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី

$$FA_{OL} = FAR_{OL} \times SA_T \qquad (៤)$$

ដោយ ៖ $FAR_{OL} = FAR_P - FAR_L$

ឬ $$FA_{OL} = FA_P - FA_L \qquad (៥)$$

ដោយ ៖ $FA_L = FAR_L \times SA_T$

- FA_{OL} (Floor Area Over Limited) = ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍
- FAR_{OL} (Floor Area Ratio Over Limited) = សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ
- FAR_P (Floor Area Ratio Proposed) = សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំដោយសាមីសំណើ
- FAR_L (Floor Area Ratio Limited) = សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ
- FA_P (Floor Areas Proposed) = ផ្ទៃក្រឡាកម្រាលសំណង់ស្នើសុំដោយសាមីសំណើ
- FA_L (Floor Areas limited) = ផ្ទៃក្រឡាកម្រាលសំណង់កំណត់ផ្លូវការ។

II. ឧទាហរណ៍អំពីការគណនាសន្ទស្សន៍ប្រើប្រាស់ដី

ក.ឧទាហរណ៍ទី១

ក១.តារាងគណនាសន្ទស្សន៍ប្រើប្រាស់ដី

-ឈ្មោះគម្រោង ៖.....

-ទីតាំង ៖ ស្ថិតនៅលើដីឡូត៍លេខ.....ផ្លូវលេខ.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត.....

ល.រ	ឈ្មោះជាន់	ផ្ទៃក្រឡាកម្រាលសំណង់តាមជាន់ (ម²)	ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍តាមជាន់(ម²)	ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍តាមជាន់(ម²)	ផ្ទៃក្រឡាសរុបនៃដីឡូត៍(ម²)	សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំ	សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ	សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ	ផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី(ម²)
១	ប្លង់ជាន់ផ្ទាល់ដី	៧៨០,៩៦	១២៣,២៦	៦១៧,៧០					
២	ប្លង់ជាន់ទី១	៨០៦,២៤	០,០០	៨០៦,២៤					
៣	ប្លង់ជាន់ទី២	៨០៦,២៤	០,០០	៨០៦,២៤					
៤	ប្លង់ជាន់ទី៣	៨០៤,០០	០,០០	៨០៤,០០					
៥	ប្លង់ជាន់ទី៤	៧៥១,៥៧	៥៣៧,៤២	២១៤,១៥					
៦	ប្លង់ជាន់ទី៥	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
៧	ប្លង់ជាន់ទី៦	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
៨	ប្លង់ជាន់ទី៧	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
៩	ប្លង់ជាន់ទី៨	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
១០	ប្លង់ជាន់ទី៩	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
១១	ប្លង់ជាន់ទី១០	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
១២	ប្លង់ជាន់ទី១១	៧៥១,៥៧	៥៥៤,៦១	១៩៦,៩៦					
១៣	ប្លង់ជាន់ទី១២	៧៥១,៥៧	៥៧៨,១១	១៧៣,៤៦					
១៤	ប្លង់ជាន់ទី១៣	៧៥០,២១	៥៦១,១៣	១៨៩,០៨					
១៥	ប្លង់ជាន់ទី១៤	៧៥០,២១	៥៦១,១៣	១៨៩,០៨					
១៦	ប្លង់ជាន់ទី១៥	៧៥០,២១	៥៦១,១៣	១៨៩,០៨					

១៧	ប្លង់ជាន់ទី១៦	៧៥០,២១	៥៦១,១៣	១៨៩,០៨					
១៨	ប្លង់ជាន់ទី១៧	៧៥០,២១	៥៦១,១៣	១៨៩,០៨					
១៩	ប្លង់ជាន់ទី១៨	៧៥០,២១	៥៦១,១៣	១៨៩,០៨					
២០	ប្លង់ជាន់ទី១៩	៧៥០,២១	៥៦១,១៣	១៨៩,០៨					
២១	ប្លង់ជាន់ទី២០	៧៥០,២១	៥៦១,១៣	១៨៩,០៨					
២២	ប្លង់ជាន់ទី២១	៧៥០,២១	៥៦១,១៣	១៨៩,០៨					
២៣	ប្លង់ជាន់ទី២២	៧៥០,២១	៥៦១,១៣	១៨៩,០៨					
២៤	ប្លង់ជាន់ទី២៣	៧៨៥,៧០	៥៧០,១៦	១៧៥,៥៤					
២៥	ប្លង់ជាន់ទី២៤	៧៨៥,៧០	៥៧០,១៦	១៧៥,៥៤					
២៦	ប្លង់ជាន់ទី២៥	៧៨៥,៧០	៥៧០,១៦	១៧៥,៥៤					
២៧	ប្លង់ជាន់ទី២៦	៧៦៥,៨០	៥៨០,៩១	២២៨,៨៩					
២៨	ប្លង់ទែរ៉ាស់ដំបូល	១២៧,៨២	0,00	១២៧,៨២					
សរុប		**២០.៥៥៨,៣៩**	**១២.៩៨៣,៧៥**	**៧.៥៧០,៦៨**	**១.១៧៥,00**	**១១,០៥**	**៥**	**៦,០៥**	**៧.១០៨,៧៥**
		FA_T	**FA_{TC} ឬ FA_P**	**FA_{TUC}**	**SA_T**	**FAR_P**	**FAR_L**	**FAR_{OL}**	**FA_{OL}**

ក២.ការគណនាតាមរូបមន្ត

១.ការគណនាសន្ទស្សន៍ប្រើប្រាស់ដី

- ឈ្មោះគម្រោង ៖ អគារស្នាក់នៅ
- ទីតាំង ៖ ស្ថិតក្នុងតំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់
- ផ្ទៃក្រឡាសរុបនៃដីឡូត៍ **(SA_T)** = ១.១៧៥,០០ ម៉ែត្រការ៉េ
- ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់ **(FA_T)** = ២០.៥៥៤,៣៩ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ **(FA_{TC})** = ១២.៩៨៣,៧៥ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **(FA_{TUC})** = ៧.៥៧០,៦៤ ម៉ែត្រក្រឡា

តាមរយៈរូបមន្ត $$\mathbf{FAR} = \frac{\mathbf{FA_{TC}}}{\mathbf{SA_T}}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី **(FAR)** $= \frac{\text{១២.៩៨៣,៧៥}}{\text{១.១៧៥,០០}} = \underline{\text{១១,០៥}}$ (១)

ឬ តាមរយៈរូបមន្ត $$\mathbf{FAR} = \frac{\mathbf{FA_T - FA_{TUC}}}{\mathbf{SA_T}}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី **(FAR)** $= \frac{\text{២០.៥៥៤,៣៩} - \text{៧.៥៧០,៦៤}}{\text{១.១៧៥,០០}} = \underline{\text{១១,០៥}}$ (២)

២.ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ

តាមរយៈរូបមន្ត $\mathbf{FA_{TC} = FA_T - FA_{TUC}}$

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ **(FA_{TC})** = ២០.៥៥៤,៣៩ – ៧.៥៧០,៦៤

= **<u>១២.៩៨៣,៧៥</u>** ម៉ែត្រក្រឡា (៣)

៣.ការគណនាផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី

តាមរយៈរូបមន្ត $\mathbf{FA_{OL} = FAR_{OL} \times SA_T}$

ដោយ៖ $\mathbf{FAR_{OL} = FAR_P - FAR_L}$

- សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំ **(FAR_P)** = ១១,០៥
- សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ **(FAR_L)** = ៥

យោងតាមមាត្រា២២នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន **តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់** ត្រូវបានកំណត់ សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើ៥។

នាំឲ្យ សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ **(FAR_{OL})** = ១១,០៥ – ៥ = ៦,០៥
ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **(FA_{OL})**= ៦,០៥ x ១.១៧៥,០០
= <u>**៧.១០៨,៧៥**</u> ម៉ែត្រក្រឡា (៤)

ឬ តាមរយៈរូបមន្ត **$FA_{OL} = FA_P - FA_L$**

– ផ្ទៃក្រឡាកម្រាលសំណង់ស្នើសុំដោយសាមីសំណើ **(FA_P)**ឬ **(FA_{TC})** = ១២.៩៨៣,៧៥ ម៉ែត្រក្រឡា

– ផ្ទៃក្រឡាកម្រាលសំណង់កំណត់ផ្លូវការ **(FA_L)** = **$FAR_L \times SA_T$**
= ៥ x ១.១៧៥,០០
= ៥.៨៧៥,០០ ម៉ែត្រក្រឡា

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **(FA_{OL})**=១២.៩៨៣,៧៥ – ៥.៨៧៥,០០
= <u>**៧.១០៨,៧៥**</u> ម៉ែត្រក្រឡា (៥)

ក៣.ប្លង់ស្តាបត្បកម្មគម្រោងស្នើសុំសាងសង់(ឧទាហរណ៍ទី១)



ប្លង់ជាន់ផ្ទាល់ដី

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ជាន់ទី១

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ជាន់ទី២

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ជាន់ទី៣

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ជួរជាន់ទី៤

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ជួរជាន់ទី៥ ដល់ជាន់ទី១១

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ជាន់ទី១២

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ជាន់ទី១៣,១៥,១៧,១៩,២១

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ជួរជាន់ទី១៤,១៦,១៨,២០,២២

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ជួរជាន់ទី២៣,២៤,២៥

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ជាន់ទី២៦

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍



ប្លង់ផែ៉ាស់ដំបូល

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍

ខ.ឧទាហរណ៍ទី២

ខ១.តារាងគណនាសន្ធស្សន៍ប្រើប្រាស់ដី

–ឈ្មោះគម្រោង ៖.....

–ទីតាំង ៖ ស្ថិតនៅលើដីឡូត៍លេខ.....ផ្លូវលេខ.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត.....

ល.រ	ឈ្មោះជាន់	ផ្ទៃក្រឡាកម្រាលសំណង់តាមជាន់ (ម²)	ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ធស្សន៍តាមជាន់(ម²)	ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ធស្សន៍តាមជាន់(ម²)	ផ្ទៃក្រឡាសរុបនៃដីឡូត៍(ម²)	សន្ធស្សន៍ប្រើប្រាស់ដីស្មើសុំ	សន្ធស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ	សន្ធស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ	ផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ធស្សន៍ប្រើប្រាស់ដី(ម²)
១	ប្លង់ជាន់ក្រោមដី	៤២៦៦,១០	0,00	៤២៦៦,១០					
២	ប្លង់ជាន់ផ្ទាល់ដី	៣៦០០,៨០	១៩២៥,០៤	១៦៧៥,៧៦					
៣	ប្លង់ជាន់ទី១	៤២៧៤,៤៥	១៩៨៦,៩២	២២៨៧,៥៣					
៤	ប្លង់ជាន់ទី២	៤៣០៨,៦៥	0,00	៤៣០៨,៦៥					
៥	ប្លង់ជាន់ទី៣	៤២៩៦,១៧	0,00	៤២៩៦,១៧					
៦	ប្លង់ជាន់ទី៤	៤២៩៦,១៧	៥៩៩,៧១	៣៦៩៦,៤៦					
៧	ប្លង់ជាន់ទី៥	៤២៩៦,១៧	0,00	៤២៩៦,១៧					
៨	ប្លង់ជាន់ទី៦	៤២៩៦,១៧	៥៩៩,៧១	៣៦៩៦,៤៦					
៩	ប្លង់ជាន់ទី៧	៤២៩៦,១៧	0,00	៤២៩៦,១៧					
១០	ប្លង់ជាន់ទី៨	៤២៤១,០៦	៣១៣១,៦៣	១១០៩,៤៣					
១១	ប្លង់ជាន់ទី៩	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១២	ប្លង់ជាន់ទី១០	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៣	ប្លង់ជាន់ទី១១	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៤	ប្លង់ជាន់ទី១២	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៥	ប្លង់ជាន់ទី១៣	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៦	ប្លង់ជាន់ទី១៤	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៧	ប្លង់ជាន់ទី១៥	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៨	ប្លង់ជាន់ទី១៦	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					
១៩	ប្លង់ជាន់ទី១៧	២៩៨៣,១០	២៥៧១,៧៨	៤១១,៣២					

២០	ប្លង់ជាន់ទី១៨	២៩៨៣,១០	២៥៧១,៧៨	៨១១,៣២					
២១	ប្លង់ជាន់ទី១៩	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២២	ប្លង់ជាន់ទី២០	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៣	ប្លង់ជាន់ទី២១	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៤	ប្លង់ជាន់ទី២២	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៥	ប្លង់ជាន់ទី២៣	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៦	ប្លង់ជាន់ទី២៤	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៧	ប្លង់ជាន់ទី២៥	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៨	ប្លង់ជាន់ទី២៦	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
២៩	ប្លង់ជាន់ទី២៧	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣០	ប្លង់ជាន់ទី២៨	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣១	ប្លង់ជាន់ទី២៩	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣២	ប្លង់ជាន់ទី៣០	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៣	ប្លង់ជាន់ទី៣១	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៤	ប្លង់ជាន់ទី៣២	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៥	ប្លង់ជាន់ទី៣៣	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៦	ប្លង់ជាន់ទី៣៤	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៧	ប្លង់ជាន់ទី៣៥	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៨	ប្លង់ជាន់ទី៣៦	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៣៩	ប្លង់ជាន់ទី៣៧	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៤០	ប្លង់ជាន់ទី៣៨	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៤១	ប្លង់ជាន់ទី៣៩	២៩៨៣,១០	២៦៣៦,១១	៣៨៦,៩៩					
៤២	ប្លង់ទែរ៉ាស់ដំបូល	៣៣,៧២	0,00	៣៣,៧២					
សរុប		១៣៤.៦៨១,៧៣	៨៩.៣១៩,១២	៨៥.៣៦២,៦១	៦.០៧២,00	១៤,៧១	១0	៤,៧១	២៩.៤៩៩,១២
		FA_T	FA_{TC} ឬ FA_P	FA_{TUC}	SA_T	FAR_P	FAR_L	FAR_{OL}	FA_{OL}

ខ២.ការគណនាតាមរូបមន្ត

១.ការគណនាសន្ទស្សន៍ប្រើប្រាស់ដី

- ឈ្មោះគម្រោង ៖ អគារពហុមុខងារ
- ទីតាំង ៖ ស្ថិតក្នុងតំបន់ចម្រុះ
- ផ្ទៃក្រឡាសរុបនៃដីឡូត៍ **(SA_T)** = ៦.០៧២,០០ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់ **(FA_T)** = ១៣៤.៦៨១,៧៣ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ **(FA_{TC})** = ៨៩.៣១៩,១២ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **(FA_{TUC})** = ៤៥.៣៦២,៦១ ម៉ែត្រក្រឡា

តាមរយៈរូបមន្ត $$FAR = \frac{FA_{TC}}{SA_T}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី **(FAR)** $= \frac{៨៩.៣១៩,១២}{៦.០៧២,០០} = \underline{\mathbf{១៤,៧១}}$ (១)

ឬ តាមរយៈរូបមន្ត $$FAR = \frac{FA_T - FA_{TUC}}{SA_T}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី **(FAR)** $= \frac{១៣៤.៦៨១,៧៣ - ៤៥.៣៦២,៦១}{៦.០៧២,០០} = \underline{\mathbf{១៤,៧១}}$ (២)

២.ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ

តាមរយៈរូបមន្ត $FA_{TC} = FA_T - FA_{TUC}$

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ **(FA_{TC})** $= ១៣៤.៦៨១,៧៣ - ៤៥.៣៦២,៦១$

$= \underline{\mathbf{៨៩.៣១៩,១២}}$ ម៉ែត្រក្រឡា (៣)

៣.ការគណនាផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី

តាមរយៈរូបមន្ត $FA_{OL} = FAR_{OL} \times SA_T$

ដោយ៖ $FAR_{OL} = FAR_P - FAR_L$

- សន្ទស្សន៍ប្រើប្រាស់ដីស្មើសុំ **(FAR_P)** = ១៤,៧១
- សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ **(FAR_L)** = ១០

យោងតាមមាត្រា២២នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន **តំបន់ចម្រុះ** ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដី អតិបរមាស្មើ១០។

នាំឲ្យ សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ **(FAR_{OL})** = ១៤,៧១ – ១០ = ៤,៧១
ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **(FA_{OL})**= ៤,៧១ x ៦.០៧២,០០
=<u>២៨.៥៩៩,១២</u> ម៉ែត្រក្រឡា (៤)

ឬ តាមរយៈរូបមន្ត **$FA_{OL} = FA_P - FA_L$**

– ផ្ទៃក្រឡាកម្រាលសំណង់ស្នើសុំដោយសាមីសំណើ **(FA_P)**ឬ **(FA_{TC})** = ៨៩.៣១៩,១២ ម៉ែត្រក្រឡា

– ផ្ទៃក្រឡាកម្រាលសំណង់កំណត់ផ្លូវការ **(FA_L)** = **$FAR_L \times SA_T$**
= ១០ x ៦.០៧២,០០
= ៦០.៧២០,០០ ម៉ែត្រក្រឡា

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **(FA_{OL})**=៨៩.៣១៩,១២ – ៦០.៧២០,០០
= <u>២៨.៥៩៩,១២</u> ម៉ែត្រក្រឡា (៥)

ខ.ប្លង់ស្តាបត្យកម្មគម្រោងស្នើសុំសាងសង់(ឧទាហរណ៍ទី២)









ជួរឥដ្ឋទី២



ជួរឥដ្ឋទី៣



ជួរឥដ្ឋទី៤


5.10
9.70
10.40
7.80
7.80
6.80
8.75
8.70
8.75
8.70
8.85
7.45
8.70
6.27
4.48
4.75
2.80
6.65
127.45
ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរជាន់ទី៥


5.10
9.70
10.40
7.80
7.80
6.80
8.75
8.70
8.75
8.70
8.85
7.45
8.70
6.27
4.48
4.75
2.80
6.65
127.45
ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរជាន់ទី៦


5.10
9.70
10.40
7.80
7.80
6.80
8.75
8.70
8.75
8.70
8.85
7.45
8.70
6.27
4.48
4.75
2.80
6.65
127.45
ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរជាន់ទី៧


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរឈរទី៨


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរឈរទី៩


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរឈរទី១0 ដល់ជួរឈរទី១៣


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរឧបាសិកាទី១៨


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរឧបាសិកាទី១៩


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ជួរឧបាសិកាទី២០ ដល់ជាន់ទី៣៩


ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍
ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍
ចំណែកដីសិក្សា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង
ស្តីពីការផ្តល់សេវា សាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឆ្នាំ ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៣៣.ប.ន.ស.សហវ...ក្រ.បក

ប្រកាសអន្តរក្រសួង
ស្តីពី
ការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០, មាត្រា ៣៤, មាត្រា ៣៨, មាត្រា ៥០, មាត្រា ៦៦, មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្គាន់ដៃបង់ប្រាក់
- យោងតាមគោលការណ៍ឯកភាពរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ២០១៩ លើលិខិតលេខ ១២០៣១ សហវ.អទច ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសំណើសុំគោលការណ៍អនុញ្ញាត ដើម្បីលើកលែងការបង់កម្រៃសេវាសាធារណៈ គ្រប់ដំណាក់កាលនៃការចុះបញ្ជីដីតាំងពីដើមរហូតដល់ចប់ ចំពោះការចុះបញ្ជីលើដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ និងគុរភណ្ឌជាដីរបស់វត្ត លើកលែងតែដីដែលជាទ្រព្យសម្បត្តិរបស់សហគ្រាសសាធារណៈត្រូវបង់កម្រៃសេវាសាធារណៈជាធម្មតា
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .–

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

ប្រការ២ .–

សេវាសាធារណៈដែលផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវារយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ ភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

ប្រការ៣ .–

ចំពោះការចុះបញ្ជីដីលើកដំបូងលើ ដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគុរភណ្ឌជាដីរបស់វត្ត ត្រូវបានលើកលែងការយកកម្រៃសេវាសាធារណៈ ប៉ុន្តែដីដែលជាទ្រព្យសម្បត្តិរបស់សហគ្រាសសាធារណៈ ត្រូវបង់កម្រៃសេវាសាធារណៈជាធម្មតា។ ការលើកលែងការយកកម្រៃសេវាសាធារណៈនេះ មានអានុភាពប្រតិសកម្ម ប៉ុន្តែក្នុងករណីដែលកម្រៃសេវាសាធារណៈពាក់ព័ន្ធទាំងនេះ ត្រូវបានប្រមូលរួចហើយ មិនត្រូវបង្វិលសងវិញទេ។

ដើម្បីជំរុញការចុះបញ្ជីដីរដ្ឋឱ្យបានឆាប់រហ័ស អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំសំណើសុំចុះបញ្ជីដីដែលមានលក្ខណៈដាច់ដោយដុំ ដោយឡែកចំពោះដីដែលស្ថិតនៅក្នុងដំណាក់កាលចុះបញ្ជីដីដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបន្តនីតិវិធីរហូតដល់ចប់ជាស្ថាពរ។

ប្រការ៤ .–

ប្រភេទអគារដែលជាកម្មវត្ថុសម្រាប់ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ រួមមាន÷

១- អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ (លើសពី ១២ ជាន់ គិតទាំងជាន់ផ្ទាល់ដី)

២- អគារពាណិជ្ជកម្ម

៣- អគារពហុមុខងារ

៤- អគារបម្រើសេវាកម្មទេសចរណ៍

៥- អគារសណ្ឋាគារ។

ប្រការ៥ .–

នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៦ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសអន្តរក្រសួង និងកម្រងសេវាសាធារណៈដែលរួមមានឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

ប្រការ៧ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ត្រូវពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

ដោយឡែកចំពោះការផ្តល់សេវាសាធារណៈរបស់មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមយន្តការ និងនីតិវិធីដែលមានស្រាប់រហូតដល់មានការប្រមូលផ្តុំឱ្យធ្វើឡើងតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ៨ .–

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៩ .–

រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមសមត្ថកិច្ចប្រមូលចំណូលរៀងៗខ្លួន។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូកគណនី អនុគណនី នៃមាតិកាចំណូលថវិកា។

ប្រការ១០ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ១១ .-

កម្រងសេវាសាធារណៈដូចមានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ១២ .-

ប្រកាសអន្តរក្រសួងនេះ មានអានុភាពជំនួស ប្រកាសរួមលេខ ៦៤៨ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៣ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.....០១..... ខែ.ភទ្ទ្ធ..... ឆ្នាំ២០១៩ តទៅ។

ថ្ងៃអង្គារ ទី១៦ ខែ ឆេត្រ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ

គ្រាប់នីតិប្រកាសរួមលេខ ៧៧៥ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៩

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក. សេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខរៀង ចំនួនសេវា	បរិយាយ	តម្លៃសេវា (ជារៀល)		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
		ខណ្ឌក្នុងរាជធានី និងក្នុងក្រុង	ខណ្ឌជាយរាជធានី និងក្រៅក្រុង			
	I. សេវាសំណង់					
	១ លិខិតអនុញ្ញាតសាងសង់					
	១.១ សំណង់លំនៅឋាន ÷ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ					
១	- ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម²	១០ ០០០ ០០០	៩ ៨០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២	- ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម²	១០ ២០០ ០០០	១០ ០០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៣	- ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម²	១០ ៥០០ ០០០	១០ ៣០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៤	- ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម²	១០ ៨០០ ០០០	១០ ៥០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៥	- ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម²	១១ ០០០ ០០០	១០ ៨០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៦	- ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម²	១១ ២០០ ០០០	១០ ៩០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៧	- ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម²	១១ ៣០០ ០០០	១១ ០០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៨	- ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម²	១១ ៤០០ ០០០	១១ ១០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
៩	- ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម²	១១ ៥០០ ០០០	១១ ២០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១០	- ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម²	១១ ៦០០ ០០០	១១ ៣០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១១	- ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម²	១១ ៦៥០ ០០០	១១ ៣៥០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១២	- ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម²	១១ ៧០០ ០០០	១១ ៤០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា (ជារៀល)		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
			ខណ្ឌក្នុងរាជធានី និងក្នុងក្រុង	ខណ្ឌជាយរាជធានី និងក្រៅក្រុង			
១៣	-	ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម²	១១ ៧៥០ ០០០	១១ ៤៥០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១៤	-	ផ្ទៃក្រឡាសំណង់ លើសពី ៩០ ០០០ ម² ដល់ ១០០ ០០០ ម²	១១ ៨០០ ០០០	១១ ៥០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១៥	-	ផ្ទៃក្រឡាសំណង់ លើសពី ១០០ ០០០ ម²	បូកបន្ថែមក្នុង ១ម² ស្មើ ១១៨រៀល	បូកបន្ថែមក្នុង ១ម² ស្មើ ១១៥រៀល	៤៥ថ្ងៃ	១ឆ្នាំ	
	១.២	សំណង់ចំរុះ ÷ លំនៅឋាន+ ការិយាល័យ+ ពាណិជ្ជកម្ម+ ភោងចក្រ+ អប់រំ+ ពេទ្យ					
១៦	-	ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម²	១៥ ០០០ ០០០	១៤ ៨០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១៧	-	ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម²	១៥ ៧០០ ០០០	១៥ ៥០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១៨	-	ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម²	១៦ ៥០០ ០០០	១៦ ៣០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
១៩	-	ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម²	១៧ ២០០ ០០០	១៧ ០០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២០	-	ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម²	១៨ ០០០ ០០០	១៧ ៧០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២១	-	ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម²	១៩ ៥០០ ០០០	១៩ ២០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២២	-	ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម²	១៩ ៦៥០ ០០០	១៩ ៣៥០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២៣	-	ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម²	១៩ ៨០០ ០០០	១៩ ៦០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២៤	-	ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម²	១៩ ៩៥០ ០០០	១៩ ៦៥០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២៥	-	ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម²	២០ ១០០ ០០០	១៩ ៨០០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២៦	-	ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម²	២០ ១៧៥ ០០០	១៩ ៨៧៥ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២៧	-	ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម²	២០ ២៥០ ០០០	១៩ ៩៥០ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
២៨	-	ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម²	២០ ៣២៥ ០០០	២០ ០២៥ ០០០	៤៥ថ្ងៃ	១ឆ្នាំ	
	វ. ការចុះបញ្ជីអំពីការបិទអ្នសអចលនវត្ថុ "ការបិទអ្នសកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគការបិទអ្នសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគការបិទអ្នសផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" ដោយការអនុវត្តសិទ្ធិប្រាតិភោគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				

លេខរៀងចំនួនសេវា	បរិយាយ	តម្លៃសេវា (ជារៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
	ស. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ "ការលុបការរឹបអូសកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគការលុបការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួល អចិន្ត្រៃយ៍អវិភាគការលុបការរឹបអូសផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" ដោយការអនុវត្តសិទ្ធិប្រាតិភោគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	ហ. ការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួល អចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	ឪ. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែក កម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	អ. ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតនិងការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងៗទៀត ដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	ក១. ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន "កម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	១១. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន "កម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	គ១. ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	ឃ១. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដែលបានបង្កើតលើកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	ង១. ការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ "កម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ ផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" (ក្នុង ១ក្បាលដី/ប័ណ្ណ)				

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា (ជារៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
		ច១. ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ "កម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគផលុបភោគឬ ចំណែកផលុបភោគអវិភាគ" (ក្នុង ១ក្បាលដី/ប័ណ្ណ)				
		ឆ១. ការចុះបញ្ជីអំពីការបង្កើត ឬ ការកែប្រែ ឬ ការលុបនូវសិទ្ធិតាមសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ (ក្នុង ១ក្បាលដី/ប័ណ្ណ)				
	២២.១	ដីផលិតកម្ម កសិកម្ម				
៣៥៩	-	ដីក្នុងរាជធានី ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប	១២០ ០០០	១០ ថ្ងៃ		
៣៦០	-	ដីក្នុងក្រុងគ្រប់ខេត្តក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប	១០០ ០០០	១០ថ្ងៃ		
៣៦១	-	ដីជនបទ ឬ ក្រៅក្រុង	៨០ ០០០	១០ថ្ងៃ		
	២២.២	ដីលំនៅដ្ឋាន ឬ ដីសាងសង់				
៣៦២	-	ដីក្នុងរាជធានី ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប	២០០ ០០០	១០ថ្ងៃ		
៣៦៣	-	ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប	១៥០ ០០០	១០ថ្ងៃ		
៣៦៤	-	ដីជនបទ ឬ ក្រៅក្រុង	១០០ ០០០	១០ថ្ងៃ		

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា (ជារៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
	២៣	ក. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីលទ្ធកម្មន្ធវសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ការចុះបញ្ជី អំពីការលុបការ ចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន "កម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ ផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" (ក្នុង ១ក្បាលដី/បណ្ណ)				
		ខ. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីលទ្ធកម្មន្ធវសិទ្ធិ ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ការចុះបញ្ជី អំពីការលុបការចុះបញ្ជីអំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន "កម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍អវិភាគ ផលុបភោគ ឬ ចំណែកផលុបភោគអវិភាគ" ដោយការអនុវត្តសិទ្ធិប្រាតិភោគ (ក្នុង ១ក្បាលដី/បណ្ណ)				
	២៣.១	ដីផលិតកម្ម កសិកម្ម				
៣៦៥	-	ដីក្នុងរាជធានី ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប	៣០០ ០០០	១៥ថ្ងៃ		បើលើសពី ១ហិកតា បន្ថែម ៣០ ០០០រៀល ក្នុង ១ហិកតា ដែលលើស (ទំហំដែលលើសគិតជាចំនួនគត់ដោយមិនគិត ចំនួនក្រោយក្បៀស)
៣៦៦	-	ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្ត សៀមរាប	២០០ ០០០	១៥ថ្ងៃ		បើលើសពី ៥ហិកតា បន្ថែម ២០ ០០០រៀល ក្នុង ១ហិកតា ដែលលើស (ទំហំដែលលើសគិតជាចំនួនគត់ដោយមិនគិត ចំនួនក្រោយក្បៀស)
៣៦៧	-	ដីជនបទ ឬ ក្រៅក្រុង	១០០ ០០០	១៥ថ្ងៃ		បើលើសពី ៥ហិកតា បន្ថែម ១០ ០០០រៀល ក្នុង ១ហិកតា ដែលលើស (ទំហំដែលលើសគិតជាចំនួនគត់ដោយមិនគិត ចំនួនក្រោយក្បៀស)

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា (ជារៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
	២៣.២	ដីលំនៅដ្ឋាន ឬ ដីសាងសង់				
៣៦៨	-	ដីក្នុងរាជធានី ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប	៦០០ ០០០	១៥ថ្ងៃ		បើលើសពី ១ហិកតា បន្ថែម ៦០ ០០០រៀល ក្នុង ១ហិកតា ដែលលើស (ទំហំដែលលើសគិតជាចំនួនគត់ដោយមិនគិត ចំនួនក្រោយក្បៀស)
៣៦៩	-	ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប	៤០០ ០០០	១៥ថ្ងៃ		បើលើសពី ១ហិកតា បន្ថែម ៤០ ០០០រៀល ក្នុង ១ហិកតា ដែលលើស (ទំហំដែលលើសគិតជាចំនួនគត់ដោយមិនគិត ចំនួនក្រោយក្បៀស)
៣៧០	-	ដីជនបទ ឬ ក្រៅក្រុង	២០០ ០០០	១៥ថ្ងៃ		បើលើសពី ១ហិកតា បន្ថែម ២០ ០០០រៀល ក្នុង ១ហិកតា ដែលលើស (ទំហំដែលលើសគិតជាចំនួនគត់ដោយមិនគិត ចំនួនក្រោយក្បៀស)
	២៤	ផែនទីជាក្រដាស (ក្នុង ១សន្លឹក)				
៣៧១	-	ផែនទីឋានលេខាមាត្រដ្ឋាន ១/១០០ ០០០ ដែលមានស្រាប់	៤០ ០០០	០៣ថ្ងៃ		
៣៧២	-	សេវាបោះពុម្ពផែនទីរដ្ឋបាល នៃព្រះរាជាណាចក្រកម្ពុជា មាត្រដ្ឋាន ១/៦៥០ ០០០	៤០ ០០០	០៣ថ្ងៃ		

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា (ជារៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
	២៥	**រូបថតអ័ព្វហ្គូទម្រង់ឌីជីថល (ក្នុង ១ត.ម²)**				
៣៧៣	-	អង្គភាពរដ្ឋដែលស្នើទិញសម្រាប់តំបន់ជនបទ និងព្រៃ	២០ ០០០	០៣ថ្ងៃ		
៣៧៤	-	អង្គភាពរដ្ឋដែលស្នើទិញ សម្រាប់តំបន់ទីប្រជុំជន និងទីក្រុង	៤០ ០០០	០៣ថ្ងៃ		
៣៧៥	-	ឯកជនដែលស្នើទិញ សម្រាប់តំបន់ជនបទ និងព្រៃ	៨០ ០០០	០៣ថ្ងៃ		
៣៧៦	-	ឯកជនដែលស្នើទិញ សម្រាប់តំបន់ទីប្រជុំជន និងទីក្រុង	២០០ ០០០	០៣ថ្ងៃ		
៣៧៧	២៦	**រូបថតអ័ព្វហ្គូទម្រង់ជាក្រដាស បោះពុម្ពជាក្រដាសខ្នាត A0 (ក្នុង ១សន្លឹក)**	៥០ ០០០	០៣ថ្ងៃ		
	២៧	**ទិន្នន័យបង្គោលប្រឹថពីវិភាគ (ប្តង់ទីតាំង និងនិយាមក) (ក្នុង ១បង្គោល)**				
៣៧៨	-	ទិន្នន័យបង្គោលប្រឹថពីវិភាគ ថ្នាក់ជាតិលំដាប់សូន្យ	៦០ ០០០	០៣ថ្ងៃ		
៣៧៩	-	ទិន្នន័យបង្គោលប្រឹថពីវិភាគ ថ្នាក់ជាតិលំដាប់ទី ១	៦០ ០០០	០៣ថ្ងៃ		
៣៨០	-	ទិន្នន័យបង្គោលប្រឹថពីវិភាគ ថ្នាក់ជាតិលំដាប់ទី ២	៥០ ០០០	០៣ថ្ងៃ		
៣៨១	-	ទិន្នន័យបង្គោលប្រឹថពីវិភាគ ថ្នាក់ជាតិលំដាប់ទី៣	៤០ ០០០	០៣ថ្ងៃ		
៣៨២	-	ទិន្នន័យបង្គោលពហុកោណគោល	៣០ ០០០	០៣ថ្ងៃ		
	២៨	**ការចុះបញ្ជីផ្ទេរបន្ទុកដោយការបំបែក ឬ បង្រួមក្បាលដី (ក្នុង ១ក្បាលដី)**				
៣៨៣	២៨.១	ការចុះបញ្ជីផ្ទេរបន្ទុកដោយបំបែកក្បាលដី	២០០ ០០០	០៥ថ្ងៃ		បើលើសពី ១ប័ណ្ណ បន្ថែម ៨០ ០០០រៀល ក្នុង ១ប័ណ្ណ ដែលលើស (គិតចាប់ពីប័ណ្ណទី ២ ឡើងទៅ)
៣៨៤	២៨.២	ការចុះបញ្ជីផ្ទេរបន្ទុកដោយបង្រួមក្បាលដី	២០០ ០០០	០៥ថ្ងៃ		បើលើសពី ១ប័ណ្ណ បន្ថែម ៨០ ០០០រៀល ក្នុង ១ប័ណ្ណ ដែលលើស (គិតចាប់ពីប័ណ្ណទី ២ ឡើងទៅ)

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា (ជារៀល)	រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព	សេចក្តីផ្សេងៗ
	២៩	ការចុះបញ្ជីព័ត៌មានអំពីអាគារ ឬ សំណង់ (តាមការស្នើសុំ)				
៣៨៥	-	ផ្ទៃក្រឡាសំណង់ ចាប់ពី ៥០០ ម^{២} ចុះក្រោម	២០០ ០០០	៦០ថ្ងៃ		
៣៨៦	-	ផ្ទៃក្រឡាសំណង់ លើសពី ៥០០ ម^{២} ដល់ ៣ ០០០ ម^{២}	៤០០ ០០០	៦០ថ្ងៃ		
៣៨៧	-	ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម^{២}	៦០០ ០០០	៦០ថ្ងៃ		
	III. **សេវាផ្តល់វិញ្ញាបនបត្រជំរុញក្រុមជាងសំណង់**					
៣៨៨	១	វិញ្ញាបនបត្រលើកដំបូងសម្រាប់ក្រុមជាងសំណង់	៨០០ ០០០	០៧ ថ្ងៃ	៣ឆ្នាំ	
៣៨៩	២	បន្តសុពលភាពសម្រាប់ក្រុមជាងសំណង់	៦០០ ០០០	០៧ ថ្ងៃ	៣ឆ្នាំ	
៣៩០	៣	ការចេញប័ណ្ណទុតិយតា ឬ តតិយតា ចំពោះគ្រប់ប្រភេទប័ណ្ណ (ក្នុង ១ប័ណ្ណ)	គិត ២០% នៃតម្លៃផ្តល់ប័ណ្ណដែលបាត់	២០ ថ្ងៃ	ដូចកាលបរិច្ឆេទ	
	IV. **សេវាថតចម្លងឯកសារបង់**					
៣៩១	១	ឯកសារស្នើសុំសាងសង់ (ក្នុង ១ច្បាប់)	៤០ ០០០			
៣៩២	២	ប្លង់ស្ថាបត្យកម្ម ឬ ប្លង់គ្រឿងចិុសំណង់ (ក្នុង ១ច្បាប់)	៤០០ ០០០			
	V. **សេវាពិគ្រោះយោបល់លើផ្លែកច្បាប់ និងបច្ចេកទេស (តាមការស្នើសុំ)**					
៣៩៣	១	លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ (ក្នុង ១ករណី)	១ ០០០ ០០០			

កំណត់សំគាល់:

១- សេវាសាធារណៈដែលផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងស៊ុរិយោដីរាជធានី ខេត្ត ដែលកំណត់ក្នុងចំណុច ខ ខាងលើនេះ មិនត្រូវបានអនុវត្តចំពោះប្រភេទសេវាទាំងឡាយណា ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើប្រតិភូកម្មឱ្យទៅក្រុង ស្រុក ខណ្ឌ ដែលមានច្រកចេញចូលតែមួយឡើយ។ ចំពោះប្រភេទសេវាសាធារណៈ ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើប្រតិភូកម្មហត្ថលេខាទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមនីតិវិធីជាធរមាន។ ចំពោះរយៈពេលផ្តល់សេវាសរុបចំនួន ២៥ថ្ងៃ នៃថ្ងៃធ្វើការ គឺនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងស៊ុរិយោដីរាជធានី ខេត្ត ផ្តល់សេវាក្នុងរយៈពេល ២០ថ្ងៃ និងរដ្ឋបាលរាជធានី ខេត្ត ផ្តល់សេវាក្នុងរយៈពេល ៥ថ្ងៃ។

២- សំណង់ដែលមិនតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតសាងសង់ និងមិនតម្រូវឱ្យបង់ថ្លៃសេវាសំណង់រួមមាន ÷ សំណង់ប្រជាពលរដ្ឋ ជាពិសេសលំនៅឋាន ប្រជាជនក្រីក្រ រាល់សំណង់តូចតាចធ្វើពី ឈើ ឬ ស្លឹករុក្ខជាតិនានា និងសំណង់បណ្តោះអាសន្ន (រោងបង្ហា ក្បុះ ដែលធ្វើពីឈើ ឬ ដែក)។ សំណង់ជាលំនៅឋានប្រជាពលរដ្ឋ ដែលស្ថិតនៅទីជនបទ ឬ តំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់យុទ្ធសាស្ត្រជាតិ តំបន់រក្សាទុកការពារដោយ ពុំគិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់ឡើយ។ ការជួលជុល និងថែរក្សាទាំងឡាយដែល មិនជ្ជាស់ប្តូរទ្រង់ទ្រាយ ឬ ទិដ្ឋភាពសំណង់លើកលែងតែការជួយជួលនោះអាចបណ្តាលអោយប៉ះពាល់ដល់អ្នកជិតខាង។

៣- ខណ្ឌក្នុងរាជធានី និងក្រុង សំដៅ ខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌ៧មករា ខណ្ឌទួលគោក និងក្រុងក្នុងខេត្តទាំងអស់។

៤- ខណ្ឌជាយរាជធានី និងទីរួមស្រុក សំដៅ ខណ្ឌសែនសុខ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌច្បារអំពៅ ខណ្ឌឫស្សីកែវ ខណ្ឌព្រែកព្នៅ ខណ្ឌជ្រោយចង្វារ ខណ្ឌមានជ័យ និងឃុំទីរួមស្រុក។

៥- ក្រៅក្រុង និងក្រៅទីរួមស្រុក សំដៅ ទីកន្លែងក្រៅពីក្រុង និងក្រៅឃុំទីរួមស្រុក។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង
ស្តីពី
នីតិវិធីនៃការធ្វើអធិការកិច្ច
សំណង់

ឆ្នាំ ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងយុត្តិធម៌

លេខ.....ប.ន.ស. - ក២

ប្រកាសអន្តរក្រសួង

ស្តីពី

នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រដ្ឋមន្ត្រី
ក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រ៥០ មាត្រ៦៦ មាត្រា៧៤ មាត្រ៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១ ..

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុឱ្យមានប្រសិទ្ធភាព គុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងបរិស្ថានសម្រាប់ការរស់នៅតាមរយៈការបង្ការនិងទប់ស្កាត់អំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់។

ប្រការ២ ..

ប្រកាសនេះ មានគោលដៅកំណត់អំពីនីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចនៃការអភិវឌ្ឍអចលនវត្ថុ។

ប្រការ៣ ..

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះ មានដូចខាងក្រោម÷

១-ការធ្វើអធិការកិច្ចសំណង់ សំដៅដល់ការតាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យការអភិវឌ្ឍអចលនវត្ថុ ដើម្បីចាត់វិធានការឬដាក់ទណ្ឌកម្មលើបុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់។

២-ការពិន័យអន្តរការណ៍ សំដៅដល់ការដាក់ទណ្ឌកម្មឱ្យបុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់ បង់ប្រាក់ជូនរដ្ឋ។

៣-ការអភិវឌ្ឍអចលនវត្ថុ សំដៅដល់ ÷

- ការសាងសង់សំណង់ថ្មី ការជួសជុល ការសាងសង់ឡើងវិញ ការពង្រីកអគារ ការសាងសង់បន្ថែមពីលើអគារដែលមានស្រាប់ ការរុះរើ ការប្តូរមុខងារប្រើប្រាស់អគារ ការប្តូរទ្រង់ទ្រាយអគារ ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់ និងការកែប្រែទិដ្ឋភាពខាងក្រៅនៃអគារដែលមានស្រាប់
- ការសាងសង់ឬប្តូរទ្រង់ទ្រាយអគារដែលអាចបង្កគ្រោះថ្នាក់អគ្គិភ័យ មានជាអាទិ៍ ស្ថានីយ៍ ដេប៉ូ កន្លែងស្តុក ឬចែកចាយផលិតផលតេលសិលា ឬឧស្ម័ន ហោងជាង ផលិតផលគ្រឿងឆេះ
- ការដាក់ស្លាកសញ្ញាផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍និងទូរគមនាគមន៍ ក្នុងគោលបំណងធ្វើពាណិជ្ជកម្មក៏ដូចជាការដាក់រចនាសម្ព័ន្ធនៅលើដីនិងអគារ
- ការអភិវឌ្ឍដី មានដូចជា ការប្តូរប្រភេទនៃការប្រើប្រាស់ដីដើម្បីគម្រោងសាងសង់ ការកែសម្រួលក្បាលដី ការរៀបចំគម្រោងបែងចែកជាដីឡូត៍ ការកែប្រែរចនាសម្ព័ន្ធដី ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍតំបន់លំនៅឋានឬបុរីនិងអគារស្នាក់នៅ ការអភិវឌ្ឍតំបន់ពាណិជ្ជកម្មនិង/ឬសេវាកម្ម និងតំបន់ចម្រុះ ការអភិវឌ្ឍតំបន់ឧស្សាហកម្ម ស្មនឧស្សាហកម្ម និងរោងចក្រ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ការអភិវឌ្ឍតំបន់ទេសចរណ៍ និងការអភិវឌ្ឍនានា
- ការផ្លាស់ប្តូរលក្ខណៈគតិយុត្តផ្សេងៗទៀត មានជាអាទិ៍ ការពន្យារសុពលភាពនៃលិខិតអនុញ្ញាតដែលហួសសុពលភាព ការផ្ទេរឈ្មោះក្នុងលិខិតអនុញ្ញាត។

៤-បទប្បញ្ញត្តិស្តីពីនគរូបនីយកម្មនិងសំណង់ សំដៅដល់វិធានពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុដែលមានចែងក្នុងអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ មាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

៥-មន្ត្រីអធិការកិច្ចសំណង់ សំដៅដល់មន្ត្រីរាជការជំនាញថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាវិស្វករឬស្ថាបត្យករ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលបានការតែងតាំង និងប្រគល់បេសកកម្មឱ្យចុះធ្វើអធិការកិច្ចសំណង់។

៦-អង្គភាពមានសមត្ថកិច្ច សំដៅដល់អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។

៧-លិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ សំដៅដល់លិខិតអនុញ្ញាតអភិវឌ្ឍដី ឬលិខិតអនុញ្ញាតសាងសង់ ឬរុះរើ។

ជំពូកទី២
សមត្ថកិច្ច

ប្រការ៤ ..

មន្ត្រីអធិការកិច្ចសំណង់ មានដូចខាងក្រោម÷

១-ថ្នាក់ដឹកនាំជាវិស្វករឬស្ថាបត្យករនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២-មន្ត្រីជំនាញជាវិស្វករឬស្ថាបត្យករនៃអគ្គនាយកដ្ឋានសំណង់និងអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៣-មន្ត្រីជំនាញជាវិស្វករឬស្ថាបត្យករនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត។

៤-មន្ត្រីជំនាញជាវិស្វករឬស្ថាបត្យករនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ។

សមាសភាពមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៣
អធិការកិច្ចសំណង់

ប្រការ៥ ..

អាជ្ញាធរមានសមត្ថកិច្ច ជាអ្នកសម្រេចធ្វើអធិការកិច្ចសំណង់។

អាជ្ញាធរមានសមត្ថកិច្ច មានដូចខាងក្រោម÷

១-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះការអភិវឌ្ឍអចលនវត្ថុគ្រប់ប្រភេទនិងទំហំ។

២-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ចំពោះការអភិវឌ្ឍអចលនវត្ថុដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត។

៣-អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចំពោះការអភិវឌ្ឍអចលនវត្ថុដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

មានតែប្រធានអង្គភាពមានសមត្ថកិច្ចប៉ុណ្ណោះ ដែលអាចលើកសំណើធ្វើអធិការកិច្ចសំណង់ទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រការ៦ ..

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់រាជធានី ខេត្ត តាមសំណើរបស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាអ្នកចេញលិខិតបញ្ជាបេសកកម្មចុះធ្វើអធិការកិច្ចសំណង់ ជូនមន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ តាមសំណើរបស់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។

ប្រការ៧ ..

រាល់ការធ្វើអធិការកិច្ចសំណង់ ត្រូវមានការចូលរួមពីមន្ត្រីអធិការកិច្ចសំណង់ចំនួន÷

- ៥ (ប្រាំ) នាក់ យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ៣ (បី) នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង
- ១ (មួយ) នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចសំណង់សម្រេចដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ប្រការ៨ ..

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ទីតាំង។

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងការដ្ឋានសំណង់បាន លុះត្រាតែការដ្ឋានសំណង់កំពុងដំណើរការ។

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងអគារឬសំណង់ដែលបើកចំហរដល់សាធារណជនតែនៅក្នុងម៉ោងធ្វើការនៅទីតាំងនោះ។

មន្ត្រីអធិការកិច្ចសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងអចលនវត្ថុឯកជន នៅក្រោយម៉ោង ៦ (ប្រាំមួយ) ព្រឹក និងមុនម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច។

ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការធ្វើអធិការកិច្ចសំណង់ នៅក្រៅម៉ោងពេលដូចមានកំណត់ក្នុងប្រការនេះ មន្ត្រីអធិការកិច្ចសំណង់ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

ប្រការ៩ ..

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចសំណង់ត្រូវមានលិខិតបញ្ជាបេសកកម្ម ស្លៀកពាក់ឯកសណ្ឋាន និងមានសញ្ញាសម្គាល់។

ប្រការ១០ ..

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចសំណង់ ត្រូវអនុវត្តដូចខាងក្រោម÷

- ត្រួតពិនិត្យនិងអង្កេតអំពីអនុលោមភាពនៃការអភិវឌ្ឍដី និង/ឬការងារសាងសង់ឬរុះរើសំណង់តាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- ត្រួតពិនិត្យការប្រកបអាជីវកម្មរបស់រូបវន្តបុគ្គលឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ និងក្រុមជាងសំណង់
- ត្រួតពិនិត្យសុវត្ថិភាពការងារនៅខាងក្នុងនិងជុំវិញបរិវេណការដ្ឋានសំណង់
- ត្រួតពិនិត្យឯកសារពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍដីនិង/ឬគម្រោងសាងសង់ឬរុះរើសំណង់ ដូចជាឯកសារបញ្ជាក់កម្មសិទ្ធិឬការកាន់កាប់ដី លិខិតអនុញ្ញាតអភិវឌ្ឍដី និង/ឬលិខិតអនុញ្ញាតសាងសង់ឬរុះរើ គម្រោងប្លង់ស្ថាបត្យកម្ម លិខិតអនុញ្ញាតបើកឬបិទការដ្ឋានសាងសង់ គម្រោងប្លង់គ្រឿងធ្លុំសំណង់និងឯកសារបច្ចេកទេសពាក់ព័ន្ធ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន និងកិច្ចសន្យាម៉ៅការសាងសង់
- ស្នើសុំឱ្យម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុផ្តល់ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ ជាងជំនាញ និង/ឬក្រុមជាងសំណង់ ដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍដីនិង/ឬគម្រោងសាងសង់ឬរុះរើ
- ណែនាំឱ្យម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ ធ្វើការកែតម្រូវតាមលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ

- ណែនាំអ្នកគ្រប់គ្រងការដ្ឋានឱ្យចាត់វិធានការបន្ទាន់ដើម្បីបញ្ឈៀសគ្រោះថ្នាក់ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈជាយថាហេតុ នៅខាងក្នុងនិងជុំវិញបរិវេណការដ្ឋានសំណង់
- ណែនាំរូបវន្តបុគ្គលឬក្រុមហ៊ុនសិក្សាគម្រោងប្តង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់អំពីបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុ
- ធ្វើកំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់
- ប្រតិបត្តិការងារផ្សេងទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចប្រគល់ជូន។

ប្រការ១១ ..

កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះធ្វើអធិការកិច្ច។

កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ របស់មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រោមជាតិដែលដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចតាមរយៈប្រធានអង្គភាពមានសមត្ថកិច្ច ត្រូវចម្លងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ១២ ..

កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ÷

- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គលឬក្រុមហ៊ុនសិក្សាគម្រោងប្តង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់
- ព័ត៌មានអំពីគម្រោងអភិវឌ្ឍដី ឬគម្រោងសាងសង់ឬរុះរើ
- លទ្ធផលនៃការផ្ទៀងផ្ទាត់អំពីអនុលោមភាពចំពោះលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ អ្នកគ្រប់គ្រងការដ្ឋាន និង/ឬម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

គំរូទម្រង់កំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ជាឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ។

ប្រការ១៣ ..

របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ដែលធ្វើជូនអាជ្ញាធរមានសមត្ថកិច្ត ត្រូវមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ÷

- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គលឬក្រុមហ៊ុន

សិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់

- ព័ត៌មានអំពីគម្រោងអភិវឌ្ឍដី ឬគម្រោងសាងសង់ឬរឺ
- លទ្ធផលនៃការផ្ទៀងផ្ទាត់អំពីអនុលោមភាពចំពោះលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ
- ការសន្និដ្ឋានចំពោះលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់
- ការលើកសំណើជាវិធានការនិង/ឬទណ្ឌកម្មជូនអាជ្ញាធរមានសមត្ថកិច្ចពិនិត្យនិងសម្រេច
- ហត្ថលេខារបស់មន្ត្រីអធិការកិច្ចសំណង់ និងហត្ថលេខារបស់ប្រធានអង្គភាពមានសមត្ថកិច្ច និងត្រារបស់អង្គភាពមានសមត្ថកិច្ច។

ក្នុងករណីមន្ត្រីអធិការកិច្ចសំណង់លើកសំណើធ្វើការពិន័យអន្តរការណ៍ របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវមានខ្លឹមសារបន្ថែមដូចខាងក្រោម÷

- ប្រភេទអំពើល្មើសដោយមានបញ្ជាក់អំពីទំហំ រយៈពេល ផលប៉ះពាល់ និងព័ត៌មានចាំបាច់ផ្សេងទៀត
- អត្តសញ្ញាណម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង/ឬក្រុមហ៊ុនសាងសង់ ដែលប្រព្រឹត្តអំពើល្មើស
- បទប្បញ្ញត្តិដែលកំណត់អំពីការពិន័យអន្តរការណ៍
- ចំនួនទឹកប្រាក់ដែលត្រូវពិន័យអន្តរការណ៍។

គំរូទម្រង់របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ជាឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

ប្រការ១៤ ..

ក្នុងករណីពិនិត្យឃើញថា ការអភិវឌ្ឍអចលនវត្ថុកំពុងដំណើរការដោយមិនអនុលោមតាមលិខិតអនុញ្ញាត បទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន របាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ត្រូវលើកសំណើចាត់វិធានការនិង/ឬដាក់ទណ្ឌកម្មមួយឬច្រើនដូចខាងក្រោម÷

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកការដ្ឋានសាងសង់
- ការព្យួរឬដកលិខិតអនុញ្ញាតអភិវឌ្ឍដី និង/ឬលិខិតអនុញ្ញាតសាងសង់ឬរឺ លិខិតអនុញ្ញាតបើកឬបិទការដ្ឋានសាងសង់ ឬវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់
- ការហាមឃាត់ការប្រើប្រាស់ ឬធ្វើអាជីវកម្មពាក់ព័ន្ធនឹងសំណង់
- ការឃាត់ទុកជាបណ្តោះអាសន្នសម្ភារ ផលិតផល បរិក្ខារ និង/ឬគ្រឿងចក្រពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើល្មើស

- ការបង្ខំឱ្យរុះរើឬស្ថាបនាឡើងវិញឱ្យដូចស្ថានភាពដើម នូវអ្វីដែលប្រែប្រួលឬបាត់បង់ដោយអំពើល្មើស
- ការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តអំពើល្មើស
- ការចាត់វិធានការផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ១៥ ៖

អាជ្ញាធរមានសមត្ថកិច្ច ត្រូវសម្រេចចាត់វិធានការ និង/ឬដាក់ទណ្ឌកម្មចំពោះបុគ្គលប្រព្រឹត្តអំពើល្មើសដោយផ្អែកលើកំណត់ហេតុនៃការចុះធ្វើអធិការកិច្ចសំណង់ និងរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចសំណង់ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើរបាយការណ៍នោះ។

ក្នុងករណីបុគ្គលមិនអនុវត្តវិធានការនិង/ឬទណ្ឌកម្មដែលអាជ្ញាធរមានសមត្ថកិច្ចបានតម្រូវ អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការដើម្បីស្នើសុំចាត់វិធានការអនុវត្តដោយបង្ខំ។

ប្រការ១៦ ៖

មន្ត្រីអធិការកិច្ចសំណង់ មិនត្រូវធ្វើសកម្មភាពដូចខាងក្រោម÷

- បង្កឱ្យមានការប៉ះពាល់ឬរាំងស្ទះដល់ដំណើរការអភិវឌ្ឍ ឬសាងសង់ ឬរុះរើ ដែលអនុលោមតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាននៅក្នុងពេលបំពេញសកម្មភាពអធិការកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានដែលពាក់ព័ន្ធនឹងបច្ចេកទេសសាងសង់ និងកិច្ចសន្យាម៉ៅការសាងសង់។

ប្រការ១៧ ៖

នៅអំឡុងពេលនៃការធ្វើអធិការកិច្ចសំណង់ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ និង/ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្តង់ និង/ឬក្រុមហ៊ុនសាងសង់ និង/ឬក្រុមជាងសំណង់ និង/ឬតំណាងមានកាតព្វកិច្ច ដូចខាងក្រោម÷

- ផ្តល់កិច្ចសហការប្រកបដោយសុឆន្ទៈក្នុងការធ្វើអធិការកិច្ចសំណង់
- អនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចសំណង់ ចូលត្រួតពិនិត្យគ្រប់ទីកន្លែងទាំងអស់នៅក្នុងការដ្ឋាន
- មិនរារាំង ហាមឃាត់ ឬបង្កការលំបាកដល់ការធ្វើអធិការកិច្ចសំណង់

- មានវត្តមាននៅក្នុងពេលប្រតិបត្តិការអធិការកិច្ចសំណង់ តាមសំណើរបស់មន្ត្រីអធិការកិច្ចសំណង់
- ផ្តល់ព័ត៌មានទូទៅពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍអចលនវត្ថុ តាមសំណើរបស់មន្ត្រីអធិការកិច្ចសំណង់ ជាអាទិ៍អំពីគ្រប់ភាគីពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- ឆ្លើយបំភ្លឺ ពន្យល់ ផ្តល់ព័ត៌មាននិងឯកសារ ឬផ្តល់សេចក្តីអះអាងពាក់ព័ន្ធនឹងការគោរពនិងអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍអចលនវត្ថុរបស់ខ្លួនប្រកបដោយសីលធម៌ សុចរិតភាព និងការទទួលខុសត្រូវ
- ចាត់វិធានការសមស្របដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់មន្ត្រីអធិការកិច្ចសំណង់ក្នុងពេលបំពេញការងារអធិការកិច្ចនៅក្នុងទីតាំងគម្រោង ឬការដ្ឋានសាងសង់ ឬសំណង់របស់ខ្លួន
- ផ្តល់នូវសំណាកនៃសម្ភារ បរិក្ខារ ផលិតផលសំណង់ ឧបករណ៍ ឬគ្រឿងចក្រផ្សេងទៀតដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនិងការធ្វើវិភាគផ្ទៀងផ្ទាត់។

ប្រការ១៨ ..

ក្នុងពេលប្រតិបត្តិការអធិការកិច្ចសំណង់ ម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ ឬរូបវន្តបុគ្គល ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ ឬក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់ ឬតំណាងមានសិទ្ធិដូចខាងក្រោម÷

- ស្នើសុំមន្ត្រីអធិការកិច្ចសំណង់បង្ហាញលិខិតបញ្ជាបេសកកម្ម
- ស្នើសុំមន្ត្រីអធិការកិច្ចសំណង់ កត់ត្រារាល់ការឆ្លើយតបឬសេចក្តីអះអាងរបស់ខ្លួននៅក្នុងកំណត់ហេតុនៃការធ្វើអធិការកិច្ចសំណង់
- ទទួលបានច្បាប់ចម្លងនៃកំណត់ហេតុអធិការកិច្ចសំណង់។

ជំពូកទី៤
បណ្តឹងតវ៉ា

ប្រការ១៩ ..

បុគ្គលដែលមិនសុខចិត្តចំពោះការចាត់វិធានការ និង/ឬដាក់ទណ្ឌកម្មរបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់ អាចធ្វើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរនោះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬបានទទួលដំណឹងអំពីសេចក្តីសម្រេចចាត់វិធានការនិង/ឬដាក់ទណ្ឌកម្ម។ អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់ ត្រូវធ្វើការសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹងតវ៉ា។

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់ មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលកំណត់ដូចមានចែងក្នុងប្រការនេះ ម្ចាស់បណ្តឹងអាចធ្វើបណ្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់តាមឋានានុក្រម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

ម្ចាស់បណ្តឹងអាចធ្វើបណ្តឹងតវ៉ាចំពោះការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចធ្វើអធិការកិច្ចសំណង់តាមឋានានុក្រម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬបានទទួលដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងតវ៉ារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួនលើបណ្តឹងតវ៉ា ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនសម្រេចលើបណ្តឹងតវ៉ា ម្ចាស់បណ្តឹងមានសិទ្ធិប្តឹងទៅតុលាការ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួនលើបណ្តឹងតវ៉ា ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួនលើបណ្តឹងតវ៉ា ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលប្រព្រឹត្តអំពើល្មើសមិនបង់ប្រាក់ពិន័យអន្តរការណ៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូង នៅពេលផុតរយៈពេលនៃបណ្តឹងតវ៉ាដូចមានកំណត់ក្នុងប្រការនេះ។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

ប្រការ២០ ..

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមិនទាន់មានប្លង់គោលប្រើប្រាស់ដី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ នោះ គ្មានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការអភិវឌ្ឍដីទេ។ ក្នុងករណីនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអាជ្ញាធរមានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការអភិវឌ្ឍដីនោះ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលមិនទាន់មានសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ជួសជុល និងរុះរើ និងលិខិតអនុញ្ញាតបើកនិងបិទការដ្ឋាន គ្មានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការងារសាងសង់ឬរុះរើទេ។ ក្នុងករណីនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអាជ្ញាធរមានសមត្ថកិច្ចសម្រេចធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការងារសាងសង់ឬរុះរើ តាមសំណើរបស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត។

ជំពូកទី៦
អវសានប្បញ្ញត្តិ

ប្រការ២១ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ២២ ..

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤កើត ខែភាទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី	**រដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	**ក្រសួងយុត្តិធម៌**
ជា សុជារ៉ា	អង្គ វង្ស វឌ្ឍានា

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ២២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១១៤ ប្រក/អន្តរ.ស.ធ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៩ ស្តីពី
នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

.....[1]

កំណត់ហេតុ
ស្តីពី
ការចុះធ្វើអធិការកិច្ចសំណង់

ឆ្នាំ.....ពុទ្ធសករាជពីរពាន់ប្រាំរយ.....ខែ.....ឆ្នាំ.....ត្រូវនឹងឆ្នាំពីរពាន់.....ខែ.....ថ្ងៃ.....ក្រុមមន្ត្រីអធិការកិច្ចសំណង់របស់[2] សហការជាមួយរដ្ឋបាល.....បានចុះធ្វើអធិការកិច្ចសំណង់ នៅការដ្ឋាន.....គម្រោង.....តំណាងដោយលោក/លោកស្រី.....ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ.....ផ្លូវ.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក.....រាជធានី/ខេត្ត..... ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ/បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....។

ទី ១. ក្រុមការងារបានចុះពិនិត្យការដ្ឋានសាងសង់ឃើញថា÷

- លិខិតអនុញ្ញាតសាងសង់.....
- លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់.....
- ការហ៊ុំព័ទ្ធការដ្ឋានសាងសង់.....
- អនាម័យការដ្ឋានសាងសង់.....
- លក្ខណៈនគរូបនីយប្បញ្ញត្តិ÷

នគរូបនីយប្បញ្ញត្តិ	ប្លង់អនុញ្ញាតដោយក្រសួង	សាងសង់ជាក់ស្តែង	មតិវាយតម្លៃ
ក. ផ្នែកម្ភាគអគារ			
ផ្នែកម្ភាគខាង.....	____ ម៉ែត្រ	____ ម៉ែត្រ	
ផ្នែកម្ភាគខាង.....	____ ម៉ែត្រ	____ ម៉ែត្រ	
ផ្នែកម្ភាគខាង.....	____ ម៉ែត្រ	____ ម៉ែត្រ	
ផ្នែកម្ភាគខាង.....	____ ម៉ែត្រ	____ ម៉ែត្រ	

[1] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ

[2] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ

ខ.កម្ពស់អគារ			
គិតជាជាន់			
គិតជាម៉ែត្រ			
គ.មុខងារប្រើប្រាស់អគារ			
មុខងារប្រើប្រាស់អគារ			
ឃ.ចំណតរថយន្ត			
ចំណតរថយន្តតូច			
ចំណតរថយន្តធំ			
ង.ហេដ្ឋារចនាសម្ព័ន្ធ			
អាងប្រព្រឹត្តកម្មទឹកកខ្វក់			
អាងបង្កន់អនាម័យ			
ប្រព័ន្ធលូ			
ប្រព័ន្ធពន្លត់អគ្គិភ័យ			
សួនជ្រាបទឹក			
ច.បទប្បញ្ញត្តិពាក់ព័ន្ធ			

ទី ២.មតិក្រុមការងារចុះពិនិត្យ÷

.....

ទី ៣.ក្រុមការងារបានណែនាំ និងបានតម្រូវឱ្យម្ចាស់សំណង់អនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម÷

១.អនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតអនុញ្ញាតសាងសង់ លិខិតបើកការដ្ឋានសាងសង់ និងបទដ្ឋានគតិយុត្ត នគរូបនីយកម្ម និងសំណង់។

២.សេចក្តីណែនាំ និងវិធានការ.....

ទី ៤.ម្ចាស់សំណង់បានស្តាប់ បានអាន និងបានឯកភាពអនុវត្តតាមសេចក្តីណែនាំ និងវិធានការ ដូចមានចែងក្នុងចំណុច ទី៣ ខាងលើ។

ឈ្មោះ **តួនាទី** **ហត្ថលេខា/ស្នាមមេដៃ**

១.....

២.....

ទី ៥. សមាសភាពក្រុមការងារចុះត្រួតពិនិត្យ រួមមាន÷

ឈ្មោះ	តួនាទី	ហត្ថលេខា
១.....		
២.....		

ការចុះត្រួតពិនិត្យនេះ ត្រូវបានបញ្ចប់នៅវេលាម៉ោង..... នាទី..... នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងទទួលខុសត្រូវខ្ពស់៕

ថ្ងៃ.....ខែ.....ឆ្នាំ.....ព.ស. ២៩.....
ធ្វើនៅ..... ថ្ងៃទី.....ខែ.....ឆ្នាំ២០....

អ្នកធ្វើកំណត់ហេតុ

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ២០១៩ ស្តីពី នីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

.....[1]

លេខ:.....ពអ/.....

សូមគោរពជូន

.....[2]

តាមរយៈ÷ .....[3]

កម្ងវត្ថុ ÷ របាយការណ៍ស្តីពីលទ្ធផលនៃចុះធ្វើអធិការកិច្ចសំណង់ នៅការដ្ឋាន.....គម្រោង.....
តំណាងដោយលោក/លោកស្រី.....ដែលមានទីតាំងស្ថិតនៅ.....

យោង ÷-លិខិតបញ្ជាបេសកកម្មលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
-បណ្តឹងឥវ៉ាចុះថ្ងៃទី.....ខែ.....ឆ្នាំ.....របស់.....

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន[4] មេត្តាជ្រាបថា កាលពីថ្ងៃទី.....ខែ.....ឆ្នាំ.....វេលាម៉ោង.....ក្រុមមន្ត្រីអធិការកិច្ចសំណង់ ដឹកនាំដោយ.....បានចុះធ្វើអធិការកិច្ចនៅការដ្ឋាន.....គម្រោង.....របស់លោក.....ឬក្រុមហ៊ុន..... តំណាងដោយលោក/លោកស្រី.....ដែលមានទីតាំងស្ថិតនៅ.....។

ក-សមាសភាពចូលរួម÷

១-លោក.....តួនាទី.....
២-លោក.....តួនាទី.....

[1] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌ

[2] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

[3] អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ឬប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬប្រធានការិយាល័យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ

[4] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ខ-លទ្ធផលនៃការធ្វើអធិការកិច្ច÷

ក្រុមហ៊ុនឬលោក.....ជាម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ លើគម្រោង.....។

ក្រោយការពិនិត្យផ្ទៀងផ្ទាត់គម្រោង.....មានកំហុសឆ្គង ដូចខាងក្រោម÷

១.....

២.....

គ-សន្និដ្ឋាន ÷

ក្រុមហ៊ុនឬលោក.....ជាម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ បានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម÷

១-ធ្វើការសាងសង់ឬរុះរើ ឬអភិវឌ្ឍ.....ល្មើសនឹងមាត្រា.....នៃអនុក្រឹត្យលេខ.....

២-ធ្វើការសាងសង់ឬរុះរើ ឬអភិវឌ្ឍ.....ល្មើសនឹងមាត្រា.....នៃអនុក្រឹត្យលេខ.....

ឃ-មតិ÷

គួរសម្រេចឱ្យលោកឬក្រុមហ៊ុន..... តំណាងដោយលោក/លោកស្រី .....

ជាម្ចាស់សំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ÷

១-បង់ប្រាក់ពិន័យអន្តរការណ៍ចំនួន.....តាមមាត្រា.....នៃអនុក្រឹត្យលេខ.....។

២-សម្រេចចាត់វិធានការ.....តាមមាត្រា.....នៃអនុក្រឹត្យលេខ.....។

ថ្ងៃ.....ខែ.....ឆ្នាំ.....ព.ស. ២៥.....

ធ្វើនៅ.....ថ្ងៃទី..... ខែ.....ឆ្នាំ ២0.....

អ្នកធ្វើរបាយការណ៍

បានឃើញនិងឯកភាព

សូមគោរពជូន[៥] មេត្តាពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់។

សូមគោរពជូន[៦] មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

ថ្ងៃ.....ខែ.....ឆ្នាំ.....ព.ស. ២៥.....

ធ្វើនៅ.....ថ្ងៃទី..... ខែ.....ឆ្នាំ ២0.....

[៧]

.....

---

[៥] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

[៦] រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

[៧] អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ឬប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬប្រធានការិយាល័យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីបែបបទនិងនីតិវិធីនៃការ ផ្តល់ ការព្យួរ និងការដកហូត វិញ្ញាបនបត្រទាស់ទែង

ឆ្នាំ ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ.....ប.ន.ស.ប្រក.

ប្រកាស
ស្តីពី
បែបបទនិងនីតិវិធីនៃការផ្តល់ ការពួរ និងការដកហូតវិញ្ញាបនបត្រទាស់ទែង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញប្រកាសលេខ ២០០ ដនស.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១ ..

ប្រកាសនេះមានគោលបំណង ៖

- ធានាប្រសិទ្ធភាពនៃការរៀបចំផែនការរៀបចំដែនដី នគរូបនីយកម្ម និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ធានាភាពជាក់លាក់នៃលទ្ធផលការងារវាស់វែងនិងផលិតផែនទី
- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការវាស់វែងនិងការផលិតផែនទី
- បង្ការនិងទប់ស្កាត់ការផ្សព្វផ្សាយ ការប្រើប្រាស់ជាសាធារណៈនូវផែនទី និងទិន្នន័យវាស់វែងដែលមិនត្រឹមត្រូវ និងគ្មានការអនុញ្ញាត។

ប្រការ២ ..

ប្រកាសនេះមានគោលដៅ ៖

- កំណត់កម្រិតវិញ្ញាបនបត្រវាស់វែងសម្រាប់អ្នកវាស់វែង
- កំណត់បែបបទនិងនីតិវិធីនៃការផ្តល់ ការពង្រួរ និងការដកហូតវិញ្ញាបនបត្រវាស់វែង។

ប្រការ៣ ..

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលដែលធ្វើសកម្មភាពវាស់វែង និង/ឬផលិតផែនទី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ៤ ..

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម ៖

- **វិញ្ញាបនបត្រវាស់វែង** សំដៅដល់លិខិតទទួលស្គាល់សមត្ថភាពវាស់វែងរបស់រូបវន្តបុគ្គលដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- **អ្នកវាស់វែងអាស៊ាន** សំដៅដល់អ្នកវាស់វែងនៃបណ្តារដ្ឋជាសមាជិកអាស៊ានដែលទទួលបានការវាយតម្លៃគុណវុឌ្ឍិនិងបទពិសោធន៍ដោយអនុលោមតាមអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសសាមី ហើយបានចុះបញ្ជីនៅគណៈកម្មាធិការអាជ្ញាធរមានសមត្ថកិច្ចអាស៊ាន។

ជំពូកទី២
គោលការណ៍នៃការជាស់វែង

ប្រការ៥ ..

រូបវន្តបុគ្គលដែលអាចធ្វើការវាស់វែងបាន ត្រូវមានវិញ្ញាបនបត្រវាស់វែងផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

វិញ្ញាបនបត្រវាស់វែងអាចផ្តល់ជូនមន្ត្រីសាធារណៈដែលកំពុងបម្រើការក្នុងក្រសួង ស្ថាប័នរដ្ឋ និងរូបវន្តបុគ្គលឯកជន។

អ្នកវាស់វែងអាស៊ាន អាចបំពេញមុខងារជាអ្នកវាស់វែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនតម្រូវឱ្យមានវិញ្ញាបនបត្រវាស់វែងឡើយ។

ជនបរទេសក្រៅពីអ្នកវាស់វែងអាស៊ាន ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចធ្វើការវាស់វែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន។

ប្រការ៦ ..

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវាស់វែង មាននីតិសម្បទាដូចខាងក្រោម ៖

- អនុវត្តការងារវាស់វែងជូនក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចវាស់វែង
- បំពេញមុខងារជានាយកបច្ចេកទេស ឬជាអ្នកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មវាស់វែង
- ចូលជាសមាជិកសមាគមអ្នកវាស់វែង។

ប្រការ៧ ..

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវាស់វែង ត្រូវ ៖

- អនុវត្តការងារស្របតាមស្តង់ដាក្នុងការវាស់វែងនិងការផលិតផែនទី
- ប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកវាស់វែង
- ទទួលការបណ្តុះបណ្តាលលើការងារវាស់វែងដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៨ ..

ការស្នើសុំវិញ្ញាបនបត្រវាស់វែង ត្រូវបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ស្របតាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៣
កម្រិតនៃវិញ្ញាបនបត្រវាស់វែង

ប្រការ៩ ..

វិញ្ញាបនបត្រវាស់វែងមាន៣(បី)កម្រិត ដូចខាងក្រោម ៖

- **វិញ្ញាបនបត្រវាស់វែងកម្រិត "ក" :** សម្រាប់ផ្តល់ជូនរូបវន្តបុគ្គលដែលមានសញ្ញាបត្រវាស់វែងកម្រិតឧត្តម ឬកម្រិតប្រហាក់ប្រហែល និងមានបទពិសោធន៍ការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ
- **វិញ្ញាបនបត្រវាស់វែងកម្រិត "ខ" :** សម្រាប់ផ្តល់ជូនរូបវន្តបុគ្គលដែលមានសញ្ញាបត្រវាស់វែងកម្រិតមធ្យម ឬកម្រិតប្រហាក់ប្រហែល និងមានបទពិសោធន៍ការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ
- **វិញ្ញាបនបត្រវាស់វែងកម្រិត "គ" :** សម្រាប់ផ្តល់ជូនរូបវន្តបុគ្គលដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រវាស់វែងកម្រិតបឋម និងមានបទពិសោធន៍ការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ។

ប្រការ១០ ..

វិញ្ញាបនបត្រវាស់វែង មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ និងអាចសុំបន្តបាន។

ការស្នើសុំបន្តវិញ្ញាបនបត្រវាស់វែងត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ មុនពេលផុតកំណត់សុពលភាព។

ជំពូកទី៤
សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង

ប្រការ១១ ..

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង មានដូចខាងក្រោម ៖

- ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង ចំនួន០២ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់អ្នកដាក់ពាក្យស្នើសុំ ចំនួន០២ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននិងទិដ្ឋាការរបស់អ្នកដាក់ពាក្យស្នើសុំ(ថតចម្លង) ចំនួន០២ច្បាប់
- សញ្ញាបត្រ ឬវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សា(ថតចម្លង) ចំនួន០២ច្បាប់

- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារវាស់វែង ឬលិខិតបញ្ជាក់សមត្ថភាពវាស់វែង ចំនួន០២ច្បាប់
- រូបថតអ្នកដាក់ពាក្យស្នើសុំ ទំហំ (៤x៦) ចំនួន០២សន្លឹក

រាល់ឯកសារថតចម្លងត្រូវធ្វើនីត្យានុកូលកម្មដោយអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។
គំរូទម្រង់សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

ជំពូកទី៥
នីតិវិធីនៃការពិនិត្យសម្រេចលើពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង

ប្រការ១២ ..

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬមិនផ្តល់វិញ្ញាបនបត្រវាស់វែង គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញនិងត្រឹមត្រូវ។

ប្រការ១៣ ..

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង ត្រូវដាក់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំនៅពេលទទួលបានសំណុំឯកសារស្នើសុំពេញលេញនិងត្រឹមត្រូវ។

បន្ទាប់ពីទទួលបានសំណុំឯកសារស្នើសុំ ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណុំឯកសារនេះទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវពិនិត្យនិងវាយតម្លៃទទួលស្គាល់សមត្ថភាពវាស់វែង និងលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ២៤(ម្ភៃបួន)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារ ដើម្បីសម្រេចផ្តល់និងចុះហត្ថលេខាលើវិញ្ញាបនបត្រវាស់វែង។

គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវបញ្ជូនវិញ្ញាបនបត្រវាស់វែងនិងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ទៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំឯកសារក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់ប្រកាសស្តីពីការផ្តល់វិញ្ញាបនបត្រវាស់វែងនិងគំរូទម្រង់វិញ្ញាបនបត្រវាស់វែង ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ជំពូកទី៦

ការព្យួរនិងការដកហូតវិញ្ញាបនបត្រវាស់វែង

ប្រការ១៤ ..

នៅពេលទទួលបានព័ត៌មាន ឬពាក្យបណ្តឹងអំពីការប្រព្រឹត្តល្មើសនីតិវិធីនៃការវាស់វែងដោយអ្នកមានវិញ្ញាបនបត្រវាស់វែង គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តអំពើល្មើសនោះ។

ក្នុងករណីអ្នកវាស់វែងមិនបានបំពេញតាមស្តង់ដានិងបច្ចេកទេសនៃការវាស់វែង គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

ក្នុងករណីអ្នកវាស់វែងមិនអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃចេញលិខិតព្រមាន គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែងត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញសេចក្តីសម្រេចព្យួរវិញ្ញាបនបត្រវាស់វែងជាបណ្តោះអាសន្នក្នុងរយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចព្យួរ។

ក្នុងករណីអ្នកវាស់វែងអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានក្នុងរយៈពេលនៃការព្យួរ គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញសេចក្តីសម្រេចលុបចោលការព្យួរវិញ្ញាបនបត្រវាស់វែង។

ក្នុងករណីអ្នកវាស់វែងមិនអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានក្នុងរយៈពេលនៃការព្យួរ គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចេញប្រកាសស្តីពីការដកហូតវិញ្ញាបនបត្រវាស់វែង។

គំរូទម្រង់ប្រកាសស្តីពីការដកហូតវិញ្ញាបនបត្រវាស់វែង ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

ប្រការ១៥ ..

ក្នុងអំឡុងពេលនៃការព្យួរវិញ្ញាបនបត្រវាស់វែង អ្នកវាស់វែងត្រូវបាត់បង់នីតិសម្បទាដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។

ជំពូកទី៧

ទណ្ឌកម្ម

ប្រការ១៦ ..

អ្នកវាស់វែងណាដែលមិនគោរពតាមបទប្បញ្ញត្តិ ស្តង់ដា និងបច្ចេកទេសនៃការវាស់វែង ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី។

ជំពូកទី៨

អវសានប្បញ្ញត្តិ

ប្រការ១៧ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៨ ..

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី **"ដើម្បីជូនជ្រាប"**
- ដូចប្រការ១៨ **"ដើម្បីមុខការ"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ខ្ញុំបាទ/នាងខ្ញុំ នៃប្រកាសលេខ ...១៧៥ ស.ជ.ក.... ចុះថ្ងៃទី ...០៥... ខែ ...ធ្នូ... ឆ្នាំ២០១៩

ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់ ការពន្យារ និងការដកហូតវិញ្ញាបនបត្រវាស់វែង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....ភេទ.....ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ..... សញ្ជាតិ..... ប្រពន្ធ/ប្តីឈ្មោះ.....
ថ្ងៃខែឆ្នាំកំណើត..... កាត់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ.....
សញ្ជាតិ.....ទីលំនៅបច្ចុប្បន្នផ្ទះលេខ.....ផ្លូវ.....ភូមិ.....ឃុំ/សង្កាត់.....
ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត..... ។

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

តាមរយៈ÷ -លោកប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង

កម្មវត្ថុ ÷ សំណើសុំផ្តល់វិញ្ញាបនបត្រវាស់វែង កម្រិត.....

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាផ្តល់វិញ្ញាបនបត្រវាស់វែងឱ្យខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

<u>សូមគោរពជូនភ្ជាប់ជាមួយនូវ</u>÷

-ប្រវត្តិរូបសង្ខេប	ចំនួន០២ច្បាប់
-ច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននិងទិដ្ឋាការ	ចំនួន០២ច្បាប់
-ច្បាប់ចម្លងសញ្ញាបត្រ ឬវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សា	ចំនួន០២ច្បាប់
-លិខិតបញ្ជាក់បទពិសោធន៍ការងារវាស់វែង ឬលិខិតបញ្ជាក់សមត្ថភាពវាស់វែង	ចំនួន០២ច្បាប់
-រូបថតអ្នកដាក់ពាក្យស្នើសុំ ទំហំ ៤x៦	ចំនួន០២សន្លឹក

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦...
ធ្វើនៅ.....ថ្ងៃទី ខែ ឆ្នាំ២០....

ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត
4x6

ប្រវត្តិរូបសង្ខេប

១. ព័ត៌មានផ្ទាល់ខ្លួន

នាម និងគោត្តនាម : ..... អក្សរឡាតាំង.....

សញ្ជាតិ : ..... ថ្ងៃខែឆ្នាំកំណើត.....

ទីកន្លែងកំណើត : .....

អត្តសញ្ញាណបណ្ណលេខ : ..... ចុះថ្ងៃទី..... ខែ..... ឆ្នាំ.....

លិខិតឆ្លងដែនលេខ : ..... ចុះថ្ងៃទី..... ខែ..... ឆ្នាំ.....

អាសយដ្ឋានបច្ចុប្បន្ន : .....

ទូរសព្ទលេខ : ..... អ៊ីមែល .....

ឈ្មោះអង្គភាពបម្រើការងារ : ..... តួនាទី.....

អាសយដ្ឋានអង្គភាពការងារ : .....

២. ស្ថានភាពគ្រួសារ

ប្តី ឬប្រពន្ធឈ្មោះ : ..... ឆ្នាំកំណើត..... មុខរបរ.....

កូនឈ្មោះ : ..... ភេទ..... ឆ្នាំកំណើត..... មុខរបរ.....

: ..... ភេទ..... ឆ្នាំកំណើត..... មុខរបរ.....

: ..... ភេទ..... ឆ្នាំកំណើត..... មុខរបរ.....

: ..... ភេទ..... ឆ្នាំកំណើត..... មុខរបរ.....

៣. ការបណ្តុះបណ្តាលបន្ត

ល.រ	ជំនាញខាងវិទ្យាសាស្ត្រ	ស្ថាប័នបណ្តុះបណ្តាល	រយៈពេល

៤. ជំនាញផ្សេងៗ

ល.រ	មុខជំនាញ	វិញ្ញាបនបត្រ/សញ្ញាបត្រ	រយៈពេល	ឆ្នាំបញ្ចប់

៥. បទពិសោធន៍ការងារ

ពីឆ្នាំណា ដល់ឆ្នាំណា	អង្គភាពបម្រើការងារ	តួនាទី

<u>បញ្ជាក់÷</u> បេក្ខជនអាចបន្ថែមទំព័រ ប្រសិនបើមានតម្រូវការសរសេរបន្ថែម។

ខ្ញុំបាទ/នាងខ្ញុំសូមធានាអះអាងថា ព័ត៌មានក្នុងប្រវត្តិរូបខាងលើនេះពិតជាត្រឹមត្រូវពិតប្រាកដមែន។ ក្នុងករណីខុសពីការពិតខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦.....

ធ្វើនៅ..... ថ្ងៃទី ខែ ឆ្នាំ២០.....

ហត្ថលេខា និងឈ្មោះ

ទំព័រ ៣ នៃទំព័រ ៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតបញ្ជាក់បន្ថែមសោធន៍ការងារអាស់វែង[1]

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..... ភេទ..... ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ..... សញ្ជាតិ..... ទីលំនៅបច្ចុប្បន្ន
ផ្ទះលេខ..... ផ្លូវ..... ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត..... (អ្នកស្នើសុំ)។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..... ភេទ..... ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ..... សញ្ជាតិ..... លំនៅបច្ចុប្បន្ន
ផ្ទះលេខ..... ផ្លូវ..... ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត..... អត្តលេខ ..... លេខវិញ្ញាបនបត្រវាស់វែង .....
ថ្ងៃខែឆ្នាំចេញវិញ្ញាបនបត្រវាស់វែង ..... ទូរសព្ទ .....
អ៊ីម៉ែល..... (អ្នកជីកនាំ)។

១.សូមបំពេញក្នុងតារាងខាងក្រោមនូវព័ត៌មានអំពីពេលវេលា ដែលអ្នកស្នើសុំស្ថិតក្រោមការជីកនាំរបស់អ្នក

ពី (ខែ/ឆ្នាំ)	ដល់ (ខែ/ ឆ្នាំ)	រយៈពេលចំនួន (ខែ)
សរុបរយៈពេលចំនួន (ខែ)		

[1] ទម្រង់លិខិតនេះ ត្រូវបំពេញដោយអ្នកវាស់វែង ដែលជាអ្នកជីកនាំការងាររបស់អ្នកស្នើសុំវិញ្ញាបនបត្រវាស់វែង និងត្រូវភ្ជាប់ជាមួយសំណុំឯកសារស្នើសុំវិញ្ញាបនបត្រវាស់វែង

២.សូមបំពេញតារាងខាងក្រោមនូវព័ត៌មានអំពីសកម្មភាពវាស់វែងរបស់អ្នកស្នើសុំក្នុងអំឡុងពេលស្ថិតក្រោមការដឹកនាំរបស់អ្នក

ការទទួលខុសត្រូវរបស់អ្នកស្នើសុំ[2]	បទពិសោធន៍លើដីជាក់ស្តែង (ខែ)	បទពិសោធន៍ក្នុងការិយាល័យ (ខែ)
ពុំមានការទទួលខុសត្រូវ		
ទទួលខុសត្រូវក្នុងការវាស់វែងសុរិយោដី		
ទទួលខុសត្រូវក្នុងការវាស់វែងគ្រប់ប្រភេទរួមទាំងការវាស់វែងសុរិយោដី		
សរុបបទពិសោធន៍ (ខែ)		

៣.សូមគូសក្នុងប្រអប់ដើម្បីបំពេញនូវការប្រកាសរបស់អ្នកស្នើសុំក្នុងការងារវាស់វែងនៅក្នុងតារាងខាងក្រោម

តើអ្នកស្នើសុំបានបំពេញដោយសមស្របចំពោះប្រភេទការងារវាស់វែងណាមួយដូចខាងក្រោមនៅពេលដែលស្ថិតនៅក្រោមការដឹកនាំរបស់អ្នក	
បទពិសោធន៍ការងារវាស់វែងដីជាក់ស្តែង	**ចម្លើយ**
ការវាស់វែងបណ្តាញប្រឹថពីរិភាគប្តង់រាប និងកម្ពស់	☐ បាទ/ចាស ☐ ទេ
ការវាស់វែងសុរិយោដី	☐ បាទ/ចាស ☐ ទេ
ការវាស់វែងប្រឹថពីរិភាគ	☐ បាទ/ចាស ☐ ទេ
ការវាស់វែងឋានលេខា	☐ បាទ/ចាស ☐ ទេ
ការវាស់វែងក្នុងគោលដៅសំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត	☐ បាទ/ចាស ☐ ទេ

[2] ការទទួលខុសត្រូវ គឺអ្នកវាស់វែងស្ថិតក្នុងតួនាទីជាអ្នកដឹកនាំក្នុងសកម្មភាពវាស់វែងណាមួយ

បទពិសោធន៍នៅក្នុងការិយាល័យ	ចម្លើយ
ការបញ្ជូល និងគណនាទិន្នន័យវាស់វែង	☐ បាទ/ចាស ☐ ទេ
ការតាក់តែងគំនូសប្លង់ ផែនទីតាមទិន្នន័យវាស់វែង	☐ បាទ/ចាស ☐ ទេ
ការតាក់តែងផែនទីតាមទិន្នន័យផែនទីគោល	☐ បាទ/ចាស ☐ ទេ

៤.ការធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំសូមធានាអះអាងថា រាល់ព័ត៌មានទាំងអស់ដែលខ្ញុំបានសរសេរក្នុងទម្រង់នេះពិតជាត្រឹមត្រូវពិតប្រាកដមែន។ ក្នុងករណីខុសពីការពិតខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦...

ធ្វើនៅ.....ថ្ងៃទី ខែ ឆ្នាំ២0.....

ហត្ថលេខា ឆិនឈ្មោះ (អ្នកដឹកនាំ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ:.....

ប្រកាស
ស្តីពី
ការផ្តល់វិញ្ញាបនបត្រវាស់វែង

ខ្ចុំនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញប្រកាសលេខ ២០០ ដនស.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- យោងតាមសំណើរបស់សាមីខ្លួន

សម្រេច

ប្រការ១ . _

ត្រូវបានផ្តល់វិញ្ញាបនបត្រវាស់វែង ជូនលោក/លោកស្រី ..... ភេទ ..... ថ្ងៃខែឆ្នាំកំណើត ..... សញ្ជាតិ ..... កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែន លេខ ..... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវលេខ ..... ឃុំ/សង្កាត់ ..... ក្រុង/ស្រុក/ខណ្ឌ ..... រាជធានី/ខេត្ត ..... ក្នុងកម្រិត ..... តទៅនេះហៅថា "**អ្នកកាន់វិញ្ញាបនបត្រវាស់វែង**"។

ប្រការ២ . _

វិញ្ញាបនបត្រវាស់វែង មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ និងអាចសុំបន្តបាន។

ការស្នើសុំបន្តវិញ្ញាបនបត្រវាស់វែងត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ មុនពេលផុតកំណត់សុពលភាព។

ប្រការ៣ . _

អ្នកកាន់វិញ្ញាបនបត្រវាស់វែង មានកាតព្វកិច្ចដូចខាងក្រោម ÷

- អនុវត្តការងារស្របតាមស្តង់ដាក្នុងការវាស់វែងនិងការផលិតផែនទី
- ប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកវាស់វែង
- ទទួលការបណ្តុះបណ្តាលលើការងារវាស់វែងដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤ . _

អ្នកវាស់វែងណាដែលមិនគោរពតាមបទប្បញ្ញត្តិ ស្តង់ដា និងបច្ចេកទេសនៃការវាស់វែង ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី។

ប្រការ៥ . _

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ៣.ស.២៥៦...

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០...

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាមីខ្លួន ដូចប្រការ១
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លេខ/N°: .....

វិញ្ញាបនបត្រវាស់វែង
CERTIFICATE FOR SURVEYING

4 x 6

គោត្តនាម និងនាម:..... ភេទ..... ថ្ងៃខែឆ្នាំកំណើត..... សញ្ជាតិ:.....
SURNAME AND NAME:..... SEX..... DATE OF BIRTH..... NATIONALITY:.....
លេខបញ្ជី:.....
REGISTRATION NUMBER:.....
កាលបរិច្ឆេទចុះបញ្ជី:.....
REGISTRATION DATE:.....
អ្នកវាស់វែង កម្រិត.....
SURVEYOR OF LEVEL:.....
សុពលភាព: ពីថ្ងៃទី.....ខែ.....ឆ្នាំ..... ដល់ថ្ងៃទី.....ខែ.....ឆ្នាំ.....
VALIDITY:..... TO .....

អ្នកកាន់វិញ្ញាបនបត្រនេះត្រូវគោរពច្បាប់និងបទបញ្ជាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
THE HOLDER OF THE CERTIFICATE SHALL OBSERVE AND COMPLY WITH LAWS, RULES AND REGULATIONS OF THE KINGDOM OF CAMBODIA.

ថ្ងៃ..... ខែ.....ឆ្នាំ..... ព.ស.....
រាជធានីភ្នំពេញ ថ្ងៃទី .....ខែ ..... ឆ្នាំ .....
PHNOM PENH, ...

រដ្ឋមន្ត្រី
MINISTER

ទំព័រ ៣ នៃទំព័រ ៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ:.....

ប្រកាស
ស្តីពី
ការដកហូតវិញ្ញាបនបត្រវាស់វែង

ខ្ចប់នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨ /៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី
- បានឃើញប្រកាសលេខ ២០០ ដនស.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង
- បានឃើញប្រកាសលេខ ..... ចុះថ្ងៃទី ..... ខែ ..... ឆ្នាំ២០..... ស្តីពីការផ្តល់វិញ្ញាបនបត្រវាស់វែង
- យោងតាមសំណើរបស់គណៈកម្មាធិការទទួលស្គាល់សមត្ថភាពវាស់វែង

សម្រេច

ប្រការ១ .-

ត្រូវបានដកហូតវិញ្ញាបនត្រវាស់វែង ពីលោក/លោកស្រី ..... ភេទ.....
ថ្ងៃខែឆ្នាំកំណើត ..... សញ្ជាតិ ..... កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែន

លេខ ..... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវលេខ .....
ឃុំ/សង្កាត់ ..... ក្រុង/ស្រុក/ខណ្ឌ ..... រាជធានី/ខេត្ត .....
ក្នុងកម្រិត ..... ដែលហៅថា "**អ្នកកាន់វិញ្ញាបនបត្រវាស់វែង**" ដែលបានផ្តល់ជូនវិញ្ញាបនបត្រវាស់វែង
តាមប្រកាសលេខ ..... ចុះថ្ងៃទី ..... ខែ ..... ឆ្នាំ២០ ..... ស្តីពី
ការផ្តល់វិញ្ញាបនបត្រវាស់វែង។

ប្រការ២ . _

រូបវន្តបុគ្គលដែលត្រូវបានដកហូតវិញ្ញាបនបត្រវាស់វែង ត្រូវបាត់បង់នីតិសម្បទា ÷

- ជាអ្នកវាស់វែង
- មិនអាចបំពេញមុខងារជានាយកបច្ចេកទេស ឬជាអ្នកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មវាស់វែង
- មិនអាចចូលជាសមាជិកសមាគមអ្នកវាស់វែង។

ប្រការ៣ . _

បុគ្គលណាដែលមិនគោរពតាមបទប្បញ្ញត្តិ ស្តង់ដា និងបច្ចេកទេសនៃការវាស់វែង ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី។

ប្រការ៤ . _

ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ៣.ស.២៥៦....
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០...

ទ្បបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាប"
- សាមីខ្លួន ដូចប្រការ១
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស
ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលបានសាងសង់រួចមុនច្បាប់សំណង់ចូលជាធរមាន

ឆ្នាំ ២០១៩

លេខ : ១៧៧ ដនស/ប្រក.

ប្រកាស
ស្តីពី
បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់
ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១ ..

ប្រកាសនេះមានគោលបំណង៖

- ធានាគុណភាព សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សោភណភាពសំណង់ បរិស្ថានល្អ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- បង្ការនិងទប់ស្កាត់ហានិភ័យដែលបង្កឡើងដោយការប្រើប្រាស់សំណង់ដែលគ្មានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់
- ការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- លើកតម្លៃសេដ្ឋកិច្ចរបស់សំណង់
- គ្រប់គ្រងទិន្នន័យសំណង់ប្រកបដោយប្រសិទ្ធភាព។

ប្រការ២ ..

ប្រកាសនេះមានគោលដៅ៖

- កំណត់សមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- កំណត់បែបបទនិងនីតិវិធីនៃការផ្តល់ ការពួយ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន
- កំណត់បទប្បញ្ញត្តិបច្ចេកទេសជាមូលដ្ឋានក្នុងការផ្តល់ ការពួយ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ប្រការ៣ ..

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់និងដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ដូចខាងក្រោម៖

- សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់
- សំណង់ដែលសាងសង់ខុសពីលិខិតអនុញ្ញាតសាងសង់
- សំណង់ដែលមានលិខិតអនុញ្ញាតសាងសង់ ប៉ុន្តែគ្មានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវឬលិខិតបិទការដ្ឋាន។

ប្រការ៤ ..

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន ម្ចាស់សំណង់ត្រូវមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ម្ចាស់នៃសំណង់ដែលបានសាងសង់រួចមុនថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៧ អាចមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ចបាន។

ប្រការ៥ ..

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

ចំពោះសំណង់ដែលបានសាងសង់ក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ វិញ្ញាបនបត្រប្រើប្រាស់សំណង់អាចផ្តល់ជូនបាន លុះត្រាតែម្ចាស់សំណង់បានបង់ប្រាក់ពិន័យអន្តរការណ៍តាមគោលការណ៍

ដែលបានកំណត់ដោយអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រ៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រ៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ប្រការ៦ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់នៅតែមានសុពលភាព ទោះបីម្ចាស់សំណង់ត្រូវបានផ្លាស់ប្តូរក៏ដោយ។

ក្នុងករណីវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរ ឬដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច សំណង់នោះមិនត្រូវបានអនុញ្ញាតឱ្យបន្តការប្រើប្រាស់ឡើយ។

រាល់ការប្តូរមុខងារប្រើប្រាស់ និង/ឬកែប្រែគ្រឿងផ្គុំនៃសំណង់ ដែលមានវិញ្ញាបនបត្រប្រើប្រាស់រួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្តូរមុខងារប្រើប្រាស់ និង/ឬកែប្រែគ្រឿងផ្គុំសំណង់ពីអាជ្ញាធរមានសមត្ថកិច្ចជាមុន។

ជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្ម នូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសំណង់។

ប្រការ៧ ..

ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់កម្រៃសេវាសាធារណៈជូនរដ្ឋ។

កម្រៃសេវាក្នុងការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៨ ..

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម៖

- **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។
- **ម្ចាស់សំណង់** សំដៅដល់ម្ចាស់នៃសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាត ឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន។

- **អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់មន្ត្រីជំនាញដែលបានទទួលការអនុញ្ញាតឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។
- **ឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់** សំដៅដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីសាមីសំណើមិនមែនជាកម្មសិទ្ធិករត្រូវមានការព្រមព្រៀងពីម្ចាស់ដី។

ជំពូកទី២
សមត្ថកិច្ច

ប្រការ៩ ..

អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការពិនិត្យ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ រួមមាន៖

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ជំពូកទី៣
បែបបទនិងនីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ផ្នែកទី ១
សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ប្រការ១០ ..

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់សំណង់ (ត្រូវធ្វើនីតិានុកូលកម្មនៅអាជ្ញាធរមានសមត្ថកិច្ចឬមន្ទីរសារការី) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន ០៣ ច្បាប់

- សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ០៣ ច្បាប់
- សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង (ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងធ្មិសំណង់ និងប្លង់អគ្គិភ័យ) ចំនួន ០៣ ច្បាប់
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) ចំនួន ០៣ ច្បាប់

គំរូទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

ប្រការ១១ ..

បុគ្គលដែលអាចចុះហត្ថលេខាទទួលខុសត្រូវលើសម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង មានដូចខាងក្រោម៖

១. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬសាងសង់។

២. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ ឬអាជ្ញាបណ្ណសាងសង់។

៣. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង ត្រូវមានបោះត្រានិងចុះលេខវិញ្ញាបនបត្រឬលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនដែលបានអនុវត្តការធ្វើសម្រង់ប្លង់នោះ។

សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បុគ្គលដែលអាចចុះហត្ថលេខាទទួលខុសត្រូវលើសម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងផងដែរ មានដូចខាងក្រោម៖

១. អ្នកវិជ្ជាជីវៈដែលមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ឬសាងសង់។

២. អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ឬអាជ្ញាបណ្ណសាងសង់។

ក្នុងករណីនេះ អ្នកវិជ្ជាជីវៈត្រូវបោះត្រានិងចុះលេខវិញ្ញាបនបត្រឬលេខអាជ្ញាបណ្ណនៅលើសម្រង់ប្លង់នោះ។

ប្រការ១២ ..

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅការិយាល័យច្រកចេញចូលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ផ្នែកទី ២

នីតិវិធីនៃការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រការ១៣ ..

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

ប្រការ១៤ ..

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ ក្នុងរយៈពេលយ៉ាងយូរ ០២ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ប្រការ១៥ ..

អគ្គនាយកដ្ឋានសំណង់ ដោយមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។ អគ្គនាយកដ្ឋានសំណង់ត្រូវធ្វើកំណត់បង្ហាញសរុបលទ្ធផលនៃការពិនិត្យនិងផ្តល់យោបល់ និងបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសម្រេច។

ប្រការ១៦ ..

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ផ្តល់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

ប្រការ១៧ ..

អគ្គនាយកដ្ឋានសំណង់ ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ផ្នែកទី៣

នីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ប្រការ១៨ ..

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

ប្រការ១៩ ..

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ប្រការ២០ ..

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដោយមានការិយាល័យសំណង់ជាសេនាធិការ ត្រូវពិនិត្យនិងផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់រយៈពេលយ៉ាងយូរ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការទៅអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ដើម្បីពិនិត្យសម្រេច។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

ប្រការ២១ ..

បន្ទាប់ពីបានពិនិត្យលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើសំណុំឯកសារស្នើសុំ ដូចខាងក្រោម៖

១. ផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន ឬ

២. ចេញលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួច ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។

ប្រការ២២ ..

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

ប្រការ២៣ ..

ក្នុងករណីសំណង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្គាប់ឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវ និង/ឬបំពេញបន្ថែម ឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ក្នុងករណីមិនអាចសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសុំយោបល់។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែម និងរយៈពេលស្នើសុំយោបល់ទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

ផ្នែកទី ៤
នីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ប្រការ២៤ ..

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំតែក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

ប្រការ២៥..

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ប្រការ២៦ ..

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

ប្រការ២៧ ..

បន្ទាប់ពីបានពិនិត្យលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើសំណុំឯកសារស្នើសុំ ដូចខាងក្រោម÷

១. ផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន ឬ

២. ចេញលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួច ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។

ប្រការ២៨ ..

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

ប្រការ២៩ ..

ក្នុងករណីសំណង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្គាប់ឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវនិង/ឬបំពេញបន្ថែមឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ក្នុងករណីមិនអាចសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បាន អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីសុំយោបល់។

ក្នុងករណីមិនអាចបានអាចផ្តល់យោបល់បាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសុំយោបល់។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែម និងរយៈពេលស្នើសុំយោបល់តាមឋានានុក្រមនេះមិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

ជំពូកទី៤
បែបបទនិងនីតិវិធីនៃការពិនិត្យ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

ប្រការ៣០ ..

អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចសម្រេចពិនិត្យឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះបាន ក្នុងករណីសំណង់នោះលែងមានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

ប្រការ៣១ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់នឹងត្រូវពិនិត្យដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់បង្ហាញថាសំណង់នោះ ពុំមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្គាប់ជាលាយលក្ខណ៍អក្សរឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវលុបការពិនិត្យវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីម្ចាស់សំណង់បានធ្វើការកែតម្រូវតាមការបង្គាប់របស់អាជ្ញាធរមានសមត្ថកិច្ច។

ប្រការ៣២ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់នឹងត្រូវដកហូតដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីណាមួយដូចខាងក្រោម៖

១. មុខងារប្រើប្រាស់សំណង់ត្រូវបានប្តូរ។

២. គ្រឿងផ្គុំសំណង់ត្រូវបានកែប្រែដោយគ្មានការអនុញ្ញាត។

៣. សំណង់មានសភាពគ្រោះថ្នាក់ តាមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

ជំពូកទី៥

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

ប្រការ៣៣ ..

អាជ្ញាធរមានសមត្ថកិច្ចត្រូវសម្រេចផ្តល់ ព្យួរ ឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយផ្អែកលើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវធ្វើដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវមានហត្ថលេខាទទួលខុសត្រូវរបស់៖

១. មន្ត្រីត្រួតពិនិត្យសំណង់ ឬ

២. នាយកបច្ចេកទេសក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬ

៣. នាយកបច្ចេកទេសក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវមានបោះត្រា និងចុះលេខវិញ្ញាបនបត្រ ឬលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ។

គំរូទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

ប្រការ៣៤ ..

មន្ត្រីត្រួតពិនិត្យសំណង់ ដែលមានសមត្ថកិច្ចចុះអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលជាកម្មវត្ថុនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ រួមមាន៖

- មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ត្រីជំនាញនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ជំពូកទី៦

បទប្បញ្ញត្តិបច្ចេកទេស

ប្រការ៣៥ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលសាងសង់នៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ស្របតាមប្លង់សុរិយោដី និងប្លង់ហេដ្ឋារចនាសម្ព័ន្ធ។

ប្រការ៣៦ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលអនុលោមតាមបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្មដូចមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

ក. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ចំពោះសំណង់ដែលបានចាប់ផ្តើមសាងសង់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៧ ដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥។

ខ. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន បទប្បញ្ញត្តិ គោលការណ៍ និងសេចក្តីណែនាំជាធរមាន ចំពោះសំណង់ដែលបានចាប់ផ្តើមសាងសង់នៅក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ និងបញ្ចប់ការសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាននៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩។

ប្រការ៣៧ ..

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដូចខាងក្រោម÷

- គ្រឿងផ្គុំសំណង់អាចទ្រាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់
- សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលអាចធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ
- មានសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ជំពូកទី៧
ការប្តឹងតវ៉ា

ប្រការ៣៨ ..

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការពារ ឬការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ មានសិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ច ឬទៅតុលាការតាមនីតិវិធីជាធរមាន។

ជំពូកទី៨
អវសានប្បញ្ញត្តិ

ប្រការ៣៩ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ៤០ ..

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៩

ទ្បបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុជាតិ

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ទ្បបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤០ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ខ្ទបសម្ព័ន្ធទី១ នៃប្រកាសលេខ.១៣៧.ស.ន.ក/ប្រក. ចុះថ្ងៃទី..០៦.....ខែ..ធ្នូ.....ឆ្នាំ២០១៩....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់

វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចុលជាធរមាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គំរូទម្រង់

សម្រាប់សមត្ថកិច្ចរបស់ក្រសួង

ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....ភេទ..... សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ..... និងប្រពន្ធ/ប្តីឈ្មោះ.....
សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត..... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ.....
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.....ផ្លូវ.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត..... តំណាងឱ្យក្រុមហ៊ុន..... ចុះបញ្ជីលេខ..... ចុះថ្ងៃទី....
ខែ.....ឆ្នាំ..... ទីស្នាក់ការស្ថិតនៅអគារលេខ..... ភូមិ.....ឃុំ/សង្កាត់.....
ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....។

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

តាមរយៈ÷ -ប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់

កម្មវត្ថុ ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ.....ឆ្នាំ.....
ជាប្រភេទសំណង់.....សាងសង់អំពី..... កំពស់..... ម៉ែត្រ ស្មើនឹង.....ជាន់
ផ្ទៃក្រឡាសំណង់សរុប.....ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ..... ផ្លូវលេខ.....
ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត.....។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

សូមគោរពជូនភ្ជាប់ជាមួយនូវ÷

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់	ចំនួន ០៣ ច្បាប់
៥. សលាកបត្រកាឡាដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត	ចំនួន ០៣ ច្បាប់
៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង	ចំនួន ០៣ ច្បាប់
៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន)	ចំនួន ០៣ ច្បាប់
៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន)	ចំនួន ០៣ ច្បាប់
៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន)	ចំនួន ០៣ ច្បាប់
១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន)	ចំនួន ០៣ ច្បាប់
១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន)	ចំនួន ០៣ ច្បាប់
១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន)	ចំនួន ០៣ ច្បាប់

ថ្ងៃ..... ខែ..... ឆ្នាំ..... ព.ស. .....
ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....
ហត្ថលេខា ឬស្លាមបេដៃស្តាំអ្នកស្នើសុំ

<u>**បញ្ជាក់**</u>: រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសាធារណៈ។

ខ្ចប់សម្ព័ន្ធទី១ នៃប្រកាសលេខ.១៧៧.ប្រ.ក.ប្រក ចុះថ្ងៃទី..០៦.....ខែ..កុម្ភៈ.....ឆ្នាំ២០១៩...ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់
វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចុលជាធរមាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូតម្រង់
សម្រាប់សមត្ថកិច្ចរបស់រដ្ឋបាលរាជធានី/ខេត្ត

ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....ភេទ..... សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ..... និងប្រពន្ធ/ប្តីឈ្មោះ.....
សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត..... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ.....
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.....ផ្លូវ.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត..... តំណាងឱ្យក្រុមហ៊ុន..... ចុះបញ្ជីលេខ..... ចុះថ្ងៃទី....
ខែ.....ឆ្នាំ..... ទីស្នាក់ការស្ថិតនៅអគារលេខ..... ភូមិ.....ឃុំ/សង្កាត់.....
ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....។

សូមគោរពជូន
ឯកឧត្តម/លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី/ខេត្ត.....

តាមរយៈ÷ -ប្រធានអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី/ខេត្ត.....
-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី/ខេត្ត.....

កម្មវត្ថុ ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ.....ឆ្នាំ.....
ជាប្រភេទសំណង់.....សាងសង់អំពី..... កំពស់..... ម៉ែត្រ ស្មើនឹង.....ជាន់
ផ្ទៃក្រឡាសំណង់សរុប.....ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ..... ផ្លូវលេខ.....
ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត.....។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាពិនិត្យនិងសម្រេច ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

សូមគោរពជូនភ្ជាប់ជាមួយនូវ÷

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់
២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន)	ចំនួន ០៣ ច្បាប់
៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់	ចំនួន ០៣ ច្បាប់
៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត	ចំនួន ០៣ ច្បាប់
៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង	ចំនួន ០៣ ច្បាប់
៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន)	ចំនួន ០៣ ច្បាប់
៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន)	ចំនួន ០៣ ច្បាប់
៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន)	ចំនួន ០៣ ច្បាប់
១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន)	ចំនួន ០៣ ច្បាប់
១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន)	ចំនួន ០៣ ច្បាប់
១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន)	ចំនួន ០៣ ច្បាប់

ថ្ងៃ..... ខែ..... ឆ្នាំ..... ព.ស. .....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....

ហត្ថលេខា ឬស្លាមេដៃស្តាំអ្នកស្នើសុំ

<u>**មញ្ញាក់:**</u> រាល់ឯកសារថតចម្លង ត្រូវធ្វើនីតិព្យាធុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

ខ្ទបសម្គ័ន្ធទី១ នៃប្រកាសលេខ.១៧៧.ប្រ.ក ចុះថ្ងៃទី..០៦.....ខែ..ធ្នូ.....ឆ្នាំ២០១៩.....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់

វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គំរូឧទ្ទេស

សម្រាប់សមត្ថកិច្ចរបស់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ

ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....ភេទ..... សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ..... និងប្រពន្ធ/ប្តីឈ្មោះ.....
សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត..... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ.....
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.....ផ្លូវ.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត..... តំណាងឱ្យក្រុមហ៊ុន..... ចុះបញ្ជីលេខ..... ចុះថ្ងៃទី....
ខែ.....ឆ្នាំ..... ទីស្នាក់ការស្ថិតនៅអគារលេខ..... ភូមិ.....ឃុំ/សង្កាត់.....
ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....។

សូមគោរពជូន

លោក/លោកស្រីអភិបាល នៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ.....

តាមរយៈ÷ -ប្រធានការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ.....

-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង/ស្រុក/ខណ្ឌ.....

កម្មវត្ថុ ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **លោក/លោកស្រីអភិបាល** មេត្តាផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ.....ឆ្នាំ.....
ជាប្រភេទសំណង់.....សាងសង់អំពី..... កំពស់..... ម៉ែត្រ ស្មើនឹង.....ជាន់
ផ្ទៃក្រឡាសំណង់សរុប.....ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ..... ផ្លូវលេខ.....
ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត.....។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោក/លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេច ដោយក្តីអនុគ្រោះ។

សូម **លោក/លោកស្រីអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

សូមគោរពជូនភ្ជាប់ជាមួយនូវ÷

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន)	ចំនួន ០៣ ច្បាប់
៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់	ចំនួន ០៣ ច្បាប់
៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត	ចំនួន ០៣ ច្បាប់
៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង	ចំនួន ០៣ ច្បាប់
៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន)	ចំនួន ០៣ ច្បាប់
៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន)	ចំនួន ០៣ ច្បាប់
៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន)	ចំនួន ០៣ ច្បាប់
១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន)	ចំនួន ០៣ ច្បាប់
១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន)	ចំនួន ០៣ ច្បាប់
១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន)	ចំនួន ០៣ ច្បាប់

ថ្ងៃ..... ខែ..... ឆ្នាំ..... ព.ស. .....

ធ្វើនៅ..... ថ្ងៃទី..... ខែ..... ឆ្នាំ.....

ហត្ថលេខា ឬស្លាមេដៃស្តាំអ្នកស្នើសុំ

<u>**មន្ទាត់ៈ**</u> រាល់ឯកសារថតចម្លង ត្រូវធ្វើទីត្បាន្ទុកូលកម្ម
នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសាលាការ។

ឧបសម្ព័ន្ធ ២ នៃប្បញ្ញត្តិសារលេខ ...ប្រកាសចុះថ្ងៃទី ...ខែ ...ឆ្នាំ ...
ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់ព័ត៌មានបន្ថែមនូវការប្រើប្រាស់សំណង់ដែលឆាងអាងសម្រាប់ការដាក់ស្នើនូវសំណង់ចុងក្រោយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION

លេខ/N°: .....

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

វិញ្ញាបនបត្រប្រើប្រាស់សំណង់
CERTIFICATE OF OCCUPANCY

- សំណង់អំពី..... កម្ពស់..... ម៉ែត្រ ស្មើនឹង..... ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប..... ម^2
CONSTRUCTION BUILT OF.....; HEIGHT.....M, ...STORIES, TOTAL AREA ..... M^2
- ទីតាំងសំណង់÷ ក្បាលដីលេខ..... ផ្លូវ..... ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត.....
LOCATION: LAND TITLE N°:....., ST.::.....VILLAGE:....., COMMUNE/SANGKAT:.....,....., KRONG/SROK/KHAN:....., CAPITAL/PROVINCE:.....
- ម្ចាស់សំណង់÷..... -មុខងារប្រើប្រាស់សំណង់ .....
OWNER: ..... USE OF THE CONSTRUCTION: .....
- ថ្ងៃចាប់ផ្តើមសាងសង់.....ថ្ងៃបញ្ចប់ការសាងសង់.....-សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
CONSTRUCTION DATE: STARTED:.....; COMPLETED:..... AS BUILT DRAWING N°.....DATED:.....
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី.....ខែ..... ឆ្នាំ..... អនុវត្តដោយ .....
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:..... DONE BY:.....

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងម៉ាសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ..... ខែ.....ឆ្នាំ..... ព.ស. .....

រាជធានីភ្នំពេញ ថ្ងៃទី .....ខែ ..... ឆ្នាំ .....
PHNOM PENH, DATE .....

ជ.រដ្ឋមន្ត្រី
FOR THE MINISTER

ទំព័រ ៤ ៤ ២

ខ្ញុំបាទសម្រេចនូវគ្រប់ការងារលេខ ០៧៧.៨៨.ស.ស/ល.ត ចុះថ្ងៃទី ០៦ ខែ ក្ក ឆ្នាំ ២០១៩
ស្តីពីការបញ្ចូលនិងកែតម្រូវនូវព័ត៌មានក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការផ្តល់ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់

និមិត្តសញ្ញារាជធានី-ខេត្ត

រដ្ឋបាលរាជធានី/ខេត្ត.....
..... CAPITAL/PROVINCIAL ADMINISTRATION

លេខ/N°: .....

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

វិញ្ញាបនបត្រប្រើប្រាស់សំណង់
CERTIFICATE OF OCCUPANCY

- សំណង់អំពី..... កម្ពស់..... ម៉ែត្រ ស្មើនឹង..... ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប..... ម²
CONSTRUCTION BUILT OF.....; HEIGHT.....M, ...STORIES, TOTAL AREA ..... M^2
- ទីតាំងសំណង់÷ ក្បាលដីលេខ..... ផ្លូវ..... ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត.....
LOCATION: LAND TITLE N°:....., ST.::.....VILLAGE:....., COMMUNE/SANGKAT:....., KRONG/SROK/KHAN:....., CAPITAL/PROVINCE:.....
- ម្ចាស់សំណង់÷.....- មុខងារប្រើប្រាស់សំណង់ .....
OWNER: ..... USE OF THE CONSTRUCTION: .....
- ថ្ងៃចាប់ផ្តើមសាងសង់..... ថ្ងៃបញ្ចប់ការសាងសង់.....- សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ..... ចុះថ្ងៃទី..... ខែ..... ឆ្នាំ.....
CONSTRUCTION DATE: STARTED:.....; COMPLETED:.....AS BUILT DRAWING N°.....DATED:.....
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី..... ខែ..... ឆ្នាំ..... អនុវត្តដោយ .....
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:..... DONE BY:.....

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងម៉ាសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ..... ខែ.....ឆ្នាំ..... ៣.ស. .....

រាជធានីភ្នំពេញ ថ្ងៃទី ..... ខែ ..... ឆ្នាំ .....
PHNOM PENH, DATE .....

ជ.អភិបាល
FOR THE GOVERNOR

ខ្ញុំបាទសម្ព័ន្ធធី ៤ នៃប្លុកសរសេរ១៧៧.សន្ទរប្លុកចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០.១៩
ស្តីពីវិបត្តិនិងវិធីនៃការផ្តល់ចិញ្ចាមនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់ខុសពីច្បាប់ស្តីពីសំណង់ទូលបាងខោន

នីមិត្តសញ្ញាក្រុងស្រុកខណ្ឌ

រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ.....
..... KRONG/SROK/KHAN ADMINISTRATION
លេខ/N°: .....

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

វិញ្ញាបនបត្រប្រើប្រាស់សំណង់
CERTIFICATE OF OCCUPANCY

- សំណង់អំពី..... កម្ពស់..... ម៉ែត្រ ស្មើនឹង..... ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប..... ម²
CONSTRUCTION BUILT OF.....; HEIGHT.....M, ...STORIES, TOTAL AREA ..... M^2
- ទីតាំងសំណង់÷ ក្បាលដីលេខ..... ផ្លូវ..... ភូមិ..... ឃុំ/សង្កាត់..... ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត.....
LOCATION: LAND TITLE N°:....., ST.::.....VILLAGE:....., COMMUNE/SANGKAT:....., KRONG/SROK/KHAN:....., CAPITAL/PROVINCE:.....
- ម្ចាស់សំណង់÷.....-មុខងារប្រើប្រាស់សំណង់ .....
OWNER: ..... USE OF THE CONSTRUCTION: .....
- ថ្ងៃចាប់ផ្តើមសាងសង់.....ថ្ងៃបញ្ចប់ការសាងសង់.....-សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
CONSTRUCTION DATE: STARTED:.....; COMPLETED:..... AS BUILT DRAWING N°.....DATED:.....
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី.....ខែ..... ឆ្នាំ..... អនុវត្តដោយ .....
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:..... DONE BY:.....

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្ទុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ..... ខែ.....ឆ្នាំ..... ព.ស. .....

រាជធានីភ្នំពេញ ថ្ងៃទី .....ខែ ..... ឆ្នាំ .....
PHNOM PENH, DATE .....

ជ.អតិបាល
FOR THE GOVERNOR

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និមិត្តសញ្ញាស្ថាប័នឬក្រុមហ៊ុន
អ្នកត្រួតពិនិត្យនិងបញ្ជាក់

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

១. ព័ត៌មានទូទៅ

ម្ចាស់សំណង់ឈ្មោះ.....ភេទ..... សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត.....
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ..... និងប្រពន្ធ/ ប្តីឈ្មោះ.....
សញ្ជាតិ.....ថ្ងៃខែឆ្នាំកំណើត..... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ
.....មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.....ផ្លូវ.....ភូមិ.....ឃុំ/ សង្កាត់.....
ក្រុង/ ស្រុក/ ខណ្ឌ.....រាជធានី/ ខេត្ត.....តំណាងឱ្យក្រុមហ៊ុន.....
..... ចុះបញ្ជីលេខ..... ចុះថ្ងៃទី..... ខែ.....ឆ្នាំ..... ទី
ស្នាក់ការស្ថិតនៅអគារលេខ..... ភូមិ.....ឃុំ/ សង្កាត់.....ក្រុង/
ស្រុក/ ខណ្ឌ.....រាជធានី/ ខេត្ត.....លេខទូរស័ព្ទ.....។

ក-ទីតាំងស្នើសុំប្រើប្រាស់ផ្ទះលេខ.....ផ្លូវ.....ភូមិ.....ឃុំ/ សង្កាត់.....
ក្រុង/ ស្រុក/ ខណ្ឌ.....រាជធានី/ ខេត្ត..... (ករណីបើខុសពីអាសយដ្ឋានរបស់ម្ចាស់សំណង់)

ខ-ប្រភេទសំណង់៖ □ភូមិគ្រឹះ □ផ្ទះល្វែង □សណ្ឋាគារ ឬផ្ទះសំណាក់ □អគារស្នាក់នៅរួម □គ្រឹះស្ថានសាធារណៈ
□រោងចក្រ □ផ្សេងៗ.....

គ-មុខងារប្រើប្រាស់អគារបច្ចុប្បន្ន៖.....

ឃ-ប្រភេទគ្រឿងផ្គុំសំណង់៖ □បេតុងសរសៃដែក □បេតុងដែក □ដែក □ឈើ □ផ្សេងៗ
.....

ង-ឯកសារគតិយុត្ត៖

- លិខិតអនុញ្ញាតសាងសង់លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
- លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
- លិខិតអនុញ្ញាតផ្សេងៗ .....

២.លទ្ធផលនៃការត្រួតពិនិត្យសំណង់

ក.ព័ត៌មានក្បាលដី

- វិញ្ញាបនបត្រ/ បណ្ណ .....លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
- សលាកបត្រក្បាលដីលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
- ទំហំដី .....ម^{2}
- កិច្ចសន្យាជួលដី ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....

ខ.ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម

ខ.១-ឆ្នាគម្លាត

ឆ្នាគម្លាតជាក់ស្តែង	ឆ្នាគម្លាតក្នុងលិខិតអនុញ្ញាត
គម្លាតខាងមុខ ៖ឆ្វេង..... ម ស្តាំ..... ម	គម្លាតខាងមុខ ៖ឆ្វេង..... ម ស្តាំ..... ម
គម្លាតខាងក្រោយ ៖ឆ្វេង..... ម ស្តាំ..... ម	គម្លាតខាងក្រោយ ៖ឆ្វេង..... ម ស្តាំ..... ម
គម្លាតចំហៀងខាងឆ្វេង៖មុខ..... ម ក្រោយ..... ម	គម្លាតចំហៀងខាងឆ្វេង៖មុខ..... ម ក្រោយ..... ម
គម្លាតចំហៀងខាងស្តាំ ៖មុខ..... ម ក្រោយ..... ម	គម្លាតចំហៀងខាងស្តាំ ៖មុខ..... ម ក្រោយ..... ម

ខ.២-ផ្នែក្រឡាកម្រាលសំណង់

ផ្នែក្រឡាកម្រាលសំណង់ជាក់ស្តែង	ផ្នែក្រឡាកម្រាលសំណង់ក្នុងលិខិតអនុញ្ញាត
ជាន់ក្រោមជី..... ជាន់ ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់	ជាន់ក្រោមជី..... ជាន់ ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់
ជាន់ផ្ទាល់ដី ផ្នែក្រឡាសំណង់..... ម^2	ជាន់ផ្ទាល់ដី ផ្នែក្រឡាសំណង់..... ម^2
ជាន់ឡៅតឿ ផ្នែក្រឡាសំណង់..... ម^2	ជាន់ឡៅតឿ ផ្នែក្រឡាសំណង់..... ម^2
ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់
ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់
ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់
ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... ផ្នែក្រឡាសំណង់..... ម^2 ក្នុង១ជាន់
ផ្នែក្រឡាកម្រាលសំណង់សរុប..... ម^2	ផ្នែក្រឡាកម្រាលសំណង់សរុប..... ម^2
ផ្នែក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍..... ម^2	ផ្នែក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍..... ម^2
ផ្នែក្រឡាកម្រាលសំណង់សរុបជាផ្លូវការ..... ម^2	ផ្នែក្រឡាកម្រាលសំណង់សរុបជាផ្លូវការ..... ម^2

ខ.៣-កម្ពស់

កម្ពស់ជាក់ស្តែង	កម្ពស់ក្នុងលិខិតអនុញ្ញាត
ជាន់ក្រោមជីចំនួន..... ជាន់ កម្ពស់..... ម ក្នុង១ជាន់	ជាន់ក្រោមជីចំនួន..... ជាន់ កម្ពស់..... ម ក្នុង១ជាន់
ជាន់ផ្ទាល់ជីកម្ពស់..... ម	ជាន់ផ្ទាល់ជីកម្ពស់..... ម
ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់
ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់
ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់
ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់	ជាន់ទី..... ដល់ជាន់ទី..... កម្ពស់..... ម ក្នុង១ជាន់
កម្ពស់សរុប ..... ម	កម្ពស់សរុប ..... ម

ខ.៤-ផ្សេងៗ

ជាក់ស្តែង	ក្នុងលិខិតអនុញ្ញាត
ផលធៀបក្រឡាផ្ទៃបាតសំណង់ (BCR) ៖ .....%	ផលធៀបក្រឡាផ្ទៃបាតសំណង់ (BCR) ៖ .....%
សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖.....%	សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖.....%
សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖.....%	សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖ .....%
ការប្រើប្រាស់លំហសាធារណៈ: ផ្លូវ □គ្មាន □មាន ទទឹងផ្លូវ.....ម បណ្តោយផ្លូវ.....ម ស្នូន □គ្មាន □មាន ផ្ទៃក្រឡាសរុប.....ម^2 លំហផ្សេងៗ.....	ការប្រើប្រាស់លំហសាធារណៈ: ផ្លូវ □គ្មាន □មាន ទទឹងផ្លូវ.....ម បណ្តោយផ្លូវ.....ម ស្នូន □គ្មាន □មាន ផ្ទៃក្រឡាសរុប.....ម^2 លំហផ្សេងៗ.....

គ. ផ្នែកស្ថាបត្យកម្មនិងសំណង់

គ.១-គម្រោងប្តង់ស្ថាបត្យកម្ម □មាន □គ្មាន អ្នកសិក្សាគម្រោងប្តង់.....

□គ្មានអាជ្ញាប័ណ្ណ□មានអាជ្ញាប័ណ្ណលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....

គ.២-ការសិក្សាពិសោធន៍ភូគព្ភសាស្ត្រ ថ្ងៃទី..... ខែ.....ឆ្នាំ .....

សិក្សាដោយ..... មន្ទីរពិសោធន៍.....

គ.៣- គម្រោងប្តង់គ្រឿងធ្ងិសំណង់

គ.៣.១-ប្តង់គ្រឿងធ្ងិសំណង់៖ □គ្មាន □មាន អ្នកសិក្សាគម្រោងប្តង់ .....

□គ្មានអាជ្ញាប័ណ្ណ □មានអាជ្ញាប័ណ្ណ លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....

គ.៣.២-បទដ្ឋានបច្ចេកទេសសំណង់ជាមូលដ្ឋាន៖.....

គ.៣.៣-សសរគ្រឹះ៖

- សសរគ្រឹះជាក់ស្តែង

ប្រភេទ	កម្លាំងបេតុង (MPA)	ប្រវែង(ម)	មុខកាត់(ស.ម)		ដែក (ម.ម)
			បណ្តោយ	ទទឹង	
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....

- **សសរគ្រឹះក្នុងលិខិតអនុញ្ញាតសាងសង់**

ប្រភេទ	កម្លាំងបេតុង (MPA)	ប្រវែង(ម)	មុខកាត់(ស.ម)		ដែក (ម.ម)
			បណ្តោយ	ទទឹង	
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....

គ.៣.៤-គ្រឹះ៖

- **គ្រឹះជាក់ស្តែង**

ប្រភេទ	កម្លាំងបេតុង (MPA)	ទំហំ (ម×ម)	មុខកាត់(ស.ម)		ដែក
			បណ្តោយ	ទទឹង	
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....

- **គ្រឹះក្នុងលិខិតអនុញ្ញាតសាងសង់**

ប្រភេទ	កម្លាំងបេតុង (MPA)	ទំហំ (ម×ម)	មុខកាត់(ស.ម)		ដែក
			បណ្តោយ	ទទឹង	
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....
					-ដែកមេ៖មុខកាត់.....កម្លាំង:..... -ដែកកង៖មុខកាត់.....កម្លាំង:..... -គម្លាតដែកកង៖.....

គ.៣.៥-ធ្នឹមគ្រឹះ៖

- ធ្នឹមគ្រឹះជាក់ស្តែង

ជាន់	ប្រភេទ	កម្លាំងបេតុង (MPA)	ប្រវែង(ម)	មុខកាត់(ស.ម)		ដែក និងកម្រាស់បេតុងការពារដែក
				បណ្តោយ	ទទឹង	
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក:.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....

- ធ្នឹមគ្រឹះក្នុងលិខិតអនុញ្ញាតសាងសង់

ជាន់	ប្រភេទ	កម្លាំងបេតុង (MPA)	ប្រវែង(ម)	មុខកាត់(ស.ម)		ដែក និងកម្រាស់បេតុងការពារដែក
				បណ្តោយ	ទទឹង	
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖.....

						-មុខកាត់ដែកកង:..... -គម្លាតដែកកង:..... -កម្រាស់បេតុងការពារដែក:.....

គ.៣.៦-សសរ

- **សសរជាក់ស្តែង**

ជាន់	ប្រភេទ	កម្លាំងបេតុង (MPA)	កម្ពស់ (ម)	បណ្តោយ (ម)	ទទឹង (ម)	ដែក និងកម្រាស់បេតុងការពារដែក
						-មុខកាត់ដែកមេ:..... -មុខកាត់ដែកកង:..... -គម្លាតដែកកង:..... -កម្រាស់បេតុងការពារដែក:.....
						-មុខកាត់ដែកមេ:..... -មុខកាត់ដែកកង:..... -គម្លាតដែកកង:..... -កម្រាស់បេតុងការពារដែក:.....
						-មុខកាត់ដែកមេ:..... -មុខកាត់ដែកកង:..... -គម្លាតដែកកង:..... -កម្រាស់បេតុងការពារដែក:.....

- **សសរក្នុងលិខិតអនុញ្ញាត**

ជាន់	ប្រភេទ	កម្លាំងបេតុង (MPA)	ប្រវែង(ម)	មុខកាត់(ស.ម)		ដែក និងកម្រាស់បេតុងការពារដែក
				បណ្តោយ	ទទឹង	
						-មុខកាត់ដែកមេ:..... -មុខកាត់ដែកកង:..... -គម្លាតដែកកង:..... -កម្រាស់បេតុងការពារដែក:.....
						-មុខកាត់ដែកមេ:..... -មុខកាត់ដែកកង:..... -គម្លាតដែកកង:.....

						-កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....

គ.៣.៧- ប្លង់កម្រាល ៖

- ប្លង់កម្រាលជាក់ស្តែង

ជាន់	ប្រភេទ	កម្លាំងបេតុង (MPA)	កម្រាស់ (ម)	បណ្តោយ (ម)	ទទឹង (ម)	ដែក និងកម្រាស់បេតុងការពារដែក
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....

- ប្លង់កម្រាលក្នុងលិខិតអនុញ្ញាត

ជាន់	ប្រភេទ	កម្លាំងបេតុង (MPA)	កម្រាស់ (ម)	បណ្តោយ (ម)	ទទឹង (ម)	ដែក និងកម្រាស់បេតុងការពារដែក
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖.....

						-មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....
						-មុខកាត់ដែកមេ៖..... -មុខកាត់ដែកកង៖..... -គម្លាតដែកកង៖..... -កម្រាស់បេតុងការពារដែក៖.....

គ.៣.៨-ប្រភេទដំបូល ៖ ☐កម្រាលបេតុង ☐ក្បឿង ☐ហ្វីប្រូ ☐ស័ង្កសី
☐ផ្សេងៗ .....

▪ ប្រភេទគ្រឿងធ្វើដំបូល ៖ ☐បេតុង ☐ដែក ☐ឈើ

២. សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់

- ដែក (ម៉ាក ..... ស្តង់ដា .....)
- បេតុង .....
- ស៊ីម៉ងត៍ (ឆ្នាំផលិត ..... ម៉ាក .....)
- ថ្ម .....
- ខ្សាច់ (ប្រភេទ) .....
- កញ្ចក់.....
- ផ្សេងៗ.....

៣. សុវត្ថិភាពអគ្គិភ័យ

-ប្រព័ន្ធពន្លត់អគ្គិភ័យ ☐មានប្លង់ ☐គ្មានប្លង់

• ទុយោពន្លត់អគ្គិភ័យ	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• ក្បាលបាញ់ទឹកពិដាន	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• ទ្វារការពារអគ្គិភ័យ	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• បំពង់ពន្លត់អគ្គិភ័យ	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• Smoke Sensor	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• កណ្តឹងប្រកាសអាសន្ន	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• អាងស្តុកទឹកក្រោមដី	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• ក្បាលបំពង់បូមពន្លត់អគ្គិភ័យ	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• ជណ្តើរអាសន្ន	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ
• ច្រកសុវត្ថិភាព	☐មាន	☐គ្មាន	☐ត្រឹមត្រូវ	☐មិនត្រឹមត្រូវ

- សញ្ញាសម្គាល់ច្រកសុវត្ថិភាព □មាន □គ្មាន □ត្រឹមត្រូវ □មិនត្រឹមត្រូវ

៤-ប្រព័ន្ធបច្ចេកទេស

- លំហពន្លឺ និងខ្យល់ □មាន □គ្មាន □ត្រឹមត្រូវ □មិនត្រឹមត្រូវ
- ប្រព័ន្ធមេកានិកនិងអគ្គិសនី □មានប្លង់ □គ្មានប្លង់ សិក្សាដោយ៖.....
  □មានអាជ្ញាប័ណ្ណលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
  □គ្មានអាជ្ញាប័ណ្ណ
- ប្រព័ន្ធទឹកស្អាត □គ្មានប្លង់ □មានប្លង់ សិក្សាដោយ÷.....
  □មានអាជ្ញាប័ណ្ណ លេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
  □គ្មានអាជ្ញាប័ណ្ណ
- ប្រព័ន្ធលូទឹកភ្លៀង ទឹកកខ្វក់ □មានប្លង់ □គ្មានប្លង់
  □មានអាជ្ញាប័ណ្ណលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....
  □គ្មានអាជ្ញាប័ណ្ណ
- ប្រព័ន្ធការពារអន្តរ៖ □មាន □គ្មាន □ត្រឹមត្រូវ □មិនត្រឹមត្រូវ

ថ្ងៃ..... ខែ..... ឆ្នាំ..... ព.ស. .....

.....ថ្ងៃទី .....ខែ.....ឆ្នាំ.....

ស្នាមមេដៃស្តាំម្ចាស់សំណង់ឬតំណាង

ឈ្មោះ .....

ហត្ថលេខានិងឈ្មោះអ្នកត្រួតពិនិត្យ

ប្រធាន .....

សមាជិក .....

សមាជិក .....

សមាជិក .....

សមាជិក .....

ការទាយតម្លៃ

ផ្នែកសុរិយោដី

.....

.....

.....

.....

ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម

.....

.....

.....

.....

ផ្នែកស្ថាបត្យកម្មនិងគ្រឿងធ្នើសំណង់

.....

.....

.....

.....

សេចក្តីសន្និដ្ឋាន

.....

.....

.....

.....

ថ្ងៃ..... ខែ..... ឆ្នាំ..... ព.ស. .....

..... ថ្ងៃទី .....ខែ.....ឆ្នាំ.....

ប្រធានក្រុមត្រួតពិនិត្យសំណង់/នាយកបច្ចេកទេស

<u>សម្គាល់</u>÷

- ម្ចាស់សំណង់ឬតំណាងត្រូវផ្តិតមេដៃស្តាំលើគ្រប់ទំព័រនៃរបាយការណ៍
- អ្នកធ្វើរបាយការណ៍មានសិទ្ធិបន្ថែមព័ត៌មានផ្សេងទៀតក្នុងករណីចាំបាច់
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពត្រូវមានភ្ជាប់ឯកសារបច្ចេកទេសពាក់ព័ន្ធ
- ករណីរបាយការណ៍ផ្តល់ដោយក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្តងឬក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ នាយកបច្ចេកទេសរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខាដោយផ្ទាល់ និងមានបោះត្រាក្រុមហ៊ុន។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង
ស្តីពី
ការផ្តល់ព័ត៌មានសុរិយោដី
តាមប្រព័ន្ធអេឡិចត្រូនិក

ឆ្នាំ ២០១៩

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...សហវ...

ប្រកាសអន្តរក្រសួង
ស្តីពី
ការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៤/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .-

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

ប្រការ២ .-

នៅក្នុងប្រកាសអន្តរក្រសួងនេះ ពាក្យ **"ព័ត៌មានសុរិយោដី"** សំដៅដល់ព័ត៌មានអំពីការជាប់បន្ទុក ឬ គ្មានជាប់បន្ទុកនៃអចលនវត្ថុណាមួយ ដែលរួមមានព័ត៌មានទាក់ទងនឹងឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សេវាភាព ការរឹបអូស ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ការហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ។

ប្រការ៣ .-

ការប្រមូលចំណូលពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវធ្វើឡើងតាមរយៈគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់តម្លៃ ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយប្រតិបត្តិការ ដោយគិតបញ្ចូលរួមទាំងកម្រៃសេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ។

ចំណូលប្រមូលបានពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ជាកម្មវត្ថុសម្រាប់ការទូទាត់កម្រៃសេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ។ ចំណូលដែលនៅសល់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

ប្រការ៤ .-

លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៥ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រកាសអន្តរក្រសួងនេះ ព្រមទាំងលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

អតិថិជនដែលមានបំណងប្រើប្រាស់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក អាចសាកសួរព័ត៌មាន និងរបៀបនៃការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬ នៅការិយាល័យច្រកចេញចូលតែមួយនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៦ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់។

នៅពេលអនុវត្តចំណូល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

ប្រការ៧ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ៨ .–

កម្រៃសេវាផ្តល់ព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានកំណត់នៅក្នុងប្រការ៣ នៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៩ .–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១០ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០៧ ខែបីកា ឆ្នាំ២០២០ តទៅ។

ថ្ងៃសុក្រ ១៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី	ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន	ជា សុជារ៉ា

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

របៀបពិនិត្យព័ត៌មានសុរិយោដី តាមប្រព័ន្ធអេឡិចត្រូនិក



ព័ត៌មានបន្ថែមសូមទំនាក់ទំនង

(+855) 23 477 5777
www.mlmupc.gov.kh
www.facebook.com/mlmupc.pressteam

© រក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
រៀបចំដោយ : នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
អាសយដ្ឋាន : លេខ៨៧១-៨៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលែក ខណ្ឌចំការមន រាជធានីភ្នំពេញ

១ ស្កែន QR Code លើសន្លឹកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ

នៅពេលលោកអ្នកស្កែន QR Code លើសន្លឹកវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ លោកអ្នកនឹងទទួលព័ត៌មាន អំពីក្បាលដីមានជាអាទិ៍÷

- ទីតាំងក្បាលដី
- លេខក្បាលដី
- ទំហំដី
- ប្រភេទទ្រព្យ
- ម្ចាស់កម្មសិទ្ធិ ដួចមានក្នុងរូបខាងស្តាំ

ព័ត៌មាននេះ ផ្តល់ជូនលោកអ្នកដោយឥតគិតថ្លៃ



២ ការចូលមើលព័ត៌មានអំពីបន្ទុកលើអចលនវត្ថុ

ដើម្បីចូលមើលព័ត៌មានអំពីបន្ទុកលើអចលនវត្ថុ សូមចុចលើពាក្យ “ព័ត៌មានអំពីបន្ទុក” ពេលនោះ លោកអ្នកនឹងឃើញអំពីតម្លៃសេវាចំនួន ២០ ០០០ រៀល ពីការទទួលព័ត៌មានសុរិយោដី ក្នុងមួយលើក។

បន្ទាប់មក សូមចុចលើប៊ូតុង “ចូលមើលព័ត៌មាន”



៣ ការបំពេញព័ត៌មានអ្នកស្នើសុំ និងការជ្រើសរើសធនាគារ

សូមបំពេញព័ត៌មានរបស់អ្នកស្នើសុំដួចខាងក្រោម÷

- បំពេញឈ្មោះ
- លេខទូរស័ព្ទ
- អ៊ីម៉ែល
- លេខកូដសុវត្ថិភាព។

បន្ទាប់មកសូមចុចប៊ូតុង “បញ្ជូន” ផ្ទាំងបញ្ជាក់ព័ត៌មានអ្នកស្នើសុំនឹងចេញមក។

បើលោកអ្នកពិនិត្យឃើញថាព័ត៌មាន ដែលបានបំពេញ ពិតជាត្រឹមត្រូវហើយ សូមចុចប៊ូតុង “យល់ព្រមទូទាត់” ដើម្បីធ្វើការបង់ថ្លៃសេវា។



៤ ការបំពេញព័ត៌មានកាតសម្រាប់ការទូទាត់

សូមបំពេញព័ត៌មានកាត រួចចុចប៊ូតុង “Confirm and Pay”។

លោកអ្នកនឹងឃើញផ្ទាំងបញ្ជាក់ពីការបង់សេវា នឹងផ្ញើទៅកាន់អ៊ីម៉ែលរបស់លោកអ្នក។ បន្ទាប់មក សូមចុចប៊ូតុង “មើលព័ត៌មានបន្ទុក”។

៥ ការបង្ហាញព័ត៌មានអំពីបន្ទុកនៅលើអចលនវត្ថុ

ក្រោយចុចប៊ូតុង “មើលព័ត៌មានបន្ទុក” ព័ត៌មានអំពីបន្ទុកលើអចលនវត្ថុនឹងបង្ហាញដួចខាងក្រោម÷

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាសអន្តរក្រសួង
ស្តីពី
ការផ្តល់ព័ត៌មានសុរិយោដី
តាមប្រព័ន្ធអេឡិចត្រូនិក

ឆ្នាំ ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៨៨ ប្រក.....សហវ.រ្យ

ប្រកាសអន្តរក្រសួង
ស្តីពី
ការផ្តល់ប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូល ពីការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្តីសម្រេចលេខ១១៩ សសរ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង-ស្ថាប័នប្រមូលចំណូល សម្រាប់ការផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៨១៤ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .-

ត្រូវបានផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ចំណាយឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត និងចំណាយពង្រឹងយន្តការប្រមូលចំណូល។

ប្រការ២ .-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង់ថវិកា ១% នៃចំណូលប្រមូលបានពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក ចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (មូលនិធិ ក.ហ.ស) ដោយអនុលោមតាមសារាចរលេខ០០៤ សហវ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ ស្តីពីការបង់ថវិកាចំណូលមិនមែនសារពើពន្ធចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៣ .-

ការផ្តល់ប្រាក់រង្វាន់ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបនឹងចំណូលដែលនៅសល់បន្ទាប់ពីបានទូទាត់កម្រៃសេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ និងត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ចំនួន ៥0%
- ថវិការបស់មូលនិធិ ក.ហ.ស ចំនួន ១%
- ថវិការង្វាន់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ៤៨%
- ថវិការង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% ។

ប្រការ៤ .–

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុរេប្រទានប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រមូលនិធិ ក.ហ.ស ពីចំណូលដែលប្រមូលបានពីកម្រៃសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក។

ប្រការ៥ .–

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវគ្រោងឥណទានចំណាយប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រមូលនិធិ ក.ហ.ស នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ឥណទានដែលបានគ្រោង ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

រាល់ប្រតិបត្តិការចំណាយប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រមូលនិធិ ក.ហ.ស ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចកិច្ចប្រតិបត្តិការចំណាយដទៃទៀតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែរ។

ប្រការ៦ .–

ការទូទាត់ប្រាក់រង្វាន់ និងថវិកា ១% សម្រាប់គាំទ្រមូលនិធិ ក.ហ.ស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

ក. ផ្នែកចំណូល

ធ្វើសលាកបត្របង់ចំណូលថវិកាជាតិដោយចុះចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងធ្វើសំណើសុំកត់ត្រាចំណូល។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណើ និងសលាកបត្របង់ចំណូលថវិកាជាតិមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវតារាងគណនាប្រាក់រង្វាន់, តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់, របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ ដែលបានបើកផ្តល់កន្លងមក។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

ខ. ផ្នែកចំណាយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើសំណើសុំទូទាត់ប្រាក់រង្វាន់, ថវិកា ១% សម្រាប់គាំទ្រមូលនិធិ ក.ហ.ស និងកម្រៃសេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ និងធ្វើអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

ប្រការ៧ .–

ការបើកផ្តល់ថវិការង្វាន់សម្រាប់ឧបត្ថម្ភមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម ÷

ក. ការបើកផ្តល់ថវិការង្វាន់ជូនមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ថវិការង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ប្រការ៨ .–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៩ .–

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។

ថ្ងៃអង្គារ ៤រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី	ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន	ជា សុផារ៉ា

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស

ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្ត សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ឆ្នាំ ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ.....ដែនសា/ប្រក/៨.ក

ប្រកាស
ស្តីពី
ការតែងតាំងមន្ត្រីអធិការកិច្ចសំណង់

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤ ន.ស.៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រ៥០ មាត្រ៦៦ មាត្រ៧៤ មាត្រ៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស.កយ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ប្រការ១ ..

តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់ស្តីពីសំណង់។

ប្រការ២ ..

មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានសមាសភាពដូចខាងក្រោមៈ

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
I. មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ជាតិ			
ក.អគ្គនាយកដ្ឋានសំណង់			
១.ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់			
១	ឆាន់ សួរ្យផល	ប្រុស	អគ្គនាយក
២	ជា ផលរី	ប្រុស	អគ្គនាយករង
៣	ប៉ាក ចាន់ផល	ប្រុស	អគ្គនាយករង
៤	យ៉ាន់ វ៉ាន់ដីលុច	ប្រុស	អគ្គនាយករង
៥	ឆេង វ៉ាន់ថា	ប្រុស	អគ្គនាយករង
៦	លី រស្មី	ប្រុស	អគ្គនាយករង

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
២.នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់			
៧	ជីវ ស៊ីវផេង	ប្រុស	ប្រធាននាយកដ្ឋាន
៨	ញ៉ូ ហេង	ប្រុស	អនុប្រធាននាយកដ្ឋាន
៩	ប៊ុល រ៉ានី	ប្រុស	អនុប្រធាននាយកដ្ឋាន
១០	លាង ហេងជ	ប្រុស	ប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម
១១	ហេង ហាក់	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម
១២	ឈង សុភ័ណ	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម
១៣	ចាន់ ធម្ម	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម
១៤	តាំង ប៊ុណ្ណារិទ្ធ	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិវិស្វកម្ម
១៥	ឥន ឆវី	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម
១៦	ផាត់ ប៊ូរី	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម
១៧	រ៉ែន កែវឡៃ	ប្រុស	អនុប្រធានការិយាល័យបទដ្ឋាននិងបទប្បញ្ញត្តិស្ថាបត្យកម្ម
១៨	ហុង ស្រ៊ុន	ប្រុស	អនុប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ
១៩	សួរ សាមី	ប្រុស	អនុប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ
២០	ទែន សារឿន	ប្រុស	អនុប្រធានការិយាល័យកិច្ចការទូទៅ ព័ត៌មានវិទ្យា និងឯកសារ
២១	ម៉ាច ហ៊ួ	ប្រុស	មន្ត្រី
៣.នាយកដ្ឋានសិក្ខាគម្រោងប្លង់			
២២	ឈៀក វីរៈ	ប្រុស	ប្រធាននាយកដ្ឋាន
២៣	ជិន ឌៀប	ប្រុស	អនុប្រធាននាយកដ្ឋាន
២៤	ឱ វឌ្ឍនៈ	ប្រុស	អនុប្រធាននាយកដ្ឋាន
២៥	លឹម ប៉ូ	ប្រុស	អនុប្រធាននាយកដ្ឋាន
២៦	ឈុត សៅ	ប្រុស	អនុប្រធាននាយកដ្ឋាន
២៧	ជួរ ជិនសុធា	ប្រុស	អនុប្រធាននាយកដ្ឋាន
២៨	យឹម មុនី	ប្រុស	ប្រធានការិយាល័យស្ថាបត្យកម្ម

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
២៩	សេក សំខេមរា	ប្រុស	ប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ
៣០	សូត្រ ពង្សវិចិត្រ	ប្រុស	ប្រធានការិយាល័យបែបបទអាជីវកម្ម
៣១	ដួង ស៊ីវុធ	ប្រុស	អនុប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ
៣២	យី វុត្ថា	ប្រុស	អនុប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ
៣៣	ម៉ូវ ច័ន្ទម៉ារ៉ា	ប្រុស	អនុប្រធានការិយាល័យវិស្វកម្មនិងកិច្ចការតម្លៃ
៣៤	កឹម សុគន្ធា	ប្រុស	អនុប្រធានការិយាល័យស្ថាបត្យកម្ម
៣៥	សុក ធី	ប្រុស	អនុប្រធានការិយាល័យស្ថាបត្យកម្ម
៣៦	សេក ច័ន្ទមុនី	ប្រុស	អនុប្រធានការិយាល័យស្ថាបត្យកម្ម
៣៧	ប៉ែង អាន	ប្រុស	អនុប្រធានការិយាល័យបែបបទអាជីវកម្ម
៤.នាយកដ្ឋានសំណង់			
៣៨	ទិត ខេមរា	ប្រុស	ប្រធាននាយកដ្ឋាន
៣៩	អ៊ុំ សារុំ	ប្រុស	អនុប្រធាននាយកដ្ឋាន
៤០	តាន់ ហ៊ាង ហានីដា	ប្រុស	អនុប្រធាននាយកដ្ឋាន
៤១	មាឃ ពន្លក	ប្រុស	អនុប្រធាននាយកដ្ឋាន
៤២	ញ៉ែម រ៉ាឌី	ប្រុស	ប្រធានការិយាល័យជួសជុលនិងថែទាំ
៤៣	រស់ សុភក្តិ	ប្រុស	ប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ
៤៤	ឡេង សេដ្ឋា	ប្រុស	ប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន
៤៥	ហេ ផាន់នី	ប្រុស	អនុប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ
៤៦	ប៉ុន សីហាមានី	ប្រុស	អនុប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ
៤៧	ហួង សុផាត	ប្រុស	អនុប្រធានការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យ
៤៨	អ៊ុំ សុពុត្រា	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន
៤៩	ប៊ុង ថារិទ្ធ	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន
៥០	ឃួន ចាន់	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន
៥១	គិត នាគសែន	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិការងារការដ្ឋាន

ល.រ	គោត្តនាម-នាម	តេទ	តួនាទី
៥២	ស៊ុក តារាវុធ	ប្រុស	អនុប្រធានការិយាល័យជួសជុលនិងថែទាំ
៥៣	ឌុច មុន្នីរក្ស	ប្រុស	អនុប្រធានការិយាល័យជួសជុលនិងថែទាំ
៥៤	ម៉ុម មុនី	ប្រុស	មន្ត្រី
៥៥	ខឹម ពិសី	ប្រុស	មន្ត្រី
៥៦	ឃុន សុធី	ប្រុស	មន្ត្រី
៥៧	ខៀង ប្លូម្ប៉ូ	ប្រុស	មន្ត្រី
៥៨	រស់ សារ៉ាត់មុនី	ប្រុស	មន្ត្រី
៥៩	ឆយ វណ្ណៈ	ប្រុស	មន្ត្រី
ខ.អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម			
១.ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម			
៦០	ឆាយ ឫទ្ធិសែន	ប្រុស	អគ្គនាយក
៦១	សារេត ឫភមី	ប្រុស	អគ្គនាយករង
៦២	ឈឹម សុគន្ធ	ប្រុស	អគ្គនាយករង
៦៣	យី យ៉ាណារតន៍	ប្រុស	អគ្គនាយករង
៦៤	លឹម អ៊ីវ	ប្រុស	អគ្គនាយករង
៦៥	ម៉ែង ប៊ុណ្ណាវិទ្ធ	ប្រុស	អគ្គនាយករង
២.នាយកដ្ឋានស្រាវជ្រាវនិងបទប្បញ្ញត្តិ			
៦៦	មៀង សុថា	ប្រុស	ប្រធាននាយកដ្ឋាន
៦៧	ចាប់ ច័ន្ទថេរា	ប្រុស	អនុប្រធាននាយកដ្ឋាន
៦៨	ចាន់ កុកអួង	ប្រុស	អនុប្រធាននាយកដ្ឋាន
៦៩	ឈឹម ណាវី	ស្រី	អនុប្រធាននាយកដ្ឋាន
៧០	អ៊ឹង ណារ៉ែត	ប្រុស	អនុប្រធាននាយកដ្ឋាន
៧១	ប៊ុន សត្យា	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិនគរូបនីយកម្ម
៧២	សាន សុភី	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិនគរូបនីយកម្ម

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
៧៣	គង់ សុគន្ធា	ប្រុស	អនុប្រធានការិយាល័យទំនាក់ទំនងនិងកិច្ចការទូទៅ
៧៤	កែវ ដាវីន	ប្រុស	អនុប្រធានការិយាល័យបទប្បញ្ញត្តិរៀបចំដែនដី
៧៥	សាយ ម៉ារុត	ប្រុស	មន្ត្រី
៧៦	ជុំ សំអាត	ប្រុស	មន្ត្រី
៧៧	ង៉ែត តារា	ប្រុស	មន្ត្រី
៧៨	សុង ឌុល	ប្រុស	មន្ត្រី
៧៩	កែ វុធនី	ប្រុស	មន្ត្រី
៨០	គីម កញ្ញា	ប្រុស	មន្ត្រី
៨១	ជាង សុងហៃ	ប្រុស	មន្ត្រី
៨២	តែ តាំងហ៊ាង	ប្រុស	មន្ត្រី
៨៣	នៀម ប្រាក់ភ្ញ	ប្រុស	មន្ត្រី
៨៤	មួន បញ្ញា	ប្រុស	មន្ត្រី
៨៥	ឈឹម ឈានី	ប្រុស	មន្ត្រី
៣.នាយកដ្ឋាននគរូបនីយកម្ម			
៨៦	សេក សុធិរិទ្ធ	ប្រុស	ប្រធាននាយកដ្ឋាន
៨៧	ប៉ុល ថាវ៉ែត	ប្រុស	អនុប្រធាននាយកដ្ឋាន
៨៨	អ៊ុំ ប៊ូរិទ្ធ	ប្រុស	អនុប្រធាននាយកដ្ឋាន
៨៩	ម៉ៅ ក្រឹង	ប្រុស	អនុប្រធាននាយកដ្ឋាន
៩០	ឆាន់ សុជាតិ	ប្រុស	អនុប្រធាននាយកដ្ឋាន
៩១	អ៊ឹង រដ្ឋា	ប្រុស	អនុប្រធាននាយកដ្ឋាន
៩២	ញឹម ណារិនដេត	ស្រី	ប្រធានការិយាល័យនគរូបនីយកម្ម
៩៣	អន ស៊ីថន	ប្រុស	អនុប្រធានការិយាល័យនគរូបនីយកម្ម
៩៤	អួន ពុទ្ធិគុណ	ប្រុស	អនុប្រធានការិយាល័យនគរូបនីយកម្ម
៩៥	សាន ស៊ីវត្ថា	ប្រុស	អនុប្រធានការិយាល័យបច្ចេកទេស

ល.រ	គោត្តនាម-នាម	តេទ	តួនាទី
៩៦	ឆាយ គន្ធា	ប្រុស	មន្ត្រី
៩៧	សំ ភក្តី	ប្រុស	មន្ត្រី
៩៨	សៅ ប្រេម៉ា	ប្រុស	មន្ត្រី
៩៩	កៅ ទ្រូក	ប្រុស	មន្ត្រី
១០០	ឈន សេដ្ឋា	ប្រុស	មន្ត្រី
១០១	អ៊ិត ច័ន្ទា	ប្រុស	មន្ត្រី
១០២	អ៊ុំ វណ្ណារិទ្ធ	ប្រុស	មន្ត្រី
១០៣	លី សុវណ្ណ	ប្រុស	មន្ត្រី
១០៤	វ៉ែ សុថា	ប្រុស	មន្ត្រី
៥.នាយកដ្ឋានរៀបចំដែនដី			
១០៥	សេង ប៊ុនឌឿន	ប្រុស	ប្រធាននាយកដ្ឋាន
១០៦	ប៊ុន បារមី	ប្រុស	អនុប្រធាននាយកដ្ឋាន
១០៧	ជា សំអាត	ប្រុស	អនុប្រធាននាយកដ្ឋាន
១០៨	យ៉ង់ សុបញ្ញា	ប្រុស	អនុប្រធាននាយកដ្ឋាន
១០៩	ហេង សុខសំបូរ	ប្រុស	ប្រធានការិយាល័យរៀបចំឯកសារដែនដី
១១០	យ៉ាវ អនាកុល	ប្រុស	ប្រធានការិយាល័យគម្រោង
១១១	យិន គីមហុង	ប្រុស	អនុប្រធានការិយាល័យអភិវឌ្ឍន៍ដែនដី
១១២	កន ជ័យ	ប្រុស	អនុប្រធានការិយាល័យអភិវឌ្ឍន៍ដែនដី
១១៣	ហេង សុភា	ប្រុស	អនុប្រធានការិយាល័យគម្រោង
១១៤	នៅ សុផាណារ៉ា	ប្រុស	អនុប្រធានការិយាល័យគម្រោង
១១៥	សិទ្ធ សុភា	ប្រុស	អនុប្រធានការិយាល័យគម្រោង
១១៦	ជាង ផល្លាយ	ប្រុស	អនុប្រធានការិយាល័យរៀបចំឯកសារដែនដី
១១៧	ឡាយ ចន្ថា	ស្រី	អនុប្រធានការិយាល័យរៀបចំឯកសារដែនដី
១១៨	សុខ ទូច	ប្រុស	មន្ត្រី

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
១១៩	ប៉ុល ច័ន្ទមុនី	ប្រុស	មន្ត្រី
១២០	អ៊ុំ ប៊ុនថន	ប្រុស	មន្ត្រី
១២១	អ៊ី ឆវីរ៉ា	ប្រុស	មន្ត្រី
១២២	បាន មុនីរដ្ឋ	ប្រុស	មន្ត្រី
១២៣	តាំង វីណា	ប្រុស	មន្ត្រី
១២៤	ធិ គុណវិចិត្រ	ប្រុស	មន្ត្រី
១២៥	កែវ វណ្ណារិន	ប្រុស	មន្ត្រី
១២៦	អ៊ីង ងួនសុង	ប្រុស	មន្ត្រី
គ.អគ្គនាយកដ្ឋានលំនៅឋាន			
១២៧	បេងហុង សុជាតិខេមរ៉ូ	ប្រុស	អគ្គនាយក
II. **មន្ត្រីអធិការកិច្ចសំណង់ថ្នាក់ក្រោមជាតិ**			
១.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ			
១២៨	សារិន វណ្ណា	ប្រុស	ប្រធានមន្ទីរ
១២៩	ស៊ឹង សុច្ចរ៉ា	ប្រុស	អនុប្រធានមន្ទីរ
១៣០	មូល ណារិន	ប្រុស	អនុប្រធានមន្ទីរ
១៣១	អេង ច័ន្ទឆវី	ស្រី	អនុប្រធានមន្ទីរ
១៣២	ម៉ី ចិត្រា	ប្រុស	អនុប្រធានមន្ទីរ
១៣៣	ម៉ុម ថាណេត	ប្រុស	អនុប្រធានមន្ទីរ
១៣៤	ហឿង រ័ត្នសុខា	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៣៥	អ៊ុក សុថា	ប្រុស	ប្រធានការិយាល័យលំនៅឋាន
១៣៦	បេ ប៊ូរិន្ទ	ប្រុស	ប្រធានការិយាល័យសំណង់
១៣៧	ហ៊ឹម ឃុនប៉ូឡា	ស្រី	អនុប្រធានការិយាល័យសំណង់
១៣៨	ហោ ប៊ុនលាង	ប្រុស	អនុប្រធានការិយាល័យសំណង់
១៣៩	ហ៊ូ កំសាន្ត	ប្រុស	អនុប្រធានការិយាល័យសំណង់

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
១៤០	តង់ ប៉ូច	ប្រុស	អនុប្រធានការិយាល័យសំណង់
១៤១	ឈុន វុឌ្ឍី	ប្រុស	អនុប្រធានការិយាល័យសំណង់
១៤២	វ៉ែង គ្រី	ប្រុស	អនុប្រធានការិយាល័យសំណង់
១៤៣	បេងហុង សុជាតិសិលា	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៤៤	ភន សុមនា	ស្រី	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៤៥	អ៊ុំ ធន់	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
១៤៦	ចាន់ វត្ថា	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៤៧	ណៅ ប៊ុនធឿន	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៤៨	ហោ សុភ័ក្ត	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៤៩	ទូស សាផាន់	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៥០	ឆុំម ឌីដា	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៥១	លឹម សាន់ដេយ៍	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
២.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ			
១៥២	អាង ណារិទ្ធ	ប្រុស	ប្រធានមន្ទីរ
១៥៣	ឡុង វុធ	ប្រុស	អនុប្រធានមន្ទីរ
១៥៤	ជាធូ វឌ្ឍនា	ប្រុស	អនុប្រធានមន្ទីរ
១៥៥	ប៉ង់ រ៉ុម	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៥៦	អួង ហេងឡុង	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៥៧	ប៉េងទី វិបុល	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តឃ្លាំងដឹបង			
១៥៨	អ៊ូ ដារី	ប្រុស	ប្រធានមន្ទីរ
១៥៩	ឃី សុផល	ប្រុស	អនុប្រធានមន្ទីរ
១៦០	សួន សុភា	ប្រុស	អនុប្រធានមន្ទីរ
១៦១	សុិម វត្ថា	ប្រុស	ប្រធានការិយាល័យសំណង់

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
១៦២	ម៉ុក សុផាន់ណារ៉ា	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៦៣	ហួត សុចិត្ត	ប្រុស	ប្រធានការិយាល័យលំនៅឋាន
១៦៤	ចាប រី	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៦៥	ញឹក ប៊ុនថុន	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៦៦	អ៊ុយ ចន្ថន	ប្រុស	អនុប្រធានការិយាល័យសំណង់
១៦៧	សុង សុវណ្ណារី	ប្រុស	អនុប្រធានការិយាល័យសំណង់
១៦៨	ហាក់ បូណា	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៦៩	ជា រដ្ឋា	ប្រុស	មន្ត្រីនៃការិយាល័យលំនៅឋាន
៤.មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល			
១៧០	សុក កាន់ណារិទ្ធ	ប្រុស	ប្រធានមន្ទីរ
១៧១	ទៀង កុស្សារៈ	ប្រុស	អនុប្រធានមន្ទីរ
១៧២	ជា វណ្ណា	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៧៣	សុខ សុវណ្ណារិទ្ធី	ប្រុស	ប្រធានការិយាល័យសំណង់
១៧៤	កែវ សារ៉ន	ប្រុស	ប្រធានការិយាល័យលំនៅឋាន
១៧៥	អន ហួច	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
១៧៦	ចាន់ សុខប៊ុល្លា	ស្រី	អនុប្រធានការិយាល័យលំនៅឋាន
១៧៧	ហាក់ ឌីម៉ង់	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៧៨	សោម សេនា	ប្រុស	អនុប្រធានការិយាល័យសំណង់
១៧៩	ថេង បញ្ញាដា	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៨០	ហេង សុធា	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៨១	ឃុន ភិរម្យ	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៨២	ហួត ខន	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៨៣	ភឿង បូផា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៨៤	ហេង វីរៈ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
១៨៥	ហេង រចនា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៨៦	ហេង រស្មី	ប្រុស	មន្ត្រីនៃការិយាល័យលំនៅឋាន
៥.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ			
១៨៧	នួន សុធា	ប្រុស	ប្រធានមន្ទីរ
១៨៨	ខួច សុភក្ត្រ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៨៩	ដួង សារ៉ាក់	ប្រុស	ប្រធានការិយាល័យលំនៅឋាន
១៩០	ភ ភិន	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
១៩១	អោម សារាក់ខណ្ឌី	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
១៩២	កង វិជ្ជាវុឌ្ឍិ	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៩៣	ទ្រូ ប៊ុនណា	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៦.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកែប			
១៩៤	សុទ្ធ ពុទ្ធិម៉ានីន	ប្រុស	ប្រធានមន្ទីរ
១៩៥	ប៉ាត ម៉ៅ	ប្រុស	អនុប្រធានមន្ទីរ
១៩៦	សុក សុវិសិទ្ធ	ប្រុស	ប្រធានការិយាល័យសំណង់
១៩៧	ណុប ប្អូរ៉ាមី	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
១៩៨	លឹម ម៉ៅ	ប្រុស	ប្រធានការិយាល័យលំនៅឋាន
១៩៩	ស៊ឹម ពលទិវា	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២០០	ណៃ ឃី	ប្រុស	អនុប្រធានការិយាល័យសំណង់
២០១	ឆែឡេង សុខថាន	ស្រី	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២០២	កែន សិរីវឌ្ឍនា	ប្រុស	មន្ត្រីនៃការិយាល័យលំនៅឋាន
៧.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត			
២០៣	ជាញ់ សារី	ប្រុស	ប្រធានមន្ទីរ
២០៤	ខៀវ រិទ្ធី	ប្រុស	អនុប្រធានមន្ទីរ
២០៥	ស៊ឹម សុខជា	ប្រុស	អនុប្រធានមន្ទីរ

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
២០៦	សំ ស៊ីណាត	ប្រុស	ប្រធានការិយាល័យសំណង់
២០៧	ម៉ុក សាយសុវណ្ណា	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២០៨	ប៊ុន សុភា	ប្រុស	អនុប្រធានការិយាល័យសំណង់
២០៩	សេង ពិសិដ្ឋ	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២១០	ប៊ុន អាន	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
៨.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ			
២១១	ចេង ស្រុង	ប្រុស	ប្រធានមន្ទីរ
២១២	ហង្ស ភិរក្ស	ប្រុស	អនុប្រធានមន្ទីរ
២១៣	លូភួង ដាវ៉ាលីន	ប្រុស	អនុប្រធានមន្ទីរ
២១៤	ប៊ុន វុត្ថា	ប្រុស	អនុប្រធានមន្ទីរ
២១៥	គាត សុវន្ត	ប្រុស	ប្រធានការិយាល័យសំណង់
២១៦	សេង សោភ័ណ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២១៧	ឃុន ដារ៉ា	ប្រុស	អនុប្រធានការិយាល័យសំណង់
២១៨	យូ ញឹមឈៀង	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២១៩	ហួយ វណ្ណដា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២២០	អន ស្រស់	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
២២១	ហែម សុភាព	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
៩.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង			
២២២	រស់ វីរ៉ាវុធ	ប្រុស	ប្រធានមន្ទីរ
២២៣	នួន ពន្លឺ	ប្រុស	អនុប្រធានមន្ទីរ
២២៤	ឡុង គីមថា	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២២៥	សេង ថៃ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២២៦	មិត្ត ចាន់បូរ៉ា	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២២៧	ហ៊ាន យុទ្ធីរ៉ា	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
២២៨	ជាំ ជីលុច	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២២៩	ប៉ូ លាងហេង	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១០.មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ			
២៣០	តាប់ ម៉ាឡៃ	ប្រុស	ប្រធានមន្ទីរ
២៣១	ជុំ ស៊ីនណារ៉ា	ប្រុស	អនុប្រធានមន្ទីរ
២៣២	ម៉ម ណារ៉ែ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៣៣	គង់ សុជា	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៣៤	ផៃ អុល	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៣៥	សួន ស៊ីថាន់	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៣៦	អ៊ុ ឆៃតេង	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៣៧	ង៉ូវ ចេងហុង	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៣៨	ហ៊ី ស៊ីថន	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៣៩	ហ៊ែល សីហា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៤០	សារី ពៅ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៤១	ឈឿម រ៉ាក់	ប្រុស	មន្ត្រីនៃការិយាល័យលំនៅឋាន
១១.មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាម			
២៤២	ម៉ា ហួឌី	ប្រុស	ប្រធានមន្ទីរ
២៤៣	ផេង ភាត	ប្រុស	ប្រធានការិយាល័យសំណង់
២៤៤	ធួន វិចាវិន	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៤៥	ព្រឹម សុខលីន	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៤៦	ម៉ម ភួងដានួ	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៤៧	ធួន សុថារី	ស្រី	អនុប្រធានការិយាល័យលំនៅឋាន
២៤៨	យិន គីមលី	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៤៩	អាន មីដា	ប្រុស	អនុប្រធានការិយាល័យសំណង់

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
២៥០	ស សូហាស់	ប្រុស	អនុប្រធានការិយាល័យសំណង់
២៥១	ផុន ផាណារិទ្ធ	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១២.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ			
២៥២	អ៊ឹម សុឌីណា	ប្រុស	ប្រធានមន្ទីរ
២៥៣	ប៉ូច ណាត	ប្រុស	អនុប្រធានមន្ទីរ
២៥៤	ប៉ែន ពីនី	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៥៥	មុយ ប៉ោគី	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៥៦	អ៊ឹម ប៊ុនថុល	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៣.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង			
២៥៧	លី សុភា	ប្រុស	ប្រធានមន្ទីរ
២៥៨	សោម សុភក្ត្រា	ប្រុស	អនុប្រធានមន្ទីរ
២៥៩	ផេង សុគន្ធ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៦០	អេង ណារិទ្ធ	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៦១	តយ ភឿង	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៦២	ផៃ សម្បត្តិ	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៦៣	ស ជារ៉ា	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៤.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់			
២៦៤	ឱន សទ្ធា	ប្រុស	ប្រធានមន្ទីរ
២៦៥	ម៊ឹង សុជាតា	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៦៦	ជុំ សារ៉ាល់	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៦៧	ប្រសិទ្ធ សិទ្ធិគុណ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៥.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តប៉ៃលិន			
២៦៨	ស សុខុន	ប្រុស	ប្រធានមន្ទីរ
២៦៩	ហុង ពៅ	ប្រុស	អនុប្រធានមន្ទីរ

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
២៧០	សួន លក្សស្មី	ប្រុស	អនុប្រធានមន្ទីរ
២៧១	ជា សុក្រលី	ប្រុស	ប្រធានការិយាល័យសំណង់
២៧២	ស៊ី រឿន	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៧៣	សោភ័ណ បញ្ញា	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៧៤	ឈិន សៀកម៉េង	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៧៥	ឃិន វុទ្ធី	ប្រុស	អនុប្រធានការិយាល័យសំណង់
២៧៦	អ៊ុំ សារ៉ន	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៧៧	វ៉ាន សម្បត្តិ	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
២៧៨	ហ៊ាន ពិសិដ្ឋ	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៦.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តឧត្តរមានជ័យ			
២៧៩	គីម គារិន	ប្រុស	ប្រធានមន្ទីរ
២៨០	សុខ សារិន	ប្រុស	អនុប្រធានមន្ទីរ
២៨១	លី រ័ត្នមនី	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៨២	ម៉ៅ ញ ជីវ័ន	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៨៣	អឹម អាន	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៨៤	តាត សុវឌ្ឍនា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៧.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ			
២៨៥	សំ សារឿន	ប្រុស	ប្រធានមន្ទីរ
២៨៦	សួស គីមសឿន	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៨៧	ឆុង រិទ្ធី	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៨៨	ជា ប៊ុនសុខគា	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
២៨៩	ម៉ុម សុទ្ធារិទ្ធ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៩០	សុន ណាំ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
១៨.មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ			
២៩១	កៅ ម៉ាឌីឡែន	ប្រុស	ប្រធានមន្ទីរ
២៩២	ឆយ គីមឆាយ	ប្រុស	អនុប្រធានមន្ទីរ
២៩៣	ចាន់ គង់	ប្រុស	អនុប្រធានមន្ទីរ
២៩៤	ជួប ចំណាន	ប្រុស	ប្រធានការិយាល័យលំនៅឋាន
២៩៥	ហ៊ិត វិច្ឆិកា	ស្រី	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៩៦	ម៉ាត់ លី	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៩៧	មេត រម្យនា	ប្រុស	អនុប្រធានការិយាល័យសំណង់
២៩៨	ជឿន វ៉ាន់ដេត	ប្រុស	អនុប្រធានការិយាល័យសំណង់
២៩៩	បេ រតនា	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
១៩.មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្ទឹងត្រែង			
៣០០	ម៉ិញ ស៊ីថាយ	ប្រុស	ប្រធានមន្ទីរ
៣០១	អ៊ូប សាខា	ប្រុស	អនុប្រធានមន្ទីរ
៣០២	ស៊ាង សុភត្ត័	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣០៣	ស សុធួ	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣០៤	លន់ ភាព	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
៣០៥	លី យីមគ្រុយ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣០៦	ម៉ៅ ប៊ុណ្ណារ៉ាត់	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣០៧	គីន ស៊ុនហួរ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២០.មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគិរី			
៣០៨	លី ឧសភា	ប្រុស	ប្រធានមន្ទីរ
៣០៩	កែវ ម៉ីនជ័យ	ប្រុស	អនុប្រធានមន្ទីរ
៣១០	ទីម មុនីរតន៍	ប្រុស	អនុប្រធានមន្ទីរ

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
៣១១	អ៊ុច វណ្ណី	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣១២	សួង វិសាល	ប្រុស	ប្រធានការិយាល័យលំនៅឋាន
៣១៣	សឿង ពិសិដ្ឋ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២១.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី			
៣១៤	ម៉ៅ ចំរើន	ប្រុស	ប្រធានមន្ទីរ
៣១៥	យិម វណ្ណា	ប្រុស	អនុប្រធានមន្ទីរ
៣១៦	ហ៊ូ រ៉ាវែង	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣១៧	ង៉ាំ សម្បត្តិ	ប្រុស	ប្រធានការិយាល័យលំនៅឋាន
៣១៨	ខឿន ចេន	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
៣១៩	សោម សុភា	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣២០	ន្ទូ សារេន	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣២១	អុន ឌីម៉ង់	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣២២	សេង ម៉ៅឫទ្ធី	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២២.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្ទឹងមានជ័យ			
៣២៣	ហ៊ី សាយ	ប្រុស	ប្រធានមន្ទីរ
៣២៤	ចៅ ឡង់ឌី	ប្រុស	អនុប្រធានមន្ទីរ
៣២៥	ឆាយ ហាក់លី	ប្រុស	ប្រធានការិយាល័យសំណង់
៣២៦	ម៉ែង ហ៊ាង	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
៣២៧	ភូ សុជា	ប្រុស	ប្រធានការិយាល័យលំនៅឋាន
៣២៨	ថាប់ ភីរុណ	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
៣២៩	មុំ បូណា	ប្រុស	អនុប្រធានការិយាល័យសំណង់
៣៣០	យាង វណ្ណា	ប្រុស	អនុប្រធានការិយាល័យសំណង់
៣៣១	ស ស៊ីណាត	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
៣៣២	ឡួយ វឌ្ឍនា	ប្រុស	អនុប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
៣៣៣	ជួង តិច	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
៣៣៤	ជួរ សំណាង	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
៣៣៥	ខ្ចៅ សុភ័ក្រ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
២៣.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រៃវែង			
៣៣៦	អេង ផេងអាន	ប្រុស	ប្រធានមន្ទីរ
៣៣៧	សុខ ហួរ	ប្រុស	អនុប្រធានមន្ទីរ
៣៣៨	បេ សុជាតិ	ប្រុស	ប្រធានការិយាល័យសំណង់
៣៣៩	ហេង ហួរ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
៣៤០	ឌី សារុឡឺ	ប្រុស	ប្រធានការិយាល័យលំនៅឋាន
៣៤១	វុធ តារាហ៍ស្ស	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
៣៤២	លៀស ភុន	ប្រុស	អនុប្រធានការិយាល័យសំណង់
២៤.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្វាយរៀង			
៣៤៣	គីម ពិសិដ្ឋ	ប្រុស	ប្រធានមន្ទីរ
៣៤៤	ចាន់ មុន្នី	ប្រុស	អនុប្រធានមន្ទីរ
៣៤៥	ប៊ុន ចំរើន	ប្រុស	ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣៤៦	អន យ៉ាន់ណា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣៤៧	អ៊ុំ វាសនា	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣៤៨	អៀង លាងហ៊ី	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៣៤៩	កែវ សិរីសិទ្ធ	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៥.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ			
៣៥០	ប៉ូច សុធារិទ្ធ	ប្រុស	ប្រធានមន្ទីរ
៣៥១	សយ វុធ	ប្រុស	អនុប្រធានមន្ទីរ
៣៥២	សុំ ឡាមី	ប្រុស	អនុប្រធានមន្ទីរ
៣៥៣	សុក រតនា	ប្រុស	អនុប្រធានមន្ទីរ

ល.រ	គោត្តនាម-នាម	ភេទ	តួនាទី
៣៥៤	អៀង សុបញ្ញា	ប្រុស	ប្រធានការិយាល័យសំណង់
៣៥៥	អ៊ុជ សគុណ	ប្រុស	ប្រធានការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
៣៥៦	មា ផ្លូ	ប្រុស	ប្រធានការិយាល័យលំនៅឋាន
៣៥៧	អ៊ីត អាឡាមីន	ប្រុស	អនុប្រធានការិយាល័យលំនៅឋាន
៣៥៨	គាំម ចាន់សត្យា	ប្រុស	អនុប្រធានការិយាល័យសំណង់
៣៥៩	ទ្រី សេងហ៊ាង	ប្រុស	មន្ត្រីនៃការិយាល័យរៀបចំដែនដីនិងនគរូបនីយកម្ម
៣៦០	កែ សុភ័ក្រ	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
៣៦១	ហេង រិទ្ធីវង្ស	ប្រុស	មន្ត្រីនៃការិយាល័យសំណង់
៣៦២	ឌុច ដេត	ប្រុស	មន្ត្រីនៃការិយាល័យសំណង់

ប្រការ៣ ..

មន្ត្រីអធិការកិច្ចសំណង់ ត្រូវបំពេញភារកិច្ចដូចមានកំណត់ក្នុងច្បាប់ស្តីពីសំណង់ និងប្រកាសអន្តរក្រសួងលេខ១១៨ ប្រក/ដ.ន.ស.កយ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនិងបែបបទនៃការធ្វើអធិការកិច្ចសំណង់។

ប្រការ៤ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥ ..

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ក្រ ៤ កើត ខែភទ្របទ ឆ្នាំជូត ឆស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស

ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្ត សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ឆ្នាំ ២០២១

ប្រកាស
ស្តីពី
បែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ឯកឧត្តមនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រ៥០ មាត្រ៦៦ មាត្រា៧៤ និងមាត្រ៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១._

ប្រកាសនេះកំណត់អំពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាពអាជ្ញាបណ្ណ និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្នុងគោលបំណងដើម្បីអនុវត្តអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ប្រការ២._

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- **តំណាងស្របច្បាប់របស់ក្រុមហ៊ុន** សំដៅដល់អគ្គនាយកក្រុមហ៊ុន នាយកក្រុមហ៊ុន ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ឬអភិបាលក្រុមហ៊ុនដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

៣-**វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់លិខិតផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤-**វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

៥-**វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ** សំដៅដល់វិញ្ញាបនបត្រស្ថាបត្យករចុះបញ្ជី វិញ្ញាបនបត្រស្ថាបត្យករ គ. ស. ក. Certificate of Registration as an ASEAN ARCHITECT (វិញ្ញាបនបត្រចុះបញ្ជីជាស្ថាបត្យករអាស៊ាន) វិញ្ញាបនបត្រស្ថាបត្យករបរទេសចុះបញ្ជី វិញ្ញាបនបត្រវិស្វករចុះបញ្ជី វិញ្ញាបនបត្រវិស្វករចុះបញ្ជីដំបូង វិញ្ញាបនបត្រវិស្វករអាជីព វិញ្ញាបនបត្រចុះបញ្ជីវិស្វករបរទេស និងវិញ្ញាបនបត្រចុះបញ្ជីវិស្វករអាជីពឆ្នើមបរទេស។

៦-**អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៧-**អ្នកកាន់អាជ្ញាបណ្ណ** សំដៅដល់អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលបានទទួលសិទ្ធិផ្តល់ដោយអាជ្ញាបណ្ណ និងដែលមានគោត្តនាមនិងនាមឬនាមករណ៍នៅលើអាជ្ញាបណ្ណ។

៨-**អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់ក្រុមការងារនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៩-**អ្នកវិជ្ជាជីវៈ** សំដៅដល់ស្ថាបត្យករនិងវិស្វករដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងនាយកបច្ចេកទេសឬអ្នកបច្ចេកទេសនៃក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ។

១០-**ឯកសារបញ្ជាក់បទពិសោធន៍ការងារ** សំដៅដល់កិច្ចសន្យាការងារ លិខិតបញ្ជាក់ ឬឯកសារដទៃទៀតដែលផ្តល់ព័ត៌មានអំពីការងារដែលអ្នកវិជ្ជាជីវៈធ្លាប់បានបំពេញកន្លងមក មានជាអាទិ៍ មុខជំនាញ រយៈពេល ទីកន្លែង អត្តសញ្ញាណរបស់និយោជក។

១១-**ឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែង** សំដៅដល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នយ៉ាងតិច១២(ដប់ពីរ)ខែ សម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាពាណិជ្ជកររួមមានទិដ្ឋាការប្រភេទ $E1_{EX}$ $E2_{EX}$ $E3_{EX}$ E_B ជនបរទេសមិនមែនអន្តោប្រវេសន្ត

ជាអ្នកបច្ចេកទេសជំនាញរួមមានទិដ្ឋាការប្រភេទ E_T និងជនបរទេសមិនមែនអន្តោប្រវេសន្ត ជានិស្សិតរួមមានទិដ្ឋាការប្រភេទ E_S។

ជំពូកទី២

បែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ

ប្រការ៣._

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ មានដូចខាងក្រោម៖

១- ពាក្យស្នើសុំអាជ្ញាបណ្ណ	ចំនួន១ច្បាប់
២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង)	ចំនួន១ច្បាប់
៣- សញ្ញាបត្រ(ថតចម្លង)	ចំនួន១ច្បាប់
៤- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង)	ចំនួន១ច្បាប់
៥- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធ(ថតចម្លង)	ចំនួន១ច្បាប់
៦- វិញ្ញាបនបត្រធានារ៉ាប់រងឬឯកសារបញ្ជាក់ការតម្កល់ប្រាក់ នៅធនាគារជាតិនៃកម្ពុជា(ថតចម្លង)	ចំនួន១ច្បាប់
៧- លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណ	ចំនួន១ច្បាប់

អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្តូរ អាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់បាន ក្នុងករណីអ្នកវិជ្ជាជីវៈនោះបំពេញលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់។

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ប្រការ៤._

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន មានដូចខាងក្រោម៖

ក. ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន

១- ពាក្យស្នើសុំអាជ្ញាបណ្ណ	ចំនួន១ច្បាប់
២- លក្ខន្តិកៈក្រុមហ៊ុន(ថតចម្លង)	ចំនួន១ច្បាប់
៣- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម(ថតចម្លង)	ចំនួន១ច្បាប់
៤- បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស	ចំនួន១ច្បាប់

៥- វិញ្ញាបនបត្រធានារ៉ាប់រងឬឯកសារបញ្ជាក់ការតម្កល់ប្រាក់
នៅធនាគារជាតិនៃកម្ពុជា(ថតចម្លង) ចំនួន១ច្បាប់

ខ. ឯកសារពាក់ព័ន្ធនឹងអភិបាលរបស់ក្រុមហ៊ុន
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

គ. ឯកសារពាក់ព័ន្ធនឹងនាយកបច្ចេកទេស

១- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

២- សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់

៣- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់

៤- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ(ថតចម្លង) ចំនួន១ច្បាប់

៥- លិខិតធានាអះអាងរបស់នាយកបច្ចេកទេស ចំនួន១ច្បាប់

ឃ. ឯកសារពាក់ព័ន្ធនឹងអ្នកបច្ចេកទេស

១- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

២- សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់

៣- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់

៤- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ(ថតចម្លង) ចំនួន១ច្បាប់

៥- លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស ចំនួន១ច្បាប់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់តំណាងក្រុមហ៊ុន ជាឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់នាយកបច្ចេកទេស ជាឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស ជាឧបសម្ព័ន្ធទី៦នៃប្រកាសនេះ។

គំរូទម្រង់បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស ជាឧបសម្ព័ន្ធទី៧នៃប្រកាសនេះ។

ប្រការ៥._

ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវបង្ហាញបទពិសោធន៍ការងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនសិក្សាគម្រោងប្តង់ឬក្រុមហ៊ុនសាងសង់ អ្នកសិក្សាគម្រោងប្តង់ឬរូបវន្តបុគ្គលសិក្សាគម្រោងប្តង់ នាយកគម្រោង អ្នកគ្រប់គ្រងគម្រោង អ្នកគ្រប់គ្រងការដ្ឋានសំណង់ ឬប្រធានការដ្ឋានសំណង់។

សម្រាប់សំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១និងអាជ្ញាបណ្ណ ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់កម្រិត១ ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់ នាយកបច្ចេកទេសដែលមានមុខជំនាញផ្នែកវិស្វកម្មគ្រឿងធ្ងុំ ត្រូវបង្ហាញបទពិសោធន៍ការងារក្នុងគម្រោង សាងសង់អគារខ្ពស់ចំនួនយ៉ាងតិច១(មួយ)គម្រោង សម្រាប់នាយកបច្ចេកទេសដែលមានសញ្ញាបត្របណ្ឌិត យ៉ាងតិច៣(បី)គម្រោង សម្រាប់នាយកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬយ៉ាងតិច ៧(ប្រាំពីរ)គម្រោង សម្រាប់នាយកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រ។

សម្រាប់សំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១និងអាជ្ញាបណ្ណ ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងធ្ងុំសំណង់កម្រិត១ ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់ អ្នកបច្ចេកទេសដែលមានមុខជំនាញផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ ត្រូវបង្ហាញបទពិសោធន៍ការងារក្នុង គម្រោងសាងសង់សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង១០(ដប់)ម៉ែត្រ ចំនួនយ៉ាងតិច១ (មួយ)គម្រោង សម្រាប់អ្នកបច្ចេកទេសដែលមានសញ្ញាបត្របណ្ឌិត យ៉ាងតិច៣(បី)គម្រោង សម្រាប់ អ្នកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬយ៉ាងតិច៧(ប្រាំពីរ)គម្រោង សម្រាប់អ្នក បច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រ។

ប្រការ៦._

ការគណនារយៈពេលនៃបទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវអនុវត្តដូចខាងក្រោម៖

- បទពិសោធន៍ការងាររយៈពេល៧(ប្រាំពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល១២(ដប់ពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល២០(ម្ភៃ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។
- បទពិសោធន៍ការងាររយៈពេល៣(បី)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល៧(ប្រាំពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល១៥(ដប់ប្រាំ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។
- បទពិសោធន៍ការងាររយៈពេល២(ពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល៥(ប្រាំ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល១០(ដប់)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។

– បទពិសោធន៍ការងាររយៈពេល១(មួយ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល៣(បី)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល៧(ប្រាំពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។

ការងារទាំងឡាយដែលអ្នកវិជ្ជាជីវៈបានបំពេញមុនកាលបរិច្ឆេទចេញសញ្ញាបត្របរិញ្ញាបត្ររបស់ខ្លួន មិនត្រូវបានរាប់បញ្ចូលសម្រាប់គណនារយៈពេលនៃបទពិសោធន៍ការងារឡើយ។

រយៈពេលនៃបទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវគណនាដោយបូកបញ្ចូលរយៈពេលបំពេញការងារដែលមានចែងក្នុងឯកសារបញ្ជាក់បទពិសោធន៍ការងារទាំងអស់។

ក្នុងករណីអ្នកវិជ្ជាជីវៈបានបំពេញការងារពេញម៉ោង រយៈពេលនៃបទពិសោធន៍ការងារត្រូវគណនាជាឆ្នាំដូចមានចែងក្នុងឯកសារបញ្ជាក់បទពិសោធន៍ការងារ។

ក្នុងករណីអ្នកវិជ្ជាជីវៈបានបំពេញការងារក្រៅម៉ោង រយៈពេលនៃបទពិសោធន៍ការងារត្រូវគិតជាឆ្នាំ ដោយក្នុងរយៈពេល១(មួយ)ឆ្នាំ អ្នកវិជ្ជាជីវៈនោះត្រូវបំពេញការងារឱ្យបានយ៉ាងតិច២០០០(ពីរពាន់)ម៉ោង។

ប្រការ៧._

តំណាងស្របច្បាប់របស់ក្រុមហ៊ុន និងអ្នកវិជ្ជាជីវៈដែលស្នើសុំអាជ្ញាបណ្ណ ត្រូវចុះហត្ថលេខាដោយផ្ទាល់លើពាក្យស្នើសុំអាជ្ញាបណ្ណ។

រាល់ឯកសារនៅក្នុងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវធ្វើជាភាសាខ្មែរ។ រាល់ឯកសារជាភាសាបរទេស ត្រូវបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ពីសារការី។

រាល់ឯកសារថតចម្លងត្រូវធ្វើនីត្យានុកូលកម្មដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ ឬដោយសារការី។

សញ្ញាបត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សានៅបរទេស ត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៨._

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវដាក់នៅច្រកចេញចូលតែមួយ។

ច្រកចេញចូលតែមួយត្រូវត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណនៅក្នុងថ្ងៃដាក់ពាក្យស្នើសុំ។

ប្រការ៩._

ក្នុងករណីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មានគ្រប់ចំនួននិងត្រឹមត្រូវផ្នែកទម្រង់ ច្រកចេញចូលតែមួយ ត្រូវអនុវត្តដូចខាងក្រោម៖

១- ចុះលេខនិងកាលបរិច្ឆេទចូលក្នុងសៀវភៅចុះលេខចូលរបស់ច្រកចេញចូលតែមួយ និងចម្លងលេខនិងកាលបរិច្ឆេទលើពាក្យស្នើសុំអាជ្ញាបណ្ណ។

២- រៀបចំបង្កាន់ដៃទទួលពាក្យស្នើសុំដោយមានលេខនិងកាលបរិច្ឆេទចូល និងហត្ថលេខារបស់មន្ត្រីទទួលបន្ទុក។

៣- ប្រគល់ច្បាប់ដើមនៃបង្កាន់ដៃទទួលពាក្យស្នើសុំដែលមានចុះលេខនិងកាលបរិច្ឆេទចូលជូនទៅម្ចាស់សំណើ នៅក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ។

៤- ថតចម្លងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណចំនួន២(ពីរ)ច្បាប់។

ប្រការ១០._

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មិនគ្រប់ចំនួនឬមិនត្រឹមត្រូវផ្នែកទម្រង់ មន្ត្រីច្រកចេញចូលតែមួយត្រូវអនុវត្តដូចខាងក្រោម៖

១- បំពេញឱ្យបានច្បាស់លាស់លើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអំពីការខ្វះឯកសារឬភាពមិនត្រឹមត្រូវនៃឯកសារ។

២- ចុះកាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសំណុំឯកសារលើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំដែលបំពេញរួច។

៣- ប្រគល់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំដែលបានបំពេញ ចុះកាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសំណុំឯកសាររួច ជូនទៅម្ចាស់សំណើនៅក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី៨នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី៩នៃប្រកាសនេះ។

ប្រការ១១._

ការពិនិត្យនិងសម្រេចលើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មានរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តាមបរិបថដូចខាងក្រោម៖

១- ច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

២- អគ្គនាយកដ្ឋានសំណង់ដែលមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការត្រូវធ្វើកំណត់បង្ហាញស្តីពីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ដោយមានភ្ជាប់សេចក្តីព្រាងអាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ។

៣- កំណត់បង្ហាញស្តីពីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណនេះ ត្រូវដាក់ឆ្លងថ្នាក់ដឹកនាំតាមឋានានុក្រមដើម្បីទទួលមតិយោបល់និងការសម្រេចរបស់ក្រសួង ក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីអគ្គនាយកដ្ឋានសំណង់។

៤- ច្រកចេញចូលតែមួយត្រូវចាត់ចែងចុះលេខ កាលបរិច្ឆេទ និងបោះត្រាលើសេចក្តីព្រាងអាជ្ញាបណ្ណ ដើម្បីប្រគល់ជូនម្ចាស់សំណើ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ១២._

ក្នុងករណីអគ្គនាយកដ្ឋានសំណង់ពិនិត្យឃើញថា សំណុំឯកសារស្នើសុំអាជ្ញាបណ្ណមិនត្រឹមត្រូវ ត្រូវអនុវត្តដូចខាងក្រោម៖

១- អគ្គនាយកដ្ឋានសំណង់ដែលមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការត្រូវធ្វើលិខិតជូនដំណឹងទៅម្ចាស់សំណើដើម្បីកែសម្រួលឬបំពេញបន្ថែម និងបញ្ជូនទៅច្រកចេញចូលតែមួយក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ។

២- ច្រកចេញចូលតែមួយ ត្រូវអញ្ជើញម្ចាស់សំណើមកទទួលយកលិខិតជូនដំណឹងអំពីការតម្រូវឱ្យកែសម្រួលឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលទទួលបានលិខិតនោះពីអគ្គនាយកដ្ឋានសំណង់។

រយៈពេលនៃការកែសម្រួលឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់អាជ្ញាបណ្ណឡើយ។ បរិបថនៃការពិនិត្យនិងសម្រេចផ្តល់អាជ្ញាបណ្ណក្នុងករណីមានការកែសម្រួលឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវចាប់រាប់ជាថ្មីឡើងវិញគិតចាប់ពីថ្ងៃច្រកចេញចូលតែមួយចេញបង្កាន់ដៃទទួលសំណុំឯកសារដែលបានកែសម្រួលឬបំពេញបន្ថែមនោះ។

ប្រការ១៣._

ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណដែលអាចផ្តល់ជូនអ្នកវិជ្ជាជីវៈ មានដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣ មុខជំនាញមេកានិក។

៤- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣ មុខជំនាញអគ្គិសនី។

៥- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣ មុខជំនាញទឹក។

គំរូទម្រង់អាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១០នៃប្រកាសនេះ។

ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណដែលអាចផ្តល់ជូនក្រុមហ៊ុន មានដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១។

៤- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២។

៥- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១។

៦- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២។

៧- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត១។

៨- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត២។

គំរូទម្រង់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១១នៃប្រកាសនេះ។

ជំពូកទី៣

បែបបទនិងបរិបថនៃការជូនដំណឹង

ប្រការ១៤._

អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីមានការផ្លាស់ប្តូរស្ថានភាពទាំងឡាយនៅក្នុងពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

គំរូទម្រង់លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១២នៃប្រកាសនេះ។

ប្រការ១៥._

អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីដូចខាងក្រោម៖

១- ការប្តូរអភិបាលក្រុមហ៊ុន។

២- ការប្តូរលក្ខន្តិកៈក្រុមហ៊ុន។

៣- ការប្តូរទីតាំងទីស្នាក់ការប្រកបអាជីវកម្ម។

៤- ការប្តូរលេខទូរស័ព្ទនិងអ៊ីមែលសម្រាប់ទំនាក់ទំនង។

៥- ការប្តូរវិញ្ញាបនបត្រធានារ៉ាប់រង។

៦- ការប្តូរចំនួនទឹកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា។

ក្នុងករណីប្តូរអភិបាលក្រុមហ៊ុន ប្តូរលក្ខន្តិកៈក្រុមហ៊ុន ប្តូរវិញ្ញាបនបត្រធានារ៉ាប់រង និងប្តូរចំនួនទឹកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់ក្រុមហ៊ុន ត្រូវមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

គំរូទម្រង់លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៣នៃប្រកាសនេះ។

ជំពូកទី៤

បែបបទនិងបរិបថនៃការប្តូរនាយកបច្ចេកទេស និងអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន

ប្រការ១៦._

សំណុំឯកសារស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសក្រុមហ៊ុន មានដូចខាងក្រោម៖

១- ពាក្យស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេស	ចំនួន១ច្បាប់
២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ របស់នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី (ថតចម្លង)	ចំនួន១ច្បាប់
៣- សញ្ញាបត្ររបស់នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី (ថតចម្លង)	ចំនួន១ច្បាប់
៤- ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់នាយកបច្ចេកទេសថ្មីនិង/ឬ អ្នកបច្ចេកទេសថ្មី	ចំនួន១ច្បាប់

៥- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈរបស់
នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី (ថតចម្លង) ចំនួន១ច្បាប់

៦- លិខិតធានាអះអាងរបស់នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី ចំនួន១ច្បាប់

៧- សន្លឹកអាជ្ញាបណ្ណចាស់ (ករណីសុំប្តូរនាយកបច្ចេកទេសថ្មី) ចំនួន១ច្បាប់

គំរូទម្រង់ពាក្យស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី ១៤នៃប្រកាសនេះ។

ប្រការ១៧._

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតជូនដំណឹងទៅអ្នកកាន់អាជ្ញាបណ្ណ ដោយមានភ្ជាប់នូវសន្លឹកអាជ្ញាបណ្ណថ្មី ក្នុងករណីនាយកបច្ចេកទេសថ្មីរបស់ក្រុមហ៊ុន បានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតជូនដំណឹងទៅអ្នកកាន់អាជ្ញាបណ្ណ ក្នុងករណីអ្នកបច្ចេកទេសថ្មីរបស់ក្រុមហ៊ុនបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់។

សន្លឹកអាជ្ញាបណ្ណថ្មី ត្រូវកត់ត្រាកាលបរិច្ឆេទផុតសុពលភាពរបស់អាជ្ញាបណ្ណចាស់ដែលត្រូវប្តូរ។

សន្លឹកអាជ្ញាបណ្ណចាស់ដែលត្រូវបានប្តូរ ត្រូវបោះត្រាមោយ:។

ទម្រង់នៃឯកសារនៅក្នុងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ និងនីតិវិធីនៃការពិនិត្យសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំប្តូរនាយកបច្ចេកទេស និងអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន។

ជំពូកទី៥

បែបបទនិងបរិបថនៃការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី

ប្រការ១៨._

អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ អាចដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីដូចខាងក្រោម:

១- ការបាត់បង់ ការរហែក ឬការខូចសន្លឹកអាជ្ញាបណ្ណ។

២- ការប្តូរគោត្តនាមនិងនាមរបស់អ្នកវិជ្ជាជីវៈ។

៣- ការប្តូរអាសយដ្ឋានការិយាល័យថ្មី។

ប្រការ១៩._

អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន អាចដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីដូចខាងក្រោម៖

១- សន្លឹកអាជ្ញាបណ្ណបានបាត់បង់ រហែក ឬខូច។

២- ការប្តូរនាមករណ៍ក្រុមហ៊ុន។

៣- ការប្តូរទីស្នាក់ការរបស់ក្រុមហ៊ុន។

៤- ការប្តូរប្រធានក្រុមហ៊ុន។

ប្រការ២០._

សំណុំឯកសារស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី មានដូចខាងក្រោម៖

១- ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ចំនួន១ច្បាប់

២- ពាក្យបណ្តឹងអំពីការបាត់បង់អាជ្ញាបណ្ណ (ថតចម្លង) ឬ
សន្លឹកអាជ្ញាបណ្ណដែលរហែកឬខូច ឬឯកសារបញ្ជាក់អំពី
ការផ្លាស់ប្តូរស្ថានភាពដែលមានចែងនៅក្នុងអាជ្ញាបណ្ណពាក់ព័ន្ធ
នឹងអ្នកកាន់អាជ្ញាបណ្ណ ចំនួន១ច្បាប់

ពាក្យបណ្តឹងអំពីការបាត់បង់អាជ្ញាបណ្ណ ត្រូវមានការបញ្ជាក់របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អំពីការទទួលពាក្យបណ្តឹង។

គំរូទម្រង់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១៥នៃប្រកាសនេះ។

គំរូទម្រង់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៦នៃប្រកាសនេះ។

ប្រការ២១._

សន្លឹកអាជ្ញាបណ្ណថ្មី ត្រូវកត់ត្រាកាលបរិច្ឆេទផុតសុពលភាពរបស់អាជ្ញាបណ្ណចាស់ដែលត្រូវប្តូរ។

អ្នកកាន់អាជ្ញាបណ្ណ ត្រូវយកសន្លឹកអាជ្ញាបណ្ណចាស់មកប្តូរយកសន្លឹកអាជ្ញាបណ្ណថ្មី លើកលែងតែករណីបាត់បង់អាជ្ញាបណ្ណ។

សន្លឹកអាជ្ញាបណ្ណចាស់ដែលត្រូវបានប្តូរ ត្រូវបោះត្រាមោឃៈ។

នីតិវិធីនៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី។

ជំពូកទី៦

បែបបទនិងបរិបថនៃការបញ្ចប់សុពលភាពអាជ្ញាបណ្ណ

ប្រការ២២._

សំណុំឯកសារស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណ មានដូចខាងក្រោម:

១- ពាក្យស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណ ចំនួន១ច្បាប់

២- សន្លឹកអាជ្ញាបណ្ណ ឬពាក្យបណ្តឹងអំពីការបាត់បង់
អាជ្ញាបណ្ណ ឬសន្លឹកអាជ្ញាបណ្ណដែលរហែកឬខូច ចំនួន១ច្បាប់

ពាក្យបណ្តឹងអំពីការបាត់បង់អាជ្ញាបណ្ណត្រូវមានការបញ្ជាក់របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អំពីការទទួលពាក្យបណ្តឹង។

គំរូទម្រង់ពាក្យស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១៧នៃប្រកាសនេះ។

គំរូទម្រង់ពាក្យស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៨នៃប្រកាសនេះ។

ប្រការ២៣._

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបញ្ចប់សុពលភាពអាជ្ញាបណ្ណដោយប្រកាស។ សន្លឹកអាជ្ញាបណ្ណដែលត្រូវបានបញ្ចប់សុពលភាព ត្រូវបោះត្រាមោយៈ។

នីតិវិធីនៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណ។

ជំពូកទី៧

បែបបទនិងបរិបថនៃការបន្តសុពលភាពអាជ្ញាបណ្ណ

ប្រការ២៤._

សំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ មានដូចខាងក្រោម:

១- ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ចំនួន១ច្បាប់

២- បណ្ណប៉ាតង់ប្រចាំឆ្នាំចុងក្រោយ(ថតចម្លង) ចំនួន១ច្បាប់

៣- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំចុងក្រោយ(ថតចម្លង) ចំនួន១ច្បាប់

ក្នុងករណីមានការកែប្រែឯកសារណាមួយនៃសំណុំឯកសារសម្រាប់ស្នើសុំអាជ្ញាបណ្ណលើកដំបូង និង/ឬសំណុំឯកសារសម្រាប់ស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបន្តបន្ទាប់ សំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ត្រូវមានបន្ថែមឯកសារថ្មីស្របតាមការកែប្រែនោះ។

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១៩នៃប្រកាសនេះ។

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី២០នៃប្រកាសនេះ។

គំរូទម្រង់របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈជាឧបសម្ព័ន្ធទី២១នៃប្រកាសនេះ។

គំរូទម្រង់របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី២២នៃប្រកាសនេះ។

ប្រការ២៥._

ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណ ត្រូវដាក់នៅច្រកចេញចូលតែមួយក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃមុនកាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបន្តសុពលអាជ្ញាបណ្ណដោយប្រកាសដោយមានភ្ជាប់សន្លឹកអាជ្ញាបណ្ណថ្មី។ សន្លឹកអាជ្ញាបណ្ណថ្មីត្រូវរក្សាលេខអាជ្ញាបណ្ណចាស់ កាលបរិច្ឆេទនៃការផ្តល់អាជ្ញាបណ្ណដំបូង និងកំណត់កាលបរិច្ឆេទផុតសុពលភាពថ្មី។

នីតិវិធីនៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណ។

ជំពូកទី៨

បែបបទសម្រាប់អ្នកវិជ្ជាជីវៈនិងក្រុមហ៊ុនសញ្ជាតិបរទេស

ប្រការ២៦._

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈសញ្ជាតិបរទេស ត្រូវមានបន្ថែមបណ្ណការងារ និងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ២៧._

សម្រាប់ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ដែលស្នើសុំអាជ្ញាបណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតប្រគល់សិទ្ធិជាភ្នាក់ងារតំណាងដែលចុះហត្ថលេខាដោយប្រធានក្រុមហ៊ុន។

សម្រាប់នាយកបច្ចេកទេសនិងអ្នកបច្ចេកទេសសញ្ជាតិបរទេស សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ត្រូវមានបន្ថែមបណ្ណាការងារ និងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់នាយកបច្ចេកទេសឬអ្នកបច្ចេកទេសនោះ។

ប្រការ២៨._

ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈសញ្ជាតិបរទេស ត្រូវមានការបញ្ជាក់ទទួលស្គាល់ដោយស្ថានទូតឬស្ថានតំណាងបរទេសពាក់ព័ន្ធប្រចាំព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី៩
ការប្តឹងតវ៉ា

ប្រការ២៩._

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការប្ដូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន ការបញ្ចប់សុពលភាពអាជ្ញាបណ្ណ និងការបន្តសុពលភាពអាជ្ញាបណ្ណ ត្រួតពិនិត្យនិងបញ្ជាក់សំណង់ មានសិទ្ធិប្តឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬទៅតុលាការតាមនីតិវិធីជាធរមាន។

ជំពូកទី១០
អន្តរប្បញ្ញត្តិ

ប្រការ៣០._

នាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនដែលមានវិញ្ញាបនបត្រសិក្សាគម្រោងប្តង់ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាចបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុននោះ ដើម្បីបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់បាន ក្នុងករណីនាយកបច្ចេកទេសឬអ្នកបច្ចេកទេសនោះ បំពេញលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ជំពូកទី១១

អវសានប្បញ្ញត្តិ

ប្រការ៣១._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣២._

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុជារ៉ា

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជ្វនជ្រាប"
- ដូចប្រការ៣២ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ភេទ ____ អាយុ ___ ឆ្នាំ សញ្ជាតិ _____

មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ_____ផុតកំណត់ _____

មានការិយាល័យស្ថិតនៅផ្ទះ/អគារលេខ _____ ផ្លូវ_____ ភូមិ _____

ឃុំ/សង្កាត់ _____ ក្រុង/ស្រុក/ខណ្ឌ _____ រាជធានី/ខេត្ត _____ អ៊ីមែល _____លេខទូរស័ព្ទ _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កម្មវត្ថុ៖ សំណើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ កម្រិត ____

យោង៖ ប្រកាសលេខ_____ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ ដើម្បីប្រកបវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ កម្រិត ____។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាអនុវត្តការងារឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់និងបទដ្ឋានគតិយុត្តដទៃទៀត ព្រមទាំងបទដ្ឋានបច្ចេកទេសនិងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ព.ស. _____

ធ្វើនៅ _____ថ្ងៃទី____ខែ_____ឆ្នាំ_____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី២នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២.១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ភេទ____ អាយុ_____ឆ្នាំ សញ្ជាតិ_____ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ_____ ផ្លូវ_____ ឃុំ/សង្កាត់_____ ក្រុង/ស្រុក/ខណ្ឌ_____ រាជធានី/ខេត្ត_____អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ_____ ផុតកំណត់ថ្ងៃទី_____ ខែ_____ឆ្នាំ_____ សូមអះអាងថា ក្នុងពេលអនុវត្តមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ខ្ញុំបាទ/នាងខ្ញុំនឹង៖

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- មិនបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនណាមួយឡើយ។

៥- គោរពតាមគោលការណ៍ណែនាំនិងចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី៣នៃប្រកាសលេខ ០៣៣ ជ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ភេទ _____ អាយុ____ឆ្នាំ សញ្ជាតិ _____មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ_____ផុតកំណត់_____

ជាតំណាងក្រុមហ៊ុន_____

ទីស្នាក់ការ ផ្ទះ/អគារលេខ_____ផ្លូវ_____ឃុំ/សង្កាត់_____ក្រុង/ស្រុក/ខណ្ឌ_____រាជធានី/ខេត្ត_____អ៊ីមែល_____លេខទូរស័ព្ទ _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ កម្រិត ____

<u>យោង</u>៖ ប្រកាសលេខ_____ ជ.ន.ស./ប្រ.ក. ចុះថ្ងៃទី___ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ និងអាចប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ កម្រិត ____ បាន។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាអនុវត្តការងារឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់និងបទដ្ឋានគតិយុត្តដទៃទៀត ព្រមទាំងបទដ្ឋានបច្ចេកទេសនិងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី៤នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់តំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ភេទ____ អាយុ_____ឆ្នាំ សញ្ជាតិ_____ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ_____ ផ្លូវ_____ ឃុំ/សង្កាត់_____ ក្រុង/ស្រុក/ខណ្ឌ_____ រាជធានី/ខេត្ត_____អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ_____ ផុតកំណត់ ថ្ងៃទី ____ ខែ_____ឆ្នាំ_____ជាតំណាងក្រុមហ៊ុន_____ សូមអះអាងថា នៅក្នុងការអនុវត្តមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្រុមហ៊ុនយើងខ្ញុំនឹង៖

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- គោរពតាមគោលការណ៍ណែនាំនិងចាត់នាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសមកចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ព.ស. ___

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី៥នៃប្រកាសលេខ ១៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់នាយកបច្ចេកទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ_____ ភេទ____ អាយុ_____ឆ្នាំ សញ្ជាតិ_____ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ_____ ផ្លូវ_____ ឃុំ/សង្កាត់_____ ក្រុង/ស្រុក/ខណ្ឌ_____ រាជធានី/ខេត្ត_____អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ_____ ផុតកំណត់ថ្ងៃទី ____ ខែ_____ឆ្នាំ_____ សូមអះអាងថា ខ្ញុំបាទ/នាងខ្ញុំបានយល់ព្រមទទួលបំពេញមុខងារជានាយកបច្ចេកទេសរបស់ក្រុមហ៊ុន_____ចាប់ពីថ្ងៃទី____ ខែ_____ ឆ្នាំ_____ តទៅ។

ក្នុងពេលអនុវត្តមុខងារជានាយកបច្ចេកទេស ខ្ញុំបាទ/នាងខ្ញុំនឹង៖

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- មិនបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនផ្សេងទៀតឡើយ។

៥- គោរពតាមគោលការណ៍ណែនាំនិងចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ_____ ខែ _____ ឆ្នាំ_____ព.ស. ___

ធ្វើនៅ_____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

បានឃើញនិងឯកភាព

ថ្ងៃ_____ ខែ _____ ឆ្នាំ_____ព.ស. ___

ធ្វើនៅ_____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី៦នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ភេទ____ អាយុ_____ឆ្នាំ សញ្ជាតិ_____ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ_____ ផ្លូវ_____ ឃុំ/សង្កាត់_____ ក្រុង/ស្រុក/ខណ្ឌ_____ រាជធានី/ខេត្ត_____អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ_____ ផុតកំណត់ ថ្ងៃទី ____ ខែ_____ឆ្នាំ_____ សូមអះអាងថា ខ្ញុំបាទ/នាងខ្ញុំបានយល់ព្រមទទួលបំពេញមុខងារជាអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន_____ចាប់ពីថ្ងៃទី____ ខែ_____ ឆ្នាំ_____ តទៅ។

ក្នុងពេលអនុវត្តមុខងារជាអ្នកបច្ចេកទេស ខ្ញុំបាទ/នាងខ្ញុំនឹង៖

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- មិនបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនផ្សេងទៀតឡើយ។

៥- គោរពតាមគោលការណ៍ណែនាំនិងចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

បានឃើញនិងឯកភាព

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី៧នៃប្រកាសលេខ ០៧៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ꕥ

នាមករណ៍ក្រុមហ៊ុន _____

លេខចុះបញ្ជីពាណិជ្ជកម្ម _____ ចុះថ្ងៃទី _____ ខែ _____ ឆ្នាំ _____

ស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ កម្រិត _____

បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន

ល.រ	គោត្តនាមនិងនាម	ភេទ	តួនាទី	សញ្ញាបត្រ	មុខជំនាញ	បទពិសោធន៍
១			នាយកបច្ចេកទេស			ឆ្នាំ
២			អ្នកបច្ចេកទេស			ឆ្នាំ
៣			អ្នកបច្ចេកទេស			ឆ្នាំ
៤			អ្នកបច្ចេកទេស			ឆ្នាំ
៥			អ្នកបច្ចេកទេស			ឆ្នាំ
៦			អ្នកបច្ចេកទេស			ឆ្នាំ
៧			អ្នកបច្ចេកទេស			ឆ្នាំ
៨			អ្នកបច្ចេកទេស			ឆ្នាំ
៩			អ្នកបច្ចេកទេស			ឆ្នាំ

ខ្ញុំបាទ/នាងខ្ញុំសូមអះអាងចំពោះមុខច្បាប់ថាព័ត៌មានខាងលើជាការពិតទាំងអស់។

ថ្ងៃ _____ ខែ _____ ឆ្នាំ _____ ព.ស. _____

ធ្វើនៅ _____ ថ្ងៃទី _____ ខែ _____ ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រារបស់ក្រុមហ៊ុន

ឧបសម្ព័ន្ធទី៨នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានរដ្ឋបាល

ច្រកចេញចូលតែមួយ

តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ សម្រាប់អ្នកវិជ្ជាជីវៈ:

ល.រ.	ឈ្មោះឯកសារ	ចំនួនតម្រូវ	ចំនួនទទួល	តារាងមិនត្រឹមត្រូវផ្នែកទម្រង់
១	ពាក្យស្នើសុំអាជ្ញាបណ្ណ	១		
២	អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ (ថតចម្លង)	១		
៣	សញ្ញាបត្រ(ថតចម្លង)	១		
៤	ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង)	១		
៥	វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធ(ថតចម្លង)	១		
៦	វិញ្ញាបនបត្រធានារ៉ាប់រង (ថតចម្លង) ឬឯកសារបញ្ជាក់ការតម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា(ថតចម្លង)	១		
៧	លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ	១		
៨	បណ្ណការងារ ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស (ថតចម្លង)	១		
៩	ឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស (ថតចម្លង)	១		

ការសន្និដ្ឋានលើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ៈ

គ្រប់គ្រាន់ □ មិនគ្រប់គ្រាន់ □ មិនត្រឹមត្រូវផ្នែកទម្រង់ □

សេចក្តីណែនាំរបស់ច្រកចេញចូលតែមួយ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់និង/ឬមិនត្រឹមត្រូវផ្នែកទម្រង់ៈ

_____

_____

ថ្ងៃ _____ ខែ _____ ឆ្នាំ_____ ព.ស. ____

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី____ខែ_____ឆ្នាំ_____

ហត្ថលេខានិងឈ្មោះមន្ត្រីទទួលបន្ទុកត្រួតពិនិត្យ

ឧបសម្ព័ន្ធទី៩នៃប្រកាសលេខ ០៣៣ ជ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានរដ្ឋបាល
ច្រកចេញចូលតែមួយ

តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ សម្រាប់ក្រុមហ៊ុន

ល.រ.	ឈ្មោះឯកសារ	ចំនួនតម្រូវ	ចំនួនទទួល	តារាងមិនត្រឹមត្រូវផ្លែកទម្រង់
ក.	**ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន**			
១	ពាក្យស្នើសុំអាជ្ញាបណ្ណ	១		
២	លក្ខន្តិកៈក្រុមហ៊ុន (ថតចម្លង)	១		
៣	វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ថតចម្លង)	១		
៤	បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស	១		
៥	វិញ្ញាបនបត្រធានាវ៉ាប់រង (ថតចម្លង) ឬឯកសារបញ្ជាក់ការតម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា (ថតចម្លង)	១		
៦	លិខិតប្រគល់សិទ្ធិដែលបញ្ជាក់ពីភាពស្របច្បាប់របស់ភ្នាក់ងារតំណាងក្នុងករណីក្រុមហ៊ុនបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ	១		
ខ.	**ឯកសារពាក់ព័ន្ធនឹងអតិថិជនក្រុមហ៊ុន**			
១	អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ (ថតចម្លង)	១		
គ.	**ឯកសារពាក់ព័ន្ធនឹងនាយកបច្ចេកទេស**			
១	អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ (ថតចម្លង)	១		
២	សញ្ញាបត្រ (ថតចម្លង)	១		
៣	ឯកសារបញ្ជាក់បទពិសោធន៍ការងារ (ថតចម្លង)	១		
៤	វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ (ថតចម្លង)	១		
៥	លិខិតធានាអះអាងរបស់នាយកបច្ចេកទេស	១		
៦	បណ្តាការងារ ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស (ថតចម្លង)	១		

๗	ឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស (ថតចម្លង)	១		
ឃ.	**ឯកសារពាក់ព័ន្ធនឹងអ្នកបច្ចេកទេស**			
១	អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ (ថតចម្លង)	១		
២	សញ្ញាបត្រ(ថតចម្លង)	១		
៣	ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង)	១		
៤	វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ(ថតចម្លង)	១		
៥	លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស	១		
៦	បណ្ណការងារ ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស (ថតចម្លង)	១		
๗	ឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីអ្នកវិជ្ជាជីវៈសញ្ជាតិបរទេស (ថតចម្លង)	១		

ការសន្និដ្ឋានលើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់៖

គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ ☐ មិនត្រឹមត្រូវផ្នែកទម្រង់ ☐

សេចក្តីណែនាំរបស់ច្រកចេញចូលតែមួយ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់និង/ឬមិនត្រឹមត្រូវផ្នែកទម្រង់៖

_____

_____

_____

_____

ថ្ងៃ_____ ខែ _____ ឆ្នាំ_____ ព.ស. ____

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះមន្ត្រីទទួលបន្ទុកត្រួតពិនិត្យ

ឧបសម្ព័ន្ធទី១០នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តីកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់អាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
Ministry of Land Management, Urban Planning and Construction
លេខ/N° _____

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
CONSTRUCTION CERTIFIER LICENCE

គោត្តនាមនិងនាម_____ ភេទ _____
Name and Surname_____ Sex _____
ថ្ងៃខែឆ្នាំកំណើត _____ សញ្ជាតិ _____
Date of Birth _____ Nationality_____
អត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែន_____ ចុះថ្ងៃទី_____
ID/Passport N° _____ Dated _____
ទីលំនៅអចិន្ត្រៃយ៍ _____
Permanent Residence _____
អត្តលេខអ្នកវិជ្ជាជីវៈ_____ ចុះថ្ងៃទី_____
Professional ID N° _____Dated_____

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ លេខ _____
Construction Certifier Licence N° _____
ផ្នែក _____ កម្រិត _____
Class_____ Level_____
កាលបរិច្ឆេទផ្តល់អាជ្ញាបណ្ណដំបូង _____
First Issue Date _____
សុពលភាពត្រឹមថ្ងៃទី _____
Valid until _____

អ្នកកាន់អាជ្ញាបណ្ណត្រូវគោរពបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
The licensee shall observe and comply with relevant laws and regulations of the Kingdom of Cambodia.

រាជធានីភ្នំពេញ ថ្ងៃ_____ ខែ _____ ឆ្នាំ _____ ព.ស._____ ត្រូវនឹងថ្ងៃទី____ ខែ _____ ឆ្នាំ _____
Phnom Penh, _____

រដ្ឋមន្ត្រី Minister

ឧបសម្ព័ន្ធទី១១នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
Ministry of Land Management, Urban Planning and Construction
លេខ/N° _____

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
CONSTRUCTION CERTIFIER LICENCE

នាមករណ៍ក្រុមហ៊ុន _____
Company Name _____
បញ្ជីពាណិជ្ជកម្មលេខ_____ ចុះថ្ងៃទី_____
Company Registration N°_____ Dated _____
ទីស្នាក់ការ _____
Head Office _____
ប្រធានក្រុមហ៊ុន _____
President/CEO_____
នាយកបច្ចេកទេស _____
Technical Director_____

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ លេខ _____
Construction Certifier Licence N° _____
ផ្នែក _____ កម្រិត_____
Class_____ Level_____
កាលបរិច្ឆេទផ្តល់អាជ្ញាបណ្ណដំបូង _____
First Issue Date _____
សុពលភាពត្រឹមថ្ងៃទី _____
Valid until _____

អ្នកកាន់អាជ្ញាបណ្ណត្រូវគោរពបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
The licensee shall observe and comply with relevant laws and regulations of the Kingdom of Cambodia.

រាជធានីភ្នំពេញ ថ្ងៃ_____ ខែ_____ ឆ្នាំ_____ ព.ស._____ ត្រូវនឹងថ្ងៃទី____ ខែ_____ ឆ្នាំ_____
Phnom Penh, _____

រដ្ឋមន្ត្រី Minister

ឧបសម្ព័ន្ធទី១២នៃប្រកាសលេខ ០៧៣ ជ. ន. ស./ប្រ. ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____

កាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កម្មវត្ថុ៖ សំណើសុំជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ

យោង៖ ប្រកាសលេខ_____ ជ. ន. ស./ប្រ. ក. ចុះថ្ងៃទី___ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់ខ្ញុំបាទ/នាងខ្ញុំ ដូចខាងក្រោម៖

- ☐ ទីតាំងការិយាល័យថ្មី ផ្ទះ/អគារលេខ _____ ផ្លូវ _____ ភូមិ _____
  ឃុំ/សង្កាត់ _____ ក្រុង/ស្រុក/ខណ្ឌ _____ រាជធានី/ខេត្ត _____
- ☐ អ៊ីមែលថ្មី _____ លេខទូរស័ព្ទថ្មី _____
- ☐ ផ្សេងៗ _____

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលជ្រាបដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ _____ ឆ្នាំ _____ ព. ស. _____

ធ្វើនៅ _____ ថ្ងៃទី _____ ខែ _____ ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី១៣នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ជាតំណាងក្រុមហ៊ុន _____
ដែលកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់ក្រុមហ៊ុន

<u>យោង</u>៖ ប្រកាសលេខ _____ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ___ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថាខ្ញុំបាទ/នាងខ្ញុំសូមគោរពជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់ក្រុមហ៊ុនយើងខ្ញុំដូចខាងក្រោម៖

- ☐ អភិបាលក្រុមហ៊ុនថ្មីឈ្មោះ_____ភេទ_____
- ☐ លក្ខន្តិក:ថ្មីឬលក្ខន្តិក:កែប្រែ ចុះថ្ងៃទី _____ ខែ _____ ឆ្នាំ _____
- ☐ ទីតាំងទីស្នាក់ការថ្មី ផ្ទះលេខ _____ ផ្លូវ _____ ភូមិ _____ ឃុំ/សង្កាត់ _____ ក្រុង/ស្រុក/ខណ្ឌ _____ រាជធានី/ខេត្ត _____
- ☐ អ៊ីមែលថ្មី _____ លេខទូរស័ព្ទថ្មី _____
- ☐ ប្តូរវិញ្ញាបនបត្រធានារ៉ាប់រង_____
- ☐ ប្តូរចំនួនទឹកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា_____

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលជ្រាបដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ _____ ឆ្នាំ _____ ព.ស. _____

ធ្វើនៅ _____ ថ្ងៃទី _____ ខែ _____ ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី១៤នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ជាតំណាងក្រុមហ៊ុន _____

ដែលកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន

<u>យោង</u>៖ ប្រកាសលេខ_____ដ.ន.ស./ប្រ.ក.ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថាក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំបានជ្រើសរើសនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសថ្មីចំនួន_____រូបដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី _____ ជានាយកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

២- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៣- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៤- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៥- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៦- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៧- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៨- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

៩- លោក/លោកស្រី _____ ជាអ្នកបច្ចេកទេសថ្មីជំនួសលោក/លោកស្រី _____

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ_____ខែ_____ឆ្នាំ _____ ព.ស. _____

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី១៥នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីសម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____

កាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំសន្លឹកអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ថ្មី

<u>យោង</u>៖ ប្រកាសលេខ_____ ដ.ន.ស./ប្រ.ក.ចុះថ្ងៃទី_____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ដោយសារមូលហេតុដូចខាងក្រោម៖

- ☐ សន្លឹកអាជ្ញាបណ្ណបានបាត់បង់ រហែក ឬខូច។
- ☐ ស្ថានភាពដែលមានចែងនៅក្នុងសន្លឹកអាជ្ញាបណ្ណចាស់ ត្រូវបានផ្លាស់ប្តូរ៖
  - គោត្តនាមនិងនាមរបស់អ្នកវិជ្ជាជីវៈ_____
  - ការិយាល័យថ្មី ផ្ទះ/អគារលេខ _____ ផ្លូវ _____ ភូមិ _____
    ឃុំ/សង្កាត់ _____ ក្រុង/ស្រុក/ខណ្ឌ _____ រាជធានី/ខេត្ត _____
  - ផ្សេងៗ _____

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ_____ខែ_____ឆ្នាំ _____ ព.ស. _____

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី១៦នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីសម្រាប់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ជាតំណាងក្រុមហ៊ុន _____

ដែលកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំសន្លឹកអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ថ្មី

<u>យោង</u>៖ ប្រកាសលេខ_____ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំ គោរពស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ដោយមូលហេតុដូចខាងក្រោម៖

☐ សន្លឹកអាជ្ញាបណ្ណបានបាត់បង់ រហែក ឬខូច។

☐ ស្ថានភាពដែលមានចែងនៅក្នុងសន្លឹកអាជ្ញាបណ្ណចាស់ ត្រូវបានផ្លាស់ប្តូរ៖

- នាមករណ៍ក្រុមហ៊ុន_____
- ទីស្នាក់ការថ្មី ផ្ទះ/អគារលេខ _____ ផ្លូវ _____

  ភូមិ_____ឃុំ/សង្កាត់_____ក្រុង/ស្រុក/ខណ្ឌ_____រាជធានី/ខេត្ត_____
- ប្រធានក្រុមហ៊ុន_____
- ផ្សេងៗ_____

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ_____ខែ_____ឆ្នាំ_____ ព.ស. _____

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី១៧នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____

កាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កម្មវត្ថុ៖ សំណើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

យោង៖ ប្រកាសលេខ_____ ដ.ន.ស./ប្រ.ក.ចុះថ្ងៃទី_____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុ_____

_____

ខ្ញុំបាទ/នាងខ្ញុំគោរពស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ខ្ញុំបាទ/នាងខ្ញុំ។

ខ្ញុំបាទ/នាងខ្ញុំសូមអះអាងថាបានអនុវត្តចប់សព្វគ្រប់នូវកាតព្វកិច្ចទាំងឡាយដែលបានបង្កើតឡើងដោយកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ និងការងារកោសល្យវិច័យសំណង់របស់ខ្ញុំបាទ/នាងខ្ញុំ។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាថានឹងទទួលខុសត្រូវចំពោះការខូចខាតដែលអាចកើតមានឡើងដោយសារការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ និងការងារកោសល្យវិច័យសំណង់របស់ខ្ញុំបាទ/នាងខ្ញុំ។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ_____ ខែ ___ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ_____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី១៨នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ជាតំណាងក្រុមហ៊ុន _____

ដែលកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

<u>យោង</u>៖ ប្រកាសលេខ_____ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុ_____

_____

ក្រុមហ៊ុនយើងខ្ញុំគោរពស្នើសុំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់យើងខ្ញុំ។

យើងខ្ញុំសូមអះអាងថាក្រុមហ៊ុនយើងខ្ញុំបានអនុវត្តចប់សព្វគ្រប់នូវកាតព្វកិច្ចទាំងឡាយដែលបានបង្កើតឡើងដោយកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ និងការងារកោសល្យវិច័យសំណង់របស់ក្រុមហ៊ុនយើងខ្ញុំ។

ក្រុមហ៊ុនយើងខ្ញុំសូមសន្យាថានឹងទទួលខុសត្រូវចំពោះការខូចខាតដែលអាចកើតមានឡើងដោយសារការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ និងការងារកោសល្យវិច័យសំណង់របស់ក្រុមហ៊ុនយើងខ្ញុំ។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ ___ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី១៩នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____

កាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កម្មវត្ថុ៖ សំណើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____កម្រិត _____

យោង៖ ប្រកាសលេខ_____ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ខ្ញុំបាទ/នាងខ្ញុំនឹងផុតសុពលភាព ថ្ងៃទី ___ ខែ _____ ឆ្នាំ _____។ ខ្ញុំបាទ/នាងខ្ញុំ គោរពស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ ___ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី____ខែ____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី២០នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ជាតំណាងក្រុមហ៊ុន _____

ដែលកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ សំណើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

<u>យោង</u>៖ ប្រកាសលេខ_____ដ.ន.ស./ប្រ.ក.ចុះថ្ងៃទី_____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបន្តសុពលភាព និងការបញ្ចប់សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ក្រុមហ៊ុនយើងខ្ញុំនឹងផុតសុពលភាព ថ្ងៃទី_____ ខែ ___ ឆ្នាំ _____។ ខ្ញុំបាទ/នាងខ្ញុំគោរពស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____ ខែ ___ ឆ្នាំ_____ព.ស. ___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន

ឧបសម្ព័ន្ធទី២១នៃប្រកាសលេខ ៧៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តីកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់អ្នកវិជ្ជាជីវៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ _____

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____

កាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់_____ លេខ _____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កម្មវត្ថុ៖ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ _____

យោង៖ ប្រកាសលេខ_____ដ.ន.ស./ប្រ.ក.ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្តីកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបអំពីលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ខ្ញុំបាទ/នាងខ្ញុំ ដូចខាងក្រោមៈ

១. ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់

- គម្រោងប្តង់ ចំនួន_____គម្រោង
- ការងារសាងសង់ ចំនួន_____គម្រោង

២. ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

- សំណង់លំនៅឋាន ចំនួន_____គម្រោង
- សំណង់ក្នុងគោលដៅអាជីវកម្ម ចំនួន_____គម្រោង
- សំណង់និងបរិក្ខារសំណង់ ចំនួន_____គម្រោង
- សំណង់ដែលមានហានិភ័យ ចំនួន_____គម្រោង

៣. ការងារកោសល្យវិច័យសំណង់

- សំណង់លំនៅឋាន ចំនួន_____គម្រោង
- សំណង់ក្នុងគោលដៅអាជីវកម្ម ចំនួន_____គម្រោង

បញ្ជាប្រឈម

១- _____

២- _____

សំណូមពរ

១- _____

២- _____

ខ្ញុំបាទ/នាងខ្ញុំសូមធានាអះអាងថារបាយការណ៍ខាងលើនេះពិតជាត្រឹមត្រូវ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ_____ ខែ ___ ឆ្នាំ_____ព.ស.___

ធ្វើនៅ _____ថ្ងៃទី_____ខែ_____ឆ្នាំ _____

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី២២នៃប្រកាសលេខ ០៣៣ ជ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ _____

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ _____ ជាតំណាងក្រុមហ៊ុន _____

ដែលកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ _____ លេខ_____ កម្រិត _____

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>កម្មវត្ថុ</u>៖ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ _____

<u>យោង</u>៖ ប្រកាសលេខ_____ ជ.ន.ស./ប្រ.ក.ចុះថ្ងៃទី_____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបអំពីលទ្ធផលការងារប្រចាំឆ្នាំនៃការប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ក្រុមហ៊ុនយើងខ្ញុំដូចខាងក្រោម៖

១. ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់

- គម្រោងប្តង់ ចំនួន_____គម្រោង
- ការងារសាងសង់ ចំនួន_____គម្រោង

២. ការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

- សំណង់លំនៅឋាន ចំនួន_____គម្រោង
- សំណង់ក្នុងគោលដៅអាជីវកម្ម ចំនួន_____គម្រោង
- សំណង់និងបរិក្ខារសំណង់ ចំនួន_____គម្រោង
- សំណង់ដែលមានហានិភ័យ ចំនួន_____គម្រោង

៣. ការងារកោសល្យវិច័យសំណង់

- សំណង់លំនៅឋាន ចំនួន_____គម្រោង
- សំណង់ក្នុងគោលដៅអាជីវកម្ម ចំនួន_____គម្រោង

បញ្ជាប្រឈម

១. _____

២. _____

សំណូមពរ

១. _____

២. _____

ខ្ញុំបាទ/នាងខ្ញុំសូមធានាអះអាងថារបាយការណ៍ខាងលើនេះពិតជាត្រឹមត្រូវ។
១២ ចំពោះសន្លឹកទី១នៃគំរោងបួងចាំបាច់ត្រូវតែមាន បួងបង្ហាញទីតាំង បួងសរុប បទបញ្ជា និង កន្លែងចុះហត្ថលេខា របស់ប្រធានមន្ទីរ និង អភិបាលខេត្ត/ក្រុង ឬ ថ្នាក់ដឹកនាំក្រសួង។

១៣- តំនូរផ្ទាកសន្លឹកបួង (កាទូស) នៃសន្លឹកបួងនិមួយៗត្រូវអនុវត្តតាមគំរូដែលមានភ្ជាប់មកជាមួយ

១៤- គំរោងបួងស្ថាបត្យកម្មត្រូវមានជាលក្ខណៈជាតិ

១៥- គំរោងបួងស្ថាបត្យកម្មដែលមានក្រឡាផ្ទៃធំជាង ៥០០ ម៉ែត្រការ៉េ ត្រូវមានស្ថាបត្យករជាអ្នកសិក្សាគំរោងដោយមាន សញ្ញាប័ត្រថតចំលងដែលមានធ្វើនិត្យានុកូលកម្មនៅសាលាខេត្ត/ក្រុង ភ្ជាប់មកជាមួយ។

អ្នកសិក្សាគំរោងបួងត្រូវចុះហត្ថលេខាទទួលខុសត្រូវនៅគ្រប់សន្លឹកបួងដែលស្នើសុំសាងសង់

II. សំណុំឯកសារដែលមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ត្រូវបំពេញ

១-សលាកប័ត្រដីឡូត៍ ត្រូវបញ្ជាក់ពី :

- ទីតាំងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ
- ទីតាំងដីឡូត៍ជាប់គ្នា
- ផ្លូវចូលទៅដីឡូត៍, លក្ខណៈរបស់ផ្លូវ និង ទំហំផ្លូវ
- ពេញ្ញៈ ឬ លេខផ្លូវធំ និង ផ្លូវតូច
- ទំហំ និង ផ្ទៃក្រឡាដីឡូត៍ (ត្រូវបញ្ជាក់ពីទំហំដីវាស់ជាក់ស្តែង និង ទំហំដីក្នុងប័ណ្ណ)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍សុំសាងសង់ (ទីតាំង និង កំពស់)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និង កំពស់របស់វា
- មាត្រដ្ឋានបួង រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនឹងថ្កល់សំរាប់ជាគោលសំគាល់កំពស់ដែលបោះនៅលើដីឡូត៍
- បន្ទាត់ផ្លូវតំរង់ផ្លូវសាធារណៈ
- បួងសលាកប័ត្រនេះត្រូវធ្វើឡើងនិងចុះហត្ថលេខាដោយមន្ត្រីសុរិយោដី ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក/ខ័ណ្ឌ និង ប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

២- របាយការណ៍ត្រួតពិនិត្យទីតាំងរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក/ខ័ណ្ឌ

៣- ការពិនិត្យគំរោងបួងស្នើសុំលិខិតអនុញ្ញាតសាងសង់ត្រូវ :

- គោរពតាមគោលការណ៍ច្បាប់ អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ និង លិខិតបម្ងន់នេ គតិយុត្តិជាធរមាន។
- ពិនិត្យគ្រប់សំណុំឯកសារ និងគ្រប់សន្លឹកបួងសុំលិខិតអនុញ្ញាតសាងសង់
- គ្រប់សន្លឹកបួងត្រូវមានចុះហត្ថលេខាដោយប្រធានការិយាល័យរៀបចំដែនដី និង នគរូបនីយកម្ម និង ប្រធានការិយាល័យសំណង់ នៃ មន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង។

៤- របាយការណ៍ចេកទេសរបស់មន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

ក្នុងរបាយការណ៍បចេកទេសត្រូវបញ្ជាក់ឱ្យច្បាស់ពី :

ក- ប្រវត្តិរបស់ដី ស្ថានភាពដី និងលក្ខណៈនៃការកាន់កាប់ដី

ខ- សំណង់ ក្នុងនេះមានប្រភេទ មុខងារ ទំហំ និងតំលៃអគារនីមួយៗព្រមទាំងក្រឡាផ្ទៃតាមជាន់ នីមួយៗ ក្រឡាផ្ទៃអគារនីមួយៗ និងក្រឡាផ្ទៃសរុបនៃគំរោងបង្គំទាំងមូល

គ- លក្ខណៈនៃការធ្វើយបញ្ជូត ដែលក្នុងនោះមាន:

- តម្លាតរបស់អគារពីគ្រប់ទិសទៅព្រំដីកាន់កាប់ស្របច្បាប់
- កំពស់អគារ
- ជលធ្លៀងផ្ទៃបាតសំណង់ទៅនឹងផ្ទៃដីឡូតិ៍កាន់កាប់ស្របច្បាប់
- សន្ទស្សន៍ប្រើប្រាស់របស់សំណង់

ឃ- យោបល់ និង ការវាយតំលៃ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

III. សមត្ថកិច្ចជំនាញពាក់ព័ន្ធ

-ក្នុងករណីដែលគំរោងស្នើសុំមានពាក់ព័ន្ធនឹងជំនាញនានា (បរិស្ថាន ឧស្សាហកម្ម អាជ្ញាធរអប្សរា.....) សំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ត្រូវភ្ជាប់មកជាមួយមតិយោបល់របស់អង្គភាពពាក់ព័ន្ធទាំងនោះ ។

IV. បើក និង បិទ ការដ្ឋាន

- បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណង់ត្រូវសុំលិខិតអនុញ្ញាតបើកការដ្ឋានពី
  - មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់សាលាខេត្ត/ក្រុង
  - អគ្គនាយកដ្ឋានសំណង់ ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បន្ទាប់ពីបានបញ្ចប់ការសាងសង់ ម្ចាស់សំណង់ត្រូវសុំលិខិតអនុញ្ញាតបិទការដ្ឋានពី
  - មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់សាលាខេត្ត/ក្រុង
  - អគ្គនាយកដ្ឋានសំណង់ ប្រសិនបើសំណង់ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

ភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អគ្គនាយកដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីណែនាំ
ស្តីពីពង្រឹងគុណភាព និង
សុវត្ថិភាពសំណង់

ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០០៤ ដនស/សណន

សេចក្តីណែនាំ
ស្តីពី
ការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំសំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីសំណង់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ហាមដាច់ខាតការសាងសង់សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។
- ហាមដាច់ខាតការអនុវត្តការងារសាងសង់ឬរុះរើ ដោយអ្នកសាងសង់ដែលគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ហាមដាច់ខាតការដ្ឋានសំណង់ដែលដំណើរការសាងសង់ឬរុះរើដោយគ្មានវិស្វករប្រចាំការដ្ឋានជាអ្នកទទួលខុសត្រូវ។
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ ទោះបីជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសំណង់។
- ហាមការប្រើប្រាស់សំណង់គ្រប់ប្រភេទ ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬលិខិតបិទការដ្ឋានផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីពិនិត្យឃើញអំពើល្មើសនីងបម្រាមខាងលើ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញលិខិតផ្អាកការសាងសង់ជាបន្ទាន់។ ក្នុងករណីការសាងសង់នៅតែបន្ត អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីជាធរមាន។

ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៃការដ្ឋានសំណង់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវយកចិត្តទុកដាក់អនុវត្តគោលការណ៍និងវិធានការដូចខាងក្រោម÷

១) លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

- គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាស្ថាបត្យករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់រុះរើត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីគម្រោងប្លង់អនុញ្ញាត មិនត្រូវបានអនុញ្ញាតឡើយក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

២) លិខិតអនុញ្ញាតបើកការដ្ឋានសំណង់

- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវមានបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វកប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។

៣) ការរៀបចំការដ្ឋាន

- មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះវាស់វែងនិងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។
- ការដ្ឋានសំណង់ត្រូវមានផ្ទាំងព័ត៌មានអំពីគម្រោងសាងសង់នៅពីមុខការដ្ឋានសំណង់ ជាអាទិ៍ ឈ្មោះគម្រោងសាងសង់ ឈ្មោះក្រុមហ៊ុនសាងសង់ ឈ្មោះមេក្រុមជាង ឈ្មោះម្ចាស់សំណង់ ឈ្មោះរបស់វិស្វកប្រចាំការដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រូបភាពនេត្រាទស្សន៍នៃគម្រោងសាងសង់ និងអាសយដ្ឋានទីតាំងសំណង់។
- ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមវិធានសុវត្ថិភាពដូចមានកំណត់ក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ (ឆ្នាំ២០១៨) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៤) ដំណើរការការដ្ឋានសំណង់

- មានតែក្រុមហ៊ុនសាងសង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចទទួលម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារមួយផ្នែកឬច្រើនទៅឱ្យក្រុមជាងសំណង់។ ក្នុងករណីនេះ ក្រុមជាងសំណង់ត្រូវអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។
- ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចទទួលម៉ៅការសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ ការងាររបស់ក្រុមជាងសំណង់ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច ០១ (មួយ) រូប ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។
- គ្រប់ការដ្ឋានសំណង់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ប្រុះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។
- ក្រុមហ៊ុនសាងសង់ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោម÷
    - ក្នុងពេលកំណត់ទីតាំងសាងសង់
    - ក្នុងពេលអនុវត្តការងារគ្រឹះ
    - ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
    - ក្នុងពេលអនុវត្តការងារគ្រឿងធ្នុំបន្តបន្ទាប់ទៀត។
- នៅរាល់ពេលចុះត្រួតពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និងវិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធ។
- ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់ប្រុះរើមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ គម្រោងប្តង់ស្ថាបត្យកម្មដែលបានអនុញ្ញាតហើយ និងបទប្បញ្ញត្តិជាធរមានដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើឬវិធានការចាំបាច់ផ្សេងទៀត។

- អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចងក្រងនិងរក្សារាល់កំណត់ហេតុ របាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយៗ ទាំងជាឯកសារីងនិងទាំងជាឯកសារអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។

៥) ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់

- គម្រោងប្តង់គ្រឿងផ្គុំសំណង់និងការងារសាងសង់ ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ ដែលជាក្រុមហ៊ុនសិក្សាគម្រោងប្តង់ឬក្រុមហ៊ុនសាងសង់ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង។
- ការត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្តង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តដាច់ខាតលើគម្រោងប្តង់ផ្នែកគ្រឹះ ជើងតាង សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាលសំខាន់ៗនៃការងារគ្រឿងផ្គុំ ជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។
- វិញ្ញាបនបត្រត្រួតពិនិត្យនិងបញ្ជាក់សំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ គឺជាឯកសារដែលអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់ក្នុងការសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលមានតម្លៃសម្រាប់ការចូលប្រើប្រាស់ ការដាក់ជួល ការលក់ ឬប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតពាក់ព័ន្ធនឹងសំណង់។
- ក្នុងករណីពិនិត្យឃើញការងារសាងសង់មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចាត់វិធានការសមស្រប។

ទទួលបានសេចក្តីណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣ ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- **"ដើម្បីជូនជ្រាប"**
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សារាចរណែនាំ
ស្តីពីការអនុវត្តតំបន់ឆ្នេរសមុទ្រ
នៃព្រះរាជាណាចក្រកម្ពុជា

ឆ្នាំ ២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១.ស.រ.ណ.ន

សារាចរណែនាំ
ស្តីពី
ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក កាលពីថ្ងៃទី២៥និងទី២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូតា ប្រទេសសេណេហ្គាល់ ដោយក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណិតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ី សេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជននៅក្នុងតំបន់ឆ្នេរសមុទ្រ ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលទាមទារឲ្យមានការអភិវឌ្ឍផ្នែករូបវន្តសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាពនិងចីរភាព ដើម្បីចៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្ម ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០(សាមសិប)ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក។
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ)ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្នែចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយនិងត្រូវរៀបចំដាក់តូបឆ្មាំឆ្នេរសមុទ្រ ដោយបំពាក់សម្ភារៈនិងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើលនិងការពារសុវត្ថិភាពជូនសាធារណជននិងអ្នកទេសចរ។

២- ដីចំណីឆ្នេរសមុទ្រនិងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតងនិងបណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរនិងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

២.១- ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។

ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០(ហាសិប)ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

២.២- ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

ទី១- ដីចំណីឆ្នេរសមុទ្រដែលមានមនុស្សរស់នៅច្រើននិងមានលក្ខណៈជាទីប្រជុំជនឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗសម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើដែលមានចម្ងាយពីតូបមួយទៅតូបមួយទៀតយ៉ាងតិច១៥(ដប់ប្រាំ)ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជននិងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារនិងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្បៈសាធារណៈ
- អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរគ្រប់ប្រភេទចូលចតក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជននិងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្របនិងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- មិនអាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែពាណិជ្ជកម្ម លើកលែងតែកំពង់ផែដែលមានស្រាប់និងទីតាំងដែលមានសក្តានុពលខ្លាំងនិងចាំបាច់សម្រាប់សាងសង់កំពង់ផែ

- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈនិងទេសចរណ៍ដូចជា៖
  - ច្រកចូលឬស្ពានសម្រាប់តភ្ជាប់ទៅរកកំពង់ផៃ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរឬសាធារណជនប្រើប្រាស់។ កំពង់ផៃទាំងនេះត្រូវមានទីតាំងសមស្របនិងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ
  - សារមន្ទីរជីវៈចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ(Aquariums) ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរឬសាធារណជនអាចឆ្លងកាត់បាន
  - ទីតាំងផ្សេងទៀតដែលរាជរដ្ឋាភិបាលអនុញ្ញាត។

ទី២- ដីចំណីឆ្នេរសមុទ្រស្ថិតក្នុងតំបន់ដែលមិនមានមនុស្សរស់នៅច្រើននិងមិនមែនជាទីប្រជុំជន ការប្រើប្រាស់ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យមានសំណង់កំពង់ផៃ ពាណិជ្ជកម្ម ឬកំពង់ផៃនេសាទ។ ចំពោះកំពង់ផៃដែលមានស្រាប់ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹង។ ក្នុងករណីចាំបាច់ ត្រូវធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថាននិងភាពសមស្របនៃទីតាំង ដើម្បីធានាសុវត្ថិភាពសុខុមាលភាពនិងការកាត់បន្ថយហានិភ័យផ្សេងៗ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាតំបន់ទេសចរណ៍លើទឹក កំពង់ផៃទេសចរណ៍ ឬតំបន់កម្សាន្តថ្មីដោយមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាភូមិទេសចរណ៍នៅក្នុងទីតាំងភូមិឋានថ្មីឬដែលមានស្រាប់ទៅតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងនៃទីតាំងនីមួយៗ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជា សំណង់រោងចក្រ ឧស្សាហកម្មរោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាសនិងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង
- អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍឬឲ្យមានសំណង់ផ្សេងទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

៣- ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រ ដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណបៗ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះនិងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្មក្នុងគោលដៅ

ថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ (ដប់ប្រាំ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

៤- តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ

តំបន់រណប គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀត ដែលស្ថិតក្នុងទិសខាងដីគោក។

ការអភិវឌ្ឍនិងការសាងសង់សំណង់នានាក្នុងតំបន់នេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់សេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត។

ដើម្បីលើកកម្ពស់សោភណភាពបរិស្ថានធម្មជាតិនិងសំណង់ ការអភិវឌ្ឍសំណង់អគារក្នុងតំបន់រណបនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប សម្រាប់គ្រប់ប្រភេទសំណង់អគារ ដូចមានចែងក្នុងបទដ្ឋាននគរូបនីយកម្ម
- ត្រូវរៀបចំឲ្យមានសួនច្បារ ដាំស្មៅ ដាំដើមឈើ និងមានផ្លូវថ្មើរជើងនៅលើចិញ្ចើមផ្លូវ ស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវរៀបចំជាលំហសាធារណៈ សួនច្បារ សួនកម្សាន្ត ឬឧទ្យានសាធារណៈជាដើម ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រ
- ត្រូវមានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសម្រាប់រាល់ការដាក់តាំងស្លាកសញ្ញាពាណិជ្ជកម្ម។

៥- ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ

ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រដែលតភ្ជាប់ទៅចំណុចប្រសព្វនឹងផ្លូវដែលជាប់នឹងដីចំណីឆ្នេរសមុទ្រត្រូវ៖

- រក្សាទុកចិញ្ចើមសងខាងយ៉ាងតិច៦(ប្រាំមួយ)ម៉ែត្រ ចំពោះកំណាត់ផ្លូវសាធារណៈនៅក្នុងតំបន់រណប ដើម្បីរៀបចំឲ្យមានសួនច្បារ ការដាំស្មៅ ការដាំដើមឈើព្រមទាំងផ្លូវថ្មើរជើងស្របតាមបទដ្ឋានបច្ចេកទេស
- រៀបចំឲ្យមានសួនច្បារ ការដាំស្មៅ និងការដាំដើមឈើអមសងខាងតាមស្ថានភាពជាក់ស្តែងនិងស្របតាមបទដ្ឋានបច្ចេកទេសចំពោះផ្លូវថ្មើរជើងដែលមានស្រាប់ឬបង្កើតថ្មី
- ត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្តាញបៃតងភ្ជាប់ទៅនឹងដីចំណីឆ្នេរសមុទ្រ ចំពោះផ្ទៃដីឬលំហសាធារណៈដែលស្ថិតនៅជាប់ផ្លូវសាធារណៈដែលមានស្រាប់ឬបង្កើតថ្មី ដើម្បីលើកកម្ពស់សោភណភាពបរិស្ថាននិងជាការបើកច្រកខ្យល់ជំនោរសមុទ្រ។

៦- ដែសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ

ដែសមុទ្រគឺជាផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដែសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដែសមុទ្រ ត្រូវកំណត់ចម្ងាយ៣០(សាមសិប)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានគឺជាផ្ទៃទឹកសាបដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ២០(ម្ភៃ)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

ផ្លូវសាធារណៈតាមបណ្តោយដីចំណីដែសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដែសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដែសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដែសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបានឬបណ្តែតបាន។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈខាងលើនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម ក្នុងគោលដៅថែរក្សាការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានដីចំណីផ្លូវយ៉ាងតិច១០(ដប់)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

នៅតាមបណ្តោយផ្លូវសាធារណៈនេះត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើន បង្កើតជាបណ្តាញបៃតង ដើម្បីលើកកម្ពស់សោភណភាពនិងបរិស្ថាន។

ការអភិវឌ្ឍជាសំណង់អគារផ្សេងៗនៅជាប់ផ្លូវសាធារណៈនេះ ត្រូវមានសន្ទស្សន៍ទាបដូចក្នុងតំបន់រណបតាមបណ្តោយផ្លូវជាប់នឹងដីចំណីឆ្នេរសមុទ្រដែរ។

៧- កោះ

កោះ ជាផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

៧.១- ការប្រើប្រាស់និងការអភិវឌ្ឍកោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ

លើកលែងតែមានការហាមឃាត់ដោយច្បាប់ កោះមួយចំនួនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាមណ្ឌោះអាសន្ននិងមិនទៀងតាមរយៈកិច្ចសន្យាច្បាស់លាស់។ ការអភិវឌ្ឍកោះក្នុងកម្មវត្ថុនេះ ត្រូវគោរពតាមបម្លែងគោលប្រើ

ប្រាស់ដី និងផែនការប្រើប្រាស់ដីព្រមទាំងបទប្បញ្ញត្តិជាធរមានឬតាមផែនការអភិវឌ្ឍដែលរាជរដ្ឋាភិបាលឬក្រសួងស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះកោះដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងកម្មវត្ថុនេះ តែពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែងនិងគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវរក្សានិងការពារធនធានធម្មជាតិ ព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិប)ភាគរយ
- ត្រូវមានសន្ទស្សន៍ទាប ដោយមានផលធៀបក្រឡាផ្ទៃបាតសំណង់ទាបជាង៣៥%(សាមសិបប្រាំ) ភាគរយ ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើនិងធ្វើជាសួនបៃតងយ៉ាងតិច៥០% (ហាសិប) ភាគរយ
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- ត្រូវរៀបចំឲ្យមានលំហសាធារណៈនិងតំបន់កម្សាន្តនានាឲ្យបានច្រើនជាអតិបរមាដើម្បីជំរុញការមកលេងកម្សាន្តរបស់សាធារណជននិងអ្នកទេសចរ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចអនុញ្ញាតឲ្យសាធារណជនទូទៅឬអ្នកទេសចរចេញចូលបាន
- ត្រូវរៀបចំឲ្យមានតំបន់កម្សាន្តនានាក្នុងករណីមានឆ្នេរខ្សាច់ និងរៀបចំកសាងផ្លូវសាធារណៈនៅក្បែរឆ្នេរនេះ ស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។ ផ្លូវសាធារណៈ ត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេសនិងតម្រូវការនៃការប្រើប្រាស់យូរអង្វែង
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការប៉ះពាល់ដល់បរិស្ថាន
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទដូចជាផ្កាថ្ម ព្រៃ និងរុក្ខជាតិសមុទ្រជាដើម ដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍។

៧.២- ការអភិវឌ្ឍនិងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ

រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍកោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជនឬផ្តល់សិទ្ធិឲ្យឯកជនធ្វើការអភិវឌ្ឍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍកោះ ជាលក្ខណៈរូបវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យភាពសមស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការអភិវឌ្ឍនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាបឬមធ្យម
- ត្រូវការពារធនធានធម្មជាតិនិងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិបភាគរយ)
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ

- ត្រូវរៀបចំប្លង់អភិវឌ្ឍន៍រូបវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ សួនច្បារ សួនឧទ្យាន បណ្តាញបៃតង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ ផ្លូវថ្មើរជើង ប្រព័ន្ធលូបង្ហូរ ប្រព័ន្ធចម្រោះទឹកកខ្វក់ ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកទេសចរនិងសាធារណជនទូទៅចេញចូលបាន តាមស្ថានភាពជាក់ស្តែងនិងមានទីតាំងសមស្រប
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការបោះសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ មុនពេលធ្វើប្រព្រឹត្តកម្ម
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ព្រៃ និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះ ដើម្បីគោលដៅទេសចរណ៍

៧.៣- ចំពោះកោះដែលមិនមានភាពអំណោយផលដល់ការប្រើប្រាស់និងមិនអាចធ្វើការអភិវឌ្ឍផ្សេងៗបាន ត្រូវរក្សាទុកសភាពដើមសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ទេសភាពសមុទ្រ។

៨. ដែនទឹកសមុទ្រ

ដែនទឹកសមុទ្រ សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះគ្រប់ប្រភេទ។

ដែនទឹកសមុទ្រ ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះនានា ដូចជា ផ្កាថ្ម ព្រៃធំតូចចម្រុះពណ៌ និងរុក្ខជាតិសមុទ្រត្រូវគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព។

ការជិះនាវាឬទូកទេសចរណ៍គ្រប់ប្រភេទ ដូចជាទូកម៉ាស៊ីន អូប៉ែរ ម៉ូតូទឹក ជាដើម អាចធ្វើឡើងតែក្នុងបរិវេណអនុញ្ញាតប៉ុណ្ណោះដើម្បីសុវត្ថិភាពអ្នកទេសចរនិងជីវៈចម្រុះ។

ការអភិវឌ្ឍកំពង់ផែទេសចរណ៍ឬទីតាំងកម្សាន្តបណ្តែតទឹកនិងក្នុងទឹកនានា ត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជា ដើម្បីពិនិត្យភាពសមស្របនៃទីតាំង តាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។

ការនេសាទក្នុងតំបន់ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះត្រូវហាមឃាត់ លើកលែងតែការនេសាទជាលក្ខណៈទេសចរណ៍ដោយប្រើប្រាស់ឧបករណ៍នេសាទគ្រួសារ។

ការបូមខ្សាច់និងការសាងសង់សំណង់ផ្សេងៗនៅក្នុងដែនទឹកសមុទ្រ ដូចជាស្ថានីយសិក្សាស្រាវជ្រាវអំពីសមុទ្រ ស្ថានីយរុករករ៉ែជាដើម ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាល។

រាល់ទីតាំងសំណង់លើទឹកទាំងអស់ ត្រូវរក្សាច្រកផ្លូវនាវាធំៗចេញចូលកំពង់ផែ។

៩. ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រ

៩.១- រាល់ការប្រគល់សិទ្ធិឲ្យឯកជនធ្វើការវិនិយោគនិងអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- រៀបចំឲ្យមានច្រកចេញចូលនៅតាមបណ្តោយឆ្នេរសមុទ្រ ដើម្បីអាចឲ្យភ្ញៀវទេសចរនិងសាធារណជនចេញចូលដើរលេងកម្សាន្តនិងប្រើប្រាស់បាន

- អនុវត្តតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត
- ត្រូវរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដោយរៀបចំឲ្យមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹក និងគ្រប់គ្រងកាកសំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស ចំពោះរាល់ការអភិវឌ្ឍ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃផលប៉ះពាល់បរិស្ថាន ឲ្យបានត្រឹមត្រូវម៉ត់ចត់ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជាសំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស និងកម្រិតបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង។

៩.២- រាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

១០- សារាចរណែនាំនេះមិនមានផលប្រតិសកម្មទេ។

១១- សារាចរណែនាំនេះមិនពាក់ព័ន្ធទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ទេ។

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ចនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៃបណ្តាខេត្តតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាពនិងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ក្រ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សារាចរណែនាំ
ស្តីពីវិធានការគ្រប់គ្រង
អាជីវកម្មចែកចាយ
ផលិតផលគេសសិល

ឆ្នាំ ២០១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ជវជ្ជាតិចាលករម្ពុជា
ចខ: ០៧៧ . សរ ណស

សារាចរណែនាំ

ស្តីពី

វិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលគេលសិលា

កន្លងមករាជរដ្ឋាភិបាលបានចេញជាបន្តបន្ទាប់ នូវអនុក្រឹត្យ លិខិតបញ្ជា ឬសារាចរណែនាំនានាមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន ជាពិសេសពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈ ការការពារអ្នកប្រើប្រាស់ និងការទប់ស្កាត់អំពើគេចពន្ធ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលគេលសិលា ពុំទាន់ត្រូវបានដំណើរការរលូននៅឡើយ ។ ក្រៅពីប៉ះពាល់ដល់ប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ-អាករ និងបង្កឲ្យមានអំពើអយុត្តិធម៌ក្នុងការប្រកួតប្រជែងពាណិជ្ជកម្មនោះ អាជីវកម្មនេះជារឿយៗក៏បានបង្កនូវហានិភ័យដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដូចជាការបង្កនូវអគ្គិភ័យតាមទីប្រជុំជននានា និងការជ្រៀតចូលផលិតផលខុសស្តង់ដារតាមស្ថានីយ៍ចែកចាយមួយចំនួន ដែលប៉ះពាល់ដល់ផលប្រយោជន៍អ្នកប្រើប្រាស់យានយន្ត និងគ្រឿងម៉ាស៊ីនជាទូទៅផងដែរ ។

ក្នុងន័យនេះ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ការការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាអនុលោមតាមការអនុវត្តល្អជាអន្តរជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលគេលសិលា រាជរដ្ឋាភិបាលសម្រេចកំណត់ដូចខាងក្រោម ៖

១. ការធ្វើអាជីវកម្មចែកចាយប្រេងឥន្ធនៈមួយចំនួន រួមមាន ប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងកាត និងប្រេងខ្មៅ ត្រូវធ្វើឡើងតែតាមបណ្តាស្ថានីយ៍ចែកចាយ ដែលមានការអនុញ្ញាតតាមបទប្បញ្ញត្តិជាធរមាន និងមានទីតាំងតាមដងផ្លូវសាធារណៈ ឬតាមទីប្រជុំជននានា លើកលែងតែអាជីវកម្មខ្នាតតូចតាមតំបន់ជនបទ ដែលពុំទាន់មានស្ថានីយ៍ចែកចាយស្របច្បាប់ ។

២. ការបង្កើត និងការធ្វើអាជីវកម្ម ស្ថានីយ៍ចែកចាយប្រេងឥន្ធនៈនីមួយៗត្រូវមានការអនុញ្ញាតជាមុនពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងត្រូវគោរពតាមស្តង់ដារសុវត្ថិភាព និងស្តង់ដារបច្ចេកទេសផ្សេងទៀត តាមបទប្បញ្ញត្តិជាធរមាន និងត្រូវស្ថិតនៅក្នុងទីតាំងដែលមិនមែនជាលំនៅដ្ឋាន ងាយស្រួលដល់ការធានានូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ និងការត្រួតពិនិត្យនានារបស់អាជ្ញាធរមានសមត្ថកិច្ច ។

៣. ស្ថានីយ៍ចែកចាយប្រេងឥន្ធនៈទាំងអស់ ត្រូវមានតាំងបង្ហាញនូវស្លាកសញ្ញាសម្គាល់ក្រុមហ៊ុនអាជីវកម្មប្រេងឥន្ធនៈ ដែលជាអ្នកផ្គត់ផ្គង់ស្របច្បាប់តែមួយគត់ នូវផលិតផលទាំងនេះដល់ស្ថានីយ៍របស់ខ្លួន ។ ការផ្គត់ផ្គង់ប្រេងឥន្ធនៈពីប្រភពផ្សេងទៀត ក្រៅពីក្រុមហ៊ុនផ្គត់ផ្គង់ដែលមានស្លាកសញ្ញាសម្គាល់ក្រុមហ៊ុនតាមស្ថានីយ៍ចែកចាយនីមួយៗ ត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៤. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកំណត់បន្ថែមនូវនីតិវិធីលម្អិត ពាក់ព័ន្ធនឹងការត្រួតពិនិត្យការដឹកជញ្ជូន ចរាចរ សន្និធិ និងការកាន់កាប់ផលិតផលគេលសិលា ដែលជាទំនិញកំណត់ពិសេស តាមបញ្ញត្តិនៃច្បាប់ស្តីពីគយជាធរមាន ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្មនេះ ។

៥. អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀតចុះណែនាំដោយផ្ទាល់ដល់អាជីវករ និងធុរជនពាក់ព័ន្ធឲ្យបានយល់ច្បាស់នូវខ្លឹមសារសារាចរនេះ ។ អាជីវករពាក់ព័ន្ធត្រូវចាត់ចែងកែសម្រួល ឬបំពេញបន្ថែមនូវភាពមិនប្រក្រតី ឬការខ្វះខាតនានាក្នុងកិច្ចដំណើរការអាជីវកម្មផលិតផលគេលសិលារបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវចំពោះមុខច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចាត់ចែងផ្សព្វផ្សាយឲ្យបានទូលាយ និងចូលរួមសហការត្រួតពិនិត្យការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>ចម្លងជូន</u> ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សារាចរណែនាំ
ស្តីពីការគ្រប់គ្រងក្រុមជាង
សំណង់

ឆ្នាំ ២០០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ០០.ប.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី ១០ ខែ ភ្នំ ឆ្នាំ ២០០

សារាចរណែនាំ

ស្តីពី

ការគ្រប់គ្រងក្រុមជាងសំណង់

អនុលោមទៅតាមប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុនស៊ីក្សាំរោងបូង និង សាងសង់ និង ដើម្បីគ្រប់គ្រងអោយមានប្រសិទ្ធភាពការងារសាងសង់ ដែលអនុវត្តដោយក្រុមជាងសំណង់នៅតាមបណ្តា ខេត្ត ក្រុង ដែលបច្ចុប្បន្ននេះក្រុមជាងសំណង់អាំងនេះប្រកបរាជីវកម្មសាងសង់តាមទ្រង់ទ្រាយអាជីវកម្មតូច និង មិនទាន់មានច្បាប់អនុញ្ញាតនៅឡើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំដូចតទៅ :

I - <u>សិទ្ធិរបស់ក្រុមជាងសំណង់</u>

ការប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់ ត្រូវបានប្រគល់សិទ្ធិអោយអនុវត្តការងារតាមការកំណត់ និង មុខជំនាញដូចខាងក្រោម ហើយដែលមានទំហំបច្ចេកទេសមិនលើសពីកំរិតកំណត់ដូចតទៅ :

- ផ្ទៃក្រឡាសំណង់សរុប 80 ម៉ែត្រទ្វេគុណ
- ផ្ទៃក្រឡាសំណង់ ដែលត្រូវសង់ថ្មីបន្ត ឬពង្រីកបន្ថែម ត្រូវបូកបញ្ចូលនឹងផ្ទៃក្រឡាសំណង់ចាស់មានស្រាប់
- ផ្ទៃក្រឡាសំណង់ត្រូវគិតបញ្ចូលគ្នា ចំពោះសំណង់ដែលមានគ្រឿងផ្តុំជាប់គ្នា មោះបីមានកម្មសិទ្ធិដោយឡែកពីគ្នា ឬពេលវេលានៃការអនុញ្ញាតអោយសាងសង់ខុសគ្នាក៏ដោយ
- កំពស់អគារមួយជាន់ (ជាន់ផ្ទាល់ដី)
- អគារពុំមានត្រឹមលក្ខណៈសង់បន្ថែមច្រើនជាន់
- សំណង់អគារពុំស្ថិតនៅតំបន់ដី បាក់ស្រុព តំបន់ដីហានកំរិតទ្រខ្សោយ
- ធ្នឹមកំរាល ធ្នឹមទ្រផ្ទេរ្យ១ មានប្រវែង 4 ម៉ែត្រ ប្រើ្រមគ្រោងដំបូលមានប្រវែង 8 ម៉ែត្រ ធ្នឹមឥរយមាន ប្រវែង 1,50 ម៉ែត្រ
- អាងកប់ដី ដែលមានចំណុះ 10 ម៉ែត្រត្រីគុណ អាងទឹកខ្ពស់ពីដី 4 ម៉ែត្រ ដែលមានចំណុះ 8 ម៉ែត្រត្រីគុណ

- របងកំពស់ 2,5 ម៉ែត្រ គិតពីនីវ៉ូ ដីត្រង់ជើងរបង
- សំណង់ជាលំនៅឋានរបស់ប្រជាពលរដ្ឋធ្វើពីឈើ (ដោយមិនគិតពីផ្ទៃក្រឡា និងកំពស់នៃសំណង់)
- ម៉ៅការបន្ត ការងារជុសជុល និង សាងសង់ពី សហគ្រាស ក្រុមហ៊ុនសាងសង់នានា ដែលមានលិខិតអនុញ្ញាត ប្រកបអាជីវកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយមានការទទួលខុសត្រូវលើ លក្ខណៈបច្ចេកទេសពីសហគ្រាស ក្រុមហ៊ុនសាងសង់នោះ

- ក្រុមជាងសំណង់ កាលណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចសុំតំឡើងឋានៈប្រភេទជាសហគ្រាស ក្រុមហ៊ុន សាងសង់បាន ដោយត្រូវធ្វើបែបបទស្នើសុំមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដើម្បី ពិនិត្យសំរេច ។

II.<u>សមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ខេត្ត ក្រុង</u>

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មអោយដល់ក្រុមជាងសំណង់
- ចេញលិខិត បិទ ផ្អាក អាជីវកម្ម ក្រុមជាងសំណង់
- ស្រង់ស្ថិតិ សហគ្រាស ក្រុមហ៊ុនរួមទាំងក្រុមជាងសំណង់ និង ក្រុមជាងតាមមុខជំនាញ ដែលធ្វើអាជីវកម្ម ក្នុងមូលដ្ឋានរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ គ្រប់គ្រងសកម្មភាពអាជីវកម្ម
- ត្រូវផ្អាក ឬ បិទសកម្មភាពអាជីវកម្មរបស់ក្រុមជាងសំណង់ណា ដែលប្រកបអាជីវកម្មជុសជុល និងសាងសង់ គ្មានលិខិតអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឬ ក្នុងករណីដែលក្រុមជាងសំណង់នោះមិនគោរពតាមការកំណត់ ការណែនាំ បទប្បញ្ញត្តិផ្សេង១ ពីក្រសួង ស្ថាប័ន និង មន្ទីរខេត្ត ក្រុងហានសមត្ថកិច្ច ។

III.<u>លក្ខខ័ណ្ឌសុំប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់</u>

១- ប្រធានក្រុមជាងសំណង់ ដែលជាមេជាងសំណង់ត្រូវមានសញ្ជាតិខ្មែរ

២- ប្រធានក្រុមជាងសំណង់ត្រូវមកដាក់ពាក្យសុំប្រកបអាជីវកម្មដោយខ្លួនឯងផ្ទាល់

៣- នាមករណ៍របស់ក្រុមជាងសំណង់មិនអនុញ្ញាតអោយប្រើពាក្យថា សហគ្រាស ឬ ក្រុមហ៊ុនឡើយ

៤- ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេង១ ស្របតាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៥- ក្រុមជាងសំណង់ ត្រូវតំណាងអុករបាយការណ៍ សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួននៅមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង តាមការណែនាំរបស់មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង

៦- ក្នុងករណីមានការផ្លាស់ប្តូរអាស័យដ្ឋាន ឬ ប្រធានក្រុមជាងសំណង់ ត្រូវជូនដំណឹងមកមន្ទីររៀបចំដែន ដី

នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង យ៉ាងយូរ២សប្តាហ៍ក្រោយការផ្លាស់ប្តូរ ។

IV- <u>ទំរង់បែបបទ សុំប្រកបអាជីវកម្ម</u>

- ពាក្យសុំប្រកបអាជីវកម្ម ៤ច្បាប់
- ជីវប្រវត្តិសង្ខេប របស់ប្រធានក្រុមជាងសំណង់ដោយមានបិទរូបថតទំហំ ៤ x ៦ ៤ច្បាប់
- ជីវប្រវត្តិសង្ខេប របស់ ជាង តាមមុខជំនាញ មានបិទរូបថត ៤ x ៦ ៤ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ របស់ប្រធានក្រុមជាងសំណង់ ដែលមានធ្វើនិត្យានុកូលកម្ម នៅសាលា ខេត្ត ក្រុង ៤ច្បាប់
- សេចក្តីប្រកាសពីភាពគ្មានទោសពៃរ៍ របស់ប្រធានក្រុមជាងសំណង់ ៤ច្បាប់
- លក្ខន្តិកៈរបស់ក្រុមជាងសំណង់ ៤ច្បាប់
- កិច្ចសន្យារវាងក្រុមជាងសំណង់ និង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដែលចេញលិខិតអនុញ្ញាតអោយប្រកបអាជីវកម្ម ៤ច្បាប់
- បញ្ជីរាយឈ្មោះជាងសំណង់តាមផ្នែកជំនាញ និង អង្គការលេខ របស់ក្រុមជាងសំណង់ ៤ច្បាប់
- ឯកសារស្នាដៃ (បើមាន) ២ច្បាប់
- បញ្ជីគ្រឿងចក្រសំណង់ (បើមាន) និង សំភារៈបរិក្ខារ ៤ច្បាប់
- ឯកសារធនាគារ (បើមាន) ១ច្បាប់
- បង្កាន់ដៃបង់ពន្ធ (ប័ណ្ណប៉ាតង់) ១ច្បាប់
- វិញ្ញាបនប័ត្រ ចុះបញ្ជីពាណិជ្ជកម្ម (បើមាន) ១ច្បាប់

រាល់ការបំពេញបែបបទដូចមានចែងក្នុងចំណុច IV ខាងលើ ត្រូវបំពេញតាមសំណុំឯកសារសុំប្រកបអាជីវកម្ម ដូចមានជូនភ្ជាប់ជាមួយ ។

V- <u>សុពលភាព នៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម</u>

លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដល់ក្រុមជាងសំណង់ មានសុពលភាពបីឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ហើយក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាពក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតជាថ្មី ពីមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ដោយភ្ជាប់មកជាមួយនូវ លិខិត អនុញ្ញាតចាស់ និង បង្កាន់ដៃបង់ ពន្ធអាករ ជាថ្មី ។

ទទួលបានសារាចរណែនាំនេះ ត្រប់អគ្គនាយកដ្ឋាន និង មន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និង មានប្រសិទ្ធភាព ។

អ៊ុំ សុភ័ណ្ឌិ

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័ន ពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ត្រប់អគ្គនាយកដ្ឋាន
- សាលាខេត្ត-ក្រុង
- ត្រប់មន្ទីរ ដ.ន.សខេត្ត ក្រុង
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សារាចរណែនាំ
ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និងសាងសង់ របស់សហគ្រាស ក្រុមហ៊ុន និង រូបវន្តបុគ្គលបរទេស

ឆ្នាំ ២០០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ០០៤ ដ.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី ៤ ខែ ០៧ ឆ្នាំ ២០០០

សារាចរណែនាំ

ស្តីពី

ការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និង សាងសង់

របស់សហគ្រាស ក្រុមហ៊ុន និង រូបវន្តបុគ្គលបរទេស

យោងមាត្រាទី ១៩ ត្រង់ផ្នែកទី ៤ នៃច្បាប់ស្តីពី " វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម " ដែលចែងពី ក្រុមហ៊ុនបរទេស ដែលមានតែសាខា ឬ ទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា និង យោងតាមប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុអហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម របស់បណ្តាសហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេសដូចតទៅ :

I <u>ការកំណត់ទ្រង់ទ្រាយ</u>

សហគ្រាស ក្រុមហ៊ុន រូបវន្តបុគ្គលបរទេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកតាមទ្រង់ទ្រាយអាជីវកម្មដូចតទៅ :

១-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការចំនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣-រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

II <u>ការចុះបញ្ជីប្រកបអាជីវកម្ម</u>

ចំពោះ :

១- អភិបាលការិយាល័យតំណាង ឬ ទីភ្នាក់ងារ និង សាខាក្រុមហ៊ុន ឬ អាណត្តិគាហកនៃ សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ទីភ្នាក់ងារ និង សាខាក្នុងព្រះរាជាណាចក្រកម្ពុជា

២- អភិបាល ឬ សមាជិកនៃសហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា

៣- រូបវន្តបុគ្គលបរទេសសិក្សាគំរោងបួង់

ត្រូវមកបំពេញដោយផ្ទាល់នូវបែបបទសុំចុះឈ្មោះការិយាល័យតំណាងទីភ្នាក់ងារ ឬ សាខាក្រុមហ៊ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង ចុះឈ្មោះសហគ្រាស ក្រុមហ៊ុន រូបវន្តបុគ្គលបរទេសសិក្សាគំរោងបួង់ក្នុងបញ្ជីអាជីវកម្ម នៅនាយកដ្ឋានសិក្សាគំរោងបួង់ចំណុះអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

អភិបាល ឬ អាណត្តិគាហក ត្រូវចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីនាយកដ្ឋានសិក្សាគំរោងបួង់ ដើម្បីធានាអះអាងទទួលខុសត្រូវលើរាល់សំណុំលិខិត ដែលខ្លួនបានយកមកតម្កល់ទុក នៅនាយកដ្ឋានសិក្សាគំរោងបួង់ ថាពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ។

ក្នុងករណីដែលពិនិត្យឃើញថា លិខិត ឬ ឯកសារណាមួយនៃសំណុំឯកសារសុំចុះបញ្ជីប្រកបអាជីវកម្មមានភាពមិនច្បាស់លាស់ អភិបាលការិយាល័យតំណាង ទីភ្នាក់ងារ សាខាក្រុមហ៊ុន ឬ ប្រធានក្រុមប្រឹក្សាអភិបាលក្រុមហ៊ុន ឬ អភិបាលណាម្នាក់ ឬ អាណត្តិគាហក ត្រូវមកបំភ្លឺ និង ដោះស្រាយទៅតាមករណីនីមួយៗតាមការកោះអញ្ជើញរបស់ប្រធាននាយកដ្ឋានសិក្សាគំរោងបួង់ ។

កាលបើពិនិត្យឃើញថា សំណុំលិខិត និង ពត៌មានមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវតាមការណែនាំ (បញ្ញត្តិ) ហើយនោះមន្ត្រីចុះបញ្ជីនៅនាយកដ្ឋានសិក្សាគំរោងបួង់ត្រូវធ្វើការចុះបញ្ជីប្រកបអាជីវកម្ម ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នឹងប្រគល់ជូនវិញ្ញាបនប័ត្រ និង ប្រកាស ដែលអនុញ្ញាតអោយប្រកបអាជីវកម្មដល់អ្នកស្នើសុំក្នុងរយៈពេលយ៉ាងយូរមិនអោយហួសពី ១ខែ ដោយគិតចាប់ពីថ្ងៃទទួលពាក្យសុំ ដែលមានលក្ខណៈត្រឹមត្រូវ និង គ្រប់គ្រាន់ ។

III ប្រភេទ សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងបួង់ និង សាងសង់

១-១- សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងបួង់ ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និង សាខា

ក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចសេចក្តីប្រកាស លេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងបួង់ និង សាងសង់ ប៉ុន្តែត្រូវបន្ថែមនូវ :

១-លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគំរោងបួង់នៃសាមីដើមប្រទេស

២-ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស

៣-ឯកសារស្តីពីលក្ខន្តិកៈ របស់សហគ្រាស និង ក្រុមហ៊ុន របស់សាមីដើមប្រទេស ។

១-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានការិយាល័យតំណាង ឬ ទីភ្នាក់ងារ

និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ ចំណុច ក ខ ក្នុងប្រការ ៣ ប៉ុន្តែត្រូវបន្ថែមនូវ :

១-លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់របស់សាមីដើមប្រទេស

២-ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស

៣-ឯកសារស្តីពីលក្ខន្តិក: របស់សហគ្រាស និង ក្រុមហ៊ុនរបស់សាមីដើមប្រទេស ។

២-១ សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុនបានបែងចែកជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ ចំណុច ក ខ គ ក្នុងប្រការ២ ។

២-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានទីស្នាក់ារធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុនសាងសង់បានបែងចែកជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះ ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ចំណុច ក ខ គ ក្នុង ប្រការ ៣ ។

៣-១- រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់ គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ត្រង់ចំណុច ឃ១ ឃ២ ឃ៣ ឃ៤ ឃ៥ ក្នុងប្រការ២ ។

IV ទំរង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់

ទំរង់បែបបទសុំប្រកបអាជីវកម្ម មានលក្ខខ័ណ្ឌកំណត់ដូចប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់ គ្រង សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ប៉ុន្តែចំពោះ :

១- នាយកបច្ចេកទេស នាយកគំរោង និង អ្នកបច្ចេកទេសនៃសហគ្រាស ក្រុមហ៊ុនបរទេសដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និង សាខា ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសញ្ជាតិ បរទេស ឬ ខ្មែរ

២- ការអនុវត្តការងារសិក្សាគំរោងប្លង់ និង សាងសង់ត្រូវអនុវត្តតាមលិខិតបទដ្ឋានបច្ចេកទេសរបស់ព្រះរាជាណាចក្រកម្ពុជា ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន និងមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ និងតាមភារកិច្ចរៀងៗខ្លួនដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរ ជ.ន.ស.ស ខេត្ត ក្រុង
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីសម្រេច
ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចឹមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជន និងជនពិការ

ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខ: ០៣៩ សសរ

សេចក្តីសម្រេច
ស្តីពី
ការដាក់ឱ្យប្រើប្រាស់បណ្តោះអាសន្នស្ថាបត្យកម្ម
ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន សម្រាប់សាធារណជន និងជនពិការ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ **៧៧** អនក្រ.បក ចុះថ្ងៃទី **៧** ខែមិថុនា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

សម្រេច

ប្រការ ១.-

ដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន សម្រាប់សាធារណជន និងជនពិការ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្រការ ២.-

ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន សម្រាប់សាធារណជន និងជនពិការ ត្រូវបានអនុវត្តសម្រាប់ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត ដើម្បីធានាសោភណភាពសាធារណៈ និងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណជន និងជនពិការ។

ប្រការ ៣.-

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តប្តង់ស្ថាបត្យកម្មខាងលើនេះ ឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជាប្រចាំជូនគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ ៥.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៧កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៨

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

ជា សុផារ៉ា

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- **"ដើម្បីគោរពជូនជ្រាប"**
- ដូចប្រការ ៥ **"ដើម្បីមុខការ"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្លង់ស្តាប់ត្យកម្ម

គម្រោងសាងសង់ : ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន សម្រាប់សាធារណជនពិការ

ទីតាំងសាងសង់ : សម្រាប់ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត

រៀបចំដោយ : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សិក្សាដោយ : ឯកឧត្តមបណ្ឌិត ម៉ែន សុផល ស្ថាបត្យករ
ឯកឧត្តម ឃស់ ភោមណារ៉ាឌី វិស្វករ

គូរដោយ : លោក សាំង ចុតា ស្ថាបត្យករ
លោក សុខ ជលសី ស្ថាបត្យករ

ថ្ងៃព្រហស្បតិ៍ ខែផល្គុន ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្លង់ស្តាប់ត្យកម្ម

គម្រោងសាងសង់ : ចិញ្ចើមថ្នល់ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន
សម្រាប់សាធារណជននិងជនពិការ

ទីតាំងសាងសង់ : សម្រាប់ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត

រៀបចំដោយ : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ:០៣៩៩ ស.ស.ស
បានឃើញ និង ឯកភាព
សម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំ ច ស័ព្ទស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ..... ឆ្នាំ ២០១៨
អនុសេដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

ជា សុផារ៉ា

លេខ:០៣៩៣...ប.ន.ស/អ.កដនជ
បានឃើញ និង ពិនិត្យត្រឹមត្រូវ
គោរពជូនឯកឧត្តម អនុសេដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធាន
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់
ថ្ងៃអង្គារ៍ ៨រោច ខែជេស្ឋ ឆ្នាំ ច ស័ព្ទស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៨
រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃ អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

បណ្ឌិត ម៉ែន សុផល

ល.រ	ថ្ងៃ ខែ ឆ្នាំ	កំណែ	លេខ.....	ហត្ថលេខា	លេខ..... ឯនសស	ហត្ថលេខា	សិក្ខាឧទម្រាំង		ឈ្មោះ-មុខងារ	ហត្ថលេខា	ថ្ងៃ ខែ ឆ្នាំ	ក្លាយបន្ទប់ត្រស់តាមសិទ្ធិ	ប្លង់ចំណាំង : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់		
